

ឯកសារគម្ពីរព្រះត្រៃបិដកស្កានេនះ
ត្រូវបានថតចេញពីច្បាប់គម្ពីរព្រះត្រៃបិដកដប៉ុន ៗ

ឯកសារគម្ពីរព្រះត្រៃបិដកនេះ ចាប់ពីភាគ១ ដល់ ភាគ៥០
គឺជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងបុត្រធីតា,
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត-សាវង្ស ៗ និងទុកក្នុង
គេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ៗ

កែសម្រួលតាមកុំព្យូទ័រ តម្រូវឧបករណ៍អានអេឡិត្រូនិច
ដោយខ្ញុំព្រះករុណា ខ្ញុំបាទ ស្រុង-ចាន់ណា ៗ៕

www.5000-years.org

# ព្រះ
# ត្រៃបិដកបាឡី
# និង
# សេចក្ដីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
## សំយុត្តនិកាយ មហាវារវគ្គ
## ឯកាទសមភាគ
# ៣៩

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព.ស. ២៤៩៦

# សុត្តន្តបិដកេ

## សំយុត្តនិកាយស្ស មហាវារវគ្គោ

---

## ឯកាទសមោ ភាគោ

## ឈានសំយុត្តំ

[១] សាវត្ថី ។ តត្រ ខោ ។ ចត្តារោ មេ ភិក្ខវេ ឈានា ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរតិ សតោ ច សម្បជានោ សុខញ្ច កាយេន បដិសំវេទេតិ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិយំ ឈានំ ឧបសម្បជ្ជ

# សុត្តន្តបិដក

# សំយុត្តនិកាយ មហាវារវគ្គ

---

## ឯកាទសមភាគ

## ឈានសំយុត្ត

(១) ក្រុងសាវត្ថី ។ គង់ទីនោះឯង ព្រះដ៏មានព្រះភាគ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឈាននេះមាន ៤ ប្រការ ។ ឈាន ៤ ប្រការគឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ក៏ចូលកាន់បឋមជ្ឈានប្រកបដោយវិតក្កៈ នឹងវិចារៈ មានតែបីតិនឹងសុខដែលកើតអំពីសេចក្ដីស្ងប់ស្ងាត់ ភិក្ខុនោះព្រោះរម្ងាប់វិតក្កៈនឹងវិចារៈ ក៏ចូលកាន់ទុតិយជ្ឈាន ដែលកើតក្នុងសន្ដានជាទីផូរផង់ មានសភាពជាចិត្តខ្ពស់ឯក គ្មានវិតក្កៈនឹងវិចារៈ មានតែបីតិនឹងសុខ ដែលកើតអំពីសមាធិ ភិក្ខុនោះព្រោះប្រាសចាកបីតិផង ជាអ្នកប្រកបដោយឧបេក្ខាផង មានស្មារតីផង ដឹងខ្លួនសោយសុខដោយនាមកាយផង ព្រះអរិយៈទាំងឡាយ តែងសរសើរនូវបុគ្គលដែលបានតតិយជ្ឈាន ថាជាអ្នកប្រកបដោយឧបេក្ខា មានស្មារតី មានធម៌ជាគ្រឿងនៅជាសុខដូច្នេះ ព្រោះតតិយជ្ឈានឯណា ក៏ចូលកាន់តតិយជ្ឈាននោះ

## ឈានសំយុត្ត

វិហរតិ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធឹ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ ឈានាតិ ។

(២) សេយ្យថាបិ ភិក្ខវេ គង្គា នទី បាចីននិន្នា បាចីនបោណា បាចីនបព្ភារា ។ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ ចត្តារោ ឈានេ ភាវេន្តោ ចត្តារោ ឈានេ ពហុលីករោន្តោ និព្វាននិន្នោ ហោតិ និព្វានបោណោ និព្វានបព្ភារោ ។

(៣) កថញ្ច ភិក្ខវេ ភិក្ខុ ចត្តារោ ឈានេ ភាវេន្តោ ចត្តារោ ឈានេ ពហុលីករោន្តោ និព្វាននិន្នោ ហោតិ និព្វានបោណោ និព្វានបព្ភារោ ។ ឥធ ភិក្ខវេ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ វិតក្កវិចារានំ វូបសមា ។ បេ ។ ទុតិយំ ឈានំ ។ តតិយំ ឈានំ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ ឯវំ ខោ ភិក្ខវេ

ភិក្ខុនោះ ព្រោះលះបង់នូវសេចក្ដីសុខផង លះបង់នូវសេចក្ដីទុក្ខផង មាន សោមនស្សនឹងទោមនស្សអស់ទៅ ក្នុងកាលមុនផង ក៏ចូលកាន់ចតុត្ថ- ជ្ឈាន ជាធម្មជាតមានអារម្មណ៍មិនមែនជាទុក្ខ មិនមែនជាសុខ គឺជា ឧបេក្ខា មានសតិដ៏បរិសុទ្ធដោយឧបេក្ខា ។ ម្នាលភិក្ខុទាំងឡាយ ឈានមាន ៤ ប្រការនេះឯង ។

(២) ម្នាលភិក្ខុទាំងឡាយ ដូចទន្លេគង្គាមានទំនាបទៅខាងកើត មានជម្រាលទៅខាងកើត ឈមទៅខាងកើតយ៉ាងណាមិញ ។ ម្នាលភិក្ខុ ទាំងឡាយ កាលភិក្ខុចំរើននូវឈានទាំង ៤ ធ្វើឲ្យច្រើននូវឈានទាំង ៤ រមែងបង្អោនទៅរកព្រះនិព្វាន សសៀរទៅរកព្រះនិព្វាន ជម្រាលទៅ រកព្រះនិព្វាន ក៏យ៉ាងនោះឯង ។

(៣) ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុចំរើននូវឈានទាំង ៤ ធ្វើឲ្យ ច្រើននូវឈានទាំង ៤ រមែងបង្អោនទៅរកព្រះនិព្វាន សសៀរទៅរកព្រះ និព្វាន ជម្រាលទៅរកព្រះនិព្វាន តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយភិក្ខុ ក្នុងសាសនានេះ ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកអកុសល ធម៌ទាំងឡាយ ចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្កៈនឹងវិចារៈ មានបីតិនឹងសុខដែលកើតអំពីសេចក្ដីស្ងប់ស្ងាត់ ព្រោះរម្ងាប់វិតក្កៈវិចារៈ ។បេ។ ចូលកាន់ទុតិយជ្ឈាន ។ តតិយជ្ឈាន ។ ចតុត្ថជ្ឈាន ។ ម្នាលភិក្ខុទាំងឡាយ

ភិក្ខុ ចត្តារោ ឈានេ ភាវេន្តោ ចត្តារោ ឈានេ ពហុលីករោន្តោ និព្វាននិន្នោ ហោតិ និព្វានបោណោ និព្វានបព្ភារោតិ ។ (ឯវំ យាវ ឯសនា ចាតិ វិត្ថារេតព្វា) (១) ។

(៤) បញ្ចិមានិ ភិក្ខវេ ឧទ្ធម្ភាគិយានិ សញ្ញោជនានិ ។ កតមានិ បញ្ច ។ រូបរាគោ អរូបរាគោ មានោ ឧទ្ធច្ចំ អវិជ្ជា ។ ឥមានិ ខោ ភិក្ខវេ បញ្ចុទ្ធម្ភាគិយានិ សញ្ញោជនានិ ។

(៥) ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ឧទ្ធម្ភាគិយានំ សញ្ញោជនានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ចត្តារោ ឈានា ភាវេតព្វា ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ

១ ឱ ឈានសញ្ញុត្តស្ស បឋមសុត្តំ យថាបិ សតិប្បដ្ឋានំ តថាបិ វិត្ថារេតព្វំ ។

កាលភិក្ខុចំរើននូវឈានទាំង ៤ ធ្វើឲ្យច្រើននូវឈានទាំង ៤ រមែងបង្អោនទៅរកព្រះនិព្វាន សសៀរទៅរកព្រះនិព្វាន ជម្រាលទៅរកព្រះនិព្វាន យ៉ាងនេះឯង ។ (បាលីដកបដល់ឯសនាបណ្ឌិតគប្បីឲ្យពិស្តារយ៉ាងនេះផងចុះ )

(៤) ម្នាលភិក្ខុទាំងឡាយ ឧទ្ធម្ភាគិយសញ្ញោជនៈនេះមាន ៥ ប្រការ ។ ចុះឧទ្ធម្ភាគិយសញ្ញោជនៈ៥ប្រការតើអ្វីខ្លះ ។ គឺរូបរាគ ១ អរូបរាគ១មានះ ១ ឧទ្ធច្ចៈ១ អវិជ្ជា១ ។ ម្នាលភិក្ខុទាំងឡាយឧទ្ធម្ភាគិយសញ្ញោជនៈ មាន៥ប្រការនេះឯង ។

(៥) ម្នាលភិក្ខុទាំងឡាយ បុគ្គលគួរចំរើនឈាន ៤ ដើម្បីត្រាស់ដឹង ដើម្បីកំណត់ដឹង ដើម្បីក្ស័យអស់ទៅ ដើម្បីលះបង់នូវឧទ្ធម្ភាគិយសញ្ញោ-ជនៈ ៥ ប្រការនេះឯង ។ ឈាន ៤ ប្រការតើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងប់ស្ងាត់ចាកកាមទាំងឡាយស្ងប់ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ចូលកាន់បឋមជ្ឈានប្រកបដោយវិតក្កៈនិងវិចារៈមានតែបីតិនិងសុខដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ ព្រោះរម្ងាប់វិតក្កៈវិចារៈក៏ចូលកាន់ទុតិយជ្ឈាន ដែលកើតក្នុងសន្តានជាទីផូរផង់ មានសភាពជាចិត្តខ្ពស់ឯក

អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ។ តតិយំ ឈានំ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ឧទ្ធម្ភាគិយានំ សញ្ញោជនានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ឥមេ ចត្តារោ ឈានា ភាវេតព្វាតិ ។ (គង្គាបេយ្យាលោ ។ យថា មគ្គសំយុត្តំ វិត្ថារិតំ ឯវំ ឈានសំយុត្តំ វិត្ថារេតព្វំ យាវ ឯសនា បាលិ) ។

ឈានសំយុត្តំ និដ្ឋិតំ

## ឈានសំយុត្ត

គ្មានវិតក្កៈនឹងវិចារៈ មានតែបីតិនឹងសុខ ដែលកើតអំពីសមាធិ ។ តតិយជ្ឈាន ។ ចតុត្ថជ្ឈាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលគួរចំរើននូវឈានទាំង ៤ នេះ ដើម្បីត្រាស់ដឹង ដើម្បីកំណត់ដឹង ដើម្បីកិរិយាអស់ទៅ ដើម្បីលះបង់នូវឧទ្ធម្ភាគិយសញ្ញោជនៈទាំង ៥ ប្រការនេះឯង ។ (គង្គាបេយ្យាល ។ មគ្គសំយុត្តដែលយើងឲ្យពិស្តារហើយយ៉ាងណា ឈានសំយុត្ត បណ្ឌិតគប្បីឲ្យពិស្តារយ៉ាងនោះចុះ ដរាបដល់បាលីឯសនា) ។

ចប់ ឈានសំយុត្ត

# អានាបានសំយុត្តំ

## ឯកធម្មវគ្គោ បឋមោ

(៦) សាវត្ថី ។ តត្រ ខោ ។ បេ ។ ឯតទវោច ឯកធម្មោ ភិក្ខវេ ភាវិតោ ពហុលីកតោ មហប្ផលោ ហោតិ មហានិសំសោ ។ កតមោ ឯកធម្មោ ។ អានាបានស្សតិ ។

(៧) កថំ ភាវិតា ច ភិក្ខវេ អានាបានស្សតិ កថំ ពហុលីកតា មហប្ផលា ហោតិ មហានិសំសា ។ ឥធ ភិក្ខវេ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា និសីទតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា ។ សោ សតោវ អស្សសតិ សតោ(១) បស្សសតិ ទីឃំ វា អស្សសន្តោ ទីឃំ អស្សសាមីតិ បជានាតិ ទីឃំ វា បស្សសន្តោ ទីឃំ បស្សសាមីតិ បជានាតិ ។ រស្សំ វា អស្សសន្តោ រស្សំ អស្សសាមីតិ បជានាតិ រស្សំ វា បស្សសន្តោ រស្សំ បស្សសាមីតិ បជានាតិ ។ សព្វកាយប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ សព្វកាយប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ ។

---

១ ឧម. សតោវ ។

# អានាបានស្សតិសំយុត្ត

## ឯកធម្មវគ្គទី ១

(៦) ក្រុងសាវត្ថី ។ កន្លែងនោះឯង ។ បេ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ធម៌១ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ។ ធម៌១ តើដូចម្តេច ។ គឺអានាបានស្សតិ ។

(៧) ម្នាលភិក្ខុទាំងឡាយ ចុះអានាបានស្សតិ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ តើដូចម្តេច ទើបមានផលច្រើន មានអានិសង្សច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ នៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី អង្គុយពែនភ្នែនតាំងកាយឲ្យត្រង់ ផ្ចង់ស្មារតីឲ្យមានមុខឆ្ពោះទៅរក (កម្មដ្ឋាន) ។ ភិក្ខុនោះមានសតិដកដង្ហើមចេញ មានសតិដកដង្ហើមចូល កាលដកដង្ហើមចេញវែង ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញវែង ឬកាលដកដង្ហើមចូលវែង ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលវែង ។ កាលដកដង្ហើមចេញខ្លី ដឹងច្បាស់ថាអាត្មាអញដកដង្ហើមចេញខ្លី ឬកាលដកដង្ហើមចូលខ្លី ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលខ្លី ។ ភិក្ខុសិក្សាថា អាត្មាអញកំណត់ដឹងច្បាស់នូវកាយ គឺ ដកដង្ហើមចេញទាំងពួង នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញកំណត់ដឹងនូវកាយ គឺដកដង្ហើមចូលទាំងពួង នឹងដកដង្ហើមចូល ។

## ឯកធម្មវគ្គោ បឋមោ

បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ បស្សម្ភយំ កាយសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ ៗ បីតិប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ បីតិប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ ៗ សុខប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ សុខប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ ៗ ចិត្តសង្ខារប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ ចិត្តសង្ខារប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ ៗ បស្សម្ភយំ ចិត្តសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ បស្សម្ភយំ ចិត្តសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ ៗ ចិត្តប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ ចិត្តប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ ៗ អភិប្បមោទយំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ អភិប្បមោទយំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ ៗ សមាទហំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ សមាទហំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ ៗ វិមោចយំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ វិមោចយំ ចិត្តំ

សិក្សាថា អាត្មាអញរម្ងាប់កាយសង្ខារ គឺដកដង្ហើមចេញ នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញរម្ងាប់កាយសង្ខារ គឺដកដង្ហើមចូល នឹងដកដង្ហើមចូល ។ ភិក្ខុសិក្សាថា អាត្មាអញដឹងច្បាស់នូវបីតិ នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញដឹងច្បាស់នូវបីតិ នឹងដកដង្ហើមចូល ។ សិក្សាថា អាត្មាអញដឹងច្បាស់នូវសេចក្តីសុខ នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញដឹងច្បាស់នូវសេចក្តីសុខ នឹងដកដង្ហើមចូល ។ សិក្សាថា អាត្មាអញដឹងច្បាស់នូវចិត្តសង្ខារ គឺសញ្ញានឹងវេទនា នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញដឹងច្បាស់នូវចិត្តសង្ខារ គឺសញ្ញានឹងវេទនា នឹងដកដង្ហើមចូល ។ សិក្សាថា អាត្មាអញរម្ងាប់នូវចិត្តសង្ខារ នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញរម្ងាប់នូវចិត្តសង្ខារ នឹងដកដង្ហើមចូល ។ សិក្សាថា អាត្មាអញដឹងច្បាស់នូវចិត្ត នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញដឹងច្បាស់នូវចិត្ត នឹងដកដង្ហើមចូល ។ សិក្សាថា អាត្មាអញធ្វើចិត្តឲ្យរីករាយចំពោះ នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញធ្វើចិត្តឲ្យរីករាយចំពោះ នឹងដកដង្ហើមចូល ។ សិក្សាថា អាត្មាអញដម្កល់ចិត្តឲ្យស្មើ (ក្នុងអារម្មណ៍) នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញដម្កល់ចិត្តឲ្យស្មើ (ក្នុងអារម្មណ៍) នឹងដកដង្ហើមចូល សិក្សាថា អាត្មាអញដោះចិត្តឲ្យរួច (ចាកនីវរណធម៌ជាដើម) នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញដោះចិត្តឲ្យរួចស្រឡះ

## សុត្តន្តបិដកេ សំយុត្តនិកាយស្ស មហាវារវគ្គោ

បស្សសិស្សាមីតិ សិក្ខតិ ។ អនិច្ចានុបស្សី អស្សសិស្សាមីតិ សិក្ខតិ អនិច្ចានុបស្សី បស្សសិស្សាមីតិ សិក្ខតិ ។ វិរាគានុបស្សី អស្សសិស្សាមីតិ សិក្ខតិ វិរាគានុបស្សី បស្សសិស្សាមីតិ សិក្ខតិ ។ និរោធានុបស្សី អស្សសិស្សាមីតិ សិក្ខតិ និរោធានុបស្សី បស្សសិស្សាមីតិ សិក្ខតិ ។ បដិនិស្សគ្គានុបស្សី អស្សសិស្សាមីតិ សិក្ខតិ បដិនិស្សគ្គានុបស្សី បស្សសិស្សាមីតិ សិក្ខតិ ។ ឯវំ ភាវិតា ខោ ភិក្ខវេ អានាបានស្សតិ ឯវំ ពហុលីកតា មហប្ផលា ហោតិ មហានិសំសាតិ ។

(៨) អានាបានស្សតិ ភិក្ខវេ ភាវិតា ពហុលីកតា មហប្ផលា ហោតិ មហានិសំសា ។

(៩) កថំ ភាវិតា ច ភិក្ខវេ អានាបានស្សតិ កថំ ពហុលីកតា មហប្ផលា ហោតិ មហានិសំសា ។

នឹងដកដង្ហើមចូល ។ សិក្សាថា អាត្មាអញឃើញរឿយៗ នូវបញ្ចក្ខន្ធថាមិនទៀង នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញឃើញរឿយៗ នូវបញ្ចក្ខន្ធថាមិនទៀង នឹងដកដង្ហើមចូល ។ សិក្សាថា អាត្មាអញឃើញរឿយៗនូវធម៌ដែលធ្វើចិត្តឲ្យប្រាសចាកតម្រេក នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញឃើញរឿយ ៗ នូវធម៌ដែលធ្វើចិត្តឲ្យប្រាសចាកតម្រេក នឹងដកដង្ហើមចូល ។ សិក្សាថា អាត្មាអញឃើញរឿយៗនូវធម៌ជាគ្រឿងរំលត់ទុក្ខ នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញឃើញរឿយៗនូវធម៌ជាគ្រឿងរំលត់ទុក្ខ នឹងដកដង្ហើមចូល ។ សិក្សាថា អាត្មាអញឃើញរឿយៗ នូវធម៌ជាគ្រឿងលះចោលនូវកិលេស នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញឃើញរឿយៗ នូវធម៌ជាគ្រឿងលះចោលនូវកិលេស នឹងដកដង្ហើមចូល ។ ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិ ដែលបុគ្គលចំរើនហើយយ៉ាងនេះ ធ្វើឲ្យច្រើនហើយយ៉ាងនេះ រមែងមានផលច្រើន មានអានិសង្សច្រើន ។

[៨] ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ។

[៩] ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ រមែងមានផលច្រើន មានអានិសង្សច្រើន តើដូចម្តេចៗ

ឥធ ភិក្ខវេ ភិក្ខុ អានាបានស្សតិសហគតំ សតិសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ អានាបានស្សតិសហគតំ ធម្មវិចយសម្ពោជ្ឈង្គំ ។ វីរិយំ បីតិំ បស្សទ្ធិំ សមាធិំ អានាបានស្សតិសហគតំ ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ឯវំ ភាវិតា ខោ ភិក្ខវេ អានាបានស្សតិ ឯវំ ពហុលីកតា មហប្ផលា ហោតិ មហានិសំសាតិ ។

(១០) អានាបានស្សតិ ភិក្ខវេ ភាវិតា ពហុលីកតា មហប្ផលា ហោតិ មហានិសំសា ។

(១១) កថំ ភាវិតា ច ភិក្ខវេ អានាបានស្សតិ កថំ ពហុលីកតា មហប្ផលា ហោតិ មហានិសំសា ។ ឥធ ភិក្ខវេ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា និសីទតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា ។ សោ សតោវ អស្សសតិ សតោ បស្សសតិ ( វិតារេតព្វា យាវ បដិនិស្សគ្គានុបស្សី

## ឯកធម្មវគ្គទី ១

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បំរើនសតិសម្ពោជ្ឈង្គ ដែលប្រកបដោយអានាបានស្សតិ អាស្រ័យនូវវិវេក អាស្រ័យនូវវិរាគ អាស្រ័យនូវនិរោធ បង្អោនទៅដើម្បីការលះបង់ ។ ធម្មវិចយសម្ពោជ្ឈង្គ ដែលប្រកបដោយអានាបានស្សតិ ។ ភិក្ខុបំរើន វីរិយៈ បីតិ បស្សទ្ធិ សមាធិ ឧបេក្ខាសម្ពោជ្ឈង្គ ដែលប្រកបដោយអានាបានស្សតិ អាស្រ័យនូវវិវេក អាស្រ័យនូវវិរាគ អាស្រ័យនូវនិរោធ បង្អោនទៅដើម្បីការលះបង់ ។ ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិ ដែលបុគ្គលបំរើនហើយ យ៉ាងនេះ ធ្វើឲ្យច្រើនហើយ យ៉ាងនេះ រមែងមានផលច្រើន មានអានិសង្សច្រើន ។

(១០) ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិ ដែលបុគ្គលបំរើនហើយ ធ្វើឲ្យច្រើនហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ។

(១១) ម្នាលភិក្ខុទាំងឡាយ ចុះអានាបានស្សតិ ដែលបុគ្គលបំរើនហើយ ធ្វើឲ្យច្រើនហើយ ទើបមានផលច្រើន មានអានិសង្សច្រើន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ នៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី អង្គុយពែនភ្នែនតាំងកាយឲ្យត្រង់ ផ្ចង់ស្មារតីឲ្យមានមុខឆ្ពោះទៅរក (កម្មដ្ឋាន) ។ ភិក្ខុនោះមានស្មារតី ដកដង្ហើមចេញ មានស្មារតីដកដង្ហើមចូល (បណ្ឌិតគប្បីឲ្យពិស្តារហូតដល់ពាក្យថា ភិក្ខុសិក្សាថា រកត្មាអញឃើញរឿយ ៗ នូវធម៌ដែលសម្រាបលះ

អស្សសិស្សាមីតិ សិក្ខតិ បដិនិស្សគ្គានុបស្សី បស្ស-សិស្សាមីតិ សិក្ខតិ) ។ ឯវំ ភាវិតា ខោ ភិក្ខវេ អានាបានស្សតិ ឯវំ ពហុលីកតា មហប្ផលា ហោតិ មហានិសំសាតិ ។

(១២) អានាបានស្សតិ ភិក្ខវេ ភាវិតា ពហុលី-កតា មហប្ផលា ហោតិ មហានិសំសា ។

(១៣) កថំ ភាវិតា ច ភិក្ខវេ អានាបានស្សតិ កថំ ពហុលីកតា មហប្ផលា ហោតិ មហានិសំសា ។ ឥធ ភិក្ខវេ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា និសីទតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតិំ ឧបដ្ឋបេត្វា ។ សោ សតោ វ អស្សសតិ សតោ បស្សសតិ ។ (វិត្ថារោ យាវ បដិនិស្សគ្គានុបស្សី អស្សសិស្សាមីតិ សិក្ខតិ បដិនិស្សគ្គានុបស្សី បស្សសិស្សាមីតិ សិក្ខតិ) ។ ឯវំ ភាវិតា ខោ ភិក្ខវេ អានាបាន-ស្សតិ ឯវំ ពហុលីកតា មហប្ផលា ហោតិ មហានិសំសា ។

ចោលនូវកិលេស នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញ ឃើញ រឿយៗនូវធម៌សម្រាប់លះចោលនូវកិលេស នឹងដកដង្ហើមចូលផងចុះ) ។ ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិ ដែលបុគ្គលចំរើនហើយយ៉ាងនេះ រមែងមានផលច្រើន មានអានិសង្សច្រើន ។

(១២) ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ។

(១៣) ម្នាលភិក្ខុទាំងឡាយ ចុះអានាបានស្សតិ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ ទើបមានផលច្រើន មានអានិសង្សច្រើន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ នៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះដ៏ស្ងាត់ក្តី អង្គុយពែនភ្នែនតាំងកាយឲ្យត្រង់ ផ្ចង់ស្មារតីឲ្យមានមុខឆ្ពោះទៅរក (កម្មដ្ឋាន) ។ ភិក្ខុនោះ មានស្មារតី ដកដង្ហើមចេញ មានស្មារតី ដកដង្ហើមចូល ។ (សេចក្តីពិស្តារមានរហូតដល់ពាក្យថា ភិក្ខុសិក្សាថា អាត្មាអញឃើញរឿយៗនូវធម៌សម្រាប់លះបង់កិលេសចោល នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញឃើញរឿយៗនូវធម៌សម្រាប់លះបង់កិលេសចោល នឹងដកដង្ហើមចូលផងចុះ) ។ ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិ ដែលបុគ្គលចំរើនហើយយ៉ាងនេះ ធ្វើឲ្យច្រើនហើយយ៉ាងនេះ រមែងមានផលច្រើន មានអានិសង្សច្រើន ។

## ឯកធម្មវគ្គោ បឋមោ

(១៤) ឯវំ ភាវិតាយ ខោ ភិក្ខវេ អានាបានស្សតិយា ឯវំ ពហុលីកតាយ ទ្វិន្នំ ផលានំ អញ្ញតរំ ផលំ បាដិកង្ខំ ទិដ្ឋេវ ធម្មេ អញ្ញា សតិ វា ឧបាទិសេសេ អនាគាមិតាតិ ។

(១៥) អានាបានស្សតិ ភិក្ខវេ ភាវិតា ពហុលីកតា មហប្ផលា ហោតិ មហានិសំសា ។

(១៦) កថំ ភាវិតា ច ភិក្ខវេ អានាបានស្សតិ កថំ ពហុលីកតា មហប្ផលា ហោតិ មហានិសំសា ។ ឥធ ភិក្ខវេ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា និសីទតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា ។ សោ សតោ វ អស្សសតិ សតោ បស្សសតិ ។ (វិត្ថារេ យាវ បដិនិស្សគ្គានុបស្សី អស្សសិស្សាមីតិ សិក្ខតិ បដិនិស្សគ្គានុបស្សី បស្សសិស្សាមីតិ សិក្ខតិ) ។

## ឯកធម្មវគ្គទី ១

(១៤) ម្នាលភិក្ខុទាំងឡាយ កាលបើអានាបានស្សតិ ដែលបុគ្គលបានចំរើនយ៉ាងនេះហើយ បានធ្វើឲ្យច្រើនយ៉ាងនេះហើយ បណ្តាផលទាំង ២ បុគ្គលនោះរមែងបានផលណាមួយ គឺអរហត្តផល ក្នុងបច្ចុប្បន្ននេះ ឬ បើមានឧបាទានក្ខន្ធសល់នៅឡើយ នឹងបានសម្រេចនូវភាពជាអនាគាមិបុគ្គល ។

(១៥) ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ។

(១៦) ម្នាលភិក្ខុទាំងឡាយ ចុះអានាបានស្សតិ ដែលបុគ្គលបានចំរើនហើយ បានធ្វើឲ្យច្រើនហើយ រមែងមានផលច្រើន មានអានិសង្សច្រើន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ នៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី អង្គុយពែនភ្នែន តាំងកាយឲ្យត្រង់ ផ្ចង់ស្មារតី ឲ្យមានមុខឆ្ពោះទៅរក (កម្មដ្ឋាន) ។ ភិក្ខុនោះមានស្មារតីដកដង្ហើមចេញ មានស្មារតីដកដង្ហើមចូល ។ (សេចក្តីពិស្តារមានហូតដល់ពាក្យថា ភិក្ខុសិក្សាថា អាត្មាអញឃើញរឿយ ៗ នូវធម៌សម្រាប់លះកិលេសចោល នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញឃើញរឿយៗ នូវធម៌សម្រាប់លះកិលេសចោល នឹងដកដង្ហើមចូលផងចុះ) ។

ឯវំ ភាវិតា ខោ ភិក្ខវេ អានាបានស្សតិ ឯវំ ពហុលីកតា មហប្ផលា ហោតិ មហានិសំសា ។

(១៧) ឯវំ ភាវិតាយ ខោ ភិក្ខវេ អានាបានស្សតិយា ឯវំ ពហុលីកតាយ សត្ត ផលា សត្តានិសំសា បាដិកង្ខា ។ កតមេ សត្ត ផលា សត្តានិសំសា ។ ទិដ្ឋេវ ធម្មេ បដិកច្ច អញ្ញំ អារាធេតិ នោ ចេ ទិដ្ឋេវ ធម្មេ បដិកច្ច អញ្ញំ អារាធេតិ អថ មរណកាលេ អញ្ញំ អារាធេតិ នោ ចេ ទិដ្ឋេវ ធម្មេ បដិកច្ច អញ្ញំ អារាធេតិ នោ ចេ មរណកាលេ អញ្ញំ អារាធេតិ ។ អថ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា អន្តរាបរិនិព្វាយី ហោតិ ឧបហច្ចបរិនិព្វាយី ហោតិ អសង្ខារបរិនិព្វាយី ហោតិ សសង្ខារបរិនិព្វាយី ហោតិ ឧទ្ធំសោតោ ហោតិ អកនិដ្ឋគាមី ។ ឯវំ ភាវិតាយ ខោ ភិក្ខវេ អានាបានស្សតិយា ឯវំ ពហុលីកតាយ ឥមេ សត្ត ផលា សត្តានិសំសា បាដិកង្ខាតិ ។

(១៨) សាវត្ថិយំ ។ តត្រ ខោ ភគវា ។បេ។ ឯតទវោច ភាវេថ នោ តុម្ហេ ភិក្ខវេ អានាបានស្សតិន្តិ ។

ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិ ដែលបុគ្គលបានចំរើនហើយយ៉ាងនេះ ធ្វើឲ្យច្រើនហើយយ៉ាងនេះ រមែងមានផលច្រើន មានអានិសង្សច្រើន ។

(១៧) ម្នាលភិក្ខុទាំងឡាយ កាលបើអានាបានស្សតិ ដែលបុគ្គលចំរើនហើយយ៉ាងនេះ ធ្វើឲ្យច្រើនហើយយ៉ាងនេះ រមែងបានសម្រេចផល ៧ ប្រការ នឹងអានិសង្ស ៧ ប្រការ ។ ផល ៧ ប្រការ អានិសង្ស ៧ ប្រការ តើដូចម្តេច ។ ក្នុងបច្ចុប្បន្ននេះ ភិក្ខុនោះបានសម្រេចអរហត្តផលជាមុន បើក្នុងបច្ចុប្បន្ននេះមិនបានសម្រេចអរហត្តផលជាមុនទេ នឹងបានសម្រេចអរហត្តផលក្នុងកាលដែលស្លាប់ បើក្នុងបច្ចុប្បន្ននេះមិនបានសម្រេចអរហត្តផលជាមុន ទាំងមិនបានសម្រេចអរហត្តផលក្នុងកាលដែលស្លាប់ទេ ។ បុគ្គលនោះ ជាអន្តរាបរិនិព្វាយី ជាឧបហច្ចបរិនិព្វាយី ជាអសង្ខារបរិនិព្វាយី ជាសសង្ខារបរិនិព្វាយី ជាឧទ្ធំសោតអកនិដ្ឋគាមី ព្រោះកិរិយាអស់ទៅនៃឱរម្ភាគិយសំយោជនៈ ៥ ប្រការដោយពិត ។ ម្នាលភិក្ខុទាំងឡាយ កាលបើអានាបានស្សតិ ដែលបុគ្គលបានចំរើនយ៉ាងនេះ បានធ្វើឲ្យច្រើនយ៉ាងនេះហើយ បុគ្គលនោះនឹងបានទទួលផល ៧ ប្រការនឹងអានិសង្ស ៧ ប្រការនេះឯង ។

(១៨) ក្នុងទីនេះឯង ព្រះដ៏មានព្រះភាគ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចំរើនអានាបានស្សតិឬទេ ។

## ឯកធម្មវគ្គោ បឋមោ

(១៩) ឯវំ វុត្តេ អាយស្មា អរិដ្ឋោ ភគវន្តំ ឯតទវោច អហំ ខោ ភន្តេ ភាវេមិ អានាបានស្សតិន្តិ ។ យថាកថំ បន ត្វំ អរិដ្ឋ ភាវេសិ អានាបានស្សតិន្តិ ។

(២០) អតីតេសុ មេ ភន្តេ កាមេសុ កាមច្ឆន្ទោ បហីនោ អនាគតេសុ មេ កាមេសុ កាមច្ឆន្ទោ វិគតោ អជ្ឈត្តំ ពហិទ្ធា ច មេ ធម្មេសុ បដិឃសញ្ញា សុប្បដិវិនីតា សោ សតោវ អស្សសិស្សាមិ សតោ បស្សសិស្សាមិ ។ ឯវំ ខ្វាហំ ភន្តេ ភាវេមិ អានាបានស្សតិន្តិ ។

(២១) អត្ថេសា អរិដ្ឋ អានាបានស្សតិ នេសា នត្ថីតិ វទាមិ ។ អបិច អរិដ្ឋ យថា អានាបានស្សតិ វិត្ថារេន បរិបុណ្ណា ហោតិ តំ សុណាហិ សាធុកំ មនសិការោហិ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អរិដ្ឋោ ភគវតោ បច្ចស្សោសិ ។ ភគវា ឯតទវោច កថញ្ច អរិដ្ឋ អានាបានស្សតិ វិត្ថារេន បរិបុណ្ណា ហោតិ ។ ឥធ អរិដ្ឋ ភិក្ខុ

## ឯកធម្មវគ្គទី ១

[ ១៩ ] កាលព្រះដ៏មានព្រះភាគត្រាស់យ៉ាងនេះហើយ ព្រះអរិដ្ឋដ៏មានអាយុ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដោយពាក្យដូច្នេះ ថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គចំរើនអានាបានស្សតិ ។ ម្នាលអរិដ្ឋ ចុះអ្នកចំរើនអានាបានស្សតិ ដូចម្តេចទៅ ។

[ ២០ ] បពិត្រព្រះអង្គដ៏ចំរើន កាមច្ឆន្ទៈក្នុងកាមទាំងឡាយ ជាអតីត ខ្ញុំព្រះអង្គបានលះបង់ហើយ កាមច្ឆន្ទៈក្នុងកាមទាំងឡាយ ជាអនាគតខ្ញុំព្រះអង្គបានប្រាសចេញហើយ បដិឃសញ្ញាក្នុងធម៌ទាំងឡាយ ជាខាងក្នុងក្តី ខាងក្រៅក្តី ខ្ញុំព្រះអង្គបានកំចាត់ចោលហើយដោយប្រពៃ ខ្ញុំព្រះអង្គនោះ មានសតិដកដង្ហើមចេញ មានសតិដកដង្ហើមចូលៗ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គចំរើនអានាបានស្សតិ យ៉ាងនេះឯង ។

[ ២១ ] ម្នាលអរិដ្ឋ អានាបានស្សតិនុ៎ះមានមែន តថាគតមិនមែនពោលថា អានាបានស្សតិនុ៎ះមិនមានដូច្នេះទេ ។ ម្នាលអរិដ្ឋ ប៉ុន្តែអានាបានស្សតិ ដែលពេញបរិបូណ៌ដោយពិស្តារបែបណា ចូរអ្នកស្តាប់បែបនោះ យកចិត្តទុកដាក់ឲ្យប្រពៃចុះ តថាគតនឹងសំដែង ។ ព្រះអរិដ្ឋដ៏មានអាយុ ក៏ទទួលព្រះពុទ្ធដីការបស់ព្រះដ៏មានព្រះភាគថា ករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលអរិដ្ឋ ចុះអានាបានស្សតិដែលបរិបូណ៌ដោយសេចក្តីពិស្តារតើដូចម្តេច ។ ម្នាលអរិដ្ឋ ភិក្ខុក្នុងសាសនានេះ

អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា និសីទតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា ។ សោ សតោវ អស្សសតិ សតោ បស្សសតិ ទីឃំ វា អស្សសន្តោ ទីឃំ អស្សសាមីតិ បជានាតិ ។ បេ ។ បដិនិស្សគ្គានុបស្សី អស្សសិស្សាមីតិ សិក្ខតិ បដិនិស្សគ្គានុបស្សី បស្សសិស្សាមីតិ សិក្ខតិ ។ ឯវំ ខោ អរិដ្ឋ អានាបានស្សតិ វិត្ថារេន បរិបុណ្ណា ហោតីតិ ។

(២២) សាវត្ថី ។ តេន ខោ បន សមយេន អាយស្មា មហាកប្បិនោ ភគវតោ អវិទូរេ និសិន្នោ ហោតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា ។

(២៣) អទ្ទសា ខោ ភគវា អាយស្មន្តំ មហាកប្បិនំ អវិទូរេ និសិន្នំ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា ទិស្វាន ភិក្ខូ អាមន្តេសិ បស្សថ នោ តុម្ហេ ភិក្ខវេ ឯតស្ស ភិក្ខុនោ កាយស្ស ឥញ្ជិតត្តំ វា ផន្ទិតត្តំ វាតិ ។

នៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី អង្គុយពែនភ្នែន តាំងកាយឲ្យត្រង់ ផ្ចង់ស្មារតី ឲ្យមានមុខឆ្ពោះទៅរក (កម្មដ្ឋាន) ។ ភិក្ខុនោះមានសតិដកដង្ហើមចេញ មានសតិដកដង្ហើមចូល កាលដកដង្ហើមចេញវែង ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញវែង ។បេ។ សិក្សាថា អាត្មាអញឃើញរឿយៗ នូវធម៌សម្រាប់លះកិលេសចោល នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញឃើញរឿយៗ នូវធម៌សម្រាប់លះកិលេសចោល នឹងដកដង្ហើមចូល ។ ម្នាលអរិដ្ឋ អានាបានស្សតិ ពេញបរិបូណ៌ ដោយសេចក្តីពិស្តារ យ៉ាងនេះឯង ។

[២២] គ្រានោះឯង ។ សម័យនោះឯង ព្រះមហាកប្បិនដ៏មានអាយុ អង្គុយពែនភ្នែន តាំងកាយឲ្យត្រង់ ផ្ចង់ស្មារតី ឲ្យមានមុខឆ្ពោះទៅរក (កម្មដ្ឋាន) ក្នុងទីជិតព្រះដ៏មានព្រះភាគ ។

[២៣] ព្រះដ៏មានព្រះភាគ បានឃើញមហាកប្បិន ដ៏មានអាយុ កំពុងអង្គុយពែនភ្នែន តាំងកាយឲ្យត្រង់ ផ្ចង់ស្មារតី ឲ្យមានមុខឆ្ពោះទៅរក (កម្មដ្ឋាន) ក្នុងទីមិនឆ្ងាយ (អំពីព្រះអង្គ) លុះឃើញហើយ ទើបត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញសេចក្តីញាប់ញ័រ ឬសេចក្តីអន្ទះអន្ទែងកាយ របស់ភិក្ខុនោះឬទេ ។

(២៤) យទាបិ មយំ ភន្តេ តំ អាយស្មន្តំ បស្សាម សង្ឃមជ្ឈេ វា និសិន្នំ ឯកំ វា រហោ និសិន្នំ តទាបិ មយំ តស្ស អាយស្មតោ ន បស្សាម កាយស្ស ឥញ្ជិតត្តំ វា ផន្ទិតត្តំ វាតិ ។

(២៥) យស្ស ភិក្ខវេ សមាធិស្ស ភាវិតត្តា ពហុលីកតត្តា នេវ កាយស្ស ឥញ្ជិតត្តំ វា ហោតិ ផន្ទិតត្តំ វា ន ចិត្តស្ស ឥញ្ជិតត្តំ វា ហោតិ ផន្ទិតត្តំ វា តស្ស សោ ភិក្ខវេ ភិក្ខុ សមាធិស្ស និកាមលាភី អកិច្ឆលាភី អកសិរលាភី ។

(២៦) កតមស្ស ច ភិក្ខវេ សមាធិស្ស ភាវិតត្តា ពហុលីកតត្តា នេវ កាយស្ស ឥញ្ជិតត្តំ វា ហោតិ ផន្ទិតត្តំ វា ន ចិត្តស្ស ឥញ្ជិតត្តំ វា ហោតិ ផន្ទិតត្តំ វា ។ អានាបានស្សតិសមាធិស្ស ភិក្ខវេ ភាវិតត្តា ពហុលីកតត្តា នេវ កាយស្ស ឥញ្ជិតត្តំ វា ហោតិ ផន្ទិតត្តំ វា ន ចិត្តស្ស ឥញ្ជិតត្តំ វា ហោតិ ផន្ទិតត្តំ វា ។

## ឯកធម្មវគ្គទី ១

(២៤) ភិក្ខុទាំងឡាយក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន កាលណាយើងខ្ញុំព្រះអង្គឃើញលោកដ៏មានអាយុនោះ កំពុងអង្គុយកណ្ដាលជំនុំសង្ឃក្ដី អង្គុយស្ងាត់តែម្នាក់ឯងក្ដី ក្នុងកាលនោះ យើងខ្ញុំព្រះអង្គមិនបានឃើញ លោកដ៏មានអាយុនោះ មានកាយញាប់ញ័រ ឬអន្ទះអន្ទែងទេ ។

(២៥) ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាបានចំរើន បានធ្វើឲ្យច្រើននូវសមាធិហើយ រមែងមានកាយមិនញាប់ញ័រ ឬមិនអន្ទះអន្ទែង មានចិត្តមិនញាប់ញ័រ ឬមិនអន្ទះអន្ទែង ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះរមែងបាននូវសមាធិដោយងាយ បានមិនលំបាក បានមិនក្រឡើយ ។

(២៦) ម្នាលភិក្ខុទាំងឡាយ ចុះសមាធិដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយតើដូចម្ដេច រមែងមានកាយមិនញាប់ញ័រ ឬមិនអន្ទះអន្ទែង មានចិត្តមិនញាប់ញ័រ ឬមិនអន្ទះអន្ទែង ។ ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិសមាធិ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ រមែងមានកាយមិនញាប់ញ័រ ឬមិនអន្ទះអន្ទែង មានចិត្តមិនញាប់ញ័រ ឬមិនអន្ទះអន្ទែងឡើយ ។

[២៧] កថំ ភាវិតេ ខោ ភិក្ខវេ អានាបានស្សតិសមាធិម្ហិ កថំ ពហុលីកតេ នេវ កាយស្ស ឥញ្ជិតត្តំ វា ហោតិ ផន្ទិតត្តំ វា ន ចិត្តស្ស ឥញ្ជិតត្តំ វា ហោតិ ផន្ទិតត្តំ វា ។ ឥធ ភិក្ខវេ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា និសីទតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា ។ សោ សតោ វ អស្សសតិ សតោ បស្សសតិ (វិត្ថារេតព្វំ យាវ បដិនិស្សគ្គានុបស្សី អស្សសិស្សាមីតិ សិក្ខតិ បដិនិស្សគ្គានុបស្សី បស្សសិស្សាមីតិ សិក្ខតិ) ។ ឯវំ ភាវិតេ ខោ ភិក្ខវេ អានាបានស្សតិសមាធិម្ហិ ឯវំ ពហុលីកតេ នេវ កាយស្ស ឥញ្ជិតត្តំ វា ហោតិ ផន្ទិតត្តំ វា ន ចិត្តស្ស ឥញ្ជិតត្តំ វា ហោតិ ផន្ទិតត្តំ វាតិ ។

[២៨] អានាបានស្សតិសមាធិ ភិក្ខវេ ភាវិតោ ពហុលីកតោ មហប្ផលោ ហោតិ មហានិសំសោ ។

[២៧] ម្នាលភិក្ខុទាំងឡាយ កាលបើអានាបានស្សតិសមាធិ ដែលបុគ្គលបានចំរើនហើយ បានធ្វើឲ្យច្រើនហើយតើដូចម្តេច ទើបបុគ្គលនោះមានកាយមិនញាប់ញ័រ ឬមានកាយមិនអន្ទះអន្ទែង មានចិត្តមិនញាប់ញ័រ ឬមានចិត្តមិនអន្ទះអន្ទែង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ នៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី អង្គុយពែនភ្នែនតាំងកាយឲ្យត្រង់ ផ្ចង់ស្មារតី ឲ្យមានមុខឆ្ពោះទៅរក(កម្មដ្ឋាន) ។ ភិក្ខុនោះមានសតិដកដង្ហើមចេញ មានសតិដកដង្ហើមចូល (បណ្ឌិតគប្បីឲ្យពិស្តារហូតដល់ពាក្យថា ភិក្ខុសិក្សាថា អាត្មាអញឃើញរឿយ ៗ នូវធម៌សម្រាប់លះបង់កិលេសចោល នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញឃើញរឿយ ៗ នូវធម៌សម្រាប់លះកិលេសចោល នឹងដកដង្ហើមចូលផងចុះ) ។ ម្នាលភិក្ខុទាំងឡាយ កាលបើ អានាបានស្សតិសមាធិ ដែលបុគ្គលបានចំរើនយ៉ាងនេះហើយ បានធ្វើឲ្យច្រើនយ៉ាងនេះហើយ រមែងមានកាយមិនញាប់ញ័រ ឬមានកាយមិនអន្ទះអន្ទែង មានចិត្តមិនញាប់ញ័រ ឬមានចិត្តមិនអន្ទះអន្ទែង ។

[២៨] ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិសមាធិ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ។

(២៩) កថំ ភាវិតោ ច ភិក្ខវេ អានាបានស្សតិសមាធិ កថំ ពហុលីកតោ មហប្ផលោ ហោតិ មហានិសំសោ ។ ឥធ ភិក្ខវេ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា និសីទតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា ។ សោ សតោវ អស្សសតិ សតោ បស្សសតិ ។ ទីឃំ វា អស្សសន្តោ ទីឃំ អស្សសាមីតិ បជានាតិ (វិត្ថារេតព្វា យាវ បដិនិស្សគ្គានុបស្សី អស្សសិស្សាមីតិ សិក្ខតិ បដិនិស្សគ្គានុបស្សី បស្សសិស្សាមីតិ សិក្ខតិ) ។ ឯវំ ភាវិតោ ខោ ភិក្ខវេ អានាបានស្សតិសមាធិ ឯវំ ពហុលីកតោ មហប្ផលោ ហោតិ មហានិសំសោ ។

(៣០) អហម្បិ សុទំ ភិក្ខវេ បុព្វេវ សម្ពោធា អនភិសម្ពុទ្ធោ ពោធិសត្តោវ សមានោ ឥមិនា វិហារេន ពហុលំ វិហរាមិ ។ តស្ស មយ្ហំ ភិក្ខវេ ឥមិនា វិហារេន ពហុលំ វិហរតោ

## ឯកធម្មវគ្គ

[២៩] ម្នាលភិក្ខុទាំងឡាយ ចុះអានាបានស្សតិសមាធិ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ ទើបមានផលច្រើន មានអានិសង្សច្រើន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ នៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី អង្គុយពែនភ្នែន តាំងកាយឲ្យត្រង់ ផ្ចង់ស្មារតី ឲ្យមានមុខឆ្ពោះទៅរក (កម្មដ្ឋាន) ។ ភិក្ខុនោះ មានសតិដកដង្ហើមចេញ មានសតិដកដង្ហើមចូល ។ កាលដកដង្ហើមចេញវែង ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញវែង (បណ្ឌិតគប្បីឲ្យពិស្តារហេតុដល់ពាក្យថា ភិក្ខុសិក្សាថា អាត្មាអញឃើញរឿយ ៗ នូវធម៌សម្រាប់លះកិលេសចោលនឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញឃើញរឿយ ៗ នូវធម៌សម្រាប់លះកិលេសចោល នឹងដកដង្ហើមចូលផងចុះ) ។ ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិសមាធិ ដែលបុគ្គលចំរើនហើយយ៉ាងនេះ ធ្វើឲ្យច្រើនហើយយ៉ាងនេះ រមែងមានផលច្រើន មានអានិសង្សច្រើន ។

[៣០] ម្នាលភិក្ខុទាំងឡាយ ក៏កាលមុនដែលតថាគត នៅជាពោធិសត្វ មិនទាន់បានត្រាស់ដឹងនូវសម្ពោធិញ្ញាណនៅឡើយ តែងសម្រេចសម្រាន្តនៅដោយច្រើន ដោយវិហារធម៌នេះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះ កំពុងសម្រេចសម្រាន្តនៅដោយច្រើន ដោយវិហារធម៌នេះ

នេវ កាយោ កិលមតិ ន ចក្ខូនិ អនុបាទាយ ច មេ អាសវេហិ ចិត្តំ វិមុច្ចតិ(១) ។

(៣១) តស្មាតិហ ភិក្ខវេ ភិក្ខុ ចេបិ អាកង្ខេយ្យ នេវ មេ កាយោបិ កិលមេយ្យ ន ចក្ខូនិ អនុបាទាយ ច មេ អាសវេហិ ចិត្តំ វិមុច្ចេយ្យាតិ អយមេវ អានាបានស្សតិសមាធិ សាធុកំ មនសិការាតព្វោ ។

(៣២) តស្មាតិហ ភិក្ខវេ ភិក្ខុ ចេបិ អាកង្ខេយ្យ យេបិ មេ គេហសិតា សរសង្កប្បា តេ បហីយេយ្យុន្តិ(២) អយមេវ អានាបានស្សតិសមាធិ សាធុកំ មនសិការាតព្វោ ។

(៣៣) តស្មាតិហ ភិក្ខវេ ភិក្ខុ ចេបិ អាកង្ខេយ្យ អប្បដិក្កូលេ បដិក្កូលសញ្ញី វិហរេយ្យន្តិ អយមេវ អានាបានស្សតិសមាធិ សាធុកំ មនសិការាតព្វោ ។

---

១ ម- វិមុច្ចិ ។ ២ ឱ. បហីហេយ្យុន្តិ ។

កាយមិនលំបាក ចក្ខុទាំងឡាយក៏មិនលំបាក ទាំងចិត្តរបស់តថាគតក៏រួចចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ។

(៣១) ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ប្រសិនបើភិក្ខុក្នុងសាសនានេះ ប៉ុនប៉ងថា កាយរបស់អាត្មាអញ កុំលំបាក ចក្ខុទាំងឡាយក៏កុំលំបាក ទាំងចិត្តរបស់អាត្មាអញក៏រួចស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ អានាបានស្សតិសមាធិនេះឯង ភិក្ខុគួរយកចិត្តទុកដាក់ដោយប្រពៃចុះ ។

(៣២) ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ប្រសិនបើភិក្ខុក្នុងសាសនានេះ ប៉ុនប៉ងថា សេចក្តីត្រិះរិះ ដោយសេចក្តីវិតកអាស្រ័យនូវកាមគុណដែលជារបស់អាត្មាអញ សេចក្តីត្រិះរិះដោយសេចក្តីវិតកនេះអាត្មាអញគួរលះបង់ចោល ព្រោះហេតុនោះ អានាបានស្សតិសមាធិនេះឯងភិក្ខុគួរយកចិត្តទុកដាក់ដោយប្រពៃចុះ ។

(៣៣) ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ប្រសិនបើភិក្ខុក្នុងសាសនានេះ ប៉ុនប៉ងថា អាត្មាអញគួរសំគាល់ក្នុងរបស់ដែលមិនមែនជាបដិកូលថាជាបដិកូល អានាបានស្សតិសមាធិនេះឯង ភិក្ខុគួរយកចិត្តទុកដាក់ដោយប្រពៃចុះ ។

## ឯកធម្មវគ្គោ បឋមោ

(៣៤) តស្មាតិហ ភិក្ខវេ ភិក្ខុ ចេបិ អាកង្ខេយ្យ បដិក្កូលេ អប្បដិក្កូលសញ្ញី វិហរេយ្យន្តិ អយមេវ អានាបានស្សតិសមាធិ សាធុកំ មនសិកាតព្វោ ។

(៣៥) តស្មាតិហ ភិក្ខវេ ភិក្ខុ ចេបិ អាកង្ខេយ្យ អប្បដិក្កូលេ ច បដិក្កូលេ ច បដិក្កូលសញ្ញី វិហរេយ្យន្តិ អយមេវ អានាបានស្សតិសមាធិ សាធុកំ មនសិកាតព្វោ ។

(៣៦) តស្មាតិហ ភិក្ខវេ ភិក្ខុ ចេបិ អាកង្ខេយ្យ បដិក្កូលេ ច អប្បដិក្កូលេ ច អប្បដិក្កូលសញ្ញី វិហរេយ្យន្តិ អយមេវ អានាបានស្សតិសមាធិ សាធុកំ មនសិកាតព្វោ ។

(៣៧) តស្មាតិហ ភិក្ខវេ ភិក្ខុ ចេបិ អាកង្ខេយ្យ អប្បដិក្កូលញ្ច បដិក្កូលញ្ច តទុភយំ អភិនិវជ្ជេត្វា ឧបេក្ខកោ វិហរេយ្យំ សតោ សម្បជានោតិ អយមេវ អានាបានស្សតិសមាធិ សាធុកំ មនសិកាតព្វោ ។

## ឯកធម្មវគ្គ ទី ១

(៣៤) ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ប្រសិនបើភិក្ខុក្នុងសាសនានេះ ប៉ុនប៉ងថា អាត្មាអញគប្បីសំគាល់ក្នុងរបស់ជាបដិកូលថាមិនមែនជាបដិកូល អានាបានស្សតិសមាធិនេះឯង ភិក្ខុគួរយកចិត្តទុកដាក់ដោយប្រពៃចុះ ។

(៣៥) ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ប្រសិនបើភិក្ខុក្នុងសាសនានេះ ប៉ុនប៉ងថា អាត្មាអញគួរសំគាល់ក្នុងរបស់មិនមែនជាបដិកូលផង ក្នុងរបស់ជាបដិកូលផង ថាជារបស់បដិកូល អានាបានស្សតិសមាធិនេះឯង ភិក្ខុគួរយកចិត្តទុកដាក់ដោយប្រពៃចុះ ។

(៣៦) ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ប្រសិនបើភិក្ខុក្នុងសាសនានេះ ប៉ុនប៉ងថា អាត្មាអញគួរសំគាល់ក្នុងរបស់ជាបដិកូលផង មិនមែនជាបដិកូលផង ថាជារបស់មិនមែនជាបដិកូល អានាបានស្សតិសមាធិនេះឯង ភិក្ខុគួរយកចិត្តទុកដាក់ដោយប្រពៃចុះ ។

(៣៧) ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះប្រសិនបើភិក្ខុក្នុងសាសនានេះ ប៉ុនប៉ងថា អាត្មាអញគប្បីវៀរនូវរបស់ទាំង២ គឺរបស់មិនមែនជាបដិកូល១ របស់ជាបដិកូល១ ជាអ្នកព្រងើយកន្តើយ ជាអ្នកមានស្មារតីដឹងខ្លួន អានាបានស្សតិសមាធិនេះឯង ភិក្ខុគួរយកចិត្តទុកដាក់ដោយប្រពៃចុះ ។

(៣៨) តស្មាតិហ ភិក្ខវេ ភិក្ខុ ចេបិ អាកង្ខេយ្យ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរេយ្យន្តិ អយមេវ អានាបានស្សតិសមាធិ សាធុកំ មនសិកាតព្វោ ។

(៣៩) តស្មាតិហ ភិក្ខវេ ភិក្ខុ ចេបិ អាកង្ខេយ្យ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរេយ្យន្តិ អយមេវ អានាបានស្សតិសមាធិ សាធុកំ មនសិកាតព្វោ ។

(៤០) តស្មាតិហ ភិក្ខវេ ភិក្ខុ ចេបិ អាកង្ខេយ្យ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរេយ្យំ សតោ ច សម្បជានោ សុខញ្ច កាយេន បដិសំវេទេយ្យំ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិយំ ឈានំ ឧបសម្បជ្ជ វិហរេយ្យន្តិ អយមេវ អានាបានស្សតិសមាធិ សាធុកំ មនសិកាតព្វោ ។

[៣៨] ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ប្រសិនបើភិក្ខុក្នុងសាសនានេះ ប៉ុនប៉ងថា អាត្មាអញគប្បីស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្កៈនឹងវិចារៈ មានបីតិនឹងសុខដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ អានាបានស្សតិសមាធិនេះឯង ភិក្ខុគួរយកចិត្តទុកដាក់ដោយប្រពៃចុះ ។

[៣៩] ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះប្រសិនបើភិក្ខុក្នុងសាសនានេះ ប៉ុនប៉ងថា អាត្មាអញចូលកាន់ទុតិយជ្ឈានដែលកើតមានក្នុងសន្តានខ្លួន ជាទីផូរផង់មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កៈនឹងវិចារៈ មានតែបីតិនឹងសុខដែលកើតអំពីសមាធិ ព្រោះរម្ងាប់វិតក្កៈនឹងវិចារៈ អានាបានស្សតិសមាធិនេះឯង ភិក្ខុគួរយកចិត្តទុកដាក់ដោយប្រពៃចុះ ។

[៤០] ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះប្រសិនបើភិក្ខុក្នុងសាសនានេះប៉ុនប៉ងថា អាត្មាអញ ព្រោះនឿយណាយចាកបីតិផង ជាអ្នកប្រកបដោយឧបេក្ខាផង មានស្មារតីដឹងខ្លួនផង សោយសេចក្តីសុខដោយនាមកាយផង ព្រះអរិយៈទាំងឡាយតែងសរសើរនូវបុគ្គលដែលបានតតិយជ្ឈានថា ជាអ្នកមានឧបេក្ខា មានស្មារតី មានធម៌ជាគ្រឿងនៅជាសុខដូច្នេះ ព្រោះតតិយជ្ឈានឯណា គប្បីចូលកាន់តតិយជ្ឈាននោះ អានាបានស្សតិសមាធិនេះឯង ភិក្ខុគួរយកចិត្តទុកដាក់ដោយប្រពៃចុះ ។

(៤១) តស្មាតិហ ភិក្ខវេ ភិក្ខុ ចេបិ អាកង្ខេយ្យ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធឹ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរេយ្យន្តិ អយមេវ អានាបានស្សតិសមាធិ សាធុកំ មនសិកាតព្វោ ។

(៤២) តស្មាតិហ ភិក្ខវេ ភិក្ខុ ចេបិ អាកង្ខេយ្យ សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរេយ្យន្តិ អយមេវ អានាបានស្សតិសមាធិ សាធុកំ មនសិកាតព្វោ ។

(៤៣) តស្មាតិហ ភិក្ខវេ ភិក្ខុ ចេបិ អាកង្ខេយ្យ សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរេយ្យន្តិ អយមេវ អានាបានស្សតិសមាធិ សាធុកំ មនសិកាតព្វោ ។

## ឯកធម្មវគ្គ ទី ១

(៤១) ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះប្រសិនបើភិក្ខុក្នុងសាសនានេះ ប៉ុនប៉ងថា អាត្មាអញព្រោះលះបង់នូវសុខផង ព្រោះលះបង់នូវទុក្ខផង មានសោមនស្សនិងទោមនស្សអស់ទៅក្នុងកាលមុនផង គប្បីចូលកាន់ចតុត្ថជ្ឈានជាធម្មជាតមានអារម្មណ៍មិនមែនជាទុក្ខ មិនមែនជាសុខ គឺជាឧបេក្ខា មានសតិដ៏បរិសុទ្ធដោយឧបេក្ខា អានាបានស្សតិសមាធិនេះឯង ភិក្ខុគួរយកចិត្តទុកដាក់ ដោយប្រពៃចុះ ។

(៤២) ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះប្រសិនបើភិក្ខុក្នុងសាសនានេះ ប៉ុនប៉ងថា អាត្មាអញព្រោះកន្លងបង់នូវរូបសញ្ញាដោយប្រការទាំងពួង ព្រោះអស់បដិឃសញ្ញា ហើយលែងធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា គប្បីចូលកាន់អាកាសានញ្ចាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុតដូច្នេះ អានាបានស្សតិសមាធិនេះឯង ភិក្ខុគួរយកចិត្តទុកដាក់ដោយប្រពៃចុះ ។

(៤៣) ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ប្រសិនបើភិក្ខុក្នុងសាសនានេះ ប៉ុនប៉ងថា អាត្មាអញព្រោះកន្លងបង់នូវអាកាសានញ្ចាយតនជ្ឈានដោយប្រការទាំងពួង គប្បីចូលកាន់វិញ្ញាណញ្ចាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមានទីបំផុតដូច្នេះ អានាបានស្សតិសមាធិនេះឯង ភិក្ខុគួរយកចិត្តទុកដាក់ដោយប្រពៃចុះ ។

[ ៤៤ ] តស្មាតិហ ភិក្ខវេ ភិក្ខុ ចេបិ អាកង្ខេយ្យ សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរេយ្យន្តិ អយមេវ អានាបានស្សតិសមាធិ សាធុកំ មនសិកាតព្វោ ។

[ ៤៥ ] តស្មាតិហ ភិក្ខវេ ភិក្ខុ ចេបិ អាកង្ខេយ្យ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរេយ្យន្តិ អយមេវ អានាបានស្សតិសមាធិ សាធុកំ មនសិកាតព្វោ ។

[៤៦] តស្មាតិហ ភិក្ខវេ ភិក្ខុ ចេបិ អាកង្ខេយ្យ សព្វសោ នេវសញ្ញានាសញ្ញាយតនំ សមតិក្កម្ម សញ្ញាវេទយិតនិរោធំ ឧបសម្បជ្ជ វិហរេយ្យន្តិ អយមេវ អានាបានស្សតិសមាធិ សាធុកំ មនសិកាតព្វោ ។

[៤៧] ឯវំ ភាវិតេ ខោ ភិក្ខវេ អានាបានស្សតិសមាធិម្ហិ ឯវំ ពហុលីកតេ សុខញ្ចេ វេទនំ វេទយតិ សា អនិច្ចាតិ បជានាតិ អនជ្ឈោសិតាតិ បជានាតិ

(៤៤) ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ប្រសិនបើ ភិក្ខុក្នុងសាសនានេះ ប៉ុនប៉ងថា អាត្មាអញព្រោះកន្លងបង់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង គប្បីចូលកាន់អាកិញ្ចញ្ញាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា អ្វីបន្តិចបន្តួចមិនមានដូច្នេះ អានាបានស្សតិសមាធិនេះឯង ភិក្ខុគួរយកចិត្តទុកដាក់ដោយប្រពៃចុះ ។

(៤៥) ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ប្រសិនបើ ភិក្ខុក្នុងសាសនានេះ ប៉ុនប៉ងថា អាត្មាអញព្រោះកន្លងបង់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង គប្បីចូលកាន់នេវសញ្ញានាសញ្ញាយតនជ្ឈាន អានាបានស្សតិសមាធិនេះឯង ភិក្ខុគួរយកចិត្តទុកដាក់ដោយប្រពៃចុះ ។

(៤៦) ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ប្រសិនបើភិក្ខុក្នុងសាសនានេះប៉ុនប៉ងថា អាត្មាអញព្រោះកន្លងបង់នូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង គប្បីចូលកាន់សញ្ញាវេទយិតនិរោធ អានាបានស្សតិសមាធិនេះឯង ភិក្ខុគួរយកចិត្តទុកដាក់ដោយប្រពៃចុះ ។

(៤៧) ម្នាលភិក្ខុទាំងឡាយ កាលបើអានាបានស្សតិសមាធិ ដែលភិក្ខុចំរើនយ៉ាងនេះហើយ ធ្វើឲ្យច្រើនយ៉ាងនេះហើយ បើភិក្ខុនោះសោយនូវវេទនាជាសុខដឹងច្បាស់ថា វេទនានោះមិនទៀង ដឹងច្បាស់ថា មិនគួរ

អនភិនន្ទិតាតិ បជានាតិ ។ ទុក្ខញ្ចេ វេទនំ វេទយតិ សោ អនិច្ចាតិ បជានាតិ អនជ្ឈោសិតាតិ បជានាតិ អនភិនន្ទិតាតិ បជានាតិ ។ អទុក្ខមសុខញ្ចេ វេទនំ វេទយតិ សោ អនិច្ចាតិ បជានាតិ អនជ្ឈោសិតាតិ បជានាតិ អនភិនន្ទិតាតិ បជានាតិ ។ សោ សុខំ ចេ វេទនំ វេទយតិ វិសំយុត្តោ នំ វេទយតិ ។ ទុក្ខំ ចេ វេទនំ វេទយតិ វិសំយុត្តោ នំ វេទយតិ ។ អទុក្ខមសុខំ ចេ វេទនំ វេទយតិ វិសំយុត្តោ នំ វេទយតិ ។ សោ កាយបរិយន្តិកំ វេទនំ វេទយមានោ កាយបរិយន្តិកំ វេទនំ វេទយាមីតិ បជានាតិ ជីវិតបរិយន្តិកំ វេទនំ វេទយមានោ ជីវិតបរិយន្តិកំ វេទនំ វេទយាមីតិ បជានាតិ កាយស្ស ភេទា ឧទ្ធំ ជីវិតបរិយាទានា ឥធេវ សព្វវេទយិតានិ អនភិនន្ទិតានិ សីតីភវិស្សន្តីតិ បជានាតិ ។

(៤៨) សេយ្យថាបិ ភិក្ខវេ តេលញ្ច បដិច្ច វដ្ដិញ្ច បដិច្ច តេលប្បទីបោ ឈាយេយ្យ តស្សេវ តេលស្ស ច វដ្ដិយា ច បរិយាទានា អនាហារោ និព្វាយេយ្យ ។

ប្រកាន់មាំ ដឹងច្បាស់ថា មិនគួរត្រេកអរ ។ បើភិក្ខុនោះសោយវេទនាជាទុក្ខដឹងច្បាស់ថា វេទនានោះមិនទៀង ដឹងច្បាស់ថា មិនគួរប្រកាន់មាំ ដឹងច្បាស់ថា មិនគួរត្រេកអរ ។ បើភិក្ខុនោះ សោយវេទនាមិនមែនទុក្ខមិនមែនសុខ ដឹងច្បាស់ថា វេទនានោះមិនទៀង ដឹងច្បាស់ថា មិនគួរប្រកាន់មាំ ដឹងច្បាស់ថា មិនគួរត្រេកអរ ។ បើភិក្ខុនោះសោយវេទនាជាសុខ មិនប្រកបដោយកិលេស សោយនូវវេទនានោះ ។ បើភិក្ខុនោះ សោយវេទនាជាទុក្ខ ក៏មិនប្រកបដោយកិលេស សោយនូវវេទនានោះ ។ បើភិក្ខុនោះសោយវេទនាមិនមែនទុក្ខមិនមែនសុខ ក៏មិនប្រកបដោយកិលេស សោយនូវវេទនានោះ ។ កាលភិក្ខុនោះសោយវេទនា មានកាយជាទីបំផុត ដឹងច្បាស់ថា អាត្មាអញសោយវេទនាមានកាយជាទីបំផុត កាលសោយវេទនាមានជីវិតជាទីបំផុត ដឹងច្បាស់ថា អាត្មាអញសោយវេទនាមានជីវិតជាទីបំផុត លុះទំលាយរាងកាយបន្ទាប់អំពីការអស់ជីវិតទៅ ដឹងច្បាស់ថា ការសោយនូវវេទនាទាំងអស់ក្នុងលោកនេះ មិនគួរត្រេកអរ នឹងរលត់ទៅវិញ ។

[៤៨] ម្នាលភិក្ខុទាំងឡាយ ដូចប្រទីបប្រេង ដែលឆេះទៅបាន ព្រោះអាស្រ័យប្រេងនឹងប្រឆេះ ដែលមិនមានអាហារ គប្បីរលត់ទៅ ព្រោះអស់ទៅនៃប្រេងនឹងប្រឆេះនោះឯង យ៉ាងណា ។

ឯវមេវ ខោ ភិក្ខវេ ភិក្ខុ កាយបរិយន្តិកំ វេទនំ វេទយមានោ កាយបរិយន្តិកំ វេទនំ វេទយាមីតិ បជានាតិ ជីវិតបរិយន្តិកំ វេទនំ វេទយមានោ ជីវិតបរិយន្តិកំ វេទនំ វេទយាមីតិ បជានាតិ កាយស្ស ភេទា ឧទ្ធំ ជីវិតបរិយាទានា ឥធេវ សព្វវេទយិតានិ អនភិនន្ទិតានិ សីតីភវិស្សន្តីតិ បជានាតីតិ ។

(៤៩) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ តេន ខោ បន សមយេន ភគវា ភិក្ខូនំ អនេក បរិយាយេន អសុភកថំ កថេតិ អសុភាយ វណ្ណំ ភាសតិ អសុភភាវនាយ វណ្ណំ ភាសតិ ។ អថខោ ភគវា ភិក្ខូ អាមន្តេសិ ឥច្ឆាមហំ ភិក្ខវេ អឌ្ឍមាសំ បដិសល្លីយិតុំ នម្ហិ កោចិ ឧបសង្កមិតព្វោ អញ្ញត្រ ឯកេន បិណ្ឌបាតនីហារកេនាតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បដិស្សុត្វា នាស្សុធ កោចិ ភគវន្តំ ឧបសង្កមតិ អញ្ញត្រ ឯកេន បិណ្ឌបាតនីហារកេន ។

ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុសោយវេទនា មានកាយជាទីបំផុត ដឹងច្បាស់ថា អាត្មាអញ សោយវេទនាមានកាយជាទីបំផុត កាលសោយវេទនាមានជីវិតជាទីបំផុត ដឹងច្បាស់ថា អាត្មាអញសោយវេទនាមានជីវិតជាទីបំផុត លុះទំលាយរាងកាយបន្ទាប់អំពីការអស់ជីវិតទៅ ដឹងច្បាស់ថា ការសោយនូវវេទនាទាំងអស់ ក្នុងលោកនេះ មិនគួរត្រេកអរ នឹងរលត់ទៅវិញ ក៏យ៉ាងនោះដែរ ។

(៤៩) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងកូដាគារសាលា នាព្រៃមហាវ័ន ទៀបក្រុងវេសាលី ។ សម័យនោះឯងព្រះដ៏មានព្រះភាគទ្រង់សំដែងអសុភកថាទ្រង់សំដែងគុណនៃអសុភ ទ្រង់សំដែងគុណនៃការចំរើនអសុភដល់ភិក្ខុទាំងឡាយដោយអនេកបរិយាយ ។ គ្រានោះឯងព្រះដ៏មានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតចង់គេចចាកអារម្មណ៍សម្ងំនៅតែម្នាក់ឯង អស់កន្លះខែ កុំឲ្យអ្នកណាមួយចូលទៅរកតថាគតឡើយ វៀរលែងតែភិក្ខុមួយរូបអ្នកនាំចង្ហាន់បិណ្ឌបាតទៅថ្វាយតថាគត ។ ពួកភិក្ខុនោះ ក៏ទទួលព្រះពុទ្ធដីការបស់ព្រះដ៏មានព្រះភាគថា ព្រះករុណា ព្រះអង្គដ៏ចំរើន ក៏ឥតមានភិក្ខុណាមួយចូលទៅរកព្រះដ៏មានព្រះភាគឡើយ វៀរលែងតែភិក្ខុ ១រូបអ្នកនាំចង្ហាន់បិណ្ឌបាតទៅថ្វាយ ព្រះដ៏មានព្រះភាគ ។

## ឯកធម្មវគ្គោ បឋមោ

(៥១) អថខោ តេ ភិក្ខូ ភគវា អនេកបរិយាយេន អសុភកថំ កថេតិ អសុភាយ វណ្ណំ ភាសតិ អសុភភាវនាយ វណ្ណំ ភាសតីតិ អនេកាការវោការំ អសុភភាវនានុយោគមនុយុត្តា វិហរន្តិ តេ ឥមិនា កាយេន អដ្ដីយមានា ហរាយមានា ជិគុច្ឆមានា សត្ថហារកំ បរិយេសន្តិ ទសបិ ភិក្ខូ ឯកាហេន សត្ថំ អាហរន្តិ វីសតិបិ ។បេ។ តឹសតិបិ ភិក្ខូ ឯកាហេន សត្ថំ អាហរន្តិ ។

(៥១) អថខោ ភគវា តស្ស អឌ្ឍមាសស្ស អច្ចយេន បដិសល្លានា វុដ្ឋិតោ អាយស្មន្តំ អានន្ទំ អាមន្តេសិ កិន្នុ ខោ អានន្ទ តនុភូតោ វិយ ភិក្ខុសង្ឃោតិ ។ តថា ហិ បន ភន្តេ ភគវា ភិក្ខូនំ អនេកបរិយាយេន អសុភកថំ កថេតិ អសុភាយ វណ្ណំ ភាសតិ អសុភភាវនាយ វណ្ណំ ភាសតិ ។ តេ ភន្តេ ភិក្ខូ

## ឯកធម្មវត្ថុ ទី១

[៥០] លំដាប់នោះ ភិក្ខុទាំងនោះក៏គិតគ្នាថា ព្រះដ៏មានព្រះភាគ ត្រាស់សំដែងអសុភកថា ពោលសរសើរគុណនៃអសុភ ពោលសរសើរគុណនៃការចំរើនអសុភដោយបរិយាយដ៏ច្រើន លុះគិតដូច្នេះហើយ ក៏នាំគ្នាប្រកបសេចក្តីព្យាយាមក្នុងការចំរើនអសុភជាច្រើនបែបច្រើនវិធី ភិក្ខុទាំងនោះក៏នឿយណាយ ធុញទ្រាន់ ខ្ពើមឆ្អើម នឹងរាងកាយនេះ នាំគ្នាស្វែងរកគ្រឿងសស្ត្រា(១)ភិក្ខុ១០រូបនាំគ្រឿងសស្ត្រាតែមួយថ្ងៃក៏មាន ២០ រូប ៗបេៗ ពួកភិក្ខុ ៣០ រូបនាំគ្រឿងសស្ត្រាមកតែមួយថ្ងៃក៏មាន ។

[៥១] គ្រានោះឯង ព្រះដ៏មានព្រះភាគ ចេញចាកផលសមាបត្តិ ដោយកាលកន្លះខែកន្លងទៅ ក៏ហៅព្រះអានន្ទដ៏មានអាយុមកថា ម្នាល អានន្ទ ហេតុដូចម្តេចហ្ន៎ បានជាពួកភិក្ខុហាក់ដូចជាស្តួចស្តើងទៅ ។ ទើប ព្រះអានន្ទក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ពិតដូចជាព្រះពុទ្ធដីកា ណាស់ ព្រោះព្រះដ៏មានព្រះភាគត្រាស់សំដែងអសុភកថា ទ្រង់ពោល សរសើរអសុភ ទ្រង់ពោលសរសើរការចំរើននូវអសុភ ដល់ភិក្ខុទាំងឡាយ ដោយបរិយាយដ៏ច្រើន ។ បពិត្រព្រះអង្គដ៏ចំរើន លុះពួកភិក្ខុនោះគិតគ្នាថា

---

១ ភិក្ខុទាំងនោះ មិនមែនគ្រាន់តែស្វែងរកគ្រឿងសស្ត្រាមកតែប៉ុណ្ណោះទេ ក៏បានផ្តាច់ជីវិតខ្លួនដោយខ្លួនឯងក៏មាន បានចូលទៅរកសមណកុត្តកៈឈ្មោះមិគលណ្ឌិក ឲ្យផ្តាច់ជីវិតខ្លួនក៏មាន(ដូចមានសេចក្តីដំណាលក្នុងវិន័យបិដកភាគទី ១ ទំព័រ ២២៣ )អដ្ឋកថា ។

ភគវា ខោ អនេកបរិយាយេន អសុភកថំ កថេតិ អសុភាយ វណ្ណំ ភាសតិ អសុភភាវនាយ វណ្ណំ ភាសតីតិ អនេកាការវោការំ អសុភភាវនានុយោគមនុយុត្តា វិហរន្តិ តេ ឥមិនា កាយេន អដ្ដិយមានា ហរាយមានា ជិគុច្ឆមានា សត្ថហារកំ បរិយេសន្តិ ទសបិ ភិក្ខូ ឯកាហេន សត្ថំ អាហរន្តិ វីសតិបិ ។ បេ ។ តឹសតិបិ ភិក្ខូ ឯកាហេន សត្ថំ អាហរន្តិ ។ សាធុ ភន្តេ ភគវា បរិយាយំ(១) អាចិក្ខតុ យថាយំ(២) ភិក្ខុសង្ឃោ អញ្ញាយ សណ្ឋហេយ្យាតិ ។

(៩២) តេនហានន្ទ យាវតិកា វេសាលឹ ឧបនិស្សាយ វិហរន្តិ តេ សព្វេ ឧបដ្ឋានសាលាយំ សន្និបាតេហីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បដិស្សុត្វា យាវតិកា ភិក្ខូ វេសាលឹ ឧបនិស្សាយ វិហរន្តិ តេ សព្វេ ឧបដ្ឋានសាលាយំ សន្និបាតេត្វា

---

១ ឱ. ម អញ្ញម្បរិយាយំ ។ ២ ឱ. តថា យថាយំ ។

ព្រះដ៏មានព្រះភាគត្រាស់សំដែងអសុភកថា ពោលសរសើរអសុភ ពោលសរសើរការចំរើននូវអសុភ ដោយបរិយាយដ៏ច្រើន លុះភិក្ខុនោះគិតដូច្នេះហើយ ក៏នាំគ្នាប្រកបសេចក្ដីព្យាយាមក្នុងការចំរើនអសុភ ជាច្រើនបែបច្រើនវិធី ពួកភិក្ខុនោះនឿយណាយ ធុញទ្រាន់ ខ្ពើមឆ្អើមនឹងរាងកាយនេះ ក៏នាំគ្នាស្វែងរកគ្រឿងសស្ត្រា ភិក្ខុ១០ រូបនាំគ្រឿងសស្ត្រាមកតែ ១ ថ្ងៃក៏មាន២០រូប ។បេ។ ៣០ រូបនាំគ្រឿងសស្ត្រាមកតែមួយថ្ងៃក៏មាន ៗ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុសង្ឃនេះស្ថិតនៅបានដោយហេតុឯណាដទៃទៀត ខ្ញុំព្រះអង្គសូមអង្វរ សូមព្រះដ៏មានព្រះភាគ សំដែងនៅហេតុនោះឲ្យទានៗ

(៥២) ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលអានន្ទ បើដូច្នោះ ពួកភិក្ខុទាំងអម្បាលមាណ ដែលនៅអាស្រ័យនឹងក្រុងវេសាលី ចូរឲ្យពួកភិក្ខុអម្បាលនោះទាំងអស់ ប្រជុំគ្នា ក្នុងឧបដ្ឋានសាលាចុះ ៗ ព្រះអានន្ទដ៏មានអាយុ ក៏ទទួលព្រះពុទ្ធដីការបស់ព្រះដ៏មានព្រះភាគថា ករុណាព្រះអង្គ ដូច្នេះហើយ ពួកភិក្ខុទាំងអម្បាលមាណដែលនៅអាស្រ័យនឹងក្រុងវេសាលី ក៏ឲ្យពួកភិក្ខុអម្បាលនោះ ទាំងអស់ ប្រជុំគ្នាក្នុងឧបដ្ឋានសាលារួចហើយ

យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ ឯតទវោច សន្និបតិតោ ភន្តេ ភិក្ខុសង្ឃោ យស្ស-ទានិ ភគវា កាលំ មញ្ញតីតិ ។

[៥៣] អថខោ ភគវា យេន ឧបដ្ឋានសាលា តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ និសជ្ជ ខោ ភគវា ភិក្ខូ អាមន្តេសិ អយំបិ ខោ ភិក្ខវេ អានាបានស្សតិសមាធិ ភាវិ-តោ ពហុលីកតោ សន្តោ ចេវ បណីតោ ច អសេចនកោ ច សុខោ ច វិហារោ ឧប្បន្នុប្បន្នេ ច បាបកេ អកុសលេ ធម្មេ ឋានសោ អន្ត-រធាបេតិ វូបសមេតិ ។

[៥៤] សេយ្យថាបិ ភិក្ខវេ គិម្ហានំ បច្ឆិមេ មាសេ ឩហតំ រជោជល្លំ តមេនំ មហា-អកាលមេឃោ ឋានសោ អន្តរធាបេតិ វូបសមេតិ ។

ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ដោយពាក្យដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុសង្ឃប្រជុំគ្នាស្រេចហើយ សូមព្រះដ៏មានព្រះភាគសំគាល់កាលគួរ ក្នុងកាលឥឡូវនេះ ។

(៤៣) គ្រានោះឯង ព្រះដ៏មានព្រះភាគ ស្ដេចចូលទៅកាន់ឧបដ្ឋានសាលា លុះចូលទៅដល់ហើយ គង់លើអាសនៈ ដែលគេក្រាលថ្វាយ ។ លុះព្រះដ៏មានព្រះភាគទ្រង់គង់ហើយ ទើបត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិសមាធិនេះឯងដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ ជាធម៌ល្អិតផង ជាធម៌ឧត្ដមផង ជាធម៌មិនច្រឡូកច្រឡំដោយ (តណ្ហា នឹងឧបាទាន) ផង ជាធម៌ជាគ្រឿងនៅនាំមកនូវសេចក្ដីសុខផង តែងញុំាងអកុសលធម៌ទាំងឡាយ ដ៏លាមកដែលកើតឡើងហើយ ៗ ឲ្យសាបសូន្យទៅ ឲ្យស្ងប់រម្ងាប់ដោយហេតុដ៏សមគួរផង ។

(៤៤) ម្នាលភិក្ខុទាំងឡាយ ដូចកំទេចធូលី ដែលខ្យល់បក់កួចឡើងក្នុងខែជាខាងចុងនៃគិម្ហរដូវ (ខែអាសាឍ) មហាអកាលមេឃ (ភ្លៀងធំបង្អុរចុះខុសកាលវេលា) តែងញុំាងកំទេចធូលីនោះឲ្យអន្តរធានឲ្យស្ងប់ទៅបានដោយទំនងដ៏សមគួរ មានឧបមាយ៉ាងណាមិញ ។

ឯវមេវ ខោ ភិក្ខវេ អានាបានស្សតិសមាធិ ភាវិតោ ពហុលីកតោ សន្តោ ចេវ បណីតោ ច អសេចនកោ ច សុខោ ច វិហារោ ឧប្បន្នុប្បន្នេ ច បាបកេ អកុសលេ ធម្មេ ឋានសោ អន្តរធាបេតិ វូបសមេតិ ។

[៨៨] កថំ ភាវិតោ ច ភិក្ខវេ អានាបានស្សតិសមាធិ កថំ ពហុលីកតោ សន្តោ ចេវ បណីតោ ច អសេចនកោ ច សុខោ ច វិហារោ ឧប្បន្នុប្បន្នេ ច បាបកេ អកុសលេ ធម្មេ ឋានសោ អន្តរធាបេតិ វូបសមេតិ ។ ឥធ ភិក្ខវេ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា និសីទតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា ។ សោ សតោវ អស្សសតិ សតោ បស្សសតិ ។ (វិត្ថារេតព្វំ) ។ បដិនិស្សគ្គានុបស្សី អស្សសិស្សាមីតិ សិក្ខតិ បដិនិស្សគ្គានុបស្សី បស្សសិស្សាមីតិ សិក្ខតិ ។

ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិសមាធិ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ ជាធម៌ល្អិតផង ជាធម៌ដ៏ឧត្តមផង ជាធម៌មិនប្រឡូកប្រឡំដោយ (តណ្ហានិងឧបាទាន) ផង ជាធម៌ជាគ្រឿងនៅ នាំមកនូវសេចក្តីសុខផង តែងញ៉ាំងធម៌ទាំងឡាយ ជាអកុសលដ៏លាមក ដែលកើតឡើងហើយ ៗ ឲ្យអន្តរធានឲ្យស្ងប់រម្ងាប់ទៅ ដោយហេតុដ៏សមគួរ ក៏យ៉ាងនោះដែរ ។

(៥៥) ម្នាលភិក្ខុទាំងឡាយ ចុះអានាបានស្សតិសមាធិ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ ជាធម៌ល្អិតផង ជាធម៌ដ៏ឧត្តមផង ជាធម៌មិនប្រឡូកប្រឡំដោយ (តណ្ហានិងឧបាទាន) ផង ជាធម៌ជាគ្រឿងនៅ នាំមកនូវសេចក្តីសុខផង តែងញ៉ាំងធម៌ទាំងឡាយ ជាអកុសលដ៏លាមក ដែលកើតឡើងហើយ ៗ ឲ្យអន្តរធានទៅ ឲ្យស្ងប់រម្ងាប់ទៅដោយហេតុដ៏សមគួរតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ នៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី អង្គុយពែនភ្នែនទាំងកាយឲ្យត្រង់ផ្ចង់ស្មារតី ឲ្យមានមុខឆ្ពោះទៅរក (កម្មដ្ឋាន) ។ ភិក្ខុនោះមានសតិដកដង្ហើមចេញ មានសតិដកដង្ហើមចូល ។ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ) ។ ភិក្ខុសិក្សាថា អាត្មាអញឃើញរឿយ ៗ នូវធម៌សម្រាប់លះកិលេសចោលហើយនឹងដកដង្ហើមចេញ សិក្សាថាអាត្មាអញឃើញរឿយ ៗ នូវធម៌សម្រាប់លះកិលេសចោល នឹងដកដង្ហើមចូល ។

ឯវំ ភាវិតោ ខោ ភិក្ខវេ អានាបានស្សតិសមាធិ ឯវំ ពហុលីកតោ សន្តោ ចេវ បណីតោ ច អសេចនកោ ច សុខោ ច វិហារោ ឧប្បន្នុប្បន្នេ ច បាបកេ អកុសលេ ធម្មេ ឋានសោ អន្តរធាបេតិ វូបសមេតីតិ ។

(៤៦) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា កិមិលាយំ វិហរតិ វេឡុវនេ ។ តត្រ ខោ ភគវា អាយស្មន្តំ កិមិលំ អាមន្តេសិ កថំ ភាវិតោ នុ ខោ កិមិល អានាបានស្សតិសមាធិ កថំ ពហុលីកតោ មហប្ផលោ ហោតិ មហានិសំសោតិ ។ ឯវំ វុត្តេ អាយស្មា កិមិលោ តុណ្ហី អហោសិ ។

(៤៧) ទុតិយម្បិ ខោ ភគវា ។ តតិយម្បិ ខោ ភគវា អាយស្មន្តំ កិមិលំ អាមន្តេសិ កថំ ភាវិតោ នុ ខោ កិមិល អានាបានស្សតិសមាធិ កថំ ពហុលីកតោ មហប្ផលោ ហោតិ មហានិសំសោតិ ។ តតិយម្បិ ខោ អាយស្មា កិមិលោ តុណ្ហី អហោសិ ។

ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិសមាធិ ដែលបុគ្គលចំរើនហើយយ៉ាងនេះ ធ្វើឲ្យច្រើនហើយយ៉ាងនេះ ជាធម៌ល្អិតផង ជាធម៌ឧត្តមផង ជាធម៌មិនច្រឡូកច្រឡំដោយ (តណ្ហានិងឧបាទាន) ផង ជាធម៌ជាគ្រឿងនៅ នាំមកនូវសេចក្ដីសុខផង រមែងញ៉ាំងធម៌ទាំងឡាយ ជាអកុសលដ៏លាមកដែលកើតឡើងហើយ ៗ ឲ្យអន្តរធានទៅ ឲ្យស្ងប់រម្ងាប់ទៅដោយហេតុដ៏សមគួរផង ។

[៥៦] ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវនទៀបក្រុងកិមិលា ។ ក្នុងទីនេះឯង ព្រះដ៏មានព្រះភាគត្រាស់នឹងព្រះកិមិលៈដ៏មានអាយុថា ម្នាលកិមិលៈ អានាបានស្សតិសមាធិ បុគ្គលចំរើនដូចម្ដេច ធ្វើឲ្យច្រើនដូចម្ដេច ទើបមានផលច្រើនមានអានិសង្សច្រើន ។ កាលបើព្រះដ៏មានព្រះភាគត្រាស់យ៉ាងនេះហើយព្រះកិមិលៈដ៏មានអាយុក៏នៅស្ងៀម ។

[៥៧] ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ជាគំរប់ ២ ដងទៀត ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់នឹងព្រះកិមិលៈដ៏មានអាយុជាគំរប់ ៣ ដងទៀតថា ម្នាលកិមិលៈ អានាបានស្សតិសមាធិ ដែលបុគ្គលចំរើនដូចម្ដេច ធ្វើឲ្យច្រើនដូចម្ដេច ទើបមានផលច្រើន មានអានិសង្សច្រើន ។ ព្រះកិមិលៈដ៏មានអាយុ ក៏នៅស្ងៀមជាគំរប់ ៣ ដងទៀត ។

( ៥៨ ) ឯវំ វុត្តេ អាយស្មា អានន្ទោ ភគវន្តំ ឯត-
ទវោច ឯតស្ស ភគវា កាលោ ឯតស្ស សុគត
កាលោ យំ ភគវា អានាបានស្សតិសមាធឹ ភាសេយ្យ
ភគវតោ សុត្វា ភិក្ខូ ធារេស្សន្តីតិ ។ តេនហានន្ទ
សុណាហិ សាធុកំ មនសិករោហិ ភាសិស្សាមីតិ ។
ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ
បច្ចស្សោសិ ។ ភគវា ឯតទវោច កថំ ភាវិតោ
ច អានន្ទ អានាបានស្សតិសមាធិ កថំ ពហុលី-
កតោ មហប្ផលោ ហោតិ មហានិសំសោ ។
ឥធានន្ទ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា
សុញ្ញាគារគតោ វា និសីទតិ បល្លង្កំ អាភុជិត្វា
ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ
ឧបដ្ឋបេត្វា ។ សោ សតោ វ អស្សសតិ ។បេ។
បដិនិស្សគ្គានុបស្សី អស្សសិស្សាមីតិ សិក្ខតិ
បដិនិស្សគ្គានុបស្សី បស្សសិស្សាមីតិ សិក្ខតិ ។

(៤៨) កាលបើព្រះដ៏មានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះអានន្ទដ៏មានអាយុ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដោយពាក្យដូច្នេះថា សូមទ្រង់ព្រះមេត្តាប្រោស កាលនេះជាកាលគួរដល់ព្រះដ៏មានព្រះភាគហើយ បពិត្រព្រះសុគត កាលនេះជាកាលគួរដល់ព្រះដ៏មានព្រះភាគ ព្រះដ៏មានព្រះភាគគួរសំដែងអានាបានស្សតិសមាធិ កាលភិក្ខុទាំងឡាយ បានស្តាប់ព្រះដ៏មានព្រះភាគហើយ នឹងបានចាំទុក ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលអានន្ទ បើដូច្នោះ ចូរអ្នកស្តាប់ចុះ យកចិត្តទុកដាក់ឲ្យប្រពៃចុះ តថាគតនឹងសំដែង។ ព្រះអានន្ទដ៏មានអាយុ ក៏ទទួលព្រះពុទ្ធដីការបស់ព្រះដ៏មានព្រះភាគថា ករុណាព្រះអង្គដូច្នេះ ។ ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដោយពាក្យដូច្នេះថា ម្នាលអានន្ទ ចុះអានាបានស្សតិសមាធិដែលបុគ្គលចំរើនដូចម្តេច ធ្វើឲ្យច្រើនដូចម្តេច ទើបមានផលច្រើនមានអានិសង្សច្រើន ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ នៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី អង្គុយពែនភ្នែនតាំងកាយឲ្យត្រង់ ផ្ចង់ស្មារតី ឲ្យមានមុខឆ្ពោះទៅរក (កម្មដ្ឋាន) ។ ភិក្ខុនោះមានស្មារតីដកដង្ហើមចេញ ។ បេ ។ សិក្សាថាអាត្មាអញឃើញរឿយ ៗ នូវធម៌សម្រាប់លះកិលេសចោល នឹងដកដង្ហើមចេញ សិក្សាថាអាត្មាអញឃើញរឿយ ៗ នូវធម៌សម្រាប់លះកិលេសចោលនឹងដកដង្ហើមចូល ។

## ឯកធម្មវគ្គោបឋមោ

ឯវំ ភាវិតោ ខោ អានន្ទ អានាបានស្សតិសមាធិ ឯវំ ពហុលីកតោ មហប្ផលោ ហោតិ មហានិសំសោ ។

(៤៩) យស្មឹ សមយេ អានន្ទ ភិក្ខុ ទីឃំ វា អស្សសន្តោ ទីឃំ អស្សសាមីតិ បជានាតិ ទីឃំ វា បស្សសន្តោ ទីឃំ បស្សសាមីតិ បជានាតិ ។ រស្សំ វា អស្សសន្តោ រស្សំ អស្សសាមីតិ បជានាតិ រស្សំ វា បស្សសន្តោ រស្សំ បស្សសាមីតិ បជានាតិ ។ សព្វកាយប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ សព្វកាយប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ ។ បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ បស្សម្ភយំ កាយសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ ។ កាយេ កាយានុបស្សី អានន្ទ ភិក្ខុ តស្មឹ សមយេ វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ តំ កិស្ស ហេតុ ។ កាយញ្ញតរាហំ អានន្ទ ឯតំ វទាមិ យទិទំ អស្សាសបស្សាសំ ។ តស្មាតិហានន្ទ កាយេ កាយានុបស្សី ភិក្ខុ

ម្នាលអានន្ទ អានាបានស្សតិសមាធិ ដែលបុគ្គលចំរើនយ៉ាងនេះ ធ្វើឲ្យច្រើនយ៉ាងនេះ រមែងមានផលច្រើន មានអានិសង្សច្រើន ។

(៩៩) ម្នាលអានន្ទ សម័យណា ដែលភិក្ខុដកដង្ហើមចេញវែង ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញវែង ឬកាលដកដង្ហើមចូលវែង ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលវែង ។ កាលដកដង្ហើមចេញខ្លី ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញខ្លី ឬកាលដកដង្ហើមចូលខ្លី ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលខ្លី ។ ភិក្ខុសិក្សាថា អាត្មាអញកំណត់ដឹងច្បាស់នូវកាយ គឺដកដង្ហើមចេញទាំងពួង នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញកំណត់ដឹងច្បាស់នូវកាយ គឺដកដង្ហើមចូលទាំងពួង នឹងដកដង្ហើមចូល ។ សិក្សាថា អាត្មាអញរម្ងាប់កាយសង្ខារ គឺដកដង្ហើមចេញ ដកដង្ហើមចេញ សិក្សាថា អាត្មាអញរម្ងាប់កាយសង្ខារ គឺដកដង្ហើមចូល ដកដង្ហើមចូល ។ ម្នាលអានន្ទ ភិក្ខុអ្នកពិចារណាឃើញកាយក្នុងកាយ ជាអ្នកមានព្យាយាមដុតកំដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កំចាត់បង់នូវអភិជ្ឈានឹងទោមនស្ស ក្នុងលោកចេញបាន ក្នុងសម័យនោះ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលអានន្ទ តថាគតពោលនូវកាយថាជាខ្យល់ចេញចូល ។ ម្នាលអានន្ទ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញកាយក្នុងកាយជាប្រក្រតី

តស្មឹ សមយេ វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។

(៦០) យស្មឹ សមយេ អានន្ទ ភិក្ខុ បីតិប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ បីតិប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ ។ សុខប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ សុខប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ ។ ចិត្តសង្ខារប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ ចិត្តសង្ខារប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ ។ បស្សម្ភយំ ចិត្តសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ បស្សម្ភយំ ចិត្តសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ ។ វេទនាសុ វេទនានុបស្សី អានន្ទ ភិក្ខុ តស្មឹ សមយេ វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ តំ កិស្ស ហេតុ ។ វេទនាញ្ញតរាហំ អានន្ទ ឯតំ វទាមិ យទិទំ អស្សាសបស្សាសានំ សាធុកំ មនសិការំ ។

ជាអ្នកមានព្យាយាមដុតកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កំចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោកចេញបាន ក្នុងសម័យនោះ ។

(១០) ម្នាលអានន្ទ ក្នុងសម័យណា ដែលភិក្ខុសិក្សាថា អាត្មាអញកំណត់ដឹងនូវបីតិ នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញកំណត់ដឹងនូវបីតិ នឹងដកដង្ហើមចូល ។ សិក្សាថា អាត្មាអញកំណត់ដឹងច្បាស់នូវសេចក្តីសុខ នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញកំណត់ដឹងច្បាស់នូវសេចក្តីសុខ នឹងដកដង្ហើមចូល ។ សិក្សាថា អាត្មាអញកំណត់ដឹងច្បាស់នូវចិត្តសង្ខារ គឺសញ្ញានិងវេទនា នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញកំណត់ដឹងច្បាស់នូវចិត្តសង្ខារ នឹងដកដង្ហើមចូល ។ សិក្សាថា អាត្មាអញរម្ងាប់នូវចិត្តសង្ខារ នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញរម្ងាប់នូវចិត្តសង្ខារ នឹងដកដង្ហើមចូល ។ ម្នាលអានន្ទ ភិក្ខុពិចារណាឃើញរឿយ ៗ នូវវេទនាក្នុងវេទនាទាំងឡាយជាប្រក្រតី ជាអ្នកមានព្យាយាមដុតកំដៅកិលេសជាអ្នកដឹងខ្លួនមានស្មារតី កំចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញបាន ក្នុងសម័យនោះ ។ ដំណើរនោះព្រោះហេតុអ្វី ។ ម្នាលអានន្ទ ព្រោះតថាគតពោលនូវវេទនាណាមួយគឺការយកចិត្តទុកដាក់ដ៏ប្រពៃចំពោះអស្សាសៈនិងបស្សាសៈទាំងឡាយ ។

## ឯកធម្មវគ្គោ បឋមោ

តស្មាតិហានន្ទ វេទនាសុ វេទនានុបស្សី ភិក្ខុ តស្មឹ សមយេ វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។

(៦១) យស្មឹ សមយេ អានន្ទ ភិក្ខុ ចិត្តប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ ចិត្តប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ ។ អភិប្បមោទយំ ចិត្តំ ។ បេ ។ សមាទហំ ចិត្តំ ។ វិមោចយំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ វិមោចយំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ ។ ចិត្តេ ចិត្តានុបស្សី អានន្ទ ភិក្ខុ តស្មឹ សមយេ វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ តំ កិស្ស ហេតុ ។ នាហំ អានន្ទ មុដ្ឋស្សតិស្ស អសម្បជានស្ស អានាបានស្សតិសមាធិភាវនំ វទាមិ ។ តស្មាតិហានន្ទ ចិត្តេ ចិត្តានុបស្សី ភិក្ខុ តស្មឹ សមយេ វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។

## ឯកធម្មវគ្គ ទី ១

ម្នាលអានន្ទ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញវេទនា ក្នុងវេទនាទាំងឡាយជាប្រក្រតី ជាអ្នកមានព្យាយាមដុតកំដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កំចាត់បង់នូវអភិជ្ឈានិងទោមនស្សចេញបាន ក្នុងសម័យនោះ ។

(៦១) ម្នាលអានន្ទ សម័យណាភិក្ខុ សិក្សាថាអាត្មាអញកំណត់ដឹងច្បាស់នូវចិត្ត នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញកំណត់ដឹងច្បាស់នូវចិត្តនឹងដកដង្ហើមចូល ។ នឹងធ្វើចិត្តឲ្យរីករាយ ។បេ។ ធ្វើចិត្តឲ្យតាំងនៅក្នុងអារម្មណ៍ដ៏ស្មើ ។ សិក្សាថា អាត្មាអញធ្វើចិត្តឲ្យរួចស្រឡះ(ចាកនីវរណធម៌ជាដើម) នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញធ្វើចិត្តឲ្យរួចស្រឡះនឹងដកដង្ហើមចូល ។ ម្នាលអានន្ទ ភិក្ខុពិចារណាឃើញនូវចិត្តក្នុងចិត្តជាប្រក្រតី ជាអ្នកមានព្យាយាមដុតកំដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កំចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញបាន ក្នុងសម័យនោះ ។ ដំណើរនោះព្រោះហេតុអ្វី ។ ម្នាលអានន្ទ ព្រោះថាតថាគតមិនបានពោលនូវកិរិយាចំរើននូវអានាបានស្សតិសមាធិ របស់បុគ្គល ជាអ្នកភ្លេចស្មារតី ជាអ្នកមិនដឹងខ្លួនទេ ។ ម្នាលអានន្ទ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវចិត្តក្នុងចិត្តជាប្រក្រតី ជាអ្នកមានព្យាយាមដុតកំដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កំចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញបាន ក្នុងសម័យនោះ ។

[៦២] យស្មឹ សមយេ អានន្ទ ភិក្ខុ អនិច្ចានុបស្សី អស្សាសិស្សាមីតិ សិក្ខតិ ។ បេ ។ វិរាគានុបស្សី និរោធានុបស្សី បដិនិស្សគ្គានុបស្សី អស្សាសិស្សាមីតិ សិក្ខតិ បដិនិស្សគ្គានុបស្សី បស្សសិស្សាមីតិ សិក្ខតិ ។ ធម្មេសុ ធម្មានុបស្សី អានន្ទ ភិក្ខុ តស្មឹ សមយេ វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ សោ យន្តំ ហោតិ អភិជ្ឈាទោមនស្សានំ បហានំ តំ បញ្ញាយ ទិស្វា សាធុកំ អជ្ឈុបេក្ខិតា ហោតិ ។ តស្មាតិហានន្ទ ធម្មេសុ ធម្មានុបស្សី ភិក្ខុ តស្មឹ សមយេ វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។

[៦៣] សេយ្យថាបិ អានន្ទ ចាតុម្មហាបថេ មហាបំសុបុញ្ជោ បុរត្ថិមាយ ចេបិ ទិសាយ អាគច្ឆេយ្យ សកដំ វា រថោ វា ឧបហនេថេវ តំ បំសុបុញ្ជំ ។ បច្ឆិមាយ ចេបិ ទិសាយ អាគច្ឆេយ្យ ។

[៦២] ម្នាលអានន្ទ សម័យណា ភិក្ខុសិក្សាថា អាត្មាអញនឹងពិចារណាឃើញនូវបញ្ចក្ខន្ធថាមិនទៀង ដកដង្ហើមចេញ ។បេ។ សិក្សាថា អាត្មាអញនឹងពិចារណាឃើញនូវធម៌ប្រាសចាកតម្រេក ពិចារណាឃើញនូវធម៌សម្រាប់រលត់ទុក្ខ ពិចារណាឃើញធម៌សម្រាប់លះកិលេសចោលនឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញពិចារណាឃើញនូវធម៌សម្រាប់លះកិលេសចោលនឹងដកដង្ហើមចូល ។ ម្នាលអានន្ទ ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី ជាអ្នកមានព្យាយាមដុតកំដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កំចាត់បង់នូវអភិជ្ឈានឹងទោមនស្ស ក្នុងលោកចេញបាន ក្នុងសម័យនោះ ការលះបង់នូវអភិជ្ឈានឹងទោមនស្សឯណា ភិក្ខុនោះឃើញការលះបង់នោះ ដោយប្រាជ្ញាហើយ សម្លឹងមើលដោយប្រពៃ ។ ម្នាលអានន្ទ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី ជាអ្នកមានព្យាយាមដុតកំដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កំចាត់បង់នូវអភិជ្ឈានឹងទោមនស្ស ក្នុងលោកចេញបាន ក្នុងសម័យនោះ ។

[៦៣] ម្នាលអានន្ទ ដូចគំនរអាចម៍ដីដ៏ច្រើន មាននៅក្នុងផ្លូវធំបែកជា ៤ ប្រសិនបើរទេះក្តី រថក្តី មកអំពីទិសខាងកើត រមែងកិននូវគំនរអាចម៍ដីនោះពុំខានឡើយ ។ ប្រសិនបើមកអំពីទិសខាងលិចក្តី ។

ឯកធម្មវគ្គោ បឋមោ

ឧត្តរាយ ចេបិ ទិសាយ អាគច្ឆេយ្យ ។ ទក្ខិណាយ ចេបិ ទិសាយ អាគច្ឆេយ្យ សកដំ វា រថោ វា ឧបហនតេវ តំ បំសុបុញ្ជំ ។ ឯវមេវ ខោ អានន្ទ ភិក្ខុ កាយេ កាយានុបស្សី វិហរន្តោបិ ឧបហនតេវ បាបកេ អកុសលេ ធម្មេ ។ វេទនាសុ ។ ចិត្តេ ។ ធម្មេសុ ធម្មានុបស្សី វិហរន្តោបិ ឧបហនតេវ បាបកេ អកុសលេ ធម្មេតិ ។

ឯកធម្មវគ្គោ បឋមោ ។

## តស្សុទ្ទានំ

ឯកធម្មោ ច ពោជ្ឈង្គា
សុទ្ធិកំ ច ទ្វេ ផលា
អរិដ្ឋា កប្បិនោ ទីបោ
វេសាលី កិមិលេន ចាតិ ។

### ឯកធម្មវគ្គ ទី ១

មកអំពីទិសខាងជើងក្តី ៗ ប្រសិនបើរទេះក្តី រថក្តី មកអំពីទិសខាងត្បូង រមែងកិននូវគំនរអាចម៍ដីនោះពុំបានឡើយ យ៉ាងណា ៗ ម្នាលអានន្ទ កាលភិក្ខុពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី រមែងកំចាត់បង់នូវពួកធម៌ជាអកុសលដ៏លាមកពុំបានឡើយ ៗ ក្នុងវេទនាទាំងឡាយ ៗ ក្នុងចិត្ត ៗ ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី រមែងកំចាត់បង់នូវពួកធម៌ជាអកុសលដ៏លាមកពុំបានឡើយ ក៏យ៉ាងនោះដែរ ៗ

ចប់ ឯកធម្មវគ្គ ទី ១ ។

## ឧទ្ទានគឺបញ្ជីរឿងនៃឯកធម្មវគ្គនោះគឺៈ

ពោលអំពីការទ្រង់សំដែងធម៌ ១ ដែលជាអង្គនៃធម៌ជាគ្រឿងត្រាស់ដឹង ១ អំពីអានាបានស្សតិសុទ្ធិមានផល ២ ប្រការ ១ អំពីអរិដ្ឋភិក្ខុ ១ អំពីព្រះមហាកប្បិន ១ អំពីសេចក្តីប្រៀបដោយប្រទីបប្រេង ១ អំពីព្រះដ៏មានព្រះភាគគង់នៅទៀបក្រុងវេសាលី ១ អំពីព្រះកិមិលៈដ៏មានអាយុ ១ ៗ

## ទុតិយវគ្គោ ទុតិយោ

(៦៤) ឯកំ សមយំ ភគវា ឥច្ឆានង្គលេ វិហរតិ ឥច្ឆានង្គលវនសណ្ឌេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ឥច្ឆាមហំ ភិក្ខវេ តេមាសំ បដិសល្លីយិតុំ នម្ហិ កេនចិ ឧបសង្កមិតព្វោ អញ្ញត្រ ឯកេន បិណ្ឌបាតនីហារកេនាតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បដិស្សុត្វា នាស្សុធ កោចិ ភគវន្តំ ឧបសង្កមតិ អញ្ញត្រ ឯកេន បិណ្ឌបាតនីហារកេន ។

(៦៥) អថខោ ភគវា តស្ស តេមាសស្ស អច្ចយេន បដិសល្លានា វុដ្ឋិតោ ភិក្ខូ អាមន្តេសិ សចេ វោ(១) ភិក្ខវេ អញ្ញតិត្ថិយា បរិព្វាជកា ឯវំ បុច្ឆេយ្យុំ កតមេនាវុសោ វិហារេន សមណោ គោតមោ វស្សាវាសំ ពហុលំ វិហាសីតិ ។ ឯវំ បុដ្ឋា តុម្ហេ ភិក្ខវេ តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ ឯវំ ព្យាករេយ្យាថ អានាបានស្សតិសមាធិនា ខោ អាវុសោ ភគវា វស្សាវាសំ ពហុលំ វិហាសីតិ ។

---

១. ម. សចេ ខោ ។

## ទុតិយវគ្គ ទី ២

[ ៦៨ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងដងព្រៃឈ្មោះឥច្ឆានង្គល ជិតស្រុកឥច្ឆានង្គល ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតប្រាថ្នានឹងសម្ងំនៅក្នុងទីស្ងាត់ អស់ ៣ ខែ កុំឲ្យភិក្ខុណាមួយចូលមករកតថាគតឡើយ វៀរលែងតែភិក្ខុ ១ រូប អ្នកនាំមកនូវបិណ្ឌបាត ។ ភិក្ខុទាំងនោះទទួលស្តាប់ព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ឥតមានភិក្ខុណាមួយហ៊ានចូលទៅគាល់ព្រះដ៏មានព្រះភាគក្នុងទីនោះទេ វៀរលែងតែភិក្ខុ ១ រូប អ្នកនាំមកនូវបិណ្ឌបាត ។

[ ៦៩ ] លុះកន្លងកាល ៣ ខែនោះទៅហើយ ទើបព្រះដ៏មានព្រះភាគចេញចាកទីសម្ងំហើយ ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើមានពួកបរិព្វាជកជាអន្យតិរ្ថិយសួរអ្នកទាំងឡាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ព្រះសមណគោតមគង់ចាំវស្សាច្រើនដោយវិហារធម៌ ( ធម៌ជាគ្រឿងនៅ ) ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កាលបើពួកបរិព្វាជកជាអន្យតិរ្ថិយសួរយ៉ាងនេះហើយ អ្នកទាំងឡាយគប្បីដោះស្រាយ ចំពោះបរិព្វាជកជាអន្យតិរ្ថិយទាំងនោះយ៉ាងនេះវិញថា ម្នាលអាវុសោទាំងឡាយ ព្រះដ៏មានព្រះភាគទ្រង់ចាំវស្សាច្រើនដោយអានាបានស្សតិសមាធិ ។

## ទុតិយវគ្គោ ទុតិយោ

(៦៦) ឥធាហំ ភិក្ខវេ សតោ អស្សសាមិ សតោ បស្សសាមិ ទីឃំ វា អស្សសន្តោ ទីឃំ អស្សសាមីតិ បជានាមិ ទីឃំ វា បស្សសន្តោ ទីឃំ បស្សសាមីតិ បជានាមិ ។ រស្សំ វា អស្សសន្តោ រស្សំ អស្សសាមីតិ បជានាមិ រស្សំ វា បស្សសន្តោ រស្សំ បស្សសាមីតិ បជានាមិ ។ សព្វកាយប្បដិសំវេទី អស្សសិស្សាមីតិ បជានាមិ (វិត្ថារោ) ។ បដិនិស្សគ្គានុបស្សី អស្សសិស្សាមីតិ បជានាមិ បដិនិស្សគ្គានុបស្សី បស្សសិស្សាមីតិ បជានាមិ ។

(៦៧) យញ្ហិ តំ ភិក្ខវេ សម្មា វទមានោ វទេយ្យ អរិយវិហារោ ឥតិបិ ព្រហ្មវិហារោ ឥតិបិ តថាគតវិហារោ ឥតិបិ អានាបានស្សតិសមាធិ សម្មា វទមានោ វទេយ្យ អរិយវិហារោ ឥតិបិ ព្រហ្មវិហារោ ឥតិបិ តថាគតវិហារោ ឥតិបិ ។

## ទុតិយវគ្គ ទី ២

(៦៦) ម្នាលភិក្ខុទាំងឡាយ ក្នុងទីនេះតថាគតមានស្មារតីតាំងដាក់ដកដង្ហើមចេញ មានស្មារតីតាំងដាក់ដកដង្ហើមចូល កាលដកដង្ហើមចេញវែងក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញវែង កាលដកដង្ហើមចូលវែងក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលវែង ។ កាលដកដង្ហើមចេញខ្លីក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញខ្លី កាលដកដង្ហើមចូលខ្លីក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលខ្លី ។ តថាគតដឹងច្បាស់ថា អាត្មាអញនឹងជាអ្នកដឹងច្បាស់នូវកាយទាំងពួង ទើបដកដង្ហើមចេញ (សេចក្ដីពិស្ដារ) ។ តថាគតដឹងច្បាស់ថា អាត្មាអញនឹងជាអ្នកពិចារ-ណាឃើញនូវធម៌ជាគ្រឿងលះបោលនូវកិលេស ទើបដកដង្ហើមចេញ ដឹងច្បាស់ថា អាត្មាអញនឹងជាអ្នកពិចារណាឃើញនូវធម៌ជាគ្រឿងលះបោលនូវកិលេសដកដង្ហើមចូល ។

(៦៧) ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលពោលឲ្យត្រូវគប្បីពោលនូវធម៌ឯណាថា អរិយវិហារ (ធម៌ជាគ្រឿងនៅរបស់ព្រះអរិយៈ) ដូច្នេះក្ដី ថា ព្រហ្មវិហារ (ធម៌ជាគ្រឿងនៅរបស់ព្រហ្ម) ដូច្នេះក្ដី ថា តថាគត-វិហារ (ធម៌ជាគ្រឿងនៅរបស់ព្រះតថាគត) ដូច្នេះក្ដី បុគ្គលកាលពោលឲ្យត្រូវ គប្បីពោលនូវអានាបានស្សតិសមាធិចុះថា អរិយវិហារដូច្នេះក៏បាន ថា ព្រហ្មវិហារដូច្នេះក៏បាន ថា តថាគតវិហារដូច្នេះក៏បាន ។

យេ តេ ភិក្ខវេ ភិក្ខូ សេក្ខា អប្បត្តមានសា អនុត្តរំ យោគក្ខេមំ បត្ថយមានា(១) វិហរន្តិ តេសំ អានាបានស្សតិសមាធិ ភាវិតោ ពហុលីកតោ អាសវានំ ខយាយ សំវត្តតិ ។

(៦៨) យេ ច ខោ តេ ភិក្ខវេ ភិក្ខូ អរហន្តោ ខីណាសវា វុសិតវន្តោ កតករណីយា ឱហិតភារា អនុប្បត្តសទត្ថា បរិក្ខីណភវសំយោជនា សម្មទញ្ញា វិមុត្តា តេសំ អានាបានស្សតិសមាធិ ភាវិតោ ពហុលីកតោ ទិដ្ឋធម្មសុខវិហារាយ ចេវ សំវត្តតិ សតិសម្បជញ្ញាយ ច ។

(៦៩) យញ្ហិ តំ ភិក្ខវេ សម្មា វទមានោ វទេយ្យ អរិយវិហារោ ឥតិបិ ព្រហ្មវិហារោ ឥតិបិ តថាគតវិហារោ ឥតិបិ អានាបានស្សតិសមាធិំ សម្មា វទមានោ វទេយ្យ អរិយវិហារោ ឥតិបិ ព្រហ្មវិហារោ ឥតិបិ តថាគតវិហារោ ឥតិបីតិ ។

---

១ បត្ថយមានាតិបិ ។ ឥទុភយំ ឯកសទិសមេវ ។

ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុឯណាជាសេក្ខៈ មិនទាន់បានសម្រេចអរហត្តផលនៅឡើយ កាលបើប្រាថ្នានូវព្រះនិព្វានជាទីក្សេមចាកយោគៈដ៏ប្រសើរ អានាបានស្សតិសមាធិដែលភិក្ខុទាំងនោះ បានចំរើនបានធ្វើឲ្យរឿយ ៗ ហើយរមែងប្រព្រឹត្តទៅដើម្បីអស់ទៅនៃអាសវៈទាំងឡាយបាន ។

( ៦៨ ) ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុឯណា ជាអរហន្តមានអាសវៈអស់ហើយ មានព្រហ្មចរិយៈនៅរួចហើយ មានសោឡសកិច្ចធ្វើស្រេចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនបានសម្រេចហើយ មានកិលេសជាគ្រឿងប្រកបក្នុងភពអស់រលីងហើយ មានចិត្តផុតស្រឡះហើយ ព្រោះដឹងច្បាស់ដោយប្រពៃ អានាបានស្សតិសមាធិដែលភិក្ខុទាំងនោះបានចំរើនបានធ្វើឲ្យរឿយ ៗ ហើយ រមែងប្រព្រឹត្តទៅដើម្បីនៅជាសុខក្នុងបច្ចុប្បន្នផង ដើម្បីសតិនិងសម្បជញ្ញៈផង ។

( ៦៩ ) ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលពោលឲ្យត្រូវគប្បីពោលនូវធម៌ឯណាថា អរិយវិហារធម៌ប្រះក្តី ថា ព្រហ្មវិហារធម៌ប្រះក្តី ថា តថាគតវិហារធម៌ប្រះក្តី បុគ្គលកាលពោលឲ្យត្រូវ គប្បីពោលនូវអានាបានស្សតិសមាធិចុះថា អរិយវិហារធម៌ប្រះក៏បាន ថា ព្រហ្មវិហារធម៌ប្រះក៏បាន ថា តថាគតវិហារធម៌ប្រះក៏បាន ។

## ទុតិយវគ្គោ ទុតិយោ

(៧០) ឯកំ សមយំ អាយស្មា លោមសកំគិយោ(១) សក្កេសុ វិហរតិ កបិលវត្ថុស្មឹ និគ្រោធារាមេ ។ អថខោ មហានាមោ សក្កោ យេនាយស្មា លោមសកំគិយោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ លោមសកំគិយំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ មហានាមោ សក្កោ អាយស្មន្តំ លោមសកំគិយំ ឯតទវោច ស្វេវ នុ ខោ ភន្តេ សេក្ខោ វិហារោ សោ តថាគតវិហារោ ។ ឧទាហុ អញ្ញោ សេក្ខោ វិហារោ អញ្ញោ តថាគតវិហារោតិ ។ ន ខោ អាវុសោ មហានាម ស្វេវ សេក្ខោ វិហារោ សោ តថាគតវិហារោ ។ អញ្ញោ ខោ អាវុសោ មហានាម សេក្ខោ វិហារោ អញ្ញោ តថាគតវិហារោ ។

(៧១) យេ តេ អាវុសោ មហានាម ភិក្ខូ សេក្ខា អប្បត្តមានសា អនុត្តរំ យោគក្ខេមំ បត្ថយមានា វិហរន្តិ តេ បញ្ច នីវរណេ បហាយ វិហរន្តិ ។

---

១ ឱ. លោមសវង្គីសោ ។

## ទុតិយវគ្គ ទី ២

[៧០] សម័យមួយ ព្រះលោមសកំកិយៈដ៏មានអាយុ គង់នៅក្នុងនិគ្រោធារាម ជិតក្រុងកបិលព័ស្ដុ ក្នុងដែនសក្កៈ ។ គ្រានោះស្ដេចសក្យឈ្មោះមហានាម ចូលទៅរកព្រះលោមសកំកិយៈដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះលោមសកំកិយៈដ៏មានអាយុ ហើយគង់ក្នុងទីដ៏សមគួរ ។ លុះមហានាមសក្យ គង់ក្នុងទីសមគួរហើយ ក៏ពោលទៅនឹងព្រះលោមសកំកិយៈដ៏មានអាយុ ដូច្នេះថា បពិត្រលោកម្ចាស់ដ៏ចំរើន សេក្ខវិហារ (ធម៌ជាគ្រឿងនៅរបស់សេក្ខៈ) នោះឯងគឺជា តថាគតវិហារនោះឬហ្ន៎ ។ ឬថាសេក្ខវិហារដោយឡែក តថាគតវិហារដោយឡែក ។ ម្នាលអាវុសោ មហានាម សេក្ខវិហារនោះឯងមិនមែនជាតថាគតវិហារនោះទេ ។ ម្នាលអាវុសោមហានាម សេក្ខវិហារដោយឡែក តថាគតវិហារដោយឡែក ។

[៧១] ម្នាលអាវុសោ មហានាម ពួកភិក្ខុឯណា ជាសេក្ខៈមិនទាន់បានសម្រេចអរហត្តផលនៅឡើយ កាលបើប្រាថ្នានូវព្រះនិព្វានជាទីក្សេមចាកយោគៈដ៏ប្រសើរ ភិក្ខុទាំងនោះលះបង់នូវនីវរណៈទាំង ៥ ចេញ ។

កតមេ បញ្ច ។ កាមច្ឆន្ទនីវរណំ បហាយ វិហរន្តិ ព្យាបាទនីវរណំ ។ បេ ។ ថីនមិទ្ធនីវរណំ ឧទ្ធច្ចកុក្កុច្ចនីវរណំ វិចិកិច្ឆានីវរណំ បហាយ វិហរន្តិ ។ យេ តេ អាវុសោ មហានាម ភិក្ខូ សេក្ខា អប្បត្តមានសា អនុត្តរំ យោគក្ខេមំ បត្ថយមានា វិហរន្តិ តេ ឥមេ បញ្ច នីវរណេ បហាយ វិហរន្តិ ។

(៧២) យេ ច ខោ តេ អាវុសោ មហានាម ភិក្ខូ អរហន្តោ ខីណាសវា វុសិតវន្តោ កតករណីយា ឱហិតភារា អនុប្បត្តសទត្ថា បរិក្ខីណភវសំយោជនា សម្មទញ្ញា វិមុត្តា តេសំ បញ្ច នីវរណា បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា (១) អាយតឹ អនុប្បាទធម្មា ។ កតមេ បញ្ច ។ កាមច្ឆន្ទនីវរណំ បហីនំ ឧច្ឆិន្នមូលំ តាលាវត្ថុកតំ អនភាវង្កតំ អាយតឹ អនុប្បាទធម្មំ ព្យាបាទនីវរណំ បហីនំ ។ បេ ។

---

១ អនភាវង្គតា តិប្បត្តិ ។

នីវរណៈ ៥ តើដូចម្តេច ។ គឺភិក្ខុទាំងនោះលះបង់កាមច្ឆន្ទនីវរណៈ ១ ព្យាបាទនីវរណៈ ១ ។បេ។ ថីនមិទ្ធនីវរណៈ ១ ឧទ្ធច្ចកុក្កុច្ចនីវរណៈ ១ លះបង់វិចិកិច្ឆានីវរណៈ ១ ។ ម្នាលអាវុសោ មហានាម ពួកភិក្ខុឯណា ជាសេក្ខៈមិនទាន់បានសម្រេចអរហត្តផលនៅឡើយ កាលបើប្រាថ្នានូវព្រះនិព្វានជាទីក្សេមចាកយោគៈដ៏ប្រសើរ ភិក្ខុទាំងនោះរមែងលះបង់នូវនីវរណៈទាំង ៥ នេះឯង ។

(៧២) ម្នាលអាវុសោ មហានាម ពួកភិក្ខុឯណា ជាអរហន្ត មានអាសវៈអស់ហើយ មានព្រហ្មចរិយៈនៅរួចហើយ មានសោឡសកិច្ចធ្វើស្រេចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនបានសម្រេចហើយ មានកិលេសជាគ្រឿងប្រកបក្នុងភពអស់រលីងហើយ មានចិត្តផុតស្រឡះហើយ ព្រោះដឹងច្បាស់ដោយប្រពៃ ភិក្ខុទាំងនោះ បានលះបង់នីវរណៈ៥ ហើយបានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាពជាសភាវៈមិនកើតឡើងតទៅទៀតឡើយ ។ នីវរណៈ៥តើដូចម្តេច ។ គឺភិក្ខុទាំងនោះបានលះបង់កាមច្ឆន្ទនីវរណៈ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាពជាសភាវៈមិនកើតឡើងតទៅទៀតឡើយ បានលះបង់ព្យាបាទនីវរណៈ ។បេ។

## ទុតិយវគ្គោ ទុតិយោ

ថីនមិទ្ធនីវរណំ ឧទ្ធច្ចកុក្កុច្ចនីវរណំ វិចិកិច្ឆានីវរណំ បហីនំ ឧច្ឆិន្នមូលំ តាលាវត្ថុកតំ អនភាវង្កតំ អាយតឹ អនុប្បាទធម្មំ ។ យេ តេ អាវុសោ មហានាម ភិក្ខូ អរហន្តោ ខីណាសវា វុសិតវន្តោ កតករណីយា ឱហិតភារា អនុប្បត្តសទត្ថា បរិក្ខីណភវសញ្ញោជនា សម្មទញ្ញា វិមុត្តា តេសំ ឥមេ បញ្ច នីវរណា បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹ អនុប្បាទធម្មា ។

(៧៣) តទមិនាបេតំ អាវុសោ មហានាម បរិយាយេន វេទិតព្វំ យថា អញ្ញោ ច សេក្ខោ វិហារោ អញ្ញោ តថាគតវិហារោ ។

(៧៤) ឯកមិទំ អាវុសោ មហានាម សមយំ ភគវា ឥច្ឆានង្គលេ វិហរតិ ឥច្ឆានង្គលវនសណ្ឌេ ។ តត្រ ខោ អាវុសោ(១) ភគវា ភិក្ខូ អាមន្តេសិ

---

១ ឱ. ម. ឯត្ថន្តរេ មហានាម ឥតិ បទំ អត្ថិ ។

ឋីនមិទ្ធនីវរណៈ ឧទ្ធច្ចកុក្កុច្ចនីវរណៈ បានលះបង់វិចិកិច្ឆានីវរណៈហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅដូចជាទីនៅនៃដើមត្នោតធ្វើមិនឲ្យមានបែបភាព ជាសភាវៈមិនកើតឡើងតទៅទៀតឡើយ ។ ម្នាលអាវុសោ មហានាម ពួកភិក្ខុឯណាជាអរហន្តមានអាសវៈអស់ហើយ មានព្រហ្មចរិយៈនៅរួចហើយ មានសោឡសកិច្ចធ្វើស្រេចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនបានសម្រេចហើយ មានកិលេសជាគ្រឿងប្រកបក្នុងភពអស់រលីងហើយ មានចិត្តផុតស្រឡះហើយ ព្រោះដឹងច្បាស់ដោយប្រពៃ ភិក្ខុទាំងនោះបានលះបង់នីវរណៈទាំង ៥ នេះ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាពជាសភាវៈមិនកើតឡើងតទៅទៀតឡើយ ។

[៧៣] ម្នាលអាវុសោ មហានាម អ្នកគប្បីដឹងនូវសេចក្តីនោះដោយបរិយាយនេះចុះ តាមទំនងថា សេក្ខវិហារដោយឡែក តថាគតវិហារដោយឡែក ។

[៧៤] ម្នាលអាវុសោ មហានាម សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងដងព្រៃឥច្ឆានង្គល ជិតដែនឥច្ឆានង្គល ។ ម្នាលអាវុសោ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយមកថា

ឥច្ឆាមហំ ភិក្ខវេ តេមាសំ បដិសល្លីយិតុំ នម្ហិ កេនចិ ឧបសង្កមិតព្វោ អញ្ញត្រ ឯកេន បិណ្ឌបាតនីហារកេនាតិ ។ ឯវំ ភន្តេតិ អាវុសោ តេ ភិក្ខូ ភគវតោ បដិស្សុត្វា នាស្សុធ កោចិ ភគវន្តំ ឧបសង្កមតិ អញ្ញត្រ ឯកេន បិណ្ឌបាតនីហារកេន ។

(៧៥) អថខោ អាវុសោ ភគវា តស្ស តេមាសស្ស អច្ចយេន បដិសល្លានា វុដ្ឋិតោ ភិក្ខូ អាមន្តេសិ សចេ វោ ភិក្ខវេ អញ្ញតិត្ថិយា បរិព្វាជកា ឯវំ បុច្ឆេយ្យុំ កតមេនាវុសោ វិហារេន សមណោ គោតមោ វស្សាវាសំ ពហុលំ វិហាសីតិ ។ ឯវំ បុដ្ឋា តុម្ហេ ភិក្ខវេ តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ ឯវំ ព្យាករេយ្យាថ អានាបានស្សតិសមាធិនា ខោ អាវុសោ ភគវា វស្សាវាសំ ពហុលំ វិហាសីតិ ។

(៧៦) ឥធាហំ ភិក្ខវេ សតោ អស្សសាមិ សតោ បស្សសាមិ ទីឃំ វា អស្សសន្តោ ទីឃំ អស្សសាមីតិ បជានាមិ ទីឃំ វា បស្សសន្តោ

ម្នាលភិក្ខុទាំងឡាយ តថាគតប្រាថ្នាដើម្បីសម្ងំនៅក្នុងទីស្ងាត់អស់ ៣ ខែ កុំឲ្យភិក្ខុណាមួយចូលមករកតថាគតឡើយ វៀរលែងតែភិក្ខុ ១ រូបអ្នកនាំទៅនូវបិណ្ឌបាត ៗ ម្នាលអាវុសោ ភិក្ខុទាំងនោះក៏ទទួលស្តាប់ព្រះពុទ្ធដីកា ព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ឥតមានភិក្ខុណាមួយហ៊ានចូលទៅគាល់ព្រះដ៏មានព្រះភាគក្នុងទីនោះទេ វៀរលែងតែភិក្ខុ ១ រូបអ្នកនាំទៅនូវបិណ្ឌបាត ៗ

[៧៥] ម្នាលអាវុសោ លុះកន្លង ៣ ខែនោះទៅ ទើបព្រះដ៏មានព្រះភាគ ទ្រង់ចេញចាកទីសម្ងំហើយ ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើពួកបរិញ្វាជកជាអន្យតិរ្ថិយសួរអ្នកទាំងឡាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ព្រះសមណគោតមគង់ចាំវស្សាច្រើនដោយវិហារធម៌ដូចម្តេច ៗ ម្នាលភិក្ខុទាំងឡាយ កាលបើពួកបរិញ្វាជកជាអន្យតិរ្ថិយសួរយ៉ាងនេះហើយ អ្នកទាំងឡាយគប្បីដោះស្រាយចំពោះពួកបរិញ្វាជកជាអន្យតិរ្ថិយទាំងនោះយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ព្រះដ៏មានព្រះភាគទ្រង់គង់ចាំវស្សាច្រើនដោយអានាបានស្សតិសមាធិ ៗ

[៧៦] ម្នាលភិក្ខុទាំងឡាយ ក្នុងទីនេះ តថាគតមានស្មារតីចាំដាក់ដកដង្ហើមចេញ មានស្មារតីចាំដាក់ដកដង្ហើមចូល កាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញវែង កាលដកដង្ហើមចូលវែង

## ទុតិយវគ្គោ ទុតិយោ

ឥឃំ បស្សសាមីតិ បជានាមិ ( វិត្ថារេតព្វំ ) ។ បដិនិស្សគ្គានុបស្សី អស្សសិស្សាមីតិ បជានាមិ បដិនិស្សគ្គានុបស្សី បស្សសិស្សាមីតិ បជានាមិ ។

( ៧៧ ) យញ្ហិ តំ ភិក្ខវេ សម្មា វទមានោ វទេយ្យ អរិយវិហារោ ឥតិបិ ព្រហ្មវិហារោ ឥតិបិ តថាគតវិហារោ ឥតិបិ អានាបានស្សតិសមាធិ សម្មា វទមានោ វទេយ្យ អរិយវិហារោ ឥតិបិ ព្រហ្មវិហារោ ឥតិបិ តថាគតវិហារោ ឥតិបិ ។ យេ តេ ភិក្ខវេ ភិក្ខូ សេក្ខា អប្បត្តមានសា អនុត្តរំ យោគក្ខេមំ បត្ថយមានា វិហរន្តិ តេសំ អានាបានស្សតិសមាធិ ភាវិតោ ពហុលីកតោ អាសវានំ ខយាយ សំវត្តតិ ។

( ៧៨ ) យេ ច ខោ តេ ភិក្ខវេ ភិក្ខូ អរហន្តោ ខីណាសវា វុសិតវន្តោ កតករណីយា ឱហិតភារា អនុប្បត្តសទត្ថា បរិក្ខីណភវសំយោជនា

## ទុតិយវគ្គ ទី ២

ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលវែង (បណ្ឌិតគប្បីសំដែងឲ្យពិស្តារផងចុះ) ។ តថាគតដឹងច្បាស់ថា អាត្មាអញទឹងជាអ្នកពិចារណាឃើញនូវធម៌ជាគ្រឿងលះបោលនូវកិលេស ទើបដកដង្ហើមចេញ ដឹងច្បាស់ថា អាត្មាអញទឹងជាអ្នកពិចារណាឃើញនូវធម៌ជាគ្រឿងលះបោលនូវកិលេស ទើបដកដង្ហើមចូល ។

(៧៧) ម្នាលភិក្ខុទាងឡាយ បុគ្គលកាលបើពោលឲ្យត្រូវគប្បីពោលនូវធម៌ឯណាថា អរិយវិហារដូច្នេះក្ដី ថា ព្រហ្មវិហារដូច្នេះក្ដី ថា តថាគតវិហារដូច្នេះក្ដី បុគ្គលកាលបើពោលឲ្យត្រូវគប្បីពោលនូវអានា-បានស្សតិសមាធិចុះថា អរិយវិហារដូច្នេះក៏បាន ថា ព្រហ្មវិហារដូច្នេះក៏បាន ថា តថាគតវិហារដូច្នេះក៏បាន ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុឯណាជាសេក្ខៈ មិនទាន់បានសម្រេចអរហត្តផលនៅឡើយ កាលបើប្រាថ្នានូវព្រះនិព្វានជាទីក្សេមចាកយោគៈដ៏ប្រសើរ អានាបានស្សតិសមាធិដែលភិក្ខុទាំងនោះបានចំរើន បានធ្វើឲ្យរឿយ ៗ រមែងប្រព្រឹត្តទៅដើម្បីអស់ទៅនៃអាសវៈទាំងឡាយបាន ។

(៧៨) ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុឯណា ជាអរហន្តមានអាសវៈអស់ហើយ មានព្រហ្មចរិយធម៌នៅរួចហើយ មានសោឡសកិច្ចបានធ្វើស្រេចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនបានសម្រេចហើយ មានកិលេសជាគ្រឿងប្រកបក្នុងភពអស់រលីងហើយ

សម្មទញ្ញា វិមុត្តា តេសំ អានាបានស្សតិសមាធិ ភាវិតោ ពហុលីកតោ ទិដ្ឋេវ ធម្មេ សុខវិហារាយ ចេវ សំវត្តតិ សតិសម្បជញ្ញាយ ច ។

(៧៩) យញ្ហិ តំ ភិក្ខវេ សម្មា វទមានោ វទេយ្យ អរិយវិហារោ ឥតិបិ ព្រហ្មវិហារោ ឥតិបិ តថាគតវិហារោ ឥតិបិ អានាបានស្សតិសមាធឹ សម្មា វទមានោ វទេយ្យ អរិយវិហារោ ឥតិបិ ព្រហ្មវិហារោ ឥតិបិ តថាគតវិហារោ ឥតិបីតិ ។

(៨០) ឥមិនា ខោ ឯតំ អាវុសោ មហានាម បរិយាយេន វេទិតព្វំ យថា អញ្ញោ ច សេក្ខវិហារោ អញ្ញោ តថាគតវិហារោតិ ។

(៨១) សាវត្ថិយំ ។ អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច អត្ថិ នុ ខោ ភន្តេ ឯកធម្មោ ភាវិតោ ពហុលីកតោ ចត្តារោ ធម្មេ បរិបូរេតិ

មានចិត្តផុតស្រឡះហើយ ព្រោះដឹងច្បាស់ដោយប្រពៃ ភិក្ខុទាំងនោះ បានចំរើនបានធ្វើឲ្យរឿយ ៗ នូវអានាបានស្សតិសមាធិហើយ រមែងប្រព្រឹត្តទៅដើម្បីនៅជាសុខក្នុងបច្ចុប្បន្នផង ដើម្បីសេចក្ដីរលឹកនឹងសេចក្ដីដឹងច្បាស់ផង ។

(៧៩) ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលបើពោលឲ្យត្រូវគប្បីពោលនូវធម៌ឯណាថា អរិយវិហារដូច្នេះក្ដី ថា ព្រហ្មវិហារដូច្នេះក្ដី ថា តថាគតវិហារដូច្នេះក្ដី បុគ្គលកាលបើពោលឲ្យត្រូវគប្បី ពោលនូវអានាបានស្សតិសមាធិចុះថា អរិយវិហារដូច្នេះក៏បាន ថា ព្រហ្មវិហារដូច្នេះក៏បាន ថា តថាគតវិហារដូច្នេះក៏បាន ។

(៨០) ម្នាលអាវុសោ មហានាម អ្នកគប្បីដឹងនូវសេចក្ដីនុ៎ះ ដោយបរិយាយនេះចុះ តាមទំនងថា សេក្ខវិហារដោយឡែក តថាគតវិហារដោយឡែក ។

(៨១) ទៀបក្រុងសាវត្ថី ។ គ្រានោះព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំ ព្រះដ៏មានព្រះភាគហើយ អង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ធម៌ ១ ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយ ៗ ហើយ រមែងញុំាងធម៌ ៤ ឲ្យពេញ

## ទុតិយវគ្គោ ទុតិយោ

ចត្តារោ ធម្មា ភាវិតា ពហុលីកតា សត្ត ធម្មេ បរិបូរេន្តិ សត្ត ធម្មា ភាវិតា ពហុលីកតា ទ្វេ ធម្មេ បរិបូរេន្តីតិ ។ អត្ថិ ខោ អានន្ទ ឯកធម្មោ ភាវិតោ ពហុលីកតោ ចត្តារោ ធម្មេ បរិបូរេតិ ចត្តារោ ធម្មា ភាវិតា ពហុលីកតា សត្ត ធម្មេ បរិបូរេន្តិ សត្ត ធម្មា ភាវិតា ពហុលីកតា ទ្វេ ធម្មេ បរិបូរេន្តីតិ ។

(៨២) កតមោ បន ភន្តេ ឯកធម្មោ ភាវិតោ ពហុលីកតោ ចត្តារោ ធម្មេ បរិបូរេតិ ចត្តារោ ធម្មា ភាវិតា ពហុលីកតា សត្ត ធម្មេ បរិបូរេន្តិ សត្ត ធម្មា ភាវិតា ពហុលីកតា ទ្វេ ធម្មេ បរិបូរេន្តីតិ ។ អានាបានស្សតិសមាធិ ខោ អានន្ទ ឯកធម្មោ ភាវិតោ ពហុលីកតោ ចត្តារោ សតិបដ្ឋានេ បរិបូរេតិ ចត្តារោ សតិបដ្ឋានា ភាវិតា ពហុលីកតា សត្ត ពោជ្ឈង្គេ បរិបូរេន្តិ សត្ត ពោជ្ឈង្គា ភាវិតា ពហុលីកតា វិជ្ជាវិមុត្តឹ បរិបូរេន្តិ ។

## ទុតិយវគ្គ ទី ២

ធម៌ ៤ ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយ ៗ ហើយរមែងញុំាងធម៌ ៧ ឲ្យពេញ ធម៌ ៧ ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយ ៗ ហើយ រមែងញុំាងធម៌ ២ ឲ្យពេញបានដែរ ៗ ម្នាលអានន្ទ ធម៌ ១ ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយ ៗ ហើយ រមែងញុំាងធម៌ ៤ ឲ្យពេញ ធម៌ ៤ ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយ ៗ ហើយ រមែងញុំាងធម៌ ៧ ឲ្យពេញ ធម៌ ៧ ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយ ៗ ហើយ រមែងញុំាងធម៌ ២ ឲ្យពេញបានដែរ ៗ

(៨២) បពិត្រព្រះអង្គដ៏ចំរើន ចុះធម៌១ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយៗហើយ រមែងញុំាងធម៌៤ឲ្យពេញ ធម៌៤ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយៗហើយ រមែងញុំាងធម៌៧ឲ្យពេញ ធម៌៧ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយៗហើយ រមែងញុំាងធម៌២ឲ្យពេញបានតើដូចម្តេច ៗ ម្នាលអានន្ទ ធម៌១គឺអានាបានស្សតិសមាធិ ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយៗហើយ រមែងញុំាងសតិប្បដ្ឋាន៤ឲ្យពេញ សតិប្បដ្ឋាន៤ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយៗហើយ រមែងញុំាងពោជ្ឈង្គ៧ ឲ្យពេញ ពោជ្ឈង្គ៧ ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយៗហើយ រមែងញុំាងវិជ្ជានឹងវិមុត្តិឲ្យពេញបាន ៗ

(៨៣) កថំ ភាវិតោ ច អានន្ទ អានាបានស្សតិសមាធិ កថំ ពហុលីកតោ ចត្តារោ សតិបដ្ឋានេ បរិបូរេតិ ។ ឥធានន្ទ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា និសីទតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា ។ សោ សតោ វ អស្សសតិ សតោ បស្សសតិ ទីឃំ វា អស្សសន្តោ ទីឃំ អស្សសាមីតិ បជានាតិ ទីឃំ វា បស្សសន្តោ ទីឃំ បស្សសាមីតិ បជានាតិ (វិត្ថារេតព្វំ) បដិនិស្សគ្គានុបស្សី អស្សសិស្សាមីតិ សិក្ខតិ ។ បដិនិស្សគ្គានុបស្សី បស្សសិស្សាមីតិ សិក្ខតិ ។ យស្មឹ សមយេ អានន្ទ ភិក្ខុ ទីឃំ វា អស្សសន្តោ ទីឃំ អស្សសាមីតិ បជានាតិ ទីឃំ វា បស្សសន្តោ ទីឃំ បស្សសាមីតិ បជានាតិ ។ រស្សំ វា ។បេ។ បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ បស្សម្ភយំ កាយសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ ។ កាយេ កាយានុបស្សី អានន្ទ ភិក្ខុ តស្មឹ សមយេ វិហរតិ

(៨៣) ម្នាលអានន្ទ ចុះអានាបានស្សតិសមាធិ ដែលបុគ្គលបានចំរើនដូចម្តេច ធ្វើឲ្យច្រើនដូចម្តេច រមែងញ៉ាំងសតិប្បដ្ឋាន ៤ ឲ្យពេញបាន ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ នៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី អង្គុយពែនភ្នែនតម្រង់កាយឲ្យត្រង់ ប្រុងស្មារតីឆ្ពោះទៅរកកម្មដ្ឋាន ។ ភិក្ខុនោះមានស្មារតីចាំជាក់ ដកដង្ហើមចេញ មានស្មារតីចាំជាក់ ដកដង្ហើមចូល កាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញវែង កាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលវែង (បណ្ឌិតគប្បីឲ្យពិស្តារផងចុះ) ។ ភិក្ខុនោះសិក្សាថា អាត្មាអញនឹងជាអ្នកពិចារណាឃើញនូវធម៌ជាគ្រឿងលះបោលនូវកិលេស ដកដង្ហើមចេញ សិក្សាថា អាត្មាអញនឹងជាអ្នកពិចារណាឃើញនូវធម៌ជាគ្រឿងលះបោលនូវកិលេស ដកដង្ហើមចូល ។ ម្នាលអានន្ទ សម័យណា ភិក្ខុកាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញវែង កាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលវែង ។ កាលដកដង្ហើមចេញខ្លី ។បេ។ ភិក្ខុសិក្សាថា អាត្មាអញនឹងរម្ងាប់នូវកាយសង្ខារគឺដកដង្ហើមចេញ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញនឹងរម្ងាប់នូវកាយសង្ខារ គឺដកដង្ហើមចូល ទើបដកដង្ហើមចូល ។ ម្នាលអានន្ទ សម័យនោះ ភិក្ខុឈ្មោះថា ពិចារណាឃើញនូវកាយក្នុងកាយ

## ទុតិយវគ្គោ ទុតិយោ

អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ តំ កិស្ស ហេតុ ។ កាយញ្ញតរាហំ អានន្ទ ឯតំ វទាមិ យទិទំ អស្សាសបស្សាសំ ។ តស្មាតិហានន្ទ កាយេ កាយានុបស្សី ភិក្ខុ តស្មឹ សមយេ វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។

(៨៤) យស្មឹ សមយេ អានន្ទ ភិក្ខុ បីតិប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ ។ សុខប្បដិសំវេទី ។ ចិត្តសង្ខារប្បដិសំវេទី ។ បស្សម្ភយំ ចិត្តសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ បស្សម្ភយំ ចិត្តសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ ។ វេទនាសុ វេទនានុបស្សី អានន្ទ ភិក្ខុ តស្មឹ សមយេ វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ តំ កិស្ស ហេតុ ។ វេទនាញ្ញតរាហំ អានន្ទ ឯតំ វទាមិ យទិទំ

## ទុតិយវគ្គ ទី២

មានព្យាយាមជាគ្រឿងដុតកំដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កំចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ សេចក្តីនោះព្រោះហេតុអ្វី ។ ម្នាលអានន្ទ (ព្រោះ)តថាគតពោលនូវកាយ(១)ណាមួយនុ៎ះ ថាបានដល់ខ្យល់ដកដង្ហើមចេញ និងដកដង្ហើមចូលៗ ម្នាលអានន្ទ ព្រោះហេតុនោះ បានជាសម័យនោះ ឈ្មោះថា ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កំចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។

(៨៤) ម្នាលអានន្ទ សម័យឯណា ភិក្ខុសិក្សាថា អាត្មាអញនឹងជាអ្នកដឹងច្បាស់នូវបីតិ ដកដង្ហើមចេញ ។ ដឹងច្បាស់នូវសុខ ។ ដឹងច្បាស់នូវចិត្តសង្ខារ ។ ភិក្ខុសិក្សាថា អាត្មាអញនឹងរម្ងាប់នូវចិត្តសង្ខារ ដកដង្ហើមចេញ សិក្សាថា អាត្មាអញនឹងរម្ងាប់នូវចិត្តសង្ខារ ដកដង្ហើមចូល ។ ម្នាលអានន្ទ សម័យនោះ ឈ្មោះថា ភិក្ខុពិចារណាឃើញនូវវេទនាក្នុងវេទនា មានព្យាយាមជាគ្រឿងដុតកំដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កំចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ សេចក្តីនោះព្រោះហេតុអ្វី ។ ម្នាលអានន្ទ (ព្រោះ)តថាគតពោលនូវវេទនាណាមួយនុ៎ះ

---

១- កាយ ៤ យ៉ាងគឺ បឋវីកាយ ១ អាបោកាយ ១ តេជោកាយ ១ វាយោកាយ ១ ក្នុងទីនេះ សំដៅយកវាយោកាយ (អដ្ឋកថា) ។

អស្សាសបស្សាសានំ សាធុកំ មនសិការា ។ តស្មាតិហានន្ទ វេទនាសុ វេទនានុបស្សី ភិក្ខុ តស្មឹ សមយេ វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។

(៨៤) យស្មឹ សមយេ អានន្ទ ភិក្ខុ ចិត្តប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ ចិត្តប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ ។ អភិប្បមោទយំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ ។ សមាទហំ ចិត្តំ ។ វិមោចយំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ វិមោចយំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ ។ ចិត្តេ ចិត្តានុបស្សី អានន្ទ ភិក្ខុ តស្មឹ សមយេ វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ តំ កិស្ស ហេតុ ។ នាហំ អានន្ទ មុដ្ឋស្សតិស្ស អសម្បជានស្ស អានាបានស្សតិសមាធិភាវនំ វទាមិ ។

ជាបានដល់ការយកចិត្តទុកដាក់ដោយប្រពៃ នូវខ្យល់ដកដង្ហើមចេញ និងខ្យល់ដកដង្ហើមចូល ។ ម្នាលអានន្ទ ព្រោះហេតុនោះ បានជា សម័យនោះ ឈ្មោះថា ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវវេទនា ក្នុងវេទនា មានព្យាយាមជាគ្រឿងដុតកំដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កំចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។

(៨៩) ម្នាលអានន្ទ សម័យឯណា ភិក្ខុសិក្សាថា អាត្មាអញនឹងជាអ្នកដឹងច្បាស់នូវចិត្ត ដកដង្ហើមចេញ សិក្សាថា អាត្មាអញនឹងជាអ្នកដឹងច្បាស់នូវចិត្ត ដកដង្ហើមចូល ។ សិក្សាថា អាត្មាអញនឹងធ្វើចិត្តឲ្យរីករាយ ដកដង្ហើមចេញ ។ នឹងដំកល់ចិត្តឲ្យស្មើក្នុងអារម្មណ៍ ។ សិក្សាថា អាត្មាអញនឹងដោះចិត្តឲ្យរួចស្រឡះ (ចាកនីវរណធម៌ជាដើម) ដកដង្ហើមចេញ សិក្សាថា អាត្មាអញនឹងដោះចិត្តឲ្យរួចស្រឡះ (ចាកនីវរណធម៌ជាដើម) ដកដង្ហើមចូល។ ម្នាលអានន្ទ សម័យនោះ ឈ្មោះថា ភិក្ខុពិចារណាឃើញនូវចិត្តក្នុងចិត្ត មានព្យាយាមជាគ្រឿងដុតកំដៅកិលេស ជាអ្នកដឹងខ្លួនមានស្មារតី កំចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក។ សេចក្តីនោះព្រោះហេតុអ្វី ។ ម្នាលអានន្ទ (ព្រោះ) តថាគតមិនពោលចំពោះការចំរើននូវអានាបានស្សតិសមាធិ របស់បុគ្គលអ្នកភ្លេចស្មារតី មិនដឹងខ្លួនទេ

## ទុតិយវគ្គោ ទុតិយោ

តស្មាតិហានន្ទ ចិត្តេ ចិត្តានុបស្សី ភិក្ខុ តស្មឹ សមយេ វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។

(៨៦) យស្មឹ សមយេ អានន្ទ ភិក្ខុ អនិច្ចានុបស្សី ។ បេ ។ វិរាគានុបស្សី ។ និរោធានុបស្សី ។ បដិនិស្សគ្គានុបស្សី អស្សសិស្សាមីតិ សិក្ខតិ បដិនិស្សគ្គានុបស្សី បស្សសិស្សាមីតិ សិក្ខតិ ។ ធម្មេសុ ធម្មានុបស្សី អានន្ទ ភិក្ខុ តស្មឹ សមយេ វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ សោ យន្តំ ហោតិ អភិជ្ឈាទោមនស្សានំ បហានំ តំ បញ្ញាយ ទិស្វា សាធុកំ អជ្ឈុបេក្ខិតា ហោតិ ។ តស្មាតិហានន្ទ ធម្មេសុ ធម្មានុបស្សី ភិក្ខុ តស្មឹ សមយេ វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។

## ទុតិយវគ្គ ទី ២

ម្នាលអានន្ទ ព្រោះហេតុនោះ បានជាសម័យនោះ ឈ្មោះ ថាភិក្ខុក្នុងសាសនានេះ បានពិចារណាឃើញនូវចិត្តក្នុងចិត្ត មានព្យាយាមជាគ្រឿងដុតកំដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កំចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។

(៨៦) ម្នាលអានន្ទ សម័យឯណា ភិក្ខុពិចារណាឃើញនូវសេចក្ដីមិនទៀង ។ បេ ។ ពិចារណាឃើញនូវធម៌ជាគ្រឿងប្រាសចាកតម្រេក ។ ពិចារណាឃើញនូវសេចក្ដីរលត់ ។ ភិក្ខុសិក្សាថា អាត្មាអញ នឹងជាអ្នកពិចារណាឃើញនូវធម៌ជាគ្រឿងលះបង់នូវកិលេស ដកដង្ហើមចេញ សិក្សាថា អាត្មាអញនឹងជាអ្នកពិចារណាឃើញនូវធម៌ជាគ្រឿងលះបង់នូវកិលេស ដកដង្ហើមចូល ។ ម្នាលអានន្ទ សម័យនោះ ឈ្មោះថា ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កំចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ភិក្ខុនោះជាអ្នកសំឡឹងដោយប្រពៃ ព្រោះបានឃើញនូវការលះបង់នូវអភិជ្ឈានិងទោមនស្សនោះដោយបញ្ញា ។ ម្នាលអានន្ទ ព្រោះហេតុនេះបានជាសម័យនោះ ឈ្មោះថា ភិក្ខុក្នុងសាសនានេះ បានពិចារណាឃើញនូវធម៌ក្នុងធម៌ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កំចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។

(៨៧) ឯវំ ភាវិតោ ខោ អានន្ទ អានាបានស្សតិសមាធិ ឯវំ ពហុលីកតោ ចត្តារោ សតិប្បដ្ឋានេ បរិបូរេតិ ។

(៨៨) កថំ ភាវិតា ចានន្ទ ចត្តារោ សតិប្បដ្ឋានា កថំ ពហុលីកតា សត្ត ពោជ្ឈង្គេ បរិបូរេន្តិ ។ យស្មឹ សមយេ អានន្ទ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ឧបដ្ឋិតស្ស តស្មឹ សមយេ សតិ ហោតិ អសម្មុដ្ឋា ។ យស្មឹ សមយេ អានន្ទ ភិក្ខុនោ ឧបដ្ឋិតា សតិ ហោតិ អសម្មុដ្ឋា សតិសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ សតិសម្ពោជ្ឈង្គំ តស្មឹ សមយេ ភិក្ខុ ភាវេតិ សតិសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ ភាវនាបារិបូរឹ គច្ឆតិ ។ សោ តថា សតោ វិហរន្តោ តំ ធម្មំ បញ្ញាយ បវិចិនតិ បវិចរតិ បរិវីមំសមាបជ្ជតិ ។

(៨៩) យស្មឹ សមយេ អានន្ទ ភិក្ខុ តថា សតោ វិហរន្តោ តំ ធម្មំ បញ្ញាយ បវិចិនតិ បវិចរតិ បរិវីមំសមាបជ្ជតិ ធម្មវិចយសម្ពោជ្ឈង្គោ

(៨៧) ម្នាលអានន្ទ អានាបានស្សតិសមាធិ ដែលបុគ្គលបានចំរើនយ៉ាងនេះ បានធ្វើឲ្យរឿយ ៗ យ៉ាងនេះហើយ រមែងញុំាងសតិប្បដ្ឋាន ៤ ឲ្យពេញបាន ។

(៨៨) ម្នាលអានន្ទ ចុះសតិប្បដ្ឋាន ៤ ដែលបុគ្គលបានចំរើនដូចម្តេច បានធ្វើឲ្យរឿយ ៗ ដូចម្តេច ទើបញុំាងពោជ្ឈង្គទាំង ៧ ឲ្យពេញបាន ។ ម្នាលអានន្ទ សម័យឯណា ភិក្ខុបានពិចារណាឃើញរឿយ ៗ នូវកាយក្នុងកាយ សម័យនោះ ឈ្មោះថា ភិក្ខុមានស្មារតីតាំងទៅខ្ជាប់ មិនភ្លាំងភ្លេច ។ ម្នាលអានន្ទ សម័យឯណា ភិក្ខុមានស្មារតីតាំងទៅខ្ជាប់ មិនភ្លាំងភ្លេច សម័យនោះ សតិសម្ពោជ្ឈង្គ (អង្គនៃប្រាជ្ញាជាគ្រឿងត្រាស់ដឹងគឺស្មារតី) ឈ្មោះថា ភិក្ខុបានប្រារព្ធហើយ សម័យនោះឈ្មោះថា ភិក្ខុចំរើននូវសតិសម្ពោជ្ឈង្គ សម័យនោះ ឈ្មោះថា សតិ-សម្ពោជ្ឈង្គបានដល់នូវការពេញ ដោយការចំរើនរបស់ភិក្ខុ ។ កាលបើភិក្ខុនោះ មានស្មារតីដូច្នោះ ក៏ស្រាវជ្រាវរកពិចារណានូវធម៌នោះដោយបញ្ញា ។

(៨៩) ម្នាលអានន្ទ សម័យឯណា ភិក្ខុមានស្មារតីដូច្នោះបាន ស្រាវជ្រាវរកពិចារណានូវធម៌នោះដោយបញ្ញា សម័យនោះ ធម្ម-វិចយសម្ពោជ្ឈង្គ (អង្គនៃប្រាជ្ញាជាគ្រឿងត្រាស់ដឹងគឺសេចក្តីត្រិះរិះធម៌)

## ទុតិយវគ្គោ ទុតិយោ

តស្មឹ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ ធម្មវិចយ-
សម្ពោជ្ឈង្គំ តស្មឹ សមយេ ភិក្ខុ ភាវេតិ ធម្មវិចយ-
សម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ ភាវនាបារិបូរឹ
គច្ឆតិ ។ តស្ស តំ ធម្មំ បញ្ញាយ បវិចិនតោ
បវិចរតោ បរីមំសមាបជ្ជតោ អារទ្ធំ ហោតិ វីរិយំ
អសល្លីនំ ។

( ៩០ ) យស្មឹ សមយេ អានន្ទ ភិក្ខុនោ តំ
ធម្មំ បញ្ញាយ បវិចិនតោ បវិចរតោ បរីមំសមាបជ្ជ-
តោ អារទ្ធំ ហោតិ វីរិយំ អសល្លីនំ វីរិយសម្ពោ-
ជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ
វីរិយសម្ពោជ្ឈង្គំ តស្មឹ សមយេ ភិក្ខុ ភាវេតិ
វីរិយសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ ភាវនា-
បារិបូរឹ គច្ឆតិ ។ អារទ្ធវីរិយស្ស ឧប្បជ្ជតិ បីតិ
និរាមិសា ។

( ៩១ ) យស្មឹ សមយេ អានន្ទ ភិក្ខុនោ អារទ្ធ-
វីរិយស្ស ឧប្បជ្ជតិ បីតិ និរាមិសា បីតិសម្ពោជ្ឈង្គោ
តស្មឹ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ

ឈ្មោះថា ភិក្ខុបានប្រារព្ធហើយ សម័យនោះ ឈ្មោះថា ភិក្ខុចំរើន នូវធម្មវិចយសម្ពោជ្ឈង្គ សម័យនោះ ឈ្មោះថា ធម្មវិចយសម្ពោជ្ឈង្គ បានដល់នូវការពេញដោយការចំរើនរបស់ភិក្ខុ ។ កាលបើភិក្ខុនោះ ស្រាវជ្រាវរកពិចារណានូវធម៌នោះដោយបញ្ញា សេចក្តីព្យាយាមមិនធូរថយ ឈ្មោះថា ភិក្ខុនោះបានប្រារព្ធហើយ ។

(៩០) ម្នាលអានន្ទ សម័យឯណា ដែលភិក្ខុស្រាវជ្រាវរកពិចារណានូវធម៌នោះដោយបញ្ញា សេចក្តីព្យាយាមមិនធូរថយ ឈ្មោះថា ភិក្ខុបានប្រារព្ធហើយ សម័យនោះ វីរិយសម្ពោជ្ឈង្គ (អង្គនៃប្រាជ្ញាជាគ្រឿងត្រាស់ដឹងគឺសេចក្តីព្យាយាម) ឈ្មោះថា ភិក្ខុនោះបានប្រារព្ធហើយ សម័យនោះ ឈ្មោះថា ភិក្ខុបានចំរើននូវវីរិយសម្ពោជ្ឈង្គ សម័យនោះ ឈ្មោះថា វីរិយសម្ពោជ្ឈង្គ ដល់នូវការពេញដោយការចំរើនរបស់ភិក្ខុ ។ កាលបើភិក្ខុមានសេចក្តីព្យាយាមប្រារព្ធហើយ បីតិប្រាសចាកអាមិសគឺកិលេសក៏កើតឡើង ។

(៩១) ម្នាលអានន្ទ សម័យឯណា ភិក្ខុមានសេចក្តីព្យាយាមប្រារព្ធហើយ បីតិប្រាសចាកអាមិសក៏កើតឡើង សម័យនោះ បីតិសម្ពោជ្ឈង្គ (អង្គនៃប្រាជ្ញាជាគ្រឿងត្រាស់ដឹងគឺបីតិ) ឈ្មោះថា ភិក្ខុបានប្រារព្ធហើយ

បីតិសម្ពោជ្ឈង្គំ តស្មឹ សមយេ ភិក្ខុ ភាវេតិ បីតិសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ ភាវនាបារិបូរឹ គច្ឆតិ ។ បីតិមនស្ស កាយោបិ បស្សម្ភតិ ចិត្តម្បិ បស្សម្ភតិ ។

(៩២) យស្មឹ សមយេ អានន្ទ ភិក្ខុនោ បីតិមនស្ស កាយោបិ បស្សម្ភតិ ចិត្តម្បិ បស្សម្ភតិ បស្សទ្ធិសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ បស្សទ្ធិសម្ពោជ្ឈង្គំ តស្មឹ សមយេ ភិក្ខុ ភាវេតិ បស្សទ្ធិសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ ភាវនាបារិបូរឹ គច្ឆតិ ។ បស្សទ្ធកាយស្ស សុខិនោ ចិត្តំ សមាធិយតិ ។

(៩៣) យស្មឹ សមយេ អានន្ទ ភិក្ខុនោ បស្សទ្ធកាយស្ស សុខិនោ ចិត្តំ សមាធិយតិ សមាធិសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ សមាធិសម្ពោជ្ឈង្គំ តស្មឹ សមយេ ភិក្ខុ ភាវេតិ សមាធិសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ ភាវនាបារិបូរឹ គច្ឆតិ ។ សោ តថា សមាហិតំ ចិត្តំ សាធុកំ អជ្ឈុបេក្ខិតា ហោតិ ។

សម័យនោះ ឈ្មោះថា ភិក្ខុបំរើននូវបីតិសម្ពោជ្ឈង្គ សម័យនោះ ឈ្មោះថា បីតិសម្ពោជ្ឈង្គ ដល់នូវការពេញដោយការចំរើនរបស់ភិក្ខុ ។ កាលបើភិក្ខុមានចិត្តត្រេកអរហើយ កាយក៏ស្ងប់ ចិត្តក៏ស្ងប់ ។

[៩២] ម្នាលអានន្ទ សម័យឯណា ភិក្ខុមានចិត្តប្រកបដោយបីតិ កាយក៏ស្ងប់ ចិត្តក៏ស្ងប់ សម័យនោះ បស្សទ្ធិសម្ពោជ្ឈង្គ (អង្គនៃប្រាជ្ញាជាគ្រឿងត្រាស់ដឹងគឺសេចក្តីស្ងប់) ឈ្មោះថា ភិក្ខុប្រារព្ធហើយ សម័យនោះ ឈ្មោះថា បស្សទ្ធិសម្ពោជ្ឈង្គដល់នូវការពេញដោយការចំរើនរបស់ភិក្ខុ ។ កាលបើភិក្ខុមានកាយស្ងប់ដល់នូវសេចក្តីសុខហើយ ចិត្តក៏ដម្កល់ខ្ជាប់ ។

[៩៣] ម្នាលអានន្ទ សម័យឯណា ភិក្ខុមានកាយស្ងប់ដល់នូវសេចក្តីសុខហើយ ចិត្តក៏ដម្កល់មាំ សម័យនោះ សមាធិសម្ពោជ្ឈង្គ (អង្គនៃប្រាជ្ញាជាគ្រឿងត្រាស់ដឹងគឺការដម្កល់ចិត្តមាំ) ឈ្មោះថា ភិក្ខុបានប្រារព្ធហើយ សម័យនោះ ឈ្មោះថា ភិក្ខុបំរើននូវសមាធិសម្ពោជ្ឈង្គ សម័យនោះ ឈ្មោះថា សមាធិសម្ពោជ្ឈង្គដល់នូវការពេញដោយការចំរើនរបស់ភិក្ខុ ។ ភិក្ខុនោះ ជាអ្នកសំឡឹង ដោយប្រពៃនូវចិត្តដែលដម្កល់មាំដូច្នោះ ។

## ទុតិយវគ្គោ ទុតិយោ

[៩៣] យស្មឹ សមយេ អានន្ទ ភិក្ខុ តថា សមាហិតំ ចិត្តំ សាធុកំ អជ្ឈុបេក្ខិតា ហោតិ ឧបេក្ខាសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ ឧបេក្ខាសម្ពោជ្ឈង្គំ តស្មឹ សមយេ ភិក្ខុ ភាវេតិ ឧបេក្ខាសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ ភាវនាបារិបូរឹ គច្ឆតិ ។

[៩៤] យស្មឹ សមយេ អានន្ទ ភិក្ខុ វេទនាសុ ចិត្តេ ធម្មេសុ ធម្មានុបស្សី វិហរតិ ឧបដ្ឋិតស្ស តស្មឹ សមយេ សតិ ហោតិ អសម្មុដ្ឋា ។

[៩៥] យស្មឹ សមយេ អានន្ទ ភិក្ខុនោ ឧបដ្ឋិតា សតិ ហោតិ អសម្មុដ្ឋា សតិសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ សតិសម្ពោជ្ឈង្គំ តស្មឹ សមយេ ភិក្ខុ ភាវេតិ សតិសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ ភាវនាបារិបូរឹ គច្ឆតិ ។ ( យថា បឋមំ សតិបដ្ឋានំ ឯវំ វិត្ថារេតព្វំ ) ។ សោ តថា សមាហិតំ ចិត្តំ សាធុកំ អជ្ឈុបេក្ខិតា ហោតិ ។

## ទុតិយវគ្គ ទី ២

[៩៤] ម្នាលអានន្ទ សម័យឯណា ភិក្ខុជាអ្នកសំឡឹងដោយប្រពៃនូវចិត្តដែលដម្កល់មាំដូច្នោះ សម័យនោះ ឧបេក្ខាសម្ពោជ្ឈង្គ (អង្គនៃប្រាជ្ញាជាគ្រឿងត្រាស់ដឹងគឺសេចក្តីព្រងើយកន្តើយ) ឈ្មោះថា ភិក្ខុបានប្រារព្ធហើយ សម័យនោះ ឈ្មោះថា ភិក្ខុចំរើននូវឧបេក្ខាសម្ពោជ្ឈង្គ សម័យនោះ ឈ្មោះថា ឧបេក្ខាសម្ពោជ្ឈង្គ ដល់នូវការពេញដោយការចំរើនរបស់ភិក្ខុ ។

[៩៥] ម្នាលអានន្ទ សម័យឯណា ភិក្ខុពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ នូវចិត្តក្នុងចិត្ត នូវធម៌ក្នុងធម៌ទាំងឡាយ សម័យនោះឈ្មោះថា ភិក្ខុមានស្មារតីដម្កល់មាំមិនបានភ្លាំងភ្លេចឡើយ ។

[៩៦] ម្នាលអានន្ទ សម័យឯណា ភិក្ខុមានស្មារតីដម្កល់មាំមិនភ្លាំងភ្លេច សម័យនោះ សតិសម្ពោជ្ឈង្គ ឈ្មោះថា ភិក្ខុបានប្រារព្ធហើយ សម័យនោះឈ្មោះថា ភិក្ខុចំរើននូវសតិសម្ពោជ្ឈង្គ សម័យនោះឈ្មោះថា សតិសម្ពោជ្ឈង្គ ដល់នូវការពេញដោយការចំរើនរបស់ភិក្ខុ ។ (សតិប្បដ្ឋានមុនយ៉ាងណាបណ្ឌិតគប្បីឲ្យពិស្តារយ៉ាងនោះផងចុះ) ។ ភិក្ខុនោះ ជាអ្នកសំឡឹង ដោយប្រពៃនូវចិត្តដែលដម្កល់មាំដូច្នោះ ។

[៩៧] យស្មឹ សមយេ អានន្ទ ភិក្ខុ តថា សមាហិតំ ចិត្តំ សាធុកំ អជ្ឈុបេក្ខិតា ហោតិ ឧបេក្ខាសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ ឧបេក្ខាសម្ពោជ្ឈង្គំ តស្មឹ សមយេ ភិក្ខុ ភាវេតិ ឧបេក្ខាសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ ភាវនាបារិបូរឹ គច្ឆតិ ។

[៩៨] ឯវំ ភាវិតា ខោ អានន្ទ ចត្តារោ សតិបដ្ឋានា ឯវំ ពហុលីកតា សត្ត ពោជ្ឈង្គេ បរិបូរេន្តិ ។

[៩៩] កថំ ភាវិតា ចានន្ទ សត្ត ពោជ្ឈង្គា កថំ ពហុលីកតា វិជ្ជាវិមុត្តឹ បរិបូរេន្តិ ។ ឥធានន្ទ ភិក្ខុ សតិសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ធម្មវិចយវីរិយបីតិបស្សទ្ធិសមាធិឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ឯវំ ភាវិតា ខោ អានន្ទ សត្ត ពោជ្ឈង្គា ឯវំ ពហុលីកតា វិជ្ជាវិមុត្តឹ បរិបូរេន្តីតិ ។

[៩៧] ម្នាលអានន្ទ សម័យឯណា ភិក្ខុជាអ្នកសំឡឹងដោយប្រពៃ ចំពោះចិត្តដែលផ្គល់មាំដូច្នោះ សម័យនោះ ឧបេក្ខាសម្ពោជ្ឈង្គ ឈ្មោះថា ភិក្ខុបានប្រារព្ធហើយ សម័យនោះ ឈ្មោះថា ភិក្ខុចំរើននូវឧបេក្ខាសម្ពោជ្ឈង្គ សម័យនោះ ឈ្មោះថា ឧបេក្ខាសម្ពោជ្ឈង្គ ដល់នូវការពេញដោយការចំរើនរបស់ភិក្ខុ ។

[៩៨] ម្នាលអានន្ទ សតិប្បដ្ឋាន ៤ ដែលបុគ្គលបានចំរើនយ៉ាងនេះ បានធ្វើឲ្យច្រើនៗ យ៉ាងនេះហើយ រមែងញ៉ាំងពោជ្ឈង្គទាំង ៧ ប្រការឲ្យពេញបាន ។

[៩៩] ម្នាលអានន្ទ ចុះពោជ្ឈង្គទាំង ៧ បុគ្គលចំរើនដូចម្តេច ធ្វើឲ្យច្រើនៗដូចម្តេច ទើបញ៉ាំងវិជ្ជានិងវិមុត្តិឲ្យពេញបាន ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ចំរើននូវសតិសម្ពោជ្ឈង្គ ដែលអាស្រ័យនូវសេចក្តីស្ងាត់ អាស្រ័យនូវការប្រាសចាកតម្រេក អាស្រ័យនូវសេចក្តីរលត់ បង្អោនទៅដើម្បីលះបង់នូវកិលេសៗ ចំរើននូវធម្មវិចយៈ វីរិយៈ បីតិ បស្សទ្ធិ សមាធិនិងឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យសេចក្តីស្ងាត់ អាស្រ័យការប្រាសចាកតម្រេក អាស្រ័យសេចក្តីរលត់ បង្អោនទៅដើម្បីលះបង់កិលេស ។ ម្នាលអានន្ទ ពោជ្ឈង្គទាំង ៧ ដែលបុគ្គលបានចំរើនយ៉ាងនេះ បានធ្វើឲ្យច្រើនៗយ៉ាងនេះហើយ រមែងញ៉ាំងវិជ្ជានិងវិមុត្តិឲ្យពេញបាន ។

## ទុតិយវគ្គោ ទុតិយោ

(១០០) អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ អានន្ទំ ភគវា ឯតទវោច អត្ថិ នុ ខោ អានន្ទ ឯកធម្មោ ភាវិតោ ពហុលីកតោ ចត្តារោ ធម្មេ បរិបូរេតិ ចត្តារោ ធម្មា ភាវិតា ពហុលីកតា សត្ត ធម្មេ បរិបូរេន្តិ សត្ត ធម្មា ភាវិតា ពហុលីកតា ទ្វេ ធម្មេ បរិបូរេន្តីតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ។បេ។ អត្ថានន្ទ ឯកធម្មោ ភាវិតោ ពហុលីកតោ ចត្តារោ ធម្មេ បរិបូរេតិ ចត្តារោ ធម្មា ភាវិតា ពហុលីកតា សត្ត ធម្មេ បរិបូរេន្តិ សត្ត ធម្មា ភាវិតា ពហុលីកតា ទ្វេ ធម្មេ បរិបូរេន្តិ ។

(១០១) កតមោ ចានន្ទ ឯកធម្មោ ភាវិតោ ពហុលីកតោ ចត្តារោ ធម្មេ បរិបូរេតិ ចត្តារោ ធម្មា ភាវិតា ពហុលីកតា សត្ត ធម្មេ បរិបូរេន្តិ សត្ត ធម្មា ភាវិតា ពហុលីកតា ទ្វេ ធម្មេ បរិបូរេន្តិ ។

## ទុតិយវគ្គ ទី ២

(១០០) គ្រានោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលអានន្ទធម៌ ១ ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយៗហើយ រមែងញុំាងធម៌ ៤ ឲ្យពេញ ធម៌ ៤ ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយៗហើយ រមែងញុំាងធម៌ ៧ ឲ្យពេញ ធម៌ ៧ ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយៗហើយ រមែងញុំាងធម៌ ២ ឲ្យពេញមានដែរឬ ។ បពិត្រព្រះអង្គដ៏ចំរើន ធម៌ទាំងឡាយរបស់យើងខ្ញុំ មានព្រះដ៏មានព្រះភាគជាមូល ។ បេ ។ ម្នាលអានន្ទ ធម៌ ១ ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយៗហើយ រមែងញុំាងធម៌ ៤ ឲ្យពេញ ធម៌ ៤ ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយៗហើយ រមែងញុំាងធម៌ ៧ ឲ្យពេញ ធម៌ ៧ ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយៗហើយ រមែងញុំាងធម៌ ២ ឲ្យពេញមានដែរ ។

(១០១) ម្នាលអានន្ទ ចុះធម៌ ១ ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយៗហើយ រមែងញុំាងធម៌ ៤ ឲ្យពេញ ធម៌ ៤ ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយៗហើយ រមែងញុំាងធម៌ ៧ ឲ្យពេញ ធម៌ ៧ ដែលបុគ្គលបានចំរើនបានធ្វើឲ្យរឿយៗហើយ រមែងញុំាងធម៌ ២ ឲ្យពេញបានតើដូចម្ដេច ។

អានាបានស្សតិសមាធិ អានន្ទ ឯកធម្មោ ភាវិតោ ពហុលីកតោ ចត្តារោ សតិប្បដ្ឋានេ បរិបូរេតិ ចត្តារោ សតិប្បដ្ឋានា ភាវិតា ពហុលីកតា សត្ត ពោជ្ឈង្គេ បរិបូរេន្តិ សត្ត ពោជ្ឈង្គា ភាវិតា ពហុលីកតា វិជ្ជាវិមុត្តឹ បរិបូរេន្តិ ។

(១០២) កថំ ភាវិតោ ចានន្ទ អានាបានស្សតិសមាធិ កថំ ពហុលីកតោ ចត្តារោ សតិប្បដ្ឋានេ បរិបូរេតិ ។ ឥធានន្ទ ភិក្ខុ អរញ្ញគតោ វា ។ បេ ។ ឯវំ ភាវិតា ខោ អានន្ទ សត្ត ពោជ្ឈង្គា ឯវំ ពហុលីកតា វិជ្ជាវិមុត្តឹ បរិបូរេន្តិ(១) ។

(១០៣) អថខោ សម្ពហុលា ភិក្ខូ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ អត្ថិ នុ ខោ ភន្តេ ឯកធម្មោ ភាវិតោ ពហុលីកតោ ចត្តារោ ធម្មេ បរិបូរេតិ ចត្តារោ ធម្មា ភាវិតា ពហុលីកតា សត្ត ធម្មេ បរិបូរេន្តិ

១ ឱ. ឥតោ បរំ យថា បុរិមសុត្តន្តេ ឯវំ វិត្ថារេតព្វំ ឥតិ បាឋោ ហោតិ ។

ម្នាលអានន្ទ ធម៌១ គឺអានាបានស្សតិសមាធិ ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយៗហើយ រមែងញុំាងសតិប្បដ្ឋាន ៤ ឲ្យពេញ សតិប្បដ្ឋាន ៤ ដែលបុគ្គលបានចំរើនបានធ្វើឲ្យរឿយៗហើយ រមែងញុំាងពោជ្ឈង្គទាំង៧ ឲ្យពេញ ពោជ្ឈង្គ៧ដែលបុគ្គលបានចំរើនបានធ្វើឲ្យរឿយ ៗ ហើយ រមែងញុំាងវិជ្ជានិងវិមុត្តិឲ្យពេញបាន ។

[១០២] ម្នាលអានន្ទ ចុះអានាបានស្សតិសមាធិ ដែលបុគ្គលបានចំរើនដូចម្តេច បានធ្វើឲ្យរឿយៗដូចម្តេច ទើបញុំាងសតិប្បដ្ឋានទាំង៤ឲ្យពេញបាន ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ នៅក្នុងព្រៃក្តី ។ បេ ។ ម្នាលអានន្ទ ពោជ្ឈង្គទាំង៧ដែលបុគ្គលបានចំរើនយ៉ាងនេះ បានធ្វើឲ្យរឿយៗយ៉ាងនេះហើយ រមែងញុំាងវិជ្ជានិងវិមុត្តិឲ្យពេញបាន ។

[១០៣] គ្រានោះ ភិក្ខុច្រើនរូប ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ធម៌១ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយៗហើយ រមែងញុំាងធម៌៤ឲ្យពេញ ធម៌៤ ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយៗ ហើយ រមែងញុំាងធម៌៧ឲ្យពេញ

## ទុតិយវគ្គោ ទុតិយោ

សត្ត ធម្មា ភាវិតា ពហុលីកតា ទ្វេ ធម្មេ បរិបូរេន្តីតិ ។ អត្ថិ ខោ ភិក្ខវេ ឯកធម្មោ ភាវិតោ ពហុលីកតោ ចត្តារោ ធម្មេ បរិបូរេតិ ចត្តារោ ធម្មា ភាវិតា ពហុលីកតា សត្ត ធម្មេ បរិបូរេន្តិ សត្ត ធម្មា ភាវិតា ពហុលីកតា ទ្វេ ធម្មេ បរិបូរេន្តីតិ ។

(១០៨) កតមោ បន ភន្តេ ឯកធម្មោ ភាវិតោ ពហុលីកតោ ចត្តារោ ធម្មេ បរិបូរេតិ ចត្តារោ ធម្មា ភាវិតា ពហុលីកតា សត្ត ធម្មេ បរិបូរេន្តិ សត្ត ធម្មា ភាវិតា ពហុលីកតា ទ្វេ ធម្មេ បរិបូរេន្តីតិ ។ អានាបានស្សតិសមាធិ ខោ ភិក្ខវេ ឯកធម្មោ ភាវិតោ ពហុលីកតោ ចត្តារោ សតិបដ្ឋានេ បរិបូរេតិ ចត្តារោ សតិបដ្ឋានា ភាវិតា ពហុលីកតា សត្ត ពោជ្ឈង្គេ បរិបូរេន្តិ សត្ត ពោជ្ឈង្គា ភាវិតា ពហុលីកតា វិជ្ជាវិមុត្តឹ បរិបូរេន្តីតិ ។ យថា ក្វតមយំ វេយ្យាករណំ ឯវំ វិត្ថារេតព្វំ ។

## ទុតិយវគ្គ ទី ២

ធម៌៧ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយៗហើយ រមែងញុំាងធម៌២ឲ្យពេញ មានដែរឬ ។ ម្នាលភិក្ខុទាំងឡាយ ធម៌១ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយៗហើយ រមែងញុំាងធម៌៤ឲ្យពេញ ធម៌៤ ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយៗហើយ រមែងញុំាងធម៌៧ឲ្យពេញ ធម៌៧ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយៗហើយ រមែងញុំាងធម៌២ឲ្យពេញមានដែរ ។

(១០៤) បពិត្រព្រះអង្គដ៏ចំរើន ចុះធម៌១ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយៗហើយ រមែងញុំាងធម៌៤ឲ្យពេញ ធម៌ ៤ ដែលបុគ្គលបានចំរើនបានធ្វើឲ្យរឿយៗហើយ រមែងញុំាងធម៌ ៧ ឲ្យពេញ ធម៌ ៧ ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយៗហើយ រមែងញុំាងធម៌ ២ ឲ្យពេញ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ១ គឺអានាបានស្សតិសមាធិ ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយៗហើយ រមែងញុំាងសតិប្បដ្ឋាន ៤ ឲ្យពេញ សតិប្បដ្ឋាន ៤ ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយៗហើយ រមែងញុំាងពោជ្ឈង្គ៧ឲ្យពេញ ពោជ្ឈង្គ៧ ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយៗហើយ រមែងញុំាងវិជ្ជានិងវិមុត្តិឲ្យពេញ ។

( វេយ្យាករណ៍ដែលបានពោលហើយយ៉ាងណា បណ្ឌិតគប្បីឲ្យពិស្តារយ៉ាងនោះផងចុះ) ។

[១០៥] អថខោ សម្ពហុលា ភិក្ខូ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នេ ខោ តេ ភិក្ខូ ភគវា ឯតទវោច អត្ថិ នុ ខោ ភិក្ខវេ ឯកធម្មោ ភាវិតោ ពហុលីកតោ ចត្តារោ ធម្មេ បរិបូរេតិ ចត្តារោ ធម្មា ភាវិតា ពហុលីកតា សត្ត ធម្មេ បរិបូរេន្តិ សត្ត ធម្មា ភាវិតា ពហុលីកតា ទ្វេ ធម្មេ បរិបូរេន្តីតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ។ បេ ។ ភគវតោ សុត្វា ភិក្ខូ ធារេស្សន្តីតិ ។ អត្ថិ ភិក្ខវេ ឯកធម្មោ ភាវិតោ ពហុលីកតោ ចត្តារោ ធម្មេ បរិបូរេតិ ចត្តារោ ធម្មា ភាវិតា ពហុលីកតា សត្ត ធម្មេ បរិបូរេន្តិ សត្ត ធម្មា ភាវិតា ពហុលីកតា ទ្វេ ធម្មេ បរិបូរេន្តិ ។

[១០៦] កតមោ ច ភិក្ខវេ ឯកធម្មោ ភាវិតោ ពហុលីកតោ ចត្តារោ ធម្មេ បរិបូរេតិ ចត្តារោ ធម្មា ភាវិតា ពហុលីកតា សត្ត ធម្មេ បរិបូរេន្តិ សត្ត ធម្មា ភាវិតា ពហុលីកតា ទ្វេ ធម្មេ បរិបូរេន្តិ ។

(១០៥) គ្រានោះភិក្ខុច្រើនរូប ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះអង្គុយក្នុងទីដ៏សមគួរហើយ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ធម៌១ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយៗហើយ រមែងញុំាងធម៌៤ឲ្យពេញ ធម៌៤ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយៗហើយរមែងញុំាងធម៌៧ឲ្យពេញ ធម៌៧ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយៗហើយ រមែងញុំាងធម៌២ឲ្យពេញ មានដែរឬ ។ បពិត្រព្រះអង្គដ៏ចំរើន ធម៌ទាំងឡាយរបស់យើងខ្ញុំ មានព្រះដ៏មានព្រះភាគជាមូល ។ បេ ។ ភិក្ខុទាំងឡាយបានស្តាប់ព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគហើយ នឹងចងចាំទុក ។ ម្នាលភិក្ខុទាំងឡាយ ធម៌១ ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយៗហើយ រមែងញុំាងធម៌៤ឲ្យពេញ ធម៌៤ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយៗហើយ រមែងញុំាងធម៌៧ឲ្យពេញ ធម៌៧ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយៗហើយ រមែងញុំាងធម៌២ឲ្យពេញមានដែរ ។

(១០៦) ម្នាលភិក្ខុទាំងឡាយ ធម៌១ដែលបុគ្គលបានចំរើន បានធ្វើហើយ រមែងញុំាងធម៌៤ឲ្យពេញ ធម៌៤ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយៗហើយ រមែងញុំាងធម៌៧ឲ្យពេញ ធម៌៧ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយៗហើយ រមែងញុំាងធម៌ ២ ឲ្យពេញ តើដូចម្តេច ។

## ទុតិយវគ្គោ ទុតិយោ

អានាបានស្សតិសមាធិ ភិក្ខវេ ឯកធម្មោ ភាវិតោ ពហុលីកតោ ចត្តារោ សតិបដ្ឋានេ បរិបូរេតិ ចត្តារោ សតិបដ្ឋានា ភាវិតា ពហុលីកតា សត្ត ពោជ្ឈង្គេ បរិបូរេន្តិ សត្ត ពោជ្ឈង្គា ភាវិតា ពហុលីកតា វិជ្ជាវិមុត្តឹ បរិបូរេន្តីតិ ។ បេ ។ (យថា ទុតិយំ វេយ្យាករណំ តថា ភិក្ខូនំ កាតព្វំ) ។ បេ ។

[១០៧] អានាបានស្សតិសមាធិ ភិក្ខវេ ភាវិតោ ពហុលីកតោ សញ្ញោជនានំ បហានាយ សំវត្តតិ ។

[១០៨] កថំ ភាវិតោ ច ភិក្ខវេ អានាបានស្សតិសមាធិ កថំ ពហុលីកតោ សញ្ញោជនានំ បហានាយ សំវត្តតិ ។ ឥធ ភិក្ខវេ ភិក្ខុ អរញ្ញគតោ វា ។ បេ ។ បដិនិស្សគ្គានុបស្សី អស្សសិស្សាមីតិ សិក្ខតិ បដិនិស្សគ្គានុបស្សី បស្សសិស្សាមីតិ សិក្ខតិ ។ ឯវំ ភាវិតោ ខោ ភិក្ខវេ អានាបានស្សតិសមាធិ

ទុតិយវគ្គ ទី ២

ម្នាលភិក្ខុទាំងឡាយ ធម៌១គឺអានាបានស្សតិសមាធិ ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយៗហើយ រមែងញុំាងសតិប្បដ្ឋាន៤ឲ្យពេញ សតិប្បដ្ឋាន៤ ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយៗហើយ រមែងញុំាងពោជ្ឈង្គ៧ ឲ្យពេញ ពោជ្ឈង្គ៧ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយៗហើយ រមែងញុំាងវិជ្ជានឹងវិមុត្តិឲ្យពេញបាន ។បេ។

(វេយ្យាករណ៍ទី៦យ៉ាងណា បណ្ឌិតគប្បីធ្វើដល់ភិក្ខុទាំងឡាយយ៉ាង នោះផងចុះ) ។ បេ ។

[១០៧] ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិសមាធិ ដែលបុគ្គល បានចំរើន បានធ្វើឲ្យរឿយៗហើយ រមែងប្រព្រឹត្តទៅដើម្បីលះបង់នូវ សញ្ញោជនៈបាន ។

[១០៨] ម្នាលភិក្ខុទាំងឡាយ ចុះអានាបានស្សតិសមាធិដែលបុគ្គល បានចំរើនដូចម្តេច បានធ្វើឲ្យរឿយៗដូចម្តេច ទើបប្រព្រឹត្តទៅដើម្បីលះបង់ សញ្ញោជនៈបាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ នៅក្នុង ព្រៃក្តី ។បេ។ សិក្សាថា អាត្មាអញនឹងជាអ្នកពិចារណាឃើញនូវធម៌ជា គ្រឿងលះបង់នូវកិលេសដោយដង្ហើមចេញ សិក្សាថា អាត្មាអញនឹងជាអ្នក ពិចារណាឃើញនូវធម៌ជាគ្រឿងលះបង់នូវកិលេសដោយដង្ហើមចូល ។ ម្នាល ភិក្ខុទាំងឡាយ អានាបានស្សតិសមាធិ ដែលបុគ្គលបានចំរើនយ៉ាងនេះ

ឯវំ ពហុលីកតោ សញ្ញោជនានំ បហានាយ សំវត្តតីតិ ។ បេ ។

[១០៩] អានាបានស្សតិសមាធិ ភិក្ខវេ ភាវិតោ ពហុលីកតោ អនុសយសមុគ្ឃាតាយ សំវត្តតិ ។ (វិត្ថារេតព្វំ) ។ ឯវំ ភាវិតោ ខោ ភិក្ខវេ អានាបា-នស្សតិសមាធិ ឯវំ ពហុលីកតោ អនុសយសមុគ្ឃា-តាយ សំវត្តតីតិ ។

[១១០] អានាបានស្សតិសមាធិ ភិក្ខវេ ភាវិតោ ពហុលីកតោ អទ្ធានបរិញ្ញាយ សំវត្តតីតិ ។ (វិត្ថារេ) ។ ឯវំ ភាវិតោ ខោ ភិក្ខវេ អានាបានស្សតិសមាធិ ឯវំ ពហុលីកតោ អទ្ធានបរិញ្ញាយ សំវត្តតីតិ ។

បានធ្វើឲ្យច្រើនៗយ៉ាងនេះហើយ រមែងប្រព្រឹត្តទៅដើម្បីលះបង់នូវសញ្ញោជនៈបាន ។ បេ ។

(១០៩) ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិសមាធិ ដែលបុគ្គលបានចំរើន បានធ្វើឲ្យច្រើនៗហើយ រមែងប្រព្រឹត្តទៅដើម្បីដកថោលនូវអនុសយកិលេសបាន ។ (បណ្ឌិតគប្បីឲ្យពិស្តារផងចុះ) ។ ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិសមាធិ ដែលបុគ្គលបានចំរើនយ៉ាងនេះ បានធ្វើឲ្យច្រើនៗយ៉ាងនេះហើយ រមែងប្រព្រឹត្តទៅដើម្បីដកថោលនូវអនុសយកិលេសបាន ។

(១១០) ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិសមាធិដែលបុគ្គលបានចំរើន បានធ្វើឲ្យច្រើនៗហើយ រមែងប្រព្រឹត្តទៅដើម្បីកំណត់ដឹងនូវផ្លូវឆ្ងាយគឺសង្សារបាន ។ (សេចក្តីពិស្តារ) ។ ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិសមាធិ ដែលបុគ្គលបានចំរើនយ៉ាងនេះ បានធ្វើឲ្យច្រើន ៗ យ៉ាងនេះហើយ រមែងប្រព្រឹត្តទៅដើម្បីកំណត់ដឹងនូវផ្លូវឆ្ងាយគឺសង្សារបាន ។

## ទុតិយវគ្គោ ទតិយោ

[១១១] អានាបានស្សតិសមាធិ ភិក្ខវេ ភាវិតោ ពហុលីកតោ អាសវានំ ខយាយ សំវត្តតីតិ ។ (វិត្ថារេ) ។ ឯវំ ភាវិតោ ខោ ភិក្ខវេ អានាបានស្សតិសមាធិ ឯវំ ពហុលីកតោ អាសវានំ ខយាយ សំវត្តតីតិ ។

**ទុតិយោ វគ្គោ ។**

## តស្សុទ្ទានំ

ឥច្ឆានង្គលំ សកំកិយំ អានន្ទ អបរេ ទុវេ

ភិក្ខុហិ ទ្វេ វុត្តា សញ្ញោជនំ អនុសយំ

អទ្ធានំ អាសវក្ខយាតិ ។

**អានាបានសំយុត្តំ និដ្ឋិតំ ។**

## ទុតិយវគ្គ ទី ២

(១១១) ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិសមាធិ ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយ ៗ ហើយ រមែងប្រព្រឹត្តទៅដើម្បីអស់ទៅនៃអាសវៈទាំងឡាយបាន ។ (សេចក្ដីពិស្ដារ) ។ ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិសមាធិ ដែលបុគ្គលបានចំរើនយ៉ាងនេះ បានធ្វើឲ្យរឿយៗយ៉ាងនេះហើយ រមែងប្រព្រឹត្តទៅដើម្បីអស់រលីងទៅនៃអាសវៈទាំងឡាយបាន ។

ចប់ វគ្គទី ២ ។

## ឧទ្ទាននៃវគ្គ ទី ២ នោះ គឺៈ

និយាយអំពីព្រះដ៏មានព្រះភាគ កាលគង់នៅគង់ដងព្រៃឥច្ឆានង្គល ១ អំពីព្រះលោមសកង្គិយៈដ៏មានអាយុ ១ អំពីព្រះអានន្ទដ៏មានអាយុ មាន ពីរលើក អំពីភិក្ខុច្រើនរូបមានពីរលើក អំពីចំរើនអានាបានស្សតិសមាធិប្រព្រឹត្តទៅដើម្បីលះសញ្ញោជនៈ១ ដើម្បីដកចោលនូវអនុសយកិលេស១ ដើម្បីកំណត់ដឹងនូវផ្លូវឆ្ងាយគឺសង្សារ១ ដើម្បីអស់ទៅនៃអាសវៈ ១ ។

ចប់ អានាបានសំយុត្ត ។

# សោតាបត្តិសំយុត្ត

## វេឡុទ្វារវគ្គោ បឋមោ

(១១២) សាវត្ថិយំ ។ តត្រ ខោ ភគវា ឯតទវោច កិញ្ចាបិ ភិក្ខវេ រាជា ចក្កវត្តិ ចតុន្នំ ទីបានំ ឥស្សរិយាធិបច្ចំ រជ្ជំ ការេត្វា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ទេវានំ តាវត្តឹសានំ សហព្យតំ ។ សោ តត្ថ នន្ទនេ វនេ អច្ឆរាសង្ឃបរិវុតោ ទិព្វេហិ បញ្ចហិ កាមគុណេហិ សមប្បិតោ សមង្គិភូតោ បរិចារេតិ ។ សោ ចតូហិ ធម្មេហិ អសមន្នាគតោ ។ អថ ខោ សោ អបរិមុត្តោ ច និរយា អបរិមុត្តោ ច តិរច្ឆានយោនិយា អបរិមុត្តោ ច បិត្តិវិសយា អបរិមុត្តោ ច អបាយទុគ្គតិវិនិបាតា ។

(១១៣) កិញ្ចាបិ ភិក្ខវេ អរិយសាវកោ បិណ្ឌិយាលោបេន យាបេតិ នន្តកានិ(១) ធារេតិ ។

---

១ ម អនន្តកានិ ប ។

# សោតាបត្តិសំយុត្ត

## វេឡុទ្វារវគ្គ ទី ១

[១១២] ទៀបក្រុងសាវត្ថី ។ គង់ទីនោះឯង ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ពិតមែនថាស្តេចចក្រពត្តិ សោយរាជសម្បត្តិ មានសភាពជាឥស្សរៈ ជាធំជាងទ្វីបទាំង ៤ លុះបែកធ្លាយរាងកាយបន្ទាប់អំពីមរណៈទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ជាមួយនឹងពួកទេវតាក្នុងស្ថានតាវត្តិង្ស ។ ទេវបុត្រនោះ មានពួកស្រីអប្សរហោមរោមក្នុងនន្ទនវនឧទ្យាន ក្នុងស្ថានតាវត្តិង្សនោះ ទ្រង់ឆ្អែតស្កប់ស្កល់ម្បូលមិត្តដោយកាមគុណទាំង ៥ ជាទិព្វ ។ បើទេវបុត្រនោះមិនបានប្រកបដោយធម៌ ៤ យ៉ាង ។ ទេវបុត្រនោះក៏គង់មិនរួចស្រឡះចាកនរក មិនរួចស្រឡះចាកកំណើតតិរច្ឆាន មិនរួចស្រឡះចាកប្រេតវិស័យ មិនរួចស្រឡះចាកអសុរកាយបានឡើយ ។

[១១៣] ម្នាលភិក្ខុទាំងឡាយ អរិយសាវក រមែងញាំងអត្តភាព ឲ្យប្រព្រឹត្តទៅដោយភោជនជាពំនូតដែលបានមក ដោយកម្លាំងកំភួនជើង ប្រើប្រាស់នូវសំពត់គ្មានជាយក៏ពិតមែនហើយ ។

## វេឡុទ្វារវគ្គោ បឋមោ

សោ ចតូហិ ធម្មេហិ សមន្នាគតោ ។ អថខោ សោ បរិមុត្តោ ច និរយា បរិមុត្តោ ច តិរច្ឆានយោនិយា បរិមុត្តោ ច បិត្តិវិសយា បរិមុត្តោ ច អបាយទុគ្គតិវិនិបាតា ។ កតមេហិ ចតូហិ ។ ឥធ ភិក្ខវេ អរិយសាវកោ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។ សង្ឃេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ

## វេឡុទ្វារវគ្គ ទី ២

តែថាអរិយសាវកនោះប្រកបដោយធម៌ ៤ យ៉ាង ។ ទើបអរិយសាវកនោះ រួចស្រឡះចាកនរក រួចស្រឡះចាកកំណើតតិរច្ឆាន រួចស្រឡះចាកប្រេតវិស័យ រួចស្រឡះចាកអសុរកាយបាន ។ ប្រកបដោយធម៌ ៤ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់បរិបូណ៌ដោយវិជ្ជានិងចរណៈ មានដំណើរល្អយាងទៅកាន់ព្រះនិព្វាន ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ប្រសើរដោយសីលាទិគុណរកបុគ្គលណាមួយស្មើគ្មាន ទ្រង់ជាអ្នកទូន្មាននូវបុរសដូចជានាយសារថី ទ្រង់ជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវអរិយសច្ច ៤ ទ្រង់ខ្ជាក់ចោលនូវត្រៃភព លែងវិលត្រឡប់មកកើតទៀត១ ។ ប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះធម៌ថា ព្រះបរិយត្តិធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់សំដែងហើយដោយប្រពៃ ព្រះនពលោកុត្តរធម៌ ជាធម៌ដែលព្រះអរិយបុគ្គលឃើញច្បាស់ដោយខ្លួនឯង ជាធម៌ឲ្យនូវផលមិនរង់ចាំកាល ជាធម៌គួរនឹងហៅបុគ្គលដទៃឲ្យចូលមកមើលបាន ជាធម៌ដែលព្រះអរិយបុគ្គល គប្បីបង្អោនចូលមកទុកក្នុងខ្លួន ជាធម៌ដែលអ្នកប្រាជ្ញទាំងឡាយ គប្បីដឹងច្បាស់ក្នុងចិត្តនៃខ្លួន ១ ។ ប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះសង្ឃថា

សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ឧជុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ញាយប្បដិបន្នោ ភគវតោ សាវកសង្ឃោ សាមីចិប្បដិបន្នោ ភគវតោ សាវកសង្ឃោ ។ យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។ អរិយកន្តេហិ សីលេហិ សមន្នាគតោ ហោតិ អខណ្ឌេហិ អច្ឆិទ្ទេហិ អសពលេហិ អកម្មាសេហិ ភុជិស្សេហិ វិញ្ញុប្បសត្ថេហិ អបរាមដ្ឋេហិ សមាធិសំវត្តនិកេហិ ។ ឥមេហិ ចតូហិ ធម្មេហិ សមន្នាគតោ ហោតិ ។

(១១៤) យោ ច ភិក្ខវេ ចតុន្នំ ទីបានំ បដិលាភោ យោ ច ចតុន្នំ ធម្មានំ បដិលាភោ ចតុន្នំ ទីបានំ បដិលាភោ ចតុន្នំ ធម្មានំ បដិលាភស្ស កលំ នាគ្ឃតិ សោឡសិំ ។

ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ ប្រតិបត្តិដោយប្រពៃ ព្រះសង្ឃសាវកនៃព្រះដ៏មានព្រះភាគ ប្រតិបត្តិដោយត្រង់ ព្រះសង្ឃសាវកនៃព្រះដ៏មានព្រះភាគ ប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ព្រះសង្ឃសាវកនៃព្រះដ៏មានព្រះភាគ ប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម ។ ព្រះសង្ឃរូបណា បើរាប់ជាគូនៃបុរសមាន ៤ គូ បើរាប់រៀងជាបុរសបុគ្គលមាន ៨ ពួក នុ៎ះជាសង្ឃសាវកនៃព្រះដ៏មានព្រះភាគ លោកគួរទទួលនូវបច្ច័យ ដែលគេនាំមកបូជា គួរទទួលនូវអាគន្តុកទាន គួរទទួលនូវទានដែលបុគ្គលជឿនូវកម្មនិងផលនៃកម្មហើយបូជា គួរដល់អញ្ជលីកម្មដែលសត្វលោកគប្បីធ្វើ ជាបុញ្ញក្ខេត្តនៃសត្វលោករកខេត្តដទៃក្រៃលែងជាងគ្មាន ១ ។ ប្រកបដោយសីលជាទីត្រេកអរនៃព្រះអរិយៈ ជាសីលមិនដាច់ មិនធ្លុះ មិនពពរុះ មិនពពាល ជាសីលជានាដែលអ្នកប្រាជ្ញគប្បីសរសើរ មិនបានប៉ះពាល់ (ដោយតណ្ហានិងទិដ្ឋិ) ប្រព្រឹត្តទៅព្រមដើម្បីសមាធិ ១ ។ អរិយសាវកជាអ្នកប្រកបដោយធម៌ទាំង៤ យ៉ាងនេះឯង ។

[១១៤] ម្នាលភិក្ខុទាំងឡាយ ការដែលបាននូវទ្វីបទាំង ៤ ហើយនិងការដែលបាននូវធម៌ទាំង៤ ឯការបាននូវទ្វីបទាំង៤ មិនដល់នូវចំណិតដែលចែកជាចំណែក ១៦ ដងនៃការបាននូវធម៌ទាំង ៤ ឡើយ ។

## វេឡុទ្វារវគ្គោ បឋមោ

( ១១៨ ) ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ អរិយសាវកោ សោតាបន្នោ ហោតិ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយណោ ។ កតមេហិ ចតូហិ ។ ឥធ ភិក្ខវេ អរិយសាវកោ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ធម្មេ ។ បេ ។ សង្ឃេ ។ បេ ។ អរិយកន្តេហិ សីលេហិ សមន្នាគតោ ហោតិ អខណ្ឌេហិ ។ បេ ។ សមាធិសំវត្តនិកេហិ ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ អរិយសាវកោ សោតាបន្នោ ហោតិ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយណោតិ ។

## វេឡុទ្វារវគ្គ ទី ១

[ ១១៩ ] ម្នាលភិក្ខុទាំងឡាយ អរិយសាវកអ្នកដល់នូវសោតៈ ប្រកបដោយធម៌ ៤ យ៉ាង មានសភាពមិនធ្លាក់ចុះទៅក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ ។ ប្រកបដោយធម៌ ៤ យ៉ាងតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវក ក្នុងសាសនានេះ ប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់បរិបូណ៌ដោយវិជ្ជានិងចរណៈ ទ្រង់មានដំណើរល្អយាងទៅកាន់ព្រះនិព្វាន ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ទ្រង់ជាអ្នកទូន្មាននូវបុរសដូចជានាយសារថី ទ្រង់ជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវអរិយសច្ច ៤ ទ្រង់ខ្ជាក់ចោលនូវត្រៃភព លែងវិលត្រឡប់មកកើតទៀត ១ ។ (ប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើក) ក្នុងព្រះធម៌ ១ ។ បេ ។ ក្នុងព្រះសង្ឃ ១ ។ បេ ។ ប្រកបដោយសីលជាទីត្រេកអរនៃព្រះអរិយៈមិនដាច់ ។ បេ ។ ប្រព្រឹត្តទៅព្រមដើម្បីសមាធិ ១ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកអ្នកបានដល់នូវសោតៈ ប្រកបដោយធម៌ទាំង ៤ យ៉ាងនេះឯង មានសភាពមិនបានធ្លាក់ចុះក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ ។

ឥទមវោច ភគវា ឥទំ វត្វាន សុគតោ អថាបរំ ឯត-ទវោច សត្ថា

(១១៦) យេសំ សទ្ធា ច សីលញ្ច
បសាទោ ធម្មទស្សនំ
តេ វេ កាលេន បច្ចេន្តិ
ព្រហ្មចរិយោគធំ សុខន្តិ ។

(១១៧) ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន ទីឃាវុ ឧបាសកោ អាពាធិកោ ហោតិ ទុក្ខិតោ ពាឡ្ហគិលានោ ។ អថខោ ទីឃាវុ ឧបាសកោ បិតរំ ជោតិយំ(១) គហបតិំ អាមន្តេសិ ឯហិ ត្វំ គហបតិ យេន ភគវា តេនុបសង្កម ឧបសង្កមិត្វា មម វចនេន ភគវតោ បាទេ សិរសា វន្ទ

---

១ ឱ. ម. ជោតិកំ ។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់នូវព្រះសូត្រនេះ លុះព្រះសុគតទ្រង់ត្រាស់នូវព្រះសូត្រនេះចប់ហើយ ព្រះសាស្តាក៏ទ្រង់ត្រាស់នូវព្រះគាថានេះតទៅទៀតថា

[១១៦] ពួកជនណា មានសទ្ធា (១) ១ មានសីល (២) ១
មានសេចក្តីជ្រះថ្លា (៣) ១ មានការឃើញនូវធម៌ (៤) ១ ជន
ទាំងនោះឯង រមែងដល់នូវសេចក្តីសុខ (៥) ជាគ្រឿងប្រជុំចុះ
ក្នុងព្រហ្មចរិយៈ តាមកាលដ៏គួរ ។

[១១៧] សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង ឧបាសកឈ្មោះទីឃាវុ មានអាពាធដល់នូវសេចក្តីទុក្ខឈឺធ្ងន់ ។ វេលានោះទីឃាវុឧបាសកហៅគហបតីឈ្មោះជោតិយៈជាបិតាមកថា បពិត្រគហបតី ចូរអ្នកទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ចូរអ្នកក្រាបថ្វាយបង្គំព្រះបាទានៃព្រះដ៏មានព្រះភាគ ដោយសិរសាតាមពាក្យនៃខ្ញុំថា

---

១ - សំដៅសេចក្តីជ្រះថ្លាក្នុងព្រះពុទ្ធ ។

២ - សំដៅយកអរិយកន្តសីល គឺសីលជាទីត្រេកអរនៃព្រះអរិយៈ ។

៣ - សំដៅយកសេចក្តីជ្រះថ្លាក្នុងព្រះសង្ឃ ។

៤ សំដៅយកសេចក្តីជ្រះថ្លាក្នុងព្រះធម៌ ។

៥ សុខប្រកបដោយមគ្គទាំង៣ខាងដើម គឺសោតាបត្តិមគ្គ សកទាគាមិមគ្គ អនាគាមិមគ្គ (អដ្ឋកថា) ។

## វេឡុទ្វារវគ្គោ បឋមោ

ទីឃាវុ ភន្តេ ឧបាសកោ អាពាធិកោ(១) ទុក្ខិតោ ពាឡ្ហគិលានោ សោ ភគវតោ បាទេ សិរសា វន្ទតីតិ ។ ឯវញ្ច វទេហិ សាធុ កិរ ភន្តេ ភគវា យេន ទីឃាវុស្ស ឧបាសកស្ស និវេសនំ តេនុបសង្កមតុ អនុកម្បំ ឧបាទាយាតិ ។ ឯវំ តាតាតិ ខោ ជោតិយោ គហបតិ ទីឃាវុស្ស ឧបាសកស្ស បដិស្សុត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។

(១១៨) ឯកមន្តំ និសិន្នោ ខោ ជោតិយោ គហបតិ ភគវន្តំ ឯតទវោច ទីឃាវុ ភន្តេ ឧបាសកោ អាពាធិកោ ទុក្ខិតោ ពាឡ្ហគិលានោ សោ ភគវតោ បាទេ សិរសា វន្ទតិ ។ ឯវញ្ច វទេតិ សាធុ កិរ ភន្តេ ភគវា យេន ទីឃាវុស្ស ឧបាសកស្ស និវេសនំ តេនុបសង្កមតុ អនុកម្បំ ឧបាទាយាតិ ។ អធិវាសេសិ ភគវា តុណ្ហីភាវេន ។

---

១ ឱ. ម. ឯត្ថន្តរេ ហោតីតិ បទំ អត្ថិ ។

## វេឡុទ្វារវគ្គ ទី ១

បពិត្រព្រះអង្គដ៏ចំរើន ទីឃាវុឧបាសក មានអាពាធដល់នូវសេចក្តីទុក្ខឈឺធ្ងន់ ទីឃាវុឧបាសកនោះ ថ្វាយបង្គំព្រះបាទានៃព្រះដ៏មានព្រះភាគដោយសិរសា ។ អ្នកចូរក្រាបបង្គំទូលយ៉ាងនេះផងថា បពិត្រព្រះអង្គដ៏ចំរើន សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះដ៏មានព្រះភាគធ្វើនូវសេចក្តីអនុគ្រោះ យាងចូលទៅកាន់លំនៅនៃទីឃាវុឧបាសក ។ ជោតិយគហបតី ទទួលស្តាប់ពាក្យទីឃាវុឧបាសកថា អើកូន ហើយក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគរួចអង្គុយក្នុងទីសមគួរ ។

(១១៨) លុះជោតិយគហបតី អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ទីឃាវុឧបាសក មានអាពាធដល់នូវសេចក្តីទុក្ខឈឺធ្ងន់ ទីឃាវុឧបាសកនោះថ្វាយបង្គំព្រះបាទាព្រះដ៏មានព្រះភាគដោយសិរសា ។ ឧបាសកនោះពោលយ៉ាងនេះផងថា បពិត្រព្រះអង្គដ៏ចំរើន សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះដ៏មានព្រះភាគធ្វើនូវសេចក្តីអនុគ្រោះ យាងចូលទៅកាន់លំនៅនៃទីឃាវុឧបាសក ។ ព្រះដ៏មានព្រះភាគទ្រង់ទទួលដោយតុណ្ហីភាព ។

## សុត្តន្តបិដកេ សំយុត្តនិកាយស្ស មហាវារវគ្គោ

(១១៩) អថខោ ភគវា(១) និវាសេត្វា បត្តចីវរមា-ទាយ យេន ទីឃាវុស្ស ឧបាសកស្ស និវេសនំ តេ-នុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ និសជ្ជ ខោ ភគវា ទីឃាវុំ ឧបាសកំ ឯតទវោច កច្ចិ តេ ទីឃាវុ ខមនីយំ កច្ចិ យាបនីយំ កច្ចិ ទុក្ខា វេទនា បដិក្កមន្តិ នោ អភិក្កមន្តិ បដិក្ក-មោសានំ បញ្ញាយតិ នោ អភិក្កមោតិ ។ ន មេ ភន្តេ ខមនីយំ ន យាបនីយំ ពាឡ្ហា មេ ទុក្ខា វេទនា អភិក្កមន្តិ នោ បដិក្កមន្តិ អភិក្កមោសានំ បញ្ញាយតិ នោ បដិក្កមោតិ ។

(១២០) តស្មាតិហ តេ ទីឃាវុ ឯវំ សិក្ខិតព្វំ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ភវិស្សាមិ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្ប-ន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ

---

១ ម. ឯត្ថន្តរេ អន្តរាភាសុកំ ឥតិបិ បាឋោ ទិស្សតិ ។

(១១៩) គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរ យាងចូលទៅកាន់លំនៅនៃទីឃាវុទុបាសក លុះចូលទៅដល់ហើយក៏គង់លើអាសនៈ ដែលគេក្រាលថ្វាយ ។ លុះព្រះដ៏មានព្រះភាគទ្រង់គង់ហើយ ក៏ត្រាស់សួរទីឃាវុទុបាសកដូច្នេះថា ម្នាលទីឃាវុ អ្នកល្មមអត់ទ្រាំបានដែរ ឬ ល្មមប្រព្រឹត្តទៅស្រួលដែរ ឬ ទុក្ខវេទនា ធូរថយទៅមិនចំរើនឡើង ការថយទៅ (នៃទុក្ខវេទនា) រមែងប្រាកដ ការចំរើនឡើងមិនប្រាកដទេឬ ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមិនល្មមអត់ទ្រាំបានទេ មិនល្មមប្រព្រឹត្តទៅបានស្រួលទេ ទុក្ខវេទនារបស់ខ្ញុំព្រះអង្គធ្ងន់ណាស់ រមែងចំរើនឡើង មិនធូរថយទេ ការចំរើនឡើង រមែងប្រាកដ ការធូរថយមិនប្រាកដទេ ។

(១២០) ម្នាលទីឃាវុ ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកគប្បីសិក្សាយ៉ាងនេះថា អាត្មាអញនឹងប្រកបដោយសេចក្តីជ្រះថ្លា មិនកម្រើកក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់បរិបូណ៌ដោយវិជ្ជានិងចរណៈ ទ្រង់មានដំណើរល្អយាងទៅកាន់ព្រះនិព្វាន ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ប្រសើរដោយសីលាទិគុណរកបុគ្គលណាមួយស្មើគ្មាន ទ្រង់ជាអ្នកទូន្មាននូវបុរសដូចជានាយសារថី

## វេឡុទ្វារវគ្គោ បឋមោ

សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ធម្មេ ។ សង្ឃេ ។ អរិយកន្តេហិ សីលេហិ សមន្នាគតោ ភវិស្សាមិ អខណ្ឌេហិ ។ បេ ។ សមាធិសំវត្តនិកេហីតិ ។ ឯវញ្ហិ តេ ទីឃាវុ សិក្ខិតព្វន្តិ ។

(១៦១) យានិមានិ ភន្តេ ភគវតា ចត្តារិ សោតាបត្តិយង្គានិ ទេសិតានិ សំវិជ្ជន្តេ តេ ធម្មា មយិ អហញ្ច តេសុ ធម្មេសុ សន្ទិស្សាមិ ។ អហញ្ហិ ភន្តេ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ឥតិបិ សោ ភគវា ។ បេ ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ធម្មេ ។ សង្ឃេ ។ អរិយកន្តេហិ សីលេហិ សមន្នាគតោ អខណ្ឌេហិ ។ បេ ។ សមាធិសំវត្តនិកេហីតិ ។

## វេឡុទ្វារវគ្គ ទី ១

ទ្រង់ជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវអរិយសច្ច ៤ ទ្រង់ខ្ជាក់ចោលនូវត្រៃភព លែងវិលត្រឡប់មកកើតទៀត ។ (ប្រកបដោយសេចក្ដីជ្រះថ្លាមិនកម្រើក) ក្នុងព្រះធម៌ ។ ក្នុងព្រះសង្ឃ ។ ប្រកបដោយសីលជាទីត្រេកអរនៃព្រះអរិយៈ ជាសីលមិនដាច់ ។បេ។ ប្រព្រឹត្តទៅព្រមដើម្បីសមាធិ ។ ម្នាលទីឃាវុ អ្នកគប្បីសិក្សាយ៉ាងនេះចុះ ។

(១២១) បពិត្រព្រះអង្គដ៏ចំរើន អង្គនៃសោតាបត្តិ ៤ ឯណា ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយ ធម៌ទាំងនោះសឹងមានព្រមក្នុងខ្លួនខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គនឹងប្រាកដក្នុងធម៌ទាំងនោះ ។ បពិត្រព្រះអង្គដ៏ចំរើន ព្រោះថា ខ្ញុំព្រះអង្គប្រកបដោយសេចក្ដីជ្រះថ្លាមិនកម្រើកក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគអង្គនោះ ។បេ។ ទ្រង់ជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវអរិយសច្ច ៤ ទ្រង់ខ្ជាក់ចោលនូវត្រៃភព លែងវិលត្រឡប់មកកើតទៀត ។ (ប្រកបដោយសេចក្ដីជ្រះថ្លាមិនកម្រើក) ក្នុងព្រះធម៌ ។ ក្នុងព្រះសង្ឃ ។ ប្រកបដោយសីលជាទីត្រេកអរនៃព្រះអរិយៈ ជាសីលមិនដាច់ ។បេ។ ប្រព្រឹត្តទៅព្រមដើម្បីសមាធិ ។

តស្មាតិហ ត្វំ ទីឃាវុ ឥមេសុ ចតូសុ សោតា-
បត្តិយង្គេសុ បតិដ្ឋាយ ឆ វិជ្ជាភាគិយេ ធម្មេ ឧត្តរឹ
ភាវេយ្យាសិ ។

(១២២) ឥធ ត្វំ ទីឃាវុ សព្វសង្ខារេសុ អនិច្ចា-
នុបស្សី វិហរាហិ អនិច្ចេ ទុក្ខសញ្ញី ទុក្ខេ អនត្ត-
សញ្ញី បហានសញ្ញី វិរាគសញ្ញី និរោធសញ្ញីតិ ។
ឯវញ្ហិ តេ ទីឃាវុ សិក្ខិតព្វន្តិ ។

(១២៣) យេមេ ភន្តេ ភគវតា ឆ វិជ្ជាភាគិយា
ធម្មា ទេសិតា សំវិជ្ជន្តេ តេ ធម្មា មយិ អហញ្ច
តេសុ ធម្មេសុ សន្ទិស្សាមិ ។ អហញ្ហិ ភន្តេ សព្វសង្ខា-
រេសុ អនិច្ចានុបស្សី វិហរាមិ អនិច្ចេ ទុក្ខសញ្ញី ទុក្ខេ
អនត្តសញ្ញី បហានសញ្ញី វិរាគសញ្ញី និរោធសញ្ញី ។

ម្នាលទីឃាវុ ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកគួរតំកល់ទៅក្នុងអង្គនៃសោតាបត្តិ ៤ នេះ ហើយចំរើននូវធម៌ជាចំណែកនៃវិជ្ជា ៦ យ៉ាងតទៅទៀត ។

(១២២) ម្នាលទីឃាវុ ក្នុងសាសនានេះ អ្នកចូរពិចារណានូវសេចក្តីមិនទៀងក្នុងសង្ខារទាំងពួង ចូរសំគាល់ថាជាទុក្ខ ក្នុងរបស់ដែលមិនទៀង សំគាល់ថាមិនមែនជារបស់ខ្លួន ក្នុងរបស់ដែលជាទុក្ខ សំគាល់នូវធម៌ជាគ្រឿងលះបង់ សំគាល់នូវធម៌ជាគ្រឿងប្រាសចាកតម្រេក សំគាល់នូវធម៌ជាគ្រឿងរលត់ ។ ម្នាលទីឃាវុ អ្នកគប្បីសិក្សាយ៉ាងនេះចុះ ។

(១២៣) បពិត្រព្រះអង្គដ៏ចំរើន ធម៌ជាចំណែកនៃវិជ្ជា ៦ ឯណា ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយ ធម៌ទាំងនោះឯង សឹងមានព្រមក្នុងខ្លួនខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គទឹងប្រាកដក្នុងធម៌ទាំងនោះ ។ បពិត្រព្រះអង្គដ៏ចំរើន ព្រោះខ្ញុំព្រះអង្គ តែងពិចារណាឃើញនូវសេចក្តីមិនទៀងក្នុងសង្ខារទាំងពួង សំគាល់ថាជាទុក្ខក្នុងរបស់ដែលមិនទៀង សំគាល់ថាមិនមែនជារបស់ខ្លួនក្នុងរបស់ដែលជាទុក្ខ សំគាល់នូវធម៌ជាគ្រឿងលះបង់ សំគាល់នូវធម៌ដែលជាគ្រឿងប្រាសចាកតម្រេក សំគាល់នូវធម៌ជាគ្រឿងរលត់ ។

## វេឡុទ្វារវគ្គោ បឋមោ

អបិច មេ ភន្តេ ឯវំ ហោតិ មា ហេវាយំ ជោតិយោ គហបតិ មមច្ចយេន វិឃាតំ អាបជ្ជីតិ(១) ។ មា ត្វំ តាត ទីឃាវុ ឯវំ មនសាកាសិ ឥង្ឃ ត្វំ តាត ទីឃាវុ យទេវ តេ ភគវា អាហ តទេវ(២) សាធុកំ មនសិករោហីតិ ។

(១៤៨) អថខោ ភគវា ទីឃាវុំ ឧបាសកំ ឥមិនា ឱវាទេន ឱវទិត្វា ឧដ្ឋាយាសនា បក្កាមិ ។ អថខោ ទីឃាវុ ឧបាសកោ អចិរបក្កន្តស្ស ភគវតោ កាលមកាសិ ។

(១៤៩) អថខោ សម្ពហុលា ភិក្ខូ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ យោ សោ ភន្តេ ទីឃាវុ នាម ឧបាសកោ ភគវតា សង្ខិត្តេន ឱវាទេន ឱវទិតោ សោ កាលង្កតោ តស្ស កា គតិ កោ អភិសម្បរាយោតិ ។ បណ្ឌិតោ ភិក្ខវេ ទីឃាវុ ឧបាសកោ អហោសិ សច្ចភាទិ(៣) ធម្មស្សានុធម្មំ

---

១ ឱ. អាបជ្ជីតិ ។ ២ ឱ ម. តទេវ ត្វំ ។ ៣ ឱ. បច្ចូភាទី ។

## វេឡុទ្វារវគ្គ ទី ១

បពិត្រព្រះអង្គដ៏ចំរើន មួយទៀត ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះយ៉ាងនេះថា ជោតិយគហបតីនេះ លុះអំណើះតអំពីខ្ញុំព្រះអង្គទៅ សូមកុំឱ្យជួបប្រទះនឹងសេចក្តីទុក្ខឡើយ ។ ម្នាលទីឃាវុ អ្នកកុំធ្វើទុក្ខក្នុងចិត្តយ៉ាងនេះឡើយ នែទីឃាវុ ព្រះដ៏មានព្រះភាគបានពោលនូវធម៌ឯណាដល់អ្នក ។ ចូរធ្វើទុកក្នុងចិត្តនូវធម៌នោះដោយប្រពៃចុះ ។

(១៦៨) លុះព្រះដ៏មានព្រះភាគ បានទូន្មានទីឃាវុឧបាសកដោយឱវាទនេះរួចហើយ ក៏ក្រោកចាកអាសនៈចៀសចេញទៅ ។ ទីឃាវុឧបាសក កាលដែលព្រះដ៏មានព្រះភាគ ចៀសចេញទៅមិនយូរប៉ុន្មាន ក៏ធ្វើមរណកាលទៅ ។

(១៦៩) គ្រានោះ ភិក្ខុច្រើនរូបចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុទាំងនោះអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ទីឃាវុឧបាសកដែលព្រះដ៏មានព្រះភាគ ទ្រង់បានទូន្មានដោយឱវាទសង្ខេប គាត់ធ្វើមរណកាលទៅហើយ តើគតិរបស់គាត់ដូចម្តេច បរលោកដែលគាត់ត្រូវបានតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ទីឃាវុឧបាសក ជាបណ្ឌិត ពោលពាក្យពិតទៅរកធម៌តាមសមគួរដល់ធម៌

ន ច ធម្មាធិករណំ វិហេសេសិ ។ ទីឃាវុ ភិក្ខវេ ឧបាសកោ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឱបបាតិកោ[១] តត្ថ បរិនិព្វាយី អនាវត្តិ-ធម្មោ តស្មា លោកាតិ ។

(១៦៦) ឯកំ សមយំ អាយស្មា ច សារិបុត្តោ អាយស្មា ច អានន្ទោ សាវត្ថិយំ វិហរន្តិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ អាយស្មា អានន្ទោ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេនាយស្មា សារិបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា ឯ-កមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ អាយស្មន្តំ សារិបុត្តំ ឯតទវោច កតីនំ នុ ខោ អាវុសោ សារិបុត្ត ធម្មានំ សមន្នាគមនហេតុ ឯវមយំ បជា ភគវតា ព្យាកតា សោតាបន្នា អវិ-និបាតធម្មា និយតា សម្ពោធិបរាយនាតិ ។

---

១ ឱ ឧបបាតិកោ ហោតិ ។

មិនបៀតបៀននូវអធិករណ៍នៃធម៌ឡើយ ។ ម្នាលភិក្ខុទាំងឡាយ ទីឃាវុ ឧបាសក បានជាឧបបាតិកៈកំណើត ហើយបរិនិព្វានក្នុងទីនោះ មានសភាពមិនត្រឡប់មកអំពីលោកនោះវិញទេ ព្រោះអស់ទៅនៃសញ្ញោជនៈជាចំណែកខាងក្រោមទាំង ៥ ។

[១៦៦] សម័យមួយ ព្រះសារីបុត្តដ៏មានអាយុ នឹងព្រះអានន្ទដ៏មានអាយុ គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុ ចេញចាកផលសមាបត្តិក្នុងវេលាសាយណ្ហសម័យ ហើយចូលទៅរកព្រះសារីបុត្តដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុអង្គុយក្នុងទីសមគួរហើយ ក៏ពោលទៅនឹងព្រះសារីបុត្តដ៏មានអាយុដូច្នេះថា ម្នាលអាវុសោសារីបុត្ត ពពួកសត្វនេះ ដែលព្រះដ៏មានព្រះភាគព្យាករថា បានដល់សោតៈ មានសភាពមិនធ្លាក់ចុះក្នុងអបាយជាបុគ្គលទៀង មានគតិយាត្រាស់ដឹងប្រព្រឹត្តទៅខាងមុខយ៉ាងនេះ ព្រោះហេតុប្រកបដោយធម៌ប៉ុន្មានយ៉ាងហ្ន៎ ។

## វេឡុទ្វារវគ្គោ បឋមោ

(១២៧) ចតុន្នំ ខោ អាវុសោ ធម្មានំ សមន្នាគមនហេតុ ឯវមយំ បជា ភគវតា ព្យាកតា សោតាបន្នា អវិនិបាតធម្មា និយតា សម្ពោធិបរាយណា ។ កតមេសំ ចតុន្នំ ។ ឥធាវុសោ អរិយសាវកោ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ ឥតិបិ សោ ភគវា ។ បេ ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ធម្មេ ។ បេ ។ សង្ឃេ ។ បេ ។ អរិយកន្តេហិ សីលេហិ សមន្នាគតោ ហោតិ អខណ្ឌេហិ ។ បេ ។ សមាធិសំវត្តនិកេហិ ។ ឥមេសំ ខោ អាវុសោ ចតុន្នំ ធម្មានំ សមន្នាគមនហេតុ ឯវមយំ បជា ភគវតា ព្យាកតា សោតាបន្នា អវិនិបាតធម្មា និយតា សម្ពោធិបរាយណាតិ ។

(១២៨) អថខោ អាយស្មា សារីបុត្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា

វេឡុទ្វារវគ្គ ទី ១

[១២៧] ម្នាលអាវុសោ ពពួកសត្វនេះ ដែលព្រះដ៏មានព្រះភាគព្យាករថា បានដល់សោតៈមានសភាពមិនបានធ្លាក់ចុះក្នុងអបាយជាបុគ្គលទៀង មានកិរិយាត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខយ៉ាងនេះ ព្រោះហេតុប្រកបដោយធម៌ ៤ យ៉ាង ។ ធម៌ ៤ យ៉ាងតើដូចម្តេច ។ ម្នាលអាវុសោ អរិយសាវក ក្នុងសាសនានេះ ប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគព្រះអង្គនោះ ។បេ។ ទ្រង់ជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវអរិយសច្ច ៤ ទ្រង់ខ្ជាក់ចោលនូវត្រៃភព លែងវិលត្រឡប់មកកើតទៀត ។ ក្នុងព្រះធម៌ ។បេ។ ក្នុងព្រះសង្ឃ ។បេ។ ប្រកបដោយសីលជាទីត្រេកអររបស់ព្រះអរិយៈ ជាសីលមិនដាច់ ។បេ។ ប្រព្រឹត្តទៅព្រមដើម្បីសមាធិ ។ ម្នាលអាវុសោ ពពួកសត្វនេះ ដែលព្រះដ៏មានព្រះភាគព្យាករថា បានដល់សោតៈមានសភាពមិនបានធ្លាក់ចុះក្នុងអបាយ ជាបុគ្គលទៀង មានកិរិយាត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខយ៉ាងនេះ ព្រោះហេតុប្រកបដោយធម៌ ៤ យ៉ាងនេះឯង ។

[១២៨] គ្រានោះ ព្រះសារីបុត្តដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ

ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ សារីបុត្តំ ភគវា ឯតទវោច សោតាបត្តិយង្គំ សោតាបត្តិយង្គន្តិ ហិទំ សារីបុត្ត វុច្ចតិ កតមំ នុ ខោ សារីបុត្ត សោតាបត្តិយង្គន្តិ ។

[១២៩] សប្បុរិសសំសេវោ ហិ ភន្តេ សោតាបត្តិយង្គំ សទ្ធម្មស្សវនំ សោតាបត្តិយង្គំ យោនិសោមនសិការោ សោតាបត្តិយង្គំ ធម្មានុធម្មប្បដិបត្តិ សោតាបត្តិយង្គន្តិ ។

[១៣០] សាធុ សាធុ សារីបុត្ត សប្បុរិសសំសេវោ ហិ សារីបុត្ត សោតាបត្តិយង្គំ សទ្ធម្មស្សវនំ សោតាបត្តិយង្គំ យោនិសោមនសិការោ សោតាបត្តិយង្គំ ធម្មានុធម្មប្បដិបត្តិ សោតាបត្តិយង្គំ ។

[១៣១] សោតោ សោតោតិ(១) ហិទំ សារីបុត្ត វុច្ចតិ កតមោ នុ ខោ សារីបុត្ត សោតោតិ ។ អយមេវ ហិ ភន្តេ អរិយោ អដ្ឋង្គិកោ មគ្គោ សោតោ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ សម្មាសង្កប្បោ

១ ឱ. សោតោ សោតាតិហេ ។

ហើយអង្គីយកង្គីទៃសមគួរ ។ លុះព្រះសារីបុត្តដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគក៏ទ្រង់ត្រាស់ដូច្នេះថា ម្នាលសារីបុត្ត គេតែងពោលថា អង្គនៃសោតាបត្តិ ។ ដូច្នេះ ម្នាលសារីបុត្ត ចុះអង្គនៃសោតាបត្តិ តើដូចម្តេច ។

[១២៩] បពិត្រព្រះអង្គដ៏ចំរើន ការសេពគប់ដោយសប្បុរស ជាអង្គនៃសោតាបត្តិ១ ការស្តាប់ព្រះសទ្ធម្ម ជាអង្គនៃសោតាបត្តិ១ ការធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ជាអង្គនៃសោតាបត្តិ ១ ការប្រតិបត្តិធម៌តាមសមគួរដល់ធម៌ ជាអង្គនៃសោតាបត្តិ១ ។

[១៣០] ម្នាលសារីបុត្ត ប្រពៃពេកណាស់ ម្នាលសារីបុត្ត មែនហើយ ការសេពគប់ដោយសប្បុរស ជាអង្គនៃសោតាបត្តិ១ ការស្តាប់ព្រះសទ្ធម្ម ជាអង្គនៃសោតាបត្តិ ១ ការធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ជាអង្គនៃសោតាបត្តិ១ ការប្រតិបត្តិធម៌តាមសមគួរដល់ធម៌ ជាអង្គនៃសោតាបត្តិ១ ។

[១៣១] ម្នាលសារីបុត្ត គេតែងពោលថា សោតៈ ។ ដូច្នេះ ម្នាលសារីបុត្ត ចុះសោតៈតើដូចម្តេច ។ បពិត្រព្រះអង្គដ៏ចំរើន ផ្លូវដ៏ប្រសើរប្រកបដោយអង្គ ៨ នេះឯង ជាសោតៈ ។ ផ្លូវដ៏ប្រសើរប្រកបដោយអង្គ ៨ តើដូចម្តេចខ្លះ ។ គឺសេចក្តីយល់ឃើញត្រូវ១ ការត្រិះរិះត្រូវ១

## វេឡុទ្វារវគ្គោ បឋមោ

សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធីតិ ។

(១៣២) សាធុ សាធុ សារីបុត្ត អយមេវ ហិ សារីបុត្ត អរិយោ អដ្ឋង្គិកោ មគ្គោ សោតោ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។

(១៣៣) សោតាបន្នោ សោតាបន្នោតិ ហិទំ សារីបុត្ត វុច្ចតិ កតមោ នុ ខោ សារីបុត្ត សោតា-បន្នោតិ ។ យោ ហិ ភន្តេ ឥមិនា អរិយេន អដ្ឋង្គិ-កេន មគ្គេន សមន្នាគតោ អយំ វុច្ចតិ សោតាបន្នោ ស្វាយំ (១) អាយស្មា ឯវំនាមោ ឯវំគោត្តោតិ ។

(១៣៤) សាធុ សាធុ សារីបុត្ត ឥមិនា អរិយេន អដ្ឋង្គិកេន មគ្គេន សមន្នាគតោ អយំ វុច្ចតិ សោ-តាបន្នោ ស្វាយំ អាយស្មា ឯវំនាមោ ឯវំគោត្តោតិ ។

(១៣៥) សាវត្ថីនិទានំ ។ តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ ភគវតោ ចីវរកម្មំ ករោន្តិ និដ្ឋិតចីវរោ ភគវា តេមាសច្ចយេន ចារិកំ បក្កមិស្សតីតិ ។

---

១ ឱ យោយំ ។

## វេឡុទ្វារវគ្គ ទី ១

ការនិយាយត្រូវ ១ ការងារត្រូវ ១ ការចិញ្ចឹមជីវិតត្រូវ ១ ការព្យាយាមត្រូវ ១ ការរលឹកត្រូវ ១ ការដំកល់ចិត្តនឹងត្រូវ ១ ។

(១៣២) ម្នាលសារីបុត្ត ប្រពៃពេកណាស់ ម្នាលសារីបុត្ត មែនហើយ ផ្លូវដ៏ប្រសើរប្រកបដោយអង្គ ៨ នេះឯង ជាសោតៈ ។ ផ្លូវដ៏ប្រសើរប្រកបដោយអង្គ ៨ តើដូចម្តេចខ្លះ ។ គឺសេចក្តីឃើញត្រូវ ១ ។ បេ ។ ការដំកល់ចិត្តនឹងត្រូវ ១ ។

(១៣៣) ម្នាលសារីបុត្ត គេតែងពោលថា បុគ្គលដល់នូវសោតៈៗ ដូច្នេះ ម្នាលសារីបុត្ត ចុះបុគ្គលដល់នូវសោតៈតើដូចម្តេច ។ បពិត្រព្រះអង្គដ៏ចំរើន បុគ្គលណាប្រកបដោយផ្លូវដ៏ប្រសើរ ប្រកបដោយអង្គ៨នេះ ហៅថា បុគ្គលដល់នូវសោតៈ លោកដ៏មានអាយុនោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ ។

(១៣៤) ម្នាលសារីបុត្ត ប្រពៃពេកណាស់ បុគ្គលប្រកបដោយផ្លូវដ៏ប្រសើរ ប្រកបដោយអង្គ៨ នេះឯង នេះហៅថា បុគ្គលដល់នូវសោតៈ លោកដ៏មានអាយុនោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ ។

(១៣៥) សាវត្ថីនិទាន ។ សម័យនោះឯងភិក្ខុច្រើនរូបធ្វើចីវរកម្ម ថ្វាយព្រះដ៏មានព្រះភាគ កាលព្រះដ៏មានព្រះភាគ មានចីវរសម្រេចហើយលុះកន្លង ៣ ខែទៅ នឹងស្តេចចៀសចេញទៅកាន់ចារិក ។

[១៣៦] តេន ខោ បន សមយេន ឥសិទត្តបុរាណា ថបតយោ សាធុកេ បដិវសន្តិ កេនចិទេវ ករណីយេន ។ អស្សោសុំ ខោ ឥសិទត្តបុរាណា ថបតយោ សម្ពហុលា កិរ ភិក្ខូ ភគវតោ ចីវរកម្មំ ករោន្តិ និដ្ឋិតចីវរោ ភគវា តេមាសច្ចយេន ចារិកំ បក្កមិស្សតីតិ ។ អថខោ ឥសិទត្តបុរាណា ថបតយោ មគ្គេ បុរិសំ ឋបេសុំ យទា ត្វំ អម្ភោ បុរិស បស្សេយ្យាសិ ភគវន្តំ អាគច្ឆន្តំ អរហន្តំ សម្មាសម្ពុទ្ធំ អថ អម្ហាកំ អារោចេយ្យាសីតិ ។ ទ្វីហំ តីហំ ឋិតោ ខោ សោ បុរិសោ អទ្ទស ភគវន្តំ ទូរតោ វ អាគច្ឆន្តំ ទិស្វាន យេន ឥសិទត្តបុរាណា ថបតយោ តេនុបសង្កមិ ឧបសង្កមិត្វា ឥសិទត្តបុរាណេ ថបតយោ ឯតទវោច អយំ សោ ភន្តេ ភគវា អាគច្ឆតិ អរហំ សម្មាសម្ពុទ្ធោ យស្សទានិ កាលំ មញ្ញថាតិ ។

[១៣៦] សម័យនោះឯង មាននាយជាងឈើ (ពីរនាក់) ឈ្មោះឥសិទត្ត (១) នឹងបុរាណៈ (២) នៅអាស្រ័យក្នុងស្រុកស្ទួយ ឥសិទត្ត នឹងបុរាណៈ បានឮដំណឹងថា ពួកភិក្ខុច្រើនរូបធ្វើចីវរកម្ម ថ្វាយព្រះដ៏មានព្រះភាគ កាលព្រះដ៏មានព្រះភាគ មានចីវរសម្រេចហើយ លុះកន្លង ៣ ខែទៅ ក៏នឹងស្តេចចៀសចេញទៅកាន់ចារិក ។ គ្រានោះនាយជាងឈើ ឈ្មោះឥសិទត្តនឹងបុរាណៈ បានឲ្យបុរសឈរចាំផ្លូវ (ហើយផ្តាំ) ថានែបុរសដ៏ចំរើន (បើ) អ្នកឃើញព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ ស្តេចមកក្នុងវេលាណា គប្បីប្រាប់ដល់យើងក្នុងវេលានោះ ។ បុរសនោះនៅចាំអស់ ២ ថ្ងៃ ៣ ថ្ងៃ ហើយ ក៏បានឃើញព្រះដ៏មានព្រះភាគ ទ្រង់ស្តេចមកអំពីចម្ងាយ លុះឃើញហើយ ក៏ត្រឡប់ចូលទៅរកនាយជាងឈើឈ្មោះឥសិទត្តនឹងបុរាណៈ លុះចូលទៅដល់ហើយ ក៏ជម្រាបទៅនាយជាងឈើឈ្មោះឥសិទត្តនឹងបុរាណៈដូច្នេះថា បពិត្រអ្នកដ៏ចំរើន ព្រះដ៏មានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធនោះ ទ្រង់ស្តេចមកដល់ហើយ អ្នកទាំងឡាយសំគាល់នូវកាលគួរ ក្នុងកាលឥឡូវនេះចុះ ។

---

១ - បានសម្រេចសកទាគាមិ ។ ២ បានសម្រេចសោតៈ ( អដ្ឋកថា ) ។

## វេឡុទ្វារវគ្គោ បឋមោ

(១៣៧) អថខោ ឥសិទត្តបុរាណា ថបតយោ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ភគវន្តំ បិដ្ឋិតោ បិដ្ឋិតោ អនុពន្ធឹសុ ។ អថខោ ភគវា មគ្គា ឱក្កម្ម យេន អញ្ញតរំ រុក្ខមូលំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ ឥសិទត្តបុរាណា ថបតយោ ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ឥសិទត្តបុរាណា ថបតយោ ភគវន្តំ ឯតទវោចុំ

(១៣៨) យទា មយំ ភន្តេ ភគវន្តំ សុណាម សាវត្ថិយា កោសលេសុ ចារិកំ បក្កមិស្សតីតិ ហោតិ នោ តស្មឹ សមយេ អនត្តមនតា ហោតិ ទោមនស្សំ ទូរេ នោ ភគវា ភវិស្សតីតិ ។ យទា បន មយំ ភន្តេ ភគវន្តំ សុណាម សាវត្ថិយា កោសលេសុ ចារិកំ បក្កន្តោតិ

## វេឡុទ្វារវគ្គ ទី ១

[១៣៧] គ្រានោះ នាយជាងឈើឈ្មោះឥសិទត្តនិងបុរាណៈ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ តាមជាប់ព្រះដ៏មានព្រះភាគអំពីក្រោយ ៗ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ស្តេចចៀសចេញអំពីផ្លូវ ចូលទៅគល់ឈើ ១ លុះចូលទៅដល់ហើយ ក៏ទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយ ៗ នាយជាងឈើឈ្មោះឥសិទត្តនិងបុរាណៈ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគហើយក៏អង្គុយក្នុងទីសមគួរ ។ លុះនាយជាងឈើឈ្មោះឥសិទត្តនិងបុរាណៈទាំងនោះ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា

[១៣៨] បពិត្រព្រះអង្គដ៏ចំរើន យើងខ្ញុំព្រះអង្គឮដំណឹងថា ព្រះដ៏មានព្រះភាគ នឹងស្តេចចេញចាកក្រុងសាវត្ថី ទៅកាន់ចារិកក្នុងដែនកោសល ក្នុងវេលាណា សេចក្តីតូចចិត្តនិងសេចក្តីទោមនស្ស ក៏កើតឡើងដល់យើងខ្ញុំព្រះអង្គ ក្នុងវេលានោះ ដោយគិតថា ព្រះដ៏មានព្រះភាគរបស់យើងទាំងឡាយ នឹងនៅក្នុងទីឆ្ងាយ ។ បពិត្រព្រះអង្គដ៏ចំរើនមួយទៀត យើងខ្ញុំព្រះអង្គឮដំណឹងថា ព្រះដ៏មានព្រះភាគស្តេចចេញចាកក្រុងសាវត្ថី ទៅកាន់ចារិកក្នុងដែនកោសលហើយ ក្នុងវេលាណា

ហោតិ នោ តស្មឹ សមយេ អនត្តមនតា ហោតិ ទោមនស្សំ ទូរេ នោ ភគវាតិ ។

(១៣៩) យទា បន មយំ ភន្តេ ភគវន្តំ សុណាម កោសលេហិ មគធេ ចារិកំ(១) បក្កមិស្សតីតិ ហោតិ នោ តស្មឹ សមយេ អនត្តមនតា ហោតិ ទោមនស្សំ ទូរេ នោ ភគវា ភវិស្សតីតិ ។ យទា បន មយំ ភន្តេ ភគវន្តំ សុណាម កោសលេហិ មគធេ ចារិកំ បក្កន្តោតិ ហោតិ នោ តស្មឹ សមយេ អនត្តមនតា ហោតិ ទោមនស្សំ ទូរេ នោ ភគវាតិ ។

(១៤០) យទា បន មយំ ភន្តេ ភគវន្តំ សុណាម មគធេហិ វជ្ជី ចារិកំ បក្កមិស្សតីតិ ហោតិ នោ តស្មឹ សមយេ អនត្តមនតា ហោតិ ទោមនស្សំ ទូរេ នោ ភគវា ភវិស្សតីតិ ។

---

១ ឱ. មគធេ ចារិកំ ។

សេចក្តីតូចចិត្តនឹងសេចក្តីទោមនស្ស ក៏កើតឡើងដល់យើងខ្ញុំព្រះអង្គ ក្នុងវេលានោះ ដោយគិតថា ព្រះដ៏មានព្រះភាគរបស់យើងទាំងឡាយ នៅក្នុងទីឆ្ងាយហើយ ។

[ ១៣៩ ] បពិត្រព្រះអង្គដ៏ចំរើន មួយទៀតយើងខ្ញុំព្រះអង្គឮដំណឹងថា ព្រះដ៏មានព្រះភាគ នឹងស្តេចចេញចាកដែនកោសល ទៅកាន់ចារិកក្នុងដែនមល្លៈក្នុងវេលាណា សេចក្តីតូចចិត្តនឹងសេចក្តីទោមនស្ស ក៏កើតឡើងដល់យើងខ្ញុំព្រះអង្គ ក្នុងវេលានោះ ដោយគិតថា ព្រះដ៏មានព្រះភាគរបស់យើងនឹងនៅក្នុងទីឆ្ងាយ ។ បពិត្រព្រះអង្គដ៏ចំរើន មួយទៀត យើងខ្ញុំព្រះអង្គឮដំណឹងថា ព្រះដ៏មានព្រះភាគទ្រង់ស្តេចចេញចាកដែនកោសលហើយ ទៅកាន់ចារិកក្នុងដែនមល្លៈក្នុងវេលាណា សេចក្តីតូចចិត្តនឹងសេចក្តីទោមនស្សក៏កើតឡើងដល់យើងខ្ញុំព្រះអង្គក្នុងវេលានោះ ដោយគិតថា ព្រះដ៏មានព្រះភាគរបស់យើងទាំងឡាយ នៅក្នុងទីឆ្ងាយហើយ ។

[១៤០] បពិត្រព្រះអង្គដ៏ចំរើន មួយទៀត យើងខ្ញុំទាំងឡាយឮដំណឹងថា ព្រះដ៏មានព្រះភាគនឹងស្តេចចេញចាកដែនមល្លៈ ទៅកាន់ចារិកក្នុងដែនវជ្ជី ក្នុងវេលាណា សេចក្តីតូចចិត្តនឹងសេចក្តីទោមនស្ស ក៏កើតឡើងដល់យើងខ្ញុំព្រះអង្គក្នុងវេលានោះ ដោយគិតថា ព្រះដ៏មានព្រះភាគ របស់យើងទាំងឡាយ នឹងនៅក្នុងទីឆ្ងាយហើយ ។

## វេឡុទ្វារវគ្គោ បឋមោ

យទា បន មយំ ភន្តេ ភគវន្តំ សុណាម មល្លេហិ វជ្ជី ចារិកំ បក្កន្តោតិ ហោតិ នោ តស្មឹ សមយេ អនត្តមនតា ហោតិ ទោមនស្សំ ទូរេ នោ ភគវាតិ ។

[១៤១] យទា បន មយំ ភន្តេ ភគវន្តំ សុណាម វជ្ជីហិ កាសី ចារិកំ បក្កមិស្សតីតិ ហោតិ នោ តស្មឹ សមយេ អនត្តមនតា ហោតិ ទោមនស្សំ ទូរេ នោ ភគវា ភវិស្សតីតិ ។ យទា បន មយំ ភន្តេ ភគវន្តំ សុណាម វជ្ជីហិ កាសី ចារិកំ បក្កន្តោតិ ហោតិ នោ តស្មឹ សមយេ អនត្តមនតា ហោតិ ទោមនស្សំ ទូរេ នោ ភគវាតិ ។

## វេឡុទ្វារវគ្គ ទី ១

បពិត្រព្រះអង្គដ៏ចំរើន មួយទៀត យើងខ្ញុំព្រះអង្គឮដំណឹងថា ព្រះដ៏មានព្រះភាគ ទ្រង់ស្តេចចេញចាកដែនមល្លៈទៅកាន់ចារិកក្នុងដែនវជ្ជីហើយ ក្នុងវេលាណា សេចក្តីតូចចិត្តនិងសេចក្តីទោមនស្ស ក៏កើតឡើងដល់យើងខ្ញុំព្រះអង្គក្នុងវេលានោះ ដោយគិតថា ព្រះដ៏មានព្រះភាគ របស់យើងទាំងឡាយនៅក្នុងទីឆ្ងាយហើយ ។

(១៤១) បពិត្រព្រះអង្គដ៏ចំរើន មួយទៀត យើងខ្ញុំព្រះអង្គឮដំណឹងថា ព្រះដ៏មានព្រះភាគ នឹងស្តេចចេញចាកដែនវជ្ជី ទៅកាន់ចារិកក្នុងដែនកាសី ក្នុងវេលាណា សេចក្តីតូចចិត្តនិងសេចក្តីទោមនស្ស ក៏កើតឡើងដល់យើងខ្ញុំព្រះអង្គ ក្នុងវេលានោះ ដោយគិតថា ព្រះដ៏មានព្រះភាគ របស់យើងទាំងឡាយនឹងនៅក្នុងទីឆ្ងាយ ។ បពិត្រព្រះអង្គដ៏ចំរើន មួយទៀត យើងខ្ញុំព្រះអង្គឮដំណឹងថា ព្រះដ៏មានព្រះភាគ ស្តេចចេញចាកដែនវជ្ជី ទៅកាន់ចារិកក្នុងដែនកាសីហើយ ក្នុងវេលាណា សេចក្តីតូចចិត្តនិងសេចក្តីទោមនស្ស ក៏កើតឡើងដល់យើងខ្ញុំព្រះអង្គ ក្នុងវេលានោះ ដោយគិតថា ព្រះដ៏មានព្រះភាគរបស់យើងទាំងឡាយនៅក្នុងទីឆ្ងាយហើយ ។

## សុត្តន្តបិដកេ សំយុត្តនិកាយស្ស មហាវគ្គោ

(១៦២) យទា បន មយំ ភន្តេ ភគវន្តំ សុ-ណោម កាសីហិ មគធេ ចារិកំ បក្កមិស្សតីតិ ហោតិ នោ តស្មឹ សមយេ អនត្តមនតា ហោតិ ទោមនស្សំ ទូរេ នោ ភគវា ភវិស្សតីតិ ។ យទា បន មយំ ភន្តេ ភគវន្តំ សុណោម កាសីហិ មគធេ ចារិកំ បក្កន្តោតិ ហោតិ អនប្បកា នោ តស្មឹ សមយេ អនត្តមនតា ហោតិ អនប្បកំ ទោមនស្សំ ទូរេ នោ ភគវាតិ ។

(១៦៣) យទា បន មយំ ភន្តេ ភគវន្តំ សុណោម មគធេហិ កាសី ចារិកំ បក្កមិស្សតីតិ ហោតិ នោ តស្មឹ សមយេ អត្តមនតា ហោតិ សោមនស្សំ អាសន្នេ នោ ភគវា ភវិស្សតីតិ ។

(១៤២) បពិត្រព្រះអង្គដ៏ចំរើន មួយទៀត យើងខ្ញុំព្រះអង្គឮដំណឹងថា ព្រះដ៏មានព្រះភាគ នឹងស្តេចចេញចាកដែនកាសី ទៅកាន់ចារិកក្នុងដែនមគធៈ ក្នុងវេលាណា សេចក្តីតូចចិត្តនឹងសេចក្តីទោមនស្ស ក៏កើតឡើងដល់យើងខ្ញុំព្រះអង្គ ក្នុងវេលានោះ ដោយគិតថា ព្រះដ៏មានព្រះភាគរបស់យើងទាំងឡាយ នឹងនៅក្នុងទីឆ្ងាយ ។ បពិត្រព្រះអង្គដ៏ចំរើន មួយទៀត យើងខ្ញុំព្រះអង្គឮដំណឹងថា ព្រះដ៏មានព្រះភាគស្តេចចេញចាកដែនកាសី ទៅកាន់ចារិកក្នុងដែនមគធៈហើយ ក្នុងវេលាណា សេចក្តីតូចចិត្តច្រើននឹងសេចក្តីទោមនស្សច្រើន ក៏កើតឡើងដល់យើងខ្ញុំព្រះអង្គ ក្នុងវេលានោះ ដោយគិតថា ព្រះដ៏មានព្រះភាគរបស់យើងទាំងឡាយ នៅក្នុងទីឆ្ងាយហើយ ។

(១៤៣) បពិត្រព្រះអង្គដ៏ចំរើន មួយទៀត យើងខ្ញុំព្រះអង្គឮដំណឹងថា ព្រះដ៏មានព្រះភាគនឹងស្តេចចេញចាកដែនមគធៈ ទៅកាន់ចារិកក្នុងដែនកាសី ក្នុងវេលាណា សេចក្តីរីករាយនឹងសេចក្តីសោមនស្ស ក៏កើតឡើងដល់យើងខ្ញុំព្រះអង្គ ក្នុងវេលានោះ ដោយគិតថា ព្រះដ៏មានព្រះភាគ របស់យើងទាំងឡាយ នឹងនៅក្នុងទីជិត ។

## វេឡុទ្វារវគ្គោ បឋមោ

យទា បន មយំ ភន្តេ ភគវន្តំ សុណាម មគធេហិ កាសឹ ចារិកំ បក្កន្តោតិ ហោតិ នោ តស្មឹ សមយេ អត្តមនតា ហោតិ សោមនស្សំ អាសន្នេ នោ ភគវាតិ ។

(១៤៤) យទា បន មយំ ភន្តេ ភគវន្តំ សុណាម កាសីហិ វជ្ជី ចារិកំ បក្កមិស្សតីតិ ហោតិ នោ តស្មឹ សមយេ អត្តមនតា ហោតិ សោមនស្សំ អាសន្នេ នោ ភគវា ភវិស្សតីតិ ។ យទា បន មយំ ភន្តេ ភគវន្តំ សុណាម កាសីហិ វជ្ជី ចារិកំ បក្កន្តោតិ ហោតិ នោ តស្មឹ សមយេ អត្តមនតា ហោតិ សោមនស្សំ អាសន្នេ នោ ភគវាតិ ។

បពិត្រព្រះអង្គដ៏ចំរើន មួយទៀត យើងខ្ញុំព្រះអង្គឮដំណឹងថា ព្រះដ៏មានព្រះភាគ ស្តេចបានចេញចាកដែនមគធៈ ទៅកាន់ចារិកក្នុងដែនកាសីហើយ ក្នុងវេលាណា សេចក្តីរីករាយនឹងសេចក្តីសោមនស្ស ក៏កើតឡើងដល់យើងខ្ញុំព្រះអង្គក្នុងវេលានោះ ដោយគិតថា ព្រះដ៏មានព្រះភាគរបស់យើងទាំងឡាយ នៅក្នុងទីជិតហើយ ។

(១៨៤) បពិត្រព្រះអង្គដ៏ចំរើន មួយទៀត យើងខ្ញុំព្រះអង្គឮដំណឹងថា ព្រះដ៏មានព្រះភាគ ទឹងស្តេចចេញចាកដែនកាសី ទៅកានចារិកក្នុងដែនវជ្ជី ក្នុងវេលាណា សេចក្តីរីករាយនឹងសេចក្តីសោ-មនស្ស ក៏កើតឡើងដល់យើងខ្ញុំព្រះអង្គក្នុងវេលានោះ ដោយគិតថា ព្រះដ៏មានព្រះភាគ របស់យើងទាំងឡាយ ទឹងនៅក្នុងទីជិត ។ បពិត្រព្រះអង្គដ៏ចំរើន មួយទៀត យើងខ្ញុំព្រះអង្គឮដំណឹងថា ព្រះដ៏មានព្រះភាគស្តេចបានចេញចាកដែនកាសី ទៅកាន់ចារិកក្នុងដែនវជ្ជីហើយ ក្នុងវេលាណា សេចក្តីរីករាយនឹងសេចក្តីសោមនស្ស ក៏កើតឡើងដល់យើងខ្ញុំព្រះអង្គក្នុងវេលានោះ ដោយគិតថា ព្រះដ៏មានព្រះភាគរបស់យើងទាំងឡាយនៅក្នុងទីជិតហើយ ។

(១៤៥) យទា បន មយំ ភន្តេ ភគវន្តំ សុណាម វជ្ជីហិ មល្លេ ចារិកំ បក្កមិស្សតីតិ ហោតិ នោ តស្មឹ សមយេ អត្តមនតា ហោតិ សោមនស្សំ អាសន្នេ នោ ភគវា ភវិស្សតីតិ ។ យទា បន មយំ ភន្តេ ភគវន្តំ សុណាម វជ្ជីហិ មល្លេ ចារិកំ បក្កន្តោតិ ហោតិ នោ តស្មឹ សមយេ អត្តមនតា ហោតិ សោមនស្សំ អាសន្នេ នោ ភគវាតិ ។

(១៤៦) យទា បន មយំ ភន្តេ ភគវន្តំ សុណាម មល្លេហិ កោសលេសុ ចារិកំ បក្កមិស្សតីតិ ហោតិ នោ តស្មឹ សមយេ អត្តមនតា ហោតិ សោមនស្សំ អាសន្នេ នោ ភគវា ភវិស្សតីតិ ។ យទា បន មយំ ភន្តេ ភគវន្តំ សុណាម មល្លេហិ កោសលេសុ ចារិកំ បក្កន្តោតិ

(១៨៥) បពិត្រព្រះអង្គដ៏ចំរើន មួយទៀត យើងខ្ញុំព្រះអង្គឮដំណឹងថា ព្រះដ៏មានព្រះភាគនឹងស្តេចចេញចាកដែនវជ្ជី ទៅកាន់ចារិកក្នុងដែនមល្លៈ ក្នុងវេលាណា សេចក្តីរីករាយនិងសេចក្តីសោមនស្ស ក៏កើតឡើងដល់យើងខ្ញុំព្រះអង្គ ក្នុងវេលានោះ ដោយគិតថា ព្រះដ៏មានព្រះភាគរបស់យើងទាំងឡាយ នឹងនៅក្នុងទីជិត ។ បពិត្រព្រះអង្គដ៏ចំរើន មួយទៀត យើងខ្ញុំព្រះអង្គឮដំណឹងថា ព្រះដ៏មានព្រះភាគស្តេចបានចេញចាកដែនវជ្ជី ទៅកាន់ចារិកក្នុងដែនមល្លៈហើយ ក្នុងវេលាណា សេចក្តីរីករាយនិងសេចក្តីសោមនស្ស ក៏កើតឡើងដល់យើងខ្ញុំព្រះអង្គក្នុងវេលានោះ ដោយគិតថា ព្រះដ៏មានព្រះភាគរបស់យើងទាំងឡាយ នៅក្នុងទីជិតហើយ ។

(១៨៦) បពិត្រព្រះអង្គដ៏ចំរើន មួយទៀត យើងខ្ញុំព្រះអង្គឮដំណឹងថា ព្រះដ៏មានព្រះភាគ នឹងស្តេចចេញចាកដែនមល្លៈទៅកាន់ចារិកក្នុងដែនកោសល ក្នុងវេលាណា សេចក្តីរីករាយនិងសេចក្តីសោមនស្ស ក៏កើតឡើងដល់យើងខ្ញុំព្រះអង្គក្នុងវេលានោះ ដោយគិតថា ព្រះដ៏មានព្រះភាគរបស់យើងទាំងឡាយនឹងនៅក្នុងទីជិត ។ បពិត្រព្រះអង្គដ៏ចំរើន មួយទៀត យើងខ្ញុំព្រះអង្គឮដំណឹងថា ព្រះដ៏មានព្រះភាគ ស្តេចបានចេញចាកដែនមល្លៈ ទៅកាន់ចារិកក្នុងដែនកោសលហើយ ក្នុងវេលាណា

## វេឡុទ្វារវគ្គោ បឋមោ

ហោតិ នោ តស្មឹ សមយេ អត្តមនតា ហោតិ សោមនស្សំ អាសន្នេ នោ ភគវាតិ ។

(១៤៧) យទា បន មយំ ភន្តេ ភគវន្តំ សុណាម កោសលេហិ សាវត្ថឹ ចារិកំ បក្កមិស្សតីតិ ហោតិ នោ តស្មឹ សមយេ អត្តមនតា ហោតិ សោមនស្សំ អាសន្នេ នោ ភគវា ភវិស្សតីតិ ។ យទា បន មយំ ភន្តេ ភគវន្តំ សុណាម សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេតិ ហោតិ អនប្បកា នោ តស្មឹ សមយេ អត្តមនតា ហោតិ អនប្បកំ សោមនស្សំ អាសន្នេ នោ ភគវាតិ ។

(១៤៨) តស្មាតិហ ថបតយោ សម្ពាធោ ឃរាវាសោ រជាបថោ អព្ភោកាសោ បព្វជ្ជា អលំ ច បន វោ ថបតយោ អប្បមាទាយាតិ ។

## វេឡុទ្វារវគ្គ ទី ១

សេចក្តីរីករាយនឹងសេចក្តីសោមនស្ស ក៏កើតឡើងដល់យើងខ្ញុំព្រះអង្គ ក្នុងវេលានោះ ដោយគិតថា ព្រះដ៏មានព្រះភាគ របស់យើងទាំងឡាយ នៅក្នុងទីជិតហើយ ។

(១៤៧) បពិត្រព្រះអង្គដ៏ចំរើន មួយទៀត យើងខ្ញុំព្រះអង្គ ឮដំណឹងថា ព្រះដ៏មានព្រះភាគ នឹងស្តេចចេញចាកដែនកោសល ទៅកាន់ចារិកក្នុងក្រុងសាវត្ថី ក្នុងវេលាណា សេចក្តីរីករាយនឹងសេចក្តីសោមនស្ស ក៏កើតឡើងដល់ខ្ញុំព្រះអង្គ ក្នុងវេលានោះ ដោយគិតថា ព្រះដ៏មានព្រះភាគ របស់យើងទាំងឡាយ នឹងនៅក្នុងទីជិត ។ បពិត្រព្រះអង្គដ៏ចំរើន មួយទៀត យើងខ្ញុំព្រះអង្គឮដំណឹងថា ព្រះដ៏មានព្រះភាគ ទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ក្នុងវេលាណា សេចក្តីរីករាយច្រើននឹងសេចក្តីសោមនស្សច្រើន ក៏កើតឡើងដល់យើងខ្ញុំព្រះអង្គ ក្នុងវេលានោះ ដោយគិតថា ព្រះដ៏មានព្រះភាគ របស់យើងទាំងឡាយនៅក្នុងទីជិត ។

(១៤៨) ព្រះអង្គត្រាស់ថា ម្នាលនាយជាងឈើទាំងឡាយ ព្រោះហេតុនោះ ក្នុងលោកនេះ ការនៅគ្រប់គ្រងផ្ទះ ជាទីចង្អៀត ជាផ្លូវហូរមកនៃធូលី មានតែបព្វជ្ជាទើបមានឱកាសទូលាយ ម្នាលនាយជាងឈើទាំងឡាយ គួរអ្នកទាំងឡាយកុំប្រមាទ ។

(១៤៩) អត្ថិ ខោ ភន្តេ ឯតម្ហា សម្ពាធា អញ្ញោ សម្ពាធោ សម្ពាធតរោ ចេវ សម្ពាធសង្ខាតតរោ ចាតិ ។ កតមោ បន វោ ថបតយោ ឯតម្ហា សម្ពាធា អញ្ញោ សម្ពាធោ សម្ពាធតរោ ចេវ សម្ពាធសង្ខាតតរោ ចាតិ ។

(១៥០) ឥធ មយំ ភន្តេ យទា រាជា បសេនទិកោសលោ ឧយ្យានភូមឹ និយ្យាតុកាមោ ហោតិ យេ តេ រញ្ញោ បសេនទិស្ស កោសលស្ស នាគា ឱបវយ្ហា(១) តេ កប្បេត្វា យា តា រញ្ញោ បសេនទិស្ស កោសលស្ស បជាបតិយោ បិយា មនាបា តា ឯកំ បុរតោ ឯកំ បច្ឆតោ និសីទាបេម ។ តាសំ ខោ បន ភន្តេ ភគិនីនំ ឯវរូបោ គន្ធោ ហោតិ សេយ្យថាបិ នាម គន្ធករណ្ឌកស្ស តាវទេវ វិវរិយមានស្ស យថា តំ រាជកញ្ញានំ គន្ធេន វិភូសិតានំ ។

---

១ ឱ. ឱបនវយ្ហា ។ ម. ឱបវយ្ហា ។

[១៨៩] បពិត្រព្រះអង្គដ៏ចំរើន សេចក្តីបង្រៀនដទៃ ដែលបង្រៀនដោយវិសេសផង ដែលពោលថា បង្រៀនដោយវិសេសផង ជាងសេចក្តីបង្រៀននុះរបស់យើងខ្ញុំព្រះអង្គមានដោយពិត ៗ ម្នាលនាយជាងឈើទាំងឡាយ ចុះសេចក្តីបង្រៀនដទៃ ដែលបង្រៀនដោយវិសេសផង ដែលពោលថា បង្រៀនដោយវិសេសផង ជាងសេចក្តីបង្រៀននុះរបស់អ្នកទាំងឡាយ តើដូចម្តេច ៗ

[១៩០] បពិត្រព្រះអង្គដ៏ចំរើន ក្នុងទីនេះ បើព្រះបាទបសេនទិកោសលមានប្រាថ្នានឹងស្តេចចេញទៅកាន់ទីឧទ្យានក្នុងកាលណា យើងខ្ញុំព្រះអង្គ ក៏រៀបចំដំរីដ៏ប្រសើរទាំងឡាយ ដែលជាព្រះទីនាំងរបស់ព្រះបាទបសេនទិកោសល ហើយ (រៀប) ព្រះមហេសីទាំងឡាយ ដែលជាទីស្រឡាញ់ ជាទីគាប់ព្រះហឫទ័យនៃព្រះបាទបសេនទិកោសល ឲ្យម្នាក់អង្គុយខាងមុខ ម្នាក់អង្គុយខាងក្រោយ (ក្នុងកាលនោះ) ៗ បពិត្រព្រះអង្គដ៏ចំរើន ឯក្លិនមានសភាពដូច្នេះ របស់នាងទាំងនោះឯង ប្រៀបដូចជាខ្ទូមានក្លិន ដែលគេបើកឡើងភ្លាមយ៉ាងណា ឯក្លិននៃពួកព្រះរាជកញ្ញា ដែលស្អិតស្អាងដោយក្លិនក៏ដូច្នោះឯង ៗ

តាសំ ខោ បន ភន្តេ ភគិនីនំ ឯវរូបោ កាយ-សម្ផស្សោ ហោតិ សេយ្យថាបិ នាម តូលបិចុនោ(១) វា កប្បាសបិចុនោ វា យថា តំ រាជកញ្ញានំ សុខេធិតានំ(២) ។ តស្មិំ ខោ បន ភន្តេ សមយេ នាថោបិ រក្ខិតព្វោ ហោតិ តាបិ ភគិនិយោ រក្ខិតព្វា ហោន្តិ អត្តាបិ រក្ខិតព្វោ ហោតិ ។

(១៥១) ន ខោ បន មយំ ភន្តេ អភិជានាម តាសុ ភគិនីសុ បាបកំ ចិត្តំ ឧប្បាទេតា ។ អយំ ខោ នោ ភន្តេ ឯតម្ហា សម្ពាធា អញ្ញោ សម្ពាធោ សម្ពាធតរោ ចេវ សម្ពាធសម្មតតរោ ចាតិ ។

(១៥២) តស្មាតិហ ថបតយោ សម្ពាធោ ឃរាវា-សោ រជាបថោ អព្ភោកាសោ បព្វជ្ជា អលំ ច បន វោ ថបតយោ អប្បមាទាយ ។

(១៥៣) ចតូហិ ខោ ថបតយោ ធម្មេហិ សមន្នាគតោ អរិយសាវកោ សោតាបន្នោ ហោតិ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយណោ ។

---

១ ឱ· ថុលបិនោ វា ។ ២ សុខេធិតានន្តិប្បត្តិ ។

## វេឡុទ្វារវគ្គ ទី ១

បពិត្រព្រះអង្គដ៏ចំរើន ឯកាយសម្ផស្សមានសភាពដូច្នេះរបស់នាងទាំងនោះឯង ប្រៀបដូចជាសំឡីគរនឹងសំឡីកប្បាស យ៉ាងណា កាយសម្ផស្សរបស់ពួកព្រះរាជកញ្ញា ដែលប្រកបដោយសេចក្ដីសុខ ក៏ដូច្នោះឯង ។ បពិត្រព្រះអង្គដ៏ចំរើន សម័យនោះឯង យើងខ្ញុំព្រះអង្គ ត្រូវរក្សាដំរីដ៏ប្រសើរផង ត្រូវរក្សានាងទាំងនោះផង ត្រូវរក្សាខ្លួនផង ។

(១៩១) បពិត្រព្រះអង្គដ៏ចំរើន យើងខ្ញុំព្រះអង្គ មិនហ៊ានញុំាងចិត្តអាក្រក់ឲ្យកើតឡើងចំពោះនាងទាំងនោះឡើយ ។ បពិត្រព្រះអង្គដ៏ចំរើន នេះឯងជាសេចក្ដីបង្អៀតដទៃ ដែលបង្អៀតដោយវិសេសផង ដែលពោលថា បង្អៀតដោយវិសេសផង ជាងសេចក្ដីបង្អៀតនុ៎ះ ។

(១៩២) ម្នាលនាយជាងឈើទាំងឡាយ ព្រោះហេតុនោះ ក្នុងលោកនេះ ការនៅគ្រប់គ្រងផ្ទះជាទីបង្អៀត ជាផ្លូវហូរមកនៃធូលី មានតែបព្វជ្ជាទើបមានឱកាសទូលាយ ម្នាលនាយជាងឈើទាំងឡាយ គួរអ្នកទាំងឡាយកុំប្រមាទ ។

(១៩៣) ម្នាលនាយជាងឈើទាំងឡាយ អរិយសាវកអ្នកដល់នូវសោតៈហើយ ប្រកបដោយធម៌ ៤ យ៉ាង មានសភាពមិនបានធ្លាក់ចុះក្នុងអបាយ ជាបុគ្គលទៀង មានកិរិយាត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ។

កតមេហិ ចតូហិ ។ ឥធ ថបតយោ អរិយសាវកោ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ ឥតិបិ សោ ភគវា ។បេ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ធម្មេ ។ សង្ឃេ ។ វិគតមលមច្ឆេរេន ចេតសា អគារំ អជ្ឈាវសតិ មុត្តចាគោ បយតបាណី វោស្សគ្គរតោ យាចយោគោ ទានសំវិភាគរតោ ។ ឥមេហិ ខោ ថបតយោ ចតូហិ ធម្មេហិ សមន្នាគតោ អរិយសាវកោ សោតាបន្នោ ហោតិ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយណោ ។

(១៥៨) តុម្ហេ ខោ ថបតយោ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតា ឥតិបិ សោ ភគវា ។បេ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។

ប្រកបដោយធម៌ ៤ យ៉ាងតើដូចម្តេច ។ ម្នាលនាយជាងឈើទាំងឡាយ អរិយសាវកក្នុងសាសនានេះ ប្រកបដោយសេចក្តីជ្រះថ្លា មិនកម្រើកក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគអង្គនោះ ។បេ។ ទ្រង់ជាគ្រូនៃទេវតានឹងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវអរិយសច្ច ៤ ទ្រង់ឆ្ងាក់ចោលនូវត្រៃកព វែងវិលត្រឡប់មកកើតទៀត ។ ក្នុងព្រះធម៌ ។ ក្នុងព្រះសង្ឃ ។ មានចិត្តប្រាសចាកមន្ទិលគឺសេចក្តីកំណាញ់ នៅគ្រប់គ្រងផ្ទះ ជាអ្នកមានទានលះបង់ស្រឡះហើយ មានដៃលាងស្អាតហើយ ជាអ្នកត្រេកអរក្នុងការលះបង់គួរដល់ការសូម ត្រេកអរក្នុងការចែករំលែកនូវទាន ។ ម្នាលនាយជាងឈើទាំងឡាយ អរិយសាវកអ្នកដល់នូវសោតៈហើយ ប្រកបដោយធម៌ ៤ យ៉ាងនេះ មានសភាពមិនបានធ្លាក់ចុះក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ។

[ ១៥៤ ] ម្នាលនាយជាងឈើទាំងឡាយ អ្នកទាំងឡាយចូរប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគអង្គនោះ ។បេ។ ទ្រង់ជាគ្រូនៃទេវតានឹងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវអរិយសច្ច ៤ ទ្រង់ឆ្ងាក់ចោលនូវត្រៃកព វែងវិលត្រឡប់មកកើតទៀត ។

## វេឡុទ្វារវគ្គោ បឋមោ

ធម្មេ ។ សង្ឃេ ។ យំ ខោ បន កិញ្ចិ កុលេ ទេយ្យធម្មំ សព្វន្តំ អប្បដិវិភត្តំ សីលវន្តេហិ កល្យាណធម្មេហិ ។ តំ កឹ មញ្ញថ ថបតយោ ។ កតិ វិយ[១] តេ កោសលេសុ មនុស្សា យេ តុម្ហាកំ សមសមា យទិទំ ទានទានសំវិភាគេហីតិ ។ លាភា នោ ភន្តេ សុលទ្ធំ នោ ភន្តេ យេសំ នោ ភគវា ឯវំ បជានាតីតិ ។

(១៥៥) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា កោសលេសុ ចារិកំ ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធឹ យេន វេឡុទ្វារំ នាម កោសលានំ ព្រាហ្មណគាមោ តទវសរិ ។

---

១ ឱ. ម. កតិវិធា ។

## វេឡុទ្វារវគ្គ ទី ១

ក្នុងព្រះធម៌ ។ ក្នុងព្រះសង្ឃ ។ ទេយ្យធម៌ណាៗ បន្តិចបន្តួចក្នុងត្រកូល ទេយ្យធម៌ទាំងអស់នោះ បុគ្គលអ្នកមានសីល មានធម៌ល្អទាំងឡាយ មិនបានចែករំលែក(១) ឡើយ ។ ម្នាលនាយជាងឈើទាំងឡាយ អ្នកទាំងឡាយសំគាល់នូវដំណើរនោះដូចម្តេច ។ ក្នុងដែនកោសល មានមនុស្សចំនួនប៉ុន្មានស្មើៗគ្នានឹងអ្នកទាំងឡាយ ដោយការចែករំលែកនូវទានដោយទាន ។ បពិត្រព្រះអង្គដ៏ចំរើន (នេះ) ជាលាភរបស់យើងខ្ញុំព្រះអង្គ បពិត្រព្រះអង្គដ៏ចំរើន (អត្តភាពជាមនុស្សនេះ) យើងខ្ញុំព្រះអង្គ បានដោយល្អហើយ ព្រោះថាព្រះដ៏មានព្រះភាគ ជ្រាបច្បាស់នូវហេតុយ៉ាងនេះ របស់យើងខ្ញុំព្រះអង្គ ។

[១៩៩] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់ពុទ្ធដំណើរទៅកាន់ចារិក ក្នុងដែនកោសល ជាមួយនឹងភិក្ខុសង្ឃច្រើនអង្គ ក៏បានទៅដល់ស្រុកជាទីនៅនៃព្រាហ្មណ៍ ឈ្មោះវេឡុទ្វារក្នុងដែនកោសល ។

---

១ ពួកអ្នកមានសីល មានធម៌ល្អ កាលបើបានទេយ្យធម៌តិចក្តី ច្រើនក្តី មិនបានចែកឡែកដាច់មុខ ថា របស់នេះសម្រាប់អាត្មាអញ របស់នេះសម្រាប់ភិក្ខុទាំងឡាយ យ៉ាងនេះឡើយ ។ (អដ្ឋកថា) ។

(១៥៦) អស្សោសុំ ខោ (១) វេឡុទ្វារេយ្យកា ព្រាហ្មណគហបតិកា សមណោ ខលុ ភោ គោតមោ សក្យបុត្តោ សក្យកុលា បព្វជិតោ កោសលេសុ ចារិកំ ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធិំ វេឡុទ្វារំ អនុប្បត្តោ ។ តំ ខោ បន ភវន្តំ គោតមំ ឯវំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ សោ ឥមំ លោកំ សទេវកំ សមារកំ សព្រហ្មកំ សស្សមណព្រាហ្មណឹ បជំ សទេវមនុស្សំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ សោ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ

---

១ ឱ ម អស្សោសុំ ខោ តេ ។

(១៥៦) ពួកព្រាហ្មណ៍និងគហបតីអ្នកនៅក្នុងវេឡុទ្វារគ្រាមបានឮដំណឹងហើយ (ក៏ប្រកាសប្រាប់គ្នាថា) នែអ្នកទាំងឡាយដ៏ចំរើន ឮថាព្រះសមណគោតមជាសក្យបុត្ត ចេញចាកសក្យត្រកូល ទ្រង់ព្រះផ្នួស ឥឡូវនេះ ទ្រង់ស្តេចទៅកាន់ចារិកក្នុងដែនកោសល ជាមួយនឹងភិក្ខុសង្ឃច្រើនអង្គ បានដល់មកវេឡុទ្វារគ្រាមហើយ ។ ឯកិត្តិសព្ទដ៏ពីរោះរបស់ព្រះគោតមដ៏ចំរើននោះ ឮខ្ចរខ្ចាយសុះសាយទៅយ៉ាងនេះថា ព្រះដ៏មានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់បរិបូណ៌ដោយវិជ្ជានិងចរណៈ ទ្រង់មានដំណើរល្អយាងទៅកាន់ព្រះនិព្វាន ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ប្រសើរដោយសីលាទិគុណរកបុគ្គលណាមួយស្មើគ្មាន ទ្រង់ទូន្មាននូវបុរសដូចជានាយសារថី ទ្រង់ជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវអរិយសច្ច ៤ ទ្រង់ខ្ជាក់ចោលនូវត្រៃ-ភព លែងវិលត្រឡប់មកកើតទៀត ។ ព្រះអង្គបានធ្វើឲ្យជាក់ច្បាស់ បានត្រាស់ដឹងដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងនូវលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ទាំងពពួកសត្វ ព្រមទាំងសមណៈនិងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ព្រះអង្គទ្រង់សំដែងធម៌ពីរោះបទដើម បទកណ្តាល និងបទចុង

## វេឡុទ្វារវគ្គោ បឋមោ

សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេតិ សាធុ ខោ បន តថារូបានំ អរហតំ ទស្សនំ ហោតីតិ ។

(១៨៧) អថខោ(១) វេឡុទ្វារេយ្យកា ព្រាហ្មណគហបតិកា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា អប្បេកច្ចេ ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ អប្បេកច្ចេ ភគវតា សទ្ធឹ សម្មោទឹសុ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទឹសុ អប្បេកច្ចេ យេន ភគវា តេនញ្ជលិម្បណាមេត្វា ឯកមន្តំ និសីទឹសុ អប្បេកច្ចេ ភគវតោ សន្តិកេ នាមគោត្តំ សាវេត្វា ឯកមន្តំ និសីទឹសុ អប្បេកច្ចេ តុណ្ហីភូតា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ វេឡុទ្វារេយ្យកា ព្រាហ្មណគហបតិកា ភគវន្តំ ឯតទវោចុំ ។

(១៨៨) មយំ ភោ គោតម ឯវំកាមា ឯវំឆន្ទា ឯវំអធិប្បាយា បុត្តសម្ពាធា សយនំ អជ្ឈាវសេយ្យាម

---

១ ឱ. ម. ឯត្ថន្តរេ តេ ឥតិ បទំ អត្ថិ ។

## វេឡុទ្វារវគ្គ ទី ១

ទ្រង់ប្រកាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថ ព្រមទាំងព្យញ្ជនៈ ដ៏ពេញបរិបូណ៌បរិសុទ្ធទាំងអស់ ក៏ការដែលបានឃើញនូវព្រះអរហន្តទាំងឡាយ មានសភាពដូច្នេះ ជាការប្រពៃពេកណាស់ ។

(១៥៧) គ្រានោះ ពួកព្រាហ្មណ៍និងគហបតីអ្នកនៅក្នុងវេឡុទ្វារគ្រាម ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ពួកខ្លះ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ពួកខ្លះក៏ពោលរាក់ទាក់ជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររាក់ទាក់ នឹងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ពួកខ្លះអង្គុយក្នុងទីសមគួរ ប្រណម្យអញ្ជលី ឆ្ពោះទៅរកព្រះដ៏មានព្រះភាគ ពួកខ្លះ អង្គុយក្នុងទីសមគួរ ប្រកាសនូវនាមនិងគោត្រក្នុងសំណាក់ព្រះដ៏មានព្រះភាគ ពួកខ្លះ នៅស្ងៀមអង្គុយក្នុងទីសមគួរ ។ លុះព្រាហ្មណ៍និងគហបតីអ្នកនៅក្នុងវេឡុទ្វារគ្រាមទាំងនោះ អង្គុយក្នុងទីសមគួរហើយក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា

(១៥៨) បពិត្រព្រះគោតមដ៏ចំរើន យើងខ្ញុំព្រះអង្គមានបំណងយ៉ាងនេះ មានសេចក្តីពេញចិត្តយ៉ាងនេះ មានសេចក្តីប្រាថ្នាយ៉ាងនេះ មានសេចក្តីបង្អៀតដោយកូន នៅគ្រប់គ្រងទីដេក

កាសិកចន្ទនំ បច្ចនុភវេយ្យាម មាលាគន្ធវិលេបនំ ធារេយ្យាម ជាតរូបរជតំ សាទិយេយ្យាម កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជេយ្យាម តេសំ នោ ភវំ គោតមោ អម្ហាកំ ឯវំកាមានំ ឯវំឆន្ទានំ ឯវំអធិប្បាយានំ តថា ធម្មំ ទេសេតុ យថា មយំ បុត្តសម្ពាធសយនំ អជ្ឈាវសេយ្យាម ។បេ។ សុគតឹ សគ្គំ លោកំ ឧបបជ្ជេយ្យាមាតិ ។

(១៤៩) អត្តុបណាយិកំ វោ គហបតយោ ធម្មបរិយាយំ ទេសេស្សាមិ តំ សុណាថ សាធុកំ មនសិការោថ ភាសិស្សាមីតិ ។ ឯវំ ភោតិ ខោ តេ វេឡុទ្វារេយ្យកា ព្រាហ្មណគហបតិកា ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច

បាននូវខ្លឹមចន្ទន៍ក្នុងដែនកាសី ទ្រទ្រង់នូវផ្កាកម្រង គ្រឿងក្រអូបនិងគ្រឿងលាប ត្រេកអរចំពោះមាសនិងប្រាក់ លុះបែកធ្លាយរាងកាយបន្ទាប់អំពីសេចក្ដីស្លាប់ទៅ គប្បីបានទៅកើតក្នុងសុគតិសួគ៌ទេវលោក យើងខ្ញុំព្រះអង្គមានសេចក្ដីបង្អៀតដោយកូន នៅគ្រប់គ្រងទីដេក ។បេ។ គប្បីបានទៅកើតក្នុងសុគតិសួគ៌ទេវលោកយ៉ាងណា សូមព្រះគោតមដ៏ចំរើន សំដែងនូវធម៌យ៉ាងនោះ ដល់យើងខ្ញុំព្រះអង្គទាំងនោះ ដែលមានបំណងយ៉ាងនេះ មានសេចក្ដីពេញចិត្តយ៉ាងនេះ មានសេចក្ដីប្រាថ្នាយ៉ាងនេះ ។

(១៨៩) ម្នាលព្រាហ្មណ៍និងគហបតីទាំងឡាយ តថាគតនឹងសំដែងនូវអត្តូបនាយិកធម្មបរិយាយ (បរិយាយធម៌ដែលបុគ្គលគបបង្អោនចូលទៅក្នុងខ្លួន) ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយយកចិត្តទុកដាក់ប្រុងចាំស្ដាប់ដោយប្រពៃនូវធម៌នោះចុះ តថាគតនឹងសំដែង ។ ពួកព្រាហ្មណ៍និងគហបតីអ្នកនៅក្នុងវេឡុទ្វារគ្រាមទាំងនោះ ទទួលស្ដាប់ព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា

## វេឡុទ្វារវគ្គោ បឋមោ

(១៦០) កតមោ ច គហបតយោ អត្តុបនាយិកោ
ធម្មបរិយាយោ ។ ឥធ គហបតយោ អរិយសាវកោ
ឥតិ បដិសញ្ចិក្ខតិ អហំ ខោស្មិ ជីវិតុកាមោ
អមរិតុកាមោ សុខកាមោ ទុក្ខប្បដិក្កូលោ យោ ខោ
មំ ជីវិតុកាមំ អមរិតុកាមំ សុខកាមំ ទុក្ខប្បដិក្កូលំ
ជីវិតា វោរោបេយ្យ ន មេ តំ អស្ស បិយំ មនាបំ
អហញ្ចេវ ខោ បន បរំ ជីវិតុកាមំ អមរិតុកាមំ
សុខកាមំ ទុក្ខប្បដិក្កូលំ ជីវិតា វោរោបេយ្យំ បរស្សបិ
តំ អស្ស អប្បិយំ អមនាបំ យោ ខោ ម្យាយំ
ធម្មោ អប្បិយោ អមនាបោ បរស្សបេសោ ធម្មោ
អប្បិយោ អមនាបោ យោ ខោ ម្យាយំ ធម្មោ
អប្បិយោ អមនាបោ កថាហំ បរំ តេន សញ្ញោ-
ជេយ្យន្តិ ។ សោ ឥតិ បដិសង្ខាយ អត្តនា ច
បាណាតិបាតា បដិវិរតោ ហោតិ បរញ្ច បាណាតិបាតា
វេរមណិយា សមាទបេតិ បាណាតិបាតា វេរមណិយា
ច វណ្ណំ ភាសតិ ។ ឯវមស្សាយំ កាយសមាចារោ
តិកោដិបរិសុទ្ធោ ហោតិ ។

## វេឡុទ្វារវគ្គ ទី ១

[ ១៦០ ] ម្នាលព្រាហ្មណ៍ និងគហបតីទាំងឡាយ ចុះអត្តូបនាយិកធម្មបរិយាយ តើដូចម្តេច ។ ម្នាលព្រាហ្មណ៍ និងគហបតីទាំងឡាយ អរិយសាវកក្នុងសាសនានេះ តែងពិចារណាដូច្នេះថា អាត្មាអញចង់រស់ មិនចង់ស្លាប់ ស្រឡាញ់សុខ ស្អប់ទុក្ខ បើបុគ្គលណាមកផ្តាច់បង់ជីវិត អាត្មាអញដែលចង់រស់ មិនចង់ស្លាប់ ស្រឡាញ់សុខ ស្អប់ទុក្ខ អំពើនោះមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញឡើយ ប្រសិនបើអាត្មាអញផ្តាច់បង់ជីវិតបុគ្គលដទៃ ដែលចង់រស់ មិនចង់ស្លាប់ ស្រឡាញ់សុខ ស្អប់ទុក្ខវិញ អំពើនោះក៏មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់បុគ្គលដទៃដែរ ធម៌ណាដែលមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញ ធម៌នុ៎ះក៏មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់បុគ្គលដទៃដែរ ធម៌ណាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញហើយ អាត្មាអញគប្បីញ៉ាំងបុគ្គលដទៃឲ្យប្រកបដោយធម៌នោះ ដូចម្តេចកើត ។ លុះអរិយសាវកនោះពិចារណាដូច្នេះហើយ ក៏វៀរចាកការសម្លាប់សត្វដោយខ្លួនឯងផង បបួលអ្នកដទៃឲ្យវៀរនូវការសម្លាប់សត្វផង សរសើរគុណនៃការវៀរចាកការសម្លាប់សត្វផង នេះជាកាយសមាចារ (ការប្រព្រឹត្តល្អដោយកាយ) មានបរិសុទ្ធ ៣ ចំណែករបស់អរិយសាវកនោះយ៉ាងនេះឯង ។

[ ១៦១ ] បុន ចបរំ គហបតយោ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ យោ ខោ មេ អទិន្នំ ថេយ្យសង្ខាតំ អាទិយេយ្យ ន មេ តំ អស្ស បិយំ មនាបំ អហញ្ចេវ ខោ បន បរស្ស អទិន្នំ ថេយ្យសង្ខាតំ អាទិយេយ្យំ បរស្សបិ តំ អស្ស អប្បិយំ អមនាបំ យោ ខោ ម្យាយំ ធម្មោ អប្បិយោ អមនាបោ បរស្សបេសោ ធម្មោ អប្បិយោ អមនាបោ យោ ខោ ម្យាយំ ធម្មោ អប្បិយោ អមនាបោ កថាហំ បរន្តេន សញ្ញោជេយ្យន្តិ ។ សោ ឥតិ បដិសង្ខាយ អត្តនា ច អទិន្នាទានា បដិវិរតោ ហោតិ បរញ្ច អទិន្នាទានា វេរមណិយា សមាទបេតិ អទិន្នាទានា វេរមណិយា ច វណ្ណំ ភាសតិ ។ ឯវមស្សាយំ កាយសមាចារោ តិកោដិបរិសុទ្ធោ ហោតិ ។

[ ១៦១ ] ម្នាលព្រាហ្មណ៍និងគហបតីទាំងឡាយ មួយទៀត អរិយសាវកតែងពិចារណាដូច្នេះថា បុគ្គលណាកាន់យកនូវវត្ថុដែលអាត្មាអញមិនបានឲ្យ គោលគឺលួចយកវត្ថុរបស់អាត្មាអញ អំពើនោះមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញឡើយ ប្រសិនបើអាត្មាអញកាន់យកវត្ថុដែលបុគ្គលដទៃមិនបានឲ្យ គោលគឺលួចយកវត្ថុរបស់បុគ្គលដទៃវិញ អំពើនោះក៏មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់បុគ្គលដទៃដែរ ធម៌ណាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញ ធម៌នុ៎ះក៏មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្ត របស់បុគ្គលដទៃដែរ ធម៌ណាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញហើយ អាត្មាអញគប្បីញុំាងបុគ្គលដទៃឲ្យប្រកបដោយអំពើនោះ ដូចម្តេចកើត ។ លុះអរិយសាវកនោះពិចារណាដូច្នេះហើយ ក៏វៀរចាកការកាន់យកវត្ថុដែលគេមិនបានឲ្យដោយខ្លួនឯងផង បបួលបុគ្គលដទៃឲ្យវៀរចាកការកាន់យកវត្ថុដែលគេមិនបានឲ្យផង សរសើរគុណនៃកិរិយាវៀរចាកការកាន់យកវត្ថុដែលគេមិនបានឲ្យផង ។ នេះជា កាយសមាចារ មានបរិសុទ្ធ ៣ ចំណែករបស់អរិយសាវកនោះយ៉ាងនេះ ។

## វេឡុទ្វារវគ្គោ បឋមោ

(១៦២) បុន ចបរំ គហបតយោ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ យោ ខោ មេ ទារេសុ ចារិត្តំ អាបជ្ជេយ្យ ន មេ តំ អស្ស បិយំ មនាបំ អហញ្ចេវ ខោ បន បរស្ស ទារេសុ ចារិត្តំ អាបជ្ជេយ្យំ បរស្សបិ តំ អស្ស អប្បិយំ អមនាបំ យោ ខោ ម្យាយំ ធម្មោ អប្បិយោ អមនាបោ បរស្សបេសោ ធម្មោ អប្បិយោ អមនាបោ យោ ខោ ម្យាយំ ធម្មោ អប្បិយោ អមនាបោ កថាហំ បរំ តេន សំយោជេយ្យន្តិ ។ សោ ឥតិ បដិសង្ខាយ អត្តនា ច កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ បរញ្ច កាមេសុ មិច្ឆាចារា វេរមណិយា សមាទបេតិ កាមេសុ មិច្ឆាចារា វេរមណិយា ច វណ្ណំ ភាសតិ ។ ឯវមស្សាយំ កាយសមាចារោ តិកោដិបរិសុទ្ធោ ហោតិ ។

## វេឡុទ្វារវគ្គ ទី ១

( ១៦២ ) ម្នាលព្រាហ្មណ៍និងគហបតីទាំងឡាយ មួយទៀត អរិយសាវកតែងពិចារណាដូច្នេះថា បុគ្គលណាដល់នូវការប្រព្រឹត្តិលើសក្នុងប្រពន្ធរបស់អាត្មាអញ អំពើនោះមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញឡើយ ប្រសិនបើអាត្មាអញគប្បីដល់នូវការប្រព្រឹត្តិលើសក្នុងប្រពន្ធរបស់បុគ្គលដទៃវិញ អំពើនោះក៏មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់បុគ្គលដទៃដែរ ធម៌ណាដែលមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញ ធម៌នុ៎ះក៏មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់បុគ្គលដទៃដែរ ធម៌ណាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញហើយ អាត្មាអញគប្បីញុំាងបុគ្គលដទៃឲ្យប្រកបដោយអំពើនោះ ដូចម្តេចកើត ។ លុះអរិយសាវកនោះពិចារណាដូច្នេះហើយ ក៏វៀរចាកការប្រព្រឹត្តិខុសក្នុងកាមដោយខ្លួនឯងផង បបួលបុគ្គលដទៃឲ្យវៀរចាកការប្រព្រឹត្តិខុសក្នុងកាមផង សរសើរគុណនៃកិរិយាវៀរចាកការប្រព្រឹត្តិខុសក្នុងកាមផង ។ នេះជា កាយសមាចារ មានបរិសុទ្ធ ៣ ចំណែក របស់អរិយសាវកនោះយ៉ាងនេះ ។

## សុត្តន្តបិដកេ សំយុត្តនិកាយស្ស មហាវគ្គោ

(១៦៣) បុន ចបរំ គហបតយោ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ យោ ខោ មេ មុសាវាទេន អត្ថំ ភញ្ជេយ្យ ន មេ តំ អស្ស បិយំ មនាបំ អហញ្ចេវ ខោ បន បរស្ស មុសាវាទេន អត្ថំ ភញ្ជេយ្យំ បរស្សបិ តំ អស្ស អប្បិយំ អមនាបំ យោ ខោ ម្វាយំ ធម្មោ អប្បិយោ អមនាបោ បរស្សបេសោ ធម្មោ អប្បិយោ អមនាបោ យោ ខោ ម្វាយំ ធម្មោ អប្បិយោ អមនាបោ កថាហំ បរេទ្តន សញ្ញោជេយ្យន្តិ ។ សោ ឥតិ បដិសង្ខាយ អត្តនា ច មុសាវាទា បដិវិរតោ ហោតិ បរញ្ច មុសាវាទា វេរមណិយា សមាទបេតិ មុសាវាទា វេរមណិយា ច វណ្ណំ ភាសតិ ។ ឯវមស្សាយំ វចីសមាចារោ តិកោដិបរិសុទ្ធោ ហោតិ ។

[ ១៦៣ ] ម្នាលព្រាហ្មណ៍និងគហបតីទាំងឡាយ មួយទៀត អរិយសាវកតែងពិចារណាដូច្នេះថា បុគ្គលណាបំបាក់បង់នូវប្រយោជន៍របស់អាត្មាអញ ដោយនិយាយកុហក អំពើនោះមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញឡើយ ប្រសិនបើអាត្មាអញគប្បីបំបាក់បង់នូវប្រយោជន៍របស់បុគ្គលដទៃ ដោយនិយាយកុហកវិញ អំពើនោះក៏មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់បុគ្គលដទៃដែរ ធម៌ណាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញ ធម៌នុ៎ះក៏មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់បុគ្គលដទៃដែរ ធម៌ណាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញហើយ អាត្មាអញគប្បីញុំាងបុគ្គលដទៃឲ្យប្រកបដោយធម៌នោះដូចម្តេចកើត ។ លុះអរិយសាវកនោះពិចារណាដូច្នេះហើយ ក៏វៀរចាកការនិយាយកុហក ដោយខ្លួនឯងផង បបួលបុគ្គលដទៃឲ្យវៀរចាកការនិយាយកុហកផង សរសើរគុណនៃកិរិយាវៀរចាកការនិយាយកុហកផង ។ នេះជា វចីសមាចារ ( ប្រព្រឹត្តល្អដោយវាចា ) មានបរិសុទ្ធ ៣ ចំណែក របស់អរិយសាវកនោះយ៉ាងនេះ ។

## វេឡុទ្វារវគ្គោ បឋមោ

(១៦៤) បុន ចបរំ គហបតយោ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ យោ ខោ មំ បិសុណាយ វាចាយ មិត្តេហិ ភេទេយ្យ ន មេ តំ អស្ស បិយំ មនាបំ អហញ្ចេវ ខោ បរំ បិសុណាយ វាចាយ មិត្តេហិ ភេទេយ្យំ បរស្សបិ តំ អស្ស អប្បិយំ អមនាបំ ។បេ។ ឯវមស្សាយំ វចីសមាចារោ តិកោដិបរិសុទ្ធោ ហោតិ ។

(១៦៥) បុន ចបរំ គហបតយោ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ យោ ខោ មំ ផរុសាយ វាចាយ សមុទាចរេយ្យ ន មេ តំ អស្ស បិយំ មនាបំ អហញ្ចេវ ខោ បរំ ផរុសាយ វាចាយ សមុទាចរេយ្យំ បរស្សបិ តំ អស្ស អប្បិយំ អមនាបំ យោ ខោ ម្យាយំ ធម្មោ ។បេ។ ឯវមស្សាយំ វចីសមាចារោ តិកោដិបរិសុទ្ធោ ហោតិ ។

## វេឡុទ្វារវគ្គ ទី ១

(១៦៤) ម្នាលព្រាហ្មណ៍និងគហបតីទាំងឡាយ មួយទៀត អរិយសាវកតែងពិចារណា ដូច្នេះថា បុគ្គលណា ញុំាងអញឲ្យបែកចាកពួកមិត្រដោយការនិយាយញុះញង់ អំពើនោះមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញឡើយ ប្រសិនបើអាត្មាអញញុំាងបុគ្គលដទៃឲ្យបែកចាកពួកមិត្រដោយនិយាយញុះញង់វិញ អំពើនោះក៏មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់បុគ្គលដទៃដែរ ។ បេ ។ នេះជាវចីសមាចារ មានបរិសុទ្ធ ៣ ចំណែក របស់អរិយសាវកនោះយ៉ាងនេះ ។

(១៦៥) ម្នាលព្រាហ្មណ៍និងគហបតីទាំងឡាយ មួយទៀត អរិយសាវកតែងពិចារណា ដូច្នេះថា បុគ្គលណាប្រព្រឹត្តនិយាយនឹងអាត្មាអញដោយសំដីទ្រគោះ អំពើនោះមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញឡើយ ប្រសិនបើអាត្មាអញប្រព្រឹត្តនិយាយនឹងបុគ្គលដទៃដោយសំដីទ្រគោះវិញ អំពើនោះក៏មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់បុគ្គលដទៃដែរ ធម៌ណា (មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្ត) របស់អាត្មាអញ ។ បេ ។ នេះជាវចីសមាចារ មានបរិសុទ្ធ ៣ ចំណែក របស់អរិយសាវកនោះយ៉ាងនេះ ។

[១៦៦] បុន ចបរំ គហបតយោ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ យោ ខោ មំ សម្ផប្បលាបភាសេន(១) សមុទាចរេយ្យ ន មេ តំ អស្ស បិយំ មនាបំ អហញ្ចេវ ខោ បន បរំ សម្ផប្បលាបភាសេន សមុទាចរេយ្យំ បរស្សបិ តំ អស្ស អប្បិយំ អមនាបំ យោ ខោ ម្យាយំ ធម្មោ អប្បិយោ អមនាបោ បរស្សបេសោ ធម្មោ អប្បិយោ អមនាបោ យោ ខោ ម្យាយំ ធម្មោ អប្បិយោ អមនាបោ កថាហំ បរំ តេន សំយោជេយ្យន្តិ ។ សោ ឥតិ បដិសង្ខាយ អត្តនា ច សម្ផប្បលាបា បដិវិរតោ ហោតិ បរញ្ច សម្ផប្បលាបា វេរមណិយា សមាទបេតិ សម្ផប្បលាបា វេរមណិយា ច វណ្ណំ ភាសតិ ។ ឯវមស្សាយំ វចីសមាចារោ តិកោដិបរិសុទ្ធោ ហោតិ ។

១ ឱ សម្បភាសេន សម្ផប្បលាបភាសេន ។ ម សម្ផភាសេន សម្ផប្បលាបភាសេន ។

(១៦៦) ម្នាលព្រាហ្មណ៍និងគហបតីទាំងឡាយ មួយវិញទៀត អរិយសាវកតែងពិចារណា ដូច្នេះថា បុគ្គលណាប្រព្រឹត្តនិយាយនឹងអាត្មាអញ ដោយពាក្យពេយពយឥតប្រយោជន៍ អំពើនោះមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញឡើយ ប្រសិនបើអាត្មាអញប្រព្រឹត្តនិយាយនឹងបុគ្គលដទៃ ដោយពាក្យពេយពយឥតប្រយោជន៍វិញ អំពើនោះក៏មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់បុគ្គលដទៃដែរ ធម៌ណាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញ ធម៌នុ៎ះក៏មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់បុគ្គលដទៃដែរ ធម៌ណាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញ ហើយអាត្មាអញគប្បីញុំាងបុគ្គលដទៃឲ្យប្រកបដោយធម៌នោះ ដូចម្ដេចកើត ។ លុះអរិយសាវកនោះពិចារណាដូច្នេះហើយ ក៏វៀរចាកការនិយាយពាក្យពេយពយឥតប្រយោជន៍ដោយខ្លួនឯងផង បបួលបុគ្គលដទៃឲ្យវៀរចាកការនិយាយពាក្យពេយពយឥតប្រយោជន៍ផង សរសើរគុណនៃកិរិយាវៀរចាកការនិយាយពាក្យពេយពយឥតប្រយោជន៍ផង ។ នេះជាវចីសមាចារ មានបរិសុទ្ធ ៣ ចំណែក របស់អរិយសាវកនោះយ៉ាងនេះ ។

## វេឡុទ្វារវគ្គោ បឋមោ

(១៦៧) សោ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ ឥតិបិ សោ ភគវា ។បេ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ធម្មេ ។ សង្ឃេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ។បេ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។ អរិយកន្តេហិ សីលេហិ សមន្នាគតោ ហោតិ អខណ្ឌេហិ អច្ឆិទ្ទេហិ អសពលេហិ អកម្មាសេហិ ភុជិស្សេហិ វិញ្ញុប្បសត្ថេហិ អបរាមដ្ឋេហិ សមាធិសំវត្តនិកេហិ ។

(១៦៨) យតោ ខោ គហបតយោ អរិយសាវកោ ឥមេហិ សត្តហិ សទ្ធម្មេហិ សមន្នាគតោ ហោតិ ឥមេហិ ចតូហិ អាកង្ខិយេហិ ឋានេហិ សោ អាកង្ខមានោ អត្តនា វ អត្តានំ ព្យាករេយ្យ ខីណនិរយោម្ហិ ខីណតិរច្ឆានយោនិយោ(១) ខីណប្បេត្តិវិសយោ ខីណាបាយទុគ្គតិវិនិបាតោ សោតាបន្នោហមស្មិ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយនោតិ ។

---

១ ឱ. ម. ខីណតិរច្ឆានយោនកោ ។

## វេឡុទ្វារវគ្គ ទី ១

[១៦៧] អរិយសាវកនោះជាអ្នកប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគអង្គនោះ ។ បេ ។ ទ្រង់ជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវអរិយសច្ច ៤ ទ្រង់ញ្ញាក់ចោលនូវត្រៃភព លែងវិលត្រឡប់មកកើតទៀត ។ ក្នុងព្រះធម៌ ប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើក ។ ក្នុងព្រះសង្ឃថា ព្រះសង្ឃសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយប្រពៃ ។ បេ ។ ជាបុញ្ញក្ខេត្តនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន ។ ប្រកបដោយសីល ជាទីត្រេកអររបស់អរិយៈ ជាសីលមិនដាច់ មិនធ្លុះ មិនពព្រុះ មិនពពាល ជាសីលជាទា អ្នកប្រាជ្ញតែងសរសើរ មិនបានប៉ះពាល់ដោយតណ្ហានិងទិដ្ឋិ ប្រព្រឹត្តទៅព្រមដើម្បីសមាធិ ។

[១៦៨] ម្នាលព្រាហ្មណ៍និងគហបតីទាំងឡាយ កាលណាបើអរិយសាវកប្រកបដោយព្រះសទ្ធម្មទាំង ៧ នេះ ដោយឋានៈដែលបណ្ឌិតត្រូវប្រាថ្នាទាំង ៤ យ៉ាងនេះហើយ អរិយសាវកនោះឯង កាលប្រាថ្នាគប្បីព្យាករនូវខ្លួនដោយខ្លួនឯងថា អាត្មាអញអស់ទៅកើតក្នុងនរកហើយ អស់ទៅកើតក្នុងកំណើតតិរច្ឆានហើយ អស់ទៅកើតក្នុងបិត្តិវិស័យហើយ អស់ទៅកើតក្នុងកំណើតអសុរកាយហើយ អាត្មាអញជាអ្នកដល់នូវសោតៈហើយ មានសភាពមិនធ្លាក់ចុះក្នុងអបាយ ជាបុគ្គលទៀង ជាអ្នកមានកិរិយាត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ ។

(១៦៩) ឯវំ វុត្តេ វេឡុទ្វារេយ្យកា ព្រាហ្មណគហ-បតិកា ភគវន្តំ ឯតទវោចុំ អភិក្កន្តំ ភោ គោតម ។បេ។ ឯតេ មយំ ភវន្តំ គោតមំ សរណំ គច្ឆាម ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកេ នោ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតេ សរណង្គតេតិ ។

(១៧០) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា ញាតិកេ វិហរតិ គិញ្ជកាវសថេ ។ អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច សាឡ្ហោ នាម ភន្តេ ភិក្ខុ កាលកតោ តស្ស កា គតិ កោ អភិសម្បរាយោ ។ នន្ទា នាម ភន្តេ ភិក្ខុនី កាលកតា តស្សា កា គតិ កោ អភិសម្បរាយោ ។

[ ១៦៩ ] កាលបើព្រះដ៏មានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ ពួកព្រាហ្មណ៍និងគហបតីអ្នកនៅក្នុងវេឡុទ្វារគ្រាម ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចំរើន ច្បាស់ពេកណាស់ ៗ បេ ៗ យើងខ្ញុំព្រះអង្គទាំងអម្បាលនេះ សូមដល់នូវព្រះគោតមដ៏ចំរើន ទាំងព្រះធម៌ ទាំងព្រះភិក្ខុសង្ឃជាទីពឹងទីរលឹក សូមព្រះគោតមដ៏ចំរើន ទ្រង់ចាំទុកនូវយើងខ្ញុំព្រះអង្គទាំងឡាយថាជាឧបាសក អ្នកដល់នូវព្រះរតនត្រ័យ ជាទីពឹងទីរលឹកស្មើដោយជីវិត តាំងអំពីថ្ងៃនេះតទៅ ៗ

[ ១៧០ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ៗ សម័យមួយព្រះដ៏មានព្រះភាគ ទ្រង់គង់ក្នុងផ្ទះសំណាក់ធ្វើដោយឥដ្ឋជិតស្រុកញាតិកៈ ៗ គ្រានោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ៗ លុះព្រះអានន្ទដ៏មានអាយុអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុឈ្មោះសាឡ្ហៈធ្វើមរណកាលទៅហើយ គតិរបស់លោកដូចម្តេច ការទៅក្នុងលោកខាងមុខដូចម្តេច ៗ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុនីឈ្មោះនន្ទាធ្វើមរណកាលទៅហើយ គតិរបស់នាងដូចម្តេច ការទៅក្នុងលោកខាងមុខដូចម្តេច ៗ

## វេឡុទ្វារវគ្គោ បឋមោ

សុទត្តោ នាម ភន្តេ ឧបាសកោ កាលកតោ តស្ស កា គតិ កោ អភិសម្បរាយោ ។ សុជាតា នាម ភន្តេ ឧបាសិកា កាលកតា តស្សា កា គតិ កោ អភិសម្បរាយោតិ ។

(១៧១) សាឡ្ហោ អានន្ទ ភិក្ខុ កាលកតោ អាសវានំ ខយា អនាសវំ ចេតោវិមុត្តិំ បញ្ញាវិមុត្តិំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ (១) ។ នន្ទា អានន្ទ ភិក្ខុនី កាលកតា បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឱប-បាតិកា តត្ថ បរិនិព្វាយិនី អនាវត្តិធម្មា តស្មា លោកា ។ សុទត្តោ អានន្ទ ឧបាសកោ កាល-កតោ តិណ្ណំ សញ្ញោជនានំ បរិក្ខយា រាគទោស-មោហានំ តនុត្តា សកទាគាមី សកិទេវ ឥមំ លោកំ អាគន្ត្វា ទុក្ខស្សន្តំ ករិស្សតិ ។ សុជាតា អានន្ទ ឧបាសិកា កាលកតា តិណ្ណំ សញ្ញោជនានំ បរិក្ខយា សោតាបន្នា អវិនិបាតធម្មា និយតា សម្ពោធិបរាយនា ។

---

១ ឱ ម. វិហាសិ ។

បពិត្រព្រះអង្គដ៏ចំរើន ឧបាសកឈ្មោះសុទត្តៈធ្វើមរណកាលទៅហើយ គតិរបស់គាត់ដូចម្តេច ការទៅកាន់លោកខាងមុខដូចម្តេច ។ បពិត្រព្រះអង្គដ៏ចំរើន ឧបាសិកាឈ្មោះសុជាតាធ្វើមរណកាលទៅហើយ គតិរបស់នាងដូចម្តេច ការទៅកាន់លោកខាងមុខដូចម្តេច ។

[១៧១] ម្នាលអានន្ទ ភិក្ខុឈ្មោះសាឡ្ហៈធ្វើមរណកាលទៅ បានធ្វើឲ្យជាក់ច្បាស់សម្រេចដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយហើយសម្រេចសម្រាន្ត ។ ម្នាលអានន្ទ ភិក្ខុនីឈ្មោះនន្ទាធ្វើមរណកាលទៅ បានជាឱបបាតិកា រលត់មិនសល់ក្នុងទីនោះ មានសភាពមិនបានត្រឡប់ចាកលោកនោះ ព្រោះអស់ទៅនៃឱរម្ភាគិយសញ្ញោជនៈទាំង៥ ។ ម្នាលអានន្ទ ឧបាសកឈ្មោះសុទត្តៈធ្វើមរណកាលទៅ បានដល់សកទាគាមី មកកាន់លោកនេះអស់វារៈម្តងទៀត ទើបធ្វើនូវព្រះនិព្វានជាទីបំផុតនៃទុក្ខ ព្រោះស្រាលស្តើងនៃរាគៈ ទោសៈ មោហៈ ព្រោះអស់ទៅនៃសញ្ញោជនៈ ៣ ។ ម្នាលអានន្ទ ឧបាសិកាឈ្មោះសុជាតា ធ្វើមរណកាលទៅ បានដល់សោតៈ មានសភាពមិនបានធ្លាក់ចុះក្នុងអបាយ ជាបុគ្គលទៀង មានកិរិយាត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ព្រោះអស់ទៅនៃសញ្ញោជនៈ ៣ ។

(១៧២) អនច្ឆរិយំ ខោ បនេតំ អានន្ទ យំ មនុស្សភូតោ កាលំ ករេយ្យ តស្មឹ តស្មឹ ចេ មំ កាលកតេ ឧបសង្កមិត្វា ឯតមត្ថំ បដិបុច្ឆិស្សថ ។ វិហេសាវេសា អស្ស អានន្ទ តថាគតស្ស ។ តស្មាតិហានន្ទ ធម្មាទាសំ នាម ធម្មបរិយាយំ ទេសេស្សាមិ យេន សមន្នាគតោ អរិយសាវកោ អាកង្ខមានោ អត្តនា វ អត្តានំ ព្យាករេយ្យ ខីណនិរយោម្ហិ ខីណតិរច្ឆានយោនិយោ ខីណប្បិត្តិវិសយោ ខីណាបាយទុគ្គតិវិនិបាតោ សោតាបន្នោហមស្មិ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយណោ ។

(១៧៣) កតមោ ច សោ អានន្ទ ធម្មាទាសោ ធម្មបរិយាយោ យេន សមន្នាគតោ អរិយសាវកោ អាកង្ខមានោ អត្តនា វ អត្តានំ ព្យាករេយ្យ ខីណនិរយោម្ហិ ខីណតិរច្ឆានយោនិយោ ខីណប្បិត្តិវិសយោ ខីណាបាយទុគ្គតិវិនិបាតោ សោតាបន្នោហមស្មិ

[១៧២] ម្នាលអានន្ទ មនុស្សធ្វើមរណកាលនេះ មិនជាអស្ចារ្យអ្វីទេ កាលបើមនុស្សនោះៗ ធ្វើមរណកាលហើយ អ្នកទាំងឡាយនឹងបេះតែចូលមកសួរសេចក្តីនុ៎ះនឹងតថាគត ៗ ម្នាលអានន្ទ នុ៎ះជាហេតុនាំឲ្យលំបាកដល់តថាគតពេកណាស់ ។ ម្នាលអានន្ទ ព្រោះហេតុនោះ ក្នុងសាសនានេះ តថាគតនឹងសំដែងនូវធម្មបរិយាយឈ្មោះធម្មាទាសៈ (កញ្ចក់ឆ្លុះពោលគឺធម៌) ដែលអរិយសាវកអ្នកប្រកប កាលបើប្រាថ្នា គប្បីព្យាករនូវខ្លួនដោយខ្លួនឯងថា អាត្មាអញអស់ទៅកើតក្នុងនរកហើយ អស់ទៅកើត ក្នុងកំណើតតិរច្ឆានហើយ អស់ទៅកើត ក្នុងបិត្តិវិស័យហើយ អស់ទៅកើតក្នុងកំណើតអសុរកាយហើយ អាត្មាអញជាអ្នកដល់នូវសោតៈ មានសភាពជាអ្នកមិនធ្លាក់ចុះក្នុងអបាយ ជាបុគ្គលទៀង មានកិរិយាត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ។

[១៧៣] ម្នាលអានន្ទ ចុះធម្មបរិយាយឈ្មោះធម្មាទាសៈនោះ តើដូចម្តេច ដែលអរិយសាវកបានប្រកបហើយ កាលបើប្រាថ្នា គប្បីព្យាករនូវខ្លួនដោយខ្លួនឯងថា អាត្មាអញអស់ទៅកើតក្នុងនរកហើយ អស់ទៅកើតក្នុងកំណើតតិរច្ឆានហើយ អស់ទៅកើតក្នុងបិត្តិវិស័យហើយ អស់ទៅកើតក្នុងកំណើតអសុរកាយហើយ អាត្មាអញជាអ្នកដល់នូវសោតៈហើយ

## វេឡុទ្វារវគ្គោ បឋមោ

អវិនិបាតធម្មោ និយតោ សម្ពោធិបរាយណោ ។ ឥធ អានន្ទ អរិយសាវកោ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ ឥតិបិ សោ ភគវា ។ បេ ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ធម្មេ ។ សង្ឃេ ។ អរិយកន្តេហិ សីលេហិ សមន្នាគតោ ហោតិ អខណ្ឌេហិ ។ បេ ។ សមាធិសំវត្តនិកេហិ ។ អយំ ខោ សោ អានន្ទ ធម្មាទាសោ ធម្មបរិយាយោ យេន សមន្នាគតោ អរិយសាវកោ អាកង្ខមានោ អត្តនា វ អត្តានំ ព្យាករេយ្យ ខីណនិរយោម្ហិ ខីណតិរច្ឆានយោនិយោ ខីណបេត្តិវិសយោ ខីណាបាយទុគ្គតិវិនិបាតោ សោតាបន្នោហមស្មិ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយណោតិ ។ (តីណិបិ សុត្តន្តានិ ឯកនិទានានិ) ។

(១៧៤) ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច អសោកោ នាម ភន្តេ ភិក្ខុ កាលកតោ តស្ស កា គតិ

មានសភាពជាអ្នកមិនធ្លាក់ចុះក្នុងអបាយ ជាបុគ្គលទៀង មានកិរិយាត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ។ ម្នាលអានន្ទ អរិយសាវកក្នុងសាសនានេះ ប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគអង្គនោះ ។បេ។ ទ្រង់ជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវអរិយសច្ច ៤ ទ្រង់ខ្ជាក់ចោលនូវត្រៃភព លែងវិលត្រឡប់មកកើតទៀត ។ ក្នុងព្រះធម៌ ។ ក្នុងព្រះសង្ឃ ។ ប្រកបដោយសីលជាទីត្រេកអររបស់ព្រះអរិយៈ ជាសីលមិនដាច់ ។បេ។ ប្រព្រឹត្តទៅដើម្បីសមាធិ ។ ម្នាលអានន្ទ នេះហៅថា ធម្មបរិយាយឈ្មោះធម្មាទាសៈ ដែលអរិយ-សាវកបានប្រកបហើយ កាលបើប្រាថ្នា គប្បីព្យាករដោយខ្លួនឯងថា អាត្មាអញអស់ទៅកើតក្នុងនរកហើយ អស់ទៅកើតក្នុងកំណើតតិរច្ឆានហើយ អស់ទៅកើតក្នុងបិត្តិវិស័យហើយ អស់ទៅកើតក្នុងកំណើតអសុរកាយហើយ អាត្មាអញជាអ្នកដល់នូវសោតៈហើយ មានសភាពជាអ្នកមិនធ្លាក់ចុះក្នុងអបាយ ជាបុគ្គលទៀង មានកិរិយាត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ។ (សូត្រទាំង ៣ មាននិទានតែមួយ) ។

[១៧៤] លុះព្រះអានន្ទ ដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុឈ្មោះអសោកៈ ធ្វើមរណកាលទៅហើយ គតិរបស់លោកដូចម្តេច

កោ អភិសម្បរាយោ ។ អសោកា នាម ភន្តេ ភិក្ខុនី កាលង្កតា ។ បេ ។ អសោកោ នាម ភន្តេ ឧបាសកោ កាលង្កតោ ។ បេ ។ អសោកា នាម ភន្តេ ឧបាសិកា កាលង្កតា តស្សា កា គតិ កោ អភិសម្បរាយោតិ ។

(១៧៥) អសោកោ អានន្ទ ភិក្ខុ កាលង្កតោ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ (១) ។ (បុរិមវេយ្យាករណេន ឯកនិទានំ) ។

(១៧៦) អយំ ខោ សោ អានន្ទ ធម្មាទាសោ ធម្មបរិយាយោ យេន សមន្នាគតោ អរិយសាវកោ អាកង្ខមានោ អត្តនាវ អត្តានំ ព្យាករេយ្យ ខីណនិរយោម្ហិ ខីណតិរច្ឆានយោនិយោ ខីណបេត្តិវិសយោ ខីណាបាយទុគ្គតិវិនិបាតោ សោតាបន្នោហមស្មិ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយណោតិ ។

---

១ ឱ ម. វិហាសិ ។

ការទៅកាន់លោកខាងមុខដូចម្ដេច ។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុនីឈ្មោះអសោកា ធ្វើមរណកាលទៅហើយ ។ បេ ។ បពិត្រព្រះអង្គដ៏ចំរើន ឧបាសកឈ្មោះអសោកៈ ធ្វើមរណកាលទៅហើយ ។ បេ ។ បពិត្រព្រះអង្គដ៏ចំរើនឧបាសិកាឈ្មោះអសោកា ធ្វើមរណកាលទៅហើយ គតិរបស់នាងដូចម្ដេច ការទៅកាន់លោកខាងមុខដូចម្ដេច ។

(១៧៥)ម្នាលអានន្ទ ភិក្ខុឈ្មោះអសោកៈ ធ្វើមរណកាលទៅ បានធ្វើឲ្យជាក់ច្បាស់សម្រេចដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ហើយសម្រេចសម្រាន្តនៅ ។ (និទានតែមួយដោយវេយ្យាករណ៍ដូចមុន) ។

(១៧៦) ម្នាលអានន្ទ នេះហៅថា ធម្មបរិយាយឈ្មោះធម្មាទាសៈ ដែលអរិយសាវកបានប្រកបហើយ កាលបើប្រាថ្នា គប្បីព្យាករនូវខ្លួនដោយខ្លួនឯងថា អាត្មាអញអស់ទៅកើតក្នុងនរកហើយ អស់ទៅកើតក្នុងកំណើតតិរច្ឆានហើយ អស់ទៅកើតក្នុងបិត្តិវិស័យហើយ អស់ទៅកើតក្នុងកំណើតអសុរកាយហើយ អាត្មាអញជាអ្នកដល់នូវសោតៈហើយ មានសភាពជាអ្នកមិនធ្លាក់ចុះក្នុងអបាយ ជាបុគ្គលទៀង មានកិរិយាត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ។

## វេឡុទ្វារវគ្គោ បឋមោ

[១៧៧] ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច កក្កុដោ នាម ភន្តេ ញាតិកោ ឧបាសកោ កាលកតោ តស្ស កា គតិ កោ អភិសម្បរាយោ ។ កាឡិម្ពោ(១) នាម ភន្តេ ញាតិកោ ឧបាសកោ ។ ននិកដ្ឋោ(២) នាម ភន្តេ ញាតិកោ ឧបាសកោ ។ កដិស្សហោ នាម ភន្តេ ញាតិកោ ឧបាសកោ ។ តុដ្ឋោ នាម ភន្តេ ញាតិកោ ឧបាសកោ ។ សន្តុដ្ឋោ នាម ភន្តេ ញាតិកោ ឧបាសកោ ។ ភទ្ទោ នាម ភន្តេ ញាតិកោ ឧបាស-កោ ។ សុភទ្ទោ នាម ភន្តេ ញាតិកោ ឧបាសកោ កាលកតោ តស្ស កា គតិ កោ អភិសម្បរាយោតិ ។

[១៧៨] កក្កុដោ អានន្ទ ឧបាសកោ កាលកតោ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឱប-បាតិកោ តត្ថ បរិនិព្វាយី អនាវត្តិធម្មោ តស្មា លោកា ។ កាឡិម្ពោ អានន្ទ ។ ននិកដ្ឋោ អានន្ទ ។

---

១ ឱ. កាឡិង្គោ នាម ។ ២ ឱ ម. និកដោ ។

## វេឡុទ្វារវគ្គទី ១

[១៧៧] លុះព្រះអានន្ទ ដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ឧបាសកឈ្មោះកក្កុដៈក្នុងស្រុកញាតិកៈ ធ្វើមរណកាលទៅហើយ គតិរបស់គាត់ដូចម្តេច ការទៅក្នុងលោកខាងមុខដូចម្តេច ។ បពិត្រព្រះអង្គដ៏ចំរើន ឧបាសកឈ្មោះកឡិង្កៈក្នុងស្រុកញាតិកៈ ។ បពិត្រព្រះអង្គដ៏ចំរើន ឧបាសកឈ្មោះទនិកដ្ឋៈក្នុងស្រុកញាតិកៈ ។ បពិត្រព្រះអង្គដ៏ចំរើន ឧបាសកឈ្មោះកដិស្សហៈ ក្នុងស្រុកញាតិកៈ ។ បពិត្រព្រះអង្គដ៏ចំរើន ឧបាសកឈ្មោះតុដ្ឋៈ ក្នុងស្រុកញាតិកៈ ។ បពិត្រព្រះអង្គដ៏ចំរើន ឧបាសកឈ្មោះសន្តុដ្ឋៈក្នុងស្រុកញាតិកៈ ។ បពិត្រព្រះអង្គដ៏ចំរើន ឧបាសកឈ្មោះភទ្ទៈ ក្នុងស្រុកញាតិកៈ ។ បពិត្រព្រះអង្គដ៏ចំរើនឧបាសកឈ្មោះសុភទ្ទៈ ក្នុងស្រុកញាតិកៈធ្វើមរណកាលទៅហើយ គតិរបស់គាត់ដូចម្តេច ការទៅក្នុងលោកខាងមុខដូចម្តេច ។

[១៧៨] ម្នាលអានន្ទ ឧបាសកឈ្មោះកក្កុដៈ ធ្វើមរណកាលទៅហើយបានជាឧបបាតិកៈរលត់អស់ក្នុងទីនោះ មានសភាពជាអ្នកមិនត្រឡប់ចាកលោកនោះ ព្រោះអស់ទៅនៃឱរម្ភាគិយសញ្ញោជនៈទាំង ៥ ។ ម្នាលអានន្ទ ឧបាសកឈ្មោះកឡិង្កៈ ។ ម្នាលអានន្ទ ឧបាសកឈ្មោះទនិកដ្ឋៈ ។

កដិស្សហោ អានន្ទ ។ តុដ្ឋោ អានន្ទ ។ សន្តុដ្ឋោ
អានន្ទ ។ ភទ្ទោ អានន្ទ ។ សុភទ្ទោ អានន្ទ
ឧបាសកោ កាលកតោ បញ្ចន្នំ ឱរម្ភាគិយានំ
សញ្ញោជនានំ បរិក្ខយា ឱបបាតិកោ តត្ថ បរិនិព្វាយី
អនាវត្តិធម្មោ តស្មា លោកា ។

(សព្ពេ ឯកាទសកា កាតព្វា) ។

(១៧៩) បរោបញ្ញាស អានន្ទ ញាតិកេ ឧបា-
សកា កាលកតា បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោ-
ជនានំ បរិក្ខយា ឱបបាតិកា តត្ថ បរិនិព្វាយិនោ
អនាវត្តិធម្មា តស្មា លោកា ។ សាធិកានវុតិ
អានន្ទ ញាតិកេ ឧបាសកា កាលកតា តិណ្ណំ
សញ្ញោជនានំ បរិក្ខយា រាគទោសមោហានំ តនុត្តា
សកទាគាមិនោ សកិទេវ ឥមំ លោកំ អាគន្ត្វា
ទុក្ខស្សន្តំ ករិស្សន្តិ ។ ឆាតិរេកានិ ខោ អានន្ទ
បញ្ចសតានិ ញាតិកេ ឧបាសកា កាលកតា
តិណ្ណំ សញ្ញោជនានំ បរិក្ខយា សោតាបន្នា អវិនិបាត-
ធម្មា និយតា សម្ពោធិបរាយណា ។

ម្នាលអានន្ទ ឧបាសកឈ្មោះកដិស្សហៈ ។ ម្នាលអានន្ទ ឧបាសកឈ្មោះតុដ្ឋៈ ។ ម្នាលអានន្ទ ឧបាសកឈ្មោះសន្តុដ្ឋៈ ។ ម្នាលអានន្ទ ឧបាសកឈ្មោះភទ្ទៈ ។ ម្នាលអានន្ទ ឧបាសកឈ្មោះសុភទ្ទៈ ធ្វើមរណកាលទៅហើយ បានជាឧបបាតិកៈ រលត់អស់ក្នុងទីនោះ មានសភាពជាអ្នកមិនត្រឡប់ចាកលោកនោះ ព្រោះអស់ទៅនៃឱរម្ភាគិយសញ្ញោជនៈទាំង ៥ ។ (ឧបាសកទាំងអស់ បណ្ឌិតគប្បីធ្វើថាមានគតិតែមួយ) ។

(១៧៥) ម្នាលអានន្ទ ពួកឧបាសកច្រើនជាង ៥០ នាក់ក្នុងស្រុកញាតិកៈ ធ្វើមរណកាលទៅ បានជាឧបបាតិកៈ រលត់អស់ទៅក្នុងទីនោះ មានសភាពជាអ្នកមិនត្រឡប់ចាកលោកនោះ ព្រោះអស់ទៅនៃឱរម្ភាគិយសញ្ញោជនៈទាំង ៥ ។ ម្នាលអានន្ទ ពួកឧបាសកច្រើនជាង ៩០ នាក់ក្នុងស្រុកញាតិកៈ ធ្វើមរណកាលទៅហើយបានដល់សកទាគាមី មកកាន់លោកនេះអស់វារៈម្តងទៀត ទើបធ្វើនូវព្រះនិព្វានជាទីបំផុតនៃទុក្ខបាន ព្រោះស្រាលស្តើងនៃរាគៈ ទោសៈ និង មោហៈ ព្រោះអស់ទៅនៃសញ្ញោជនៈទាំង ៣ ។ ម្នាលអានន្ទ ពួកឧបាសក ៥០៦ នាក់ក្នុងស្រុកញាតិកៈ ធ្វើមរណកាលទៅហើយ បានដល់សោតៈ មានសភាពជាអ្នកមិនធ្លាក់ចុះក្នុងអបាយ ជាបុគ្គលទៀង មានកិរិយាត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខព្រោះអស់ទៅនៃសញ្ញោជនៈ ៣ ។

## វេឡុទ្វារវគ្គោ បឋមោ

(១៨០) អញ្ញតរិយំ ខោ បនេតំ អានន្ទ យំ មនុស្សភូតោ កាលំ ករេយ្យ តស្មិំ តស្មិំ ចេ មំ កាលកតេ ឧបសង្កមិត្វា ឯតមត្ថំ បដិបុច្ឆិស្សថ ។ វិហេសាហេសា អានន្ទ អស្ស តថាគតស្ស ។ តស្មាតិហានន្ទ ធម្មាទាសំ នាម ធម្មបរិយាយំ ទេសេស្សាមិ យេន សមន្នាគតោ អរិយសាវកោ អាកង្ខមានោ អត្តនា វ អត្តានំ ព្យាករេយ្យ ខីណនិរយោម្ហិ ខីណតិរច្ឆានយោនិយោ ខីណបេត្តិវិសយោ ខីណាបាយទុគ្គតិវិនិបាតោ សោតាបន្នោហមស្មិ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយណោ ។

(១៨១) កតមោ ច សោ អានន្ទ ធម្មាទាសោ ធម្មបរិយាយោ យេន សមន្នាគតោ អរិយសាវកោ អាកង្ខមានោ អត្តនា វ អត្តានំ ព្យាករេយ្យ ខីណនិរយោម្ហិ ខីណតិរច្ឆានយោនិយោ ខីណបេត្តិវិសយោ

## វេឡុទ្វារវគ្គទី ១

[១៨០] ម្នាលអានន្ទ មនុស្សធ្វើមរណកាលនេះមិនជាអស្ចារ្យអ្វីទេ កាលបើមនុស្សនោះៗ ធ្វើមរណកាលទៅហើយ អ្នកទាំងឡាយនឹងបេះតែចូលមកសួរសេចក្តីនុ៎ះនឹងតថាគត ម្នាលអានន្ទ នុ៎ះជាហេតុនាំឲ្យលំបាកដល់តថាគតពេកណាស់ ៗ ម្នាលអានន្ទ ព្រោះហេតុនោះ ក្នុងសាសនានេះ តថាគត នឹងសំដែងនូវធម្មបរិយាយ ឈ្មោះធម្មាទាសៈ ដែលអរិយសាវកបានប្រកបហើយ កាលបើប្រាថ្នា គប្បីព្យាករនូវខ្លួនដោយខ្លួនឯងថា អាត្មាអញអសទៅកើតក្នុងនរកហើយ អសទៅកើតក្នុងកំណើតតិរច្ឆានហើយ អស់ទៅកើតក្នុងបិត្តិវិស័យហើយ អស់ទៅកើតក្នុងកំណើតអសុរកាយហើយ អាត្មាអញបានដល់សោតៈហើយ មានសភាពជាអ្នកមិនធ្លាក់ចុះក្នុងអបាយ ជាបុគ្គលទៀង មានកិរិយាត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ៗ

[១៨១] ម្នាលអានន្ទ ចុះធម្មបរិយាយ ឈ្មោះធម្មាទាសៈនោះ តើដូចម្តេច ដែលអរិយសាវកប្រកបហើយ កាលបើប្រាថ្នា គប្បីព្យាករនូវខ្លួនដោយខ្លួនឯងថា អាត្មាអញអស់ទៅកើតក្នុងនរកហើយ អស់ទៅកើត ក្នុងកំណើតតិរច្ឆានហើយ អស់ទៅកើត ក្នុងបិត្តិវិស័យហើយ

ខីណាបាយទុគ្គតិវិនិបាតោ សោតាបន្នោហមស្មិ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយណោ ។ ឥធានន្ទ អរិយសាវកោ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ ឥតិបិ សោ ភគវា ។បេ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ធម្មេ ។ សង្ឃេ ។ អរិយកន្តេហិ សីលេហិ សមន្នាគតោ ហោតិ អខណ្ឌេហិ ។បេ។ សមាធិសំវត្តនិកេហិ ។ អយំ ខោ សោ អានន្ទ ធម្មាទាសោ ធម្មបរិយាយោ យេន សមន្នាគតោ អរិយសាវកោ អាកង្ខមានោ អត្តនា វ អត្តានំ ព្យាករេយ្យ ខីណនិរយោម្ហិ ខីណតិរច្ឆានយោនិយោ ខីណបេត្តិវិសយោ ខីណាបាយទុគ្គតិវិនិបាតោ សោតាបន្នោហមស្មិ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយណោតិ ។

វេឡុទ្វារវគ្គោ បឋមោ ។

អស់ទៅកើត ក្នុងកំណើតអសុរកាយហើយ អាត្មាអញបានដល់សោតៈ ហើយ មានសភាពជាអ្នកមិនធ្លាក់ចុះក្នុងអបាយ ជាបុគ្គលទៀង មានកិរិយាត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ។ ម្នាលអានន្ទ អរិយសាវកក្នុងសាសនានេះ ប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគអង្គនោះ ។ បេ ។ ទ្រង់ជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវអរិយសច្ច ៤ ទ្រង់ចែកលោកនូវត្រៃកពលែងវិលត្រឡប់មកកើតទៀត ។ ក្នុងព្រះធម៌ ។ ក្នុងព្រះសង្ឃ ។ ប្រកបដោយសីលជាទីត្រេកអររបស់ព្រះអរិយៈ ជាសីលមិនដាច់ ។ បេ ។ ប្រព្រឹត្តទៅដើម្បីសមាធិ ។ ម្នាលអានន្ទ នេះហៅថា ធម្មបរិយាយឈ្មោះធម្មាទាសៈ ដែលអរិយសាវកបានប្រកបហើយ កាលបើប្រាថ្នាគប្បីព្យាករនូវខ្លួនដោយខ្លួនឯងថា អាត្មាអញអស់ទៅកើតក្នុងនរកហើយ អស់ទៅកើតក្នុងកំណើតតិរច្ឆានហើយ អស់ទៅកើតក្នុងបិត្តិវិស័យហើយ អស់ទៅកើត ក្នុងកំណើតអសុរកាយហើយ អាត្មាអញបានដល់សោតៈហើយ មានសភាពជាអ្នកមិនធ្លាក់ចុះក្នុងអបាយ ជាបុគ្គលទៀង មានកិរិយាត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ។

ចប់វេឡុទ្វារវគ្គ ទី ១ ។

## វេឡុទ្វារវគ្គោ បឋមោ

### តស្សុទ្ទានំ

រាជា ឱគធទីឃាវុ
សារីបុត្តា អបរេ ទុវេ
ថបតយោ វេឡុទ្វារេយ្យា
គិញ្ជកាវសថេ តយោតិ ។

## វេរញ្ជវគ្គទី ១

# ឧទ្ទាននៃវេរញ្ជវគ្គនោះ គឺ

និយាយអំពីស្តេចចក្រពត្តិ ១ អំពីសេចក្តីសុខជាទីប្រជុំចុះនៃព្រហ្មចរិយៈ១ អំពីទីឃាវុឧបាសក ១ អំពីព្រះសារីបុត្តមាន២លើក អំពីនាយជាងឈើ១ អំពីពួកព្រាហ្មណ៍និងគហបតីអ្នកនៅក្នុងស្រុកវេរញ្ជា១ អំពីរឿងដែលព្រះដ៏មានព្រះភាគទ្រង់គង់ក្នុងផ្ទះធ្វើដោយឥដ្ឋមាន ៣ លើក ។

# រាជការាមវគ្គោ ទុតិយោ

[១៨២] សាវត្ថិយំ វិហរតិ រាជការាមេ ។ អថខោ សហស្សភិក្ខុនីសង្ឃោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតា ខោ តា ភិក្ខុនិយោ ភគវា ឯតទវោច ចតូហិ ខោ ភិក្ខុនិយោ ធម្មេហិ សមន្នាគតោ អរិយសាវកោ សោតាបន្នោ ហោតិ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយនោ ។ កតមេហិ ចតូហិ ។ ឥធ ភិក្ខុនិយោ អរិយសាវកោ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ ឥតិបិ សោ ភគវា ។បេ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ធម្មេ ។ សង្ឃេ ។ អរិយកន្តេហិ សីលេហិ សមន្នាគតោ ហោតិ អខណ្ឌេហិ ។បេ។ សមាធិសំវត្តនិកេហិ ។ ឥមេហិ ខោ ភិក្ខុនិយោ ចតូហិ ធម្មេហិ សមន្នាគតោ អរិយសាវកោ សោតាបន្នោ ហោតិ

# រាជការាមវគ្គទី ២

(១៨៤) ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងរាជការាម ទៀបក្រុងសាវត្ថី ។ គ្រានោះ ភិក្ខុនីសង្ឃប្រមាណមួយពាន់រូប បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយថ្វាយបង្គំព្រះដ៏មានព្រះភាគហើយឋិតក្នុងទីដ៏សមគួរ ។ លុះភិក្ខុនីទាំងនោះឋិតក្នុងទីដ៏សមគួរហើយ ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុនីទាំងឡាយ អរិយសាវកអ្នកប្រកបដោយធម៌ ៤ យ៉ាងជាសោតាបន្នបុគ្គល មានសភាពមិនធ្លាក់ទៅក្នុងអបាយ ។ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ។ ធម៌ ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុនីទាំងឡាយ អរិយសាវកក្នុងធម្មវិន័យនេះ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគអង្គនោះ ។ បេ ។ ព្រះអង្គជាគ្រូនៃទេវតានឹងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលមកកាន់ភពថ្មីទៀត ។ (អរិយសាវកប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ) ក្នុងព្រះធម៌ ។ ក្នុងព្រះសង្ឃ ។ ជាអ្នកប្រកបដោយសីលជាទីស្រឡាញ់របស់អរិយបុគ្គល ជាសីលមិនដាច់ ។ បេ ។ ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ ។ ម្នាលភិក្ខុនីទាំងឡាយ អរិយសាវកប្រកបដោយធម៌ទាំង ៤ យ៉ាងនេះឯង ជាសោតាបន្នបុគ្គល

អវិនិបាតធម្មោ និយតោ សម្ពោធិបរាយណោតិ ។

(១៨៣) សាវត្ថីនិទានំ ។ ព្រាហ្មណា ភិក្ខវេ ឧទយគាមិនឹ នាម បដិបទំ បញ្ញបេន្តិ តេ សាវកំ ឯវំ សមាទបេន្តិ ឯហិ ត្វំ អម្ភោ បុរិស កាលស្សេវ ឧដ្ឋាយ បាចីនមុខោ យាហិ សោ ត្វំ មា សោព្ភំ(១) បរិវជ្ជេហិ មា បបាតំ មា ខាណុំ មា កណ្ដកដ្ឋានំ មា ចន្ទនិកំ មា ឱឡិគល្លំ យត្ថ បបតេយ្យាសិ តត្ថេវ មរណំ អាគមេយ្យាសិ(២) ឯវំ ត្វំ អម្ភោ បុរិស កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជិស្សសីតិ ។

(១៨៤) តំ ខោ បនេតំ ភិក្ខវេ ព្រាហ្មណានំ ពាលគមនមេតំ មូឡ្ហគមនមេតំ ន និព្ពិទាយ ន វិរាគាយ ន និរោធាយ ន ឧបសមាយ ន អភិញ្ញាយ

---

១ ឱ. សេម្ភំ ។ ម. សោម្ភំ ។ ២ អាគច្ឆេយ្យាសិ ។

មានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹង ប្រព្រឹត្តទៅក្នុងខាងមុខ ។

(១៨៣) សាវត្ថីនិទាន។ ម្នាលភិក្ខុទាំងឡាយ ព្រាហ្មណ៍ទាំងឡាយ តែងបញ្ញត្តនូវបដិបទា ឈ្មោះឧទយគាមិនី (ដំណើរទៅកាន់សេចក្ដីចំរើនក្នុងលទ្ធិរបស់ខ្លួន) ព្រាហ្មណ៍ទាំងនោះតែងញុំាងសាវកឲ្យសមាទានយ៉ាងនេះថា នែបុរសដ៏ចំរើន អ្នកចូរមកនេះ អ្នកចូរក្រោកឡើងអំពីព្រលឹម ហើយបែរមុខទៅខាងកើតទៅ ចូរអ្នកកុំវៀរត្រពាំងទឹក កុំវៀរអណ្ដូងទឹកឬជ្រោះ កុំវៀរដង្គត់ កុំវៀរទីមានបន្លា កុំវៀរអណ្ដូងជ្រាំ កុំវៀររណ្ដៅដំស្នោកគ្រោក បើអ្នកធ្លាក់ចុះក្នុងទីណា អ្នកគប្បីរង់ចាំសេចក្ដីស្លាប់ក្នុងទីនោះឯង ម្នាលបុរសដ៏ចំរើន កាលបើយ៉ាងនេះ លុះអ្នករំលាងខ្លួនបន្ទាប់អំពីសេចក្ដីស្លាប់ទៅ នឹងទៅកាន់លោកគឺសុគតិ ស្ថានសួគ៌ ។

(១៨៤) ម្នាលភិក្ខុទាំងឡាយ ការបញ្ញត្តិនូវបដិបទានោះឯង នេះជាដំណើររបស់មនុស្សពាល នេះជាដំណើររបស់មនុស្សវង្វេង នៃពួកព្រាហ្មណ៍ តែងមិនប្រព្រឹត្តទៅដើម្បីសេចក្ដីនឿយណាយ មិនប្រព្រឹត្តទៅដើម្បីសេចក្ដីប្រាសចាកតម្រេក មិនប្រព្រឹត្តទៅដើម្បីសេចក្ដីរលត់ មិនប្រព្រឹត្តទៅដើម្បីសេចក្ដីស្ងប់ស្ងាត់ មិនប្រព្រឹត្តទៅដើម្បីសេចក្ដីដឹងច្បាស់

ន សម្ពោធាយ ន និព្វានាយ សំវត្តតិ ។ អហញ្ច ខោ ភិក្ខវេ អរិយស្ស វិនយេ ឧទយគាមិនី បដិបទំ បញ្ញបេមិ យា ឯកន្តនិព្វិទាយ វិរាគាយ និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ។

[១៨៥] កតមា ច សា(១) ភិក្ខវេ ឧទយគាមិនី បដិបទា យា ឯកន្តនិព្វិទាយ ។ បេ ។ និព្វានាយ សំវត្តតិ ។ ឥធ ភិក្ខវេ អរិយសាវកោ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ ឥតិបិ សោ ភគវា ។ បេ ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ធម្មេ ។ សង្ឃេ ។ អរិយកន្តេហិ សីលេហិ សមន្នាគតោ ហោតិ អខណ្ឌេហិ ។ បេ ។ សមាធិសំវត្តនិកេហិ ។ អយំ ខោ សា ភិក្ខវេ ឧទយគាមិនី បដិបទា យា ឯកន្តនិព្វិទាយ

១ ឱ យា ។

មិនប្រព្រឹត្តទៅដើម្បីសេចក្តីត្រាស់ដឹង មិនប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ទេ ។ ម្នាលភិក្ខុទាំងឡាយ ចំណែកតថាគត តែងបញ្ញត្តនូវបដិបទា ជាដំណើរទៅកាន់សេចក្តីចំរើន ក្នុងអរិយវិន័យ ដែលប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយដោយពិតប្រាកដ ដើម្បីសេចក្តីប្រាសចាកតម្រេក ដើម្បីសេចក្តីរលត់ ដើម្បីសេចក្តីស្ងប់ស្ងាត់ ដើម្បីសេចក្តីដឹងច្បាស់ ដើម្បីសេចក្តីត្រាស់ដឹង ដើម្បីព្រះនិព្វាន ។

(១៨៥) ម្នាលភិក្ខុទាំងឡាយ ចុះបដិបទាជាដំណើរទៅកាន់សេចក្តីចំរើន ដែលប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយដោយពិតប្រាកដ ។បេ។ ដើម្បីព្រះនិព្វាន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងធម្មវិន័យនេះ ជាអ្នកប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគព្រះអង្គនោះ ។ បេ ។ ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀត ។ (អរិយសាវកប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ) ក្នុងព្រះធម៌ ។ ក្នុងព្រះសង្ឃ ។ ជាអ្នកប្រកបដោយសីលជាទីស្រឡាញ់របស់អរិយៈ ជាសីលមិនដាច់ ។បេ។ ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងជាបដិបទា ជាដំណើរទៅកាន់សេចក្តីចំរើន ដែលប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយដោយពិតប្រាកដ

វិរាគាយ និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតីតិ ។

(១៨៦) ឯកំ សមយំ អាយស្មា ច សារីបុត្តោ អាយស្មា ច អានន្ទោ សាវត្ថិយំ វិហរន្តិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ អាយស្មា សារីបុត្តោ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេន អាយស្មា អានន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា អានន្ទេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សារីបុត្តោ អាយស្មន្តំ អានន្ទំ ឯតទវោច កិត្តកានំ នុ ខោ អាវុសោ អានន្ទ ធម្មានំ បហានា កិត្តកានំ ធម្មានំ សមន្នាគមនហេតុ ឯវមយំ បជា ភគវតា ព្យាកតា សោតាបន្នា អវិនិបាតធម្មា និយតា សម្ពោធិបរាយណាតិ ។

(១៨៧) ចតុន្នំ ខោ អាវុសោ ធម្មានំ បហានា ចតុន្នំ ធម្មានំ សមន្នាគមនហេតុ ឯវមយំ បជា ភគវតា ព្យាកតា សោតាបន្នា អវិនិបាតធម្មា និយតា

ដើម្បីប្រាសចាកតម្រេក ដើម្បីសេចក្ដីរលត់ ដើម្បីសេចក្ដីស្ងប់ស្ងាត់ ដើម្បីសេចក្ដីដឹងច្បាស់ ដើម្បីសេចក្ដីត្រាស់ដឹង ដើម្បីព្រះនិព្វាន ។

[១៨៦] សម័យមួយ ព្រះសារីបុត្តដ៏មានអាយុនឹងព្រះអានន្ទដ៏មានអាយុ នៅក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ព្រះសារីបុត្តដ៏មានអាយុ ចេញអំពីទីពួនសម្ងំក្នុងសាយណ្ហសម័យ ចូលទៅរកព្រះអានន្ទដ៏មានអាយុ លុះចូលទៅដល់ ក៏ពោលពាក្យរាក់ទាក់ជាមួយនឹងព្រះអានន្ទដ៏មានអាយុ លុះបញ្ចប់ពាក្យដែលគួររាក់ទាក់ គួរឲ្យកើតសេចក្ដីរីករាយហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះសារីបុត្តដ៏មានអាយុអង្គុយក្នុងទីដ៏សមគួរហើយ ទើបសួរព្រះអានន្ទដ៏មានអាយុដូច្នេះថា អាវុសោអានន្ទ ព្រោះលះបង់ធម៌ប៉ុន្មានយ៉ាង ព្រោះប្រកបធម៌ប៉ុន្មានយ៉ាង ទើបព្រះដ៏មានព្រះភាគទ្រង់ព្យាករពួកសត្វនេះយ៉ាងនេះថា ជាសោតាបន្នបុគ្គល មានសភាពមិនធ្លាក់ទៅក្នុងអបាយជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ។

[១៨៧] ម្នាលអាវុសោ ព្រោះលះធម៌៤យ៉ាង ព្រោះប្រកបធម៌ ៤ យ៉ាង ទើបព្រះដ៏មានព្រះភាគទ្រង់ព្យាករពួកសត្វនេះយ៉ាងនេះថា ជាសោតាបន្នបុគ្គល មានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង

សម្ពោធិបរាយណាតិ ។ កតមេសំ ចតុន្នំ ។ យថារូបេន ខោ អាវុសោ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ អស្សុតវា បុថុជ្ជនោ កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ តថារូបស្ស ពុទ្ធេ អវេច្ចប្បសាទោ ន ហោតិ ។ យថារូបេន ច ខោ អាវុសោ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ សុតវា អរិយសាវកោ កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ តថារូបស្ស ពុទ្ធេ អវេច្ចប្បសាទោ ហោតិ ឥតិបិ សោ ភគវា ។បេ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។

(១៨៨) យថារូបេន ខោ អាវុសោ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ អស្សុតវា បុថុជ្ជនោ កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ តថារូបស្ស ធម្មេ អវេច្ចប្បសាទោ

មានការត្រាស់ដឹងជាទីប្រព្រឹត្តទៅក្នុងខាងមុខ ។ ធម៌ ៤ យ៉ាង ដូចម្តេចខ្លះ ។ ម្នាលអាវុសោ បុថុជ្ជនអ្នកមិនចេះដឹង ប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រក្នុងព្រះពុទ្ធ មានសភាពយ៉ាងណា លុះរំលាងខន្ធ បន្ទាប់អំពីមរណៈក៏ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក សេចក្តីជ្រះថ្លាមិនញាប់ញ័រក្នុងព្រះពុទ្ធ មានសភាពយ៉ាងនោះ ឥតមានដល់អរិយសាវកនោះឡើយ ។ ម្នាលអាវុសោ ចំណែកអរិយសាវកអ្នកចេះដឹង ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រ ក្នុងព្រះពុទ្ធ មានសភាពយ៉ាងណា លុះដល់រំលាងខន្ធ បន្ទាប់អំពីមរណៈទៅកើតក្នុងលោកគឺសុគតិ ស្ថានសួគ៌ សេចក្តីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធ មានសភាពយ៉ាងនោះ តែងមានដល់អរិយសាវកនោះថា ព្រះដ៏មានព្រះភាគអង្គនោះ ។បេ។ ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលមកកាន់ភពថ្មីទៀតដូច្នេះ ។

[១៨៨] ម្នាលអាវុសោ បុថុជ្ជន អ្នកមិនចេះដឹង ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ មានសភាពយ៉ាងណា លុះរំលាងខន្ធ បន្ទាប់អំពីមរណៈ ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក សេចក្តីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះធម៌ មានសភាពយ៉ាងនោះ

ន ហោតិ ។ យថារូបេន ច ខោ អាវុសោ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ សុតវា អរិយសាវកោ កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ តថារូបស្ស ធម្មេ អវេច្ចប្បសាទោ ហោតិ ស្វាក្ខាតោ ភគវតា ធម្មោ ។បេ។

(១៨៩) យថារូបេន ខោ អាវុសោ សង្ឃេ អវេច្ចប្បសាទេន សមន្នាគតោ អស្សុតវា បុថុជ្ជនោ កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិ-បាតំ និរយំ ឧបបជ្ជតិ តថារូបស្ស សង្ឃេ អវេច្ចប្បសា-ទោ ន ហោតិ ។ យថារូបេន ច ខោ អាវុសោ សង្ឃេ អវេច្ចប្បសាទេន សមន្នាគតោ សុតវា អរិយសាវកោ កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ តថារូបស្ស សង្ឃេ អវេច្ចប្បសាទោ ហោតិ សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ។បេ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

ឥតមានដល់អរិយសាវកនោះឡើយ ។ ម្នាលអាវុសោ បំណែកអរិយ-សាវកអ្នកចេះដឹង ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ មានសភាពយ៉ាងណា លុះរំលាយខន្ធ បន្ទាប់អំពីមរណៈ ទៅកើតក្នុងលោកគឺសុគតិស្ថានសួគ៌ សេចក្តីជ្រះថ្លាមិនញាប់ញ័រក្នុងព្រះធម៌ មានសភាពយ៉ាងនោះ តែងមានដល់អរិយសាវកនោះថា ព្រះធម៌ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ប្រពៃហើយ ។ បេ ។

(១៨៩) ម្នាលអាវុសោ បុថុជ្ជនអ្នកមិនចេះដឹង ប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះសង្ឃ មានសភាពយ៉ាងណា លុះរំលាយខន្ធ បន្ទាប់អំពីមរណៈ ទៅកើតក្នុងអបាយ ទុគ្គតិ និបាត នរក សេចក្តីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះសង្ឃ មានសភាពយ៉ាងនោះ ឥតមានដល់អរិយសាវកនោះឡើយ ។ ម្នាលអាវុសោ បំណែកអរិយសាវកអ្នកចេះដឹង ប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះសង្ឃ មានសភាពយ៉ាងណា លុះដល់រំលាយខន្ធបន្ទាប់អំពីមរណៈ ទៅកើតក្នុងលោកគឺសុគតិស្ថានសួគ៌ សេចក្តីជ្រះថ្លាមិនញាប់ញ័រក្នុងព្រះសង្ឃ មានសភាពយ៉ាងនោះ តែងមានដល់អរិយសាវកនោះថា ព្រះសង្ឃសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិប្រពៃហើយ ។ បេ ។ ជាស្រែបុណ្យដ៏ប្រសើរនៃសត្វលោក ។

(១៩០) យថារូបេន ខោ អាវុសោ ទុស្សីល្យេន សមន្នាគតោ អស្សុតវា បុថុជ្ជនោ កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ តថារូបស្ស ទុស្សីល្យំ ន ហោតិ(១) ។ យថារូបេហិ ច ខោ អាវុសោ អរិយកន្តេហិ សីលេហិ សមន្នាគតោ អរិយ-សាវកោ កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ តថារូបានិស្ស អរិយកន្តានិ សីលានិ ហោន្តិ អខណ្ឌានិ ។បេ។ សមាធិសំវត្តនិកានិ ។

(១៩១) ឥមេសំ ខោ អាវុសោ ចតុន្នំ ធម្មានំ បហានា ឥមេសំ ចតុន្នំ ធម្មានំ សមន្នាគមនហេតុ ឯវមយំ បជា ភគវតា ព្យាកតា សោតាបន្នា អវិនិបាតធម្មា និយតា សម្ពោធិបរាយណាតិ ។

(១៩២) ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ អរិយសាវកោ សព្វទុគ្គតិភយំ សមតិក្កន្តោ ហោតិ ។ កតមេហិ ចតូហិ ។ ឥធ ភិក្ខវេ អរិយសាវកោ

---

១ ឱ. ទុស្សីល្យេន ហោតិ ។

[១៩០] ម្នាលអាវុសោ បុថុជ្ជន អ្នកមិនចេះដឹង ប្រកបដោយការៈជាអ្នកទ្រុស្តសីល មានសភាពយ៉ាងណា លុះរំលាងខន្ធ បន្ទាប់អំពីមរណៈរមែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ការៈជាអ្នកទ្រុស្តសីល មានសភាពយ៉ាងនោះ ឥតមានដល់អរិយសាវកនោះឡើយ ។ ម្នាលអាវុសោ ចំណែកអរិយសាវក ប្រកបដោយសីលទាំងឡាយ ជាទីស្រឡាញ់របស់អរិយៈ មានសភាពយ៉ាងណា លុះរំលាងខន្ធ បន្ទាប់អំពីមរណៈ រមែងទៅកើតក្នុងលោកគឺសុគតិស្ថានសួគ៌ សីលទាំងឡាយ ជាទីស្រឡាញ់របស់អរិយៈ មានសភាពយ៉ាងនោះ ជាសីលមិនដាច់ ។បេ។ ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ តែងមានដល់អរិយសាវកនោះ ។

[១៩១] ម្នាលអាវុសោ ព្រោះលះធម៌ ៤ យ៉ាងនេះឯង ព្រោះប្រកបដោយធម៌ ៤ យ៉ាងនេះឯង ទើបព្រះដ៏មានព្រះភាគ ទ្រង់ព្យាករពួកសត្វនេះយ៉ាងនេះថា សោតាបន្នបុគ្គល មានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ ។

[១៩២] ម្នាលភិក្ខុទាំងឡាយ អរិយសាវកប្រកបដោយធម៌ ៤ យ៉ាងនេះ ទើបគន្លងបង់នូវភ័យក្នុងទុគ្គតិទាំងពួងបាន ។ ធម៌ទាំង ៤ យ៉ាងតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងធម្មវិន័យនេះ

ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ ឥតិបិ សោ ភគវា ។បេ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ធម្មេ ។ សង្ឃេ ។ អរិយកន្តេហិ សីលេហិ សមន្នាគតោ ហោតិ អខណ្ឌេហិ ។បេ។ សមាធិសំវត្តនិកេហិ ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ អរិយសាវកោ សព្វទុគ្គតិភយំ សមតិក្កន្តោ ហោតីតិ ។

[ ១៩៣ ] ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ហោតិ អរិយសាវកោ សព្វទុគ្គតិវិនិបាតភយំ សមតិក្កន្តោ ហោតិ ។ កតមេហិ ចតូហិ ។ ឥធ ភិក្ខវេ អរិយសាវកោ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ ឥតិបិ សោ ភគវា ។បេ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ធម្មេ ។ សង្ឃេ ។ អរិយកន្តេហិ សីលេហិ សមន្នាគតោ ហោតិ

ប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគអង្គនោះ ។ បេ ។ ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលមកកាន់កពថ្មីទៀត ។ (អរិយសាវកប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ) ក្នុងព្រះធម៌ ។ ក្នុងព្រះសង្ឃ ។ អរិយសាវកប្រកបដោយសីលទាំងឡាយ ជាទីស្រឡាញ់របស់អរិយៈ ជាសីលមិនដាច់ ។ បេ ។ ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកប្រកបដោយធម៌ ៤ យ៉ាងនេះឯង តែងកន្ទងបង់នូវភ័យក្នុងទុគ្គតិទាំងពួងបាន ។

(១៩៣) ម្នាលភិក្ខុទាំងឡាយ អរិយសាវក ប្រកបដោយធម៌៤យ៉ាង រមែងកន្ទងបង់នូវភ័យក្នុងទុគ្គតិនិងអបាយទាំងពួងបាន ។ ធម៌ ៤ យ៉ាង តើដូចម្តេចៗ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងធម្មវិន័យនេះ ប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគអង្គនោះ ។ បេ ។ ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលមកកាន់កពថ្មីទៀត ។ (អរិយសាវកប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ) ក្នុងព្រះធម៌ ។ ក្នុងព្រះសង្ឃ ។ អរិយសាវក ប្រកបដោយសីលទាំងឡាយ ជាទីស្រឡាញ់របស់អរិយៈ

អខណ្ឌេហិ ។បេ។ សមាធិសំវត្តនិកេហិ ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ អរិយសាវកោ សព្វទុគ្គតិវិនិបាតភយំ សមតិក្កន្តោ ហោតីតិ ។

(១៩៤) យេ តេ(១) ភិក្ខវេ អនុកម្បេយ្យាថ យេ ច សោតព្វំ មញ្ញេយ្យុំ មិត្តា វា អមច្ចា វា ញាតី វា សាលោហិតា វា តេ(២) ភិក្ខវេ ចតូសុ សោតាបត្តិយង្គេសុ សមាទបេតព្វា និវេសេតព្វា បតិដ្ឋាបេតព្វា ។ កតមេសុ ចតូសុ ។ ពុទ្ធេ អវេច្ចប្បសាទេ សមាទបេតព្វា និវេសេតព្វា បតិដ្ឋាបេតព្វា ឥតិបិ សោ ភគវា ។បេ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ធម្មេ ។ សង្ឃេ ។ អរិយកន្តេសុ សីលេសុ សមាទបេតព្វា និវេសេតព្វា បតិដ្ឋាបេតព្វា អខណ្ឌេសុ ។បេ។

---

១ ឱ. យេ ហិ ។ ២ ឱ. តេ វោ ។

ជាសីលមិនដាច់ ។បេ។ ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវក ប្រកបដោយធម៌ ៤ យ៉ាងនេះឯង ឈ្មោះថាកន្លងបង់នូវភ័យក្នុងទុគ្គតិនិងអបាយទាំងពួងបាន ។

(១៩៤) ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គួរអនុគ្រោះចំពោះជនពួកណា មួយទៀត ជនពួកណាជាមិត្រក្តី អមាត្យក្តី ញាតិក្តី សាលោហិតក្តី គប្បីសំគាល់នូវពាក្យដែលខ្លួនគួរស្តាប់ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវញុំាងពួកជនទាំងអស់នោះ ឲ្យសមាទាន ឲ្យតាំងនៅ ឲ្យប្រតិស្ឋានទៅ ក្នុងអង្គនៃសោតាបត្តិ ៤ យ៉ាង ។ អង្គនៃសោតាបត្តិ ៤ យ៉ាងដូចម្តេច ។ គឺអ្នកទាំងឡាយ ត្រូវញុំាងពួកជនទាំងអស់នោះ ឲ្យសមាទាន ឲ្យតាំងនៅ ឲ្យប្រតិស្ឋានទៅ ក្នុងសេចក្តីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគអង្គនោះ ។បេ។ ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលមកកាន់ភពថ្មីទៀត ។ (អរិយសាវកប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ) ក្នុងព្រះធម៌ ។ ក្នុងព្រះសង្ឃ ។ អ្នកទាំងឡាយ ត្រូវញុំាងពួកជនទាំងអស់នោះ ឲ្យសមាទាន ឲ្យតាំងនៅ ឲ្យប្រតិស្ឋានទៅ ក្នុងសីលទាំងឡាយ ជាទីស្រឡាញ់របស់អរិយៈ ជាសីលមិនដាច់ ។បេ។

សមាធិសំវត្តនិកេសុ ។ យេ តេ ភិក្ខវេ អនុកម្បេយ្យាថ យេ ច សោតព្វំ មញ្ញេយ្យុំ មិត្តា វា អមច្ចា វា ញាតី វា សាលោហិតា វា តេ ភិក្ខវេ ឥមេសុ ចតូសុ សោតាបត្តិយង្គេសុ សមាទបេតព្វា និវេសេតព្វា បតិដ្ឋាបេតព្វាតិ ។

(១៩៨) យេ តេ ភិក្ខវេ អនុកម្បេយ្យាថ យេ ច សោតព្វំ មញ្ញេយ្យុំ មិត្តា វា អមច្ចា វា ញាតី វា សាលោហិតា វា តេ ភិក្ខវេ ចតូសុ សោតាបត្តិយង្គេសុ សមាទបេតព្វា និវេសេតព្វា បតិដ្ឋាបេតព្វា ។ កតមេសុ ចតូសុ ។ ពុទ្ធេ អវេច្ចប្បសាទេ សមាទបេតព្វា និវេសេតព្វា បតិដ្ឋាបេតព្វា ឥតិបិ សោ ភគវា ។បេ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។

ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគួរអនុគ្រោះចំពោះជនពួកណា មួយទៀត ជនពួកណាជាមិត្រក្តី អមាត្យក្តី ញាតិក្តី សាលោហិតក្តី គប្បីសំគាល់នូវពាក្យដែលខ្លួនគួរស្តាប់ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវញុំាងពួកជនទាំងអស់នោះ ឲ្យសមាទាន ឲ្យតាំងនៅ ឲ្យប្រតិស្ឋានទៅ ក្នុងអង្គនៃសោតាបត្តិទាំង ៤ យ៉ាងនេះ ។

[១៩៥] ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គួរអនុគ្រោះចំពោះជនពួកណា មួយទៀត ជនពួកណាជាមិត្រក្តី អមាត្យក្តី ញាតិក្តី សាលោហិតក្តី គប្បីសំគាល់នូវពាក្យដែលខ្លួនគួរស្តាប់ ម្នាលភិក្ខុទាំង-ឡាយ អ្នកទាំងឡាយ ត្រូវញុំាងពួកជនទាំងអស់នោះ ឲ្យសមាទាន ឲ្យតាំងនៅ ឲ្យប្រតិស្ឋានទៅ ក្នុងអង្គនៃសោតាបត្តិ ៤ យ៉ាង ។ អង្គនៃសោតាបត្តិ ៤ យ៉ាង តើដូចម្តេច ។ គឺត្រូវញុំាងពួកជនទាំងអស់នោះ ឲ្យសមាទាន ឲ្យតាំងនៅ ឲ្យប្រតិស្ឋានទៅ ក្នុងសេចក្តីជ្រះថ្លាមិនញាប់ញ័រក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគអង្គនោះ ។បេ។ ព្រះអង្គជាគ្រូនៃទេវតានឹងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលមកកាន់កពថ្មីទៀត ។

[១៩៦] សិយា ភិក្ខវេ ចតុន្នំ មហាភូតានំ អញ្ញថត្តំ បឋវីធាតុយា អាបោធាតុយា តេជោធាតុយា វាយោធាតុយា ។ ន ត្វេវ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតស្ស អរិយសាវកស្ស សិយា អញ្ញថត្តំ ។ តត្រិទំ អញ្ញថត្តំ ។ សោ វត ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ អរិយសាវកោ និរយំ វា តិរច្ឆានយោនិំ វា បិត្តិវិសយំ វា ឧបបជ្ជិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ ធម្មេ ។ សង្ឃេ ។ អរិយកន្តេសុ សីលេសុ សមាទបេតព្វា និវេសេតព្វា បតិដ្ឋាបេតព្វា អខណ្ឌេសុ ។ បេ ។ សមាធិសំវត្តនិកេសុ ។

(១៩៧) សិយា ភិក្ខវេ ចតុន្នំ មហាភូតានំ អញ្ញថត្តំ បឋវីធាតុយា អាបោធាតុយា តេជោធាតុយា វាយោធាតុយា ។ ន ត្វេវ អរិយកន្តេហិ សីលេហិ សមន្នាគតស្ស អរិយសាវកស្ស សិយា អញ្ញថត្តំ ។ តត្រិទំ អញ្ញថត្តំ ។ សោ វត អរិយកន្តេហិ សីលេហិ សមន្នាគតោ អរិយសាវកោ និរយំ វា តិរច្ឆានយោនិំ វា បិត្តិវិសយំ វា ឧបបជ្ជិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។

[១៩៦] ម្នាលភិក្ខុទាំងឡាយ បើសេចក្ដីប្រែប្រួលទៅនៃមហាភូតរូប ៤ គឺធាតុដី ធាតុទឹក ធាតុភ្លើង ធាតុខ្យល់ គប្បីមាន ។ (តែចិត្ត) របស់អរិយសាវក ដែលប្រកបដោយសេចក្ដីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធនឹងបានប្រែប្រួលទៅក៏ទេ ។ នេះជាសេចក្ដីប្រែប្រួលក្នុងហេតុនោះ ។ អរិយសាវកនោះ ប្រកបដោយសេចក្ដីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធហើយនឹងទៅកើត ក្នុងនរកឬកំណើតសត្វតិរច្ឆានឬប្រេតវិស័យដូច្នេះ នេះមិនមែនជាឋានៈឡើយ ។ (អរិយសាវកប្រកបដោយសេចក្ដីជ្រះថ្លាមិនញាប់ញ័រ) ក្នុងព្រះធម៌ ។ ក្នុងព្រះសង្ឃ ។ អ្នកទាំងឡាយ ត្រូវញុំាងពួកជនទាំងអស់នោះ ឲ្យសមាទាន ឲ្យតាំងនៅ ឲ្យប្រតិស្ឋានទៅ ក្នុងសីលទាំងឡាយ ជាទីស្រឡាញ់របស់អរិយៈ ជាសីលមិនដាច់ ។ បេ ។ ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ ។

[១៩៧] ម្នាលភិក្ខុទាំងឡាយ សេចក្ដីប្រែប្រួលនៃមហាភូតរូប ៤ គឺធាតុដី ធាតុទឹក ធាតុភ្លើង ធាតុខ្យល់ គប្បីមាន (តែចិត្ត) របស់អរិយសាវកដែលប្រកបដោយសីលទាំងឡាយ ជាទីស្រឡាញ់របស់អរិយៈហើយ នឹងបានប្រែប្រួលទៅក៏ទេ ។ នេះជាសេចក្ដីប្រែប្រួលក្នុងហេតុនោះ ។ អរិយសាវកនោះ ប្រកបដោយសីលទាំងឡាយ ជាទីស្រឡាញ់របស់អរិយៈហើយ នឹងទៅកើត ក្នុងនរកឬកំណើតសត្វតិរច្ឆានឬប្រេតវិស័យដូច្នេះ នេះមិនមែនជាឋានៈឡើយ ។

## រាជការាមវគ្គោ ទុតិយោ

(១៩៨) យេ តេ ភិក្ខវេ អនុកម្បេយ្យាថ យេ ច វោ សោតព្វំ មញ្ញេយ្យុំ មិត្តា វា អមច្ចា វា ញាតី វា សាលោហិតា វា តេ ភិក្ខវេ ឥមេសុ ចតូសុ សោតាបត្តិយង្គេសុ សមាទបេតព្វា និវេសេតព្វា បតិដ្ឋាបេតព្វាតិ ។

(១៩៩) សាវត្ថីនិទានំ ។ អថខោ អាយស្មា មហាមោគ្គល្លានោ សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ ជេតវនេ អន្តរហិតោ ទេវេសុ តាវតឹសេសុ បាតុរហោសិ ។ អថខោ សម្ពហុលា តាវតឹសកាយិកា ទេវតាយោ យេនាយស្មា មហាមោគ្គល្លានោ តេនុបសង្កមឹសុ ឧបសង្កមិត្វា អាយស្មន្តំ មហាមោគ្គល្លានំ អភិវាទេត្វា ឯកមន្តំ អដ្ឋំសុ ។ ឯកមន្តំ ឋិតា ខោ តា ទេវតាយោ អាយស្មា មហាមោគ្គល្លានោ ឯតទវោច

(២០០) សាធុ ខោ អាវុសោ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគមនំ ហោតិ ឥតិបិ សោ ភគវា ។ បេ ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។

ភាណវារៈទី ២

[១៩៨] ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គួរអនុគ្រោះចំពោះជនពួកណាមួយទៀត ជនពួកណាជាមិត្រក្តី អមាត្យក្តី ញាតិក្តី សាលោហិតក្តី គប្បីសំគាល់នូវពាក្យដែលខ្លួនគួរស្តាប់ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវញ៉ាំងពួកជនទាំងអស់នោះ ឲ្យសមាទាន ឲ្យតាំងនៅ ឲ្យប្រតិស្ឋាននៅ ក្នុងអង្គនៃសោតាបត្តិទាំង ៤ នេះចុះ ។

[១៩៩] សាវត្ថីនិទាន ។ គ្រានោះឯង ព្រះមហាមោគ្គល្លានដ៏មានអាយុ ក៏បាត់ខ្លួនក្នុងវត្តជេតពន មកប្រាកដក្នុងពួកទេវតាជាន់តាវត្តិង្ស ដូចជាបុរសមានកម្លាំងលាដៃដែលបត់ចូល ឬបត់ចូលនូវដៃដែលលាចេញ ដូច្នោះឯង ។ គ្រានោះឯង ទេវតាទាំងឡាយ ដែលនៅក្នុងពួកទេវតាជាន់តាវត្តិង្សជាច្រើន បាននាំគ្នាចូលទៅរកព្រះមហាមោគ្គល្លានដ៏មានអាយុ លុះចូលទៅដល់ថ្វាយបង្គំព្រះមហាមោគ្គល្លានដ៏មានអាយុ ហើយឋិតនៅក្នុងទីដ៏សមគួរ ។ លុះទេវតាទាំងនោះឋិតនៅក្នុងទីដ៏សមគួរហើយ ទើបព្រះមហាមោគ្គល្លានដ៏មានអាយុ បានពោលដូច្នេះថា

[២០០] ម្នាលអ្នកដ៏មានអាយុទាំងឡាយ ប្រពៃណាស់ហើយ ការប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគអង្គនោះ ។ បេ ។ ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលមកកាន់ភពថ្មីទៀតហើយ ។

ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគមនហេតុ ខោ អាវុសោ ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ។ សាធុ ខោ អាវុសោ ធម្មេ ។ សង្ឃេ ។ សាធុ ខោ អាវុសោ អរិយកន្តេហិ សីលេហិ សមន្នាគមនំ ហោតិ អខណ្ឌេហិ ។បេ។ សមាធិសំវត្តនិកេហិ ។ អរិយ-កន្តេហិ សីលេហិ សមន្នាគមនហេតុ ខោ អាវុសោ ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តីតិ ។

(២០១) សាធុ ខោ មារិស មោគ្គល្លាន ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគមនំ ហោតិ ឥតិបិ សោ ភគវា ។បេ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។

ម្នាលអ្នកដ៏មានអាយុទាំងឡាយ សត្វទាំងឡាយពួកខ្លះ ក្នុងលោកនេះ ហេតុតែប្រកបដោយសេចក្ដីជ្រះថ្លា មិនញាប់ញ័រ ក្នុងព្រះពុទ្ធយ៉ាងនេះ លុះដល់រំលាងខ្លួន បន្ទាប់អំពីមរណៈ រមែងទៅកើតក្នុងលោកគឺសុគតិ ស្ថានសួគ៌ ។ ម្នាលអ្នកដ៏មានអាយុទាំងឡាយ ប្រពៃណាស់ហើយ (ការប្រកបដោយសេចក្ដីជ្រះថ្លាមិនញាប់ញ័រ) ក្នុងព្រះធម៌ ។ ក្នុងព្រះសង្ឃ ។ ម្នាលអ្នកដ៏មានអាយុទាំងឡាយ ប្រពៃណាស់ហើយ ការប្រកបដោយសីលទាំងឡាយ ជាទីស្រឡាញ់របស់អរិយៈ ជាសីលមិនដាច់ ។ បេ ។ ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ ។ ម្នាលអ្នកដ៏មានអាយុទាំងឡាយ សត្វទាំងឡាយពួកខ្លះ ក្នុងលោកនេះ ហេតុតែប្រកបដោយសីលទាំងឡាយរបស់អរិយៈយ៉ាងនេះ លុះរំលាងខ្លួន បន្ទាប់អំពីមរណៈ រមែងទៅកើតក្នុងលោកគឺសុគតិ ស្ថានសួគ៌ ។

(២០១) ពួកទេវតាក្នុងជាន់តាវត្តិង្ស ទូលតបព្រះមហាមោគ្គល្លានវិញថា បពិត្រព្រះមោគ្គល្លាន អ្នកនិទ្ទុក្ខ ប្រពៃណាស់ហើយ ការប្រកបដោយសេចក្ដីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគអង្គនោះ ។ បេ ។ ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលមកកាន់ភពថ្មីទៀតហើយ ។

ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគមនហេតុ ខោ មារិស មោគ្គល្លាន ឥធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ។ សាធុ ខោ មារិស មោគ្គល្លាន ធម្មេ ។ សង្ឃេ ។ អរិយ-កន្តេហិ សីលេហិ សមន្នាគមនំ ហោតិ អខណ្ឌេហិ ។ បេ ។ សមាធិសំវត្តនិកេហិ ។ អរិយកន្តេហិ សីលេហិ សមន្នាគមនហេតុ ខោ មារិស មោគ្គល្លាន ឥធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តីតិ ។

[២០២] សាវត្ថីនិទានំ ។ អថខោ អាយស្មា មហាមោគ្គល្លានោ សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ ជេតវនេ អន្តរហិតោ ទេវេសុ តាវត្តឹសេសុ បាតុរហោសិ ។ អថខោ សម្ពហុលា តាវត្តឹសកាយិកា ទេវតាយោ យេនាយស្មា មហាមោគ្គល្លានោ តេនុបសង្កមឹសុ

បពិត្រព្រះមោគ្គល្លានអ្នកនិទុក្ខ សត្វទាំងឡាយពួកខ្លះ ក្នុងលោកនេះ ហេតុតែប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធយ៉ាងនេះ លុះដល់រំលាយខន្ធ បន្ទាប់អំពីមរណៈ រមែងទៅកើតក្នុងលោកគឺសុគតិ ស្ថានសួគ៌ ។ បពិត្រព្រះមោគ្គល្លានអ្នកនិទុក្ខ ប្រពៃណាស់ហើយ (ការប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ) ក្នុងព្រះធម៌ ។ ក្នុងព្រះសង្ឃ ។ ការប្រកបដោយសីលទាំងឡាយ ជាទីស្រឡាញ់របស់អរិយៈ ជាសីលមិនដាច់ ។ បេ ។ ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ ។ បពិត្រព្រះមោគ្គល្លានអ្នកនិទុក្ខ សត្វទាំងឡាយពួកខ្លះ ក្នុងលោកនេះ ហេតុតែប្រកបដោយសីលទាំងឡាយ ជាទីស្រឡាញ់របស់អរិយៈយ៉ាងនេះ លុះរំលាយខន្ធ បន្ទាប់អំពីមរណៈ រមែងទៅកើតក្នុងលោកគឺសុគតិស្ថានសួគ៌ ។

[២០២] សាវត្ថីនិទាន ។ គ្រានោះឯង ព្រះមហាមោគ្គល្លានដ៏មានអាយុ ក៏បាត់ខ្លួនក្នុងវត្តជេតពន ទៅប្រាកដក្នុងឋានតាវត្តិង្សទេវលោក ដូចជាបុរសមានកម្លាំង លាដៃដែលបត់ចូល ឬ បត់ចូលនូវដៃដែលលាចេញ ដូច្នោះឯង ។ គ្រានោះ ទេវតាទាំងឡាយដែលនៅក្នុងពួកទេវតាជាន់តាវត្តិង្សដ៏ច្រើន បាននាំគ្នាចូលទៅរកព្រះមហាមោគ្គល្លានដ៏មានអាយុ

ឧបសង្កមិត្វា អាយស្មន្តំ មហាមោគ្គល្លានំ អភិវាទេត្វា ឯកមន្តំ អដ្ឋំសុ ។ ឯកមន្តំ ឋិតា ខោ តា ទេវតាយោ អាយស្មា មហាមោគ្គល្លានោ ឯតទវោច

(២០៣) សាធុ ខោ អាវុសោ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគមនំ ហោតិ ឥតិបិ សោ ភគវា ។ បេ ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគមនហេតុ ខោ អាវុសោ ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបន្នា ។ សាធុ ខោ អាវុសោ ធម្មេ ។ សង្ឃេ ។ អរិយកន្តេហិ សីលេហិ សមន្នាគមនំ ហោតិ អខណ្ឌេហិ ។ បេ ។ សមាធិសំវត្តនិកេហិ ។ អរិយកន្តេហិ សីលេហិ សមន្នាគមនហេតុ ខោ អាវុសោ ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបន្នាតិ ។

លុះចូលទៅដល់ថ្វាយបង្គំព្រះមហាមោគ្គល្លានដ៏មានអាយុ ហើយបិតនៅក្នុងទីដ៏សមគួរ ។ លុះទេវតាទាំងនោះ បិតនៅក្នុងទីដ៏សមគួរហើយ ទើបព្រះមហាមោគ្គល្លានដ៏មានអាយុ បានពោលដូច្នេះថា

[២០៣] ម្នាលអ្នកដ៏មានអាយុទាំងឡាយ ប្រពៃណាស់ហើយ ការប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគអង្គនោះ ។ បេ ។ ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលមកកាន់កំណើតទៀតហើយ ។ ម្នាលអ្នកដ៏មានអាយុទាំងឡាយ សត្វទាំងឡាយពួកខ្លះ ក្នុងលោកនេះ ហេតុតែប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធយ៉ាងនេះ លុះដល់រំលាយខន្ធ បន្ទាប់អំពីមរណៈ រមែងទៅកើតក្នុងលោកគឺសុគតិសួគ៌ ។ ម្នាលអ្នកដ៏មានអាយុទាំងឡាយ ប្រពៃណាស់ហើយ (ការប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រ) ក្នុងព្រះធម៌ ។ ក្នុងព្រះសង្ឃ ។ ការប្រកបដោយសីលទាំងឡាយ ជាទីស្រឡាញ់របស់អរិយៈ ជាសីលមិនដាច់ ។ បេ ។ ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ ។ ម្នាលអ្នកដ៏មានអាយុទាំងឡាយ សត្វទាំងឡាយពួកខ្លះ ក្នុងលោកនេះ ហេតុតែប្រកបដោយសីលទាំងឡាយ ជាទីស្រឡាញ់របស់អរិយៈយ៉ាងនេះ លុះដល់រំលាយខន្ធ បន្ទាប់អំពីមរណៈ រមែងទៅកើតក្នុងលោកគឺសុគតិសួគ៌ ។

(២០៤) សាធុ ខោ មារិស មោគ្គល្លាន ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគមនំ ហោតិ ឥតិបិ សោ ភគវា ។បេ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគមនហេតុ ខោ មារិស មោគ្គល្លាន ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបន្នា ។ សាធុ ខោ មារិស មោគ្គល្លាន ធម្មេ ។ សង្ឃេ ។ អរិយកន្តេហិ សីលេហិ សមន្នាគមនំ ហោតិ អខណ្ឌេហិ ។បេ។ សមាធិសំវត្តនិកេហិ ។ អរិយកន្តេហិ សីលេហិ សមន្នាគមនហេតុ ខោ មារិស មោគ្គល្លាន ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបន្នាតិ ។

## ភាណវារវគ្គទី ២

[២០៤] ពួកទេវតាជាន់តាវត្តិង្ស ទូលតបព្រះមហាមោគ្គល្លាន វិញថា បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ ប្រពៃណាស់ហើយ ការប្រកប ដោយសេចក្ដីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគអង្គ នោះ ។បេ។ ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលមកកាន់កពភ៌ទៀតហើយ ។ បពិត្រ ព្រះមោគ្គល្លានអ្នកនិរទុក្ខ សត្វទាំងឡាយពួកខ្លះ ក្នុងលោកនេះ ហេតុតែ ប្រកបដោយសេចក្ដីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធយ៉ាងនេះ លុះដល់ រំលាងខន្ធ បន្ទាប់អំពីមរណៈ រមែងទៅកើតក្នុងលោកគឺសុគតិស្ថានសួគ៌ ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ ប្រពៃណាស់ហើយ (ការប្រកបដោយ សេចក្ដីជ្រះថ្លាមិនញាប់ញ័រ) ក្នុងព្រះធម៌ ។ ក្នុងព្រះសង្ឃ ។ ការប្រកប ដោយសីលទាំងឡាយ ជាទីស្រឡាញ់របស់អរិយៈ ជាសីលមិនដាច់ ។បេ។ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ សត្វទាំងឡាយពួកខ្លះ ក្នុងលោកនេះ ហេតុតែប្រកបដោយសីលទាំង ឡាយ ជាទីស្រឡាញ់របស់អរិយៈយ៉ាងនេះ លុះរំលាងខន្ធ បន្ទាប់អំពី មរណៈ រមែងទៅកើតក្នុងលោកគឺសុគតិ ស្ថានសួគ៌ ។

[២០៥] អថខោ ភគវា សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ ជេតវនេ អន្តរហិតោ ទេវេសុ តាវត្តឹសេសុ បាតុរហោសិ ។ អថខោ សម្ពហុលា តាវត្តឹសកាយិកា ទេវតាយោ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋំសុ ។ ឯកមន្តំ ឋិតា ខោ តា ទេវតាយោ ភគវា ឯតទវោច

[២០៦] សាធុ ខោ អាវុសោ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគមនំ ហោតិ ឥតិបិ សោ ភគវា ។បេ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគមនហេតុ ខោ អាវុសោ ឯវមិធេកច្ចេ សត្តា សោតាបន្នា អវិនិបាតធម្មា និយតា សម្ពោធិបរាយណា ។

[២០៥] គ្រានោះឯង ព្រះដ៏មានព្រះភាគក៏បាត់ព្រះអង្គក្នុងវត្តជេតពន ទៅប្រាកដក្នុងពួកទេវតាជាន់តាវត្តិង្ស ដូចជាបុរសមានកម្លាំងលាដៃដែលបត់ចូល ឬបត់ចូលនូវដៃដែលលាចេញ ដូច្នោះឯង ។ គ្រានោះឯង ទេវតាទាំងឡាយ ដែលនៅក្នុងពួកទេវតាជាន់តាវត្តិង្សដ៏ច្រើន បាននាំគ្នាចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយឋិតនៅក្នុងទីដ៏សមគួរ ។ លុះទេវតាទាំងនោះឋិតនៅក្នុងទីដ៏សមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា

[២០៦] ម្នាលអ្នកដ៏មានអាយុទាំងឡាយ ប្រពៃណាស់ហើយ ការប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគអង្គនោះ ។បេ។ ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលមកកាន់ភពថ្មីទៀតហើយ ។ ម្នាលអ្នកដ៏មានអាយុទាំងឡាយ សត្វទាំងឡាយពួកខ្លះ ក្នុងលោកនេះ ហេតុតែប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធយ៉ាងនេះ រមែងបានជាសោតាបន្នបុគ្គល មានសភាពមិនធ្លាក់ចុះទៅក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ។

សាធុ ខោ អាវុសោ ធម្មេ ។ សង្ឃេ ។ អរិយកន្តេហិ សីលេហិ សមន្នាគមនំ ហោតិ អខណ្ឌេហិ ។បេ។ សមាធិសំវត្តនិកេហិ ។ អរិយកន្តេហិ សីលេហិ សមន្នាគមនហេតុ ខោ អាវុសោ ឯវមិធេកច្ចេ សត្តា សោតាបន្នា អវិនិបាតធម្មា និយតា សម្ពោធិបរាយនាតិ ។

(២០៧) សាធុ ខោ មារិស ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគមនំ ហោតិ ឥតិបិ សោ ភគវា ។បេ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគមនហេតុ ខោ មារិស ឯវមយំ បជា សោតាបន្នា អវិនិបាតធម្មា និយតា សម្ពោធិបរាយនា ។

ម្នាលអ្នកដ៏មានអាយុទាំងឡាយ ប្រពៃណាស់ហើយ (ការប្រកបដោយសេចក្ដីជ្រះថ្លាមិនញាប់ញ័រ) ក្នុងព្រះធម៌ ។ ក្នុងព្រះសង្ឃ ។ ការប្រកបដោយសីលទាំងឡាយ ជាទីស្រឡាញ់របស់អរិយៈ ជាសីលមិនដាច់ ។ បេ ។ ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ ។ ម្នាលអ្នកដ៏មានអាយុទាំងឡាយ សត្វទាំងឡាយពួកខ្លះ ក្នុងលោកនេះ ហេតុតែប្រកបដោយសីលទាំងឡាយ ជាទីស្រឡាញ់របស់អរិយៈយ៉ាងនេះ ទើបបានជាសោតាបន្នបុគ្គល មានសភាពមិនធ្លាក់ចុះទៅក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ។

(២០៧) ពួកទេវតាក្នុងជាន់តាវត្តិង្ស ក្រាបទូលថា បពិត្រព្រះអង្គអ្នកនិទុក្ខ ប្រពៃណាស់ហើយ ការប្រកបដោយសេចក្ដីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគអង្គនោះ ។ បេ ។ ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលមកកាន់ភពថ្មីទៀតហើយ ។ បពិត្រព្រះអង្គអ្នកនិទុក្ខ ពួកសត្វនេះ ហេតុតែប្រកបដោយសេចក្ដីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធយ៉ាងនេះ ទើបបានជាសោតាបន្នបុគ្គល មានសភាពមិនធ្លាក់ចុះទៅក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ។

សាធុ ខោ មារិស ធម្មេ ។ សង្ឃេ ។ អរិយកន្តេហិ សីលេហិ សមន្នាគមនំ ហោតិ អខណ្ឌេហិ ។ បេ ។ សមាធិសំវត្តនិកេហិ ។ អរិយកន្តេហិ សីលេហិ សមន្នាគមនហេតុ ខោ មារិស ឯវមិយំ បជា សោតាបន្នា អវិនិបាតធម្មា និយតា សម្ពោធិបរាយនាតិ ។

រាជការាមវគ្គោ (១)ទុតិយោ ។

## តស្សុទ្ទានំ

សហស្សព្រាហ្មណា អានន្ទោ
ទុគ្គតិ អបរេ ទុវេ
មិត្តាមច្ចា ទ្វេ វុត្តា
តយោ ច ទេវចារិកាតិ ។

---

១ ឱ. សហស្សកវគ្គោ ។

បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ប្រពៃណាស់ហើយ (ការប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ) ក្នុងព្រះធម៌ ។ ក្នុងព្រះសង្ឃ ។ ការប្រកបដោយសីលទាំងឡាយ ជាទីស្រឡាញ់របស់អរិយៈ ជាសីលមិនដាច់ ។ បេ ។ ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ ។ បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ពួកសត្វនេះ ហេតុតែប្រកបដោយសីលទាំងឡាយ ជាទីស្រឡាញ់របស់អរិយៈយ៉ាងនេះ ទើបបានជាសោតាបន្នបុគ្គល មានសភាពមិនធ្លាក់ចុះទៅក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ។

ចប់ រាជការាមវគ្គទី ២ ។

## ឧទ្ទាននៃរាជការាមវគ្គនោះគឺ

ពោលអំពីភិក្ខុនីមួយពាន់រូប ១ អំពីព្រាហ្មណ៍ ១ អំពី
ព្រះសារីបុត្តនឹងព្រះអានន្ទ ១ អំពីទុគ្គតិ នឹងសុគតិ មាន
២ លើក អំពីមិត្រនឹងអមាត្យជាដើមមាន ២ លើក អំពី
ការត្រេចទៅកាន់ចារិកក្នុងទេវលោកមាន ៣ លើក ។

# សរកានិវគ្គោ(១) តតិយោ

[២០៨] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សក្កេសុ វិហរតិ កបិលវត្ថុស្មឹ និគ្រោធារាមេ ។ អថ ខោ មហានាមោ សក្កោ យេន ភគវា តេនុប-សង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ មហានាមោ សក្កោ ភគវន្តំ ឯតទវោច ឥទំ ភន្តេ កបិលវត្ថុ ឥទ្ធញ្ចេវ ផីតញ្ច ពហុជញ្ញំ(២) អាកិណ្ណមនុស្សំ សម្ពា-ធព្យូហំ(៣) ។ សោ ខ្វាហំ ភន្តេ ភគវន្តំ វា បយិរុបា-សិត្វា មនោភាវនីយេ វា ភិក្ខូ សាយណ្ហសមយំ កបិលវត្ថុំ បវិសន្តោ ភន្តេនបិ(៤) ហត្ថិនា សមាគច្ឆាមិ ភន្តេនបិ អស្សេន សមាគច្ឆាមិ ភន្តេនបិ រថេន សមាគច្ឆាមិ ភន្តេនបិ សកដេន សមាគច្ឆាមិ ភន្តេ-នបិ បុរិសេន សមាគច្ឆាមិ ។ តស្ស មយ្ហំ ភន្តេ តស្មឹ សមយេ មុស្សតេវ ភគវន្តំ អារព្ភ សតិ មុស្សតិ ធម្មំ អារព្ភ សតិ មុស្សតិ សង្ឃំ អារព្ភ សតិ ។

---

១ ម. សរណានិវគ្គោ ។ ២ ឱ. ពហុជនំ ។ ៣ សម្ពាធព្យូហន្តិ អដ្ឋកថាយំ ទិស្សតិ ។
៤ ភមន្តេនាបិ ហត្ថិនា ។

# សរកានិវគ្គទី ៣

[២០៨] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងនិគ្រោធារាម ជិតក្រុងកបិលព័ស្តុ ក្នុងដែនសក្កៈ ។ គ្រានោះឯង ព្រះមហានាមសក្យរាជចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះបានចូលទៅដល់ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ គង់ក្នុងទីដ៏សមគួរ ។ លុះព្រះមហានាមសក្យរាជ គង់ក្នុងទីដ៏សមគួរហើយ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន នគរកបិលព័ស្តុនេះ ជានគរស្តុកស្តម្ភធំទូលាយ មានមនុស្សច្រើន មានមនុស្សកុះករ មានច្រកបង្អៀតដ៏ច្រើន ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនោះឯង បានចូលមកអង្គុយជិតព្រះដ៏មានព្រះភាគផង បានចូលមកអង្គុយជិតភិក្ខុទាំងឡាយ ដែលគួរជាទីចំរើនចិត្តផង ហើយចូលទៅនគរកបិលព័ស្តុក្នុងវេលាល្ងាចវិញ តែងទៅដោយដំរីល្បឿនក៏មាន ទៅដោយសេះល្បឿនក៏មាន ទៅដោយរថល្បឿនក៏មាន ទៅដោយរទេះល្បឿនក៏មាន ទៅដោយបុរសល្បឿនក៏មាន ។ បពិត្រព្រះអង្គដ៏ចំរើន ក្នុងពេលនោះ សតិរបស់ខ្ញុំព្រះអង្គប្រារព្ធព្រះដ៏មានព្រះភាគ ក៏ភ្លេចបាត់ទៅ សតិប្រារព្ធព្រះធម៌ក៏ភ្លេចបាត់ទៅ សតិប្រារព្ធព្រះសង្ឃក៏ភេចបាត់ទៅ ។

តស្ស មយ្ហំ ភន្តេ ឯវំ ហោតិ ឥមម្ហិ ចាហំ សមយេ កាលំ ករេយ្យំ កា មយ្ហំ គតិ កោ អភិសម្បរាយោតិ ។

(២០៩) មា ភាយិ មហានាម មា ភាយិ មហានាម អបាបកន្តេ មរណំ ភវិស្សតិ អបាបិកា កាលកិរិយា ។ យស្ស កស្សចិ មហានាម ទីឃរត្តំ សទ្ធាបរិភាវិតំ ចិត្តំ សីលបរិភាវិតំ ចិត្តំ សុតបរិភាវិតំ ចិត្តំ ចាគបរិភាវិតំ ចិត្តំ បញ្ញាបរិភាវិតំ ចិត្តំ ។ តស្ស យោ ហិ ខ្វាយំ កាយោ រូបី ចាតុម្មហាភូតិកោ មាតាបេត្តិកសម្ភវោ ឱទនកុម្មាសុបចយោ អនិច្ចុច្ឆាទនបរិមទ្ទនភេទនវិទ្ធំសនធម្មោ តំ ឥធេវ កាកា វា ខាទន្តិ គិជ្ឈា វា ខាទន្តិ កុលលា វា ខាទន្តិ សុនខា វា ខាទន្តិ សិគាលា វា ខាទន្តិ វិវិធា វា បាណកជាតា ខាទន្តិ ។

បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ប្រសិនបើអាត្មាអញធ្វើមរណកាលក្នុងសម័យនេះ គតិរបស់អាត្មាអញដូចម្តេចទៅ អភិសម្បរាយភពរបស់អាត្មាអញដូចម្តេចទៅ ។

(២០៩) ព្រះដ៏មានព្រះភាគត្រាស់ថា បពិត្រព្រះមហានាម ព្រះអង្គកុំខ្លាចឡើយ បពិត្រព្រះមហានាម ព្រះអង្គកុំខ្លាចឡើយ មរណភាពរបស់ព្រះអង្គ មុខជាមិនថយថោកទេ កាលកិរិយារបស់ព្រះអង្គ មុខជាមិនថយថោកទេ ។ បពិត្រព្រះមហានាម ចិត្តដែលបុគ្គលណា អប់រំហើយដោយសទ្ធា ចិត្តដែលបុគ្គលណា អប់រំហើយដោយសីល ចិត្តដែលបុគ្គលណា អប់រំហើយដោយសុតៈ ចិត្តដែលបុគ្គលណា អប់រំហើយដោយចាគៈ ចិត្តដែលបុគ្គលណា អប់រំហើយដោយបញ្ញា អស់កាលដ៏យូរ ។ ក៏កាយឯណារបស់បុគ្គលនោះមានរូបជាទីប្រជុំនៃមហាភូតទាំង៤ កើតមកអំពីមាតានឹងបិតាចំរើនឡើងដោយបាយនឹងនំកុម្មាស មានការមិនទៀង ការដុសលាង ការគក់ប្របាច់ ការបែកធ្លាយ នឹងការរលាយទៅជាធម្មតា ក្អែកទាំងឡាយតែងចឹកស៊ីខ្លះ ត្មាតទាំងឡាយតែងចឹកស៊ីខ្លះ ត្រដក់ទាំងឡាយតែងចឹកស៊ីខ្លះ សុនខទាំងឡាយតែងទំពាស៊ីខ្លះ ចចកទាំងឡាយតែងទំពាស៊ីខ្លះ បាណកជាតទាំងឡាយផ្សេង ៗ (សត្តតូច ៗ មានរុយជាដើម) តែងបោមពេមជញ្ជក់ស៊ីខ្លះ នូវកាយនោះឯង ។

## សរកានិវគ្គោ តតិយោ

យញ្ច ខ្វស្ស ចិត្តំ ទីឃរត្តំ សទ្ធាបរិភាវិតំ សីល-សុតចាគបញ្ញាបរិភាវិតំ តំ ឧទ្ធង្គាមិ ហោតិ វិសេសគាមិ ។

(២១០) សេយ្យថាបិ មហានាម បុរិសោ សប្បិ-កុម្ភំ វា តេលកុម្ភំ វា គម្ភីរំ ឧទករហទំ ឱគាហេត្វា ភិន្ទេយ្យ តត្រ យា អស្ស សក្ខរា វា កឋលា វា សា អធោគាមី អស្ស យញ្ច ខ្វស្ស តត្រ សប្បិ វា តេលំ វា តំ ឧទ្ធង្គាមិ អស្ស វិសេសគាមិ ។ ឯវមេវ ខោ មហានាម យស្ស កស្សចិ ទីឃរត្តំ សទ្ធាបរិភាវិតំ ចិត្តំ សីលសុតចាគបញ្ញាបរិភាវិតំ ចិត្តំ តស្ស(១) យោ ហិ ខ្វាយំ កាយោ រូបី ចាតុម្មហាភូតិកោ មាតា-បេត្តិកសម្ភវោ ឱទនកុម្មាសុបចយោ អនិច្ចុច្ឆាទនបរិ-មទ្ទនភេទនវិទ្ធំសនធម្មោ តំ ឥធេវ កាកា វា ខាទន្តិ គិជ្ឈា វា ខាទន្តិ កុលលា វា ខាទន្តិ សុនខា វា ខាទន្តិ សិគាលា វា ខាទន្តិ វិវិធា វា បាណកជាតា

១ ឱ. តស្ស ហោតិ ។

ចំណែកចិត្តណា ដែលបុគ្គលនោះអប់រំហើយដោយសទ្ធា អប់រំហើយដោយសីលៈ សុតៈ ចាគៈ បញ្ញា អស់កាលដ៏យូរ ចិត្តនោះតែងអណ្តែតខ្ពស់ឡើង ដល់នូវភាពជាចិត្តវិសេស ។

(៤១០) បពិត្រព្រះមហានាម ដូចបុរសចុះទៅកាន់អន្លង់ទឹកដ៏ជ្រៅ ហើយវាយបំបែកនូវឆ្នាំងសប្បិ ឬឆ្នាំងប្រេង ក្រួសឬអំបែងឯណាដែលមានក្នុងឆ្នាំងនោះ ក្រួសឬអំបែងនោះ តែងលិចចុះក្រោម ចំណែកសប្បិឬប្រេងឯណាដែលមានក្នុងឆ្នាំងនោះ សប្បិឬប្រេងនោះតែងអណ្តែតឡើងលើ ដល់នូវភាពជាវត្ថុវិសេសដូចម្តេចមិញ ។ បពិត្រព្រះមហានាម ចិត្តដែលបុគ្គលណាមួយ បានអប់រំហើយដោយសទ្ធា អប់រំហើយដោយសីលៈសុតៈចាគៈ បញ្ញា អស់កាលដ៏យូរ ចំណែកកាយឯណារបស់បុគ្គលនោះ មានរូបជាទីប្រជុំនៃមហាភូតទាំង៤កើតមកអំពីមាតានិងបិតាចំរើនឡើងដោយបាយនិងនំកុម្មាស មានការមិនទៀង ការដុសលាង ការគក់ច្របាច់ ការបែកធ្លាយនិងការរាត់រាយទៅជាធម្មតា ក្អែកទាំង-ឡាយតែងចឹកស៊ីខ្លះ ត្មាតទាំងឡាយតែងចឹកស៊ីខ្លះ ត្រដក់ទាំងឡាយតែងចឹកស៊ីខ្លះ សុនខទាំងឡាយតែងទំពាស៊ីខ្លះ ចចកទាំងឡាយតែងទំពាស៊ីខ្លះ បាណកជាតទាំងឡាយផ្សេងៗ (សត្វតូចៗ មានដង្កូវជាដើម)

ខាទន្តិ យញ្ច ខ្វស្ស(១) ចិត្តំ ទីឃរត្តំ សទ្ធាបរិភាវិតំ សីលសុតចាគបញ្ញាបរិភាវិតំ តំ ឧទ្ធង្គាមិ ហោតិ វិសេសគាមិ ។ តុយ្ហំ ខោ បន មហានាម ទីឃរត្តំ សទ្ធាបរិភាវិតំ ចិត្តំ សីលសុតចាគបញ្ញាបរិភាវិតំ ចិត្តំ ។ មា ភាយិ មហានាម មា ភាយិ មហានាម អបាបកន្តេ មរណំ ភវិស្សតិ អបាបិកា កាល-កិរិយាតិ ។

(២១១) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សក្កេសុ វិហរតិ កបិលវត្ថុស្មឹ និគ្រោធារាមេ ។ អថខោ មហានាមោ សក្កោ យេន ភគវា តេនុ-បសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ មហានាមោ សក្កោ ភគវន្តំ ឯតទវោច ឥទំ ភន្តេ កបិលវត្ថុ ឥទ្ធញ្ចេវ ផីតញ្ច ពាហុជញ្ញំ អាកិណ្ណមនុស្សំ សម្ពាធ-វ្យូហំ ។ សោ ខ្វាហំ ភន្តេ ភគវន្តំ វា បយិរុបាសិត្វា

---

១ឱ ខ្វស្ស ត់ ។

តែងទោមកោមផញ្ញក់ស៊ុខ្ទះនូវកាយនោះឯង ចំណែកចិត្តណា ដែលបុគ្គល នោះអប់រំហើយ ដោយសទ្ធា អប់រំហើយដោយសីលៈ សុតៈ ចាគៈ បញ្ញា អស់កាលដ៏យូរ ចិត្តនោះតែងអណ្តែតឡើង ដល់នូវភាពជាចិត្តវិសេស មានឧបមេយ្យដូច្នោះឯង ។ បពិត្រព្រះមហានាម ចិត្តដែលព្រះអង្គបាន អប់រំហើយដោយសទ្ធា អប់រំហើយដោយសីលៈ សុតៈ ចាគៈ បញ្ញា អស់ កាលដ៏យូរ ។ បពិត្រព្រះមហានាម ព្រះអង្គកុំខ្លាចឡើយ បពិត្រព្រះ មហានាម ព្រះអង្គកុំខ្លាចឡើយ មរណភាពរបស់ព្រះអង្គ មុខជាមិន ថយថោកឡើយ កាលកិរិយារបស់ព្រះអង្គ មុខជាមិនថយថោកឡើយ ។

[២១១] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះដ៏មាន ព្រះភាគ ទ្រង់គង់នៅក្នុងនិគ្រោធារាម ជិតក្រុងកបិលព័ស្តុ ក្នុងដែន សក្កៈ ។ គ្រានោះឯង ព្រះមហានាមសក្យរាជ ចូលទៅគាល់ព្រះ ដ៏មានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយគង់ ក្នុងទីដ៏សមគួរ ។ លុះព្រះមហានាមសក្យរាជ គង់ក្នុងទីដ៏សមគួរ ហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គ ដ៏ចំរើន នគរកបិលព័ស្តុនេះ ជានគរស្តុកស្តម្ភធំទូលាយ មានមនុស្ស ច្រើន មានមនុស្សកុះករ មានច្រកបង្អៀតដ៏ច្រើន ។ បពិត្រព្រះអង្គ ដ៏ចំរើន ខ្ញុំព្រះអង្គនោះឯង បានចូលមកអង្គុយជិតព្រះដ៏មានព្រះភាគផង

មនោភាវនីយេ វា ភិក្ខូ សាយណ្ហសមយំ កបិលវត្ថុំ បវិសន្តោ ភន្តេនបិ ហត្ថិនា សមាគច្ឆាមិ ភន្តេនបិ អស្សេន សមាគច្ឆាមិ ភន្តេនបិ រថេន សមាគច្ឆាមិ ភន្តេនបិ សកដេន សមាគច្ឆាមិ ភន្តេនបិ បុរិសេន សមាគច្ឆាមិ ។ តស្ស មយ្ហំ ភន្តេ តស្មឹ សមយេ មុស្សតេវ ភគវន្តំ អារព្ភ សតិ ។ មុស្សតិ ធម្មំ អារព្ភ សតិ មុស្សតិ សង្ឃំ អារព្ភ សតិ ។ តស្ស មយ្ហំ ភន្តេ ឯវំ ហោតិ ឥមម្ហិ ចាហំ សមយេ កាលំ ករេយ្យំ កា មយ្ហំ គតិ កោ អភិសម្បរាយោតិ ។

(២១២) មា ភាយិ មហានាម មា ភាយិ មហានាម អបាបកន្តេ មរណំ ភវិស្សតិ អបាបិកា កាលកិរិយា ។ ចតូហិ ខោ មហានាម ធម្មេហិ សមន្នាគតោ អរិយសាវកោ និព្វាននិន្នោ ហោតិ និព្វានបោណោ និព្វានបព្ភារោ ។ កតមេហិ ចតូហិ ។ ឥធ មហានាម អរិយសាវកោ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ ឥតិបិ សោ ភគវា ។ បេ ។ សត្ថា ទេវមនុស្សានំ

បានចូលមកអង្គុយជិតភិក្ខុទាំងឡាយដែលគួរជាទីចំរើនចិត្តផង ហើយចូលទៅនគរកបិលព័ស្តុ ក្នុងវេលាល្ងាចវិញ តែងទៅដោយដំរីលឿនក៏មាន ទៅដោយសេះលឿនក៏មាន ទៅដោយរថលឿនក៏មាន ទៅដោយរទេះលឿនក៏មាន ទៅដោយបុរសលឿនក៏មាន ។ បពិត្រព្រះអង្គដ៏ចំរើន ក្នុងពេលនោះ សតិរបស់ខ្ញុំព្រះអង្គ ប្រារព្ធព្រះដ៏មានព្រះភាគ ក៏ភ្លេចបាត់ទៅ សតិប្រារព្ធព្រះធម៌ក៏ភ្លេចបាត់ទៅ សតិប្រារព្ធព្រះសង្ឃក៏ភ្លេចបាត់ទៅ ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ប្រសិនបើអញធ្វើមរណកាលក្នុងសម័យនេះ គតិរបស់អញដូចម្តេចទៅ អភិសម្បរាយភពរបស់អញដូចម្តេចទៅ ។

[២១២] បពិត្រព្រះមហានាម ព្រះអង្គកុំខ្លាចឡើយ បពិត្រព្រះមហានាម ព្រះអង្គកុំខ្លាចឡើយ មរណភាពរបស់ព្រះអង្គ មុខជាមិនថយថោកទេ កាលកិរិយារបស់ព្រះអង្គ មុខជាមិនថយថោកទេ ។ បពិត្រព្រះមហានាម អរិយសាវក ប្រកបដោយធម៌ ៤ យ៉ាង តែងបង្អោនទៅរកព្រះនិព្វាន ជម្រាលទៅរកព្រះនិព្វាន ឈមទៅរកព្រះនិព្វាន ។ ធម៌ ៤ យ៉ាងគឺអ្វីខ្លះ ។ បពិត្រព្រះមហានាម អរិយសាវកក្នុងធម្មវិន័យនេះ ប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគអង្គនោះ ។ បេ ។ ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ

ពុទ្ធោ ភគវតិ ។ ធម្មេ ។ សង្ឃេ ។ អរិយកន្តេហិ សីលេហិ សមន្នាគតោ ហោតិ អខណ្ឌេហិ ។បេ។ សមាធិសំវត្តនិកេហិ ។

(២១៣) សេយ្យថាបិ មហានាម រុក្ខោ បាចីននិន្នោ បាចីនបោណោ បាចីនបព្ភារោ សោ មូលេ ឆិន្នេ កតមេន បបតេយ្យាតិ ។ យេន ភន្តេ និន្នោ យេន បោណោ យេន បព្ភារោតិ ។ ឯវមេវ ខោ មហានាម ឥមេហិ ចតូហិ ធម្មេហិ សមន្នាគតោ អរិយសាវកោ និព្វាននិន្នោ ហោតិ និព្វានបោណោ និព្វានបព្ភារោតិ ។

(២១៤) កាបិលវត្ថុនិទានំ ។ អថខោ មហានាមោ សក្កោ យេន គោធា សក្កោ តេនុបសង្កមិ ឧបសង្កមិត្វា គោធំ សក្កំ ឯតទវោច

ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់កពថ្មីទៀត ។ (អរិយសាវកប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ) ក្នុងព្រះធម៌ ។ ក្នុងព្រះសង្ឃ ។ ប្រកបដោយសីលទាំងឡាយ ជាទីស្រឡាញ់របស់អរិយៈ ជាសីលមិនដាច់ ។បេ។ ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ ។

[២១៣] បពិត្រព្រះមហានាម ដូចដើមឈើតែងទេរទៅកាន់ទិសខាងកើត ទោរទៅកាន់ទិសខាងកើត ទ្រេតទៅកាន់ទិសខាងកើត ឈើនោះ កាលបើឫសដាច់ហើយ តើគប្បីដួលទៅទិសខាងណា ។ ព្រះមហានាមសក្យរាជក្រាបទូលថា បពិត្រព្រះអង្គ ឈើនោះទេរទៅខាងណា ទោរទៅខាងណា ទ្រេតទៅខាងណា (គប្បីដួលទៅខាងនោះ) ។ ព្រះដ៏មានព្រះភាគត្រាស់ថា បពិត្រព្រះមហានាម អរិយសាវក ប្រកបដោយធម៌ទាំង ៤ យ៉ាងនេះ រមែងបង្អោនទៅរកព្រះនិព្វាន ជម្រាលទៅរកព្រះនិព្វាន ឈមទៅរកព្រះនិព្វានក៏ដូច្នោះឯង ។

[២១៤] កបិលវត្ថុនិទាន ។ គ្រានោះឯង ព្រះមហានាមសក្យរាជចូលទៅរកព្រះគោធាសក្យរាជ លុះចូលទៅដល់ហើយ ទូលព្រះគោធាសក្យរាជដូច្នេះថា

## សរកានិវគ្គោ តតិយោ

[២១៥] កតីហិ នុ ខោ ធម្មេហិ សមន្នាគតំ សោតាបន្នំ បុគ្គលំ អាជានាសិ អវិនិបាតធម្មំ និយតំ សម្ពោធិបរាយនន្តិ ។ តីហិ ខ្វាហំ មហានាម ធម្មេហិ សមន្នាគតំ សោតាបន្នំ បុគ្គលំ អាជានាមិ អវិនិបាតធម្មំ និយតំ សម្ពោធិបរាយនំ ។ កតមេហិ តីហិ ។ ឥធ មហានាម អរិយសាវកោ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ ឥតិបិ សោ ភគវា ។បេ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ធម្មេ ។ សង្ឃេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ។បេ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។ ឥមេហិ ខ្វាហំ មហានាម តីហិ ធម្មេហិ សមន្នាគតំ សោតាបន្នំ បុគ្គលំ អាជានាមិ អវិនិបាតធម្មំ និយតំ សម្ពោធិបរាយនំ ។

## សរកានិវគ្គទី ៣

(២១៥) បពិត្រព្រះគោធា ព្រះអង្គបានជ្រាបបុគ្គលដែលជាសោតាបន្នៈ ប្រកបដោយធម៌ប៉ុន្មានយ៉ាង ទើបជាបុគ្គលមានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ។ ព្រះគោធាសក្យរាជទូលថា បពិត្រព្រះមហានាម ខ្ញុំដឹងច្បាស់នូវបុគ្គលដែលជាសោតាបន្នៈ ប្រកបដោយធម៌ទាំង៣ យ៉ាង ទើបជាបុគ្គលមានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ។ ធម៌ទាំង៣ យ៉ាងដូចម្តេចខ្លះ ។ បពិត្រព្រះមហានាម អរិយសាវកក្នុងធម្មវិន័យនេះ ប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគអង្គនោះ ។បេ។ ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀត ។ (អរិយសាវកប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ) ក្នុងព្រះធម៌ ។ ប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រក្នុងព្រះសង្ឃថា ព្រះសង្ឃសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិល្អហើយ ។បេ។ ជាស្រែបុណ្យដ៏ប្រសើរនៃសត្វលោក ។ បពិត្រព្រះមហានាម ខ្ញុំដឹងច្បាស់នូវបុគ្គលដែលជាសោតាបន្នៈ ប្រកបដោយធម៌ទាំង ៣ យ៉ាងនេះឯង ទើបជាបុគ្គល មានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ។

[៦១៦] ត្វំ បន មហានាម កតីហិ ធម្មេហិ សមន្នាគតំ សោតាបន្នំ បុគ្គលំ អាជានាសិ អវិនិបាត-ធម្មំ និយតំ សម្ពោធិបរាយនន្តិ ។ ចតូហិ ខ្វាហំ (១) ភន្តេ ធម្មេហិ សមន្នាគតំ សោតាបន្នំ បុគ្គលំ អាជានាមិ អវិនិបាតធម្មំ និយតំ សម្ពោធិបរាយនំ ។ កតមេហិ ចតូហិ ។ ឥធ ភន្តេ អរិយសាវកោ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ ឥតិបិ សោ ភគវា ។បេ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ធម្មេ ។ សង្ឃេ ។ អរិយកន្តេហិ សីលេហិ សមន្នា-គតោ ហោតិ អខណ្ឌេហិ ។បេ។ សមាធិសំវត្តនិកេ-ហិ ។ ឥមេហិ ខ្វាហំ ភន្តេ ចតូហិ ធម្មេហិ សមន្នា-គតំ សោតាបន្នំ បុគ្គលំ អាជានាមិ អវិនិបាតធម្មំ និយតំ សម្ពោធិបរាយនន្តិ ។

---

១ ឱ. ឯត្ថន្តរេ ភោតិតិបិ សទ្ទោ អត្ថិ ។

[៤១៦] ព្រះគោធាសក្យរាជទូលព្រះមហានាមវិញថា បពិត្រព្រះមហានាម ចុះព្រះអង្គបានជ្រាបបុគ្គលដែលជាសោតាបន្ន: ប្រកបដោយធម៌ប៉ុន្មានយ៉ាង ទើបជាបុគ្គលមានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង ជាបុគ្គលមានការត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ៗ ព្រះមហានាមសក្យរាជទូលតបវិញថា បពិត្រព្រះគោធា ខ្ញុំដឹងច្បាស់នូវបុគ្គលដែលជាសោតាបន្ន: ប្រកបដោយធម៌៤យ៉ាង ទើបជាបុគ្គលមានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង ជាបុគ្គលមានការត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ៗ ធម៌៤យ៉ាងដូចម្តេចខ្លះ ៗ បពិត្រព្រះគោធា អរិយសាវកក្នុងធម្មវិន័យនេះ ប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគអង្គនោះ ។បេ។ ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀតហើយ ។ (អរិយសាវកប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ) ក្នុងព្រះធម៌ ។ ក្នុងព្រះសង្ឃ ។ អរិយសាវកប្រកបដោយសីលជាទីស្រឡាញ់របស់អរិយ: ជាសីលមិនដាច់ ។បេ។ ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ ។ បពិត្រព្រះគោធា ខ្ញុំដឹងច្បាស់នូវបុគ្គលដែលជាសោតាបន្ន: ប្រកបដោយធម៌ ៤ យ៉ាងនេះឯង ទើបជាបុគ្គលមានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង ជាបុគ្គលមានការត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ។

(២១៧) អាគមេហិ ត្វំ មហានាម អាគមេហិ ត្វំ មហានាម ភគវា វ ឯវំ ជានេយ្យ ឯតេហិ ធម្មេហិ សមន្នាគតំ វា អសមន្នាគតំ វាតិ ។ អាយាម គោធ យេន ភគវា តេនុបសង្កមេយ្យាម ឧបសង្កមិត្វា ភគវតោ ឯតមត្ថំ អារោចេស្សាមាតិ ។

(២១៨) អថខោ មហានាមោ ច សក្កោ គោធា ច សក្កោ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នោ ខោ មហានាមោ សក្កោ ភគវន្តំ ឯតទវោច ឥធាហំ ភន្តេ យេន គោធា សក្កោ តេនុបសង្កមឹ ឧបសង្កមិត្វា គោធំ សក្កំ ឯតទវោចំ កតីហិ ត្វំ គោធ ធម្មេហិ សមន្នាគតំ សោតាបន្នំ បុគ្គលំ អាជានាសិ អវិនិបាតធម្មំ និយតំ សម្ពោធិបរាយនន្តិ ។

## សរកានិវគ្គទី ៣

(២១៧) ព្រះគោធាសក្យរាជទូលព្រះមហានាមថា បពិត្រព្រះមហានាម សូមព្រះអង្គរង់ចាំសិន បពិត្រព្រះមហានាម សូមព្រះអង្គរង់ចាំសិន មានតែព្រះដ៏មានព្រះភាគមួយអង្គប៉ុណ្ណោះ ទើបទ្រង់ជ្រាបនូវបុគ្គលដែលជាសោតាបន្នៈនុ៎ះ ប្រកបឬមិនប្រកបដោយធម៌ទាំងឡាយនេះបាន ៗ ព្រះមហានាមទូលព្រះគោធាសក្យរាជវិញថា បពិត្រព្រះគោធា មកយើងនាំគ្នាទៅ យើងគួរចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ នឹងក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ៗ

(២១៨) គ្រានោះឯង ព្រះមហានាមសក្យរាជនឹងព្រះគោធាសក្យរាជ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ ទើបគង់ក្នុងទីដ៏សមគួរ ៗ លុះព្រះមហានាមសក្យរាជ គង់ក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន អម្បាញ់មិញនេះ ខ្ញុំបានចូលទៅរកព្រះគោធាសក្យរាជ លុះចូលទៅដល់ ទូលព្រះគោធាសក្យរាជដូច្នេះថា បពិត្រព្រះគោធា ព្រះអង្គបានជ្រាបនូវបុគ្គលដែលជាសោតាបន្នៈ ប្រកបដោយធម៌ប៉ុន្មានយ៉ាង ទើបជាបុគ្គលមានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ៗ

(២១៩) ឯវំ វុត្តេ ភន្តេ គោធា សក្កោ មំ ឯតទវោច តីហិ ខ្វាហំ មហានាម ធម្មេហិ សមន្នាគតំ សោតាបន្នំ បុគ្គលំ អាជានាមិ អវិនិបាតធម្មំ និយតំ សម្ពោធិបរាយនំ ។ កតមេហិ តីហិ ។ ឥធ មហានាម អរិយសាវកោ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ ឥតិបិ សោ ភគវា ។ បេ ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ធម្មេ ។ សង្ឃេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ។ បេ ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។ ឥមេហិ ខ្វាហំ មហានាម តីហិ ធម្មេហិ សមន្នាគតំ សោតាបន្នំ បុគ្គលំ អាជានាមិ អវិនិបាតធម្មំ និយតំ សម្ពោធិបរាយនំ ។

(២១៩) បពិត្រព្រះអង្គដ៏ចំរើន កាលខ្ញុំទូលយ៉ាងនេះហើយ ព្រះគោធាសក្យរាជបានឆ្លើយមកខ្ញុំព្រះអង្គវិញដូច្នេះថា បពិត្រព្រះមហានាម ខ្ញុំបានដឹងនូវបុគ្គលដែលជាសោតាបន្នៈ ប្រកបដោយធម៌ ៣ យ៉ាង ជាអ្នកមានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ។ ធម៌ ៣ យ៉ាង ដូចម្តេចខ្លះ ។ បពិត្រព្រះមហានាម អរិយសាវកក្នុងធម្មវិន័យនេះ ជាអ្នកប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគអង្គនោះ ។ បេ ។ ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលមកកាន់កំណើតទៀតហើយ ។ (អរិយសាវកប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ) ក្នុងព្រះធម៌ ។ ប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះសង្ឃថា ព្រះសង្ឃសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិល្អហើយ ។ បេ ។ ជាស្រែបុណ្យដ៏ប្រសើរនៃសត្វលោក ។ បពិត្រព្រះមហានាម ខ្ញុំដឹងច្បាស់នូវបុគ្គលដែលជាសោតាបន្នៈប្រកបដោយធម៌ទាំង ៣ យ៉ាងនេះឯង ទើបជាបុគ្គលមានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ។

## សរកានិវគ្គោ តតិយោ

ត្វំ បន មហានាម កតីហិ ធម្មេហិ សមន្នាគតំ សោតាបន្នំ បុគ្គលំ អាជានាសិ អវិនិបាតធម្មំ និយតំ សម្ពោធិបរាយនន្តិ ។

[២២០] ឯវំ វុត្តាហំ ភន្តេ គោធំ សក្កំ ឯតទវោចំ ចតូហិ ខ្វាហំ គោធ ធម្មេហិ សមន្នាគតំ សោតាបន្នំ បុគ្គលំ អាជានាមិ អវិនិបាតធម្មំ និយតំ សម្ពោធិបរាយនំ ។ កតមេហិ ចតូហិ ។ ឥធ គោធ អរិយសាវកោ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ ឥតិបិ សោ ភគវា ។បេ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ធម្មេ ។ សង្ឃេ ។ អរិយកន្តេហិ សីលេហិ សមន្នាគតោ ហោតិ អខណ្ឌេហិ ។បេ។

បពិត្រព្រះមហានាម ចុះព្រះអង្គ ជ្រាបច្បាស់នូវបុគ្គលដែលជាសោតាបន្នៈប្រកបដោយធម៌ប៉ុន្មានយ៉ាង ទើបជាបុគ្គល មានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ។

(៧២០) ព្រះមហានាមសក្យរាជ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន កាលព្រះគោធាសក្យរាជពោលយ៉ាងនេះហើយ ខ្ញុំព្រះអង្គបានទូលព្រះគោធាសក្យរាជដូច្នេះថា បពិត្រព្រះគោធា ខ្ញុំដឹងច្បាស់នូវបុគ្គលដែលជាសោតាបន្នៈប្រកបដោយធម៌៤ យ៉ាង ទើបជាបុគ្គលមានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ។ ធម៌៤ យ៉ាង ដូចម្តេចខ្លះ ។ បពិត្រព្រះគោធា អរិយសាវកក្នុងធម្មវិន័យនេះ ប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគអង្គនោះ ។ បេ ។ ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀតហើយ ។ (អរិយសាវកប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ) ក្នុងព្រះធម៌ ។ ក្នុងព្រះសង្ឃ ។ ជាអ្នកប្រកបដោយសីល ជាទីស្រឡាញ់របស់អរិយៈ ជាសីលមិនដាច់ ។ បេ ។

សមាធិសំវត្តនិកោ ហិ ។ ឥមេហិ ខ្វាហំ គោធេ ចតូហិ ធម្មេហិ សមន្នាគតំ សោតាបន្នំ បុគ្គលំ អាជានាមិ អវិនិបាតធម្មំ និយតំ សម្ពោធិបរាយនន្តិ ។

(២២១) ឯវំ វុត្តេ ភន្តេ គោធា សក្កោ មំ ឯតទវោច អាគមេហិ ត្វំ មហានាម អាគមេហិ ត្វំ មហានាម ភគវា វ ឯតំ ជានេយ្យ ឯតេហិ ធម្មេហិ សមន្នាគតំ វា អសមន្នាគតំ វាតិ ។

(២២២) ឥធ ភន្តេ កោចិទេវ ធម្មសមុប្បាទោ ឧប្បជ្ជេយ្យ ឯកតោ អស្ស ភគវា ឯកតោ ភិក្ខុសង្ឃោ ច យេនេវ ភគវា តេនេវាហំ អស្សំ (១) ឯវំ បសន្នំ មំ ភន្តេ ភគវា ធារេតុ ។

---

១ ម. អយំ

ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ ។ បពិត្រព្រះគោធា ខ្ញុំដឹងច្បាស់នូវបុគ្គលដែលជាសោតាបន្នៈប្រកបដោយធម៌ ៤ យ៉ាងនេះឯង ទើបជាបុគ្គលមានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ។

(៤២១) បពិត្រព្រះអង្គដ៏ចំរើន កាលខ្ញុំព្រះអង្គពោលយ៉ាងនេះហើយ ព្រះគោធាសក្យរាជបានឆ្លើយមកខ្ញុំព្រះអង្គវិញដូច្នេះថា បពិត្រព្រះមហានាម សូមព្រះអង្គរង់ចាំសិន បពិត្រព្រះមហានាម សូមព្រះអង្គរង់ចាំសិន មានតែព្រះដ៏មានព្រះភាគមួយព្រះអង្គប៉ុណ្ណោះ ទើបទ្រង់ជ្រាបនូវបុគ្គលដែលជាសោតាបន្នៈនុ៎ះ ប្រកបឬមិនប្រកបដោយធម៌ទាំងអម្បាលនេះបាន ។

(៤២២) បពិត្រព្រះអង្គដ៏ចំរើន ការកើតឡើងនៃធម៌ណាមួយគប្បីកើតឡើងក្នុងធម្មវិន័យនេះ ព្រះដ៏មានព្រះភាគ គប្បីមូលជាមួយគ្នា ទាំងភិក្ខុសង្ឃ ក៏គប្បីមូលជាមួយគ្នា ព្រះដ៏មានព្រះភាគព្រះអង្គត្រាស់ព្រះវាចាឯណា ខ្ញុំព្រះអង្គក៏ប្រកាន់តាមព្រះវាចានោះ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគ ទ្រង់ចាំទុកនូវខ្ញុំព្រះអង្គដែលជាអ្នកជ្រះថ្លាយ៉ាងនេះចុះ ។

## សរកានិវគ្គោ តតិយោ

[៤២៣] ឥធ ភន្តេ កោចិទេវ ធម្មសមុប្បាទោ ឧប្បជ្ជេយ្យ ឯកតោ អស្សុ(១) ភគវា ឯកតោ ភិក្ខុសង្ឃោ ភិក្ខុនីសង្ឃោ ច យេនេវ ភគវា តេនេវាហំ អស្សុំ(១) ឯវំ បសន្នំ មំ ភន្តេ ភគវា ធារេតុ ។

[៤២៤] ឥធ ភន្តេ កោចិទេវ ធម្មសមុប្បាទោ ឧប្បជ្ជេយ្យ ឯកតោ អស្សុ ភគវា ឯកតោ ភិក្ខុសង្ឃោ ភិក្ខុនីសង្ឃោ ឧបាសកា ច យេនេវ ភគវា តេនេវាហំ អស្សុំ ឯវំ បសន្នំ មំ ភន្តេ ភគវា ធារេតុ ។

[៤២៥] ឥធ ភន្តេ កោចិទេវ ធម្មសមុប្បាទោ ឧប្បជ្ជេយ្យ ឯកតោ អស្សុ ភគវា ឯកតោ ភិក្ខុសង្ឃោ ភិក្ខុនីសង្ឃោ ឧបាសកា ឧបាសិកាយោ ច

---

១ ម. អយំ ។

## សរកានិវត្តទី ៣

(៤៤៣) បពិត្រព្រះអង្គដ៏ចំរើន ការកើតឡើងនៃធម៌ណាមួយ គប្បីកើតឡើងក្នុងធម្មវិន័យនេះ ព្រះដ៏មានព្រះភាគ គប្បីមូលជាមួយគ្នា ទាំងភិក្ខុសង្ឃទាំងភិក្ខុនីសង្ឃ ក៏គប្បីមូលជាមួយគ្នា ព្រះដ៏មានព្រះភាគ ព្រះអង្គត្រាស់ព្រះវាចាឯណា ខ្ញុំព្រះអង្គ ក៏ប្រកាន់តាមព្រះវាចានោះ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគ ទ្រង់ចាំទុកនូវខ្ញុំព្រះអង្គ ជាអ្នកជ្រះថ្លាយ៉ាងនេះចុះ ។

(៤៤៤) បពិត្រព្រះអង្គដ៏ចំរើន ការកើតឡើងនៃធម៌ណាមួយគប្បីកើតឡើងក្នុងធម្មវិន័យនេះ ព្រះដ៏មានព្រះភាគ គប្បីមូលជាមួយគ្នា ទាំងភិក្ខុសង្ឃទាំងភិក្ខុនីសង្ឃទាំងពួកឧបាសក ក៏គប្បីមូលជាមួយគ្នា ព្រះដ៏មានព្រះភាគ ព្រះអង្គត្រាស់ព្រះវាចាឯណា ខ្ញុំព្រះអង្គក៏ប្រកាន់តាមព្រះវាចានោះ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគ ទ្រង់ចាំទុកនូវខ្ញុំព្រះអង្គជាអ្នកជ្រះថ្លាយ៉ាងនេះចុះ ។

(៤៤៥) បពិត្រព្រះអង្គដ៏ចំរើន ការកើតឡើងនៃធម៌ណាមួយ គប្បីកើតឡើងក្នុងធម្មវិន័យនេះ ព្រះដ៏មានព្រះភាគ ក៏គប្បីមូលជាមួយគ្នា ទាំងភិក្ខុសង្ឃភិក្ខុនីសង្ឃពួកឧបាសកនិងពួកឧបាសិកា ក៏គប្បីមូលជាមួយគ្នា

យេនេវ ភគវា តេនេវាហំ អស្ស ឯវំ បសន្នំ មំ ភន្តេ ភគវា ធារេតុ ។

(២២៦) ឥធ ភន្តេ កោចិទេវ ធម្មសមុប្បាទោ ឧប្បជ្ជេយ្យ ឯកតោ អស្ស ភគវា ឯកតោ ភិក្ខុសង្ឃោ ភិក្ខុនីសង្ឃោ ឧបាសកា ឧបាសិកាយោ សទេវកោ ច លោកោ សមារកោ សព្រហ្មកោ សស្សមណព្រាហ្មណី បជា សទេវមនុស្សា យេនេវ ភគវា តេនេវាហំ អស្សំ ឯវំ បសន្នំ មំ ភន្តេ ភគវា ធារេតូតិ ។

(២២៧) ឯវំវាទី(១) ត្វំ គោធ មហានាមំ សក្កំ កឹ វទេសីតិ ។ ឯវំវាទាហំ ភន្តេ មហានាមំ សក្កំ ន កិញ្ចិ វទាមិ អញ្ញត្រ កល្យាណា អញ្ញត្រ កុសលាតិ ។

---

១ ឱ. ឯវំភទី ។

ព្រះដ៏មានព្រះភាគព្រះអង្គត្រាស់ព្រះវាចាឯណា ខ្ញុំព្រះអង្គក៏ប្រកាន់តាមព្រះវាចានោះ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគ ទ្រង់ចាំទុកនូវខ្ញុំព្រះអង្គជាអ្នកជ្រះថ្លាយ៉ាងនេះចុះ ។

(២២៦) បពិត្រព្រះអង្គដ៏ចំរើន ការកើតឡើងនៃធម៌ណាមួយគប្បីកើតឡើងក្នុងធម្មវិន័យនេះ ព្រះដ៏មានព្រះភាគ ក៏គប្បីមូលជាមួយគ្នាចាំងពីភិក្ខុសង្ឃ ភិក្ខុនីសង្ឃ ពួកឧបាសក ឧបាសិកា និងមនុស្សលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក និងពពួកសត្វ ព្រមទាំងសមណៈ និងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ក៏គប្បីមូលជាមួយគ្នា ព្រះដ៏មានព្រះភាគ ព្រះអង្គត្រាស់ព្រះវាចាឯណា ខ្ញុំព្រះអង្គក៏ប្រកាន់តាមព្រះវាចានោះ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគទ្រង់ចាំទុកនូវខ្ញុំព្រះអង្គជាអ្នកជ្រះថ្លាយ៉ាងនេះចុះ ។

(២២៧) ព្រះដ៏មានព្រះភាគត្រាស់ថា បពិត្រព្រះគោធា ព្រះអង្គមានវាទៈយ៉ាងនេះហើយ ចុះមានព្រះបន្ទូលដូចម្ដេចទៅនឹងព្រះមហានាមសក្យរាជទៀត ។ ព្រះគោធាសក្យរាជក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមានវាទៈយ៉ាងនេះហើយ ក្រៅអំពីកល្យាណធម៌ និងកុសលធម៌ ឥតមានពោលពាក្យអ្វីនឹងព្រះមហានាមសក្យរាជទេ ។

## សរកានិវគ្គោ តតិយោ

(២២៨) កាបិលវត្ថុនិទានំ ។ តេន ខោ បន សមយេន សរកានិ(១) សក្កោ កាលកតោ ហោតិ ភគវតា ព្យាកតោ សោតាបន្នោ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយនោតិ ។ តត្រ សុទំ សម្ពហុលា សក្កា សង្គម្ម សមាគម្ម ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ ឯត្ថទានិ កោ ន សោតាបន្នោ ភវិស្សតិ យត្រ ហិ នាម សរកានិ សក្កោ កាលកតោ ហោតិ ភគវតា ព្យាកតោ សោតាបន្នោ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយនោតិ ។ សរកានិ សក្កោ សិក្ខាទុព្ពល្យមាបាទិ មជ្ជបានំ អបាយីតិ ។

(២២៩) អថខោ មហានាមោ សក្កោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ

១ ម. សរណានិ ។

(២២៨) កបិលវត្ថុនិទាន ។ សម័យនោះឯង ព្រះសរកានិសក្យរាជ ទ្រង់ទិវង្គតទៅ ព្រះអង្គជាអ្នកដែលព្រះដ៏មានព្រះភាគទ្រង់ព្យាករហើយ ថា ជាសោតាបន្នបុគ្គល មានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ។ បានឮថាពួកសក្យរាជជាច្រើនអង្គ មកប្រជុំគ្នាក្នុងទីនោះហើយ តោលទោស តិះដៀល បន្តុះបង្អាប់ថា អើហ្ន៎ អស្ចារ្យណាស់តើ អើហ្ន៎ មិនដែលកើតមានទេតើ បើយ៉ាងហ្នឹង នរណានឹងមិនបានជាសោតាបន្នបុគ្គល ក្នុងសាសនានេះ ព្រះសរកានិសក្យរាជ ដែលទ្រង់ទិវង្គតទៅហើយនោះ មិនសមបើព្រះដ៏មានព្រះភាគ ទ្រង់ព្យាករថា ជាសោតាបន្នបុគ្គល មានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខសោះ ។ ដ្បិតព្រះសរកានិសក្យរាជ ដល់នូវភាពនៃខ្លួនជាអ្នកមានកំឡាំងខ្សោយដោយសិក្ខា អ្នកក្រេបផឹកនូវទឹកស្រវឹង ។

(២២៩) គ្រានោះឯង ព្រះមហានាមសក្យរាជ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ គង់ក្នុងទីដ៏សមគួរ ។ លុះព្រះមហានាមសក្យរាជ គង់ក្នុងទីដ៏សមគួរហើយ

មហានាមោ សក្កោ ភគវន្តំ ឯតទវោច ឥធ ភន្តេ សរកានិ សក្កោ កាលគតោ សោ ភគវតា ព្យាកតោ សោតាបន្នោ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយនោតិ ។ តត្រ សុទំ ភន្តេ សម្ពហុលា សក្កា សង្គម្ម សមាគម្ម ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ ឯត្ថទានិ កោ ន សោតាបន្នោ ភវិស្សតិ យត្រ ហិ នាម សរកានិ សក្កោ កាលកតោ សោ ភគវតា ព្យាកតោ សោតាបន្នោ អវិនិបាតធម្មោ និយតោ សម្ពោធិ-បរាយនោតិ ។ សរកានិ សក្កោ សិក្ខាទុព្វល្យ-មាបាទិ មជ្ជបានំ អបាយីតិ ។

(២៣០) យោ សោ មហានាម ទីឃរត្តំ ឧបា-សកោ ពុទ្ធំ សរណំ គតោ ធម្មំ សរណំ គតោ

ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន អម្បាញ់មិញនេះ ព្រះសរកានិសក្យរាជ ទ្រង់ទិវង្គតហើយ ព្រះអង្គជាអ្នក ដែលព្រះដ៏មានព្រះភាគទ្រង់ព្យាករថា ជាសោតាបន្នបុគ្គល មានសភាព មិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅក្នុង ខាងមុខ ៗ បពិត្រព្រះអង្គដ៏ចំរើន បានឮថា ពួកសក្យរាជជាច្រើនអង្គ បានមកប្រជុំក្នុងទីនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា អើហ្ន៎ អស្ចារ្យណាស់តើ អើហ្ន៎ មិនដែលកើតមានទេតើ ឥឡូវនេះ ជនណា នឹងមិនបានជាសោតាបន្នបុគ្គល ក្នុងព្រះសាសនានេះ ព្រះសរកានិ- សក្យរាជ ដែលទ្រង់ទិវង្គតទៅហើយនោះ មិនសមបើព្រះដ៏មានព្រះភាគ ទ្រង់ព្យាករថា ជាសោតាបន្នបុគ្គល មានសភាពមិនធ្លាក់ចុះទៅក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខសោះ ៗ ព្រោះ ព្រះសរកានិសក្យរាជ បានដល់នូវភាពនៃខ្លួនជាអ្នកមានកំឡាំងខ្សោយ ដោយសិក្ខា អ្នកក្រេបផឹកនូវទឹកស្រវឹង ៗ

[២៣០] ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា បពិត្រព្រះមហានាម បុគ្គលណាជាឧបាសក ដល់នូវព្រះពុទ្ធជាទីពឹង ដល់នូវព្រះធម៌ជាទីពឹង

សង្ឃំ សរណំ គតោ សោ កថំ វិនិបាតំ គច្ឆេយ្យ ។ យញ្ហិ តំ មហានាម សម្មា វទមានោ វទេយ្យ ទីឃរត្តំ ឧបាសកោ ពុទ្ធំ សរណំ គតោ ធម្មំ សរណំ គតោ សង្ឃំ សរណំ គតោតិ ។ សរកានឹ សក្កំ សម្មា វទមានោ វទេយ្យ សរកានិ មហានាម សក្កោ ទីឃរត្តំ ឧបាសកោ ពុទ្ធំ សរណំ គតោ ធម្មំ សរណំ គតោ សង្ឃំ សរណំ គតោ សោ កថំ វិនិបាតំ គច្ឆេយ្យ ។

(២៣១) ឥធ មហានាម ឯកច្ចោ បុគ្គលោ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ ឥតិបិ សោ ភគវា ។បេ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ធម្មេ ។ សង្ឃេ ។ ហាសប្បញ្ញោ ជវនប្បញ្ញោ វិមុត្តិយា ច សមន្នាគតោ ។ សោ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។

ដល់នូវព្រះសង្ឃជាទីពឹង អស់រាត្រីវែង បុគ្គលនោះគប្បីទៅកាន់អបាយដូចម្ដេចបាន ។ បពិត្រព្រះមហានាម បុគ្គលកាលពោលចំពោះបុគ្គលដែលជាឧបាសកដល់នូវព្រះពុទ្ធជាទីពឹង ដល់នូវព្រះធម៌ជាទីពឹង ដល់នូវព្រះសង្ឃជាទីពឹង អស់រាត្រីវែង គប្បីពោលដោយប្រពៃ ។ បពិត្រព្រះមហានាម បុគ្គលកាលពោលអំពីព្រះសរកានិសក្យរាជ គប្បីពោលដោយប្រពៃថា ព្រះសរកានិសក្យរាជជាឧបាសក ដល់នូវព្រះពុទ្ធជាទីពឹង ដល់នូវព្រះធម៌ជាទីពឹង ដល់នូវព្រះសង្ឃជាទីពឹង អស់រាត្រីវែង គប្បីទៅកាន់អបាយដូចម្ដេចបាន ។

(២៣១) បពិត្រព្រះមហានាម បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកប្រកបដោយសេចក្ដីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគអង្គនោះ ។ បេ ។ ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀត ។ (ជាអ្នកប្រកបដោយសេចក្ដីជ្រះថ្លាមិនញាប់ញ័រ) ក្នុងព្រះធម៌ ។ ក្នុងព្រះសង្ឃ ។ ជាអ្នកមានបញ្ញាជាគ្រឿងរីករាយមានបញ្ញារាងរៃប្រកបដោយវិមុត្តិ ។ បុគ្គលនោះធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយបញ្ញាដ៏ក្រៃលែង ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន សម្រេចសម្រាន្តនៅ ។

អយម្បិ ខោ មហានាម បុគ្គលោ បរិមុត្តោ និរយា បរិមុត្តោ តិរច្ឆានយោនិយា បរិមុត្តោ បិត្តិវិសយា បរិមុត្តោ អបាយទុគ្គតិវិនិបាតា ។

[៦៣២] ឥធ បន មហានាម ឯកច្ចោ បុគ្គលោ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ ឥតិបិ សោ ភគវា ។ បេ ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ធម្មេ ។ សង្ឃេ ។ ហាសប្បញ្ញោ ជវនប្បញ្ញោ ន ច វិមុត្តិយា សមន្នាគតោ ។ សោ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឱបបាតិកោ ហោតិ តត្ថ បរិនិព្វាយី អនាវត្តិធម្មោ អស្មា លោកា ។ អយម្បិ ខោ មហានាម បុគ្គលោ បរិមុត្តោ និរយា បរិមុត្តោ តិរច្ឆានយោនិយា បរិមុត្តោ បិត្តិវិសយា បរិមុត្តោ អបាយទុគ្គតិវិនិបាតា ។

[៦៣៣] ឥធ បន មហានាម ឯកច្ចោ បុគ្គលោ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ

បពិត្រព្រះមហានាម បុគ្គលនេះឯង ឈ្មោះថារួចចាកនរក រួចចាកកំណើត តិរច្ឆាន រួចចាកប្រេតវិស័យ រួចចាកអបាយ ទុគ្គតិ វិនិបាត ។

(២៣២) បពិត្រព្រះមហានាម មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគអង្គនោះ ។ បេ ។ ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀត ។ (ជាអ្នកប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ) ក្នុងព្រះធម៌ ។ ក្នុងព្រះសង្ឃ ។ ជាអ្នកមានបញ្ញាជាគ្រឿងរីករាយ មានបញ្ញាវាងវៃ ប៉ុន្តែមិនប្រកបដោយវិមុត្តិ ។ បុគ្គលនោះមានសភាពជាឱបបាតិកសត្វ ហើយបរិនិព្វានក្នុងលោកនេះ មានសភាពមិនត្រឡប់ចាកលោកនោះ ព្រោះអស់សញ្ញោជនៈ ៥ ជាចំណែកខាងក្រោម ។ បពិត្រព្រះមហានាម បុគ្គលនេះឯង ឈ្មោះថារួចចាកនរក រួចចាកកំណើតតិរច្ឆាន រួចចាកប្រេតវិស័យ រួចចាកអបាយ ទុគ្គតិ វិនិបាត ។

(២៣៣) បពិត្រព្រះមហានាម មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធថា

ឥតិបិ សោ ភគវា ។ បេ ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ធម្មេ ។ សង្ឃេ ។ ន ហាសបញ្ញោ ន ជវនបញ្ញោ ន ច វិមុត្តិយា សមន្នាគតោ ។ សោ តិណ្ណំ សញ្ញោជនានំ បរិក្ខយា រាគទោសមោហានំ តនុត្តា សកទាគាមី ហោតិ សកិទេវ ឥមំ លោកំ អាគន្ត្វា ទុក្ខស្សន្តំ ករោតិ ។ អយម្បិ ខោ មហានាម បុគ្គលោ បរិមុត្តោ និរយា បរិមុត្តោ តិរច្ឆានយោនិយា បរិមុត្តោ បិត្តិវិសយា បរិមុត្តោ អបាយទុគ្គតិវិនិបាតា ។

[២៣៤] ឥធ បន មហានាម ឯកច្ចោ បុគ្គលោ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ ឥតិបិ សោ ភគវា ។ បេ ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ធម្មេ ។ សង្ឃេ ។ ន ហាសបញ្ញោ ន ជវនបញ្ញោ ន ច វិមុត្តិយា សមន្នាគតោ ។ សោ តិណ្ណំ សញ្ញោជនានំ បរិក្ខយា សោតាបន្នោ ហោតិ អវិនិបាតធម្មោ និយតោ

ព្រះដ៏មានព្រះភាគអង្គនោះ ។បេ។ ព្រះអង្គជាគ្រូនៃទេវតានឹងមនុស្ស ទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀត ។ (ជាអ្នកប្រកបដោយសេចក្ដីជ្រះថ្លាមិនញាប់ញ័រ) ក្នុងព្រះធម៌ ។ ក្នុងព្រះសង្ឃ ។ ប៉ុន្តែមិនមានបញ្ញាជាគ្រឿងរីករាយ មិនមានបញ្ញារាងវៃ នឹងមិនប្រកបដោយវិមុត្តិ ។ បុគ្គលនោះ ជាសកទាគាមី នឹងមកកាន់លោកនេះម្ដងទៀត ហើយធ្វើនូវទីបំផុតនៃទុក្ខ ព្រោះអស់សញ្ញោជនៈ៣ប្រការ ព្រោះធ្វើរាគៈ ទោសៈ មោហៈ ឲ្យស្រាលស្តើង ។ បពិត្រព្រះមហានាម បុគ្គលនេះឯង ឈ្មោះថារួចចាកនរក រួចចាកកំណើតតិរច្ឆាន រួចចាកប្រេតវិស័យ រួចចាកអបាយ ទុគ្គតិ វិនិបាត ។

(៤៣៤) បពិត្រព្រះមហានាម មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកប្រកបដោយសេចក្ដីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគអង្គនោះ ។បេ។ ព្រះអង្គជាគ្រូនៃទេវតានឹងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀត ។ (ជាអ្នកប្រកបដោយសេចក្ដីជ្រះថ្លាមិនញាប់ញ័រ) ក្នុងព្រះធម៌ ។ ក្នុងព្រះសង្ឃ ។ ប៉ុន្តែមិនមានបញ្ញាជាគ្រឿងរីករាយ មិនមានបញ្ញារាងវៃ នឹងមិនប្រកបដោយវិមុត្តិ ។ បុគ្គលនោះជាសោតាបន្នបុគ្គល មានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង

សម្ពោធិបរាយណោ ។ អយម្បិ ខោ មហានាម បុគ្គលោ បរិមុត្តោ និរយា បរិមុត្តោ តិរច្ឆានយោនិយា បរិមុត្តោ បិត្តិវិសយា បរិមុត្តោ អបាយទុគ្គតិវិនិបាតា ។

(២៣៥) ឥធ បន មហានាម ឯកច្ចោ បុគ្គលោ ន ហេវ ខោ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ ។ ន ធម្មេ ។ ន សង្ឃេ ។ ន ហាសប្បញ្ញោ ន ជវនប្បញ្ញោ ន ច វិមុត្តិយា សមន្នាគតោ ។ អបិចស្ស ឥមេ ធម្មា ហោន្តិ សទ្ធិន្ទ្រិយំ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ ។ តថាគតប្ប-វេទិតា ចស្ស ធម្មា បញ្ញាយ មត្តសោ និជ្ឈានំ ខមន្តិ ។ អយម្បិ ខោ មហានាម បុគ្គលោ អគន្តា និរយំ អគន្តា តិរច្ឆានយោនឹ អគន្តា បិត្តិវិសយំ អគន្តា អបាយទុគ្គតិវិនិបាតំ ។

(២៣៦) ឥធ បន មហានាម ឯកច្ចោ បុគ្គលោ ន ហេវ ខោ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ ។ ន ធម្មេ ។ ន សង្ឃេ ។ ន ហាសប្បញ្ញោ

មានការត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ព្រោះអស់សញ្ញោជនៈ ៣ ប្រការ ។ បពិត្រព្រះមហានាម បុគ្គលនេះឯង ជាអ្នក រួចចាកនរក រួចចាកតិរច្ឆាន រួចចាកប្រេតវិស័យ រួចចាកអបាយ ទុគ្គតិ វិនិបាត ។

[២៣៥] បពិត្រព្រះមហានាម មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះមិនបានប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធទេ ។ ក្នុងព្រះធម៌ទេ ។ ក្នុងព្រះសង្ឃទេ ។ មិនមានបញ្ញាជាគ្រឿងរីករាយទេ មិនមានបញ្ញារហ័សទេ មិនប្រកបដោយវិមុត្តិទេ ។ តែថា ធម៌អម្បាលនេះ គឺសទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ តែងមានដល់បុគ្គលនោះ ។ មួយទៀត ធម៌ទាំងឡាយ ដែលព្រះតថាគតទ្រង់ប្រកាសហើយ តែងសមគួរដល់ការពិចារណា ដោយបញ្ញារបស់បុគ្គលនោះដោយក្រៃពេក ។ បពិត្រព្រះមហានាម បុគ្គលនេះឯង ជាអ្នក មិនទៅកាន់នរក មិនទៅកាន់កំណើតតិរច្ឆាន មិនទៅកាន់ប្រេតវិស័យ មិនទៅកាន់អបាយ ទុគ្គតិ វិនិបាត ។

[២៣៦] បពិត្រព្រះមហានាម មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះមិនបានប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធទេ ។ ក្នុងព្រះធម៌ទេ ។ ក្នុងព្រះសង្ឃទេ ។ មិនមានបញ្ញាជាគ្រឿងរីករាយទេ

## សរកានិវគ្គោ តតិយោ

ន ជវនបញ្ញោ ន ច វិមុត្តិយា សមន្នាគតោ ។ អបិចស្ស ឥមេ ធម្មា ហោន្តិ សទ្ធិន្ទ្រិយំ ។បេ។ បញ្ញិន្ទ្រិយំ ។ តថាគតេ ចស្ស សទ្ធាមត្តំ ហោតិ បេមមត្តំ ។ អយម្បិ ខោ មហានាម បុគ្គលោ អគន្តា និរយំ អគន្តា តិរច្ឆានយោនឹ អគន្តា បេត្តិវិសយំ អគន្តា អបាយទុគ្គតិវិនិបាតំ ។

[២៣៧] ឥមេ ចេបិ មហានាម មហាសាលា សុភាសិតំ ទុព្ភាសិតំ អាជានេយ្យុំ ឥមេវាហំ មហាសាលេ ព្យាករេយ្យំ សោតាបន្នា អវិនិបាតធម្មា និយតា សម្ពោធិបរាយណាតិ ។ កិមង្គំ បន សរកានឹ សក្កំ សរកានិ មហានាម សក្កោ មរណកាលេ សិក្ខំ សមាទិយីតិ ។

[២៣៨] កបិលវត្ថុនិទានំ ។ តេន ខោ បន សមយេន សរកានិ សក្កោ កាលកតោ ហោតិ ។ សោ ភគវតា ព្យាកតោ សោតាបន្នោ អវិនិបាតធម្មោ

មិនមានបញ្ញាវាងវៃទេ មិនប្រកបដោយវិមុត្តិទេ ។ តែថា ធម៌អម្បាលនេះ គឺសទ្ធិន្រ្ទិយ ។បេ។ បញ្ញិន្រ្ទិយ តែងមានដល់បុគ្គលនោះ ។ មួយទៀត បុគ្គលនោះគ្រាន់តែមានសទ្ធានឹងសេចក្តីស្រឡាញ់ ក្នុងព្រះតថាគត ។ បពិត្រព្រះមហានាម បុគ្គលនេះឯង ជាអ្នក មិនទៅកាន់នរក មិនទៅកាន់កំណើតតិរច្ឆាន មិនទៅកាន់ប្រេតវិស័យ មិនទៅកាន់អបាយ ទុគ្គតិ វិនិបាត ។

(២៣៧) បពិត្រព្រះមហានាម បើពួកមហាសាលអម្បាលនេះ គប្បីដឹងច្បាស់នូវពាក្យជាសុភាសិតនឹងពាក្យជាទុព្ភាសិត តថាគតគប្បីព្យាករនូវពួកមហាសាលអម្បាលនេះថា សោតាបន្នបុគ្គល មានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ។ នឹងបាច់ពោលទៅថ្វី ដល់ព្រះសរកានិសក្យរាជ បពិត្រព្រះមហានាម ដ្បិតព្រះសរកានិសក្យរាជ បានសមាទាននូវសិក្ខា ក្នុងកាលជិតមរណៈ ។

(២៣៨) កបិលវត្ថុនិទាន ។ សម័យនោះឯង ព្រះសរកានិសក្យរាជ ទ្រង់ទិវង្គតទៅ ។ ព្រះអង្គជាអ្នកដែលព្រះដ៏មានព្រះភាគទ្រង់ព្យាករហើយថា ជាសោតាបន្នបុគ្គល មានសភាពមិនធ្លាក់ទៅក្នុងអបាយ

និយតោ សម្ពោធិបរាយណោតិ ។ តត្រ សុទំ សម្ពហុលា សក្កា សង្គម្ម សមាគម្ម ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ ឯត្ថទានិ ភោ ន សោតាបន្នោ ភវិស្សតិ យត្រ ហិ នាម សរកានិ សក្កោ កាលកតោ ភគវតា ព្យាកតោ សោតាបន្នោ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយណោតិ ។ សរកានិ សក្កោ សិក្ខាយ អបរិបូរិការី អហោសីតិ ។

[២៣៩] អថខោ មហានាមោ សក្កោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ មហានាមោ សក្កោ ភគវន្តំ ឯតទវោច ឥធ ភន្តេ សរកានិ សក្កោ កាលកតោ សោ ភគវតា ព្យាកតោ សោតាបន្នោ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយណោតិ ។ តត្រ សុទំ ភន្តេ សម្ពហុលា សក្កា សង្គម្ម សមាគម្ម ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ

ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ៗ បានឮថា ពួកសក្យរាជច្រើនអង្គ មកប្រជុំគ្នាក្នុងទីនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា អើហ្ន៎ អស្ចារ្យណាស់តើ អើហ្ន៎ មិនដែលកើតមានទេតើ បើយ៉ាងហ្នឹង នរណានឹងមិនបានជាសោតាបន្នបុគ្គលក្នុងសាសនានេះ ព្រោះសរកានិសក្យរាជ ដែលទ្រង់ទិវង្គតទៅហើយនេះ មិនសមបើព្រះដ៏មានព្រះភាគទ្រង់ព្យាករថា ជាសោតាបន្នបុគ្គល មានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខសោះ ។ ដ្បិតព្រះសរកានិសក្យរាជ មិនបានធ្វើឲ្យពេញបរិបូណ៌ក្នុងសិក្ខាទេ ។

[២៣៩] គ្រានោះឯង ព្រះមហានាមសក្យរាជ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយគង់ក្នុងទីដ៏សមគួរ ។ លុះព្រះមហានាមសក្យរាជ គង់ក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូល ព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន អម្បាញ់មិញនេះ ព្រះសរកានិសក្យរាជ ទ្រង់ទិវង្គតទៅហើយ ព្រះអង្គជាអ្នកដែលព្រះដ៏មានព្រះភាគ ទ្រង់ព្យាករថា ជាសោតាបន្នបុគ្គល មានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ៗ បពិត្រព្រះអង្គដ៏ចំរើន បានឮថា ពួកសក្យរាជច្រើនអង្គ មកប្រជុំគ្នាក្នុងទីនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា

## សរកានិវគ្គោ តតិយោ

អច្ចរិយំ វត ភោ អព្ភុតំ វត ភោ ឯតទានិ ភោ ន សោតាបន្នោ ករិស្សតិ យត្រ ហិ នាម សរកានិ សក្កោ កាលកតោ សោ ភគវតា ព្យាកតោ សោតាបន្នោ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយណោតិ ។ សរកានិ សក្កោ សិក្ខាយ អបរិបូរការី អហោសីតិ ។

(២៤០) យោ សោ មហានាម ទីឃរត្តំ ឧបាសកោ ពុទ្ធំ សរណំ គតោ ធម្មំ សរណំ គតោ សង្ឃំ សរណំ គតោ សោ កថំ វិនិបាតំ គច្ឆេយ្យ ។ យញ្ហិ តំ មហានាម សម្មា វទមានោ វទេយ្យ ទីឃរត្តំ ឧបាសកោ ពុទ្ធំ សរណំ គតោ ធម្មំ សរណំ គតោ សង្ឃំ សរណំ គតោតិ សរកានិំ សក្កំ សម្មា វទមានោ វទេយ្យ សរកានិ មហានាម សក្កោ ទីឃរត្តំ ឧបាសកោ ពុទ្ធំ សរណំ គតោ ធម្មំ សរណំ គតោ សង្ឃំ សរណំ គតោ សោ កថំ វិនិបាតំ គច្ឆេយ្យ ។

អើហ្ន៎ អស្ចារ្យណាស់តើ អើហ្ន៎ មិនដែលកើតមានទេតើ បើយ៉ាងហ្នឹង នរណានឹងមិនបានជាសោតាបន្នបុគ្គល ក្នុងសាសនានេះ ព្រះសរកានិសក្យរាជ ដែលទ្រង់ទិវង្គតទៅហើយនោះ មិនសមបើព្រះដ៏មានព្រះភាគទ្រង់ព្យាករថា ជាសោតាបន្នបុគ្គល មានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខសោះ ៗ ដ្បិតព្រះសរកានិសក្យរាជ មិនបានធ្វើឲ្យពេញបរិបូណ៌ក្នុងសិក្ខាទេ ៗ

(២៤០) ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា បពិត្រព្រះមហានាម បុគ្គលណាជាឧបាសក ដល់នូវព្រះពុទ្ធជាទីពឹង ដល់នូវព្រះធម៌ជាទីពឹង ដល់នូវព្រះសង្ឃជាទីពឹងអស់រាត្រីវែង បុគ្គលនោះ គប្បីទៅកាន់អបាយដូចម្តេចបាន ៗ បពិត្រព្រះមហានាម បុគ្គលកាលពោលដោយប្រពៃ គប្បីពោលតាមហេតុពិតថា បុគ្គលជាឧបាសក ដល់នូវព្រះពុទ្ធជាទីពឹង ដល់នូវព្រះធម៌ជាទីពឹង ដល់នូវព្រះសង្ឃជាទីពឹង អស់រាត្រីវែង បុគ្គលកាលពោលដោយប្រពៃ គប្បីពោលចំពោះព្រះសរកានិសក្យរាជ បពិត្រព្រះមហានាម ព្រះសរកានិសក្យរាជ ជាឧបាសក ដល់នូវព្រះពុទ្ធជាទីពឹង ដល់នូវព្រះធម៌ជាទីពឹង ដល់នូវព្រះសង្ឃជាទីពឹងអស់រាត្រីវែង ព្រះសរកានិសក្យរាជនោះ គប្បីទៅកាន់អបាយដូចម្តេចបាន ៗ

(២៤១) ឥធ មហានាម ឯកច្ចោ បុគ្គលោ ពុទ្ធេ ឯកន្តគតោ ហោតិ អភិប្បសន្នោ ឥតិបិ សោ ភគវា ។បេ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ធម្មេ ។ សង្ឃេ ។ ហាសបញ្ញោ ជវនបញ្ញោ វិមុត្តិយា ច សមន្នាគតោ ។ សោ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ អយម្បិ ខោ មហានាម បុគ្គលោ បរិមុត្តោ និរយា បរិមុត្តោ តិរច្ឆានយោនិយា បរិមុត្តោ បិត្តិវិសយា បរិមុត្តោ អបាយទុគ្គតិវិនិបាតា ។

(២៤២) ឥធ បន មហានាម ឯកច្ចោ បុគ្គលោ ពុទ្ធេ ឯកន្តគតោ ហោតិ អភិប្បសន្នោ ឥតិបិ សោ ភគវា ។បេ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។

[៤៤១] បពិត្រព្រះមហានាម បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកជ្រះថ្លាក្រៃលែងពិតប្រាកដ ក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគអង្គនោះ ។បេ។ ព្រះអង្គជាគ្រូនៃទេវតានឹងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់កពថ្មីទៀត ។ (បុគ្គលជាអ្នកជ្រះថ្លាក្រៃលែងពិតប្រាកដក្នុងព្រះធម៌ ។ ក្នុងព្រះសង្ឃ ។ ជាអ្នកមានបញ្ញាជាគ្រឿងរីករាយ មានបញ្ញារាងរៃនឹងប្រកបដោយវិមុត្តិ ។ បុគ្គលនោះធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ នឹងបញ្ញាវិមុត្តិ មិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយបញ្ញាដ៏ក្រៃលែងដោយខ្លួនឯង ក្នុងបច្ចុប្បន្នហើយសម្រេចសម្រាន្តនៅ ។ បពិត្រព្រះមហានាម បុគ្គលនេះឯងជាអ្នកបានរួចចាកនរក រួចចាកកំណើតតិរច្ឆាន រួចចាកប្រេតវិស័យ រួចចាកអបាយ ទុគ្គតិ វិនិបាត ។

[៤៤២] បពិត្រព្រះមហានាម មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកជ្រះថ្លាក្រៃលែងពិតប្រាកដ ក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគអង្គនោះ ។ បេ ។ ព្រះអង្គជាគ្រូនៃទេវតានឹងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់កពថ្មីទៀត ។

ធម្មេ ។ សង្ឃេ ។ ហាសបញ្ញោ ជវនបញ្ញោ ន ច វិមុត្តិយា សមន្នាគតោ ។ សោ បញ្ចន្នំ ឱរម្ភាគិយានំ សំយោជនានំ បរិក្ខយា អន្តរាបរិនិព្វាយី ហោតិ ឧបហច្ចបរិនិព្វាយី ហោតិ អសង្ខារបរិនិព្វាយី ហោតិ សសង្ខារបរិនិព្វាយី ហោតិ ឧទ្ធំសោតោ ហោតិ អកនិដ្ឋគាមី ។ អយម្បិ ខោ មហានាម បុគ្គលោ បរិមុត្តោ និរយា បរិមុត្តោ តិរច្ឆានយោនិយា បរិមុត្តោ បិត្តិវិសយា បរិមុត្តោ អបាយទុគ្គតិវិនិបាតា ។

(៤៤៣) ឥធ បន មហានាម ឯកច្ចោ បុគ្គលោ ពុទ្ធេ ឯកន្តគតោ ហោតិ អភិប្បសន្នោ ឥតិបិ សោ ភគវា ។ បេ ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ធម្មេ ។ សង្ឃេ ។ ន ហាសបញ្ញោ ន ជវនបញ្ញោ ន ច វិមុត្តិយា សមន្នាគតោ ។

(ជាអ្នកជ្រះថ្លាក្រៃលែងពិតប្រាកដ) ក្នុងព្រះធម៌ ។ ក្នុងព្រះសង្ឃ ។ ជាអ្នកមានបញ្ញាជាគ្រឿងរីករាយ មានបញ្ញាវាងវៃ តែមិនប្រកបដោយវិមុត្តិ ។ បុគ្គលនោះ នឹងបរិនិព្វានក្នុងរវាងអាយុនៅមិនទាន់ដល់ពាក់កណ្តាល នឹងបរិនិព្វានក្នុងអាយុផុតពាក់កណ្តាលហើយ ជិតដល់ទីបំផុត នឹងបរិនិព្វាន ដោយធ្វើសេចក្តីព្យាយាមយ៉ាងខ្លាំងនឹងបរិនិព្វាន ដោយមិនបាច់ធ្វើសេចក្តីព្យាយាមពេកទេ នឹងមានខ្សែធម៌ឡើងខាងលើទៅកាន់អកនិដ្ឋភព ព្រោះអស់ពួកសញ្ញោជនៈជាចំណែកខាងក្រោម ៥ ។ បពិត្រព្រះមហានាម បុគ្គលនេះឯង ជាអ្នក រួចចាកនរក រួចចាកកំណើតតិរច្ឆាន រួចចាកប្រេតវិស័យ រួចចាកអបាយ ទុគ្គតិ វិនិបាត ។

[៤៨៣] បពិត្រព្រះមហានាម មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកជ្រះថ្លាក្រៃលែងពិតប្រាកដ ក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគអង្គនោះ ។បេ។ ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀត ។ (ជាអ្នកជ្រះថ្លាក្រៃលែងពិតប្រាកដ) ក្នុងព្រះធម៌ ។ ក្នុងព្រះសង្ឃ ។ តែមិនមានបញ្ញាជាគ្រឿងរីករាយ មិនមានបញ្ញាវាងវៃ នឹងមិនប្រកបដោយវិមុត្តិ ។

សោ តិណ្ណំ សញ្ញោជនានំ បរិក្ខយា រាគទោសមោហានំ តនុត្តា សកទាគាមី ហោតិ សកិទេវ ឥមំ លោកំ អាគន្ត្វា ទុក្ខស្សន្តំ ករោតិ ។ អយម្បិ ខោ មហានាម បុគ្គលោ បរិមុត្តោ និរយា បរិមុត្តោ តិរច្ឆានយោនិយា បរិមុត្តោ បេត្តិវិសយា បរិមុត្តោ អបាយទុគ្គតិវិនិបាតា ។

[២៤៤] ឥធ បន មហានាម ឯកច្ចោ បុគ្គលោ ពុទ្ធេ ឯកន្តគតោ ហោតិ អភិប្បសន្នោ ឥតិបិ សោ ភគវា ។បេ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ធម្មេ ។ សង្ឃេ ។ ន ហាសប្បញ្ញោ ន ជវនប្បញ្ញោ ន ច វិមុត្តិយា សមន្នាគតោ ។ សោ តិណ្ណំ សញ្ញោជនានំ បរិក្ខយា សោតាបន្នោ ហោតិ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយនោ ។ អយម្បិ ខោ មហានាម បុគ្គលោ បរិមុត្តោ និរយា បរិមុត្តោ តិរច្ឆានយោនិយា បរិមុត្តោ បេត្តិវិសយា បរិមុត្តោ អបាយទុគ្គតិវិនិបាតា ។

បុគ្គលនោះ ជាសកទាគាមី នឹងមកកាន់លោកនេះម្តងទៀត ទើបធ្វើនូវទីបំផុតនៃទុក្ខបាន ព្រោះអស់សញ្ញោជនៈ ៣ ប្រការ ព្រោះធ្វើរាគៈ ទោសៈ មោហៈ ឲ្យស្រាលស្តើង ។ បពិត្រព្រះមហានាម បុគ្គលនេះឯង ជាអ្នករួចចាកនរក រួចចាកកំណើតតិរច្ឆាន រួចចាកប្រេតវិស័យ រួចចាកអបាយ ទុគ្គតិ វិនិបាត ។

(៤៤៤) បពិត្រព្រះមហានាម មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកជ្រះថ្លាក្រៃលែងពិតប្រាកដ ក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគអង្គនោះ ។ បេ ។ ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀត ។ (ជាអ្នកជ្រះថ្លាក្រៃលែងពិតប្រាកដ) ក្នុងព្រះធម៌ ។ ក្នុងព្រះសង្ឃ ។ តែមិនមានបញ្ញាជាគ្រឿងរីករាយ មិនមានបញ្ញារហ័សរហួន នឹងមិនប្រកបដោយវិមុត្តិ ។ បុគ្គលនោះ ជាសោតាបន្នបុគ្គល មានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ព្រោះអស់សញ្ញោជនៈទាំង ៣ ប្រការ ។ បពិត្រព្រះមហានាម បុគ្គលនេះឯង ជាអ្នករួចចាកនរក រួចចាកកំណើតតិរច្ឆាន រួចចាកប្រេតវិស័យ រួចចាកអបាយ ទុគ្គតិ វិនិបាត ។

## សរកានិវគ្គោ តតិយោ

(២៤៥) ឥធ បន មហានាម ឯកច្ចោ បុគ្គលោ ន ហេវ ខោ ពុទ្ធេ ឯកន្តគតោ ហោតិ អភិប្បសន្នោ ។ ន ធម្មេ ។ ន សង្ឃេ ។ ន ហាសប្បញ្ញោ ន ជវនប្បញ្ញោ ន ច វិមុត្តិយា សមន្នាគតោ ។ អបិចស្ស ឥមេ ធម្មា ហោន្តិ សទ្ធិន្ទ្រិយំ ។ បេ ។ បញ្ញិន្ទ្រិយំ ។ តថាគតប្បវេទិតា ចស្ស ធម្មា បញ្ញាយ មត្តសោ និជ្ឈានំ ខមន្តិ ។ អយម្បិ ខោ មហានាម បុគ្គលោ អគន្តា និរយំ អគន្តា តិរច្ឆានយោនឹ អគន្តា បេត្តិវិសយំ អគន្តា អបាយទុគ្គតិវិនិបាតំ ។

(២៤៦) ឥធ បន មហានាម ឯកច្ចោ បុគ្គលោ ន ហេវ ខោ ពុទ្ធេ ឯកន្តគតោ ហោតិ អភិប្បសន្នោ ។ ន ធម្មេ ។ ន សង្ឃេ ។ ន ហាសប្បញ្ញោ ន ជវនប្បញ្ញោ ន ច វិមុត្តិយា សមន្នាគតោ ។ អបិចស្ស ឥមេ ធម្មា ហោន្តិ សទ្ធិន្ទ្រិយំ ។ បេ ។ បញ្ញិន្ទ្រិយំ ។

## សរកានិវគ្គទី ៣

(២៤៥) បពិត្រព្រះមហានាម មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនបានជ្រះថ្លាក្រៃលែងពិតប្រាកដ ក្នុងព្រះពុទ្ធទេ ។ ក្នុងព្រះធម៌ទេ ។ ក្នុងព្រះសង្ឃទេ ។ មិនមានបញ្ញាជាគ្រឿងរីករាយទេ មិនមានបញ្ញាវាងវៃទេ មិនប្រកបដោយវិមុត្តិទេ ។ តែថា ធម៌អម្បាលនេះ គឺសទ្ធិន្ទ្រិយ ។ បេ ។ បញ្ញិន្ទ្រិយ តែងមានដល់បុគ្គលនោះ ។ មួយទៀត ធម៌ទាំងឡាយ ដែលព្រះតថាគតទ្រង់ប្រកាសហើយ ជាធម៌គួរដល់ការពិចារណា ដោយបញ្ញាដ៏ក្រៃលែង ដល់បុគ្គលនោះ ។ បពិត្រព្រះមហានាម បុគ្គលនេះឯង ជាអ្នក មិនទៅកាន់នរក មិនទៅកាន់កំណើតតិរច្ឆាន មិនទៅកាន់ប្រេតវិស័យ មិនទៅកាន់អបាយ ទុគ្គតិ វិនិបាត ។

(២៤៦) បពិត្រព្រះមហានាម មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនបានជ្រះថ្លាក្រៃលែងពិតប្រាកដ ក្នុងព្រះពុទ្ធទេ ។ ក្នុងព្រះធម៌ទេ ។ ក្នុងព្រះសង្ឃទេ ។ មិនមានបញ្ញាជាគ្រឿងរីករាយទេ មិនមានបញ្ញាវាងវៃទេ មិនប្រកបដោយវិមុត្តិទេ តែថា ធម៌អម្បាលនេះ គឺសទ្ធិន្ទ្រិយ ។ បេ ។ បញ្ញិន្ទ្រិយ តែងមានដល់បុគ្គលនោះ ។

តថាគតេ ចស្ស សទ្ធាមត្តំ ហោតិ បេមមត្តំ ។ អយម្បិ ខោ មហានាម បុគ្គលោ អគន្តា និរយំ អគន្តា តិរច្ឆានយោនឹ អគន្តា បិត្តិវិសយំ អគន្តា អបាយទុគ្គតិវិនិបាតំ ។

[៦៤៧] សេយ្យថាបិ មហានាម ទុក្ខេត្តំ ទុព្ភូមឹ អវិហតខាណុកំ ពីជានិ ចស្សុ ខណ្ឌានិ បូតីនិ វាតាតបហតានិ អសារកានិ(១) អសុខសយិតានិ ទេវោ ច ន សម្មា ធារំ អនុប្បវេច្ឆេយ្យ ។ អបិ នុ តានិ ពីជានិ វុឌ្ឍឹ វិរុឡ្ហឹ វេបុល្លំ អាបជ្ជេយ្យុន្តិ ។ នោ ហេតំ ភន្តេ ។ ឯវមេវ ខោ មហានាម ឥធ ធម្មោ ទុរក្ខាតោ ហោតិ ទុប្បវេទិតោ អនិយ្យានិកោ អនុបសមសំវត្តនិកោ អសម្មាសម្ពុទ្ធប្បវេទិតោ(២) ឥទមហំ ទុក្ខេត្តស្មឹ វទាមិ ។

---

១- ឱ. អសារកនិ ។ ២- ឱ. ទុក្ខុពោ ។

មួយទៀត បុគ្គលនោះគ្រាន់តែមានសទ្ធានឹងសេចក្ដីស្រឡាញ់ ក្នុងព្រះតថាគត ។ បពិត្រព្រះមហានាម បុគ្គលនេះឯង ជាអ្នក មិនទៅកាន់នរក មិនទៅកាន់កំណើតតិរច្ឆាន មិនទៅកាន់ប្រេតវិស័យ មិនទៅកាន់អបាយ ទុគ្គតិ វិនិបាត ។

(៤៤៧) បពិត្រព្រះមហានាម ដូចពូជទាំងឡាយ ដែលបាក់ខ្ទេច ដែលស្អុយ ដែលក្រៀមក្រោះ ដោយខ្យល់នឹងកំដៅថ្ងៃ ដែលឥតពន្លក ដែលគេទុកដាក់ក្នុងទីមិនស្អាត ភ្លៀងក៏បង្អុរនូវទឹកភ្លៀងដោយស្រួលចុះកាន់ស្រែ ដែលក្រហែងក្រហូង មានផែនដីអាក្រក់ ដែលគេមិនពាន់បានគាស់រានយកដង្គត់ឈើចេញនៅឡើយ ពូជទាំងអម្បាលនោះនឹងដល់នូវសេចក្ដីចំរើន ដុះដាល លូតលាស់បានដែរឬទេ ។ មិនបានទេព្រះអង្គ ។ បពិត្រព្រះមហានាម សេចក្ដីឧបមេយ្យក៏ដូច្នោះដែរ ធម៌ក្នុងលោកនេះ ជាធម៌ដែលបុគ្គលពោលមិនល្អ ជាធម៌ដែលបុគ្គលប្រកាសមិនល្អ ជាធម៌មិននាំសត្វចេញចាកទុក្ខបាន មិនប្រព្រឹត្តទៅដើម្បីសេចក្ដីស្ងប់ស្ងាត់ ជាធម៌ដែលបុគ្គលមិនមែនសម្មាសម្ពុទ្ធប្រកាសហើយ តថាគតពោលថា ធម៌នេះ ដូចស្រែដែលក្រហែងក្រហូង ។

## សរណានិវគ្គោ តតិយោ

តស្មិំ ច ធម្មេ សាវកោ វិហរតិ ធម្មានុធម្មប្បដិបន្នោ សាមីចិប្បដិបន្នោ អនុធម្មចារី ឥទមហំ ទុព្វីជស្មិំ វទាមិ ។

(៨៨) សេយ្យថាបិ មហានាម សុក្ខេត្តំ សុភូមី សុវិហតក្ខាណុកំ ពីជានិ ចស្សុ អខណ្ឌានិ អបូតីនិ អវាតាតបហតានិ សារាទានិ សុខសយិតានិ ទេវោ ចស្ស សម្មា ធារំ អនុប្បវេច្ឆេយ្យ អបិ នុ តានិ ពីជានិ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជេយ្យុន្តិ ។ ឯវំ ភន្តេ ។ ឯវមេវ ខោ មហានាម ឥធ ធម្មោ ស្វាក្ខាតោ ហោតិ សុប្បវេទិតោ និយ្យានិកោ ឧបសមសំវត្តនិកោ សម្មាសម្ពុទ្ធប្បវេទិតោ ឥទមហំ សុក្ខេត្តស្មិំ វទាមិ ។ តស្មិំ ច ធម្មេ សាវកោ វិហរតិ ធម្មានុធម្មប្បដិបន្នោ សាមីចិប្បដិបន្នោ អនុធម្មចារី ឥទមហំ សុពីជស្មិំ វទាមិ ។

មួយវិញទៀត សាវកដែលប្រតិបត្តិនូវធម៌តាមធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តនូវធម៌ដ៏សមគួរ នៅគ្រប់ឥរិយាបថ គុណធម៌នោះ តថាគតពោលថា សាវកអ្នកប្រតិបត្តិធម៌តាមធម៌ នៅគ្រប់ឥរិយាបថនេះដូចជាពូជអាក្រក់ ៗ

(៤៤៨) បពិត្រព្រះមហានាម ដូចពូជទាំងឡាយ ដែលមិនបាក់ខូច ដែលមិនស្អុយ ដែលមិនក្រៀមក្រោះ ដោយខ្យល់និងកំដៅថ្ងៃ មានពន្លកដែលគេទុកដាក់គង់ទីដ៏ស្អាត ទាំងភ្លៀងក៏បង្អុរនូវទឹកភ្លៀងដោយស្រួលចុះកាន់ស្រែដែលល្អ មានផែនដីពបស្មើ ដែលគេបានគាស់ពនយកដង្គត់ឈើចេញហើយ ពូជអម្បាលនោះនឹងដល់នូវសេចក្តីចំរើន ដុះដាល លូតលាស់ឡើងបានឬទេ ។ យ៉ាងហ្នឹងហើយព្រះអង្គ ។ បពិត្រព្រះមហានាម សេចក្តីឧបមេយ្យក៏ដូច្នោះដែរ ធម៌កងលោកនេះ ជាធម៌ដែលបុគ្គលពោលទុកល្អហើយ ធម៌ដែលបុគ្គលប្រកាសទុកល្អហើយ ជាធម៌នាំសត្វចេញចាកទុក្ខបាន ជាធម៌ប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់ស្ងាត់ ជាធម៌ដែលព្រះសម្មាសម្ពុទ្ធទ្រង់ប្រកាសហើយ តថាគតពោលថា ធម៌នេះ ដូចជាស្រែដ៏ល្អ ៗ មួយវិញទៀត សាវកដែលប្រតិបត្តិនូវធម៌តាមធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តនូវធម៌ដ៏សមគួរ នៅគ្រប់ឥរិយាបថ គុណធម៌នោះ តថាគតពោលថា សាវកអ្នកប្រតិបត្តិធម៌តាមធម៌ នៅគ្រប់ឥរិយាបថនេះ ដូចជាពូជដ៏ល្អ ៗ

កិមង្គំ បន សរកានឹ សក្កំ សរកានិ មហានាម សក្កោ មរណកាលេ សិក្ខាយ បរិបូរការី អហោសីតិ ។

[២៤៩] សាវត្ថីនិទានំ ។ តេន ខោ បន សមយេន អនាថបិណ្ឌិកោ គហបតិ អាពាធិកោ ហោតិ ទុក្ខិតោ ពាឡ្ហគិលានោ ។ អថខោ អនាថបិណ្ឌិកោ គហបតិ អញ្ញតរំ បុរិសំ អាមន្តេសិ ឯហិ ត្វំ អម្ភោ បុរិស យេនាយស្មា សារីបុត្តោ តេនុបសង្កម ឧបសង្កមិត្វា មម វចនេន អាយស្មតោ សារីបុត្តស្ស បាទេ សិរសា វន្ទ អនាថបិណ្ឌិកោ ភន្តេ គហបតិ អាពាធិកោ ទុក្ខិតោ ពាឡ្ហគិលានោ សោ អាយស្មតោ សារីបុត្តស្ស បាទេ សិរសា វន្ទតីតិ ។ ឯវញ្ច វទេហិ សាធុ កិរ ភន្តេ អាយស្មា សារីបុត្តោ យេន អនាថបិណ្ឌិកស្ស គហបតិស្ស និវេសនំ តេនុបសង្កមតុ អនុកម្បំ ឧបាទាយាតិ ។ ឯវំ ភន្តេតិ ខោ សោ បុរិសោ អនាថបិណ្ឌិកស្ស គហបតិស្ស បដិស្សុត្វា យេនាយស្មា សារីបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ សារីបុត្តំ អភិវាទេត្វា

នឹងឃាត់ពោលទៅថា ដល់ព្រះសរកានិសក្យរាជ បពិត្រព្រះមហានាម ព្រះសរកានិសក្យរាជ ជាអ្នកបានធ្វើឲ្យពេញបរិបូណ៌ក្នុងសិក្ខា ក្នុងកាលជិតមរណៈ ។

(៤៤៩) សាវត្ថីនិទាន ។ សម័យនោះឯង អនាថបិណ្ឌិកគហបតី មានអាពាធ ប្រកបដោយទុក្ខ មានជម្ងឺជាទម្ងន់ ។ លំដាប់នោះ អនាថ-បិណ្ឌិកគហបតី បានហៅបុរសម្នាក់មកថា ម្នាលបុរសដ៏ចំរើន ឯងចូរមកនេះ ឯងចូរទៅរកព្រះសារីបុត្រដ៏មានអាយុ លុះចូលទៅដល់ហើយ ចូរថ្វាយបង្គំបាទាព្រះសារីបុត្រដ៏មានអាយុ ដោយសិរសា តាមពាក្យអញថា បពិត្រព្រះករុណាដ៏ចំរើន អនាថបិណ្ឌិកគហបតី មានអាពាធ ប្រកបដោយទុក្ខ មានជម្ងឺជាទម្ងន់ លោកថ្វាយបង្គំបាទាព្រះសារីបុត្រដ៏មានអាយុដោយសិរសា ។ រួចហើយ ឯងចូរនិមន្តយ៉ាងនេះថា បពិត្រព្រះករុណាដ៏ចំរើន សូមព្រះសារីបុត្រដ៏មានអាយុ អាស្រ័យនូវសេចក្តីអនុគ្រោះ និមន្តទៅកាន់ទីលំនៅអនាថបិណ្ឌិកគហបតីឲ្យបាន ។ បុរសនោះទទួលពាក្យអនាថបិណ្ឌិកគហបតីថា ប្របាទ ហើយក៏ចូលទៅរកព្រះសារីបុត្រដ៏មានអាយុ លុះចូលទៅដល់ ថ្វាយបង្គំព្រះសារីបុត្រដ៏មានអាយុហើយ

ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ បុរិសោ អាយស្មន្តំ សារីបុត្តំ ឯតទវោច អនាថបិណ្ឌិកោ ភន្តេ គហបតិ អាពាធិកោ ទុក្ខិតោ ពាឡ្ហគិលានោ សោ អាយស្មតោ សារីបុត្តស្ស បាទេ សិរសា វន្ទតិ ។ ឯវញ្ច វទេតិ សាធុ កិរ ភន្តេ អាយស្មា សារីបុត្តោ យេន អនាថបិណ្ឌិកស្ស គហបតិស្ស និវេសនំ តេនុបសង្កមតុ អនុកម្បំ ឧបាទាយាតិ ។ អធិវាសេសិ ខោ អាយស្មា សារីបុត្តោ តុណ្ហីភាវេន ។

(២៥០) អថខោ អាយស្មា សារីបុត្តោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ អាយស្មតា អានន្ទេន បច្ឆាសមណេន យេន អនាថបិណ្ឌិកស្ស គហបតិស្ស និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ និសជ្ជ ខោ អាយស្មា សារីបុត្តោ អនាថបិណ្ឌិកំ គហបតឹ ឯតទវោច កច្ចិ តេ គហបតិ ខមនីយំ កច្ចិ យាបនីយំ កច្ចិ ទុក្ខា វេទនា បដិក្កមន្តិ នោ អភិក្កមន្តិ បដិក្កមោសានំ បញ្ញាយតិ នោ អភិក្កមោតិ ។

ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះបុរសនោះ អង្គុយក្នុងទីដ៏សមគួរហើយ បានទូលព្រះសារីបុត្តដ៏មានអាយុ ដូច្នេះថា បពិត្រព្រះករុណាដ៏ចំរើន អនាថបិណ្ឌិកគហបតី មានអាពាធ ប្រកបដោយទុក្ខ មានជម្ងឺជាទម្ងន់ លោកថ្វាយបង្គំព្រះបាទព្រះសារីបុត្តដ៏មានអាយុ ដោយសិរសា ។ រួចពោលយ៉ាងនេះថា បពិត្រព្រះករុណាដ៏ចំរើន សូមព្រះសារីបុត្តដ៏មានអាយុ អាស្រ័យនូវសេចក្តីអនុគ្រោះ និមន្តទៅកាន់ទីលំនៅ អនាថបិណ្ឌិកគហបតីឲ្យបាន ។ ព្រះសារីបុត្តដ៏មានអាយុ បានទទួលនិមន្ត ដោយអាការស្ងៀម ។

(៤៩០) លំដាប់នោះ ព្រះសារីបុត្តដ៏មានអាយុ ស្លៀកស្បង់ ប្រដាប់បាត្រនិងចីវរ ក្នុងវេលាបុព្វណ្ហសម័យ មានព្រះអានន្ទដ៏មានអាយុ ជាបច្ឆាសមណៈ ចូលទៅកាន់ទីលំនៅអនាថបិណ្ឌិកគហបតី លុះចូលទៅដល់គង់លើអាសនៈ ដែលគេក្រាលហើយ ។ លុះព្រះសារីបុត្តដ៏មានអាយុគង់ហើយ ក៏ពោលនឹងអនាថបិណ្ឌិកគហបតីដូច្នេះថា ម្នាលគហបតី អ្នកល្មមអត់ធន់បានទេឬ ល្មមប្រព្រឹត្តទៅបានទេឬ ទុក្ខវេទនាធូរថយ មិនចំរើនឡើងទេឬ សេចក្តីធូរថយ (បាកពេគ) រមែងប្រាកដ ឯសេចក្តីមិនចំរើនឡើងនៃរោគ រមែងមិនប្រាកដទេឬ ។

ន មេ ភន្តេ ខមនីយំ ន យាបនីយំ ពាឡ្ហា មេ ទុក្ខា វេទនា អភិក្កមន្តិ នោ បដិក្កមន្តិ អភិក្កមោសានំ បញ្ញាយតិ នោ បដិក្កមោតិ ។

(២៩១) យថារូបេន ខោ គហបតិ ពុទ្ធេ អវេច្ចប្ប-សាទេន សមន្នាគតោ អស្សុតវា បុថុជ្ជនោ កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ តថារូបោ តេ ពុទ្ធេ អប្បសាទោ នត្ថិ ។ អត្ថិ ច ខោ តេ គហបតិ ពុទ្ធេ អវេច្ចប្បសាទោ ឥតិបិ សោ ភគវា ។បេ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ តញ្ច បន តេ ពុទ្ធេ អវេច្ច-ប្បសាទំ អត្តនិ សមនុបស្សតោ ឋានសោ វេទនា បដិប្បស្សម្ភេយ្យុំ ។

អនាថបិណ្ឌិកគហបតី ទូលថា បពិត្រព្រះករុណាដ៏ចំរើន ខ្ញុំព្រះករុណាអត់ធន់មិនបានទេ ខ្ញុំព្រះករុណាប្រព្រឹត្តទៅមិនបានទេ ទុក្ខវេទនារបស់ខ្ញុំព្រះករុណាចំរើនឡើងខ្លាំងណាស់ មិនធូរថយទេ សេចក្តីចំរើន (នៃរោគ) រមែងតែប្រាកដឡើងមិនមានធូរថយទេ ។

[២៥១] ព្រះសារីបុត្រពោលថា ម្នាលគហបតី បុថុជ្ជនដែលមិនចេះដឹង ប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធ មានសភាពយ៉ាងណា លុះដល់រំលាយខន្ធ បន្ទាប់អំពីមរណៈរមែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ឯសេចក្តីមិនជ្រះថ្លា ក្នុងព្រះពុទ្ធ មានសភាពយ៉ាងនោះ មិនមានដល់អ្នកទេ ។ ម្នាលគហបតី មួយទៀត សេចក្តីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធ តែងមានដល់អ្នកថា ព្រះដ៏មានព្រះភាគអង្គនោះ ។ បេ ។ ព្រះអង្គជាគ្រូនៃទេវតានឹងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀត ។ កាលបើអ្នកពិចារណាឃើញនូវសេចក្តីជ្រះថ្លាមិនញាប់ញ័រក្នុងព្រះពុទ្ធនោះ ចំពោះខ្លួន វេទនាទាំងឡាយ គប្បីស្ងប់រម្ងាប់ទៅដោយហេតុដ៏សមគួរបាន ។

## សរកានិវគ្គោ តតិយោ

(២៩២) យថារូបេន ខោ គហបតិ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ អស្សុតវា បុថុជ្ជនោ កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ តថារូបោ តេ ធម្មេ អប្បសាទោ នត្ថិ ។ អត្ថិ ច ខោ តេ គហបតិ ធម្មេ អវេច្ចប្បសាទោ ស្វាក្ខាតោ ភគវតា ធម្មោ ។ បេ ។ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។ តញ្ច បន តេ ធម្មេ អវេច្ចប្បសាទំ អត្តនិ សមនុបស្សតោ ឋានសោ វេទនា បដិប្បស្សម្ភេយ្យ ។

(២៩៣) យថារូបេន ខោ គហបតិ សង្ឃេ អវេច្ចប្បសាទេន សមន្នាគតោ អស្សុតវា បុថុជ្ជនោ កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ តថារូបោ តេ សង្ឃេ អប្បសាទោ នត្ថិ ។ អត្ថិ ច ខោ តេ គហបតិ សង្ឃេ អវេច្ចប្បសាទោ សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ។ បេ ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

[២៥២] ម្នាលគហបតី បុថុជ្ជនដែលមិនចេះដឹង ប្រកបដោយសេចក្ដីជ្រះថ្លា មិនញាប់ញ័រ ក្នុងព្រះធម៌ មានសភាពយ៉ាងណា លុះរំលាយខន្ធ បន្ទាប់អំពីមរណៈរមែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក សេចក្ដីមិនជ្រះថ្លា ក្នុងព្រះធម៌ មានសភាពយ៉ាងនោះ មិនមានដល់អ្នកឡើយ ។ ម្នាលគហបតី មួយទៀត សេចក្ដីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះធម៌ មានដល់អ្នកថា ព្រះធម៌ដែលព្រះដ៏មានព្រះភាគត្រាស់ប្រពៃហើយ ។បេ។ ជាធម៌ដែលវិញ្ញូជនទាំងឡាយគប្បីដឹងចំពោះខ្លួន កាលបើអ្នកពិចារណាឃើញនូវសេចក្ដីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះធម៌នោះចំពោះខ្លួន វេទនាទាំងឡាយ គប្បីស្ងប់រម្ងាប់ទៅ ដោយហេតុដ៏សមគួរ ។

[២៥៣] ម្នាលគហបតី បុថុជ្ជនដែលមិនចេះដឹង ប្រកបដោយសេចក្ដីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះសង្ឃ មានសភាពយ៉ាងណា លុះរំលាយខន្ធ បន្ទាប់អំពីមរណៈរមែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ឯសេចក្ដីមិនជ្រះថ្លាមានសភាពយ៉ាងនោះ ក្នុងព្រះសង្ឃ មិនមានដល់អ្នកឡើយ ។ ម្នាលគហបតី មួយទៀត សេចក្ដីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះសង្ឃ ក៏មានដល់អ្នកថា ព្រះសង្ឃសាវកនៃព្រះដ៏មានព្រះភាគលោកប្រតិបត្តិល្អហើយ ។បេ។ ជាស្រែបុណ្យដ៏ប្រសើរនៃសត្វលោក ។

តញ្ច បន តេ សង្ឃេ អវេច្ចប្បសាទំ អត្តនិ សមនុបស្សតោ ឋានសោ វេទនា បដិប្បស្សម្ភេយ្យ ។

(២៥៤) យថារូបេន ខោ គហបតិ ទុស្សីល្យេន សមន្នាគតោ អស្សុតវា បុថុជ្ជនោ កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ តថារូបន្តេ ទុស្សីល្យំ នត្ថិ ។ អត្ថិ ច ខោ តេ គហបតិ អរិយកន្តានិ សីលានិ អខណ្ឌានិ ។ បេ ។ សមាធិសំវត្តនិកានិ ។ តានិ ច បន តេ អរិយកន្តានិ សីលានិ អត្តនិ សមនុបស្សតោ ឋានសោ វេទនា បដិប្បស្សម្ភេយ្យ ។

(២៥៥) យថារូបាយ ខោ គហបតិ មិច្ឆាទិដ្ឋិយា សមន្នាគតោ អស្សុតវា បុថុជ្ជនោ កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ តថារូបា តេ មិច្ឆាទិដ្ឋិ នត្ថិ ។ អត្ថិ ច ខោ តេ គហបតិ សម្មាទិដ្ឋិ ។ តញ្ច បន តេ សម្មាទិដ្ឋឹ អត្តនិ សមនុបស្សតោ ឋានសោ វេទនា បដិប្បស្សម្ភេយ្យ ។

កាលបើអ្នកពិចារណាឃើញនូវសេចក្តីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះសង្ឃនោះ ចំពោះខ្លួន វេទនាទាំងឡាយ គប្បីស្ងប់រម្ងាប់ទៅ ដោយហេតុដ៏សមគួរ ។

[៤៥៨] ម្នាលគហបតី បុថុជ្ជនដែលមិនចេះដឹង ប្រកបដោយភាពជាអ្នកទ្រុស្តសីល មានសភាពយ៉ាងណា លុះរំលាងខ្លួន បន្ទាប់អំពីមរណៈ រមែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ឯភាពជាអ្នកទ្រុស្តសីល មានសភាពយ៉ាងនោះ មិនមានដល់អ្នកឡើយ ។ ម្នាលគហបតី មួយទៀត សីលទាំងឡាយជាទីស្រឡាញ់របស់អរិយៈ ជាសីលមិនដាច់ ។បេ។ ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ ក៏មានដល់អ្នក ។ កាលបើអ្នកពិចារណាឃើញនូវសីលទាំងឡាយ ដែលជាទីស្រឡាញ់របស់អរិយៈនោះចំពោះខ្លួន វេទនាទាំងឡាយ គប្បីស្ងប់រម្ងាប់ទៅ ដោយហេតុដ៏សមគួរបាន ។

[៤៥៩] ម្នាលគហបតី បុថុជ្ជនដែលមិនចេះដឹង ប្រកបដោយមិច្ឆាទិដ្ឋិ មានសភាពយ៉ាងណា លុះរំលាងខ្លួន បន្ទាប់អំពីមរណៈរមែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក មិច្ឆាទិដ្ឋិ មានសភាពយ៉ាងនោះ មិនមានដល់អ្នកឡើយ ។ ម្នាលគហបតី មួយទៀត សម្មាទិដ្ឋិ ក៏មានដល់អ្នក ។ កាលបើអ្នកពិចារណាឃើញនូវសម្មាទិដ្ឋិនោះចំពោះខ្លួន វេទនាទាំងឡាយ គប្បីស្ងប់រម្ងាប់ទៅ ដោយហេតុដ៏សមគួរ ។

## សរកានិវគ្គោ តតិយោ

[២៨៦] យថារូបេន ខោ គហបតិ មិច្ឆាសង្កប្បេ-ន សមន្នាគតោ អស្សុតវា បុថុជ្ជនោ កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ តថារូបោ តេ មិច្ឆាសង្កប្បោ នត្ថិ ។ អត្ថិ ច ខោ តេ គហបតិ សម្មាសង្កប្បោ ។ តញ្ច បន តេ សម្មាសង្កប្បំ អត្តនិ សមនុបស្សតោ ឋានសោ វេទនា បដិប្បស្សម្ភេយ្យ ។

[២៨៧] យថារូបាយ ខោ គហបតិ មិច្ឆាវាចាយ សមន្នាគតោ អស្សុតវា បុថុជ្ជនោ កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ តថារូបា តេ មិច្ឆាវាចា នត្ថិ ។ អត្ថិ ច ខោ តេ គហបតិ សម្មាវាចា ។ តញ្ច បន តេ សម្មាវាចំ អត្តនិ សមនុបស្សតោ ឋានសោ វេទនា បដិប្បស្សម្ភេយ្យ ។

## សរកានិវគ្គទី ៣

(២៥៦) ម្នាលគហបតី បុថុជ្ជនដែលមិនចេះដឹង ប្រកបដោយមិច្ឆាសង្កប្បៈ មានសភាពយ៉ាងណា លុះរំលាយខន្ធ បន្ទាប់អំពីមរណៈ រមែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក មិច្ឆាសង្កប្បៈ មានសភាពយ៉ាងនោះ មិនមានដល់អ្នកឡើយ ។ ម្នាលគហបតី មួយទៀត សម្មាសង្កប្បៈ ក៏មានដល់អ្នក ។ កាលបើអ្នកពិចារណាឃើញនូវសម្មាសង្កប្បៈនោះ ចំពោះខ្លួន វេទនាទាំងឡាយ គប្បីស្ងប់រម្ងាប់ទៅដោយហេតុដ៏សមគួរ ។

(២៥៧) ម្នាលគហបតី បុថុជ្ជនដែលមិនចេះដឹង ប្រកបដោយមិច្ឆាវាចា មានសភាពយ៉ាងណា លុះរំលាយខន្ធ បន្ទាប់អំពីមរណៈរមែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក មិច្ឆាវាចាមានសភាពយ៉ាងនោះ មិនមានដល់អ្នកឡើយ ។ ម្នាលគហបតី មួយទៀត សម្មាវាចាក៏មានដល់អ្នក ។ កាលបើអ្នកពិចារណាឃើញនូវសម្មាវាចានោះចំពោះខ្លួន វេទនាទាំងឡាយ គប្បីស្ងប់រម្ងាប់ទៅ ដោយហេតុដ៏សមគួរ ។

(២៨៨) យថារូបេន ខោ គហបតិ មិច្ឆាកម្មន្តេន សមន្នាគតោ អស្សុតវា បុថុជ្ជនោ កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ តថារូបោ តេ មិច្ឆាកម្មន្តោ នត្ថិ ។ អត្ថិ ច ខោ តេ គហបតិ សម្មាកម្មន្តោ ។ តញ្ច បន តេ សម្មាកម្មន្តំ អត្តនិ សមនុបស្សតោ ឋានសោ វេទនា បដិប្បស្សម្ភេយ្យ ។

(២៨៩) យថារូបេន ខោ គហបតិ មិច្ឆាអាជីវេន សមន្នាគតោ អស្សុតវា បុថុជ្ជនោ កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ តថារូបោ តេ មិច្ឆាអាជីវោ នត្ថិ ។ អត្ថិ ច ខោ តេ គហបតិ សម្មាអាជីវោ ។ តញ្ច បន តេ សម្មាអាជីវំ អត្តនិ សមនុបស្សតោ ឋានសោ វេទនា បដិប្បស្សម្ភេយ្យ ។

(២៥៨) ម្នាលគហបតី បុថុជ្ជនដែលមិនចេះដឹង ប្រកបដោយមិច្ឆាកម្មន្តៈមានសភាពយ៉ាងណា លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈ ក៏ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក មិច្ឆាកម្មន្តៈមានសភាពយ៉ាងនោះ មិនមានដល់អ្នកឡើយ ។ ម្នាលគហបតី មួយទៀត សម្មាកម្មន្តៈក៏មានដល់អ្នក ។ កាលបើអ្នកពិចារណាឃើញនូវសម្មាកម្មន្តៈនោះ ចំពោះខ្លួន វេទនាទាំងឡាយ គប្បីស្ងប់រម្ងាប់ទៅ ដោយហេតុដ៏សមគួរ ។

(២៥៩) ម្នាលគហបតី បុថុជ្ជនដែលមិនចេះដឹង ប្រកបដោយមិច្ឆាអាជីវៈ មានសភាពយ៉ាងណា លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈ ក៏ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក មិច្ឆាអាជីវៈមានសភាពយ៉ាងនោះ មិនមានដល់អ្នកឡើយ ។ ម្នាលគហបតី មួយទៀត សម្មាអាជីវៈក៏មានដល់អ្នក ។ កាលបើអ្នកពិចារណាឃើញនូវសម្មាអាជីវៈនោះចំពោះខ្លួន វេទនាទាំងឡាយគប្បីស្ងប់រម្ងាប់ទៅ ដោយហេតុដ៏សមគួរ ។

[២៦០] យថារូបេន ខោ គហបតិ មិច្ឆាវាយា-
មេន សមន្នាគតោ អស្សុតវា បុថុជ្ជនោ កាយស្ស
ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ
ឧបបជ្ជតិ តថារូបោ តេ មិច្ឆាវាយាមោ នត្ថិ ។ អត្ថិ
ច ខោ តេ គហបតិ សម្មាវាយាមោ ។ តញ្ច បន
តេ សម្មាវាយាមំ អត្តនិ សមនុបស្សតោ ឋានសោ
វេទនា បដិប្បស្សម្ភេយ្យុំ ។

[២៦១] យថារូបាយ ខោ គហបតិ មិច្ឆាសតិយា
សមន្នាគតោ អស្សុតវា បុថុជ្ជនោ កាយស្ស ភេទា
បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ
តថារូបា តេ មិច្ឆាសតិ នត្ថិ ។ អត្ថិ ច ខោ តេ
គហបតិ សម្មាសតិ ។ តញ្ច បន តេ សម្មា-
សតឹ អត្តនិ សមនុបស្សតោ ឋានសោ វេទនា
បដិប្បស្សម្ភេយ្យុំ ។

## សរកានិវគ្គទី ៣

(៤៦០) ម្នាលគហបតី បុថុជ្ជនដែលមិនចេះដឹង ប្រកបដោយមិច្ឆាវាយាមៈ មានសភាពយ៉ាងណា លុះរំលាងខ្លួន បន្ទាប់អំពីមរណៈ ក៏ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក មិច្ឆាវាយាមៈមានសភាពយ៉ាងនោះ មិនមានដល់អ្នកឡើយ ។ ម្នាលគហបតី មួយទៀត សម្មាវាយាមៈក៏មានដល់អ្នក ។ កាលបើអ្នកពិចារណាឃើញនូវសម្មាវាយាម នោះបំពោះខ្លួន វេទនាទាំងឡាយ គប្បីស្ងប់រម្ងាប់ទៅ ដោយហេតុដ៏សមគួរ ។

(៤៦១) ម្នាលគហបតី បុថុជ្ជនដែលមិនចេះដឹង ប្រកបដោយមិច្ឆាសតិ មានសភាពយ៉ាងណា លុះរំលាងខ្លួន បន្ទាប់អំពីមរណៈ ក៏ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក មិច្ឆាសតិមានសភាពយ៉ាងនោះ មិនមានដល់អ្នកឡើយ ។ ម្នាលគហបតី មួយទៀត សម្មាសតិក៏មានដល់អ្នក ។ កាលបើអ្នកពិចារណាឃើញនូវសម្មាសតិនោះបំពោះខ្លួន វេទនាទាំងឡាយ គប្បីស្ងប់រម្ងាប់ទៅ ដោយហេតុដ៏សមគួរ ។

(២៦២) យថារូបេន ខោ គហបតិ មិច្ឆាសមាធិនា សមន្នាគតោ អស្សុតវា បុថុជ្ជនោ កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ តថារូបោ តេ មិច្ឆាសមាធិ នត្ថិ ។ អត្ថិ ច ខោ តេ គហបតិ សម្មាសមាធិ ។ តញ្ច បន តេ សម្មាសមាធឹ អត្តនិ សមនុបស្សតោ ឋានសោ វេទនា បដិប្បស្សម្ភេយ្យ ។

(២៦៣) យថារូបេន ខោ គហបតិ មិច្ឆាញាណេន សមន្នាគតោ អស្សុតវា បុថុជ្ជនោ កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ តថារូបន្តេ មិច្ឆាញាណំ នត្ថិ ។ អត្ថិ ច ខោ តេ គហបតិ សម្មាញាណំ ។ តញ្ច បន តេ សម្មាញាណំ អត្តនិ សមនុបស្សតោ ឋានសោ វេទនា បដិប្បស្សម្ភេយ្យ ។

(២៦២) ម្នាលគហបតី បុថុជ្ជនដែលមិនចេះដឹង ជាអ្នកប្រកបដោយមិច្ឆាសមាធិមានសភាពយ៉ាងណា លុះដល់រំលាយខ្លួន បន្ទាប់អំពីមរណៈ ក៏ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក មិច្ឆាសមាធិមានសភាពយ៉ាងនោះ មិនមានដល់អ្នកឡើយ ។ ម្នាលគហបតី មួយទៀត សម្មាសមាធិក៏មានដល់អ្នក ។ កាលបើអ្នកពិចារណាឃើញនូវសម្មាសមាធិនោះចំពោះខ្លួន វេទនាទាំងឡាយ គប្បីស្ងប់រម្ងាប់ទៅដោយហេតុដ៏សមគួរ ។

(២៦៣) ម្នាលគហបតី បុថុជ្ជនដែលមិនចេះដឹង ជាអ្នកប្រកបដោយមិច្ឆាញាណ មានសភាពយ៉ាងណា លុះដល់រំលាយខ្លួន បន្ទាប់អំពីមរណៈ ក៏ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក មិច្ឆាញាណមានសភាពយ៉ាងនោះមិនមានដល់អ្នកឡើយ ។ ម្នាលគហបតី មួយទៀត សម្មាញាណក៏មានដល់អ្នក ។ កាលបើអ្នកពិចារណាឃើញនូវសម្មាញាណនោះចំពោះខ្លួន វេទនាទាំងឡាយគប្បីស្ងប់រម្ងាប់ទៅ ដោយហេតុដ៏សមគួរ ។

## សរកានិវគ្គោ តតិយោ

[២៦៤] យថារូបាយ ខោ គហបតិ មិច្ឆាវិមុត្តិយា សមន្នាគតោ អស្សុតវា បុថុជ្ជនោ កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ តថារូបា តេ មិច្ឆាវិមុត្តិ នត្ថិ ។ អត្ថិ ច ខោ តេ គហបតិ សម្មាវិមុត្តិ ។ តញ្ច បន តេ សម្មាវិមុត្តឹ អត្តនិ សមនុបស្សតោ ឋានសោ វេទនា បដិប្បស្សម្ភេយ្យុន្តិ ។

[២៦៥] អថខោ អនាថបិណ្ឌិកស្ស គហបតិស្ស ឋានសោ វេទនា បដិប្បស្សម្ភឹសុ ។ អថខោ អនាថបិណ្ឌិកោ គហបតិ(១) អាយស្មន្តញ្ច សារីបុត្តំ អាយស្មន្តញ្ច អានន្ទំ សកេនេវ ថាលិបាកេន បរិវិសិ ។ អថខោ អនាថបិណ្ឌិកោ គហបតិ អាយស្មន្តំ សារីបុត្តំ ភុត្តាវឹ ឱនីតបត្តបាណឹ អញ្ញតរំ នីចំ អាសនំ គហេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អនាថបិណ្ឌិកំ គហបតឹ អាយស្មា សារីបុត្តោ ឥមាហិ គាថាហិ អនុមោទិ

---

១ ឱ. គហបតិ ឧបសង្កមិត្វា ។

## សរភាណវគ្គទី ៣

[២៦៨] ម្នាលគហបតី បុថុជ្ជនដែលមិនចេះដឹង ជាអ្នកប្រកប ដោយមិច្ឆាវិមុត្តិ មានសភាពយ៉ាងណា លុះដល់រំលាងខ្លួន បន្ទាប់អំពីមរណៈ ក៏ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក មិច្ឆាវិមុត្តិ មានសភាពយ៉ាងនោះមិនមានដល់អ្នកឡើយ ។ ម្នាលគហបតី មួយទៀត សម្មាវិមុត្តិក៏មានដល់អ្នក ។ កាលបើអ្នកពិចារណាឃើញនូវសម្មាវិមុត្តិនោះចំពោះខ្លួន វេទនាទាំងឡាយគប្បីស្ងប់រម្ងាប់ទៅដោយហេតុដ៏សមគួរ ។

[២៦៩] គ្រានោះឯង វេទនារបស់អនាថបិណ្ឌិកគហបតីក៏ស្ងប់រម្ងាប់ដោយមួយរំពេច ។ ទើបអនាថបិណ្ឌិកគហបតីអង្គាសព្រះសារីបុត្តដ៏មានអាយុផង ព្រះអានន្ទដ៏មានអាយុផង ដោយម្ហូបចំណីដ៏ឆ្អិនក្នុងថាសជារបស់ខ្លួន ។ អនាថបិណ្ឌិកគហបតីបានដឹងថា ព្រះសារីបុត្តដ៏មានអាយុឆាន់ហើយ ដាក់ព្រះហស្តចេញពីបាត្រហើយ ក៏កាន់យកនូវអាសនៈដ៏ទាបមួយអង្គុយក្នុងទីដ៏សមគួរ ។ ព្រះសារីបុត្តដ៏មានអាយុអនុមោទនាចំពោះអនាថបិណ្ឌិកគហបតីដែលអង្គុយក្នុងទីសមគួរដោយគាថាទាំងឡាយនេះថា

(២៦៦) យស្ស សទ្ធា តថាគតេ
អចលា សុប្បតិដ្ឋិតា
សីលញ្ច យស្ស កល្យាណំ
អរិយកន្តំ បសំសិតំ ។
សង្ឃេ បសាទោ យស្សត្ថិ
ឧជុភូតញ្ច ទស្សនំ
អទលិទ្ទោតិ តំ អាហុ
អមោឃន្តស្ស ជីវិតំ ។
តស្មា សទ្ធញ្ច សីលញ្ច
បសាទំ ធម្មទស្សនំ
អនុយុញ្ជេថ មេធាវី
សរំ ពុទ្ធានសាសនន្តិ ។

(២៦៧) អថខោ អាយស្មា សារីបុត្តោ អនាថ-
បិណ្ឌិកំ គហបតឹ ឥមាហិ គាថាហិ អនុមោទិត្វា
ឧដ្ឋាយាសនា បក្កាមិ ។

[២៦៦] សទ្ធារបស់បុគ្គលណាមិនញាប់ញ័រ បាន

ដម្កល់ស៊ប់ល្អហើយ ក្នុងព្រះតថាគតផង សីលរបស់បុគ្គល

ណាល្អ ដែលព្រះអរិយៈត្រូវការសរសើរផង ។ សេចក្តី

ជ្រះថ្លា ក្នុងសង្ឃនឹងសេចក្តីឃើញត្រង់មានដល់បុគ្គលណា

ផង អ្នកប្រាជ្ញទាំងឡាយហៅបុគ្គលនោះថា ជាអ្នកមិនខ្សត់

ទាំងជីវិតរបស់បុគ្គលនោះមិនសោះសូន្យឡើយ ។ ហេតុ

នោះ អ្នកមានប្រាជ្ញា កាលបើរលឹកឃើញនូវពុទ្ធសាសនា

ហើយ គួរប្រកបនូវសទ្ធាផង សីលផង សេចក្តីជ្រះថ្លាផង

ការឃើញធម៌ផង ។

[២៦៧] លុះព្រះសារីបុត្តដ៏មានអាយុបានអនុមោទនាដោយគាថា

ទាំងឡាយនេះ ចំពោះអនាថបិណ្ឌិកគហបតីរួចហើយ ក៏ក្រោកចាក

អាសនៈចេញទៅ ។

## សរកានិវគ្គោ តតិយោ

(២៦៨) អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ អានន្ទំ ភគវា ឯតទវោច ហន្ទ កុតោ នុ ត្វំ អានន្ទ អាគច្ឆសិ ទិវា ទិវស្សាតិ ។ អាយស្មតា ភន្តេ សារីបុត្តេន អនាថបិណ្ឌិកោ គហបតិ ឥមិនា ច ឥមិនា ច ឱវាទេន ឱវទិតោតិ ។ បណ្ឌិតោ អានន្ទ សារីបុត្តោ មហាបញ្ញោ អានន្ទ សារីបុត្តោ យត្រ ហិ នាម ចត្តារិ សោតាបត្តិយង្គានិ ទសហាការេហិ វិភជិស្សតីតិ ។

(២៦៩) សាវត្ថីនិទានំ ។ តេន ខោ បន សមយេន អនាថបិណ្ឌិកោ គហបតិ អាពាធិកោ ហោតិ ទុក្ខិតោ ពាឡ្ហគិលានោ ។ អថខោ អនាថបិណ្ឌិកោ គហបតិ អញ្ញតរំ បុរិសំ អាមន្តេសិ ឯហិ ត្វំ អម្ភោ បុរិស យេនាយស្មា អានន្ទោ តេនុបសង្កម ឧបសង្កមិត្វា មម វចនេន អាយស្មតោ អានន្ទស្ស បាទេ សិរសា វន្ទ អនាថបិណ្ឌិកោ ភន្តេ គហបតិ អាពាធិកោ ទុក្ខិតោ ពាឡ្ហគិលានោ

## សរកានិវគ្គទី ៣

(២៦៨) គ្រានោះឯង ព្រះអានន្ទដ៏មានអាយុ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សួរព្រះអានន្ទដ៏មានអាយុដែលអង្គុយក្នុងទីដ៏សមគួរថា ម្នាលអានន្ទ អ្នកទើបមកពីណាហ្ន៎ថ្ងៃម្ល៉េះ ។ បពិត្រព្រះអង្គដ៏ចំរើន ព្រះសារីបុត្តដ៏មានអាយុបានទូន្មានអនាថបិណ្ឌិកគហបតីដោយឱវាទនេះផងនេះផង ។ ម្នាលអានន្ទ សារីបុត្តជាបណ្ឌិត ម្នាលអានន្ទ សារីបុត្តមានប្រាជ្ញាច្រើន ព្រោះសារីបុត្តអាចនឹងចែកនូវសោតាបត្តិយង្គ (អង្គនៃធម៌សម្រាប់បាននូវសោតៈ) ៤ ដោយអាការ ១០ បាន ។

(២៦៩) សាវត្ថីនិទាន ។ សម័យនោះឯង អនាថបិណ្ឌិកគហបតីមានអាពាធ ប្រកបដោយទុក្ខវេទនាឈឺធ្ងន់ ។ គ្រានោះឯង អនាថបិណ្ឌិកគហបតីហៅបុរស១នាក់មកថា ម្នាលបុរសដ៏ចំរើន អ្នកចូរមកនេះ ចូរអ្នកទៅគាល់ព្រះអានន្ទ លុះចូលទៅដល់ហើយ ចូរថ្វាយបង្គំព្រះបាទាព្រះអានន្ទដ៏មានអាយុ ដោយក្បាលតាមពាក្យរបស់ខ្ញុំថា បពិត្រព្រះថេរៈដ៏ចំរើន អនាថបិណ្ឌិកគហបតី មានអាពាធប្រកបដោយទុក្ខវេទនាឈឺធ្ងន់

សោ អាយស្មតោ អានន្ទស្ស បាទេ សិរសា វន្ទតីតិ ។ ឯវញ្ច វទេហិ សាធុ កិរ ភន្តេ អាយស្មា អានន្ទោ យេន អនាថបិណ្ឌិកស្ស គហបតិស្ស និវេសនំ តេនុ-បសង្កមតុ អនុកម្បំ ឧបាទាយាតិ ។ ឯវំ ភន្តេតិ ខោ សោ បុរិសោ អនាថបិណ្ឌិកស្ស គហបតិស្ស បដិស្សុត្វា យេនាយស្មា អានន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ បុរិសោ អាយស្មន្តំ អានន្ទំ ឯតទវោច អនាថបិណ្ឌិកោ ភន្តេ គហបតិ អាពាធិកោ ទុក្ខិតោ ពាឡ្ហគិលានោ ។ សោ អាយស្មតោ អានន្ទស្ស បាទេ សិរសា វន្ទតិ ឯវញ្ច វទេតិ សាធុ កិរ ភន្តេ អាយស្មា អានន្ទោ យេន អនាថបិណ្ឌិកស្ស គហបតិស្ស និវេសនំ តេនុបសង្កមតុ អនុកម្បំ ឧបាទាយាតិ ។ អធិវាសេសិ ខោ អាយស្មា អានន្ទោ តុណ្ហីភាវេន ។

លោកថ្វាយបង្គំព្រះបាទាព្រះអានន្ទដ៏មានអាយុដោយក្បាល ៗ ចូរអ្នកនិយាយយ៉ាងនេះទៀតថា បពិត្រព្រះថេរៈដ៏ចំរើន យើងខ្ញុំសូមអង្វរ សូមព្រះអានន្ទដ៏មានអាយុ និមន្តទៅឯទីលំនៅរបស់អនាថបិណ្ឌិកគហបតីដោយសេចក្តីអនុគ្រោះ ៗ បុរសនោះទទួលស្តាប់អនាថបិណ្ឌិកគហបតីថាបាទលោកដ៏ចំរើន ហើយចូលទៅគាល់ព្រះអានន្ទដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះអានន្ទដ៏មានអាយុ ហើយអង្គុយក្នុងទីដ៏សមគួរ ៗ លុះបុរសនោះអង្គុយក្នុងទីដ៏សមគួរហើយ បាននិយាយនឹងព្រះអានន្ទដ៏មានអាយុយ៉ាងនេះថា បពិត្រព្រះថេរៈដ៏ចំរើន អនាថបិណ្ឌិកគហបតី មានអាពាធប្រកបដោយទុក្ខវេទនាឈឺធ្ងន់ ៗ លោកថ្វាយបង្គំព្រះបាទាព្រះអានន្ទដ៏មានអាយុដោយក្បាល ទាំងនិយាយយ៉ាងនេះទៀតថា បពិត្រព្រះថេរៈដ៏ចំរើន យើងខ្ញុំសូមអង្វរ សូមព្រះអានន្ទដ៏មានអាយុនិមន្តទៅឯទីលំនៅរបស់អនាថបិណ្ឌិកគហបតី ដើម្បីសេចក្តីអនុគ្រោះ ៗ ព្រះអានន្ទដ៏មានអាយុបានទទួលនិមន្តដោយតុណ្ហីភាព ៗ

## សរកានិវគ្គោ តតិយោ

[២៧០] អថខោ អាយស្មា អានន្ទោ បុព្វណ្ហ-
សមយំ និវាសេត្វា បត្តចីវរមាទាយ យេន
អនាថបិណ្ឌិកស្ស និវេសនំ តេនុបសង្កមិ ឧប-
សង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ និសជ្ជ
ខោ អាយស្មា អានន្ទោ អនាថបិណ្ឌិកំ គហបតឹ
ឯតទវោច

[២៧១] កច្ចិ តេ គហបតិ ខមនីយំ កច្ចិ
យាបនីយំ កច្ចិ ទុក្ខា វេទនា បដិក្កមន្តិ នោ
អភិក្កមន្តិ បដិក្កមោសានំ បញ្ញាយតិ នោ អភិក្ក-
មោតិ ។ ន មេ ភន្តេ ខមនីយំ ន យាបនីយំ
ពាឡ្ហា មេ ទុក្ខា វេទនា អភិក្កមន្តិ នោ បដិក្កមន្តិ
អភិក្កមោសានំ បញ្ញាយតិ នោ បដិក្កមោតិ ។

## សរកានិវគ្គទី ៣

[២៧០] គ្រានោះឯង ព្រះអានន្ទដ៏មានអាយុស្លៀកស្បង់ប្រដាប់ដោយបាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅឯទីលំនៅរបស់អនាថបិណ្ឌិកគហបតី លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលទុក ៗ លុះព្រះអានន្ទដ៏មានអាយុគង់ស្ងប់ហើយ បាននិយាយនឹងអនាថបិណ្ឌិកគហបតីយ៉ាងនេះថា

[២៧១] ម្នាលគហបតី សរីរយន្តរបស់អ្នក ល្មមអត់ទ្រាំបានទេឬ ល្មមឲ្យប្រព្រឹត្តទៅបានទេឬ ទុក្ខវេទនាបានស្រាកស្រាន្តទៅ មិនតែឡើងមានតែធូរថយទៅ មិនចំរើនឡើងទេឬ ៗ បពិត្រព្រះថេរៈដ៏ចំរើន សរីរយន្តរបស់ខ្ញុំព្រះករុណា មិនល្មមអត់ទ្រាំបានទេ មិនល្មមឲ្យប្រព្រឹត្តទៅបានទេ ទុក្ខវេទនារបស់ខ្ញុំខ្លាំងណាស់ ចំរើនឡើងមិនធូរស្រាលទេមានតែតែឡើង មិនស្រាកស្រាន្តទេ ៗ

(២៧២) ចតូហិ ខោ គហបតិ ធម្មេហិ សមន្នាគតស្ស អស្សុតវតោ បុថុជ្ជនស្ស ហោតិ ឧត្រាសោ(១) ហោតិ ឆម្ភិតត្តំ ហោតិ សម្បរាយិកំ មរណភយំ ។ កតមេហិ ចតូហិ ។ ឥធ គហបតិ អស្សុតវា បុថុជ្ជនោ ពុទ្ធេ អប្បសាទេន សមន្នាគតោ ហោតិ ។ តញ្ច បនស្ស ពុទ្ធេ អប្បសាទំ អត្តនិ សមនុបស្សតោ ហោតិ ឧត្រាសោ ហោតិ ឆម្ភិតត្តំ ហោតិ សម្បរាយិកំ មរណភយំ ។ បុន ចបរំ គហបតិ អស្សុតវា បុថុជ្ជនោ ធម្មេ អប្បសាទេន សមន្នាគតោ ហោតិ ។ តញ្ច បនស្ស ធម្មេ អប្បសាទំ អត្តនិ សមនុបស្សតោ ហោតិ ឧត្រាសោ ហោតិ ឆម្ភិតត្តំ ហោតិ សម្បរាយិកំ មរណភយំ ។ បុន ចបរំ គហបតិ អស្សុតវា បុថុជ្ជនោ សង្ឃេ អប្បសាទេន សមន្នាគតោ ហោតិ ។ តញ្ច បនស្ស សង្ឃេ អប្បសាទំ អត្តនិ សមនុបស្សតោ ហោតិ ឧត្រាសោ ហោតិ ឆម្ភិតត្តំ ហោតិ សម្បរាយិកំ មរណភយំ ។

---

១ ឱ. ម. ឧត្តាសោ ។

[២៧២] ម្នាលគហបតី សេចក្តីតក់ស្លុតរន្ធត់នឹងសេចក្តីខ្លាចស្លាប់ទៅខាងមុខ តែងមានដល់បុថុជ្ជនជាអ្នកមិនចេះដឹង ប្រកបដោយធម៌ ៤ ។ ធម៌ ៤ តើដូចម្តេចខ្លះ ។ ម្នាលគហបតី បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនចេះដឹង ប្រកបដោយសេចក្តីមិនជ្រះថ្លា ក្នុងព្រះពុទ្ធ ។ កាលបើបុថុជ្ជននោះ ពិចារណាឃើញសេចក្តីមិនជ្រះថ្លា ក្នុងព្រះពុទ្ធនោះក្នុងខ្លួន រមែងកើតសេចក្តីតក់ស្លុតរន្ធត់នឹងសេចក្តីខ្លាចស្លាប់ទៅខាងមុខ ។ ម្នាលគហបតី មួយទៀត បុថុជ្ជនជាអ្នកមិនចេះដឹង ប្រកបដោយសេចក្តីមិនជ្រះថ្លា ក្នុងព្រះធម៌ ។ កាលបើបុថុជ្ជននោះ ពិចារណាឃើញនូវសេចក្តីមិនជ្រះថ្លា ក្នុងព្រះធម៌នោះក្នុងខ្លួន រមែងមានសេចក្តីតក់ស្លុតរន្ធត់នឹងសេចក្តីខ្លាចស្លាប់ទៅខាងមុខ ។ ម្នាលគហបតី មួយទៀត បុថុជ្ជនជាអ្នកមិនចេះដឹង ប្រកបដោយសេចក្តីមិនជ្រះថ្លា ក្នុងព្រះសង្ឃ ។ កាលបើបុថុជ្ជននោះពិចារណា ឃើញនូវសេចក្តីមិនជ្រះថ្លា ក្នុងព្រះសង្ឃនោះក្នុងខ្លួន រមែងមានសេចក្តីតក់ស្លុតរន្ធត់នឹងសេចក្តីខ្លាចស្លាប់ទៅខាងមុខ ។

## សរកានិវគ្គោ តតិយោ

បុន ចបរំ គហបតិ អស្សុតវា បុថុជ្ជនោ ទុស្សីល្យេន សមន្នាគតោ ហោតិ ។ តញ្ច បនស្ស ទុស្សីល្យំ អត្ថិ សមនុបស្សតោ ហោតិ ឧត្រាសោ ហោតិ ឆម្ភិតត្តំ ហោតិ សម្បរាយិកំ មរណភយំ ។ ឥមេហិ ខោ គហបតិ ចតូហិ ធម្មេហិ សមន្នាគតស្ស អស្សុតវតោ បុថុជ្ជនស្ស ហោតិ ឧត្រាសោ ហោតិ ឆម្ភិតត្តំ ហោតិ សម្បរាយិកំ មរណភយំ ។

(២៧៣) ចតូហិ ខោ គហបតិ ធម្មេហិ សមន្នាគតស្ស សុតវតោ អរិយសាវកស្ស ន ហោតិ ឧត្រាសោ ន ហោតិ ឆម្ភិតត្តំ ន ហោតិ សម្បរាយិកំ មរណភយំ ។ កតមេហិ ចតូហិ ។ ឥធ គហបតិ សុតវា អរិយសាវកោ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ ឥតិបិ សោ ភគវា ។បេ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ តញ្ច បនស្ស ពុទ្ធេ អវេច្ចប្បសាទំ អត្ថិ សមនុបស្សតោ ន ហោតិ ឧត្រាសោ

ម្នាលគហបតី មួយទៀត បុថុជ្ជនជាអ្នកមិនចេះដឹង ប្រកបដោយភាពជាបុគ្គលទ្រុស្តសីល ៗ កាលបើបុថុជ្ជនពិចារណាឃើញនូវភាពជាអ្នកទ្រុស្តសីលនោះក្នុងខ្លួន រមែងមានសេចក្តីតក់ស្លុតរន្ធត់នឹងសេចក្តីខ្លាចស្លាប់ទៅខាងមុខ ៗ ម្នាលគហបតី សេចក្តីតក់ស្លុតរន្ធត់នឹងសេចក្តីខ្លាចស្លាប់ទៅខាងមុខ តែងកើតឡើងដល់បុថុជ្ជនជាអ្នកមិនចេះដឹង ប្រកបដោយធម៌ ៤ នេះឯង ៗ

(២៧៣) ម្នាលគហបតី អរិយសាវកជាអ្នកចេះដឹង ប្រកបដោយធម៌ ៤ រមែងមិនតក់ស្លុតមិនរន្ធត់ មិនខ្លាចស្លាប់ទៅខាងមុខទេ ៗ ធម៌ ៤ តើអ្វីខ្លះ ៗ ម្នាលគហបតី អរិយសាវកក្នុងសាសនានេះ ជាអ្នកចេះដឹង ប្រ-កបដោយសេចក្តីជ្រះថ្លាមិនកម្រើក ក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគអង្គនោះ ៗបេ ៗ ជាសាស្តានៃទេវតានឹងមនុស្សទាំងឡាយ ជាព្រះពុទ្ធមានជោគ ដោយហេតុដូច្នេះឯង ៗ កាលបើ អរិយសាវកនោះ ពិចារណាឃើញនូវសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះពុទ្ធនោះក្នុងខ្លួន រមែងមិនតក់ស្លុត

[៣១៨] កបិលវត្ថុនិទាន ។ ព្រះដ៏មានព្រះភាគបានត្រាស់នឹងនន្ទិយសក្កៈដែលគង់ក្នុងទីសមគួរយ៉ាងនេះថា ម្នាលនន្ទិយៈ អរិយសាវកដែលប្រកបដោយធម៌៤ រមែងសម្រេចស្រោតៈ មានធម៌មិនបានធ្លាក់ចុះទៀងតែនឹងត្រាស់ដឹងទៅខាងមុខ ។ ធម៌៤តើដូចម្តេចខ្លះ ។ ម្នាលនន្ទិយៈ អរិយសាវកក្នុងសាសនានេះ ប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគនោះ ។ បេ ។ ជាសាស្តានៃទេវតានឹងមនុស្សទាំងឡាយ ជាព្រះពុទ្ធមានជោគ ដោយហេតុដូច្នេះឯង ។ ក្នុងព្រះធម៌ ។ ក្នុងព្រះសង្ឃ ។ ប្រកបដោយអរិយកន្តសីល ជាសីលមិនដាច់ ។ បេ ។ ប្រព្រឹត្តទៅដើម្បីសមាធិ ។ ម្នាលនន្ទិយៈ អរិយសាវកដែលប្រកបដោយធម៌ទាំង៤នេះឯង រមែងសម្រេចស្រោតៈ មានធម៌មិនបានធ្លាក់ចុះ ទៀងតែនឹងត្រាស់ដឹងទៅខាងមុខ ។

[៣១៩] កបិលវត្ថុនិទាន ។ (ត្រូវសំដែងការចូលគាល់ផងចុះ)។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់នឹងនន្ទិយសក្កៈ ដែលគង់ក្នុងទីសមគួរយ៉ាងនេះថា ម្នាលនន្ទិយៈ អរិយសាវកប្រកបដោយធម៌៤រមែងសម្រេចស្រោតៈ

អវិនិបាតធម្មោ និយតោ សម្ពោធិបរាយណោ ។ កតមេហិ ចតូហិ ។ ឥធ ភិក្ខវេ អរិយសាវកោ ពុទ្ធេ ។ ធម្មេ ។ សង្ឃេ ។ អរិយកន្តេហិ សីលេហិ សមន្នាគតោ ហោតិ អខណ្ឌេហិ ។បេ។ សមាធិសំវត្តនិកេហិ ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ អរិយសាវកោ សោតាបន្នោ ហោតិ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយណោតិ ។

(៣២០) កបិលវត្ថុនិទានំ ។ (ឧបសង្កមនំ កាតព្វំ) ។ ឯកមន្តំ និសិន្នំ ខោ មហានាមំ សក្កំ ភគវា ឯតទវោច ចតូហិ ខោ មហានាម ធម្មេហិ សមន្នាគតោ អរិយសាវកោ សោតាបន្នោ ហោតិ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយណោ ។ កតមេហិ ចតូហិ ។ ឥធ មហានាម អរិយសាវកោ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ ឥតិបិ សោ ភគវា ។បេ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ធម្មេ ។

មានធម៌មិនបានធ្លាក់ចុះ ទៀងតែនឹងត្រាស់ដឹងទៅខាងមុខ ៗ ធម៌ ៤ តើដូចម្តេចខ្លះ ៗ ម្នាលភិក្ខុទាំងឡាយ អរិយសាវក ក្នុងសាសនានេះ (ប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ) ក្នុងព្រះពុទ្ធ ៗ ក្នុងព្រះធម៌ ៗ ក្នុងព្រះសង្ឃ ៗ ប្រកបដោយអរិយកន្តសីល ជាសីលមិនដាច់ ៗ បេ ៗ ប្រព្រឹត្តទៅដើម្បីសមាធិ ៗ ម្នាលភិក្ខុទាំងឡាយ អរិយសាវកដែលប្រកបដោយធម៌ ៤ នេះ រមែងសម្រេចសោតៈ មានធម៌មិនបានធ្លាក់ចុះ ទៀងតែនឹងត្រាស់ដឹងទៅខាងមុខ ៗ

[៣៤០] កបិលវត្ថុនិទាន ៗ (ត្រូវសំដែងការចូលគាល់ផងចុះ) ៗ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់នឹងមហានាមសក្កៈ ដែលគង់ក្នុងទីដ៏សមគួរយ៉ាងនេះថា ម្នាលមហានាម អរិយសាវក ប្រកបដោយធម៌ ៤ រមែងបានសម្រេចសោតៈ មានធម៌មិនបានធ្លាក់ចុះ ទៀងតែនឹងត្រាស់ដឹងទៅខាងមុខ ៗ ធម៌ ៤ តើដូចម្តេចខ្លះ ៗ ម្នាលមហានាម អរិយសាវកក្នុងសាសនានេះប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគនោះ ៗ បេ ៗ ជាសាស្តានៃទេវតានឹងមនុស្សទាំងឡាយ ជាព្រះពុទ្ធដ៏មានព្រះភាគដោយហេតុដូច្នេះឯង ៗ ក្នុងព្រះធម៌ ៗ

សង្ឃេ ។ អរិយកន្តេហិ សីលេហិ សមន្នាគតោ ហោតិ អខណ្ឌេហិ ។ បេ ។ សមាធិសំវត្តនិកេហិ ។ ឥមេហិ ខោ មហានាម ចតូហិ ធម្មេហិ សមន្នាគតោ អរិយសាវកោ សោតាបន្នោ ហោតិ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយណោតិ ។

(៣២១) ចត្តារិមានិ ភិក្ខវេ សោតាបត្តិយង្គានិ ។ កតមានិ ចត្តារិ ។ សប្បុរិសសំសេវោ សទ្ធម្មស្សវនំ យោនិសោមនសិការោ ធម្មានុធម្មប្បដិបត្តិ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ សោតាបត្តិយង្គានីតិ ។

**សគាថកបុញ្ញាភិសន្ទវគ្គោ បញ្ចមោ ។**

## តស្សុទ្ទានំ

អភិសន្ទេន តយោ វុត្តា
ទុវេ មហទ្ធនេន ច
ភិក្ខុ នន្ទិយភទ្ទិយំ
មហានាមេន តេ ទសាតិ ។

គុណព្រះសង្ឃ ។ ប្រកបដោយអរិយកន្តសីល ជាសីលមិនដាច់ ។ បេ ។ ប្រព្រឹត្តទៅដើម្បីសមាធិ ។ ម្នាលមហានាម អរិយសាវក ដែលប្រកបដោយធម៌ ៤ នេះឯង រមែងបានសម្រេចសោតៈ មានធម៌មិនបានធ្លាក់ចុះទៀតនឹងបានត្រាស់ដឹងទៅខាងមុខ ។

[៣៦១] ម្នាលភិក្ខុទាំងឡាយ សោតាបត្តិយង្គនេះមាន ៤ ។ សោតាបត្តិយង្គ ៤ តើដូចម្តេច ។ គឺការសេពគប់សប្បុរស ១ ការស្តាប់ធម៌របស់សប្បុរស ១ ការធ្វើទុកក្នុងចិត្តដោយឧបាយ ១ សេចក្តីប្រតិបត្តិធម៌សមគួរដល់ធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងសោតាបត្តិយង្គ ៤ ។

ចប់ សគាថកបុញ្ញាភិសន្ទវគ្គទី ៥ ។

## ឧទ្ទាននៃសគាថកបុញ្ញាភិសន្ទវគ្គនោះគឺ

សំដែងអំពីស្ទឹងគឺបុណ្យ ៣ សូត្រ អំពីសោតាបន្នបុគ្គលមានទ្រព្យច្រើន ២ សូត្រ ចំពោះភិក្ខុ ១ សូត្រ នន្ទិយសក្កៈ ១ សូត្រ ភទ្ទិយសក្កៈ ១ សូត្រ មហានាម ១ សូត្រ គំរប់ ១០ ទាំងសោតាបត្តិយង្គ ។

## សប្បញ្ញវគ្គោ ឆដ្ឋោ

[៣២២] ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ អរិយសាវកោ សោតាបន្នោ ហោតិ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយនោ ។ កតមេហិ ចតូហិ ។ ឥធ ភិក្ខវេ អរិយសាវកោ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ ឥតិបិ សោ ភគវា ។បេ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ធម្មេ ។ សង្ឃេ ។ អរិយកន្តេហិ សីលេហិ សមន្នាគតោ ហោតិ អខណ្ឌេហិ ។បេ។ សមាធិសំវត្តនិកេហិ ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ អរិយសាវកោ សោតាបន្នោ ហោតិ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយនោតិ ។ ឥទមវោច ភគវា

## សប្បាវគ្គ ទី ៦

(៣៤៤) ម្នាលភិក្ខុទាំងឡាយ អរិយសាវក ដែលប្រកបដោយធម៌ ៤ រមែងសម្រេចសោតៈ មានធម៌មិនបានធ្លាក់ចុះ ទៀងតែនឹងបានត្រាស់ដឹងទៅខាងមុខ ។ ធម៌ ៤ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវក ក្នុងសាសនានេះ ប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគអង្គនោះ ។ បេ ។ ជាសាស្តានៃទេវតានឹងមនុស្សទាំងឡាយ ជាព្រះពុទ្ធមានជោគ ដោយហេតុដូច្នេះឯង ។ ក្នុងព្រះធម៌ ។ ក្នុងព្រះសង្ឃ ។ ប្រកបដោយអរិយកន្តសីល ជាសីលមិនដាច់ ។ បេ ។ ប្រព្រឹត្តទៅដើម្បីសមាធិ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវក ដែលប្រកបដោយធម៌ទាំង ៤ នេះឯង រមែងសម្រេចសោតៈ មានធម៌មិនបានធ្លាក់ចុះ ទៀងតែនឹងបានត្រាស់ដឹងទៅខាងមុខ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់គាថាពន្ធនេះថា

(៣៨៣) យស្ស សទ្ធា តថាគតេ
អចលា សុប្បតិដ្ឋិតា
សីលញ្ច យស្ស កល្យាណំ
អរិយកន្តំ បសំសិតំ ។
សង្ឃេ បសាទោ យស្សត្ថិ
ឧជុភូតញ្ច ទស្សនំ
អទលិទ្ទោតិ តំ អាហុ
អមោឃន្តស្ស ជីវិតំ ។
តស្មា សទ្ធញ្ច សីលញ្ច
បសាទំ ធម្មទស្សនំ
អនុយុញ្ជេថ មេធាវី
សរំ ពុទ្ធាន សាសនន្តិ ។

(៣៨៤) ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ សាវត្ថិយំ វស្សំ វុត្ថោ កបិលវត្ថុំ អនុប្បត្តោ ហោតិ កេនចិទេវ ករណីយេន ។

[៣៤៣] សទ្ធារបស់អ្នកណាមិនញាប់ញ័រ បានដម្កល់មាំក្នុងព្រះតថាគតផង កល្យាណសីលរបស់អ្នកណា ជាសីលដែលព្រះអរិយៈត្រេកអរសរសើរហើយផង ។ សេចក្តីជ្រះថ្លា ក្នុងព្រះសង្ឃផង សេចក្តីឃើញត្រង់ផង មានដល់អ្នកណា បណ្ឌិតទាំងឡាយ ហៅអ្នកនោះថា មិនពាល់ក្រ ជីវិតរបស់អ្នកនោះមិនសោះសូន្យទេ ។ ព្រោះហេតុនោះ កាលបើអ្នកប្រាជ្ញ រលឹកឃើញពុទ្ធសាសនា គប្បីប្រកបនូវសទ្ធាផង សីលផង សេចក្តីជ្រះថ្លាផង ការឃើញធម៌ផង ។

[៣៤៤] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ក៏សម័យនោះឯង មានភិក្ខុមួយរូបនៅចាំវស្សា ទៀបក្រុងសាវត្ថីរួចហើយ បានទៅដល់ក្រុងកបិលព័ស្ដុ ដោយកិច្ចអ្វីមួយ ។

## សប្បញ្ញវគ្គោ ឆដ្ឋោ

អស្សោសុំ ខោ កាបិលវត្ថវា សក្យា អញ្ញតរោ កិរ ភិក្ខុ សាវត្ថិយំ វស្សំ វុត្ថោ កបិលវត្ថុំ អនុប្បត្តោតិ ។ អថខោ កាបិលវត្ថវា សក្យា យេន សោ ភិក្ខុ តេនុបសង្កមឹសុ ឧបសង្កមិត្វា តំ ភិក្ខុំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ កាបិលវត្ថវា សក្យា តំ ភិក្ខុំ ឯតទវោចុំ

(៣៤៨) កច្ចិ ភន្តេ ភគវា អរោគោ ចេវ ពលវា ចាតិ ។ អរោគោ ចេវ អាវុសោ ភគវា ពលវា ចាតិ ។ កច្ចិ បន ភន្តេ សារីបុត្តមោគ្គល្លានា អរោគា ចេវ ពលវន្តោ ចាតិ ។ សារីបុត្តមោគ្គល្លានាបិ ខោ អាវុសោ អរោគា ចេវ ពលវន្តោ ចាតិ ។ កច្ចិ បន ភន្តេ ភិក្ខុសង្ឃោ អរោគោ ច ពលវា ចាតិ ។ ភិក្ខុសង្ឃោបិ ខោ អាវុសោ អរោគោ ច ពលវា ចាតិ ។ អត្ថិ បន តេ ភន្តេ កិញ្ចិ ឥមិនា អន្តរវស្សេន ភគវតោ សម្មុខា សុតំ សម្មុខា បដិគ្គហិតន្តិ ។

ពួកសក្យនៅក្នុងក្រុងកបិលព័ស្ដុបានឮដំណឹងថា ឮថា ភិក្ខុមួយរូបនៅចាំវស្សា ទៀបក្រុងសាវត្ថីរួចហើយមកដល់ក្រុងកបិលព័ស្ដុ ។ គ្រានោះឯង ពួកសក្យនៅក្នុងក្រុងកបិលព័ស្ដុ ក៏ចូលទៅរកភិក្ខុនោះ លុះចូលទៅដល់ ថ្វាយបង្គំភិក្ខុនោះហើយអង្គុយក្នុងទីសមគួរ ។ លុះពួកសក្យនៅក្នុងក្រុងកបិលព័ស្ដុ អង្គុយក្នុងទីសមគួរហើយ បាននិយាយនឹងភិក្ខុនោះយ៉ាងនេះថា

[៣២៤] បពិត្រលោកដ៏ចំរើន ព្រះដ៏មានព្រះភាគ មិនមានព្រះរោគទាំងមានព្រះកាយពលឬទេ ។ ម្នាលអាវុសោទាំងឡាយ ព្រះដ៏មានព្រះភាគ មិនមានព្រះរោគទាំងមានព្រះកាយពលដែរ ។ បពិត្រលោកដ៏ចំរើន ព្រះសារីបុត្តនឹងព្រះមោគ្គល្លាន មិនមានរោគទាំងមានកំឡាំងដែរឬ ។ ម្នាលអាវុសោទាំងឡាយ ព្រះសារីបុត្តនឹងព្រះមោគ្គល្លាន លោកមិនមានរោគទាំងមានកំឡាំងដែរ ។ បពិត្រលោកដ៏ចំរើន ភិក្ខុសង្ឃមិនមានរោគទាំងមានកំឡាំងដែរឬ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុសង្ឃមិនមានរោគទាំងមានកំឡាំងដែរ ។ បពិត្រលោកដ៏ចំរើន ក្នុងចន្លោះវស្សានេះ តើលោកបានស្ដាប់ធម៌ចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគ បានទទួលកិច្ចការអ្វីចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគដែរឬ ។

សម្មុខា មេ តំ អាវុសោ ភគវតោ សុតំ សម្មុខា បដិគ្គហិតំ អប្បេកា តេ ភិក្ខវេ ភិក្ខូ យេ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តិ អថខោ តតោ ពហុតរា ភិក្ខូ យេ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោ-ជនានំ បរិក្ខយា ឱបបាតិកា តត្ថ បរិនិព្ពាយិនោ អនាវត្តិធម្មា អស្មា លោកាតិ ។ អបរំបិ ខោ មេ អាវុសោ ភគវតោ សម្មុខា សុតំ សម្មុខា បដិគ្គហិតំ អប្បេកា តេ ភិក្ខវេ ភិក្ខូ យេ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឱបបាតិកា តត្ថ បរិនិព្ពា-យិនោ អនាវត្តិធម្មា អស្មា លោកា អថខោ តតោ ពហុតរា ភិក្ខូ យេ តិណ្ណំ សញ្ញោជនានំ បរិក្ខយា រាគទោសមោហានំ តនុត្តា សកទាគាមិនោ សកិ-ទេវ ឥមំ លោកំ អាគន្ត្វា ទុក្ខស្សន្តំ ករិស្សន្តីតិ ។

ម្នាលអាវុសោទាំងឡាយ អាត្មាបានស្តាប់ធម៌ចំពោះព្រះភក្ត្រ បានទទួលចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុដែលបានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ក្រៃលែងខ្លួនឯង ក្នុងបច្ចុប្បន្ន ពួកភិក្ខុនោះ មានប្រមាណតិចទេ មានតែពួកភិក្ខុដែលធ្វើសំយោជនៈជាចំណែកខាងក្រោម ៥ ឲ្យអស់រលីង ជាឧបបាតិកៈបរិនិព្វាន ក្នុងទីនោះ ទៀងតែមិនត្រឡប់មកអំពីលោកនោះ ពួកភិក្ខុនុ៎ះឯងទើបមានច្រើនជាង ។ ម្នាលអាវុសោ អាត្មាបានស្តាប់ធម៌ចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគ បានទទួលចំពោះព្រះភក្ត្រនូវព្រះពុទ្ធដីកាដទៃទៀតថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុដែលធ្វើសញ្ញោជនៈជាចំណែកខាងក្រោម ៥ ឲ្យអស់រលីង ជាឧបបាតិកៈ បរិនិព្វានក្នុងទីនោះទៀងតែមិនត្រឡប់អំពីលោកនោះ ពួកនោះមានប្រមាណតិច មានតែពួកភិក្ខុដែលធ្វើឲ្យអស់ត្រឹមតែសញ្ញោជនៈ ៣ ជាសកទាគាមី ព្រោះធ្វើរាគៈ ទោសៈ មោហៈ ឲ្យស្រាលស្តើងនឹងមកកាន់លោកនេះម្តងទៀតហើយធ្វើនូវទីបំផុតនៃទុក្ខបាន ពួកភិក្ខុនោះឯងទើបមានច្រើនជាង ។

## សប្បញ្ញវគ្គោ ឆដ្ឋោ

អបរំបិ ខោ មេ អាវុសោ ភគវតោ សម្មុខា សុតំ សម្មុខា បដិគ្គហិតំ អប្បកា តេ ភិក្ខវេ ភិក្ខូ យេ តិណ្ណំ សញ្ញោជនានំ បរិក្ខយា រាគទោសមោហានំ តនុត្តា សកទាគាមិនោ សកិទេវ ឥមំ លោកំ អាគន្ត្វា ទុក្ខស្សន្តំ ករិស្សន្តិ អថខោ ឯតេ ពហុតរា ភិក្ខូ យេ តិណ្ណំ សញ្ញោជនានំ បរិក្ខយា សោតាបន្នា អវិនិបាតធម្មា និយតា សម្ពោធិបរាយណាតិ ។

(៣២៦) ឯកំ សមយំ ភគវា ពារាណសិយំ វិហរតិ ឥសិបតនេ មិគទាយេ ។ អថខោ ធម្មទិន្នោ ឧបាសកោ បញ្ចហិ ឧបាសកសតេហិ សទ្ធឹ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ធម្មទិន្នោ ឧបាសកោ ភគវន្តំ ឯតទវោច ឱវទតុ នោ ភន្តេ ភគវា អនុសាសតុ នោ ភន្តេ ភគវា យំ អម្ហាកំ អស្ស ទីឃរត្តំ ហិតាយ សុខាយាតិ ។

ម្នាលអាវុសោ អាត្មាបានស្តាប់ធម៌ ចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគ បានទទួលចំពោះព្រះភក្ត្រនូវព្រះពុទ្ធដីកាដទៃទៀតថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុដែលធ្វើឲ្យអស់ត្រឹមសញ្ញោជនៈ ៣ ជាសកទាគាមី ព្រោះធ្វើរាគៈ ទោសៈ មោហៈ ឲ្យស្រាលស្តើងនឹងមកកាន់លោកនេះម្តងទៀត ហើយធ្វើនូវទីបំផុតទុក្ខបាន ពួកភិក្ខុទាំងនុ៎ះមានប្រមាណតិច មានតែពួកភិក្ខុដែលសម្រេចស្រោតៈ ព្រោះអស់សញ្ញោជនៈ ៣ មានធម៌មិនបានធ្លាក់ចុះ ទៀងតែនឹងបានត្រាស់ដឹងទៅខាងមុខ ពួកភិក្ខុនោះឯងទើបមានច្រើនជាង ។

[៣២៦] សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅ ក្នុងឥសិបតនមិគទាយវ័ន ទៀបក្រុងពារាណសី ។ គ្រានោះឯង ឧបាសកឈ្មោះធម្មទិន្នព្រមដោយពួកឧបាសក ៥០០ នាក់ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ បានថ្វាយបង្គំព្រះដ៏មានព្រះភាគរួចអង្គុយក្នុងទីសមគួរ ។ លុះធម្មទិន្នឧបាសកអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគទូន្មានពួកខ្ញុំព្រះអង្គ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគ ប្រៀនប្រដៅពួកខ្ញុំព្រះអង្គនូវធម៌ ដែលឲ្យបានប្រយោជន៍នឹងសេចក្តីសុខដល់យើងខ្ញុំ អស់កាលជាយូរអង្វែង ។

តស្មាតិហ ភេ(១) ធម្មទិន្ន ឯវំ សិក្ខិតព្វំ យេ តេ សុត្តន្តា តថាគតភាសិតា គម្ភីរា គម្ភីរត្ថា លោកុត្តរា សុញ្ញតប្បដិសំយុត្តា តេ កាលេន កាលំ ឧបសម្បជ្ជ វិហរិស្សាមាតិ ។ ឯវញ្ហិ ភេ(២) ធម្មទិន្ន សិក្ខិតព្វន្តិ ។

(៣៤៧) ន ខោ នេតំ ភន្តេ សុករំ អម្ហេហិ បុត្តសម្ពាធសយនំ អជ្ឈាវសន្តេហិ កាសិកចន្ទនំ បច្ចនុភោន្តេហិ មាលាគន្ធវិលេបនំ ធារយន្តេហិ ជាតរូបរជតំ សាទិយន្តេហិ យេ(៣) សុត្តន្តា តថាគតភាសិតា គម្ភីរា គម្ភីរត្ថា លោកុត្តរា សុញ្ញតប្បដិសំយុត្តា តេ កាលេន កាលំ ឧបសម្បជ្ជ វិហរិតុំ តេសន្នោ ភន្តេ ភគវា អម្ហាកំ បញ្ចសុ សិក្ខាបទេសុ ឋិតានំ ឧត្តរឹ ធម្មំ ទេសេតូតិ ។ តស្មាតិហ ភេ ធម្មទិន្ន ឯវំ សិក្ខិតព្វំ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតា ភវិស្សាម ឥតិបិ សោ ភគវា ។បេ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។

---

១ ម. តស្មាតិហ តេ ។ ២ តេ ។ ៣ ឱ. ម. យេ តេ ។

ម្នាលធម្មទិន្ន ព្រោះហេតុដូច្នោះ ក្នុងសាសនានេះ អ្នកទាំងឡាយត្រូវសិក្សាយ៉ាងនេះថា សូត្រណាដែលតថាគតសំដែងហើយ ជាសូត្រមានធម៌ដ៏ជ្រៅ មានអត្ថដ៏ជ្រៅ បំភ្លឺនូវប្រយោជន៍ឲ្យឆ្លងផុតចាកលោក ប្រកបដោយធម៌ដ៏សូន្យចាកកិលេស យើងនឹងបាន (ស្តាប់) សូត្រទាំងនោះតាមកាលដ៏គួរ ។ ម្នាលធម្មទិន្ន ពួកអ្នក ត្រូវសិក្សាយ៉ាងនេះចុះ ។

[៣២៧] បពិត្រព្រះអង្គដ៏ចំរើន ពួកខ្ញុំព្រះអង្គកំពុងនៅគ្រប់គ្រងទីដេកដែលចង្អៀតដោយកូន នៅស្អិតស្អាងខ្លឹមចន្ទន៍ក្នុងដែនកាសី ទ្រទ្រង់កម្រងផ្កា នឹងគ្រឿងក្រអូបនឹងគ្រឿងលាបនឹងត្រេកអរ ទទួលយកនូវមាសប្រាក់ មិនងាយនឹងបានប្រតិបត្តិពួកសូត្រដែលព្រះតថាគតសំដែងហើយ ជាសូត្រមានធម៌ដ៏ជ្រៅ មានអត្ថដ៏ជ្រៅ បំភ្លឺនូវប្រយោជន៍ឲ្យឆ្លងផុតចាកលោក ប្រកបដោយធម៌ដ៏សូន្យចាកកិលេស តាមកាលដ៏គួរនុ៎ះបានទេ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគ ទ្រង់សំដែងធម៌ដល់ពួកយើងខ្ញុំដែលតាំងនៅក្នុងសិក្ខាបទ ៥ នោះឲ្យក្រៃលែងទៅទៀត ។ ម្នាលធម្មទិន្ន ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកទាំងឡាយត្រូវសិក្សាយ៉ាងនេះថា យើងទាំងឡាយនឹងប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគនោះ ។បេ។ ជាសាស្តានៃទេវតានឹងមនុស្សទាំងឡាយ ជាព្រះពុទ្ធមានជោគ ដោយហេតុដូច្នេះឯង ។

## សប្បញ្ញវគ្គោ ឆដ្ឋោ

ធម្មេ ។ សង្ឃេ ។ អរិយកន្តេហិ សីលេហិ សមន្នាគតា ភវិស្សាម អខណ្ឌេហិ ។បេ។ សមាធិសំវត្តនិកេហីតិ ។ ឯវញ្ហិ វោ ធម្មទិន្ន សិក្ខិតព្វន្តិ ។ យានិមានិ ភន្តេ ភគវតា ចត្តារិ សោតាបត្តិយង្គានិ ទេសិតានិ សំវិជ្ជន្តិ(១) តេ ធម្មា អម្ហេសុ មយំ ច តេសុ ធម្មេសុ សន្ទិស្សាម ។ មយញ្ហិ ភន្តេ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតា ឥតិបិ សោ ភគវា ។បេ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ធម្មេ ។ សង្ឃេ ។ អរិយកន្តេហិ សីលេហិ សមន្នាគតា ភវិស្សាម អខណ្ឌេហិ ។បេ។ សមាធិសំវត្តនិកេហីតិ ។ លាភា វោ ធម្មទិន្ន សុលទ្ធំ វោ ធម្មទិន្ន សោតាបត្តិផលំ ធម្មទិន្ន តុម្ហេហិ ព្យាកតន្តិ ។

[៣៤៨] ឯកំ សមយំ ភគវា សក្កេសុ វិហរតិ កបិលវត្ថុស្មឹ និគ្រោធារាមេ ។ តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ ភគវតោ ចីវរកម្មំ ករោន្តិ និដ្ឋិតចីវរោ ភគវា តេមាសច្ចយេន ចារិកំ បក្កមិស្សតីតិ ។ អស្សោសិ ខោ មហានាមោ សក្កោ

---

១ ឱ. ម. សំវិជ្ជន្តេ ។

សប្បញ្ញវគ្គទី ៦

ក្នុងព្រះធម៌ ។ ក្នុងព្រះសង្ឃ ។ ប្រកបដោយអរិយកន្តសីល ជាសីលមិនដាច់ ។បេ។ ប្រព្រឹត្តទៅដើម្បីសមាធិ ។ មាលធម្មទិន្ន អ្នកទាំងឡាយត្រូវសិក្សាយ៉ាងនេះចុះ ។ បពិត្រព្រះអង្គដ៏ចំរើន សោតាបត្តិយង្គទាំង ៤ នេះព្រះដ៏មានព្រះភាគទ្រង់សំដែងហើយ ធម៌ទាំងនោះមានក្នុងពួកយើងខ្ញុំផង ពួកយើងខ្ញុំនឹងឃើញច្បាស់ ក្នុងធម៌ទាំងនោះផង ។ បពិត្រព្រះអង្គដ៏ចំរើន ព្រោះថា ពួកយើងខ្ញុំប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគនោះ ។បេ។ ជាសាស្តានៃទេវតានឹងមនុស្សទាំងឡាយ ជាព្រះពុទ្ធមានជោគដោយហេតុដូច្នេះឯង ។ ក្នុងព្រះធម៌ ។ ក្នុងព្រះសង្ឃ ។ ពួកយើងខ្ញុំប្រកបដោយអរិយកន្តសីល ជាសីលមិនដាច់ ។បេ។ ប្រព្រឹត្តទៅដើម្បីសមាធិ ។ មាលធម្មទិន្ន ជាលាភរបស់ពួកអ្នកហើយ មាលធម្មទិន្ន ពួកអ្នកឈ្មោះថាបានល្អហើយ មាលធម្មទិន្ន ព្រោះពួកអ្នកបានធ្វើឲ្យច្បាស់នូវសោតាបត្តិផលហើយ ។

[៣២៨] សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងនិគ្រោធារាម ទៀបក្រុងកបិលព័ស្តុ ក្នុងដែនសក្កៈ ។ ក៏ក្នុងសម័យនោះឯង ពួកភិក្ខុច្រើនរូបនាំគ្នាធ្វើចីវរថ្វាយព្រះដ៏មានព្រះភាគដោយគិតថា ព្រះដ៏មានព្រះភាគមានចីវរសម្រេចហើយ ព្រះអង្គនឹងស្តេចទៅកាន់ចារិកដោយកាលប្រព្រឹត្តកន្លងទៅនៃខែ ៣ ។ មហានាមសក្កៈបានឮដំណឹងថា

សម្ពហុលា កិរ ភិក្ខូ ភគវតោ ចីវរកម្មំ ករោន្តិ និដ្ឋិតចីវរោ ភគវា តេមាសច្ចយេន ចារិកំ បក្កមិស្សតីតិ ។ អថខោ មហានាមោ សក្កោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ មហានាមោ សក្កោ ភគវន្តំ ឯតទវោច សុតម្មេតំ ភន្តេ សម្ពហុលា កិរ ភិក្ខូ ភគវតោ ចីវរកម្មំ ករោន្តិ និដ្ឋិតចីវរោ ភគវា តេមាសច្ចយេន ចារិកំ បក្កមិស្សតីតិ ។ ន ខោ នេតំ ភន្តេ ភគវតោ សម្មុខា សុតំ សម្មុខា បដិគ្គហិតំ សប្បញ្ញេន ឧបាសកេន សប្បញ្ញោ ឧបាសកោ អាពាធិកោ ទុក្ខិតោ ពាឡ្ហគិលានោ ឱវទិតព្វោតិ ។

(៣២) សប្បញ្ញេន មហានាម ឧបាសកេន សប្បញ្ញោ ឧបាសកោ អាពាធិកោ ទុក្ខិតោ ពាឡ្ហគិលានោ ចតូហិ អស្សាសនីយេហិ ធម្មេហិ អស្សាសេតព្វោ អស្សាសេតាយស្មា អត្ថាយស្មតោ ពុទ្ធេ អវេច្ចប្បសាទោ

ឮថាពួកភិក្ខុច្រើនរូបធ្វើចីវរថ្វាយព្រះដ៏មានព្រះភាគដោយគិតថា ព្រះដ៏មានព្រះភាគមានចីវរសម្រេចហើយ ព្រះអង្គនឹងស្តេចទៅកាន់ចារិកដោយកាលប្រព្រឹត្តកន្លងទៅនៃខែ ៣ ។ លំដាប់នោះ មហានាមសក្កៈក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគរួចគង់ក្នុងទីសមគួរ ។ លុះមហានាមសក្កៈ គង់ក្នុងទីសមគួរហើយ ក្រាបទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គឮដំណឹងនេះថា ឮថា ពួកភិក្ខុច្រើនរូបធ្វើចីវរថ្វាយព្រះដ៏មានព្រះភាគដោយគិតថា ព្រះដ៏មានព្រះភាគមានចីវរសម្រេចហើយ ព្រះអង្គនឹងស្តេចទៅកាន់ចារិកដោយកាលប្រព្រឹត្តកន្លងទៅនៃខែ ៣ ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមិនទាន់បានស្តាប់ធម៌ចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគ មិនទាន់បានទទួលចំពោះព្រះភក្ត្រយ៉ាងនេះថា ឧបាសក ប្រកបដោយប្រាជ្ញា (សម្រេចស្រោតៈ) ដែលមានអាពាធ ដល់នូវទុក្ខវេទនាឈឺធ្ងន់ ត្រូវតែឧបាសកដែលប្រកបដោយប្រាជ្ញាទូន្មានគ្នា ។

[៣៦៩] ម្នាលមហានាម ឧបាសក ដែលប្រកបដោយប្រាជ្ញា មានអាពាធ ដល់នូវទុក្ខវេទនា ឈឺធ្ងន់ ត្រូវតែឧបាសកប្រកបដោយប្រាជ្ញា លួងលោមដោយធម៌ ដែលគួរលួងលោម ៤ យ៉ាងថា អ្នកដ៏មានអាយុ ចូរដកដង្ហើមឲ្យស្រួលចុះ ព្រោះអ្នកដ៏មានអាយុ មានសេចក្តីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធថា

## សប្បញ្ញវគ្គោ ឆដ្ឋោ

ឥតិបិ សោ ភគវា ។ បេ ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ អស្សាសតាយស្មា អត្ថាយស្មតោ ធម្មេ ។ សង្ឃេ ។ អរិយកន្តានិ សីលានិ អខណ្ឌានិ ។ បេ ។ សមាធិសំវត្តនិកានីតិ ។

(៣៣០) សប្បញ្ញេន មហានាម ឧបាសកេន សប្បញ្ញោ ឧបាសកោ អាពាធិកោ ទុក្ខិតោ ពាឡ្ហ-គិលានោ ឥមេហិ ចតូហិ អស្សាសនីយេហិ ធម្មេហិ អស្សាសេត្វា ឯវមស្ស វចនីយោ អត្ថាយស្មតោ មាតាបិតូសុ អបេក្ខាតិ ។ សោ ចេ ឯវំ វទេយ្យ អត្ថិ មេ មាតាបិតូសុ អបេក្ខាតិ ។ សោ ឯវមស្ស វចនីយោ អាយស្មា ខោ មារិសោ មរណធម្មោ សចេ-បាយស្មា មាតាបិតូសុ អបេក្ខំ ករិស្សតិ មរិស្សតេវ នោ ចេបាយស្មា មាតាបិតូសុ អបេក្ខំ ករិស្សតិ មរិស្សតេវ សាធាយស្មា យា តេ មាតាបិតូសុ អបេក្ខា តំ បជហាតិ ។ សោ ចេ ឯវំ វទេយ្យ យា មេ មាតាបិតូសុ អបេក្ខា សា បហីនាតិ ។

សប្បញ្ញវគ្គទី ៦

ព្រះដ៏មានព្រះភាគនោះ ។ បេ ។ ជាសាស្តានៃទេវតានិងមនុស្សទាំងឡាយ ជាព្រះពុទ្ធមានជោគ ដោយហេតុដូច្នេះឯង ។ អ្នកដ៏មានអាយុ ចូរដកដង្ហើមឲ្យស្រួលចុះ ព្រោះអ្នកដ៏មានអាយុ (មានសេចក្តីជ្រះថ្លាមិនញាប់ញ័រ) ក្នុងព្រះធម៌ ។ ក្នុងព្រះសង្ឃ ។ អរិយកន្តសីល ជាសីលមិនដាច់ ប្រព្រឹត្តទៅដើម្បីសមាធិ ។

[៣៣០] ម្នាលមហានាម ឧបាសក ប្រកបដោយប្រាជ្ញា មានអាពាធ ដល់នូវទុក្ខវេទនាឈឺធ្ងន់ ដែលឧបាសកប្រកបដោយប្រាជ្ញាទូន្មានដោយធម៌ ដែលគួរល្អងលោមទាំង៤នេះហើយ ត្រូវនិយាយយ៉ាងនេះថា អ្នកដ៏មានអាយុមានសេចក្តីអាឡោះអាល័យមាតាបិតាឬ ។ បើឧបាសកនោះនិយាយយ៉ាងនេះថា ខ្ញុំនៅមានសេចក្តីអាឡោះអាល័យមាតាបិតាដែរ ។ ត្រូវនិយាយនឹងឧបាសកនោះយ៉ាងនេះថា អ្នកដ៏មានអាយុជាប់ដំពាក់ដោយសេចក្តីស្លាប់ ទៀងតែនឹងស្លាប់ ប្រសិនបើអ្នកដ៏មានអាយុនៅជាប់អាឡោះអាល័យនឹងមាតាបិតា អ្នកដ៏មានអាយុគង់តែនឹងស្លាប់ បើទុកជាអ្នកដ៏មានអាយុមិនអាឡោះអាល័យនឹងមាតាបិតា អ្នកដ៏មានអាយុគង់តែនឹងស្លាប់ដែរ សូមឲ្យអ្នកដ៏មានអាយុលះបង់សេចក្តីអាឡោះអាល័យរបស់អ្នកក្នុងមាតាបិតានោះចេញ ។ បើឧបាសកនោះនិយាយយ៉ាងនេះថា ខ្ញុំលះបង់សេចក្តីអាឡោះអាល័យក្នុងមាតាបិតានោះរួចហើយ ។

[៣៣១] សោ ឯវមស្ស វចនីយោ អត្ថិ បនាយស្មតោ បុត្តទារេសុ អបេក្ខាតិ ។ សោ ចេ ឯវំ វទេយ្យ អត្ថិ មេ បុត្តទារេសុ អបេក្ខាតិ ។ សោ ឯវមស្ស វចនីយោ អាយស្មា ខោ មារិសោ មរណធម្មោ សចេបាយស្មា បុត្តទារេសុ អបេក្ខំ ករិស្សតិ មរិស្សតេវ នោ ចេបាយស្មា បុត្តទារេសុ អបេក្ខំ ករិស្សតិ មរិស្សតេវ សាធាយស្មា យា តេ បុត្តទារេសុ អបេក្ខា តំ បជហាតិ ។ សោ ចេ ឯវំ វទេយ្យ យា មេ បុត្តទារេសុ អបេក្ខា សា បហីនាតិ ។

[៣៣២] សោ ឯវមស្ស វចនីយោ អត្ថិ បនាយស្មតោ មានុសកេសុ បញ្ចសុ កាមគុណេសុ អបេក្ខាតិ ។ សោ ចេ ឯវំ វទេយ្យ អត្ថិ មេ មានុសកេសុ បញ្ចសុ កាមគុណេសុ អបេក្ខាតិ ។ សោ ឯវមស្ស វចនីយោ មានុសកេហិ ខោ អាវុសោ កាមេហិ ទិព្វា កាមា អភិក្កន្តតរា ច បណីតតរា ច

[៣៣១] ត្រូវនិយាយនឹងឧបាសកនោះយ៉ាងនេះថា អ្នកដ៏មានអាយុមានសេចក្តីអាឡោះអាល័យក្នុងបុត្តនឹងភរិយាដែរឬ ។ បើឧបាសកនោះនិយាយយ៉ាងនេះថា ខ្ញុំនៅមានសេចក្តីអាឡោះអាល័យក្នុងបុត្តនឹងភរិយាដែរ ។ ត្រូវនិយាយនឹងឧបាសកនោះយ៉ាងនេះថា អ្នកដ៏មានអាយុជាប់ជំពាក់នឹងសេចក្តីស្លាប់ហើយទៀងតែនឹងស្លាប់ បើទុកជាអ្នកដ៏មានអាយុនៅមានសេចក្តីអាឡោះអាល័យក្នុងបុត្តនឹងភរិយា អ្នកដ៏មានអាយុគង់តែនឹងស្លាប់ បើអ្នកដ៏មានអាយុមិនមានសេចក្តីអាឡោះអាល័យក្នុងបុត្តនឹងភរិយា អ្នកដ៏មានអាយុគង់តែនឹងស្លាប់ សូមអ្នកដ៏មានអាយុលះសេចក្តីអាឡោះអាល័យក្នុងបុត្តនឹងភរិយារបស់អ្នកនោះចេញ ។ បើឧបាសកនោះនិយាយយ៉ាងនេះថា ខ្ញុំបានលះសេចក្តីអាឡោះអាល័យក្នុងបុត្តនឹងភរិយានោះចេញហើយ ។

[៣៣២] ត្រូវនិយាយនឹងឧបាសកនោះយ៉ាងនេះថា អ្នកដ៏មានអាយុ មានសេចក្តីអាឡោះអាល័យក្នុងកាមគុណទាំង ៥ ជារបស់មនុស្សដែរឬ ។ បើឧបាសកនោះនិយាយយ៉ាងនេះថា ខ្ញុំមានសេចក្តីអាឡោះអាល័យក្នុងកាមគុណទាំង ៥ ជារបស់មនុស្សដែរ ។ ត្រូវនិយាយនឹងឧបាសកនោះយ៉ាងនេះថា ម្នាលអាវុសោ កាមជាទិព្វជារបស់ប្រសើរផង ឧត្តមផង ជាងកាមទាំងឡាយ ជារបស់មនុស្ស

សាធាយស្មា មានុសកេហិ កាមេហិ ចិត្តំ វុដ្ឋាបេត្វា ចាតុម្មហារាជិកេសុ ទេវេសុ ចិត្តំ អធិមោចេហីតិ ។ សោ ចេ ឯវំ វទេយ្យ មានុសកេហិ មេ កាមេហិ ចិត្តំ វុដ្ឋិតំ ចាតុម្មហារាជិកេសុ ទេវេសុ ចិត្តំ អធិមោចិតន្តិ ។

(៣៣៣) សោ ឯវមស្ស វចនីយោ ចាតុមហារាជិកេហិ ខោ អាវុសោ ទេវេហិ តាវតឹសា ទេវា អភិក្កន្តតរា ច បណីតតរា ច សាធាយស្មា ចាតុម្មហារាជិកេហិ ទេវេហិ ចិត្តំ វុដ្ឋាបេត្វា តាវតឹសេសុ ទេវេសុ ចិត្តំ អធិមោចេហីតិ ។ សោ ចេ ឯវំ វទេយ្យ ចាតុម្មហារាជិកេហិ មេ ទេវេហិ ចិត្តំ វុដ្ឋិតំ តាវតឹសេសុ ទេវេសុ ចិត្តំ អធិមោចិតន្តិ ។ សោ ឯវមស្ស វចនីយោ តាវតឹសេហិ ខោ អាវុសោ ទេវេហិ យាមា ទេវា ។ តុសិតា ទេវា ។ និម្មានរតី ទេវា ។ បរនិម្មិតវសវត្តិនោ ទេវា ។

សូមអ្នកដ៏មានអាយុធ្វើចិត្តឲ្យផុតចាកកាមជារបស់មនុស្សចេញ ហើយចូរដម្កល់ចិត្តក្នុងពួកទេវតាស្ថានចាតុម្មហារាជិកចុះ ។ បើឧបាសកនោះនិយាយយ៉ាងនេះថា ចិត្តរបស់ខ្ញុំផុតស្រឡះចាកកាមជារបស់មនុស្សហើយ ខ្ញុំបានដម្កល់ចិត្តទុកក្នុងពួកទេវតាជាន់ចាតុម្មហារាជិកហើយ ។

(៣៣៣) ត្រូវនិយាយនឹងឧបាសកនោះយ៉ាងនេះថា ម្នាលអាវុសោ ពួកតាវត្តិង្សទេវតារុងរឿងជាង ឧត្តមជាងពួកចាតុម្មហារាជិកទេវតា សូមអ្នកដ៏មានអាយុដកចិត្តអំពីពួកចាតុម្មហារាជិកទេវតាចេញ ហើយដំកល់ចិត្តក្នុងពួកតាវត្តិង្សទេវតាចុះ ។ បើឧបាសកនោះនិយាយយ៉ាងនេះថា ចិត្តខ្ញុំបានដកផុតអំពីពួកចាតុម្មហារាជិកទេវតាហើយ ខ្ញុំបានដម្កល់ចិត្តទុកក្នុងពួកតាវត្តិង្សទេវតាហើយ ។ ត្រូវនិយាយនឹងឧបាសកនោះយ៉ាងនេះថា ម្នាលអាវុសោ ពួកយាមទេវតារុងរឿងជាងពួកតាវត្តិង្សទេវតា ។ ពួកតុសិតទេវតា ។ ពួកនិម្មានរតីទេវតា ។ ពួកបរនិម្មិតវសវត្តីទេវតា ។

បរនិម្មិតវសវត្តីហិ ខោ អាវុសោ ទេវេហិ ព្រហ្មលោកោ អភិក្កន្តតរោ ច បណីតតរោ ច សាធាយស្មា បរនិម្មិតវសវត្តីហិ ទេវេហិ ចិត្តំ វុដ្ឋាបេត្វា ព្រហ្មលោកេ ចិត្តំ អធិមោចេហីតិ ។ សោ ចេ ឯវំ វទេយ្យ បរនិម្មិតវសវត្តីហិ មេ ទេវេហិ ចិត្តំ វុដ្ឋិតំ ព្រហ្មលោកេ ចិត្តំ អធិមោចិតន្តិ ។

(៣៣៤) សោ ឯវមស្ស វចនីយោ ព្រហ្មលោកោបិ ខោ អាវុសោ អនិច្ចោ អទ្ធុវោ សក្កាយបរិយាបន្នោ សាធាយស្មា ព្រហ្មលោកា ចិត្តំ វុដ្ឋាបេត្វា សក្កាយនិរោធេ ចិត្តំ ឧបសំហរាតិ(១) ។ សោ ចេ ឯវំ វទេយ្យ ព្រហ្មលោកា មេ ចិត្តំ វុដ្ឋិតំ សក្កាយនិរោធេ ចិត្តំ ឧបសំហតន្តិ(២) ។ ឯវំ វិមុត្តចិត្តស្ស(៣) ខោ មហានាម ឧបាសកស្ស វស្សសត(៤) វិមុត្តចិត្តេន ភិក្ខុនា ន កិញ្ចិ នានាករណំ វទាមិ យទិទំ វិមុត្តិយា វិមុត្តិន្តិ ។

---

១ ឱ. ម. ឧបសំហរាហីតិ ។ ២ ឧបសំហរាមីតិ ។ ៣ ឯវំ វុត្តស្ស ។ ៤ ឱ. ម. អាសវា ។

ម្នាលអាវុសោ ព្រហ្មលោករុងរឿងជាង ឧត្តមជាងពួកបរនិម្មិតវសវត្តីទេវតា សូមអ្នកដ៏មានអាយុដកចិត្តអំពីពួកបរនិម្មិតវសវត្តីទេវតាចេញ ហើយដម្កល់ចិត្តក្នុងព្រហ្មលោកវិញ ។ បើឧបាសកនោះនិយាយយ៉ាងនេះថា ចិត្តខ្ញុំបានដកចេញអំពីពួកបរនិម្មិតវសវត្តីទេវតាហើយ បានដម្កល់ចិត្តក្នុងព្រហ្មលោកហើយ ។

[៣៣៤] គួរនិយាយនឹងឧបាសកនោះយ៉ាងនេះថា ម្នាលអាវុសោ សូម្បីព្រហ្មលោកក៏នៅតែមិនទៀង មិនខ្ជាប់ខ្ជួន រាប់បញ្ចូលជាសក្កាយ សូមអ្នកដ៏មានអាយុដកចិត្តអំពីព្រហ្មលោកចេញ ហើយប្រមូលចិត្តទៅក្នុងព្រះនិព្វានជាទីរំលត់នូវសក្កាយវិញ ។ បើឧបាសកនោះនិយាយយ៉ាងនេះថា ចិត្តខ្ញុំដកផុតអំពីព្រហ្មលោកហើយ ចិត្តខ្ញុំក៏បានប្រមូលទៅក្នុងព្រះនិព្វានជាទីរំលត់សក្កាយហើយ ។ ម្នាលមហានាម ចិត្តដែលរួចស្រឡះដោយអរហត្តផលវិមុត្តិរបស់ឧបាសក ដែលមានចិត្តរួចស្រឡះហើយយ៉ាងនេះ តថាគតមិនពោលថា មានការផ្សេងគ្នាអំពីភិក្ខុដែលមានចិត្តរួចស្រឡះហើយ អស់ ១០០ ឆ្នាំ នោះតែបន្តិចសោះឡើយ ។

## សប្បញ្ញវគ្គោ ឆដ្ឋោ

(៣៣៥) ចត្តារោមេ ភិក្ខវេ ធម្មា ភាវិតា ពហុលីកតា សោតាបត្តិផលសច្ឆិកិរិយាយ សំវត្តន្តិ ។ កតមេ ចត្តារោ ។ សប្បុរិសសំសេវោ សទ្ធម្មស្សវនំ យោនិសោមនសិការោ ធម្មានុធម្មប្បដិបត្តិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ ធម្មា ភាវិតា ពហុលីកតា សោតាបត្តិផលសច្ឆិកិរិយាយ សំវត្តន្តីតិ ។

(៣៣៦) ចត្តារោមេ ភិក្ខវេ ធម្មា ភាវិតា ពហុលីកតា សកទាគាមិផលសច្ឆិកិរិយាយ សំវត្តន្តីតិ ។

(៣៣៧) អនាគាមិផលសច្ឆិកិរិយាយ សំវត្តន្តីតិ ។

(៣៣៨) អរហត្តផលសច្ឆិកិរិយាយ សំវត្តន្តីតិ ។

(៣៣៩) បញ្ញាបដិលាភាយ សំវត្តន្តីតិ ។

(៣៤០) បញ្ញាវុឌ្ឍិយា សំវត្តន្តីតិ ។

(៣៤១) បញ្ញាវេបុល្លាយ សំវត្តន្តីតិ ។

សប្បញ្ញវគ្គោ ឆដ្ឋោ ។

## សប្បញ្ញវគ្គទី ៦

[៣៣៥] ម្នាលភិក្ខុទាំងឡាយធម៌ ៤ នេះដែលបុគ្គលបានចំរើនហើយធ្វើឲ្យច្រើនហើយ តែងប្រព្រឹត្តទៅ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ។ ធម៌៤ តើដូចម្តេចខ្លះ ។ គឺការសេពគប់សប្បុរស ១ ការស្តាប់ធម៌របស់សប្បុរស ១ ការធ្វើទុកក្នុងចិត្តដោយឧបាយ ១ សេចក្តីប្រតិបត្តិនូវធម៌សមគួរតាមធម៌ ១ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង៤ នេះឯង ដែលបុគ្គលបានចំរើនហើយ ធ្វើឲ្យច្រើនហើយ តែងប្រព្រឹត្តទៅដើម្បីធ្វើឲ្យច្បាស់នូវសោតាបត្តិផល ។

[៣៣៦] ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង៤នេះ ដែលបុគ្គលបានចំរើនហើយ ធ្វើឲ្យច្រើនហើយ តែងប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ។

[៣៣៧] តែងប្រព្រឹត្តទៅ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ។

[៣៣៨] តែងប្រព្រឹត្តទៅ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល ។

[៣៣៩] តែងប្រព្រឹត្តទៅ ដើម្បីបាននូវប្រាជ្ញា ។

[៣៤០] តែងប្រព្រឹត្តទៅ ដើម្បីចំរើនប្រាជ្ញា ។

[៣៤១] តែងប្រព្រឹត្តទៅ ដើម្បីធ្វើប្រាជ្ញាឲ្យធំទូលាយ ។

ចប់ សប្បញ្ញវគ្គទី ៦ ។

តស្សុទ្ទានំ

សគាថកំ វស្សវុត្ថំ

ធម្មទិន្នគិលាយនំ (១)

ចតុរោ ផលា បដិលាភោ

វុឌ្ឍិ វេបុល្លតាយ ចាតិ ។

---

១ ឱ. ម ធម្មទិន្នទិគិលាយនំ ។

## ឧទ្ទាននៃសប្បញ្ញាវគ្គនោះគឺ

ពុទ្ធភាសិតប្រកបដោយគាថា ១ សូត្រ ភិក្ខុចាំវស្សារួចហើយ ១ សូត្រ ធម្មទិន្នឧបាសក ១ សូត្រ ឧបាសកឈឺ ១ សូត្រ ផល ៤ សូត្រ ការបានប្រាជ្ញា ១ សូត្រ ចំរើនប្រាជ្ញា ១ សូត្រ ការធ្វើប្រាជ្ញាឲ្យធំទូលាយ ១ សូត្រ ។

# មហាបញ្ញាវគ្គោ សត្តមោ

[៣៨២] មហាបញ្ញតាយ សំវត្តន្តីតិ ។

[៣៨៣] បុថុប្បញ្ញតាយ សំវត្តន្តីតិ ។

[៣៨៤] វិបុលប្បញ្ញតាយ សំវត្តន្តីតិ ។

[៣៨៥] គម្ភីរប្បញ្ញតាយ សំវត្តន្តីតិ ។

[៣៨៦] អប្បមត្តប្បញ្ញតាយ សំវត្តន្តីតិ ។

[៣៨៧] ភូរិប្បញ្ញតាយ សំវត្តន្តីតិ ។

[៣៨៨] បញ្ញាពាហុល្លាយ សំវត្តន្តីតិ ។

[៣៨៩] សីឃប្បញ្ញតាយ សំវត្តន្តីតិ ។

[៣៩០] លហុប្បញ្ញតាយ(១) សំវត្តន្តីតិ ។

[៣៩១] ហាសប្បញ្ញតាយ សំវត្តន្តីតិ ។

[៣៩២] ជវនប្បញ្ញតាយ សំវត្តន្តីតិ ។

[៣៩៣] តិក្ខប្បញ្ញតាយ សំវត្តន្តីតិ ។

[៣៩៤] និព្វេធិកប្បញ្ញតាយ(២) សំវត្តន្តីតិ ។

---

១ ឱ. ពហុលប្បញ្ញតាយ ។ ២ ឱ. និព្វេធិកាយ ។

## មហាបញ្ញាវគ្គ ទី ៣

[៣៤២] (ធម៌ ៤) តែងប្រព្រឹត្តទៅ ដើម្បីប្រាជ្ញាច្រើន ។

[៣៤៣] ប្រព្រឹត្តទៅ ដើម្បីប្រាជ្ញាដ៏ក្រាស់ ។

[៣៤៤] ប្រព្រឹត្តទៅ ដើម្បីប្រាជ្ញាដ៏ធំទូលាយ ។

[៣៤៥] ប្រព្រឹត្តទៅ ដើម្បីប្រាជ្ញាដ៏ជ្រៅ ។

[៣៤៦] ប្រព្រឹត្តទៅ ដើម្បីប្រាជ្ញាប្រមាណមិនបាន ។

[៣៤៧] ប្រព្រឹត្តទៅ ដើម្បីប្រាជ្ញាដូចជាផែនដី ។

[៣៤៨] ប្រព្រឹត្តទៅ ដើម្បីប្រាជ្ញាដ៏ច្រើន ។

[៣៤៩] ប្រព្រឹត្តទៅ ដើម្បីប្រាជ្ញាឆាប់ ។

[៣៥០] ប្រព្រឹត្តទៅ ដើម្បីប្រាជ្ញារហ័ស ។

[៣៥១] ប្រព្រឹត្តទៅ ដើម្បីប្រាជ្ញាដ៏រីករាយ ។

[៣៥២] ប្រព្រឹត្តទៅ ដើម្បីប្រាជ្ញាជាទីស្ទុះទៅ ។

[៣៥៣] ប្រព្រឹត្តទៅ ដើម្បីប្រាជ្ញាដ៏ក្លៀវក្លា ។

[៣៥៤] ប្រព្រឹត្តទៅ ដើម្បីប្រាជ្ញាដ៏មោះមុត ។

កតមេ ចត្តារោ ។ សប្បុរិសសំសេវោ សទ្ធម្មស្ស-វនំ យោនិសោមនសិការោ ធម្មានុធម្មប្បដិបត្តិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ ធម្មា ភាវិតា ពហុ-លីកតា និព្វេធិកប្បញ្ញតាយ សំវត្តន្តីតិ ។

មហា ញ្ញាវគ្គោ សត្តមោ ។

## តស្សុទ្ទានំ

មហាបុថុវិបុលគម្ភីរ-
អប្បមត្តភូរិពាហុល-
សីឃលហុហាសជវន-
តិក្ខនិព្វេធិកាយ ចាតិ ។

សោតាបត្តិសំយុត្តំ សមត្តំ ។

ធម៌ ៤ ដូចម្ដេចខ្លះ ។ គឺការសេពគប់សប្បុរស ១ ការស្ដាប់ធម៌របស់សប្បុរស ១ ការធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា ១ សេចក្ដីប្រតិបត្តិធម៌សមគួរតាមធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៤ នេះឯង ដែលបុគ្គលបានចំរើនហើយ ធ្វើឲ្យច្រើនហើយ តែងប្រព្រឹត្តទៅដើម្បីបានប្រាជ្ញាដ៏មោះមុត ។

ចប់ មហាបញ្ញាវគ្គ ទី ៧ ។

## ឧទ្ទាននៃមហាបញ្ញាវគ្គនោះគឺ

ធម៌ ៤ ប្រព្រឹត្តទៅ ដើម្បីប្រាជ្ញាធំ ១ ប្រាជ្ញាក្រាស់ ១ ប្រាជ្ញាទូលាយ ១ ប្រាជ្ញាជ្រៅ ១ ប្រាជ្ញាប្រមាណមិនបាន ១ ប្រាជ្ញាដូចផែនដី ១ ប្រាជ្ញាច្រើន ១ ប្រាជ្ញាឆាប់ ១ ប្រាជ្ញារហ័ស ១ ប្រាជ្ញារីករាយ ១ ប្រាជ្ញាជាទីស្ទុះទៅ ១ ប្រាជ្ញាក្លៀវក្លា ១ ប្រាជ្ញាដ៏មោះមុត ១ ។

ចប់ សោតាបត្តិសំយុត្ត ។

# សច្ចសំយុត្តំ

## សមាធិវគ្គោ បឋមោ

(៣៥៥) សាវត្ថិនិទានំ ។ សមាធឹ ភិក្ខវេ ភាវេថ ។ សមាហិតោ ភិក្ខវេ ភិក្ខុ យថាភូតំ បជានាតិ ។ កិញ្ច យថាភូតំ បជានាតិ ។ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ អយំ ទុក្ខសមុទយោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យថាភូតំ បជានាតិ ។ សមាធឹ ភិក្ខវេ ភាវេថ ។ សមាហិតោ ភិក្ខវេ ភិក្ខុ យថាភូតំ បជានាតិ ។ តស្មាតិហ ភិក្ខវេ ឥទំ ទុក្ខន្តិ យោគោ ករណីយោ អយំ ទុក្ខសមុទយោតិ យោគោ ករណីយោ អយំ ទុក្ខនិរោធោតិ យោគោ ករណីយោ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យោគោ ករណីយោតិ ។

# សច្ចសំយុត្ត

## សមាធិវគ្គ ទី ១

[៣៥៥] សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរចំរើនសមាធិ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលមានចិត្តដំកល់នឹង រមែងដឹងច្បាស់តាមសេចក្តីពិត ។ ចុះដឹងច្បាស់នូវអ្វីតាមសេចក្តីពិត ។ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខ ។ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាហេតុជាទីកើតឡើងនៃទុក្ខ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទីរលត់ទុក្ខ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរចំរើននូវសមាធិ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលមានចិត្តដំកល់នឹង រមែងដឹងច្បាស់តាមសេចក្តីពិត ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរធ្វើសេចក្តីព្យាយាមថា នេះជាទុក្ខ គួរធ្វើសេចក្តីព្យាយាមថា នេះជាហេតុជាទីកើតឡើងនៃទុក្ខ គួរធ្វើសេចក្តីព្យាយាមថា នេះជាទីរលត់ទុក្ខ គួរធ្វើសេចក្តីព្យាយាមថា នេះជាបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ ។

[៣៩៦] បដិសល្លានេ ភិក្ខវេ យោគមាបជ្ជថ ។ បដិសល្លីនោ ភិក្ខវេ ភិក្ខុ យថាភូតំ បជានាតិ ។ កិញ្ច យថាភូតំ បជានាតិ ។ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ អយំ ទុក្ខសមុទយោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យថាភូតំ បជានាតិ ។ បដិសល្លានេ ភិក្ខវេ យោគមាបជ្ជថ ។ បដិសល្លីនោ ភិក្ខវេ ភិក្ខុ យថាភូតំ បជានាតិ ។ តស្មាតិហ ភិក្ខវេ ឥទំ ទុក្ខន្តិ យោគោ ករណីយោ អយំ ទុក្ខសមុទយោតិ យោគោ ករណីយោ អយំ ទុក្ខនិរោធោតិ យោគោ ករណីយោ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យោគោ ករណីយោតិ ។

[៣៩៧] យេ ហិ កេចិ ភិក្ខវេ អតីតមទ្ធានំ កុលបុត្តា សម្មា អគារស្មា អនគារិយំ បព្វជិំសុ

[៣៩៦] ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរប្រកបនូវសេចក្តីព្យាយាម ក្នុងការពួនសម្ងំ (ក្នុងផលសមាបត្តិ) ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលពួនសម្ងំ រមែងដឹងច្បាស់តាមសេចក្តីពិត ។ ចុះដឹងច្បាស់នូវអ្វីតាមសេចក្តីពិត ។ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាហេតុជាទីកើតឡើងនៃទុក្ខ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទីរលត់ទុក្ខ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរប្រកបនូវសេចក្តីព្យាយាម ក្នុងការពួនសម្ងំ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលពួនសម្ងំនៅជាប្រក្រតី រមែងដឹងច្បាស់តាមសេចក្តីពិត ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរធ្វើសេចក្តីព្យាយាមថា នេះជាទុក្ខ គួរធ្វើសេចក្តីព្យាយាមថា នេះជាហេតុជាទីកើតឡើងនៃទុក្ខ គួរធ្វើសេចក្តីព្យាយាមថា នេះជាទីរលត់ទុក្ខ គួរធ្វើសេចក្តីព្យាយាមថា នេះជាបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ ។

[៣៩៧] ម្នាលភិក្ខុទាំងឡាយ ពួកកុលបុត្តឯណានីមួយ ក្នុងកាលដែលកន្លងទៅហើយ បានចេញចាកផ្ទះចូលកាន់ផ្នួស ដោយប្រពៃ

## សមាធិវគ្គោ បឋមោ

សព្វេ តេ ចតុន្នំ អរិយសច្ចានំ យថាភូតំ អភិ-
សមយាយ ។ យេ ហិ កេចិ ភិក្ខវេ អនាគត-
មទ្ធានំ កុលបុត្តា សម្មា អគារស្មា អនគារិយំ
បព្វជិស្សន្តិ សព្វេ តេ ចតុន្នំ អរិយសច្ចានំ យថា-
ភូតំ អភិសមយាយ ។ យេ ហិ កេចិ ភិក្ខវេ
ឯតរហិ កុលបុត្តា សម្មា អគារស្មា អនគារិយំ
បព្វជន្តិ សព្វេ តេ ចតុន្នំ អរិយសច្ចានំ យថាភូតំ
អភិសមយាយ ។ កតមេសំ ចតុន្នំ ។ ទុក្ខស្ស
អរិយសច្ចស្ស ទុក្ខសមុទយស្ស អរិយសច្ចស្ស
ទុក្ខនិរោធស្ស អរិយសច្ចស្ស ទុក្ខនិរោធគាមិនីបដិ-
បទាយ អរិយសច្ចស្ស ។ យេ ហិ កេចិ ភិក្ខវេ
អតីតមទ្ធានំ កុលបុត្តា សម្មា អគារស្មា អន-
គារិយំ បព្វជឹសុ បព្វជិស្សន្តិ បព្វជន្តិ សព្វេ តេ
ឥមេសំយេវ ចតុន្នំ អរិយសច្ចានំ យថាភូតំ អភិ-
សមយាយ ។ តស្មាតិហ ភិក្ខវេ ឥទំ ទុក្ខន្តិ
យោគោ ករណីយោ ។បេ។ អយំ ទុក្ខនិរោធ-
គាមិនីបដិបទាតិ យោគោ ករណីយោតិ ។

## សមាធិវគ្គទី ១

កុលបុត្តទាំងអស់នោះ (រមែងប្រាថ្នា) ដើម្បីត្រាស់ដឹងនូវអរិយសច្ចទាំង ៤ ប្រការតាមសេចក្តីពិត ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្តទាំងឡាយឯណានីមួយ ក្នុងកាលជាអនាគតនឹងចេញចាកផ្ទះចូលកាន់ផ្នួស ដោយប្រពៃ កុលបុត្តទាំងអស់នោះ (រមែងប្រាថ្នា) ដើម្បីត្រាស់ដឹងនូវអរិយសច្ចទាំង ៤ ប្រការតាមសេចក្តីពិត ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្តទាំងឡាយឯណានីមួយ ក្នុងកាលឥឡូវនេះ ចេញចាកផ្ទះចូលកាន់ផ្នួស ដោយប្រពៃ កុលបុត្តទាំងអស់នោះ ( រមែងប្រាថ្នា ) ដើម្បីត្រាស់ដឹងនូវអរិយសច្ច ៤ ប្រការ តាមសេចក្តីពិត ។ អរិយសច្ច ៤ ប្រការគឺអ្វីខ្លះ ។ គឺទុក្ខអរិយសច្ច ១ ទុក្ខសមុទយអរិយសច្ច ១ ទុក្ខនិរោធអរិយសច្ច ១ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច១។ ម្នាលភិក្ខុទាំងឡាយ កុលបុត្តទាំងឡាយឯណានីមួយក្នុងកាលជាអតីត បានចេញចាកផ្ទះចូលកាន់ផ្នួស ដោយប្រពៃ បួសហើយ (ក្តី) នឹងបួស (ក្តី) បួសឥឡូវនេះ (ក្តី) កុលបុត្តទាំងអស់នោះ (រមែងប្រាថ្នា) ដើម្បីត្រាស់ដឹងនូវអរិយសច្ចទាំង ៤ ប្រការ នេះឯង តាមសេចក្តីពិត ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរធ្វើសេចក្តីព្យាយាមថា នេះជាទុក្ខ ។ បេ ។ គួរធ្វើសេចក្តីព្យាយាមថា នេះជាបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ ។

(៣៥៨) យេ ហិ កេចិ ភិក្ខវេ អតីតមទ្ធានំ កុលបុត្តា សម្មា អគារស្មា អនគារិយំ បព្វជិតា យថាភូតំ អភិសមេសុំ សព្វេ តេ ចត្តារិ អរិយសច្ចានិ យថាភូតំ អភិសមេសុំ ។ យេ ហិ កេចិ ភិក្ខវេ អនាគតមទ្ធានំ កុលបុត្តា សម្មា អគារស្មា អនគារិយំ បព្វជិតា យថាភូតំ អភិសមេស្សន្តិ សព្វេ តេ ចត្តារិ អរិយសច្ចានិ យថាភូតំ អភិសមេស្សន្តិ ។ យេ ហិ កេចិ ភិក្ខវេ ឯតរហិ កុលបុត្តា សម្មា អគារស្មា អនគារិយំ បព្វជិតា យថាភូតំ អភិសមេន្តិ សព្វេ តេ ចត្តារិ អរិយសច្ចានិ យថាភូតំ អភិសមេន្តិ ។ កតមានិ ចត្តារិ ។ ទុក្ខំ អរិយសច្ចំ ទុក្ខសមុទយោ អរិយសច្ចំ ទុក្ខនិរោធោ អរិយសច្ចំ ទុក្ខនិរោធគាមិនីបដិបទា អរិយសច្ចំ ។ យេ ហិ កេចិ ភិក្ខវេ អតីតមទ្ធានំ កុលបុត្តា សម្មា អគារស្មា អនគារិយំ បព្វជិតា យថាភូតំ អភិសមេសុំ អភិសមេស្សន្តិ អភិសមេន្តិ

(៣៩៨) ម្នាលភិក្ខុទាំងឡាយ កុលបុត្តទាំងឡាយឯណានីមួយ ក្នុងកាលជាអតីត ចេញចាកផ្ទះចូលកាន់ផ្នួសដោយប្រពៃ បានត្រាស់ដឹងតាមសេចក្ដីពិតហើយ កុលបុត្តទាំងអស់នោះ បានត្រាស់ដឹងនូវអរិយសច្ចទាំង ៤ ប្រការ តាមសេចក្ដីពិត ។ ម្នាលភិក្ខុទាំងឡាយ ពួកកុលបុត្តឯណានីមួយ ក្នុងកាលជាអនាគតនឹងចេញចាកផ្ទះចូលកាន់ផ្នួសដោយប្រពៃ នឹងត្រាស់ដឹងតាមសេចក្ដីពិត ពួកកុលបុត្តទាំងអស់នោះនឹងត្រាស់ដឹងនូវអរិយសច្ចទាំង ៤ ប្រការ តាមសេចក្ដីពិត ។ ម្នាលភិក្ខុទាំងឡាយ ពួកកុលបុត្តឯណានីមួយ ក្នុងកាលឥឡូវនេះ ចេញចាកផ្ទះចូលកាន់ផ្នួសដោយប្រពៃ រមែងត្រាស់ដឹងតាមសេចក្ដីពិត ពួកកុលបុត្តទាំងអស់នោះ រមែងត្រាស់ដឹងនូវអរិយសច្ចទាំង ៤ ប្រការ តាមសេចក្ដីពិត ។ អរិយសច្ចទាំង៤ គឺអ្វីខ្លះ។ គឺទុក្ខអរិយសច្ច ១ ទុក្ខសមុទយអរិយសច្ច ១ ទុក្ខនិរោធអរិយសច្ច ១ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ១ ។ ម្នាលភិក្ខុទាំងឡាយ ពួកកុលបុត្តឯណានីមួយ ក្នុងកាលជាអតីត បានចេញចាកផ្ទះចូលកាន់ផ្នួស ដោយប្រពៃ បានត្រាស់ដឹងហើយនឹងត្រាស់ដឹង រមែងត្រាស់ដឹងតាមសេចក្ដីពិត

សព្វេ តេ ឥមានិ ចត្តារិ អរិយសច្ចានិ យថាភូតំ អភិសមេន្តិ ។ តស្មាតិហ ភិក្ខវេ ឥទំ ទុក្ខន្តិ យោគោ ករណីយោ ។ បេ ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យោគោ ករណីយោតិ ។

[១៥៩] យេ ហិ កេចិ ភិក្ខវេ អតីតមទ្ធានំ សមណា វា ព្រាហ្មណា វា យថាភូតំ អភិសម្ពុជ្ឈឹសុ សព្វេ តេ ចត្តារិ អរិយសច្ចានិ យថាភូតំ អភិសម្ពុជ្ឈឹសុ ។ យេ ហិ កេចិ ភិក្ខវេ អនាគតមទ្ធានំ សមណា វា ព្រាហ្មណា វា យថាភូតំ អភិសម្ពុជ្ឈិស្សន្តិ សព្វេ តេ ចត្តារិ អរិយសច្ចានិ យថាភូតំ អភិសម្ពុជ្ឈិស្សន្តិ ។ យេ ហិ កេចិ ភិក្ខវេ ឯតរហិ សមណា វា ព្រាហ្មណា វា យថាភូតំ អភិសម្ពុជ្ឈន្តិ សព្វេ តេ ចត្តារិ អរិយសច្ចានិ យថាភូតំ អភិសម្ពុជ្ឈន្តិ ។ កតមានិ ចត្តារិ ។ ទុក្ខំ អរិយសច្ចំ ។ បេ ។ ទុក្ខនិរោធគាមិនីបដិបទា

ពួកកុលបុត្តទាំងអស់នោះ រមែងត្រាស់ដឹងនូវអរិយសច្ចទាំង ៤ នេះឯង តាមសេចក្តីពិត ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរធ្វើសេចក្តីព្យាយាមថា នេះជាទុក្ខ ។ បេ ។ គួរធ្វើសេចក្តីព្យាយាមថា នេះជាបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ ។

[៣៩៩] ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ឯណានីមួយ ក្នុងកាលជាអតីត ត្រាស់ដឹងតាមសេចក្តីពិតហើយ ពួកសមណៈឬព្រាហ្មណ៍ ទាំងនោះ បានត្រាស់ដឹងនូវអរិយសច្ចទាំង ៤ ប្រការ តាមសេចក្តីពិត ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ឯណាមួយ ក្នុងកាលជាអនាគតនឹងត្រាស់ដឹងតាមសេចក្តីពិត ពួកសមណៈឬព្រាហ្មណ៍ទាំងអស់នោះ នឹងត្រាស់ដឹងនូវអរិយសច្ចទាំង ៤ ប្រការ តាមសេចក្តីពិត ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ឯណានីមួយ ក្នុងកាលឥឡូវនេះ រមែងត្រាស់ដឹងតាមសេចក្តីពិត ពួកសមណៈឬព្រាហ្មណ៍ទាំងអស់នោះ រមែងត្រាស់ដឹងនូវអរិយសច្ចទាំង ៤ ប្រការ តាមសេចក្តីពិត ។ អរិយសច្ចទាំង ៤ គឺអ្វីខ្លះ ។ គឺទុក្ខអរិយសច្ច ១ ។ បេ ។ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ១ ។

អរិយសច្ចំ យេ ហិ កេចិ ភិក្ខវេ អតីតមទ្ធានំ សមណា វា ព្រាហ្មណា វា យថាភូតំ អភិសម្ពុជ្ឈឹសុ អភិសម្ពុជ្ឈិស្សន្តិ អភិសម្ពុជ្ឈន្តិ សព្វេ តេ ឥមានិ ចត្តារិ អរិយសច្ចានិ យថាភូតំ អភិសម្ពុជ្ឈន្តិ ។ តស្មាតិហ ភិក្ខវេ ឥទំ ទុក្ខន្តិ យោគោ ករណីយោ ។ បេ ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យោគោ ករណីយោតិ ។

[៣៦០] យេ ហិ កេចិ ភិក្ខវេ អតីតមទ្ធានំ សមណា វា ព្រាហ្មណា វា យថាភូតំ អភិសម្ពុទ្ធំ បកាសេសុំ សព្វេ តេ ចត្តារិ អរិយសច្ចានិ យថាភូតំ អភិសម្ពុទ្ធំ បកាសេសុំ ។ យេ ហិ កេចិ ភិក្ខវេ អនាគតមទ្ធានំ សមណា វា ព្រាហ្មណា វា យថាភូតំ អភិសម្ពុទ្ធំ បកាសេស្សន្តិ សព្វេ តេ ចត្តារិ អរិយសច្ចានិ យថាភូតំ អភិសម្ពុទ្ធំ បកាសេស្សន្តិ ។ យេ ហិ កេចិ ភិក្ខវេ ឯតរហិ សមណា វា ព្រាហ្មណា វា យថាភូតំ អភិសម្ពុទ្ធំ បកាសេន្តិ សព្វេ តេ ចត្តារិ អរិយសច្ចានិ យថាភូតំ អភិសម្ពុទ្ធំ បកាសេន្តិ ។ កតមានិ ចត្តារិ ។

ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ឯណានីមួយ ក្នុងកាលជាអតីត ត្រាស់ដឹងហើយនឹងត្រាស់ដឹង រមែងត្រាស់ដឹងតាមសេចក្តីពិត ពួកសមណៈឬព្រាហ្មណ៍ទាំងអស់នោះ រមែងត្រាស់ដឹងនូវអរិយសច្ចទាំង ៤ នេះឯង តាមសេចក្តីពិត ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរធ្វើសេចក្តីព្យាយាមថា នេះជាទុក្ខ ។បេ។ គួរធ្វើសេចក្តីព្យាយាមថា នេះជាបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ ។

(៣៦០) ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ឯណានីមួយ ក្នុងកាលជាអតីត បានប្រកាសនូវការត្រាស់ដឹងតាមសេចក្តីពិតហើយ ពួកសមណៈឬព្រាហ្មណ៍ទាំងអស់នោះ បានប្រកាសនូវការត្រាស់ដឹងនូវអរិយសច្ចទាំង ៤ ប្រការ តាមសេចក្តីពិត ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ឯណានីមួយ ក្នុងកាលជាអនាគត នឹងប្រកាសនូវសេចក្តីត្រាស់ដឹង តាមសេចក្តីពិត ពួកសមណៈឬព្រាហ្មណ៍ទាំងអស់នោះ នឹងប្រកាសនូវការត្រាស់ដឹងនូវអរិយសច្ចទាំង៤ ប្រការ តាមសេចក្តីពិត ។ ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ឯណានីមួយ ក្នុងកាលឥឡូវនេះ ប្រកាសនូវការត្រាស់ដឹង តាមសេចក្តីពិត ពួកសមណៈឬព្រាហ្មណ៍ទាំងអស់នោះ រមែងប្រកាសនូវការត្រាស់ដឹងនូវអរិយសច្ចទាំង ៤ ប្រការ តាមសេចក្តីពិត ។ អរិយសច្ចទាំង ៤ គឺអ្វីខ្លះ ។

ទុក្ខំ អរិយសច្ចំ ។ បេ ។ ទុក្ខនិរោធគាមិនីបដិបទា អរិយសច្ចំ ។ យេ ហិ កេចិ ភិក្ខវេ អតីតមទ្ធានំ សមណា វា ព្រាហ្មណា វា យថាភូតំ អភិសម្ពុទ្ធំ បកាសេសុំ បកាសេស្សន្តិ បកាសេន្តិ សព្វេ តេ ឥមានិ ចត្តារិ អរិយសច្ចានិ យថាភូតំ អភិសម្ពុទ្ធំ បកាសេសុំ បកាសេស្សន្តិ បកាសេន្តិ ។ តស្មា-តិហ ភិក្ខវេ ឥទំ ទុក្ខន្តិ យោគោ ករណីយោ ។ បេ ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យោគោ ករណីយោតិ ។

[៣៦១] មា ភិក្ខវេ បាបកេ អកុសលេ វិតក្កេ វិតក្កេថ (១) ។ សេយ្យថីទំ ។ កាមវិតក្កំ ព្យាបាទ-វិតក្កំ វិហឹសាវិតក្កំ ។ តំ កិស្ស ហេតុ ។ នេតេ ភិក្ខវេ វិតក្កា អត្ថសញ្ហិតា នាទិព្រហ្មចរិយកា ន និព្វិទាយ ន វិរាគាយ ន និរោធាយ ន ឧបសមាយ ន អភិញ្ញាយ ន សម្ពោធាយ ន និព្វានាយ សំវត្តន្តិ ។

១ ឱ. ម. វិតក្កេយ្យាថ ។

សមាធិវគ្គទី ១

គឺទុក្ខអរិយសច្ច ១ ។ បេ ។ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ១ ។ ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ឯណានីមួយ ក្នុងកាលជាអតីត ប្រកាសហើយនឹងប្រកាស ប្រកាសនូវការត្រាស់ដឹង តាមសេចក្តីពិត ពួកសមណៈឬព្រាហ្មណ៍ទាំងអស់នោះ បានប្រកាសហើយ នឹងប្រកាស រមែងប្រកាសនូវការត្រាស់ដឹង នូវអរិយសច្ចទាំង ៤ នេះ តាមសេចក្តីពិត ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ក្នុងសាសនានេះ គួរធ្វើសេចក្តីព្យាយាមថា នេះជាទុក្ខ ។ បេ ។ គួរធ្វើសេចក្តីព្យាយាមថា នេះជាបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ ។

[៣៦១] ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំត្រិះរិះនូវវិតក្កៈជាអកុសលដ៏លាមក ។ វិតក្កៈគឺអ្វីខ្លះ ។ គឺកាមវិតក្កៈ១ ព្យាបាទវិតក្កៈ១ វិហឹសាវិតក្កៈ ១ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា វិតក្កៈទាំងនុ៎ះ មិនមែនប្រកបដោយប្រយោជន៍ ជាអាទិព្រហ្មចរិយធម៌ មិនប្រព្រឹត្តទៅដើម្បីនឿយណាយ មិនប្រព្រឹត្តទៅដើម្បីប្រាសចាកតម្រេកមិនប្រព្រឹត្តទៅដើម្បីរលត់ទុក្ខ មិនប្រព្រឹត្តទៅដើម្បីស្ងប់រម្ងាប់ មិនប្រព្រឹត្តទៅដើម្បីដឹងច្បាស់ មិនប្រព្រឹត្តទៅដើម្បីត្រាស់ដឹង មិនប្រព្រឹត្តដើម្បីនិព្វាន ។

វិតក្កាន្តា(១) ច ខោ តុម្ហេ ភិក្ខវេ ឥទំ ទុក្ខន្តិ វិតក្កេយ្យាថ អយំ ទុក្ខសមុទយោតិ វិតក្កេយ្យាថ អយំ ទុក្ខនិរោធោតិ វិតក្កេយ្យាថ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ វិតក្កេយ្យាថ ។ តំ កិស្ស ហេតុ ។ ឯតេ ភិក្ខវេ វិតក្កា អត្ថសញ្ហិតា ឯតេ អាទិព្រហ្មចរិយកា ឯតេ និព្វិទាយ វិរាគាយ និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តន្តិ ។ តស្មាតិហ ភិក្ខវេ ឥទំ ទុក្ខន្តិ យោគោ ករណីយោ ។ បេ ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យោគោ ករណីយោតិ ។

(៣៦២) មា ភិក្ខវេ បាបកំ អកុសលំ ចិត្តំ ចិន្តេថ(២) សស្សតោ លោកោតិ វា អសស្សតោ លោកោតិ វា អន្តវា លោកោតិ វា អនន្តវា លោកោតិ វា តំ ជីវំ តំ សរីរន្តិ វា អញ្ញំ ជីវំ អញ្ញំ សរីរន្តិ វា ហោតិ តថាគតោ បរំ មរណាតិ វា

---

១ ឱ វិតក្កេន្តា ។ ២ ឱ. ចិន្តេយ្យាថ ។

ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយត្រិះរិះ គួរត្រិះរិះថា នេះជាទុក្ខ គួរត្រិះរិះថា នេះជាហេតុជាទីកើតឡើងនៃទុក្ខ គួរត្រិះរិះថា នេះជាទីរលត់ទុក្ខ គួរត្រិះរិះថា នេះជាបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះវិតក្កៈទាំងនុ៎ះ ប្រកបដោយប្រយោជន៍ វិតក្កៈទាំងនុ៎ះជាអាទិព្រហ្មចរិយធម៌ វិតក្កៈទាំងនុ៎ះ ប្រព្រឹត្តទៅដើម្បីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីរលត់ទុក្ខ ដើម្បីសេចក្ដីស្ងប់រម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានោះ គួរធ្វើសេចក្ដីព្យាយាមថា នេះជាទុក្ខ ។ បេ ។ គួរធ្វើសេចក្ដីព្យាយាមថា នេះជាបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ ។

[៣៦២] ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំនឹកដោយចិត្តជាអកុសលដ៏លាមកថា លោកទៀងដូច្នេះក្ដី លោកមិនទៀងដូច្នេះក្ដី លោកមានទីបំផុតដូច្នេះក្ដី លោកមិនមានទីបំផុតដូច្នេះក្ដី ជីវិតនោះក៏គឺសរីរៈនោះដូច្នេះក្ដី ជីវិតដទៃសរីរៈដទៃដូច្នេះក្ដី សត្វស្លាប់ទៅកើតទៀតក្ដី

## សមាធិវគ្គោ បឋមោ

ន ហោតិ តថាគតោ បរំ មរណាតិ វា ហោតិ ច ន ច ហោតិ តថាគតោ បរំ មរណាតិ វា នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ វា ។ តំ កិស្ស ហេតុ ។ នេសា ភិក្ខវេ ចិន្តា អត្ថសញ្ហិតា នាទិព្រហ្មចរិយកា ន និព្វិទាយ ន វិរាគាយ ន និរោធាយ ន ឧបសមាយ ន អភិញ្ញាយ ន សម្ពោធាយ ន និព្វានាយ សំវត្តតិ ។ ចិន្តេន្តា ច ខោ តុម្ហេ ភិក្ខវេ ឥទំ ទុក្ខន្តិ ចិន្តេយ្យាថ អយំ ទុក្ខសមុទយោតិ ចិន្តេយ្យាថ អយំ ទុក្ខនិរោធោតិ ចិន្តេយ្យាថ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ ចិន្តេយ្យាថ ។ តំ កិស្ស ហេតុ ។ ឯសា ភិក្ខវេ ចិន្តា អត្ថសញ្ហិតា ឯសា អាទិព្រហ្មចរិយកា ឯសា និព្វិទាយ វិរាគាយ និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ។ តស្មាតិហ ភិក្ខវេ ឥទំ ទុក្ខន្តិ យោគោ ករណីយោ ។បេ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យោគោ ករណីយោតិ ។

## សមាធិវគ្គទី ១

សត្វស្លាប់ទៅមិនកើតទៀតក្តី សត្វស្លាប់ទៅកើតទៀតក៏មាន មិនកើតទៀតក៏មាន ដូច្នេះក្តី សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះក្តី ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា គំនិតនុ៎ះមិនមែនប្រកបដោយប្រយោជន៍ មិនមែនជាអាទិព្រហ្មចរិយធម៌ មិនប្រព្រឹត្តទៅដើម្បីនឿយណាយ មិនប្រព្រឹត្តទៅដើម្បីប្រាសចាកតម្រេក មិនប្រព្រឹត្តទៅដើម្បីរលត់ទុក្ខ មិនប្រព្រឹត្តទៅដើម្បីស្ងប់រម្ងាប់ មិនប្រព្រឹត្តទៅដើម្បីដឹងច្បាស់ មិនប្រព្រឹត្តទៅដើម្បីត្រាស់ដឹង មិនប្រព្រឹត្តទៅដើម្បីនិព្វាន ។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយគិត គួរគិតថា នេះជាទុក្ខ គួរគិតថា នេះជាហេតុជាទីកើតឡើងនៃទុក្ខ គួរគិតថា នេះជាទីរលត់ទុក្ខ គួរគិតថា នេះជាបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា គំនិតនុ៎ះប្រកបដោយប្រយោជន៍ គំនិតនុ៎ះជាអាទិព្រហ្មចរិយធម៌ គំនិតនុ៎ះប្រព្រឹត្តទៅដើម្បីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីរលត់ទុក្ខ ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរធ្វើសេចក្តីព្យាយាមថា នេះជាទុក្ខ ។ បេ ។ គួរធ្វើសេចក្តីព្យាយាមថា នេះជាបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ ។

(៣៦៣) មា ភិក្ខវេ វិគ្គាហិកកថំ កថេថ (១) ន ត្វំ ឥមំ ធម្មវិនយំ អាជានាសិ អហំ ឥមំ ធម្មវិនយំ អាជានាមិ កឹ ត្វំ ឥមំ ធម្មវិនយំ អាជានិស្សសិ មិច្ឆាបដិបន្នោ ត្វមសិ អហមស្មិ សម្មាបដិបន្នោ បុរេ វចនីយំ បច្ឆា អវច បច្ឆា វចនីយំ បុរេ អវច សហិតំ មេ អសហិតន្តេ អធិចិណ្ណន្តេ វិបរាវត្តំ អារោបិតោ តេ វាទោ ចរវាទប្បមោក្ខាយ និគ្គហិតោសិ និព្វេឋេហិ វា សចេ បហោសីតិ ។ តំ កិស្ស ហេតុ ។ នេសា ភិក្ខវេ កថា អត្ថសញ្ហិតា នាទិព្រហ្មចរិយកា ន និព្វិទាយ ន វិរាគាយ ន និរោធាយ ន ឧបសមាយ ន អភិញ្ញាយ ន សម្ពោធាយ ន និព្វានាយ សំវត្តតិ ។ កថេន្តា ច ខោ តុម្ហេ ភិក្ខវេ ឥទំ ទុក្ខន្តិ កថេយ្យាថ អយំ ទុក្ខសមុទយោតិ កថេយ្យាថ អយំ ទុក្ខនិរោធោតិ កថេយ្យាថ

---

១ ឱ. ម. កថេយ្យាថ ។

(៣៦៣) ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំពោលពាក្យប្រកាន់ផ្សេងគ្នាថា លោកមិនចេះធម្មវិន័យនេះទេ ខ្ញុំទើបចេះធម្មវិន័យនេះ លោកនឹងចេះនូវធម្មវិន័យនេះដូចម្តេចបាន លោកជាអ្នកប្រតិបត្តិខុស ខ្ញុំទើបជាអ្នកប្រតិបត្តិត្រូវ ពាក្យដែលគេត្រូវនិយាយមុន លោកត្រឡប់ជានិយាយក្រោយវិញ ពាក្យដែលត្រូវនិយាយក្រោយ លោកត្រឡប់ជានិយាយមុនវិញ ពាក្យរបស់ខ្ញុំប្រកបដោយប្រយោជន៍ ពាក្យរបស់លោកមិនប្រកបដោយប្រយោជន៍ទេ ពាក្យដ៏យូរលោកប្រព្រឹត្តមកហើយ សំដីរបស់លោក ខ្ញុំបានលើកចោលហើយ លោកជាមនុស្សត្រូវខ្ញុំសង្កត់សង្កិនហើយ ត្រូវការដោះស្រាយនូវសំដីរបស់ជនដទៃ ឬបើលោកអាចចូរលោកដោះស្រាយឲ្យរួចខ្លួនចុះ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា ពាក្យនោះ មិនប្រកបដោយប្រយោជន៍ មិនមែនជាអាទិព្រហ្មចរិយធម៌ មិនមែនប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ មិនប្រព្រឹត្តទៅដើម្បីប្រាសចាកតម្រេក មិនប្រព្រឹត្តទៅដើម្បីរំលត់ទុក្ខ មិនប្រព្រឹត្តទៅដើម្បីស្ងប់រម្ងាប់ មិនប្រព្រឹត្តទៅដើម្បីដឹងច្បាស់ មិនប្រព្រឹត្តទៅដើម្បីត្រាស់ដឹង មិនប្រព្រឹត្តទៅដើម្បីនិព្វាន ។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយពោល គួរពោលថា នេះជាទុក្ខ គួរពោលថា នេះជាហេតុជាទីកើតឡើងនៃទុក្ខ គួរពោលថា នេះជាទីរំលត់ទុក្ខ

## សមាធិវគ្គោ បឋមោ

អយំ ទុក្ខនិរោធគាមិនីបដិបទាតិ ។ បេ ។ យោគោ ករណីយោតិ ។

[៣៦៤] មា ភិក្ខវេ អនេកវិហិតំ តិរច្ឆានកថំ កថេថ (១) ។ សេយ្យថីទំ ។ រាជកថំ ចោរកថំ មហាមត្តកថំ សេនាកថំ ភយកថំ យុទ្ធកថំ អន្នកថំ បានកថំ វត្ថកថំ សយនកថំ មាលាកថំ គន្ធកថំ ញាតិកថំ យានកថំ គាមកថំ និគមកថំ នគរកថំ ជនបទកថំ ឥត្ថីកថំ បុរិសកថំ សុរាកថំ វិសិខាកថំ កុម្ភដ្ឋានកថំ បុព្វបេតកថំ នានត្តកថំ លោកក្ខាយិកំ សមុទ្ទក្ខាយិកំ ឥតិភវាភវកថំ ឥតិ វា ។ តំ កិស្ស ហេតុ ។ នេសា ភិក្ខវេ កថា អត្ថសញ្ហិតា នាទិព្រហ្មចរិយកា ន និព្វិទាយ ន វិរាគាយ ន និរោធាយ ន ឧបសមាយ

---

១ ឱ. ម. កថេយ្យាថ ។

## សមាធិវគ្គទី ១

គួរពោលថា នេះជាបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ ។ បេ ។ គួរធ្វើសេចក្តីព្យាយាម ។

[៣៦៤] ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំពោលពាក្យតិរច្ឆានកថាច្រើនប្រការ ។ តិរច្ឆានកថា គឺអ្វីខ្លះ ។ គឺនិយាយអំពីស្តេច និយាយអំពីចោរ និយាយអំពីមហាមាត្យ និយាយអំពីសេនា និយាយអំពីភ័យ និយាយអំពីចម្បាំង និយាយអំពីគ្រឿងស៊ី និយាយអំពីគ្រឿងផឹក និយាយអំពីសំពត់ និយាយអំពីទីដេក និយាយអំពីកម្រងផ្កា និយាយអំពីគ្រឿងក្រអូប និយាយអំពីញាតិ និយាយអំពីយាន និយាយអំពីស្រុក និយាយអំពីនិគម និយាយអំពីនគរ និយាយអំពីជនបទ និយាយអំពីស្រី និយាយអំពីប្រុស និយាយអំពីទាហានដ៏ក្លៀវក្លា និយាយអំពីច្រកផ្លូវ និយាយអំពីកំពង់ទឹក និយាយអំពីបុព្វប្រេតគឺញាតិដែលបែកស្លានទៅហើយ និយាយអំពីពាក្យឥតប្រយោជន៍ផ្សេងៗ និយាយអំពីលោក និយាយអំពីការជីកសមុទ្រ និយាយអំពីសេចក្តីចំរើននឹងមិនចំរើនដូច្នេះៗ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាការពោលនុ៎ះ មិនប្រកបដោយប្រយោជន៍ មិនមែនជាអាទិព្រហ្មចរិយធម៌ មិនប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ មិនប្រព្រឹត្តទៅដើម្បីប្រាសចាកតម្រេក មិនប្រព្រឹត្តទៅដើម្បីសេចក្តីរលត់ទុក្ខ មិនប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់ស្ងាត់

ន អភិញ្ញាយ ន សម្ពោធាយ ន និព្វានាយ សំវត្តតិ ។ កថេន្តា ច ខោ តុម្ហេ ភិក្ខវេ ឥទំ ទុក្ខន្តិ កថេយ្យាថ អយំ ទុក្ខសមុទយោតិ កថេយ្យាថ អយំ ទុក្ខនិរោធោតិ កថេយ្យាថ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ កថេយ្យាថ ។ តំ កិស្ស ហេតុ ។ ឯសា ភិក្ខវេ កថា អត្ថសញ្ហិតា ឯសា អាទិព្រហ្មចរិយកា ឯសា និព្វិទាយ វិរាគាយ និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ។ តស្មាតិហ ភិក្ខវេ ឥទំ ទុក្ខន្តិ យោគោ ករណីយោ ។ បេ ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យោគោ ករណីយោតិ ។

សមាធិវគ្គោ បឋមោ ។

មិនប្រព្រឹត្តទៅដើម្បីដឹងច្បាស់ មិនប្រព្រឹត្តទៅដើម្បីត្រាស់ដឹង មិនប្រព្រឹត្តទៅដើម្បីនិព្វាន ។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយពោល គួរពោលថា នេះជាទុក្ខ គួរពោលថា នេះហេតុជាទីកើតឡើងនៃទុក្ខ គួរពោលថា នេះជាទីរលត់ទុក្ខ គួរពោលថា នេះជាបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា ការពោលនុ៎ះប្រកបដោយប្រយោជន៍ ការពោលនុ៎ះជាអាទិព្រហ្មចរិយធម៌ ការពោលនុ៎ះ ប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីរលត់ទុក្ខ ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរធ្វើសេចក្តីព្យាយាមថា នេះជាទុក្ខ ។ បេ ។ គួរធ្វើសេចក្តីព្យាយាមថា នេះជាបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ

ចប់ សមាធិវគ្គ ទី ១ ។

### តស្សុទ្ទានំ

សមាធិប្បដិសល្លាណា
កុលបុត្តា អបរេ ទ្វេ(១)
សមណព្រាហ្មណាវិតក្កា-
ចិន្តា វិគ្គាហិកា កថា ។

---

១ កុលបុត្តាបរេ ទុវេតិ យុត្តតរំ ។

# ឧទ្ទាននៃសមាធិវគ្គនោះគឺ

និយាយអំពីសមាធិ ១ អំពីការធ្វើសេចក្ដីព្យាយាម

ក្នុងការពួនសម្ងំ ១ អំពីពួកកុលបុត្តមាន ២ លើក

អំពីពួកសមណៈព្រាហ្មណ៍មាន ២ លើក អំពីកុំ

ឲ្យត្រិះរិះនូវអកុសលវិតក្កៈ ១ អំពីកុំឲ្យគិតជាអកុ-

សល ១ អំពីពោលពាក្យប្រកាន់ផ្សេងគ្នា ១ អំពី

តិរច្ឆានកថា ១ ។

# ធម្មចក្កប្បវត្តនវគ្គោ ទុតិយោ

(៣៦៩) ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា ពារាណសិយំ វិហរតិ ឥសិបតនេ មិគទាយេ ។ តត្រ ខោ ភគវា បញ្ចវគ្គិយេ ភិក្ខូ អាមន្តេសិ ទ្វេមេ ភិក្ខវេ អន្តា បព្វជិតេន ន សេវិតព្វា ។ កតមេ ទ្វេ ។ យោ ចាយំ កាមេសុ កាមសុខល្លិកានុយោគោ ហីនោ គម្មោ ពោថុជ្ជនិកោ អនរិយោ អនត្ថសញ្ហិតោ យោ ចាយំ អត្តកិលមថានុយោគោ ទុក្ខោ អនរិយោ អនត្ថសញ្ហិតោ ។ ឯតេតេ(១) ភិក្ខវេ ឧភោ អន្តេ អនុបគម្ម មជ្ឈិមា បដិបទា តថាគតេន អភិសម្ពុទ្ធា ចក្ខុករណី ញាណករណី ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ។ កតមា ច សា ភិក្ខវេ មជ្ឈិមា បដិបទា តថាគតេន អភិសម្ពុទ្ធា ចក្ខុករណី ញាណករណី ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ។

---

១ ម. ឯតេ ខោ ។

# ធម្មចក្កប្បវត្តនវគ្គទី ២

(៣៦៥) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងឥសិបតនមិគទាយវ័ន ទៀបក្រុងពារាណសី ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ចំពោះបញ្ចវគ្គិយភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ធម៌អមខាង ២ ប្រការនេះ បព្វជិតមិនគួរសេពគប់ឡើយ ។ ធម៌អមខាង ២ ប្រការគឺអ្វីខ្លះ ។ ការប្រកបរឿយៗនូវសេចក្តីជាប់ជំពាក់ដោយកាមសុខក្នុងកាមទាំងឡាយ ដែលជាធម៌ថោកទាប ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនមែនជារបស់អរិយបុគ្គល មិនប្រកបដោយប្រយោជន៍ ១ ការប្រកបរឿយៗនូវសេចក្តីព្យាយាមធ្វើខ្លួនឯងឲ្យលំបាក ដែលនាំមកនូវសេចក្តីទុក្ខ មិនមែនជារបស់អរិយបុគ្គល មិនប្រកបដោយប្រយោជន៍ ១ ។ ម្នាលភិក្ខុទាំងឡាយ មជ្ឈិមាបដិបទាមិនប៉ះពាល់នូវធម៌អមខាងទាំង ២ នុ៎ះ តថាគតបានត្រាស់ដឹងហើយ ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតបញ្ញាចក្ខុ ធ្វើឲ្យកើតសេចក្តីចេះដឹង ប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់រម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ។ ម្នាលភិក្ខុទាំងឡាយ ចុះមជ្ឈិមាបដិបទានោះ តើដូចម្តេច ដែលតថាគតត្រាស់ដឹងហើយ ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតបញ្ញាចក្ខុ ធ្វើឲ្យកើតសេចក្តីចេះដឹង ប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់រម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ។

អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ ។ អយំ ខោ សា ភិក្ខវេ មជ្ឈិមា បដិបទា តថាគតេន អភិសម្ពុទ្ធា ចក្ខុករណី ញាណករណី ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ។

(៣៦៦) ឥទំ ខោ បន ភិក្ខវេ ទុក្ខំ អរិយសច្ចំ ។ ជាតិបិ ទុក្ខា ជរាបិ ទុក្ខា ព្យាធិបិ ទុក្ខា មរណម្បិ ទុក្ខំ[១] អប្បិយេហិ សម្បយោគោ ទុក្ខោ បិយេហិ វិប្បយោគោ ទុក្ខោ យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ សង្ខិត្តេន បញ្ចុបាទានក្ខន្ធា[២] ទុក្ខា ។ ឥទំ ខោ បន ភិក្ខវេ ទុក្ខសមុទយោ អរិយសច្ចំ ។ យាយំ តណ្ហា បោនោព្ភវិកា នន្ទិរាគសហគតា តត្រ តត្រាភិនន្ទិនី ។

---

១ ឱ. ឯត្ថន្តរេ សោកបរិទេវទុក្ខទោមនស្សុបាយាសាបិ ទុក្ខាតិ ទិស្សន្តិ ។ ២ ឱ.ម. បញ្ចុបាទានក្ខន្ធាបិ ។

(មជ្ឈិមាបដិបទា) គឺ អរិយមគ្គ ប្រកបដោយអង្គ ៨ ប្រការនេះឯង ។ អរិយមគ្គ ៨ ប្រការគឺអ្វីខ្លះ ។ គឺសេចក្ដីយល់ត្រូវ១ សេចក្ដីត្រិះរិះត្រូវ១ វាចាត្រូវ១ ការងារត្រូវ១ ការចិញ្ចឹមជីវិតត្រូវ១ សេចក្ដីព្យាយាមត្រូវ១ សេចក្ដីរឭកត្រូវ១ ការធ្វើចិត្តឲ្យនឹងត្រូវ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯង ហៅថា មជ្ឈិមាបដិបទា ដែលតថាគតត្រាស់ដឹងហើយ ជាសេចក្ដីប្រតិបត្តិ ធ្វើឲ្យកើតបញ្ញាចក្ខុ ធ្វើឲ្យកើតសេចក្ដីចេះដឹង ប្រព្រឹត្តទៅ ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ។

(៣៦៦) ម្នាលភិក្ខុទាំងឡាយ ក៏សេចក្ដីទុក្ខនេះឯង ហៅថា អរិយសច្ច គឺជាតិជាទុក្ខ១ ជរាជាទុក្ខ១ ព្យាធិជាទុក្ខ១ មរណៈជាទុក្ខ១ ដំណើរចួបប្រសព្វដោយសត្វនិងសង្ខារ មិនជាទីស្រឡាញ់ទាំងឡាយ ជាទុក្ខ១ ដំណើរព្រាត់ប្រាសចាកសត្វនិងសង្ខារ ជាទីស្រឡាញ់ទាំងឡាយជាទុក្ខ១ បុគ្គលប្រាថ្នារបស់ណា មិនបានរបស់នោះជាទុក្ខ១ បើពោលដោយសង្ខេប ឧបាទានក្ខន្ធទាំង៥ប្រការ ឈ្មោះថាជាទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ហេតុជាទីកើតឡើងនៃទុក្ខនេះ ហៅថា អរិយសច្ច ។ គឺតណ្ហានេះឯង ជាធម្មជាតិនាំសត្វឲ្យកើតទៀត ប្រកបដោយសេចក្ដីរីករាយនឹងត្រេកត្រអាល ជាធម្មជាតិនាំសត្វឲ្យត្រេកត្រអាលក្នុងភពនោះ ៗ ។

សេយ្យថីទំ ។ កាមតណ្ហា ភវតណ្ហា វិភវតណ្ហា ។ ឥទំ ខោ បន ភិក្ខវេ ទុក្ខនិរោធោ អរិយសច្ចំ ។ យោ តស្សាយេវ តណ្ហាយ អសេសវិរាគនិរោធោ ចាគោ បដិនិស្សគ្គោ មុត្តិ អនាលយោ ។ ឥទំ ខោ បន ភិក្ខវេ ទុក្ខនិរោធគាមិនីបដិបទា អរិយសច្ចំ ។ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ។

(៣៦៧) ឥទំ ទុក្ខំ អរិយសច្ចន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។ តំ ខោ បនិទំ ទុក្ខំ អរិយសច្ចំ បរិញ្ញេយ្យន្តិ មេ ភិក្ខវេ បុព្វេ ។បេ។ បរិញ្ញាតន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។

តណ្ហា គឺអ្វីខ្លះ ។ គឺកាមតណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១ ។ ម្នាលភិក្ខុទាំងឡាយ សេចក្ដីរលត់នៃទុក្ខនេះ ហៅថា អរិយសច្ច ។ គឺសភាវៈនឿយណាយនឹងការរលត់ដោយមិនមានសេសសល់ ជាសភាវៈលះបង់ គ្រវែងចោល ជម្រុះចោល មិនមានអាល័យ ចំពោះតណ្ហានោះ ។ ម្នាលភិក្ខុទាំងឡាយ បដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខនេះ ហៅថា អរិយសច្ច ។ គឺអរិយមគ្គប្រកបដោយអង្គ ៨ ប្រការនេះឯង ។ អរិយមគ្គ គឺអ្វីខ្លះ ។ គឺសេចក្ដីយល់ត្រូវ ១ ។ បេ ។ ការដំកល់ចិត្តត្រូវ ១ ។

(៣៦៧) ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលតថាគតមិនដែលបានឮក្នុងកាលមុនថា ទុក្ខនេះហៅថា អរិយសច្ចដូច្នេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ពន្លឺកើតឡើងហើយដល់តថាគតថា ទុក្ខនោះហៅថា អរិយសច្ច ដែលតថាគតគប្បីកំណត់ដឹង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលតថាគតមិនដែលបានឮក្នុងកាលមុនថា ទុក្ខនេះហៅថា អរិយសច្ច ដែលតថាគតបានកំណត់ដឹងហើយ ។

## ធម្មចក្កប្បវត្តនវគ្គោ ទុតិយោ

[៣៦៨] ឥទំ ទុក្ខសមុទយោ អរិយសច្ចន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។ តំ ខោ បនិទំ ទុក្ខសមុទយោ អរិយសច្ចំ បហាតព្វន្តិ មេ ភិក្ខវេ បុព្វេ ។បេ។ បហីនន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។

[៣៦៩] ឥទំ ទុក្ខនិរោធោ អរិយសច្ចន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។ តំ ខោ បនិទំ ទុក្ខនិរោធោ អរិយសច្ចំ សច្ឆិកាតព្វន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។

(៣៦៨) ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ ប្រាជ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលតថាគតមិនដែលបានឮក្នុងកាលមុនថា ហេតុជាទីកើតឡើងនៃទុក្ខនេះ ហៅថា អរិយសច្ច ដូច្នេះឡើយ ៗ ម្នាលភិក្ខុទាំងឡាយ ពន្លឺកើតឡើងហើយ ដល់តថាគតថា តណ្ហាជាហេតុឲ្យកើតទុក្ខនោះ ឈ្មោះថា អរិយសច្ច ដែលតថាគតគប្បីលះបង់ចោល ៗ បេ ៗ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ ប្រាជ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលតថាគតមិនដែលបានឮក្នុងកាលមុនថា តណ្ហាជាហេតុឲ្យកើតទុក្ខនោះ ឈ្មោះថា អរិយសច្ច ដែលតថាគត លះចោលហើយ ៗ

(៣៦៩) ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើង ពន្លឺកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលតថាគតមិនដែលបានឮមកក្នុងកាលមុនថា សេចក្តីរលត់ទុក្ខនេះ ហៅថា អរិយសច្ច ដូច្នេះឡើយ ៗ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយ

តំ ខោ បនិទំ ទុក្ខនិរោធោ អរិយសច្ចំ សច្ឆិកាតព្វន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។

(៣៧០) ឥទំ ទុក្ខនិរោធគាមិនីបដិបទា អរិយសច្ចន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។ តំ ខោ បនិទំ ទុក្ខនិរោធគាមិនីបដិបទា អរិយសច្ចំ ភាវេតព្វន្តិ មេ ភិក្ខវេ ។បេ។ ភាវិតន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។

ដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលតថាគតមិនដែលបានឮមកក្នុងកាលមុនថា សេចក្តីរលត់ទុក្ខនោះ ឈ្មោះថា អរិយសច្ច ដែលតថាគតគប្បីធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលតថាគតមិនដែលបានឮមកក្នុងកាលមុនថា សេចក្តីរលត់ទុក្ខនោះហៅថា អរិយសច្ច ដែលតថាគតធ្វើឲ្យជាក់ច្បាស់ហើយ ។

(៣៧០) ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលតថាគតមិនដែលបានឮមកក្នុងកាលមុនថា បដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខនេះ ហៅថា អរិយសច្ច ដូច្នេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ពន្លឺកើតឡើងហើយ ដល់តថាគតថា បដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខនោះ ហៅថា អរិយសច្ច ដែលតថាគតគប្បីចំរើន ។បេ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយដែលតថាគតមិនដែលបានឮមក ក្នុងកាលមុនថា បដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខនោះ ឈ្មោះថា អរិយសច្ច ដែលតថាគតចំរើនហើយ ។

(៣៧១) យាវកីវញ្ច មេ ភិក្ខវេ ឥមេសុ ចតូសុ អរិយសច្ចេសុ ឯវន្តិបរិវដ្ដំ ទ្វាទសាការំ យថាភូតំ ញាណទស្សនំ ន សុវិសុទ្ធំ អហោសិ នេវ តាវាហំ ភិក្ខវេ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោ(១) បច្ចញ្ញាសឹ ។ យតោ ច ខោ មេ ភិក្ខវេ ឥមេសុ ចតូសុ អរិយសច្ចេសុ ឯវន្តិបរិវដ្ដំ ទ្វាទសាការំ យថាភូតំ ញាណទស្សនំ សុវិសុទ្ធំ អហោសិ អថាហំ ភិក្ខវេ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោ បច្ចញ្ញាសឹ ។ ញាណញ្ច បន មេ ទស្សនំ ឧទបាទិ អកុប្បា មេ វិមុត្តិ(២) អយមន្តិមា ជាតិ នត្ថិទានិ បុនព្ភវោតិ ។ ឥទមវោច ភគវា ។ អត្តមនា បញ្ចវគ្គិយា ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុំ ។

---

១ ឱ. ម. អភិសម្ពុទ្ធោតិ ។ ២ ឱ. ចេតោវិមុត្តិ ។

(៣៧១) ម្នាលភិក្ខុទាំងឡាយ មួយទៀត ញាណទស្សនៈ (ការដឹងនឹងការឃើញ) មានបរិវដ្ដ (វិល) ៣ មានអាការ ១២ យ៉ាងនេះ ក្នុងអរិយសច្ចទាំង ៤ នេះ របស់តថាគតនៅមិនទាន់បរិសុទ្ធតាមពិតត្រឹមណា ភិក្ខុទាំងឡាយ តថាគតក៏មិនទាន់ប្ដេជ្ញាខ្លួនថា ជាអ្នកត្រាស់ដឹងចំពោះសម្មាសម្ពោធិញាណដ៏ប្រសើរ ក្នុងលោកព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព នឹងមនុស្សដ៏សេសត្រឹមណោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ លុះតែញាណទស្សនៈ មានបរិវដ្ដ ៣ មានអាការ ១២ យ៉ាងនេះ ក្នុងអរិយសច្ចទាំង ៤ នេះរបស់តថាគតបរិសុទ្ធតាមពិតក្នុងកាលណា ម្នាលភិក្ខុទាំងឡាយ ទើបតថាគត ប្ដេជ្ញាខ្លួនថា ជាអ្នកត្រាស់ដឹងចំពោះសម្មាសម្ពោធិញាណដ៏ប្រសើរក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព នឹងមនុស្សដ៏សេសក្នុងកាលណោះ ។ មួយទៀត ញាណទស្សនៈកើតឡើងដល់តថាគតថា វិមុត្តិគឺអរហត្តផលរបស់តថាគតមិនកម្រើកឡើយ ជាតិនេះផុតត្រឹមនេះហើយ ឥឡូវនេះភពថ្មីមិនមានទេ ។ លុះព្រះដ៏មានព្រះភាគត្រាស់ពាក្យនេះចប់ហើយ ។ ពួកបញ្ចវគ្គិយភិក្ខុ ក៏មានចិត្តត្រេកអរ រីករាយ ចំពោះភាសិតរបស់ព្រះដ៏មានព្រះភាគ ។

(៣៧២) ឥមស្មិញ្ច បន វេយ្យាករណស្មឹ ភញ្ញមានេ អាយស្មតោ កោណ្ឌញ្ញស្ស វិរជំ វីតមលំ ធម្មចក្ខុំ ឧទបាទិ យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ ។ បវត្តិតេ ច ភគវតា(១) ធម្មចក្កេ ភុម្មា ទេវា សទ្ទមនុស្សាវេសុំ ឯតម្ភគវតា ពារាណសិយំ ឥសិបតនេ មិគទាយេ អនុត្តរំ ធម្មចក្កំ បវត្តិតំ អប្បដិវត្តិយំ សមណេន វា ព្រាហ្មណេន វា ទេវេន វា មារេន វា ព្រហ្មុនា វា កេនចិ វា លោកស្មិន្តិ ។ ភុម្មានំ ទេវានំ សទ្ទំ សុត្វា ចាតុម្មហារាជិកា ទេវា សទ្ទមនុស្សាវេសុំ ឯតម្ភគវតា ពារាណសិយំ ឥសិបតនេ មិគទាយេ អនុត្តរំ ធម្មចក្កំ បវត្តិតំ អប្បដិវត្តិយំ សមណេន វា ព្រាហ្មណេន វា ទេវេន វា មារេន វា ព្រហ្មុនា វា កេនចិ វា លោកស្មិន្តិ ។ ចាតុម្មហារាជិកានំ ទេវានំ សទ្ទំ សុត្វា តាវត្តឹសា ទេវា ។

---

១ ឱ. ម. ឯវំ បវត្តិតេ ច បន ភគវតា ។

(៣៧២) កាលដែលព្រះដ៏មានព្រះភាគ កំពុងសំដែងនូវវេយ្យាករណ៍នេះ ធម្មចក្ខុ (ភ្នែកឃើញធម៌) ដ៏ប្រាសចាកធូលីគឺកាមរាគក្កិលេស ប្រាសចាកមន្ទិលគឺទិដ្ឋិនិងវិចិកិច្ឆា បានកើតឡើងហើយដល់កោណ្ឌញ្ញភិក្ខុ ដ៏មានអាយុថា ធម្មជាតណាមួយដែលកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះក៏រលត់ទៅវិញជាធម្មតា ។ កាលបើ ធម្មចក្កដែលព្រះមានព្រះភាគឲ្យប្រព្រឹត្តទៅ (សំដែងដូចជាគេបង្វិលយ៉ាងនេះ) ហើយ ភុម្មទេវតាទាំងឡាយ ក៏បន្លឺនូវសូរស័ព្ទថា ធម្មចក្កនេះ មិនមានបក្កដទៃក្រៃលែងជាង តោះបីសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ជនឯណានីមួយក្តី ក្នុងលោក មិនអាចនឹងឲ្យប្រព្រឹត្តទៅបានឡើយ (ឥឡូវ) ព្រះដ៏មានព្រះភាគ ទ្រង់ឲ្យប្រព្រឹត្តទៅបានហើយ ក្នុងឥសិបតនមិគទាយវន ជិតក្រុងពារាណសី ។ ពួកទេវតានៅក្នុងឋានចាតុម្មហារាជិកទាំងឡាយ ឮសំឡេងរបស់ភុម្មទេវតាទាំងឡាយហើយ ក៏បន្លឺនូវសំឡេងថា ធម្មចក្កនុះ មិនមានបក្កដទៃក្រៃលែងជាង តោះបីសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ជនឯណានីមួយក្តី ក្នុងលោកមិនអាចឲ្យប្រព្រឹត្តទៅបានឡើយ (ឥឡូវ) ព្រះដ៏មានព្រះភាគទ្រង់ឲ្យប្រព្រឹត្តទៅបានហើយក្នុងឥសិបតនមិគទាយវន ជិតក្រុងពារាណសី ។ ពួកទេវតានៅឋានតាវត្តិង្ស ឮសំឡេងរបស់ទេវតានៅក្នុងឋានចាតុម្មហារាជិក ។

យាមា ទេវា ។ តុសិតា ទេវា ។ និម្មានរតី ទេវា ។ បរនិម្មិតវសវត្តី ទេវា ។ ព្រហ្មកាយិកា ទេវា សទ្ទមនុស្សាវេសុំ ឯតម្ភគវតា ពារាណសិយំ ឥសិបតនេ មិគទាយេ អនុត្តរំ ធម្មចក្កំ បវត្តិតំ អប្បដិវត្តិយំ សមណេន វា ព្រាហ្មណេន វា ទេវេន វា មារេន វា ព្រហ្មុនា វា កេនចិ វា លោកស្មិន្តិ ។

(៣៧៣) ឥតិហ តេន ខណេន(១) តេន មុហុត្តេន យាវ ព្រហ្មលោកា សទ្ទោ អព្ភុគ្គច្ឆិ ។ អយញ្ច ទសសហស្សី លោកធាតុ សង្កម្បិ សម្បកម្បិ សម្បវេធិ ។ អប្បមាណោ ច ឧឡារោ ឱភាសោ លោកេ បាតុរហោសិ អតិក្កម្មេវ(២) ទេវានំ ទេវានុភាវន្តិ ។

(៣៧៤) អថខោ ភគវា ឧទានំ ឧទានេសិ អញ្ញាសិ វត ភោ កោណ្ឌញ្ញោ អញ្ញាសិ វត ភោ កោណ្ឌញ្ញោតិ ។ ឥតិហិទំ អាយស្មតោ កោណ្ឌញ្ញស្ស អញ្ញាកោណ្ឌញ្ញោត្វេវ នាមំ អហោសីតិ ។

---

១ ឱ. ម. តេន លយេន ។ ២. អតិក្កម្ម ទេវានំ ។

ពួកទេវតាក្នុងឋានយាមៈ ។ ទេវតានៅក្នុងឋានតុសិត ។ ពួកទេវតានៅក្នុងឋាននិម្មានរតី ។ ពួកទេវតានៅក្នុងឋានបរនិម្មិតវសវត្តី ។ ទេវតាទាំងឡាយដែលរាប់ក្នុងពពួកព្រហ្ម ក៏បន្លឺនូវសូរសព្ទថា ព្រះធម្មចក្ករនេះមិនមានចក្កដទៃក្រៅលែងជាង ទោះបីសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ជនឯណានីមួយក្តី ក្នុងលោកមិនអាចនឹងឲ្យប្រព្រឹត្តទៅបានឡើយ (ឥឡូវ) ព្រះដ៏មានព្រះភាគ ទ្រង់ឲ្យប្រព្រឹត្តទៅបានហើយ ក្នុងឥសិបតនមិគទាយវន ជិតក្រុងពារាណសី ។

(៣៧៣) សំឡេង ( ការពោល ) ក៏លាន់ឮឡើងទៅដរាបដល់ព្រហ្មលោកក្នុងខណៈមួយរំពេចនោះ ដោយប្រការដូច្នេះ ។ លោកធាតុទាំង១ហ្មឺននេះ ក៏កក្រើករំពើកញាប់ញ័រ ។ ទាំងពន្លឺភ្លឺធំទូលាយប្រមាណមិនបាន កន្លងលើសអានុភាពរបស់ទេវតាទាំងឡាយ ក៏កើតប្រាកដឡើងក្នុងលោក ។

(៣៧៤) លំដាប់នោះឯង ព្រះដ៏មានព្រះភាគទ្រង់បន្លឺនូវឧទានវាចាថា អើហ្ន៎ កោណ្ឌញ្ញៈបានត្រាស់ដឹងពិតហើយ អើហ្ន៎ កោណ្ឌញ្ញៈបានត្រាស់ដឹងពិតហើយ ។ ព្រោះហេតុនោះ ពាក្យថា អញ្ញាកោណ្ឌញ្ញៈនេះ ក៏បានជាប់ជានាមរបស់ព្រះកោណ្ឌញ្ញត្ថេរដ៏មានអាយុ ដោយប្រការដូច្នេះ ។

(៣៧៥) ឥទំ ទុក្ខំ អរិយសច្ចន្តិ ភិក្ខវេ តថាគតានំ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។ តំ ខោ បនិទំ ទុក្ខំ អរិយសច្ចំ បរិញ្ញេយ្យន្តិ ភិក្ខវេ តថាគតានំ បុព្វេ ។បេ។ បរិញ្ញាតន្តិ ភិក្ខវេ តថាគតានំ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។

(៣៧៦) ឥទំ ទុក្ខសមុទយោ អរិយសច្ចន្តិ ភិក្ខវេ តថាគតានំ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។ តំ ខោ បនិទំ ទុក្ខសមុទយោ អរិយសច្ចំ បហាតព្វន្តិ ភិក្ខវេ តថាគតានំ

[៣៧៥] ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយ ដល់ព្រះតថាគតទាំងឡាយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់បានឮមកក្នុងកាលមុនថា សេចក្តីទុក្ខនេះហៅថា អរិយសច្ច ។ ម្នាលភិក្ខុទាំងឡាយ ពន្លឺកើតឡើងហើយ ដល់ព្រះតថាគតទាំងឡាយថា សេចក្តីទុក្ខនោះ ហៅថា អរិយសច្ច បុគ្គលគួរកំណត់ដឹង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយ ដល់ព្រះតថាគតទាំងឡាយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់បានឮមកក្នុងកាលមុនថា សេចក្តីទុក្ខនោះ ហៅថា អរិយសច្ច ដែលតថាគតបានកំណត់ដឹងហើយ ។

[៣៧៦] ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយ ដល់ព្រះតថាគតទាំងឡាយ ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់បានឮមកក្នុងកាលមុនថា ហេតុជាទីកើតឡើងនៃទុក្ខនេះ ហៅថា អរិយសច្ច ។ ម្នាលភិក្ខុទាំងឡាយ ពន្លឺកើតឡើងហើយ ដល់តថាគតទាំងឡាយថា ហេតុជាទីកើតឡើងនៃទុក្ខនោះ ហៅថា អរិយសច្ច ដែលតថាគតគប្បី

បុព្វេ ។បេ។ បហីនន្តិ ភិក្ខវេ តថាគតានំ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។

[៣៧៧] ឥទំ ទុក្ខនិរោធោ អរិយសច្ចន្តិ ភិក្ខវេ តថាគតានំ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។ តំ ខោ បនិទំ ទុក្ខនិរោធោ អរិយសច្ចំ សច្ឆិកាតព្វន្តិ ភិក្ខវេ តថាគតានំ បុព្វេ ។បេ។ សច្ឆិកតន្តិ ភិក្ខវេ តថាគតានំ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។

លះបង់ ។ល។ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយដល់ព្រះតថាគតទាំងឡាយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់បានឮមកក្នុងកាលមុនថា ហេតុជាទីកើតឡើងនៃទុក្ខនោះ ហៅថា អរិយសច្ចដែលតថាគត លះបង់ចោលហើយ ។

(៣៧៧) ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយ ដល់ព្រះតថាគតទាំងឡាយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮមកក្នុងកាលមុនថា សេចក្តីរលត់ទុក្ខនេះ ហៅថា អរិយសច្ច ។ ម្នាលភិក្ខុទាំងឡាយ ពន្លឺកើតឡើងហើយ ដល់ព្រះតថាគតទាំងឡាយ ក្នុងកាលមុនថា សេចក្តីរលត់ទុក្ខនោះ ហៅថា អរិយសច្ចដែលតថាគតគប្បីធ្វើឲ្យជាក់ច្បាស់ ។ល។ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយ ដល់ព្រះតថាគតទាំងឡាយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់បានឮមកក្នុងកាលមុនថា សេចក្តីទុក្ខនោះ ហៅថា អរិយ-សច្ច ដែលតថាគត ធ្វើឲ្យជាក់ច្បាស់ហើយ ។

(១៣៧៨) ឥទំ(១) ទុក្ខនិរោធគាមិនីបដិបទា អរិយសច្ចន្តិ ភិក្ខវេ តថាគតានំ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។ តំ ខោ បនិទំ ទុក្ខនិរោធគាមិនីបដិបទា អរិយសច្ចំ ភាវេតព្វន្តិ ភិក្ខវេ តថាគតានំ បុព្វេ ។បេ។ ភាវិតន្តិ ភិក្ខវេ តថាគតានំ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទីតិ ។

(១៣៧៩) ចត្តារិមានិ ភិក្ខវេ អរិយសច្ចានិ ។ កតមានិ ចត្តារិ ។ ទុក្ខំ អរិយសច្ចំ ទុក្ខសមុទយោ អរិយសច្ចំ ទុក្ខនិរោធោ អរិយសច្ចំ ទុក្ខនិរោធគាមិនីបដិបទា អរិយសច្ចំ ។

---

១ ម. អយំ ។

(៣៧៨) ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយ ដល់ព្រះតថាគតទាំងឡាយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់បានឮមកក្នុងកាលមុនថា បដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខនេះ ហៅថា អរិយសច្ច ។ ម្នាលភិក្ខុទាំងឡាយ ពន្លឺកើតឡើងហើយ ដល់ព្រះតថាគតទាំងឡាយថា បដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខនោះ ហៅថា អរិយសច្ច ដែលតថាគតគប្បីចំរើន ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយ ដល់ព្រះតថាគតទាំងឡាយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់បានឮមក ក្នុងកាលមុនថា បដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខនោះ ហៅថា អរិយសច្ច ដែលតថាគតចំរើនហើយ ។

(៣៧៩) ម្នាលភិក្ខុទាំងឡាយ អរិយសច្ច ៤ នេះ ។ អរិយសច្ច ៤ តើអ្វីខ្លះ ។ គឺទុក្ខអរិយសច្ច ១ ទុក្ខសមុទយអរិយសច្ច ១ ទុក្ខនិរោធ-អរិយសច្ច ១ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ១ ។

(៣៨០) កតមញ្ច ភិក្ខវេ ទុក្ខំ អរិយសច្ចំ បញ្ចុបាទានក្ខន្ធាតិស្ស វចនីយំ ។ កតមេ បញ្ច(១) ។ រូបុបាទានក្ខន្ធោ ។ បេ ។ វិញ្ញាណុបាទានក្ខន្ធោ ។ ឥទំ វុច្ចតិ ភិក្ខវេ ទុក្ខំ អរិយសច្ចំ ។

(៣៨១) កតមញ្ច ភិក្ខវេ ទុក្ខសមុទយោ អរិយសច្ចំ ។ យាយំ តណ្ហា បោនោព្ភវិកា នន្ទិរាគសហគតា តត្រ តត្រាភិនន្ទិនី ។ សេយ្យថីទំ ។ កាមតណ្ហា ភវតណ្ហា វិភវតណ្ហា ។ ឥទំ វុច្ចតិ ភិក្ខវេ ទុក្ខសមុទយោ អរិយសច្ចំ ។

(៣៨២) កតមញ្ច ភិក្ខវេ ទុក្ខនិរោធោ អរិយសច្ចំ ។ យោ តស្សាយេវ តណ្ហាយ អសេសវិរាគនិរោធោ ចាគោ បដិនិស្សគ្គោ មុត្តិ អនាលយោ ។ ឥទំ វុច្ចតិ ភិក្ខវេ ទុក្ខនិរោធោ អរិយសច្ចំ ។

---

១ ឱ. ម សេយ្យថីទំ ។

ធម្មចក្កប្បវត្តនវគ្គទី ២

(៣៨០) ម្នាលភិក្ខុទាំងឡាយ ចុះទុក្ខអរិយសច្ច តើដូចម្តេច ។ ពាក្យថា ឧបាទានក្ខន្ធ ៥ គួរពោលថាជាឈ្មោះនៃទុក្ខអរិយសច្ចនោះ ។ ឧបាទានក្ខន្ធ ៥ តើដូចម្តេច ។ គឺរូបជាឧបាទានក្ខន្ធ ១ ។ បេ ។ វិញ្ញាណជាឧបាទានក្ខន្ធ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទុក្ខអរិយសច្ច ។

(៣៨១) ម្នាលភិក្ខុទាំងឡាយ ចុះទុក្ខសមុទយអរិយសច្ច តើដូចម្តេច ។ តណ្ហាណាដែលនាំសត្វឲ្យកើតក្នុងភពថ្មីទៀត ប្រកបដោយសេចក្តីរីករាយ នឹងតម្រេកនាំសត្វឲ្យត្រេកត្រអាល ក្នុងភពនោះៗ ។ តណ្ហានោះគឺអ្វីខ្លះ ។ គឺកាមតណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទុក្ខសមុទយអរិយសច្ច ។

(៣៨២) ម្នាលភិក្ខុទាំងឡាយ ចុះទុក្ខនិរោធអរិយសច្ច តើដូចម្តេច ។ គឺសភាវៈនឿយណាយនឹងការរលត់ដោយមិនមានសេសសល់ ជាសភាវៈលះបង់ ត្រវែងចោល ជម្រុះចោល មិនមានអាល័យ ចំពោះតណ្ហានោះឯង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទុក្ខនិរោធអរិយសច្ច ។

(៣៨៣) កតមញ្ច ភិក្ខវេ ទុក្ខនិរោធគាមិនី-បដិបទា អរិយសច្ចំ ។ អយមេវ អរិយោ អដ្ឋ-ង្គិកោ មគ្គោ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ។ ឥទំ វុច្ចតិ ភិក្ខវេ ទុក្ខ-និរោធគាមិនីបដិបទា អរិយសច្ចំ ។

(៣៨៤) ឥមានិ ខោ ភិក្ខវេ ចត្តារិ អរិយ-សច្ចានិ ។ តស្មាតិហ ភិក្ខវេ ឥទំ ទុក្ខន្តិ យោគោ ករណីយោ ។បេ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យោគោ ករណីយោតិ ។

(៣៨៥) ចត្តារិមានិ ភិក្ខវេ អរិយសច្ចានិ ។ កត-មានិ ចត្តារិ ។ ទុក្ខំ អរិយសច្ចំ ទុក្ខសមុទយោ អរិយសច្ចំ ទុក្ខនិរោធោ អរិយសច្ចំ ទុក្ខនិរោធ-គាមិនីបដិបទា អរិយសច្ចំ ។

(៣៨៦) កតមញ្ច ភិក្ខវេ ទុក្ខំ អរិយ-សច្ចំ ។ ឆ អជ្ឈត្តិកានិ អាយតនានីតិស្ស វច-នីយំ ។ កតមានិ ឆ ។ ចក្ខាយតនំ ។បេ។ មនាយតនំ ។ ឥទំ វុច្ចតិ ភិក្ខវេ ទុក្ខំ អរិយសច្ចំ ។

[ ៣៨៣ ] ម្នាលភិក្ខុទាំងឡាយ ចុះទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច តើដូចម្តេច ។ គឺ អរិយមគ្គដែលប្រកបដោយអង្គទាំង ៨ ប្រការនេះឯង ។ អរិយមគ្គ ៨ ប្រការគឺអ្វីខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ ។ បេ ។ ការដំកល់ចិត្តនឹងត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ។

[ ៣៨៤ ] ម្នាលភិក្ខុទាំងឡាយ អរិយសច្ចមាន ៤ នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរធ្វើសេចក្តីព្យាយាមថា នេះជាទុក្ខ ។បេ។ គួរធ្វើសេចក្តីព្យាយាមថា នេះជាបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខ ។

[ ៣៨៥ ] ម្នាលភិក្ខុទាំងឡាយ អរិយសច្ចមាន ៤ នេះ ។ អរិយសច្ច ៤ គឺអ្វីខ្លះ ។ គឺទុក្ខអរិយសច្ច ១ ទុក្ខសមុទយអរិយសច្ច ១ ទុក្ខនិរោធអរិយសច្ច ១ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ១ ។

[ ៣៨៦ ] ម្នាលភិក្ខុទាំងឡាយ ចុះទុក្ខអរិយសច្ច តើដូចម្តេច ។ ពាក្យថា អាយតនៈខាងក្នុង ៦ គួរពោលថា ជាឈ្មោះរបស់នៃទុក្ខអរិយសច្ចនោះ ។ អាយតនៈ ៦ គឺអ្វីខ្លះ ។ អាយតនៈ គឺចក្ខុ ១ ។ បេ ។ អាយតនៈគឺចិត្ត ១ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទុក្ខអរិយសច្ច ។

### ធម្មចក្កប្បវត្តនវគ្គោ ទុតិយោ

(៣៨៧) កតមញ្ច ភិក្ខវេ ទុក្ខសមុទយោ អរិយសច្ចំ ។ យាយំ តណ្ហា ពោនោព្ភវិកា នន្ទិរាគសហគតា តត្រ តត្រាភិនន្ទិនី ។ សេយ្យថីទំ ។ កាមតណ្ហា ភវតណ្ហា វិភវតណ្ហា ។ ឥទំ វុច្ចតិ ភិក្ខវេ ទុក្ខសមុទយោ អរិយសច្ចំ ។

(៣៨៨) កតមញ្ច ភិក្ខវេ ទុក្ខនិរោធោ អរិយសច្ចំ ។ យោ តស្សាយេវ តណ្ហាយ អសេសវិរាគនិរោធោ ចាគោ បដិនិស្សគ្គោ មុត្តិ អនាលយោ ។ ឥទំ វុច្ចតិ ភិក្ខវេ ទុក្ខនិរោធោ អរិយសច្ចំ ។

(៣៨៩) កតមញ្ច ភិក្ខវេ ទុក្ខនិរោធគាមិនីបដិបទា អរិយសច្ចំ ។ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ។ ឥទំ វុច្ចតិ ភិក្ខវេ ទុក្ខនិរោធគាមិនីបដិបទា អរិយសច្ចំ ។

(៣៩០) ឥមានិ ខោ ភិក្ខវេ ចត្តារិ អរិយសច្ចានិ ។ តស្មាតិហ ភិក្ខវេ ឥទំ ទុក្ខន្តិ យោគោ ករណីយោ ។ បេ ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យោគោ ករណីយោតិ ។

[៣៨៧] ម្នាលភិក្ខុទាំងឡាយ ចុះទុក្ខសមុទយអរិយសច្ច តើដូចម្តេច ។ គឺតណ្ហាណាដែលនាំសត្វឲ្យកើតក្នុងភពថ្មីទៀត ប្រកបដោយសេចក្តីរីករាយនឹងតម្រេកនាំសត្វឲ្យត្រេកត្រអាលចំពោះភពនោះ ៗ ។ តណ្ហានោះអ្វីខ្លះ ។ គឺ កាមតណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទុក្ខសមុទយអរិយសច្ច ។

[៣៨៨] ម្នាលភិក្ខុទាំងឡាយ ចុះទុក្ខនិរោធអរិយសច្ច តើដូចម្តេច ។ គឺសភាវៈដែលប្រាសចាកតម្រេកនឹងការរលត់មិនមានសេសសល់ ជម្រុះចោលត្រវែងចោល រួចស្រឡះ មិនមានអាល័យ ចំពោះតណ្ហានោះឯង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទុក្ខនិរោធអរិយសច្ច ។

[៣៨៩] ម្នាលភិក្ខុទាំងឡាយ ចុះទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច តើដូចម្តេច ។ គឺអរិយមគ្គដែលប្រកបដោយអង្គ ៨ នេះឯង ។ អរិយមគ្គទាំង ៨ គឺអ្វីខ្លះ ។ គឺសេចក្តីយល់ត្រូវ ១ ។ បេ ។ ការដំកល់ចិត្តនឹងត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ។

[៣៩០] ម្នាលភិក្ខុទាំងឡាយ អរិយសច្ចមាន ៤ នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរធ្វើសេចក្តីព្យាយាមថា នេះជាទុក្ខ ។ បេ ។ គួរធ្វើសេចក្តីព្យាយាមថា នេះជាបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខ ។

(៣៩១) ជានាថ នោ តុម្ហេ ភិក្ខវេ មយា ចត្តារិ អរិយសច្ចានិ ទេសិតានីតិ ។ ឯវំ វុត្តេ អញ្ញតរោ ភិក្ខុ ភគវន្តំ ឯតទវោច អហំ ខោ ភន្តេ ជានាមិ ភគវតា ចត្តារិ អរិយសច្ចានិ ទេសិតានីតិ ។ យថាកថំ បន ត្វំ ភិក្ខុ ជានាសិ មយា ចត្តារិ អរិយសច្ចានិ ទេសិតានីតិ ។ ទុក្ខំ ខ្វាហំ ភន្តេ ភគវតា បឋមំ អរិយសច្ចំ ទេសិតំ ជានាមិ ទុក្ខសមុទយំ ខ្វាហំ ភន្តេ ភគវតា ទុតិយំ អរិយសច្ចំ ទេសិតំ ជានាមិ ទុក្ខនិរោធំ ខ្វាហំ ភន្តេ ភគវតា តតិយំ អរិយសច្ចំ ទេសិតំ ជានាមិ ទុក្ខនិរោធគាមិនីបដិបទំ ខ្វាហំ ភន្តេ ភគវតា ចតុត្ថំ អរិយសច្ចំ ទេសិតំ ជានាមិ ។ ឯវំ ខ្វាហំ ភន្តេ ជានាមិ ភគវតា ចត្តារិ អរិយសច្ចានិ ទេសិតានីតិ ។

(៣៩១) ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចាំទុកនូវអរិយសច្ច ៤ ដែលតថាគតសំដែងហើយបានដែរឬ ។ កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ភិក្ខុ ១ រូប ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គចាំនូវអរិយសច្ច ៤ ដែលព្រះមានព្រះភាគត្រាស់ហើយ ។ ម្នាលភិក្ខុ ចុះអ្នកចាំអរិយសច្ច ៤ ដែលតថាគតសំដែងហើយ តើដូចម្តេចខ្លះ ។ ភិក្ខុនោះក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គចាំនូវទុក្ខដែលព្រះដ៏មានព្រះភាគត្រាស់ហើយថាជាអរិយសច្ចទី ១ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គចាំនូវហេតុជាទីកើតឡើងនៃទុក្ខដែលព្រះមានជោគត្រាស់ហើយថាជាអរិយសច្ចទី ២ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គចាំនូវសេចក្តីរលត់ទុក្ខដែលព្រះមានព្រះភាគទ្រង់ត្រាស់ហើយថាជាអរិយសច្ចទី ៣ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គចាំនូវបដិបទាជាដំណើរទៅកាន់សេចក្តីរលត់ទុក្ខ ដែលព្រះមានព្រះភាគត្រាស់ហើយថាជាអរិយសច្ចទី ៤ ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គចាំទុកនូវអរិយសច្ច ៤ ដែលព្រះមានព្រះភាគត្រាស់ហើយយ៉ាងនេះ ។

## ធម្មចក្កប្បវត្តនវគ្គោ ទុតិយោ

(៣៩២) សាធុ សាធុ ភិក្ខុ សាធុ ខោ ត្វំ ភិក្ខុ ជានាសិ មយា ចត្តារិ អរិយសច្ចានិ ទេសិតានិ ។ ទុក្ខំ ខោ ភិក្ខុ មយា បឋមំ អរិយសច្ចំ ទេសិតំ តថា នំ ជានាហិ ទុក្ខសមុទយោ ខោ ភិក្ខុ មយា ទុតិយំ អរិយសច្ចំ ទេសិតំ តថា នំ ជានាហិ ទុក្ខនិរោធោ ខោ ភិក្ខុ មយា តតិយំ អរិយសច្ចំ ទេសិតំ តថា នំ ជានាហិ ទុក្ខនិរោធគាមិនីបដិបទា ខោ ភិក្ខុ មយា ចតុត្ថំ អរិយសច្ចំ ទេសិតំ តថា នំ ជានាហិ ។ ឯវំ ខោ ភិក្ខុ ជានាហិ មយា ចត្តារិ អរិយសច្ចានិ ទេសិតានិ ។ តស្មាតិហ ភិក្ខុ ឥទំ ទុក្ខន្តិ យោគោ ករណីយោ ។ បេ ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យោគោ ករណីយោតិ ។

## ធម្មចក្កប្បវត្តនវគ្គទី ២

[៣៩២] ម្នាលភិក្ខុ ប្រពៃណាស់ហើយ ម្នាលភិក្ខុ អ្នកចាំនូវអរិសច្ច ៤ ដែលតថាគតសំដែងហើយប្រពៃណាស់ហើយ ៗ ម្នាលភិក្ខុ សេចក្ដីទុក្ខហ្នឹងឯង តថាគតសំដែងហើយថាជាអរិយសច្ចទី ១ ចូរអ្នកចាំនូវអរិយសច្ចទី ១ នោះ ដូច្នោះចុះ ម្នាលភិក្ខុ ហេតុជាទីកើតឡើងនៃទុក្ខ តថាគតសំដែងហើយថាជា អរិយសច្ចទី ២ ចូរអ្នកចាំទុកអរិយសច្ចទី ២ នោះ ដូច្នោះចុះ ម្នាលភិក្ខុ សេចក្ដីរលត់ទុក្ខ តថាគតសំដែងហើយថាជា អរិយសច្ចទី ៣ ចូរអ្នកចាំទុកនូវអរិយសច្ចទី៣នោះ ដូច្នោះចុះ ម្នាលភិក្ខុ បដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខហ្នឹងឯង តថាគតសំដែងហើយថាជា អរិយសច្ចទី ៤ ចូរអ្នកចាំទុកនូវអរិយសច្ចទី ៤ នោះដូច្នោះចុះ ៗ ម្នាលភិក្ខុ ចូរអ្នកចាំទុកនូវអរិយសច្ច ៤ ដែលតថាគតសំដែងហើយ យ៉ាងនេះចុះ ៗ ម្នាលភិក្ខុ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរធ្វើសេចក្ដីព្យាយាមថា នេះជាទុក្ខ ៗ បេ ៗ គួរធ្វើសេចក្ដីព្យាយាមថា នេះជាបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខ ៗ

(៣៩៣) ធារេថ នោ តុម្ហេ ភិក្ខវេ មយា ចត្តារិ អរិយសច្ចានិ ទេសិតានីតិ ។ ឯវំ វុត្តេ អញ្ញតរោ ភិក្ខុ ភគវន្តំ ឯតទវោច អហំ ខោ ភន្តេ ធារេមិ ភគវតា ចត្តារិ អរិយច្ចានិ ទេសិតានីតិ ។ យថាកថំ បន ត្វំ ភិក្ខុ ធារេសិ មយា ចត្តារិ អរិយសច្ចានិ ទេសិតានីតិ ។ ទុក្ខំ ខ្វាហំ ភន្តេ ភគវតា បឋមំ អរិយសច្ចំ ទេសិតំ ធារេមិ ។ យោ ហិ កោចិ ភន្តេ សមណោ វា ព្រាហ្មណោ វា ឯវំ វទេយ្យ នេតំ ទុក្ខំ បឋមំ អរិយ-សច្ចំ យំ សមណេន គោតមេន ទេសិតំ អហមេតំ ទុក្ខំ បឋមំ អរិយសច្ចំ បច្ចក្ខាយ អញ្ញំ ទុក្ខំ បឋមំ អរិយសច្ចំ បញ្ញបេស្សាមីតិ នេតំ ឋានំ វិជ្ជតិ ។ ទុក្ខសមុទយំ ខ្វាហំ ភន្តេ ភគវតា ។ បេ ។ ទុក្ខនិរោធគាមិនីបដិបទំ ខ្វាហំ ភន្តេ ភគវតា ចតុត្ថំ អរិយសច្ចំ ទេសិតំ ធារេមិ ។ យោ ហិ កោចិ ភន្តេ សមណោ វា ព្រាហ្មណោ វា ឯវំ វទេយ្យ

(៣៩៣) ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចាំទុកនូវអរិយ-សច្ច ៤ ដែលតថាគតសំដែងហើយបានដែរឬ ។ កាលបើព្រះមានជោគទ្រង់ត្រាស់យ៉ាងនេះហើយ ភិក្ខុមួយរូបក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គចាំនូវអរិយសច្ច ៤ ដែលព្រះមានបុញ្ញាកសីត្រាស់ហើយ ។ ម្នាលភិក្ខុ ចុះអ្នកចាំនូវអរិយសច្ច ៤ ដែលតថាគតសំដែងហើយ តើដូចម្តេច ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គចាំនូវទុក្ខ ហ្នឹងឯង ដែលព្រះមានព្រះភាគត្រាស់ហើយថាជាអរិយសច្ចទី ១ ។ បពិតព្រះអង្គដ៏ចំរើន ទោះបើសមណៈឬព្រាហ្មណ៍ឯណានីមួយនិយាយយ៉ាងនេះថា សេចក្តីទុក្ខឯណា ដែលព្រះសមណគោតមត្រាស់ហើយ សេចក្តីទុក្ខនុ៎ះ មិនមែនជាអរិយសច្ចទី ១ ទេ ខ្ញុំព្រះអង្គបដិសេធនូវសេចក្តីទុក្ខដែលបាត់ជាអរិយសច្ចទី១នុ៎ះចោលចេញ ហើយបញ្ញត្តសេចក្តីទុក្ខឯទៀតថាជាអរិយសច្ចទី ១ វិញដូច្នេះ ហេតុនោះមិនមានឡើយ ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គចាំនូវហេតុជាទីកើតឡើងនៃទុក្ខហ្នឹងឯង ដែលព្រះមានព្រះភាគ ។ បេ ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គចាំនូវបដិបទាជាដំណើរទៅកាន់ទីរំលត់ទុក្ខហ្នឹងឯង ដែលព្រះមានព្រះភាគត្រាស់ហើយថា ជាអរិយសច្ចទី ៤ ។ បពិត្រព្រះអង្គដ៏ចំរើន ទោះបើសមណៈឬព្រាហ្មណ៍ឯណានីមួយ គប្បីនិយាយយ៉ាងនេះថា

នេតំ ទុក្ខនិរោធគាមិនីបដិបទា ចតុត្ថំ អរិយសច្ចំ យំ សមណេន គោតមេន ទេសិតំ អហមេតំ ទុក្ខនិរោធគាមិនីបដិបទំ ចតុត្ថំ អរិយសច្ចំ បច្ចក្ខាយ អញ្ញំ ទុក្ខនិរោធគាមិនីបដិបទំ ចតុត្ថំ អរិយសច្ចំ បញ្ញបេស្សាមីតិ នេតំ ឋានំ វិជ្ជតិ ។ ឯវំ ខ្វាហំ ភន្តេ ធារេមិ ភគវតា ចត្តារិ អរិយសច្ចានិ ទេសិតានីតិ ។

(១៩៤) សាធុ សាធុ ភិក្ខុ សាធុ ខោ ត្វំ ភិក្ខុ ធារេសិ មយា ចត្តារិ អរិយសច្ចានិ ទេសិតានិ ។ ទុក្ខំ ខោ ភិក្ខុ មយា បឋមំ អរិយសច្ចំ ទេសិតំ តថា នំ ធារេហិ ។ យោ ហិ កោចិ ភិក្ខុ សមណោ វា ព្រាហ្មណោ វា ឯវំ វទេយ្យ នេតំ ទុក្ខំ បឋមំ អរិយសច្ចំ យំ សមណេន គោតមេន ទេសិតំ អហមេតំ ទុក្ខំ បឋមំ អរិយសច្ចំ បច្ចក្ខាយ អញ្ញំ ទុក្ខំ បឋមំ អរិយសច្ចំ បញ្ញបេស្សាមីតិ នេតំ ឋានំ វិជ្ជតិ ។

បដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខឯណា ដែលព្រះសមណគោតមសំដែងហើយ បដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខនុ៎ះ មិនមែនជាអរិយសច្ចទី៤ទេ ខ្ញុំព្រះអង្គនឹងបដិសេធនូវបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខ ដែលថាត់ជាអរិយសច្ចទី ៤ នោះចោល ហើយបញ្ញត្តបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខដទៃថាជា អរិយសច្ចទី ៤ វិញ ហេតុនុ៎ះមិនមានឡើយ ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គតាំងនូវអរិយសច្ច ៤ ដែលព្រះមានព្រះភាគត្រាស់ហើយយ៉ាងនេះ ។

(៣៩៤) ម្នាលភិក្ខុ ប្រពៃណាស់ហើយ ប្រពៃណាស់ហើយ ម្នាលភិក្ខុ អ្នកតាំងនូវអរិយសច្ច ៤ ដែលតថាគតសំដែងហើយ ប្រពៃណាស់ហើយ ។ ម្នាលភិក្ខុ ទុក្ខនោះឯង តថាគតសំដែងហើយថាជា អរិយសច្ចទី ១ ចូរអ្នកតាំងនូវអរិយសច្ចទី ១ នោះដូច្នោះចុះ ។ ម្នាលភិក្ខុ ពោះបើសមណៈឬព្រាហ្មណ៍ឯណាទីមួយគប្បីពោលយ៉ាងនេះថា សេចក្តីទុក្ខណា ដែលព្រះសមណគោតមត្រាស់ហើយ សេចក្តីទុក្ខនុ៎ះមិនមែនជាអរិយសច្ចទី១ទេ តថាគតនឹងបដិសេធនូវសេចក្តីទុក្ខដែលថាត់ជាអរិយសច្ចទី ១ នោះហើយ បញ្ញត្តសេចក្តីទុក្ខដទៃថាជា អរិយសច្ចទី១ ដូច្នេះវិញ ហេតុនុ៎ះមិនមានឡើយ ។

ទុក្ខសមុទយោ ខោ ភិក្ខុ ។បេ។ ទុក្ខនិរោធោ ខោ ភិក្ខុ ។បេ។ ទុក្ខនិរោធគាមិនីបដិបទា ខោ ភិក្ខុ មយា ចតុត្ថំ អរិយសច្ចំ ទេសិតំ តថា នំ ធារេហិ ។ យោ ហិ កោចិ ភិក្ខុ សមណោ វា ព្រាហ្មណោ វា ឯវំ វទេយ្យ នេតំ ទុក្ខនិរោធគាមិនីបដិបទា ចតុត្ថំ អរិយសច្ចំ យំ សមណេន គោតមេន ទេសិតំ អហមេតំ ទុក្ខនិរោធគាមិនីបដិបទំ ចតុត្ថំ អរិយសច្ចំ បច្ចក្ខាយ អញ្ញំ ទុក្ខនិរោធគាមិនីបដិបទំ ចតុត្ថំ អរិយសច្ចំ បញ្ញបេស្សាមីតិ នេតំ ឋានំ វិជ្ជតិ ។ ឯវំ ខោ ត្វំ ភិក្ខុ ធារេហិ មយា ចត្តារិ អរិយសច្ចានិ ទេសិតានិ ។ តស្មាតិហ ភិក្ខុ ឥទំ ទុក្ខន្តិ យោគោ ករណីយោ ។បេ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យោគោ ករណីយោតិ ។

(៣៩៨) ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច អវិជ្ជា អវិជ្ជាតិ ភន្តេ វុច្ចតិ កតមា នុ ខោ ភន្តេ អវិជ្ជា កិត្តាវតា ច អវិជ្ជាគតោ ហោតីតិ ។ យំ ខោ ភិក្ខុ ទុក្ខេ អញ្ញាណំ

ម្នាលភិក្ខុ ហេតុជាទីកើតឡើងនៃទុក្ខ ។ បេ ។ ម្នាលភិក្ខុ សេចក្តីរលត់ទុក្ខ ។ បេ ។ ម្នាលភិក្ខុ បដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខ ដែលតថាគតសំដែងហើយថាជា អរិយសច្ចទី ៤ ចូរអ្នកចាំទុកនូវអរិយសច្ចទី ៤ នុ៎ះដូច្នោះចុះ ។ ម្នាលភិក្ខុ បើសមណៈឬព្រាហ្មណ៍ឯណានីមួយ គប្បីពោលយ៉ាងនេះថា បដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខឯណា ដែលព្រះសមណគោតមត្រាស់ហើយ បដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខនុ៎ះ មិនមែនជាអរិយសច្ចទី ៤ ទេ តថាគតនឹងបដិសេធបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខ ដែលចាត់ជាអរិយសច្ចទី ៤ នុ៎ះចោលហើយ បញ្ញត្តនូវបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខដទៃថាជា អរិយសច្ចទី ៤ វិញ ហេតុនុ៎ះ មិនមានឡើយ ។ ម្នាលភិក្ខុ ចូរអ្នកចាំទុកនូវអរិយសច្ច ៤ ដែលតថាគតសំដែងហើយយ៉ាងនេះចុះ ។ ម្នាលភិក្ខុ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរធ្វើសេចក្តីព្យាយាម ថានេះជាទុក្ខ ។ បេ ។ គួរធ្វើសេចក្តីព្យាយាមថានេះជាបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ ។

[៣៩៥] លុះភិក្ខុនោះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ដែលហៅថា អវិជ្ជា អវិជ្ជា ដូច្នេះ បពិត្រព្រះអង្គដ៏ចំរើន អវិជ្ជា តើដូចម្តេច មួយទៀត បុគ្គលដែលលុះក្នុងអវិជ្ជា តើដូចម្តេច ។ ម្នាលភិក្ខុ ការមិនដឹងទុក្ខ

ទុក្ខសមុទយេ អញ្ញាណំ ទុក្ខនិរោធេ អញ្ញាណំ ទុក្ខនិរោធគាមិនិយា បដិបទាយ អញ្ញាណំ ។ អយំ វុច្ចតិ ភិក្ខុ អវិជ្ជា ឯត្តាវតា ច អវិជ្ជាគតោ ហោតិ ។ តស្មាតិហ ភិក្ខុ ឥទំ ទុក្ខន្តិ យោគោ ករណីយោ ។ បេ ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យោគោ ករណីយោតិ ។

(៣៩៦) ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច វិជ្ជា វិជ្ជាតិ ភន្តេ វុច្ចតិ កតមា នុ ខោ ភន្តេ វិជ្ជា កិត្តាវតា ច វិជ្ជាគតោ ហោតីតិ ។ យំ ខោ ភិក្ខុ ទុក្ខេ ញាណំ ទុក្ខសមុទយេ ញាណំ ទុក្ខនិរោធេ ញាណំ ទុក្ខនិរោធគាមិនិយា បដិបទាយ ញាណំ ។ អយំ វុច្ចតិ ភិក្ខុ វិជ្ជា ឯត្តាវតា ច វិជ្ជាគតោ ហោតិ ។ តស្មាតិហ ភិក្ខុ ឥទំ ទុក្ខន្តិ យោគោ ករណីយោ ។ បេ ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យោគោ ករណីយោតិ ។

មិនដឹងហេតុជាទីកើតឡើងនៃទុក្ខ មិនដឹងទីរលត់ទុក្ខ មិនដឹងបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខឯណា ។ ម្នាលភិក្ខុ នេះហៅថា អវិជ្ជា មួយវិញទៀត បុគ្គលដែលលុះក្នុងអវិជ្ជា រមែងមានដោយហេតុប៉ុណ្ណោះឯង ។ ម្នាលភិក្ខុ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរធ្វើសេចក្តីព្យាយាមថា នេះជាទុក្ខ ។បេ។ គួរធ្វើសេចក្តីព្យាយាមថា នេះជាបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ ។

[៣៩៦] លុះភិក្ខុនោះ អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ដែលហៅថាវិជ្ជា ដូច្នេះ បពិត្រព្រះអង្គដ៏ចំរើន វិជ្ជា តើដូចម្តេច មួយទៀត បុគ្គលដែលប្រកបដោយវិជ្ជាដូចម្តេច ។ ម្នាលភិក្ខុ ការដឹងទុក្ខ ការដឹងហេតុជាទីកើតឡើងនៃទុក្ខ ការដឹងទីរលត់ទុក្ខ ការដឹងបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខឯណា ។ ម្នាលភិក្ខុ នេះហៅថា វិជ្ជា មួយវិញទៀត បុគ្គលដែលប្រកបដោយវិជ្ជា ក៏រមែងមានដោយហេតុប៉ុណ្ណោះឯង ។ ម្នាលភិក្ខុ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរធ្វើសេចក្តីព្យាយាមថា នេះជាទុក្ខ ។បេ។ គួរធ្វើសេចក្តីព្យាយាមថា នេះជាបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ ។

(៣៩៧) ឥទំ ទុក្ខំ អរិយសច្ចន្តិ ភិក្ខវេ មយា បញ្ញត្តំ តត្ថ អបរិមាណា វណ្ណា អបរិមាណា ព្យញ្ជនា អបរិមាណា សង្កាសនា(១) ឥតិបិទំ ទុក្ខំ អរិយសច្ចន្តិ ។ ឥទំ ទុក្ខសមុទយោ អរិយសច្ចន្តិ ភិក្ខវេ ។ បេ ។ ឥទំ ទុក្ខនិរោធគាមិនីបដិបទា អរិយសច្ចន្តិ ភិក្ខវេ មយា បញ្ញត្តំ តត្ថ អបរិមាណា វណ្ណា អបរិមាណា ព្យញ្ជនា អបរិមាណា សង្កាសនា ឥតិបិទំ ទុក្ខនិរោធគាមិនីបដិបទា អរិយសច្ចន្តិ ។ តស្មាតិហ ភិក្ខវេ ឥទំ ទុក្ខន្តិ យោគោ ករណីយោ ។ បេ ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យោគោ ករណីយោតិ ។

(៣៩៨) ចត្តារិមានិ ភិក្ខវេ តថានិ អវិតថានិ អនញ្ញថានិ ។ កតមានិ ចត្តារិ ។ ឥទំ ទុក្ខន្តិ ភិក្ខវេ តថមេតំ អវិតថមេតំ អនញ្ញថមេតំ ។ អយំ ទុក្ខសមុទយោតិ តថមេតំ អវិតថមេតំ អនញ្ញថមេតំ ។

១ សង្កស្សនាតិ ប្បត្តិ ។

(៣៩៧) ម្នាលភិក្ខុទាំងឡាយ សេចក្តីទុក្ខនេះ តថាគតបញ្ញត្តថាជាអរិយសច្ចដូច្នេះ វណ្ណៈគឺអក្ខរៈមានប្រមាណមិនបាន ព្យញ្ជនៈមានប្រមាណមិនបាន វិកត្តិក៏មានប្រមាណមិនបាន ក្នុងអរិយសច្ចនោះថា សេចក្តីទុក្ខនេះហៅថា អរិយសច្ច ដូច្នេះខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ហេតុជាទីកើតឡើងនៃទុក្ខនេះហៅថា អរិយសច្ច ។បេ។ ម្នាលភិក្ខុទាំងឡាយ បដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខនេះ តថាគតបញ្ញត្តថាជាអរិយសច្ច វណ្ណៈមានប្រមាណមិនបាន ព្យញ្ជនៈមានប្រមាណមិនបាន វិកត្តិក៏មានប្រមាណមិនបាន ក្នុងអរិយសច្ចនោះថា បដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខនេះហៅថា អរិយសច្ច ដូច្នេះខ្លះ ។ ម្នាលភិក្ខុ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះគួរធ្វើសេចក្តីព្យាយាមថា នេះជាទុក្ខ ។បេ។ គួរធ្វើសេចក្តីព្យាយាមថា នេះជាបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ ។

(៣៩៨) ម្នាលភិក្ខុទាំងឡាយ ធម្មជាត ៤ យ៉ាងនេះជារបស់ពិតមិនប្រែប្រួល មិនក្លាយទៅជារបស់ដទៃឡើយ ។ ធម្មជាត ៤ គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា នេះជាទុក្ខ +នុ៎ះជាធម្មជាតពិត មិនប្រែប្រួល មិនក្លាយទៅជារបស់ដទៃឡើយ ។ ពាក្យថា នេះជាហេតុជាទីកើតឡើងនៃទុក្ខ +នុ៎ះជាធម្មជាតពិត មិនប្រែប្រួល មិនក្លាយទៅជារបស់ដទៃឡើយ

អយំ ទុក្ខនិរោធោតិ ។ បេ ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ តថមេតំ អវិតថមេតំ អនញ្ញថមេតំ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ តថានិ អវិតថានិ អនញ្ញថានិ ។ តស្មាតិហ ភិក្ខវេ ឥទំ ទុក្ខន្តិ យោគោ ករណីយោ ។ បេ ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យោគោ ករណីយោតិ ។

ធម្មចក្កប្បវត្តនវគ្គោ ទុតិយោ ។

## តស្សុទ្ទានំ

តថាគតេន ទ្វេ វុត្តា
ខន្ធា អាយតនេន ច
ធារណាយ ច ទ្វេ វុត្តា អវិជ្ជា
វិជ្ជា សង្កាសនា តថេន ចាតិ ។

ពាក្យថា នេះជាសេចក្ដីរលត់ទុក្ខ ។ បេ ។ ពាក្យថា នេះជាបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខ នុ៎ះជាធម្មជាតពិត មិនប្រែប្រួល មិនក្លាយទៅជារបស់ដទៃឡើយ ។ ម្នាលភិក្ខុទាំងឡាយ ធម្មជាត ៤ នេះជារបស់ពិត មិនប្រែប្រួល មិនក្លាយទៅជារបស់ដទៃឡើយ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរធ្វើសេចក្ដីព្យាយាមថា នេះជាទុក្ខ ។ បេ ។ គួរធ្វើសេចក្ដីព្យាយាមថា នេះជាបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខ ។

ចប់ ធម្មចក្កប្បវត្តនវគ្គ ទី ២ ។

## ឧទ្ទាននៃធម្មចក្កប្បវត្តនវគ្គនោះគឺ

ពោលអំពីព្រះតថាគតមាន២លើក អំពីឧបាទានក្ខន្ធប្រាំ ១
អំពីអាយតនៈប្រាំមួយ ១ អំពីភិក្ខុចាំអរិយសច្ចមាន ២ លើក
អំពីអវិជ្ជា ១ អំពីវិជ្ជា ១ អរិយសច្ចមានវិកត្តិជាដើម ១
អំពីធម្មជាតពិត ១ ។

# កោដិគាមវគ្គោ តតិយោ

(៣៩៩) ឯកំ សមយំ ភគវា វជ្ជីសុ វិហរតិ កោដិគាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ចតុន្នំ ភិក្ខវេ អរិយសច្ចានំ អននុពោធា អប្បដិវេធា ឯវមិទំ ទីឃមទ្ធានំ សន្ធាវិតំ សំសរិតំ មមញ្ចេវ តុម្ហាកញ្ច ។ កតមេសំ ចតុន្នំ ។ ទុក្ខស្ស ភិក្ខវេ អរិយសច្ចស្ស អននុពោធា អប្បដិវេធា ឯវមិទំ ទីឃមទ្ធានំ សន្ធាវិតំ សំសរិតំ មមញ្ចេវ តុម្ហាកញ្ច ទុក្ខសមុទយស្ស អរិយសច្ចស្ស ។ បេ ។ ទុក្ខនិរោធស្ស អរិយសច្ចស្ស ។ ទុក្ខនិរោធគាមិនីបដិបទាយ អរិយសច្ចស្ស អននុពោធា អប្បដិវេធា ឯវមិទំ ទីឃមទ្ធានំ សន្ធាវិតំ សំសរិតំ មមញ្ចេវ តុម្ហាកញ្ច ។ តយិទំ ភិក្ខវេ ទុក្ខំ អរិយសច្ចំ អនុពុទ្ធំ បដិវិទ្ធំ ទុក្ខសមុទយោ អរិយសច្ចំ អនុពុទ្ធំ បដិវិទ្ធំ ទុក្ខនិរោធោ អរិយសចំ អនុពុទ្ធំ បដិវិទ្ធំ ទុក្ខនិរោធគាមិនីបដិបទា អរិយសច្ចំ អនុពុទ្ធំ បដិវិទ្ធំ ។

# កោដិគាមវគ្គ ទី ៣

(៣៩៩) សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងកោដិគ្រាម ក្នុងដែនវជ្ជី ។ ក្នុងទីនោះឯង ព្រះមានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតក្តី អ្នកទាំងឡាយក្តី ដែលអន្ទោល ត្រាច់វង្គត់ទៅ អស់កាលយូរអង្វែងយ៉ាងនេះ ព្រោះមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវអរិយសច្ច ៤ ។ អរិយសច្ច ៤ គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតក្តី អ្នកទាំងឡាយក្តី ដែលអន្ទោលទៅ ត្រាច់វង្គត់ទៅ អស់កាលយូរអង្វែងយ៉ាងនេះ ព្រោះមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវទុក្ខអរិយសច្ច ទុក្ខសមុទយអរិយសច្ច ។ បេ ។ ទុក្ខនិរោធអរិយសច្ច ។ តថាគតក្តី អ្នកទាំងឡាយក្តី ដែលអន្ទោលទៅ ត្រាច់វង្គត់ទៅ អស់កាលយូរអង្វែងយ៉ាងនេះ ព្រោះមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ។ ម្នាលភិក្ខុទាំងឡាយ ទុក្ខអរិយសច្ចនេះ តថាគតក្តី អ្នកទាំងឡាយក្តី បានត្រាស់ដឹងហើយ បានចាក់ធ្លុះហើយ ទុក្ខសមុទយអរិយសច្ច តថាគតក្តី អ្នកទាំងឡាយក្តី បានត្រាស់ដឹងហើយ បានចាក់ធ្លុះហើយ ទុក្ខនិរោធអរិយសច្ច តថាគតក្តី អ្នកទាំងឡាយក្តី បានត្រាស់ដឹងហើយ បានចាក់ធ្លុះហើយ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច តថាគតក្តី អ្នកទាំងឡាយក្តី បានត្រាស់ដឹងហើយ បានចាក់ធ្លុះហើយ ។

## កោដិគាមវគ្គោ តតិយោ

ឧច្ឆិន្នា ភវតណ្ហា ខីណា ភវនេត្តិ នត្ថិទានិ បុនព្ភ-វោតិ ។ ឥទមវោច ភគវា ឥទំ វត្វា សុគតោ អថាបរំ ឯតទវោច សត្ថា

[៤០០] ចតុន្នំ អរិយសច្ចានំ
យថាភូតមទស្សនា
សំសរិតំ ទីឃមទ្ធានំ
តាសុ តាស្វេវ ជាតិសុ ។
យានិ ឯតានិ ទិដ្ឋានិ
ភវនេត្តិ សមូហតា
ឧច្ឆិន្នំ មូលំ ទុក្ខស្ស
នត្ថិទានិ បុនព្ភវោតិ ។

[៤០១] យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឥទំ ទុក្ខន្តិ យថាភូតំ នប្បជានន្តិ អយំ ទុក្ខសមុទយោតិ យថាភូតំ នប្បជានន្តិ អយំ ទុក្ខនិរោធោតិ យថាភូតំ នប្បជានន្តិ អយំ ទុក្ខ-និរោធគាមិនីបដិបទាតិ យថាភូតំ នប្បជានន្តិ ។ ន មេតេ ភិក្ខវេ សមណា វា ព្រាហ្មណា វា

ភវតណ្ហាជាធម្មជាតិនាំសត្វឲ្យចូលទៅកាន់ភព បានផ្តាច់ផ្តិលអស់ហើយ ភពថ្មីទៀត ក្នុងកាលឥឡូវនេះមិនមានឡើយ ។ ព្រះមានព្រះភាគ បានត្រាស់ពាក្យនេះហើយ លុះព្រះសុគតទ្រង់ត្រាស់ពាក្យនេះចប់ហើយ ព្រះសាស្តាក៏ត្រាស់គាថានេះតទៅទៀតថា

[៤០០] តថាគតក្តី អ្នកទាំងឡាយក្តី ដែលអន្ទោលទៅ
ក្នុងជាតិទាំងឡាយនោះ ៗ អស់កាលយូរអង្វែង
ព្រោះមិនបានឃើញនូវអរិយសច្ច ៤ តាមសេចក្តីពិត ។
អរិយសច្ច ៤ នុ៎ះតថាគតបានឃើញហើយ តណ្ហាដែលនាំ
សត្វឲ្យចូលទៅកាន់ភព តថាគត បានដកចោលហើយ
ឫសគល់នៃសេចក្តីទុក្ខ តថាគត បានរំលើងចោលហើយ
ភពថ្មីទៀត ក្នុងកាលឥឡូវនេះ មិនមានឡើយ ។

[៤០១] ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ឯណានីមួយ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាហេតុជាទីកើតឡើងនៃទុក្ខ មិនដឹងច្បាស់តាមពិតថា នេះជាសេចក្តីរលត់ទុក្ខ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខ ៗ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ទាំងនុ៎ះ

សមណេសុ វា សមណសម្មតា ព្រាហ្មណេសុ វា ព្រាហ្មណសម្មតា ន ច បនេតេ អាយស្មន្តោ សាមញ្ញត្ថំ វា ព្រាហ្មញ្ញត្ថំ វា ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តិ ។

[៤០២] យេ ច ខោ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឥទំ ទុក្ខន្តិ យថាភូតំ បជានន្តិ អយំ ទុក្ខសមុទយោតិ យថាភូតំ បជានន្តិ អយំ ទុក្ខនិរោធោតិ យថាភូតំ បជានន្តិ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យថាភូតំ បជានន្តិ ។ តេ ខោ មេ ភិក្ខវេ សមណា វា ព្រាហ្មណា វា សមណេសុ ចេវ សមណសម្មតា ព្រាហ្មណេសុ ច ព្រាហ្មណសម្មតា តេ ច បនាយស្មន្តោ សាមញ្ញត្ថញ្ច ព្រាហ្មញ្ញត្ថញ្ច ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តីតិ ។ ឥទមវោច ភគវា ឥទំ វត្វាន សុគតោ អថាបរំ ឯតទវោច សត្ថា

តថាគតមិនបានសន្មតថាជាសមណៈក្នុងសមណៈទាំងឡាយផង មិនបានសន្មតថាជាព្រាហ្មណ៍ ក្នុងព្រាហ្មណ៍ទាំងឡាយផង ដ្បិតលោកដ៏មានអាយុទាំងនុះ មិនបានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវសាមញ្ញផលផង ព្រហ្មញ្ញផលផង ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្នហើយសម្រេចសម្រាន្តនៅ ។

[៤០២] ម្នាលភិក្ខុទាំងឡាយ លុះតែពួកសមណៈឬព្រាហ្មណ៍ឯណានីមួយ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាហេតុជាទីកើតឡើងនៃទុក្ខ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាសេចក្តីរលត់ទុក្ខ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ទាំងនោះទើបតថាគតសន្មតថា សមណៈក្នុងពួកសមណៈផង សន្មតថាព្រាហ្មណ៍ក្នុងពួកព្រាហ្មណ៍ផង ដ្បិតលោកដ៏មានអាយុទាំងនោះ បានធ្វើឲ្យជាក់ច្បាស់សម្រេចនូវសាមញ្ញផលផង ព្រហ្មញ្ញផលផង ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ហើយសម្រេចសម្រាន្តនៅ ។ ព្រះដ៏មានព្រះភាគ បានត្រាស់ពាក្យនេះ លុះព្រះសុគតបានត្រាស់ពាក្យនេះចប់ហើយ ទើបព្រះសាស្តាត្រាស់គាថានេះតទៅទៀតថា

(៤០៣) យេ ទុក្ខំ នប្បជានន្តិ
អថោ ទុក្ខស្ស សម្ភវំ
យត្ថ ច សព្វសោ ទុក្ខំ
អសេសំ ឧបរុជ្ឈតិ ។
តញ្ច មគ្គំ ន ជានន្តិ
ទុក្ខូបសមគាមិនំ
ចេតោវិមុត្តិហីនា តេ
អថោ បញ្ញាវិមុត្តិយា
អភព្វា តេ អន្តកិរិយាយ
តេ វេ ជាតិជរូបគា ។
យេ ច ទុក្ខំ បជានន្តិ
អថោ ទុក្ខស្ស សម្ភវំ
យត្ថ ច សព្វសោ ទុក្ខំ
អសេសំ ឧបរុជ្ឈតិ ។
តញ្ច មគ្គំ បជានន្តិ
ទុក្ខូបសមគាមិនំ

កោដិគាមវគ្គទី ៣

[៤០៣] ពួកជនណាមិនដឹងច្បាស់នូវសេចក្ដីទុក្ខ ទាំងហេតុដែលនាំឲ្យកើតទុក្ខ សេចក្ដីទុក្ខរលត់ ឥតមានសេសសល់ សព្វអន្លើ ព្រោះមគ្គឯណា ៗ ពួកជននោះមិនដឹងនូវមគ្គ ដែលជាដំណើរទៅកាន់សេចក្ដីរម្ងាប់ទុក្ខនោះ ជាអ្នកសាបសូន្យចាកចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ជនទាំងនោះ មិនគួរដើម្បីធ្វើទីបំផុតនៃសេចក្ដីទុក្ខ ជនទាំងនោះ ជាអ្នកចូលទៅកាន់ជាតិនិងជរា ៗ លុះតែពួកជនណា ដឹងច្បាស់នូវសេចក្ដីទុក្ខទាំងហេតុដែលនាំឲ្យកើតទុក្ខ សេចក្ដីទុក្ខ រមែងរលត់ទៅ ឥតមានសេសសល់សព្វអន្លើ ព្រោះមគ្គឯណា ៗ ពួកជននោះដឹងច្បាស់នូវមគ្គ ដែលជាដំណើរទៅកាន់សេចក្ដីស្ងប់រម្ងាប់ទុក្ខនោះ

ចេតោវិមុត្តិសម្បន្នា
អថោ បញ្ញាវិមុត្តិយោ
ភព្វា តេ អន្តកិរិយាយ
ន តេ ជាតិជរូបគាតិ ។

(៤០៤) សាវត្ថី ។ ចត្តារិមានិ ភិក្ខវេ អរិយសច្ចានិ ។ កតមានិ ចត្តារិ ។ ទុក្ខំ អរិយសច្ចំ ។បេ។ ទុក្ខនិរោធគាមិនីបដិបទា អរិយសច្ចំ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ អរិយសច្ចានិ ។ ឥមេសំ ខោ ភិក្ខវេ ចតុន្នំ អរិយសច្ចានំ យថាភូតំ អភិសម្ពុទ្ធត្តា តថាគតោ អរហំ សម្មាសម្ពុទ្ធោតិ វុច្ចតិ ។ តស្មាតិហ ភិក្ខវេ ឥទំ ទុក្ខន្តិ យោគោ ករណីយោ ។បេ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យោគោ ករណីយោតិ ។

(៤០៥) សាវត្ថី ។ យេបិ ហិ កេចិ ភិក្ខវេ អតីតមទ្ធានំ អរហន្តោ សម្មាសម្ពុទ្ធា យថាភូតំ អភិសម្ពុជ្ឈិំសុ សព្វេ តេ ចត្តារិ អរិយសច្ចានិ យថាភូតំ អភិសម្ពុជ្ឈិំសុ ។ យេបិ ហិ កេចិ ភិក្ខវេ

ជាអ្នកបរិបូណ៌ដោយចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ជនទាំង
នោះ គួរដើម្បីធ្វើទីបំផុតនៃសេចក្ដីទុក្ខបាន ជនទាំងនោះ
ជាអ្នកមិនចូលទៅជិតកាន់ជាតិនិងជរាឡើយ ។

[៤០៤] សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ អរិយសច្ចមាន ៤
នេះ ។ អរិយសច្ច ៤ គឺអ្វីខ្លះ ។ គឺទុក្ខអរិយសច្ច ១ ។ បេ ។ ទុក្ខនិរោធគាមិ-
នីបដិបទាអរិយសច្ច ១ ។ ម្នាលភិក្ខុទាំងឡាយ អរិយសច្ចមាន ៤ នេះឯង ។
ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតដែលមានឈ្មោះថា អរហំសម្មាសម្ពុទ្ធ
ព្រោះព្រះតថាគត បានត្រាស់ដឹងនូវអរិយសច្ច ៤ នេះ តាមសេចក្ដីពិត ។
ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរធ្វើសេចក្ដី
ព្យាយាមថា នេះជាទុក្ខ ។ បេ ។ គួរធ្វើសេចក្ដីព្យាយាមថា នេះជាបដិបទា
ជាដំណើរទៅកាន់ទីរលត់ទុក្ខ ។

[៤០៥] សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ ព្រះអរហន្ត-
សម្មាសម្ពុទ្ធទាំងឡាយណានីមួយ ក្នុងកាលជាអតីត ត្រាស់ដឹងហើយ
តាមសេចក្ដីពិត ព្រះអរហន្តសម្មាសម្ពុទ្ធគ្រប់ព្រះអង្គនោះ ត្រាស់
ដឹងហើយនូវអរិយសច្ច ៤ តាមសេចក្ដីពិត ។ ម្នាលភិក្ខុទាំងឡាយ

## កោដិគាមវគ្គោ តតិយោ

អនាគតមទ្ធានំ អរហន្តោ សម្មាសម្ពុទ្ធា យថាភូតំ
អភិសម្ពុជ្ឈិស្សន្តិ សព្វេ តេ ចត្តារិ អរិយសច្ចានិ
យថាភូតំ អភិសម្ពុជ្ឈិស្សន្តិ ។ យេ ហិ កេចិ
ភិក្ខវេ ឯតរហិ អរហន្តោ សម្មាសម្ពុទ្ធា យថាភូតំ
អភិសម្ពុជ្ឈន្តិ សព្វេ តេ ចត្តារិ អរិយសច្ចានិ យថា-
ភូតំ អភិសម្ពុជ្ឈន្តិ ។ កតមានិ ចត្តារិ ។ ទុក្ខំ
អរិយសច្ចំ ទុក្ខសមុទយោ អរិយសច្ចំ ទុក្ខនិរោធោ
អរិយសច្ចំ ទុក្ខនិរោធគាមិនីបដិបទា អរិយសច្ចំ ។
យេ ហិ កេចិ ភិក្ខវេ អតីតមទ្ធានំ អរហន្តោ
សម្មាសម្ពុទ្ធា យថាភូតំ អភិសម្ពុជ្ឈឹសុ អភិសម្ពុជ្ឈិ-
ស្សន្តិ អភិសម្ពុជ្ឈន្តិ សព្វេ តេ ឥមានិ ចត្តារិ
អរិយសច្ចានិ យថាភូតំ អភិសម្ពុជ្ឈន្តិ ។ តស្មាតិហ
ភិក្ខវេ ឥទំ ទុក្ខន្តិ យោគោ ករណីយោ
។ បេ ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យោគោ
ករណីយោតិ ។

ព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយណាទីមួយ ក្នុងកាលជាអនាគត នឹងត្រាស់ដឹងតាមសេចក្ដីពិត ព្រះអរហន្តសម្មាសម្ពុទ្ធគ្រប់ព្រះអង្គនោះ នឹងត្រាស់ដឹងនូវអរិយសច្ច ៤ តាមសេចក្ដីពិត ។ ម្នាលភិក្ខុទាំងឡាយ ព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយណាទីមួយ ក្នុងកាលជាបច្ចុប្បន្ន រមែងត្រាស់ដឹងតាមសេចក្ដីពិត ព្រះអរហន្តសម្មាសម្ពុទ្ធគ្រប់ព្រះអង្គនោះ រមែងត្រាស់ដឹងនូវអរិយសច្ច ៤ តាមសេចក្ដីពិត ។ អរិយសច្ច ៤ គឺអ្វីខ្លះ ។ គឺទុក្ខអរិយសច្ច ១ ទុក្ខសមុទយអរិយសច្ច ១ ទុក្ខនិរោធអរិយសច្ច ១ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ១ ។ ម្នាលភិក្ខុទាំងឡាយ ព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយណាទីមួយ ក្នុងកាលជាអតីត ត្រាស់ដឹងហើយនឹងត្រាស់ដឹងឥឡូវនេះ ត្រាស់ដឹងតាមសេចក្ដីពិត ពួកព្រះអរហន្តសម្មាសម្ពុទ្ធគ្រប់ព្រះអង្គនោះ រមែងត្រាស់ដឹងនូវអរិយសច្ច ៤ នេះ តាមសេចក្ដីពិត ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរធ្វើសេចក្ដីព្យាយាមថា នេះជាទុក្ខ ។ បេ ។ គួរធ្វើសេចក្ដីព្យាយាមថា នេះជាបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខ ។

[៤០៦] ជានតោ អហំ ភិក្ខវេ បស្សតោ អាសវានំ ខយំ វទាមិ នោ អជានតោ អបស្សតោ ។ កិញ្ច ភិក្ខវេ ជានតោ កិំ បស្សតោ អាសវានំ ខយោ ហោតិ ។ ឥទំ ទុក្ខន្តិ ភិក្ខវេ ជានតោ បស្សតោ អាសវានំ ខយោ ហោតិ អយំ ទុក្ខសមុទយោតិ ជានតោ បស្សតោ អាសវានំ ខយោ ហោតិ អយំ ទុក្ខនិរោធោតិ ជានតោ បស្សតោ អាសវានំ ខយោ ហោតិ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ ជានតោ បស្សតោ អាសវានំ ខយោ ហោតិ ។ ឯវំ ខោ ភិក្ខវេ ជានតោ ឯវំ បស្សតោ អាសវានំ ខយោ ហោតិ ។ តស្មាតិហ ភិក្ខវេ ឥទំ ទុក្ខន្តិ យោគោ ករណីយោ ។បេ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យោគោ ករណីយោតិ ។

[៤០៦] ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការអស់ទៅនៃអាសវៈទាំងឡាយចំពោះបុគ្គល ដែលដឹងដែលឃើញ មិនមែនចំពោះបុគ្គលដែលមិនដឹងមិនឃើញទេ ។ ម្នាលភិក្ខុទាំងឡាយ ចុះការអស់ទៅនៃអាសវៈទាំងឡាយ រមែងមានចំពោះបុគ្គល ដែលដឹងអ្វីដែលឃើញអ្វី ។ ម្នាលភិក្ខុទាំងឡាយ ការអស់ទៅនៃអាសវៈទាំងឡាយ រមែងមានចំពោះបុគ្គលដែលដឹងដែលឃើញថា នេះជាទុក្ខ ការអស់ទៅនៃអាសវៈទាំងឡាយ រមែងមានចំពោះបុគ្គលដែលដឹងដែលឃើញថា នេះជាហេតុជាទីកើតឡើងនៃទុក្ខ ការអស់ទៅនៃអាសវៈទាំងឡាយ រមែងមានចំពោះបុគ្គលដែលដឹងដែលឃើញថា នេះជាសេចក្តីរលត់ទុក្ខ ការអស់ទៅនៃអាសវៈទាំងឡាយ រមែងមានចំពោះបុគ្គលដែលដឹងដែលឃើញថា នេះជាបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ការអស់ទៅនៃអាសវៈទាំងឡាយ រមែងមានចំពោះបុគ្គលដែលដឹងយ៉ាងនេះ ដែលឃើញយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរធ្វើសេចក្តីព្យាយាមថា នេះជាទុក្ខ ។ បេ ។ គួរធ្វើសេចក្តីព្យាយាមថា នេះជាបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ ។

## កោដិគាមវគ្គោ តតិយោ

[៤០៧] យេ ហិ កេចិ ភិក្ខវេ អនុកម្បេយ្យាថ យេ ច សោតព្វំ មញ្ញេយ្យុំ មិត្តា វា អមច្ចា វា ញាតី វា សាលោហិតា វា តេ វោ ភិក្ខវេ ចតុន្នំ អរិយសច្ចានំ យថាភូតំ អភិសមយាយ សមាទបេតព្វា និវេសេតព្វា បតិដ្ឋាបេតព្វា ។ កតមេសំ ចតុន្នំ ។ ទុក្ខស្ស អរិយសច្ចស្ស ទុក្ខសមុទយស្ស អរិយសច្ចស្ស ទុក្ខនិរោធស្ស អរិយសច្ចស្ស ទុក្ខនិរោធគាមិនិបដិបទាយ អរិយសច្ចស្ស ។ យេ ហិ កេចិ ភិក្ខវេ អនុកម្បេយ្យាថ យេ ច សោតព្វំ មញ្ញេយ្យុំ មិត្តា វា អមច្ចា វា ញាតី វា សាលោហិតា វា ។ បេ ។ តេ វោ ភិក្ខវេ ឥមេសំ ចតុន្នំ អរិយសច្ចានំ យថាភូតំ អភិសមយាយ សមាទបេតព្វា និវេសេតព្វា បតិដ្ឋាបេតព្វា ។ តស្មាតិហ ភិក្ខវេ ឥទំ ទុក្ខន្តិ យោគោ ករណីយោ ។ បេ ។ អយំ ទុក្ខនិរោធគាមិនិបដិបទាតិ យោគោ ករណីយោតិ ។

## កោដិគាមវគ្គទី ៣

(៤០៧) ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគួរអនុគ្រោះចំពោះជនពួកណាមួយ មួយទៀត ជនពួកណាជាមិត្តក្តី ជាអមាត្យក្តី ញាតិក្តី សាលោហិតក្តី គប្បីសំគាល់នូវពាក្យដែលគួរស្តាប់ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គួរញុំាងជនទាំងនោះឲ្យសមាទាន ឲ្យតាំងនៅ ឲ្យដំកល់នៅ ក្នុងការត្រាស់ដឹងនូវអរិយសច្ច ៤ តាមសេចក្តីពិត ។ អរិយសច្ច ៤ គឺអ្វីខ្លះ ។ គឺទុក្ខអរិយសច្ច ១ ទុក្ខសមុទយអរិយសច្ច ១ ទុក្ខនិរោធអរិយសច្ច ១ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ១ ។ ម្នាលភិក្ខុទាំងឡាយ គួរអ្នកទាំងឡាយអនុគ្រោះចំពោះជនពួកណាមួយ មួយទៀត ជនពួកណា ជាមិត្តក្តី អមាត្យក្តី ញាតិក្តី សាលោហិតក្តី គប្បីសំគាល់នូវពាក្យដែលគួរស្តាប់ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គួរញុំាងជនទាំងនោះឲ្យសមាទាន ឲ្យតាំងនៅ ឲ្យដំកល់នៅក្នុងការត្រាស់ដឹងនូវអរិយសច្ច ៤ នេះ តាមសេចក្តីពិត ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរធ្វើសេចក្តីព្យាយាមថា នេះជាទុក្ខ ។បេ។ គួរធ្វើសេចក្តីព្យាយាមថា នេះជាបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខ ។

[២០៨] ចត្តារិមានិ ភិក្ខវេ អរិយសច្ចានិ ។ កតមានិ ចត្តារិ ។ ទុក្ខំ អរិយសច្ចំ ទុក្ខសមុទយោ អរិយសច្ចំ ទុក្ខនិរោធោ អរិយសច្ចំ ទុក្ខនិរោធគាមិនីបដិបទា អរិយសច្ចំ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ អរិយសច្ចានិ តថានិ អវិតថានិ អនញ្ញថានិ តស្មា អរិយសច្ចានីតិ វុច្ចតិ ។ តស្មាតិហ ភិក្ខវេ ឥទំ ទុក្ខន្តិ យោគោ ករណីយោ ។ បេ ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យោគោ ករណីយោតិ ។

[២០៩] ចត្តារិមានិ ភិក្ខវេ អរិយសច្ចានិ ។ កតមានិ ចត្តារិ ។ ទុក្ខំ អរិយសច្ចំ ទុក្ខសមុទយោ អរិយសច្ចំ ទុក្ខនិរោធោ អរិយសច្ចំ ទុក្ខនិរោធគាមិនីបដិបទា អរិយសច្ចំ ។ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ តថាគតោ អរិយោ តស្មា អរិយសច្ចានីតិ វុច្ចន្តិ ។ តស្មាតិហ ភិក្ខវេ ឥទំ ទុក្ខន្តិ យោគោ ករណីយោ ។ បេ ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យោគោ ករណីយោតិ ។

[៤០៨] ម្នាលភិក្ខុទាំងឡាយ អរិយសច្ច ៤ នេះ ។ អរិយសច្ច ៤ គឺអ្វីខ្លះ ។ ទុក្ខអរិយសច្ច ១ ទុក្ខសមុទយអរិយសច្ច ១ ទុក្ខនិរោធអរិយសច្ច ១ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ១ ។ ម្នាលភិក្ខុទាំងឡាយ អរិយសច្ច ៤ នេះជារបស់ពិត មិនប្រែប្រួល មិនក្លាយទៅជារបស់ដទៃឡើយ ព្រោះហេតុនោះ បានជាតថាគត ហៅថា អរិយសច្ច ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរធ្វើសេចក្ដីព្យាយាមថា នេះជាទុក្ខ ។ បេ ។ គួរធ្វើសេចក្ដីព្យាយាមថា នេះជាបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខ ។

[៤០៩] ម្នាលភិក្ខុទាំងឡាយ អរិយសច្ច ៤ នេះ ។ អរិយសច្ច ៤ គឺអ្វីខ្លះ ។ គឺទុក្ខអរិយសច្ច ១ ទុក្ខសមុទយអរិយសច្ច ១ ទុក្ខនិរោធអរិយសច្ច ១ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ១ ។ ព្រះតថាគតជាអរិយបុគ្គលក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេពនឹងមនុស្សដ៏សេស ព្រោះហេតុនោះ (សច្ច ៤ ដែលតថាគតសំដែងហើយ) ហៅថា អរិយសច្ច ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរធ្វើសេចក្ដីព្យាយាមថា នេះជាទុក្ខ ។ បេ ។ គួរធ្វើសេចក្ដីព្យាយាមថា នេះជាបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខ ។

## កោដិគាមវគ្គោ តតិយោ

[៥១០] ចត្តារិមានិ ភិក្ខវេ អរិយសច្ចានិ ។ កតមានិ ចត្តារិ ។ ទុក្ខំ អរិយសច្ចំ ទុក្ខសមុទយោ អរិយសច្ចំ ទុក្ខនិរោធោ អរិយសច្ចំ ទុក្ខនិរោធគាមិនីបដិបទា អរិយសច្ចំ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ អរិយសច្ចានិ ។ ឥមេសំ ខោ ភិក្ខវេ ចតុន្នំ អរិយសច្ចានំ អត្ថិ អរិយសច្ចំ បរិញ្ញេយ្យំ អត្ថិ អរិយសច្ចំ បហាតព្វំ អត្ថិ អរិយសច្ចំ សច្ឆិកាតព្វំ អត្ថិ អរិយសច្ចំ ភាវេតព្វំ ។ កតមញ្ច ភិក្ខវេ អរិយសច្ចំ បរិញ្ញេយ្យំ ។ ទុក្ខំ ភិក្ខវេ អរិយសច្ចំ បរិញ្ញេយ្យំ ទុក្ខសមុទយោ អរិយសច្ចំ បហាតព្វំ ទុក្ខនិរោធោ អរិយសច្ចំ សច្ឆិកាតព្វំ ទុក្ខនិរោធគាមិនីបដិបទា អរិយសច្ចំ ភាវេតព្វំ ។ តស្មាតិហ ភិក្ខវេ ឥទំ ទុក្ខន្តិ យោគោ ករណីយោ ។បេ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យោគោ ករណីយោតិ ។

កោដិគាមវគ្គទី ៣

(៤១០) ម្នាលភិក្ខុទាំងឡាយ អរិយសច្ចមាន ៤ នេះ ។ អរិយសច្ច៤ គឺអ្វីខ្លះ ។ គឺទុក្ខអរិយសច្ច១ ទុក្ខសមុទយអរិយសច្ច១ ទុក្ខនិរោធអរិយសច្ច ១ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ១ ។ ម្នាលភិក្ខុទាំងឡាយ អរិយសច្ចមាន៤នេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាអរិយសច្ច៤នេះ អរិយសច្ចគួរកំណត់ដឹងក៏មាន អរិយសច្ចគួរលះបង់ក៏មាន អរិយសច្ចគួរធ្វើឲ្យជាក់ច្បាស់ក៏មាន អរិយសច្ចគួរចំរើនក៏មាន ។ ម្នាលភិក្ខុទាំងឡាយ ចុះអរិយសច្ចដូចម្តេចដែលគួរកំណត់ដឹង ។ ម្នាលភិក្ខុទាំងឡាយ ទុក្ខអរិយសច្ច គួរកំណត់ដឹង ទុក្ខសមុទយអរិយសច្ច គួរលះបង់ ទុក្ខនិរោធអរិយសច្ច គួរធ្វើឲ្យជាក់ច្បាស់ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច គួរចំរើន ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរធ្វើសេចក្តីព្យាយាមថា នេះជាទុក្ខ ។បេ។ គួរធ្វើសេចក្តីព្យាយាមថា នេះជាបដិបទា ជាដំណើរទៅកាន់ទីរំលត់ទុក្ខ ។

(៤១១) ឯកំ សមយំ សម្ពហុលា ថេរា ភិក្ខូ ចេតិយេសុ(១) វិហរន្តិ សហជនិយេ(២) ។ តេន ខោ បន សមយេន សម្ពហុលានំ ថេរានំ ភិក្ខូនំ បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តានំ មណ្ឌលមាឡេ សន្និសិន្នានំ សន្និបតិតានំ អយមន្តរាកថា ឧទបាទិ យោ នុ ខោ អាវុសោ ទុក្ខំ បស្សតិ ទុក្ខសមុទយំបិ សោ បស្សតិ ទុក្ខនិរោធំបិ បស្សតិ ទុក្ខនិរោធគាមិនឹ បដិបទំបិ បស្សតីតិ ។

(៤១២) ឯវំ វុត្តេ អាយស្មា គវម្បតិត្ថេរោ ភិក្ខូ ឯតទវោច សម្មុខា មេតំ អាវុសោ ភគវតោ សុតំ សម្មុខា បដិគ្គហិតំ យោ ភិក្ខវេ ទុក្ខំ បស្សតិ ទុក្ខសមុទយំបិ សោ បស្សតិ ទុក្ខនិរោធំបិ បស្សតិ ទុក្ខនិរោធគាមិនឹ បដិបទំបិ បស្សតិ ។ យោ ទុក្ខសមុទយំ បស្សតិ ទុក្ខំបិ សោ បស្សតិ ទុក្ខនិរោធំបិ បស្សតិ

---

១ ឱ. ម. ចេតេសុ ។ ២ សហញ្ចនិកេ ។

[៤១១] សម័យមួយ ពួកភិក្ខុជាថេរៈច្រើនរូបនៅក្នុងក្រុងសហជនិយៈ ក្នុងដែនចេតិយៈ ។ ក៏សម័យនោះឯង កាលភិក្ខុជាថេរៈមានប្រមាណច្រើនរូប ត្រឡប់មកពីបិណ្ឌបាតក្នុងវេលាក្រោយភត្ត អង្គុយប្រជុំគ្នាក្នុងរោងមូល ក៏កើតមានពាក្យជាចន្លោះឡើងថា ម្នាលអាវុសោ បុគ្គលណាឃើញសេចក្តីទុក្ខ បុគ្គលនោះឈ្មោះថា ឃើញហេតុជាទីកើតឡើងនៃទុក្ខផង ឃើញទីរលត់នៃទុក្ខផង ឃើញបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខផង ។

[៤១២] កាលបើភិក្ខុទាំងនោះពោលយ៉ាងនេះហើយ តវម្បុតិតេរដ៏មានអាយុ ក៏ពោលនឹងពួកភិក្ខុដូច្នេះថា ម្នាលអាវុសោទាំងឡាយ ពាក្យនុះខ្ញុំបានស្តាប់មកក្នុងទីចំពោះព្រះភក្ត្រព្រះដ៏មានបុណ្យ ខ្ញុំបានទទួលក្នុងទីចំពោះព្រះភក្ត្រព្រះដ៏មានបុណ្យថា ម្នាលភិក្ខុទាំងឡាយ បុគ្គលណាឃើញទុក្ខ បុគ្គលនោះឈ្មោះថា ឃើញទុក្ខសមុទ័យផង ឃើញទុក្ខនិរោធផង ឃើញទុក្ខនិរោធគាមិនីបដិបទាផង ។ បុគ្គលណាឃើញទុក្ខសមុទ័យ បុគ្គលនោះឈ្មោះថា ឃើញទុក្ខផង ឃើញទុក្ខនិរោធផង

### កោដិគាមវគ្គោ តតិយោ

ទុក្ខនិរោធគាមិនី បដិបទំបិ បស្សតិ ។ យោ ទុក្ខនិរោធំ បស្សតិ ទុក្ខំបិ សោ បស្សតិ ទុក្ខសមុទយំបិ បស្សតិ ទុក្ខនិរោធគាមិនី បដិបទំបិ បស្សតិ ។ យោ ទុក្ខនិរោធគាមិនី បដិបទំ បស្សតិ ទុក្ខំបិ សោ បស្សតិ ទុក្ខសមុទយំបិ បស្សតិ ទុក្ខនិរោធំបិ បស្សតីតិ ។

កោដិគាមវគ្គោ តតិយោ ។

### តស្សុទ្ទានំ

ទ្វេ វជ្ជី សម្មាសម្ពុទ្ធោ
អរហំ អាសវក្ខយោ
មិត្តំ(១) តថា ច លោកោ ច
អភិញ្ញេយ្យំ គវម្បតីតិ ។

---

១ ឱ. មិត្តា ។

## កោដិគាមវគ្គ ទី ៣

ឃើញទុក្ខនិរោធគាមិនីបដិបទាផង ។ បុគ្គលណា ឃើញទុក្ខនិរោធ បុគ្គលនោះឈ្មោះថា ឃើញទុក្ខផង ឃើញទុក្ខសមុទ័យផង ឃើញទុក្ខនិរោធគាមិនីបដិបទាផង ។ បុគ្គលណា ឃើញទុក្ខនិរោធគាមិនីបដិបទា បុគ្គលនោះឈ្មោះថា ឃើញទុក្ខផង ឃើញទុក្ខសមុទ័យផង ឃើញទុក្ខនិរោធផង ។

ចប់ កោដិគាមវគ្គទី ៣ ។

## ឧទ្ទាននៃកោដិគាមវគ្គនោះគឺ

ពោលអំពីព្រះដ៏មានព្រះភាគគង់នៅក្នុងដែនវជ្ជីមាន២លើក អំពីឈ្មោះថាអរហន្តសម្មាសម្ពុទ្ធព្រោះត្រាស់ដឹងអរិយសច្ច១ អំពីព្រះអរហន្តសម្មាសម្ពុទ្ធត្រាស់ដឹងហើយក្នុងអតីតកាលជាដើម១ អំពីការអស់ទៅនៃអាសវៈ១ អំពីទ្រង់សំដែងការអនុគ្រោះជនជាមិត្រជាដើម១ អំពីការទ្រង់សំដែងធម្មជាតជារបស់ពិត១ អំពីព្រះតថាគតជាអរិយបុគ្គលក្នុងលោក១ អំពីអរិយសច្ចដែលបុគ្គលគួរត្រាស់ដឹង១ អំពីព្រះគវម្បតិត្ថេរ១ ។

# សីសបាបណ្ណវគ្គោ ចតុត្ថោ

(៤១៣) ឯកំ សមយំ ភគវា កោសម្ពិយំ វិហរតិ សីសបាវនេ ។ អថខោ ភគវា បរិត្តានិ សីសបាបណ្ណានិ បាណិនា គហេត្វា ភិក្ខូ អាមន្តេសិ តំ កឹ មញ្ញថ ភិក្ខវេ កតមំ នុ ខោ ពហុតរំ យានិ វា មយា បរិត្តានិ សីសបាបណ្ណានិ បាណិនា គហិតានិ យទិទំ ឧបរិ សីសបាយេតិ(១) ។ អប្បមត្តកានិ ភន្តេ ភគវតា បរិត្តានិ សីសបាបណ្ណានិ បាណិនា គហិតានិ អថខោ ឯតានេវ ពហុតរានិ យទិទំ ឧបរិ សីសបាយេតិ(២) ។ ឯវមេវ ខោ ភិក្ខវេ ឯតទេវ ពហុតរំ យំ វោ មយា អភិញ្ញាយ អនក្ខាតំ(៣) ។ កស្មា ចេតំ ភិក្ខវេ មយា អនក្ខាតំ ។ ន ហេតំ ភិក្ខវេ អត្ថសញ្ហិតំ នាទិព្រហ្មចរិយកំ ន និព្វិទាយ ន វិរាគាយ ន និរោធាយ ន ឧបសមាយ

---

១ ឱ. សីសបាបណ្ណានំ ។ ២ ម. សីសបាវនេតិ ។ ឱ. សីសបាវនេតិ ។ ៣ ឱ. ឥតោបរំ អប្បមត្តកំ អក្ខាតន្តិ ទិស្សតិ ។

## សីសបាបណ្ណវគ្គ ទី ៤

(៤១៣) សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងសីសបាវន (ព្រៃឈើ) ទៀបក្រុងកោសម្ពី ។ គ្រានោះឯង ព្រះមានព្រះភាគទ្រង់ចាប់ស្លឹកឈើបន្តិចដោយព្រះហស្ត ត្រាស់សួរភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកសំគាល់សេចក្តីនុ៎ះដូចម្តេច ស្លឹកឈើបន្តិចដែលតថាគតចាប់ដោយដៃក្តី ស្លឹកឈើដែលនៅឯដើមឈើក្តី ស្លឹកនោះតើស្លឹកណាច្រើនជាង ។ បពិត្រព្រះអង្គដ៏ចំរើន ស្លឹកឈើ ដែលព្រះមានព្រះភាគចាប់ដោយព្រះហស្តមានប្រមាណតិចណាស់ ឯស្លឹកឈើទាំងនោះ ដែលនៅដើមឈើមានចំនួនច្រើនជាង ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះមែនហើយ ពាក្យណា ដែលតថាគតមិនសំដែងដើម្បីសេចក្តីត្រាស់ដឹងដល់អ្នកទាំងឡាយ ពាក្យនុ៎ះឯងមានចំនួនច្រើនជាង ។ ម្នាលភិក្ខុទាំងឡាយ ពាក្យនុ៎ះបានជាតថាគតមិនសំដែង ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាពាក្យនុ៎ះ មិនប្រកបដោយប្រយោជន៍ មិនមែនជាអាទិព្រហ្មចរិយធម៌ មិនប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ មិនប្រព្រឹត្តទៅដើម្បីប្រាសចាកតម្រេក មិនប្រព្រឹត្តទៅដើម្បីរលត់ទុក្ខ មិនប្រព្រឹត្តទៅដើម្បីស្ងប់រម្ងាប់

ន អភិញ្ញាយ ន សម្ពោធាយ ន និព្វានាយ សំវត្តតិ ។ តស្មា តំ មយា អនក្ខាតំ ។

(៤០៤) កិញ្ច ភិក្ខវេ មយា អក្ខាតំ ។ ឥទំ ទុក្ខន្តិ ភិក្ខវេ មយា អក្ខាតំ អយំ ទុក្ខសមុទយោតិ មយា អក្ខាតំ អយំ ទុក្ខនិរោធោតិ មយា អក្ខាតំ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ មយា អក្ខាតំ ។ កស្មា ចេតំ ភិក្ខវេ មយា អក្ខាតំ ។ ឯតញ្ហិ ភិក្ខវេ អត្ថសញ្ហិតំ ឯតំ អាទិព្រហ្មចរិយកំ ឯតំ និព្វិទាយ វិរាគាយ និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ។ តស្មា តំ អក្ខាតំ ។ តស្មាតិហ ភិក្ខវេ ឥទំ ទុក្ខន្តិ យោគោករណីយោ ។បេ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យោគោ ករណីយោតិ ។

(៤០៥) យោ ភិក្ខវេ ឯវំ វទេយ្យ

មិនប្រព្រឹត្តទៅដើម្បីដឹងច្បាស់ មិនប្រព្រឹត្តទៅដើម្បីត្រាស់ដឹង មិនប្រព្រឹត្តទៅដើម្បីនិព្វាន ។ ព្រោះហេតុនោះ បានជាតថាគត មិនសំដែងពាក្យនោះឡើយ ។

(៨១៨) ម្នាលភិក្ខុទាំងឡាយ ចុះតថាគត សំដែងពាក្យដូចម្តេចវិញ ។ ម្នាលភិក្ខុទាំងឡាយ តថាគតសំដែងថា នេះជាទុក្ខ តថាគតសំដែងថា នេះហេតុជាទីកើតឡើងនៃទុក្ខ តថាគតសំដែងថា នេះជាសេចក្តីរលត់ទុក្ខ តថាគតសំដែងថា នេះបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យនុ៎ះបានជាតថាគតសំដែង តើព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា ពាក្យនុ៎ះប្រកបដោយប្រយោជន៍ ពាក្យនុ៎ះជាអាទិព្រហ្មចរិយធម៌ ពាក្យនុ៎ះប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីរលត់ទុក្ខ ដើម្បីសេចក្តីស្ងប់រម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ។ ព្រោះហេតុនោះ បានជាតថាគតសំដែងពាក្យនុ៎ះ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរធ្វើសេចក្តីព្យាយាមថា នេះជាទុក្ខ ។បេ។ គួរធ្វើសេចក្តីព្យាយាមថា នេះបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ ។

(៨១៩) ម្នាលភិក្ខុទាំងឡាយ បុគ្គលណា និយាយយ៉ាងនេះថា

អហំ ទុក្ខំ អរិយសច្ចំ យថាភូតំ អនភិសមេច្ច ទុក្ខសមុទយំ អរិយសច្ចំ យថាភូតំ អនភិសមេច្ច ទុក្ខនិរោធំ អរិយសច្ចំ យថាភូតំ អនភិសមេច្ច ទុក្ខនិរោធគាមិនីបដិបទំ អរិយសច្ចំ យថាភូតំ អនភិសមេច្ច សម្មា ទុក្ខស្សន្តំ ករិស្សាមីតិ នេតំ ឋានំ វិជ្ជតិ ។ សេយ្យថាបិ ភិក្ខវេ យោ ឯវំ វទេយ្យ អហំ ខទិរបត្តានំ វា បលាសបត្តានំ វា អាមលកបត្តានំ(១) វា បុដំ ករិត្វា ឧទកំ វា តាលបត្តំ(២) វា ហរិស្សាមីតិ(៣) នេតំ ឋានំ វិជ្ជតិ ។ ឯវមេវ ខោ ភិក្ខវេ យោ ឯវំ វទេយ្យ អហំ ទុក្ខំ អរិយសច្ចំ យថាភូតំ អនភិសមេច្ច ។ បេ ។ ទុក្ខនិរោធគាមិនីបដិបទំ អរិយសច្ចំ យថាភូតំ អនភិសមេច្ច សម្មា ទុក្ខស្សន្តំ ករិស្សាមីតិ នេតំ ឋានំ វិជ្ជតិ ។

[៤១៦] យោ ច ខោ ភិក្ខវេ ឯវំ វទេយ្យ អហំ ទុក្ខំ អរិយសច្ចំ យថាភូតំ អភិសមេច្ច

---

១ ម. សលិលបត្តានំ អាមលកិប្បត្តានំ វា ។ ២ តាលុទកន្តិ មញ្ញេ ភវេយ្យ ។ អយមេវ បាឋោ យុត្តតរោ ។ ៣ ឱ. ម. អាហរិស្សាមីតិ ។

ខ្ញុំមិនបានត្រាស់ដឹងនូវទុក្ខអរិយសច្ច តាមសេចក្ដីពិត មិនបានត្រាស់ដឹងនូវទុក្ខសមុទយអរិយសច្ច តាមសេចក្ដីពិត មិនបានត្រាស់ដឹងនូវទុក្ខនិរោធ-អរិយសច្ច តាមសេចក្ដីពិត មិនបានត្រាស់ដឹងនូវទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច តាមសេចក្ដីពិត តែនឹងធ្វើនូវទីធំបំផុតនៃសេចក្ដីទុក្ខដោយប្រពៃបាន ហេតុនុ៎ះមិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាបុគ្គលណា និយាយយ៉ាងនេះថា ខ្ញុំធ្វើកញ្ចប់នៃស្លឹកគគីរក្តី ស្លឹកស្រល់ក្តី ស្លឹកកន្ទួតព្រៃក្តី ហើយនឹងនាំទៅនូវទឹក ឬចម្រៀកត្នោត(១) ហេតុនុ៎ះមិនមានឡើយ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលណា និយាយយ៉ាងនេះថា ខ្ញុំមិនបានត្រាស់ដឹងនូវទុក្ខអរិយសច្ច តាមសេចក្ដីពិត ។បេ។ មិនបានត្រាស់ដឹងនូវទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច តាមសេចក្ដីពិត តែនឹងធ្វើនូវទីបំផុតនៃសេចក្ដីទុក្ខ ដោយប្រពៃបាន ហេតុនុ៎ះ មិនមានឡើយ ក៏យ៉ាងនោះដែរ ។

[៤១៦] ម្នាលភិក្ខុទាំងឡាយ លុះតែបុគ្គលណា និយាយយ៉ាងនេះថា ខ្ញុំបានត្រាស់ដឹងនូវទុក្ខអរិយសច្ច តាមសេចក្ដីពិត

---

១.. ស័ព្ទថា តាលបត្តំ គួរប្រែថាស្លឹកត្នោត ដ្បិតស្លឹកត្នោតឬចម្រៀកត្នោត ប៉ុន្តែមិនសមសេចក្ដីសោះ ក្នុងទីនេះគួរថា តាលុទកំ ប្រែថាទឹកត្នោតខ្ចិច្ចេះវិញ ទើបសមសេចក្ដីផង ។

ទុក្ខសមុទយំ អរិយសច្ចំ យថាភូតំ អភិសមេច្ច ទុក្ខនិរោធំ អរិយសច្ចំ យថាភូតំ អភិសមេច្ច ទុក្ខនិរោធគាមិនីបដិបទំ អរិយសច្ចំ យថាភូតំ អភិសមេច្ច សម្មា ទុក្ខស្សន្តំ ករិស្សាមីតិ ឋានមេតំ វិជ្ជតិ ។ សេយ្យថាបិ ភិក្ខវេ យោ ឯវំ វទេយ្យ អហំ បទុមបត្តានំ វា បលាសបត្តានំ វា មាលុវបត្តានំ(១) វា បុដំ ករិត្វា ឧទកំ វា តាលបត្តំ វា ហរិស្សាមីតិ(២) ឋានមេតំ វិជ្ជតិ ។ ឯវមេវ ខោ ភិក្ខវេ យោ ឯវំ វទេយ្យ អហំ ទុក្ខំ អរិយសច្ចំ យថាភូតំ អភិសមេច្ច ។បេ។ ទុក្ខនិរោធគាមិនីបដិបទំ អរិយសច្ចំ យថាភូតំ អភិសមេច្ច សម្មា ទុក្ខស្សន្តំ ករិស្សាមីតិ ឋានមេតំ វិជ្ជតិ ។ តស្មាតិហ ភិក្ខវេ ឥទំ ទុក្ខន្តិ យោគោ ករណីយោ ។ បេ ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យោគោ ករណីយោតិ ។

---

១ ឱ. មាលុវាបត្តានិ វា ។ ម មាលុវប្បត្តានិ វា ។ ២ ឱ ម. អាហរិស្សាមីតិ ។

## សីសបាបណ្ណវគ្គ ទី ៤

ត្រាស់ដឹងនូវទុក្ខសមុទយអរិយសច្ច តាមសេចក្តីពិត ត្រាស់ដឹងនូវទុក្ខនិរោធអរិយសច្ច តាមសេចក្តីពិត ត្រាស់ដឹងនូវទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច តាមសេចក្តីពិតនឹងធ្វើនូវទីបំផុតនៃទុក្ខ ដោយប្រពៃបាន ហេតុនុ៎ះទើបមានមែន ។ ម្នាលភិក្ខុទាំងឡាយ ដូចជាបុគ្គលណា និយាយយ៉ាងនេះថា ខ្ញុំធ្វើនូវកញ្ចប់នៃស្លឹកឈូកក្តី ស្លឹកចារក្តី ស្លឹកល្មុក្តី ហើយនឹងនាំទៅនូវទឹកឬបម្រៀកត្នោត ហេតុនុ៎ះទើបមានមែន យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលណា និយាយយ៉ាងនេះថា ខ្ញុំត្រាស់ដឹងនូវទុក្ខអរិយសច្ច តាមសេចក្តីពិត ។បេ។ ត្រាស់ដឹងនូវទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច តាមសេចក្តីពិត នឹងធ្វើនូវទីបំផុតនៃទុក្ខ ដោយប្រពៃបាន ហេតុនុ៎ះទើបមានមែន ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរធ្វើសេចក្តីព្យាយាមថា នេះជាទុក្ខ ។បេ។ គួរធ្វើសេចក្តីព្យាយាមថា នេះបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខ ។

(២១៧) សេយ្យថាបិ ភិក្ខវេ ទណ្ឌោ ឧបរិវេហាសំ ខិត្តោ សកិម្បិ មូលេន និបតតិ សកិម្បិ មជ្ឈេន និបតតិ សកិម្បិ អគ្គេន និបតតិ ។ ឯវមេវ ខោ ភិក្ខវេ អវិជ្ជានីវរណា សត្តា តណ្ហាសញ្ញោជនា សន្ធាវន្តា(១) សំសរន្តា សកិម្បិ អស្មា លោកា បរំ លោកំ គច្ឆន្តិ សកិម្បិ បរស្មា លោកា ឥមំ លោកំ អាគច្ឆន្តិ ។ តំ កិស្ស ហេតុ ។ អទិដ្ឋត្តា ភិក្ខវេ ចតុន្នំ អរិយសច្ចានំ ។ កតមេសំ ចតុន្នំ ។ ទុក្ខស្ស អរិយសច្ចស្ស ។បេ។ ទុក្ខនិរោធគាមិនីបដិបទាយ អរិយសច្ចស្ស ។ តស្មាតិហ ភិក្ខវេ ឥទំ ទុក្ខន្តិ យោគោ ករណីយោ ។បេ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យោគោ ករណីយោតិ ។

(២១៨) អាទិត្តេ ភិក្ខវេ ចេលេ វា សីសេ វា កិមស្ស ករណីយន្តិ ។ អាទិត្តេ ភន្តេ ចេលេ វា សីសេ វា តស្សេវ ចេលស្ស វា សីសស្ស វា និព្វាបនាយ អធិមត្តោ ឆន្ទោ ច វាយាមោ ច

---

១ ម. តណ្ហា ញោជនពទ្ធា ន្ធាវតា ។

(៤១៧) ម្នាលភិក្ខុទាំងឡាយ ដូចដំបងដែលគេបោលទៅឯអាកាស តែងធ្លាក់ចុះខាងគល់ដំបងក៏មាន ធ្លាក់ចុះត្រង់កណ្តាលដំបងក៏មាន ធ្លាក់ចុះខាងចុងដំបងក៏មាន យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយដែលមានអវិជ្ជាជាគ្រឿងរាំង មានតណ្ហាជាគ្រឿងប្រកប កាលអន្ទោលទៅ ត្រាច់រង្គាត់ទៅ តែងចេញពីលោកនេះ ទៅកាន់លោកដទៃក៏មាន ត្រឡប់មកពីលោកដទៃ មកកាន់លោកនេះក៏មាន ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាសត្វទាំងនោះមិនបានឃើញនូវអរិយសច្ច ៤ ។ អរិយសច្ច ៤ គឺអ្វីខ្លះ ។ គឺទុក្ខអរិយសច្ច ១ ។ បេ ។ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ១ យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរធ្វើសេចក្តីព្យាយាមថា នេះជាទុក្ខ ។ បេ ។ គួរធ្វើសេចក្តីព្យាយាមថា នេះបដិបទាជាដំណើរទៅកាន់ទីរំលត់ទុក្ខ ។

(៤១៨) ម្នាលភិក្ខុទាំងឡាយ សំពត់ឬក្បាល ដែលភ្លើងកំពុងឆេះ បុរសនោះគួរធ្វើដូចម្តេច ។ បពិត្រព្រះអង្គដ៏ចំរើន កាលបើសំពត់ឬក្បាលដែលភ្លើងកំពុងឆេះ បុរសនោះគួរធ្វើសេចក្តីប៉ុនប៉ងផង ព្យាយាមផង

ឧស្សាហោ ច ឧស្សោឡ្ហី ច អប្បដិវានិ ច សតិ ច សម្បជញ្ញញ្ច ករណីយន្តិ ។ អាទិត្តំ ភិក្ខវេ ចេលំ វា សីសំ វា អជ្ឈុបេក្ខិត្វា អមនសិការិត្វា អនភិសមេតានំ ចតុន្នំ អរិយសច្ចានំ យថាភូតំ អភិសមយាយ អធិមត្តោ ឆន្ទោ ច វាយាមោ ច ឧស្សាហោ ច ឧស្សោឡ្ហី ច អប្បដិវានិ ច សតិ ច សម្បជញ្ញញ្ច ករណីយំ ។ កតមេសំ ចតុន្នំ ។ ទុក្ខស្ស អរិយសច្ចស្ស ។បេ។ ទុក្ខនិរោធគាមិនី-បដិបទាយ អរិយសច្ចស្ស ។ តស្មាតិហ ភិក្ខវេ ឥទំ ទុក្ខន្តិ យោគោ ករណីយោតិ ។បេ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យោគោ ករណីយោតិ ។

(៤១៩) សេយ្យថាបិ ភិក្ខវេ បុរិសោ វស្សសតា-យុកោ វស្សសតជីវិតមេនំ ឯវំ វទេយ្យ ឯហម្ភោ បុរិស បុព្វណ្ហសមយំ តំ សត្តិសតេន ហនិស្សន្តិ មជ្ឈន្តិក-សមយំ សត្តិសតេន ហនិស្សន្តិ សាយណ្ហសមយំ សត្តិសតេន(១) ហនិស្សន្តិ ។ សោ ខោ ត្វំ អម្ភោ បុរិស

---

១ ឱ. សត្តិសតេហិ ។

## សីសបាបណ្ណវគ្គ ទី ៤

សេចក្តីប្រឹងប្រែងផង សេចក្តីខ្មីឃ្មាតផង ការមិនរុញរាផង សតិផង សម្បជញ្ញៈផង ដ៏មាំមួន ដើម្បីនឹងលត់នូវសំពត់ឬក្បាលនោះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលគួរកុំសំឡឹងមើល កុំយកចិត្តទុកដាក់ចំពោះសំពត់ឬក្បាល ដែលភ្លើងកំពុងឆេះឡើយ គួរធ្វើសេចក្តីប៉ុនប៉ងផង សេចក្តីព្យាយាមផង សេចក្តីខ្មីឃ្មាតផង ការមិនរុញរាផង សតិផង សម្បជញ្ញៈផង ដ៏មាំមួន ដើម្បីនឹងត្រាស់ដឹងនូវអរិយសច្ច ៤ ដែលខ្លួនមិនទាន់បានត្រាស់ដឹងតាមសេចក្តីពិតនៅឡើយ ។ អរិយសច្ច ៤ គឺអ្វីខ្លះ ។ គឺទុក្ខអរិយសច្ច ១ ។បេ។ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ១ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរធ្វើសេចក្តីព្យាយាមថា នេះជាទុក្ខ ។បេ។ គួរធ្វើសេចក្តីព្យាយាមថា នេះបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ ។

[៤១៩] ម្នាលភិក្ខុទាំងឡាយ ដូចបុរសមានអាយុ ១០០ ឆ្នាំនិយាយនឹងបុរសដែលមានអាយុរស់នៅ ១០០ ឆ្នាំដូចគ្នាយ៉ាងនេះថា នែបុរសអើយ ចូរអ្នកមកអាយ ជនទាំងឡាយនឹងសំឡាប់អ្នក ដោយរយនៃលំពែងក្នុងបុព្វណ្ហសម័យ (ពេលព្រឹក) នឹងសំឡាប់អ្នក ដោយរយនៃលំពែងក្នុងមជ្ឈន្តិកសម័យ (ពេលថ្ងៃត្រង់) នឹងសំឡាប់អ្នក ដោយរយនៃលំពែងក្នុងសាយណ្ហសម័យ (ពេលល្ងាច) ។ បុរសនោះ ក៏និយាយថា នែបុរសអើយ

ទិវសេ ទិវសេ តីណិ សត្តិសតេហិ ហញ្ញមានោ វស្សសតាយុកោ វស្សសតជីវី វស្សសតស្ស អច្ចយេន អនភិសមេតានិ ចត្តារិ អរិយសច្ចានិ អភិសមេស្សសីតិ ។ អត្ថវសិកេន ភិក្ខវេ កុលបុត្តេន អលំ ឧបគន្តុំ ។ តំ កិស្ស ហេតុ ។ អនមតគ្គោយំ ភិក្ខវេ សំសារោ បុព្វា កោដិ ន បញ្ញាយតិ សត្តិប្បហារានំ អសិប្បហារានំ ឧសុប្បហារានំ ផរសុប្បហារានំ ។ ឯវំ ចេតំ ភិក្ខវេ អស្ស ន ខោ បនាហំ ភិក្ខវេ សហ ទុក្ខេន សហ ទោមនស្សេន ចតុន្នំ អរិយសច្ចានំ អភិសមយំ វទាមិ ។ អបិ ចាហំ ភិក្ខវេ សហា វ សុខេន សហា វ សោមនស្សេន ចតុន្នំ អរិយសច្ចានំ អភិសមយំ វទាមិ ។ កតមេសំ ចតុន្នំ ។ ទុក្ខស្ស អរិយសច្ចស្ស ។ បេ ។ ទុក្ខនិរោធគាមិនីបដិបទា អរិយសច្ចស្ស ។ តស្មាតិហ ភិក្ខវេ ឥទំ ទុក្ខន្តិ យោគោ ករណីយោ ។ បេ ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យោគោ ករណីយោតិ ។

(៤២០) សេយ្យថាបិ ភិក្ខវេ បុរិសោ យំ ឥមស្មឹ ជម្ពុទីបេ តិណកដ្ឋសាខាបលាសំ តច្ឆេត្វា ឯកជ្ឈំ សំហរេយ្យ

អ្នកឯងមានអាយុ ១០០ ឆ្នាំ រស់នៅអស់ ១០០ ឆ្នាំ កាលបើត្រូវគេសំឡាប់ដោយលំពែង ៣០០ រាល់ៗថ្ងៃ លុះកន្លង ១០០ ឆ្នាំទៅ នឹងបានត្រាស់ដឹងនូវអរិយសច្ច ៤ ដែលមិនទាន់បានត្រាស់ដឹងនៅឡើយ ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្តដែលលុះក្នុងអំណាចនៃប្រយោជន៍ គួរតែចូលទៅ ។ ដំណើរនោះព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាសង្សារនេះមិនមានទីបំផុតទេ ខាងដើមនឹងខាងចុងនៃការប្រហារដោយលំពែង ប្រហារដោយដាវ ប្រហារដោយកូនសរ ប្រហារដោយប៉ូថៅ ក៏មិនប្រាកដឡើយ ។ ម្នាលភិក្ខុទាំងឡាយ ដំណើរនោះគួរមានយ៉ាងនេះមែន ម្នាលភិក្ខុទាំងឡាយ តែតថាគតមិនបានពោលនូវការត្រាស់ដឹងនូវអរិយសច្ច ៤ ជាមួយនឹងសេចក្តីទុក្ខ ជាមួយនឹងទោមនស្សទេ ។ ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែតថាគតតែងពោលនូវសេចក្តីត្រាស់ដឹងចំពោះអរិយសច្ចទាំង ៤ ជាមួយនឹងសេចក្តីសុខ នឹងសោមនស្សទេតើ ។ អរិយសច្ច ៤ គឺអ្វីខ្លះ ។ គឺទុក្ខអរិយសច្ច ១ ។ បេ ។ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ១ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរធ្វើសេចក្តីព្យាយាមថា នេះជាទុក្ខ ។ បេ ។ គួរធ្វើសេចក្តីព្យាយាមថា នេះបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខ ។

[៤២០] ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសកាត់ស្មៅ កំណាត់ឈើ មែកឈើ ស្លឹកឈើ ក្នុងជម្ពូទ្វីបនេះ មកប្រមូលទុក ក្នុងទីជាមួយគ្នា

ឯកជ្ឈំ សំហរិត្វា សូលំ ការេយ្យ សូលំ ការិត្វា យេ មហាសមុទ្ទេ មហន្តកា មច្ឆា តេ មហន្តកេសុ សូលេសុ អាវុនេយ្យ យេ មហាសមុទ្ទេ មជ្ឈិមកា មច្ឆា តេ មជ្ឈិមកេសុ សូលេសុ អាវុនេយ្យ យេ មហាសមុទ្ទេ សុខុមកា មច្ឆា តេ សុខុមកេសុ សូលេសុ អាវុនេយ្យ ។ អបរិយាទិន្នា ច ភិក្ខវេ មហាសមុទ្ទេ ឱឡារិកា មច្ឆា អស្សុ អថ ឥមស្មិំ(១) ជម្ពុទីបេ តិណកដ្ឋសាខាបលាសំ បរិក្ខយំ បរិយាទានំ គច្ឆេយ្យ ។ ឥតោ(២) ពហុតរា ខោ ភិក្ខវេ មហាសមុទ្ទេ សុខុមកា មច្ឆា យេ ន សុករា សូលេន(៣) អាវុនិតុំ ។ តំ កិស្ស ហេតុ ។ សុខុមត្តា ភិក្ខវេ អត្តភាវស្ស ។ ឯវំ មហា ខោ ភិក្ខវេ អបាយោ ។ ឯវំ មហន្តស្មា ខោ ភិក្ខវេ អបាយស្មា បរិមុត្តោ ទិដ្ឋិសម្បន្នោ បុគ្គលោ ឥទំ(៤) ទុក្ខន្តិ យថាភូតំ បជានាតិ ។បេ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យថាភូតំ បជានាតិ ។ តស្មាតិហ ភិក្ខវេ ឥទំ ទុក្ខន្តិ យោគោ ករណីយោ ។បេ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យោគោ ករណីយោតិ ។

---

១ ឱ. អថ តេ ឥមស្មិំ ។ ២ ឱ.ម. អតោ ។ ៣ ឱ.ម. សូលេសុ ។ ៤ ឱ. យោ ឥទំ ។

## សីសបាបណ្ណវគ្គ ទី ៤

លុះប្រមូលទុកក្នុងទីជាមួយគ្នាហើយ គប្បីធ្វើជាឈើអណ្តែត លុះធ្វើជាឈើអណ្តែតហើយ ទើបដោតពួកសត្វធំៗដែលនៅក្នុងមហាសមុទ្រក្នុងឈើអណ្តែតធំៗ ដោតពួកសត្វជាន់កណ្តាលៗ ដែលនៅក្នុងមហាសមុទ្រក្នុងឈើអណ្តែតជាន់កណ្តាលៗ ដោតពួកសត្វតូចៗដែលនៅក្នុងមហាសមុទ្រក្នុងឈើអណ្តែតតូចៗ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វធំៗក្នុងមហាសមុទ្រ មិនអស់ទេ ឯស្មៅ កំណាត់ឈើ មែកឈើ ស្លឹកឈើក្នុងជម្ពូទ្វីបនេះដល់នូវការអស់ទៅសូន្យទៅមិនខាន ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វតូចៗ ក្នុងមហាសមុទ្រ ច្រើនជាងពួកសត្វធំៗទៅទៀត បុគ្គលណាមួយ មិនងាយនឹងដោតដោយឈើអណ្តែតឡើយ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះសត្វទាំងនោះមានអត្តភាពតូចៗ ។ ម្នាលភិក្ខុទាំងឡាយ អបាយធំយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលរួចចាកអបាយដែលធំយ៉ាងនេះ ជាអ្នកបរិបូណ៌ដោយទិដ្ឋិ ទើបដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខ ។ បេ ។ ដឹងច្បាស់តាមសេចក្តីពិតថា នេះបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរធ្វើសេចក្តីព្យាយាមថា នេះជាទុក្ខ ។ បេ ។ គួរធ្វើសេចក្តីព្យាយាមថា នេះបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ ។

(៤២១) សុរិយស្ស ភិក្ខវេ ឧទយតោ ឯតំ បុព្វង្គមំ ឯតំ បុព្វនិមិត្តំ យទិទំ អរុណុគ្គំ ។ ឯវមេវ ខោ ភិក្ខវេ ភិក្ខុនោ ចតុន្នំ អរិយសច្ចានំ យថាភូតំ អភិសមយាយ ឯតំ បុព្វង្គមំ ឯតំ បុព្វនិមិត្តំ យទិទំ សម្មាទិដ្ឋិ ។ សម្មាទិដ្ឋិកស្សេតំ ភិក្ខវេ ភិក្ខុនោ បាដិកង្ខំ ឥទំ ទុក្ខន្តិ យថាភូតំ បជានិស្សតិ ។បេ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យថាភូតំ បជានិស្សតិ ។ តស្មាតិហ ភិក្ខវេ ឥទំ ទុក្ខន្តិ យោគោ ករណីយោ ។បេ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យោគោ ករណីយោតិ ។

(៤២២) យាវកីវញ្ច ភិក្ខវេ ចន្ទិមសុរិយា លោកេ នុប្បជ្ជន្តិ នេវ តាវ មហតោ អាលោកស្ស បាតុភាវោ ហោតិ មហតោ ឱភាសស្ស អន្ធតមំ តទា ហោតិ អន្ធការតិមិសា នេវ តាវ រត្តិន្ទិវា បញ្ញាយន្តិ ន មាសឌ្ឍមាសា បញ្ញាយន្តិ ន ឧតុសំវច្ឆរា បញ្ញាយន្តិ ។ យតោ ច ខោ ភិក្ខវេ ចន្ទិមសុរិយា លោកេ ឧប្បជ្ជន្តិ អថ មហតោ អាលោកស្ស បាតុភាវោ ហោតិ មហតោ ឱភាសស្ស

[៤២១] ម្នាលភិក្ខុទាំងឡាយ កាលព្រះអាទិត្យរះឡើង រមែងមានការរះឡើងនៃអរុណ ជាប្រធានជាបុព្វនិមិត្ត ។ ម្នាលភិក្ខុទាំងឡាយយ៉ាងនេះមែនហើយ ភិក្ខុដែលត្រាស់ដឹងតាមសេចក្ដីពិតនូវអរិយសច្ច ៤ រមែងមានសម្មាទិដ្ឋិនុ៎ះ ជាប្រធានជាបុព្វនិមិត្ត ។ ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះ រមែងកើតប្រាកដដល់ភិក្ខុ ដែលប្រកបដោយសម្មាទិដ្ឋិ ដឹងច្បាស់តាមសេចក្ដីពិតថា នេះបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរធ្វើសេចក្ដីព្យាយាមថា នេះជាទុក្ខ ។ បេ ។ គួរធ្វើសេចក្ដីព្យាយាមថា នេះបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ ។

[៤២២] ម្នាលភិក្ខុទាំងឡាយ ព្រះចន្ទនិងព្រះអាទិត្យ មិនទាន់កើតឡើងក្នុងលោកដរាបណា ពន្លឺធំ រស្មីធំ ក៏មិនទាន់កើតប្រាកដក្នុងកាលនោះ មានតែងងឹតនឹងអ័ព្ទសូន្យឈឹងដរាបនោះ យប់នឹងថ្ងៃក៏មានមិនប្រាកដ ខែនិងកន្លះខែក៏មិនទាន់ប្រាកដ រដូវនិងឆ្នាំក៏មិនប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ លុះតែព្រះចន្ទនិងព្រះអាទិត្យកើតឡើងក្នុងលោកកាលណា ពន្លឺធំ រស្មីធំ ក៏កើតប្រាកដក្នុងកាលណោះ

## សីសបាបណ្ណវគ្គោ ចតុត្ថោ

នេវ អន្ធតមំ តទា ហោតិ ន អន្ធការតិមិសា អថ រត្តិន្ទិវា បញ្ញាយន្តិ មាសឌ្ឍមាសា បញ្ញាយន្តិ ឧតុ-សំវច្ឆរា បញ្ញាយន្តិ ។ ឯវមេវ ខោ ភិក្ខវេ យាវកីវញ្ច តថាគតោ លោកេ នុប្បជ្ជតិ អរហំ សម្មាសម្ពុទ្ធោ នេវ តាវ មហតោ អាលោកស្ស បាតុភាវោ ហោតិ មហតោ ឱភាសស្ស អន្ធតមំ តទា ហោតិ អន្ធការតិមិសា នេវ តាវ ចតុន្នំ អរិយសច្ចានំ អាចិក្ខណា ហោតិ ទេសនា បញ្ញាបនា បដ្ឋបនា វិវរណា វិភជនា ឧត្តានីកម្មំ ។ យតោ ច ខោ ភិក្ខវេ តថាគតោ លោកេ ឧប្បជ្ជតិ អរហំ សម្មាសម្ពុទ្ធោ អថ មហតោ អាលោកស្ស បាតុភាវោ ហោតិ មហតោ ឱភាសស្ស នេវ អន្ធតមំ តទា ហោតិ ន អន្ធការតិមិសា អថ(២) ចតុន្នំ អរិយសច្ចានំ អាចិក្ខណា ហោតិ ទេសនា បញ្ញាបនា បដ្ឋបនា វិវរណា វិភជនា ឧត្តានីកម្មំ ។ កតមេសំ ចតុន្នំ ។

---

១ ឱ. អន្ធតមោ ។ ២ ឱ. ម. អថខោ ។

អ័ព្ទសូន្យឈឹងក៏មិនមានឡើយក្នុងកាលណោះ យប់នឹងថ្ងៃក៏ប្រាកដ ខែនឹងកន្លះខែក៏ប្រាកដ រដូវនឹងឆ្នាំក៏ប្រាកដ ក្នុងកាលណោះ ៗ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះមែនហើយ ព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធមិនទាន់កើតឡើងក្នុងលោកដរាបណា ពន្លឺធំ រស្មីធំ ក៏មិនទាន់មានប្រាកដដរាបនោះ ក្នុងកាលណោះមានតែងងឹតទឹងអ័ព្ទសូន្យឈឹង ឯការប្រាប់ ការសំដែង ការតាក់តែង ការផ្តួចផ្តើម ការបើក ការចែករលែក ការធ្វើឲ្យរាក់ឡើងនូវអរិយសច្ច ៤ ក៏មិនទាន់មាននៅឡើយដរាបនោះ ៗ ម្នាលភិក្ខុទាំងឡាយ លុះតែព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធកើតឡើងក្នុងលោកកាលណា ពន្លឺធំ រស្មីធំ ទើបប្រាកដក្នុងកាលណោះ ងងឹតទឹងអ័ព្ទសូន្យឈឹងក៏មិនមានឡើយក្នុងកាលណោះ ឯការប្រាប់ ការសំដែង ការតាក់តែង ការផ្តួចផ្តើម ការបើក ការចែករលែក ការធ្វើឲ្យរាក់ឡើងនូវអរិយសច្ច ៤ ក៏មានប្រាកដក្នុងកាលណោះ ៗ អរិយសច្ច ៤ គឺអ្វីខ្លះ ៗ

ទុក្ខស្ស អរិយសច្ចស្ស ។ បេ ។ ទុក្ខនិរោធគាមិនីបដិបទាយ អរិយសច្ចស្ស ។ តស្មាតិហ ភិក្ខវេ ឥទំ ទុក្ខន្តិ យោគោ ករណីយោ ។ បេ ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យោគោ ករណីយោតិ ។

(៤២៣) យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឥទំ ទុក្ខន្តិ យថាភូតំ នប្បជានន្តិ ។ បេ ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យថាភូតំ នប្បជានន្តិ តេ អញ្ញស្ស សមណស្ស វា ព្រាហ្មណស្ស វា មុខំ ឱលោកេន្តិ អយំ នូន ភវំ ជានំ ជានាតិ បស្សំ បស្សតីតិ ។ សេយ្យថាបិ ភិក្ខវេ តូលបិចុ វា កប្បាសបិចុ វា លហុកោ វាតុបាទានោ សមេ ភូមិភាគេ និក្ខិត្តោ តមេនំ បុរត្ថិមោ វាតោ បច្ឆិមេន សំហរេយ្យ បច្ឆិមោ វាតោ បុរត្ថិមេន សំហរេយ្យ ឧត្តរោ វាតោ ទក្ខិណេន សំហរេយ្យ ទក្ខិណោ វាតោ ឧត្តរេន សំហរេយ្យ ។ តំ កិស្ស ហេតុ ។

គឺទុក្ខអរិយសច្ច ។បេ។ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរធ្វើសេចក្តីព្យាយាមថា នេះជាទុក្ខ ។បេ។ គួរធ្វើសេចក្តីព្យាយាមថា នេះបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខ ។

[៤៦៣] ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ឯណានីមួយ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខ ។បេ។ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខ សមណៈឬព្រាហ្មណ៍ទាំងនោះ រមែងក្រឡេកមើលមុខ (អធ្យាស្រ័យ) របស់សមណៈឬព្រាហ្មណ៍ដទៃថា លោកដ៏ចំរើននេះ កាលបើដឹង ក៏ដឹងដោយពិត កាលបើឃើញ ក៏ឃើញដោយពិត ។ ម្នាលភិក្ខុទាំងឡាយ ដូចប៉ុយគរឬកប្បាសដែលជារបស់ស្រាលមានខ្យល់ជាទុកធាន គេដាក់លើផែនដីដ៏ស្មើ ខ្យល់ពីខាងកើត ក៏បក់ប៉ុយនោះទៅខាងលិច ខ្យល់ពីខាងលិចបក់ប៉ុយនោះទៅខាងកើត ខ្យល់ពីខាងជើងបក់ប៉ុយនោះទៅខាងត្បូង ខ្យល់ពីខាងត្បូងបក់ប៉ុយនោះទៅខាងជើង ។ ដំណើរនោះ ព្រោះហេតុអ្វី ។

លហុកត្តា ភិក្ខវេ កប្បាសបិចុនោ ។ ឯវមេវ ខោ ភិក្ខវេ យេ ហិ កេចិ សមណា វា ព្រាហ្មណា វា ឥទំ ទុក្ខន្តិ យថាភូតំ នប្បជានន្តិ ។បេ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យថាភូតំ នប្បជានន្តិ តេ អញ្ញស្ស សមណស្ស វា ព្រាហ្មណស្ស វា មុខំ ឧល្លោកេន្តិ អយំ នូន ភវំ ជានំ ជានាតិ បស្សំ បស្សតីតិ ។ តំ កិស្ស ហេតុ ។ អទិដ្ឋត្តា ភិក្ខវេ ចតុន្នំ អរិយសច្ចានំ ។

(៤២៤) យេ ច ខោ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឥទំ ទុក្ខន្តិ យថាភូតំ បជានន្តិ ។បេ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យថាភូតំ បជានន្តិ តេ ន អញ្ញស្ស សមណស្ស វា ព្រាហ្មណស្ស វា មុខំ ឧល្លោកេន្តិ អយំ នូន ភវំ ជានំ ជានាតិ បស្សំ បស្សតីតិ ។ សេយ្យថាបិ ភិក្ខវេ អយោខីលោ វា ឥន្ទខីលោ វា គម្ភីរនេមោ សុនិខាតោ អចលោ

ម្នាលភិក្ខុទាំងឡាយ ព្រោះថាប៉ុយកឃ្លាសជារបស់ស្រាលយ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ឯណានីមួយ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខ ។ បេ ។ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះបដិបទាជាដំណើរទៅកាន់ទីរំលត់ទុក្ខ សមណៈឬព្រាហ្មណ៍ទាំងនោះ ក្រឡេកមើលមុខ របស់សមណៈឬព្រាហ្មណ៍ដទៃថា លោកដ៏ចំរើននេះ កាលបើដឹង ក៏ដឹងដោយពិត កាលបើឃើញ ក៏ឃើញដោយពិត ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា មិនបាន ឃើញនូវអរិយសច្ច ៤ ក៏យ៉ាងនោះឯង ។

[៤២៤] ម្នាលភិក្ខុទាំងឡាយ ឯពួកសមណៈឬព្រាហ្មណ៍ឯណា-នីមួយ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខ ។ បេ ។ ដឹងច្បាស់តាមសេចក្តីពិតថា នេះបដិបទាជាដំណើរទៅកាន់ទីរំលត់ទុក្ខ សមណៈឬព្រាហ្មណ៍ទាំងនោះ មិនក្រឡេកមើលមុខសមណៈឬព្រាហ្មណ៍ដទៃថា លោកដ៏ចំរើននេះ កាលបើដឹង ក៏ដឹងដោយពិត កាលបើឃើញ ក៏ឃើញដោយពិតដូច្នេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ដូចសសរដែកក្តី សសរគោលក្តី ដែលមានរណ្តៅដ៏ជ្រៅ គេដាំសិប់សួនល្អឥតមានកម្រើក ឥតមានញាប់ញ័រ បើទុកជាភ្លៀងលាយដោយខ្យល់ដ៏ខ្លាំងមកអំពីទិសខាងកើតក៏មិនធ្វើសសរនោះឲ្យកម្រើក មិនធ្វើឲ្យរញ្ជួយ មិនធ្វើឲ្យញាប់ញ័រ

អសម្បវេធី បុរត្ថិមាយ ចេបិ ទិសាយ អា-
គច្ឆេយ្យ ភុសា វាតវុដ្ឋិ នេវ សង្កម្បេយ្យ(១) ន
សម្បកម្បេយ្យ ន សម្បចាលេយ្យ បច្ឆិមាយ ចេបិ
ទិសាយ ។បេ។ ឧត្តរាយ ចេបិ ទិសាយ ទក្ខិណាយ
ចេបិ ទិសាយ អាគច្ឆេយ្យ ភុសា វាតវុដ្ឋិ នេវ
សង្កម្បេយ្យ ន សម្បកម្បេយ្យ ន សម្បចាលេយ្យ ។
តំ កិស្ស ហេតុ ។ គម្ភីរត្តា ភិក្ខវេ នេមស្ស សុនិ-
ខាតត្តា ឥន្ទខីលស្ស ។ ឯវមេវ ខោ ភិក្ខវេ យេ(២)
កេចិ សមណា វា ព្រាហ្មណា វា ឥទំ ទុក្ខន្តិ
យថាភូតំ បជានន្តិ ។បេ។ អយំ ទុក្ខនិរោធគាមិនី-
បដិបទាតិ យថាភូតំ បជានន្តិ តេ ន អញ្ញស្ស
សមណស្ស វា ព្រាហ្មណស្ស វា មុខំ ឱលោកេន្តិ
អយំ នូន ភវំ ជានំ ជានាតិ បស្សំ បស្សតីតិ ។
តំ កិស្ស ហេតុ ។ សុទិដ្ឋត្តា ភិក្ខវេ ចតុន្នំ
អរិយសច្ចានំ ។ កតមេសំ ចតុន្នំ ។

---

១ ឱ. នេវ នំ សង្កម្បេយ្យ ។ ២ ឱ. ម. យេ ច ខោ ។

បើទុកជាខ្យល់បក់មកអំពីទិសខាងលិចក្តី ។ បេ ។ អំពីខាងជើងក្តី ភ្លៀងដែលលាយដោយខ្យល់ដ៏ខ្លាំងមកអំពីទិសខាងត្បូងក្តី ក៏មិនធ្វើឲ្យសសរនោះកម្រើករញ្ជួយញាប់ញ័រឡើយ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះរណ្តៅជ្រៅ ព្រោះសសរ គេដាំស៊ប់ស្កួនល្អយ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ឯណា-នីមួយ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខ ។ បេ ។ ដឹងច្បាស់តាមសេចក្តីពិតថា នេះបដិបទា ជាដំណើរទៅកាន់ទីរំលត់ទុក្ខ សមណៈឬព្រាហ្មណ៍ទាំងនោះ មិនក្រឡេកមើលមុខសមណ ឬព្រាហ្មណ៍ដទៃថា លោកដ៏ចំរើននេះ កាលបើដឹងក៏ដឹងដោយពិត កាលបើឃើញក៏ឃើញដោយពិត ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាបានឃើញនូវអរិយសច្ច ៤ ដោយប្រពៃ ។ អរិយសច្ច ៤ គឺអ្វីខ្លះ ។

ទុក្ខស្ស អរិយសច្ចស្ស ។បេ។ ទុក្ខនិរោធគាមិនីបដិបទាយ អរិយសច្ចស្ស ។ តស្មាតិហ ភិក្ខវេ ឥទំ ទុក្ខន្តិ យោគោ ករណីយោ ។បេ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យោគោ ករណីយោតិ ។

(៤២៨) យោ ហិ កោចិ ភិក្ខវេ ភិក្ខុ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ ។បេ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យថាភូតំ បជានាតិ ។ បុរត្ថិមាយ ចេបិ ទិសាយ អាគច្ឆេយ្យ សមណោ វា ព្រាហ្មណោ វា វាទត្ថិកោ វាទគវេសី វាទមស្ស អារោបេស្សាមីតិ ។ តំ វត សហធម្មេន សង្កម្បេស្សតិ វា សម្បកម្បេស្សតិ វា សម្បចាលេស្សតិ វាតិ នេតំ ឋានំ វិជ្ជតិ ។ បច្ឆិមាយ ចេបិ ទិសាយ ។ ឧត្តរាយ ចេបិ ទិសាយ ។ ទក្ខិណាយ ចេបិ ទិសាយ អាគច្ឆេយ្យ សមណោ វា ព្រាហ្មណោ វា វាទត្ថិកោ វាទគវេសី វាទមស្ស អារោបេស្សាមីតិ ។ តំ វត សហធម្មេន សង្កម្បេស្សតិ វា សម្បកម្បេស្សតិ វា សម្បចាលេស្សតិ វាតិ នេតំ ឋានំ វិជ្ជតិ ។

គឺទុក្ខអរិយសច្ច ១ ។ បេ ។ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ១ ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរធ្វើសេចក្តីព្យាយាមថា នេះជាទុក្ខ ។ បេ ។ គួរធ្វើសេចក្តីព្យាយាមថា នេះបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ ។

[៤៤៩] ម្នាលភិក្ខុទាំងឡាយ ភិក្ខុឯណានីមួយ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខ ។ បេ ។ ដឹងច្បាស់តាមសេចក្តីពិតថា នេះបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ ។ ប្រសិនបើ សមណៈឬព្រាហ្មណ៍ អ្នកត្រូវការដោយវាទៈ អ្នកស្វែងរកវាទៈមកអំពីទិសខាងកើត ដោយគិតថា អាត្មាអញ នឹងលើកវាទៈរបស់ភិក្ខុនោះចេញ ។ សមណៈឬព្រាហ្មណ៍នោះនឹងធ្វើឲ្យភិក្ខុនោះកម្រើកក្តី រញ្ជួយក្តី ញាប់-ញ័រក្តី ដោយពាក្យប្រកបដោយធម៌ ហេតុនុ៎ះមិនមានឡើយ ។ បើមកអំពីទិសខាងលិចក្តី ។ មកអំពីទិសខាងជើងក្តី ។ ប្រសិនបើសមណៈឬព្រាហ្មណ៍ អ្នកត្រូវការដោយវាទៈស្វែងរកវាទៈ មកអំពីទិសខាងត្បូង ដោយគិតថា អាត្មាអញនឹងលើកវាទៈរបស់ភិក្ខុនោះចេញ ។ សមណៈឬព្រាហ្មណ៍នោះនឹងធ្វើឲ្យភិក្ខុនោះកម្រើកក្តី រញ្ជួយក្តី ញាប់ញ័រក្តី ដោយពាក្យប្រកបដោយធម៌ ហេតុនុ៎ះមិនមានឡើយ ។

សេយ្យថាបិ ភិក្ខវេ សិលាយូបោ សោឡស-
កុក្កុកោ តស្សស្សុ អដ្ឋកុក្កុ ហេដ្ឋានេមង្គមា
អដ្ឋកុក្កុ ឧបរិនេមស្ស បុរត្ថិមាយ ចេបិ
ទិសាយ អាគច្ឆេយ្យ ភុសា វាតវុដ្ឋិ នេវ សង្កម្បេយ្យ
ន សម្បកម្បេយ្យ ន សម្បចាលេយ្យ បច្ឆិមាយ ចេបិ
ទិសាយ ។ ឧត្តរាយ ចេបិ ទិសាយ ។ ទក្ខិណាយ
ចេបិ ទិសាយ អាគច្ឆេយ្យ ភុសា វាតវុដ្ឋិ នេវ
សង្កម្បេយ្យ ន សម្បកម្បេយ្យ ន សម្បចាលេយ្យ ។
តំ កិស្ស ហេតុ ។ គម្ភីរត្តា ភិក្ខវេ នេមស្ស សុនិ-
ខាតត្តា សិលាយូបស្ស ។ ឯវមេវ ខោ ភិក្ខវេ យោ
ហិ កោចិ ភិក្ខុ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ ។
បេ ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យថាភូតំ
បជានាតិ ។ បុរត្ថិមាយ ចេបិ ទិសាយ អាគច្ឆេយ្យ
សមណោ វា ព្រាហ្មណោ វា វាទត្ថិកោ វាទគវេសី
វាទមស្ស អារោបេស្សាមីតិ ។ តំ វត សហធម្មេន
សង្កម្បេស្សតិ វា សម្បកម្បេស្សតិ វា សម្បចាលេស្សតិ
វាតិ នេតំ ឋានំ វិជ្ជតិ ។ បច្ឆិមាយ ចេបិ ទិសាយ ។

ម្នាលភិក្ខុទាំងឡាយ ដូចសសរថ្មប្រវែង ១៦ ហត្ថ សសរថ្មនោះដាំចុះទៅក្នុងរណ្តៅខាងក្រោម៨ហត្ថ នៅខាងលើរណ្តៅ៨ហត្ថ ប្រសិនជាភ្លៀងលាយដោយខ្យល់ដ៏ខ្លាំង មកអំពីទិសខាងកើតក្តី ក៏មិនគប្បីធ្វើឲ្យកម្រើក ធ្វើឲ្យរញ្ជួយ ធ្វើឲ្យញាប់ញ័របានឡើយ បើមកអំពីទិសខាងលិចក្តី ។ អំពីទិសខាងជើងក្តី ។ បើទុកជាគ្រាប់ភ្លៀងលាយដោយខ្យល់ដ៏ខ្លាំង មកអំពីទិសខាងត្បូងក្តី ក៏មិនគប្បីធ្វើឲ្យកម្រើក ធ្វើឲ្យរញ្ជួយ ធ្វើឲ្យញាប់ញ័របានឡើយ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះរណ្តៅក៏ជ្រៅ សសរថ្មក៏គេដាំស៊ប់ស្ងួនល្អ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុឯណានីមួយ ដឹងច្បាស់តាមពិតថា នេះជាទុក្ខ ។បេ។ ដឹងច្បាស់តាមពិតថា នេះបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ ។ ទោះបីសមណៈឬព្រាហ្មណ៍ អ្នកត្រូវការដោយវាទៈ ស្វែងរកវាទៈ មកអំពីទិសខាងកើតក្តី ដោយគិតថា អាត្មាអញនឹងលើកនូវវាទៈរបស់ភិក្ខុនោះចេញ ។ សមណៈឬព្រាហ្មណ៍នោះនឹងធ្វើឲ្យភិក្ខុនោះកម្រើកក្តី ធ្វើឲ្យរញ្ជួយក្តី ធ្វើឲ្យញាប់ញ័រក្តី ដោយពាក្យប្រកបដោយធម៌ ហេតុនុ៎ះមិនមានឡើយ ។ អំពីទិសខាងលិចក្តី ។

ឧត្តរាយ ចេបិ ទិសាយ ។ ទក្ខិណាយ ចេបិ ទិសាយ អាគច្ឆេយ្យ សមណោ វា ព្រាហ្មណោ វា វាទត្ថិកោ វាទគវេសី វាទមស្ស អារោបេស្សាមីតិ ។ តំ វត សហធម្មេន សង្កម្បេស្សតិ វា សម្បកម្បេស្សតិ វា សម្បចាលេស្សតិ វាតិ នេតំ ឋានំ វិជ្ជតិ ។ តំ កិស្ស ហេតុ ។ សុទិដ្ឋត្តា ភិក្ខវេ ចតុន្នំ អរិយសច្ចានំ ។ កតមេសំ ចតុន្នំ ។ ទុក្ខស្ស អរិយសច្ចស្ស ។បេ។ ទុក្ខនិរោធគាមិនិបដិបទាយ អរិយសច្ចស្ស ។ តស្មាតិហ ភិក្ខវេ ឥទំ ទុក្ខន្តិ យោគោ ករណីយោ ។បេ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យោគោ ករណីយោតិ ។

**សីសបាបណ្ណវគ្គោ ចតុត្ថោ ។**

## សីសបាបណ្ណវគ្គទី ៤

អំពីទិសខាងជើងក្តី ។ ទោះបីសមណៈឬព្រាហ្មណ៍ អ្នកត្រូវការដោយវាទៈ ស្វែងរកវាទៈ មកអំពីទិសខាងត្បូង ដោយគិតថា អាត្មាអញនឹងលើកវាទៈរបស់ភិក្ខុនោះចេញ ។ សមណៈឬព្រាហ្មណ៍នោះនឹងធ្វើឲ្យភិក្ខុនោះកម្រើកក្តី នឹងធ្វើឲ្យរញ្ជួយក្តី នឹងធ្វើឲ្យញាប់ញ័រក្តី ដោយពាក្យប្រកបដោយធម៌ ហេតុនុ៎ះមិនមានឡើយ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះភិក្ខុនោះបានឃើញនូវអរិយសច្ច ៤ ដោយប្រពៃហើយ ។ អរិយសច្ច ៤ គឺអ្វីខ្លះ ។ គឺទុក្ខអរិយសច្ច ១ ។ បេ ។ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ១ ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរធ្វើសេចក្តីព្យាយាមថា នេះជាទុក្ខ ។ បេ ។ គួរធ្វើសេចក្តីព្យាយាមថា នេះបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខ ។

ចប់ សីសបាបណ្ណវគ្គ ទី ៤,

## តស្សុទ្ទានំ

សីសបា ខទិរោ ទណ្ឌោ
ចេលា សត្តិសតេន ច
បាណា សុរិយូបមា ទ្វេធា
ឥន្ទខីលោ ច វាទិនោតិ(១) ។

---

១ ឱ.ម. ភទិនោតិ បាឋោ ទិស្សតិ ។

## ឧទ្ទាននៃសីសបាបណ្ណវគ្គនោះគឺ

ពោលអំពីព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងសីសបាវន ១ អំពីសេចក្តីប្រៀបដូចស្លឹកគគីរជាដើម ១ អំពីសេចក្តីប្រៀបដូចដំបង ១ អំពីសេចក្តីប្រៀបដូចភ្លើងឆេះសំពត់ ១ អំពីសេចក្តីប្រៀបដូចបុរសដែលគេចាក់ដោយលំពែងរាប់រយ ១ អំពីការដោតពួកសត្វដោយឈើអណ្តោត ១ អំពីសេចក្តីប្រៀបដូចព្រះចន្ទ្រនិងព្រះអាទិត្យមានពីរលើក អំពីសេចក្តីប្រៀបដូចសសរគោល ១ អំពីអ្នកលើកវាទៈ ១ ។

# បបាតវគ្គោ បញ្ចមោ

(៤៤៦) ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភូតបុព្វំ ភិក្ខវេ អញ្ញតរោ បុរិសោ រាជគហា និក្ខមិត្វា លោកចិន្តំ ចិន្តេស្សាមីតិ យេន សុមាគធា បោក្ខរណី តេនុបសង្កមិ ឧបសង្កមិត្វា សុមាគធាយ បោក្ខរណិយា តីរេ និសីទិ លោកចិន្តំ ចិន្តេន្តោ ។ អទ្ទសា ខោ ភិក្ខវេ សោ បុរិសោ សុមាគធាយ បោក្ខរណិយា តីរេ ចតុរង្គិនឹ សេនំ ភិសមុឡាលំ បវិសន្តំ ។ ទិស្វានស្ស ឯតទហោសិ ឧម្មត្តោស្មិ នាមាហំ វិចេតោស្មិ នាមាហំ យំ លោកេ នត្ថិ តំ មយា ទិដ្ឋន្តិ ។ អថ ខោ សោ ភិក្ខវេ បុរិសោ នគរំ បវិសិត្វា មហា-ជនកាយស្ស អារោចេសិ ឧម្មត្តោស្មិ នាមាហំ ភន្តេ

# បបាតវគ្គ ទី ៥

(៤២៦) សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ ក្នុងទីនោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ពីព្រេងនាយមក មានបុរសម្នាក់ ចេញអំពីក្រុងរាជគ្រឹះដោយគិតថា អញនឹងគិតនូវលោកចិន្តា(១) ( គិតអំពីលោក ) ដូច្នេះហើយចូលទៅរកស្រះបោក្ខរណី ឈ្មោះសុមាគធា លុះចូលទៅដល់ហើយ ក៏អង្គុយទៀបឆ្នេរស្រះបោក្ខរណី ឈ្មោះសុមាគធា ហើយគិតលោកចិន្តា ។ ម្នាលភិក្ខុទាំងឡាយ បុរសនោះ ក៏ស្រាប់តែឃើញនូវសេនាមានអង្គ ៤ កំពុងចូលទៅក្នុងក្រឪឈូក ទៀបឆ្នេរស្រះបោក្ខរណីឈ្មោះសុមាគធា ។ លុះបុរសនោះឃើញហើយ ក៏មានសេចក្តីត្រិះរិះដូច្នេះថា អញជាមនុស្សឆ្កួតទេតើ អញជាមនុស្សមានបិត្តពាយមាយទេតើ វត្ថុណាមិនមានក្នុងលោក វត្ថុនោះអញបានឃើញហើយ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះបុរសនោះ ត្រឡប់ចូលទៅកាន់នគរ ហើយប្រាប់ពួកមហាជនថា នែអ្នកទាំងឡាយដ៏ចំរើន ខ្ញុំជាមនុស្សឆ្កួត

---

១ - គឺគិតថា នរណាបង្កើតព្រះចន្ទនឹងព្រះអាទិត្យ នរណាបង្កើតផែនដី នរណាតាក់តែងសមុទ្រ នរណាតាក់តែងពួកសត្វដែលជាឧបបាតិកៈ នរណាតាក់តែងភ្នំ នរណាតាក់តែងដើមស្វាយ ត្នោត ដូង ជាដើមមក នេះហៅថា លោកចិន្តា ( អដ្ឋកថា ។

វិចេតោស្មិ នាមាហំ ភន្តេ យំ លោកេ នត្ថិ តំ មយា ទិដ្ឋន្តិ ។ យថាកថំ បន(១) ត្វំ អម្ភោ បុរិស ឧម្មត្តោ កថំ វិចេតោ កិញ្ច លោកេ នត្ថិ យន្តយា ទិដ្ឋន្តិ ។ ឥធាហំ ភន្តេ រាជគហា និក្ខមិត្វា លោកចិន្តំ ចិន្តេស្សាមីតិ យេន សុមាគធា បោក្ខរណី តេនុបសង្កមឹ ឧបសង្កមិត្វា សុមាគធាយ បោក្ខរណិយា តីរេ និសីទឹ លោកចិន្តំ ចិន្តេន្តោ ។ អទ្ទសំ ខ្វាហំ ភន្តេ សុមាគធាយ បោក្ខរណិយា តីរេ ចតុរង្គិនឹ សេនំ ភិសមុឡាលំ បវិសន្តំ ។ ឯវំ ខ្វាហំ ភន្តេ ឧម្មត្តោ ឯវំ វិចេតោ ឥធញ្ច លោកេ នត្ថិ យំ មយា ទិដ្ឋន្តិ ។ តគ្ឃ ត្វំ អម្ភោ បុរិស ឧម្មត្តោ តគ្ឃ វិចេតោ ឥធញ្ច លោកេ នត្ថិ យំ តយា ទិដ្ឋន្តិ ។ តំ ខោ បន ភិក្ខវេ សោ បុរិសោ ភូតំយេវ អទ្ទស នោ អភូតំ ។

---

១ ម.ម. កថំ បន ត្វំ ។

នែអ្នកទាំងឡាយដ៏ចំរើន ខ្ញុំជាមនុស្សមានចិត្តភាយមាយ វត្ថុណាមិនមានក្នុងលោក វត្ថុនោះខ្ញុំបានឃើញហើយ ។ ពួកមហាជន តបវិញថា នែបុរសដ៏ចំរើន ចុះហេតុដូចម្តេច បានជាអ្នកឆ្កួត ហេតុដូចម្តេច បានជាអ្នកមានចិត្តភាយមាយ វត្ថុដែលអ្នកបានឃើញហើយមិនមានក្នុងលោកតើដូចម្តេច ។ នែអ្នកទាំងឡាយដ៏ចំរើន ក្នុងទីឯណោះ ខ្ញុំចេញអំពីក្រុងរាជគ្រឹះ ដោយគិតថា អាត្មាអញនឹងគិតនូវលោកចិន្តាដូច្នេះហើយចូលទៅរកស្រះបោក្ខរណីឈ្មោះសុមាគធា លុះចូលទៅដល់ហើយ ក៏អង្គុយទៀបឆ្នេរស្រះបោក្ខរណីឈ្មោះសុមាគធា គិតនូវលោកចិន្តា ។ នែអ្នកទាំងឡាយដ៏ចំរើន ខ្ញុំក៏បានឃើញនូវសេនាមានអង្គ ៤ កំពុងចូលទៅក្នុងក្រឱឈូកទៀបឆ្នេរស្រះបោក្ខរណីឈ្មោះសុមាគធា ។ នែអ្នកទាំងឡាយដ៏ចំរើន ខ្ញុំជាមនុស្សឆ្កួត យ៉ាងនេះឯង ខ្ញុំជាមនុស្សមានចិត្តភាយមាយ យ៉ាងនេះ វត្ថុដែលខ្ញុំឃើញនេះហើយមិនដែលមានក្នុងលោកទេ ។ នែបុរសដ៏ចំរើន ខ្ញុំសូមលើកអ្នក ជាមនុស្សឆ្កួតហើយ ខ្ញុំសូមលើកអ្នក ជាមនុស្ស មានចិត្តភាយមាយហើយ វត្ថុដែលអ្នកឃើញហើយនេះ មិនដែលមានក្នុងលោកទេ ។ ម្នាលភិក្ខុទាំងឡាយ ឯបុរសនោះបានឃើញវត្ថុដែលពិតមែន មិនមែនបានឃើញនូវវត្ថុដែលមិនពិតទេ ។

## បបាតវគ្គោ បញ្ចមោ

(៤២៧) ភូតបុព្វំ ភិក្ខវេ ទេវាសុរសង្គាមោ សមុបព្យូឡ្ហោ អហោសិ ។ តស្មឹ ខោ បន ភិក្ខវេ សង្គាមេ ទេវា ជិនឹសុ អសុរា បរាជិនឹសុ ។ បរាជិតា ច ខោ ភិក្ខវេ អសុរា ភីតា ភិសមុឡាលេន អសុរបុរំ បវិសឹសុ ទេវានំយេវ មោហយមានា(១) ។ តស្មាតិហ ភិក្ខវេ មា លោកចិន្តំ ចិន្តេថ សស្សតោ លោកោតិ វា អសស្សតោ លោកោតិ វា អន្តវា លោកោតិ វា អនន្តវា លោកោតិ វា តំ ជីវំ តំ សរីរន្តិ វា អញ្ញំ ជីវំ អញ្ញំ សរីរន្តិ វា ហោតិ តថាគតោ បរំ មរណាតិ វា ន ហោតិ តថាគតោ បរំ មរណាតិ វា ហោតិ ច ន ច ហោតិ តថាគតោ បរំ មរណាតិ វា នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ វា ។ តំ កិស្ស ហេតុ ។ នេសា ភិក្ខវេ ចិន្តា អត្ថសញ្ហិតា ន អាទិព្រហ្មចរិយកា ន និព្វិទាយ ន វិរាគាយ ន និរោធាយ ន ឧបសមាយ ន អភិញ្ញាយ ន សម្ពោធាយ ន និព្វានាយ សំវត្តតិ ។

---

១ ឱ.ម. ទេវានំយេវ ខោ ភាយមានា ។

## បឋាតវគ្គ ទី ៥

(៤២៧) ម្នាលភិក្ខុទាំងឡាយ ពីព្រេងនាយមក មានសង្គ្រាមទេវតានឹងអសុរ ជាសង្គ្រាមតទល់ប្រកៀកគ្នា ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសង្គ្រាម នោះឯង ពួកទេវតាឈ្នះ ពួកអសុរចាញ់ ។ ម្នាលភិក្ខុទាំងឡាយ លុះពួកអសុរចាញ់ហើយ ក៏ភ័យរត់ចូលទៅកាន់អសុរបុរីតាមចន្លោះក្រឡូក (ញាំងចិត្ត) ពួកទេវតាឲ្យភ័ន្តច្រឡំ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ក្នុងលោកនេះ អ្នកកុំគិតនូវលោកចិន្តាថា លោកទៀងដូច្នេះក្តី លោកមិនទៀងដូច្នេះក្តី លោកមានទីបំផុតដូច្នេះក្តី លោកមិនមានទីបំផុតដូច្នេះក្តី ជីវិតនោះគឺសរីរៈនោះដូច្នេះក្តី ជីវិតដទៃសរីរៈដទៃដូច្នេះក្តី សត្វស្លាប់ទៅកើតទៀតដូច្នេះក្តី សត្វស្លាប់ទៅមិនកើតទៀតដូច្នេះក្តី សត្វស្លាប់ទៅកើតទៀតក៏មាន មិនកើតទៀតក៏មានដូច្នេះក្តី សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះក្តី ។ ដំណើរនោះព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះការគិតនុ៎ះ មិនប្រកបដោយប្រយោជន៍ មិនមែនជាអាទិព្រហ្មចរិយៈ មិនប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ មិនប្រព្រឹត្តទៅដើម្បីប្រាសចាករាគៈ មិនប្រព្រឹត្តទៅដើម្បីរំលត់ មិនប្រព្រឹត្តទៅដើម្បីស្ងប់រម្ងាប់ មិនប្រព្រឹត្តទៅដើម្បីដឹង មិនប្រព្រឹត្តទៅដើម្បីត្រាស់ដឹង មិនប្រព្រឹត្តទៅដើម្បីនិព្វានទេ ។

(៤២៨) ចិន្តេន្តា ច ខោ តុម្ហេ ភិក្ខវេ ឥទំ ទុក្ខន្តិ ចិន្តេយ្យាថ ។ បេ ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ ចិន្តេយ្យាថ ។ តំ កិស្ស ហេតុ ។ ឯសា ភិក្ខវេ ចិន្តា អត្ថសញ្ហិតា ឯសា អាទិព្រហ្មចរិយកា ឯសា និព្វិ-ទាយ វិរាគាយ និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ។ តស្មាតិហ ភិក្ខវេ ឥទំ ទុក្ខន្តិ យោគោ ករណីយោ ។ បេ ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យោគោ ករណីយោតិ ។

(៤២៩) ឯកំ សមយំ ភគវា រាជគហេ វិហរតិ គិជ្ឈកូដេ បព្វតេ ។ អថខោ ភគវា ភិក្ខូ អាម-ន្តេសិ អាយាម ភិក្ខវេ យេន បដិភាណកូដោ តេនុបសង្កមិស្សាម ទិវាវិហារាយាតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ អថខោ ភគវា សម្ពហុលេហិ ភិក្ខូហិ សទ្ធឹ យេន បដិ-ភាណកូដោ តេនុបសង្កមិ ។ អទ្ទសា ខោ អញ្ញតរោ ភិក្ខុ បដិភាណកូដេ មហន្តំ បបាតំ ទិស្វាន ភគវន្តំ ឯតទវោច មហា វតាយំ ភន្តេ បបាតោ

(៤២៨) ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយគិត គួរគិតថា នេះជាទុក្ខ ។ បេ ។ គួរគិតថា នេះជាទុក្ខនិរោធគាមិនីបដិបទាវិញ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ (ព្រោះ) ការគិតនេះ ប្រកបដោយប្រយោជន៍ ការគិតនេះ ជាអាទិព្រហ្មចរិយៈ ការគិតនេះ ប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ ដើម្បីប្រាសចាករាគៈ ដើម្បីរលត់ ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងចំពោះ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរធ្វើសេចក្តីព្យាយាមថា នេះជាទុក្ខ ។ បេ ។ គួរធ្វើសេចក្តីព្យាយាមថា បដិបទានេះ ជាទុក្ខនិរោធគាមិនីបដិបទា ។

(៤២៩) សម័យមួយ ព្រះមានព្រះភាគ គង់លើភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ មក យើងនឹងចូលទៅឯបដិភាណកូដ (ថ្មជាព្រំខណ្ឌបែបភ្នំ) ដើម្បីសម្រាកក្នុងវេលាថ្ងៃ ។ ភិក្ខុទាំងនោះទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ចូលទៅឯបដិភាណកូដជាមួយនឹងភិក្ខុច្រើនរូប ។ ភិក្ខុមួយរូបបានឃើញនូវជ្រោះធំជិតថ្មបដិភាណកូដ លុះឃើញហើយក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ជ្រោះនេះធំណាស់តើ

## បបាតវគ្គោ បញ្ចមោ

សុមហា វតាយំ(១) ភន្តេ បបាតោ អត្ថិ នុ ខោ ភន្តេ ឯតម្ហា បបាតា អញ្ញោ បបាតោ មហន្តតរោ ច ភយានកតរោ ចាតិ ។ អត្ថិ ខោ ភិក្ខុ(២) ឯតម្ហា បបាតា អញ្ញោ បបាតោ មហន្តតរោ ច ភយានកតរោ ចាតិ ។ កតមោ ច ភន្តេ ឯតម្ហា បបាតា អញ្ញោ បបាតោ មហន្តតរោ ច ភយានកតរោ ចាតិ ។

(៨៣០) យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឥទំ ទុក្ខន្តិ យថាភូតំ នប្បជានន្តិ អយំ ទុក្ខសមុទយោតិ យថាភូតំ នប្បជានន្តិ អយំ ទុក្ខនិរោធោតិ យថាភូតំ នប្បជានន្តិ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យថាភូតំ នប្បជានន្តិ ។ តេ ជាតិសំវត្តនិកេសុ សង្ខារេសុ អភិរមន្តិ ជរាសំវត្តនិកេសុ សង្ខារេសុ អភិរមន្តិ មរណសំវត្តនិកេសុ សង្ខារេសុ អភិរមន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសសំវត្តនិកេសុ សង្ខារេសុ អភិរមន្តិ ។

---

១ ឱ. ម សុភយានកោ ។ ២ ឱ. អត្ថិ ខោ ភិក្ខវេ ។

បពិត្រព្រះអង្គដ៏ចំរើន ជ្រោះនេះធំពេកណាស់តើ បពិត្រព្រះអង្គដ៏ចំរើន ជ្រោះដទៃធំជាងផង គួរខ្លាចផង ជាងជ្រោះនេះទៅទៀត មានដែរឬ ។ ម្នាលភិក្ខុ ជ្រោះដទៃធំជាងផង គួរខ្លាចផង ជាងជ្រោះនេះមានដែរ ។ បពិត្រព្រះអង្គដ៏ចំរើន ជ្រោះដទៃធំជាងផង គួរខ្លាចផង ជាងជ្រោះនេះទៅទៀត តើដូចម្តេច ។

(៤៣០) ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ឯណា-នីមួយ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខសមុទ័យ មិនដឹងច្បាស់ តាមសេចក្តីពិតថា នេះជាទុក្ខនិរោធ មិនដឹងច្បាស់ តាមសេចក្តីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទា ។ សមណៈឬព្រាហ្មណ៍ទាំងនោះ តែងត្រេកអរក្នុងសង្ខារទាំងឡាយ ដែលប្រព្រឹត្តទៅដើម្បីជាតិ ត្រេកអរក្នុងសង្ខារទាំងឡាយ ដែលប្រព្រឹត្តទៅដើម្បីជរា ត្រេកអរក្នុងសង្ខារទាំងឡាយ ដែលប្រព្រឹត្តទៅដើម្បីមរណៈ ត្រេកអរក្នុងសង្ខារទាំងឡាយ ដែលប្រព្រឹត្តទៅដើម្បីសោក បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសៈ ។

តេ ជាតិសំវត្តនិកេសុ សង្ខារេសុ អភិរតា ជរាសំវត្តនិកេសុ សង្ខារេសុ អភិរតា មរណសំវត្តនិកេសុ សង្ខារេសុ អភិរតា សោកបរិទេវទុក្ខទោមនស្សុបាយាសសំវត្តនិកេសុ សង្ខារេសុ អភិរតា ជាតិសំវត្តនិកេបិ សង្ខារេ អភិសង្ខរោន្តិ ជរាសំវត្តនិកេបិ សង្ខារេ អភិសង្ខរោន្តិ មរណសំវត្តនិកេបិ សង្ខារេ អភិសង្ខរោន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសសំវត្តនិកេបិ សង្ខារេ អភិសង្ខរោន្តិ ។ តេ ជាតិសំវត្តនិកេបិ សង្ខារេ អភិសង្ខរិត្វា ជរាសំវត្តនិកេបិ សង្ខារេ អភិសង្ខរិត្វា មរណសំវត្តនិកេបិ សង្ខារេ អភិសង្ខរិត្វា សោកបរិទេវទុក្ខទោមនស្សុបាយាសសំវត្តនិកេបិ សង្ខារេ អភិសង្ខរិត្វា ជាតិបបាតម្បិ បបតន្តិ ជរាបបាតម្បិ បបតន្តិ មរណបបាតម្បិ បបតន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសបបាតម្បិ បបតន្តិ ។ តេ ន បរិមុច្ចន្តិ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ ន បរិមុច្ចន្តិ ទុក្ខស្មាតិ វទាមិ ។

កាលបើសមណៈឬព្រាហ្មណ៍ទាំងនោះ ត្រេកអរក្នុងសង្ខារទាំងឡាយ ដែលប្រព្រឹត្តទៅដើម្បីជាតិ ត្រេកអរក្នុងសង្ខារទាំងឡាយ ដែលប្រព្រឹត្តទៅដើម្បីជរា ត្រេកអរក្នុងសង្ខារទាំងឡាយ ដែលប្រព្រឹត្តទៅដើម្បីមរណៈ ត្រេកអរក្នុងសង្ខារទាំងឡាយ ដែលប្រព្រឹត្តទៅដើម្បីសោក បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសៈហើយ ឈ្មោះថា តាក់តែងនូវសង្ខារដែលប្រព្រឹត្តទៅដើម្បីជាតិ តាក់តែងនូវសង្ខារទាំងឡាយ ដែលប្រព្រឹត្តទៅដើម្បីជរា តាក់តែងនូវសង្ខារទាំងឡាយ ដែលប្រព្រឹត្តទៅដើម្បីមរណៈ តាក់តែងនូវសង្ខារទាំងឡាយ ដែលប្រព្រឹត្តទៅដើម្បីសោក បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសៈ ។ លុះសមណៈឬព្រាហ្មណ៍ទាំងនោះ តាក់តែងនូវសង្ខារទាំងឡាយដែលប្រព្រឹត្តទៅដើម្បីជាតិ តាក់តែងនូវសង្ខារទាំងឡាយ ដែលប្រព្រឹត្តទៅដើម្បីជរា តាក់តែងនូវសង្ខារទាំងឡាយ ដែលប្រព្រឹត្តទៅដើម្បីមរណៈ តាក់តែងនូវសង្ខារទាំងឡាយ ដែលប្រព្រឹត្តទៅដើម្បីសោក បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសៈហើយ ក៏ឈ្មោះថាធ្លាក់ចុះកាន់ជ្រោះគឺជាតិផង ធ្លាក់ចុះកាន់ជ្រោះគឺជរាផង ធ្លាក់ចុះកាន់ជ្រោះគឺមរណៈផង ធ្លាក់ចុះកាន់ជ្រោះគឺសោក បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសៈផង ។ សមណៈឬព្រាហ្មណ៍ទាំងនោះ មិនផុតចាកជាតិ ជរា មរណៈ សោក បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសៈទាំងឡាយ តថាគតពោលថា មិនផុតស្រឡះចាកទុក្ខឡើយ ។

### បបាតវគ្គោ បញ្ចមោ

[៤៣១] យេ ច ខោ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឥទំ ទុក្ខន្តិ យថាភូតំ បជានន្តិ ។ បេ ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យថាភូតំ បជានន្តិ ។ តេ ជាតិសំវត្តនិកេសុ សង្ខារេសុ ន អភិរមន្តិ ជរាសំវត្តនិកេសុ សង្ខារេសុ ន អភិរមន្តិ មរណសំវត្តនិកេសុ សង្ខារេសុ ន អភិរមន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសសំវត្តនិកេសុ សង្ខារេសុ ន អភិរមន្តិ ។ តេ ជាតិសំវត្តនិកេសុ សង្ខារេសុ អនភិរតា ជរាសំវត្តនិកេសុ សង្ខារេសុ អនភិរតា មរណសំវត្តនិកេសុ សង្ខារេសុ អនភិរតា សោកបរិទេវទុក្ខទោមនស្សុបាយាសសំវត្តនិកេសុ សង្ខារេសុ អនភិរតា ជរាសំវត្តនិកេបិ សង្ខារេ ន អភិសង្ខរោន្តិ មរណសំវត្តនិកេបិ សង្ខារេ ន អភិសង្ខរោន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសសំវត្តនិកេបិ សង្ខារេ ន អភិសង្ខរោន្តិ ។

បឋមវគ្គ ទី ៥

(៤៣១) ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ឯណានីមួយ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខ ។ បេ ។ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទា ។ សមណៈឬព្រាហ្មណ៍ទាំងនោះ មិនត្រេកអរក្នុងសង្ខារទាំងឡាយ ដែលប្រព្រឹត្តទៅដើម្បីជាតិ មិនត្រេកអរក្នុងសង្ខារទាំងឡាយ ដែលប្រព្រឹត្តទៅដើម្បីជរា មិនត្រេកអរក្នុងសង្ខារទាំងឡាយ ដែលប្រព្រឹត្តទៅដើម្បីមរណៈ មិនត្រេកអរក្នុងសង្ខារទាំងឡាយ ដែលប្រព្រឹត្តទៅដើម្បីសោក បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសៈ ។ កាលបើសមណៈឬព្រាហ្មណ៍ទាំងនោះ មិនត្រេកអរក្នុងសង្ខារទាំងឡាយ ដែលប្រព្រឹត្តទៅដើម្បីជាតិ មិនត្រេកអរក្នុងសង្ខារទាំងឡាយ ដែលប្រព្រឹត្តទៅដើម្បីជរា មិនត្រេកអរក្នុងសង្ខារទាំងឡាយ ដែលប្រព្រឹត្តទៅដើម្បីមរណៈ មិនត្រេកអរក្នុងសង្ខារទាំងឡាយ ដែលប្រព្រឹត្តទៅដើម្បី សោក បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសៈ ហើយ ឈ្មោះថា មិនបានតាក់តែងនូវសង្ខារទាំងឡាយ ដែលប្រព្រឹត្តទៅដើម្បីជាតិ មិនតាក់តែងនូវសង្ខារទាំងឡាយ ដែលប្រព្រឹត្តទៅដើម្បីជរា មិនតាក់តែងនូវសង្ខារទាំងឡាយ ដែលប្រព្រឹត្តទៅដើម្បីមរណៈ ដើម្បី សោក បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសៈឡើយ ។

តេ ជាតិសំវត្តនិកេបិ សង្ខារេ អនភិសង្ខរិត្វា ជរាសំវត្តនិកេបិ សង្ខារេ អនភិសង្ខរិត្វា មរណសំវត្តនិកេបិ សង្ខារេ អនភិសង្ខរិត្វា សោកបរិទេវទុក្ខទោមនស្សុបាយាសសំវត្តនិកេបិ សង្ខារេ អនភិសង្ខរិត្វា ជាតិបបាតម្បិ ន បបតន្តិ ជរាបបាតម្បិ ន បបតន្តិ មរណបបាតម្បិ ន បបតន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសបបាតម្បិ ន បបតន្តិ ។ តេ បរិមុច្ចន្តិ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ បរិមុច្ចន្តិ ទុក្ខស្មាតិ វទាមិ ។ តស្មាតិហ ភិក្ខវេ ឥទំ ទុក្ខន្តិ យោគោ ករណីយោ ។បេ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យោគោ ករណីយោតិ ។

(៤៣៤) អត្ថិ ភិក្ខវេ មហាបរិឡាហោ នាម និរយោ តត្ថ យំកិញ្ចិ ចក្ខុនា រូបំ បស្សតិ អនិដ្ឋរូបញ្ញេវ បស្សតិ នោ ឥដ្ឋរូបំ អកន្តរូបញ្ញេវ បស្សតិ នោ កន្តរូបំ អមនាបរូបញ្ញេវ បស្សតិ នោ មនាបរូបំ យំកិញ្ចិ សោតេន សទ្ទំ សុណាតិ ។បេ។

លុះសមណ ឬព្រាហ្មណ៍ទាំងនោះ មិនបានតាក់តែងនូវសង្ខារទាំងឡាយ ដែលប្រព្រឹត្តទៅដើម្បីជាតិ មិនបានតាក់តែងនូវសង្ខារទាំងឡាយ ដែលប្រព្រឹត្តទៅដើម្បីជរា មិនបានតាក់តែងនូវសង្ខារទាំងឡាយ ដែលប្រព្រឹត្តទៅដើម្បីមរណៈ មិនបានតាក់តែងនូវសង្ខារទាំងឡាយ ដែលប្រព្រឹត្តទៅដើម្បីសោក បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសៈហើយ រមែងមិនធ្លាក់ចុះកាន់ជ្រោះគឺជាតិផង មិនធ្លាក់ចុះកាន់ជ្រោះគឺជរាផង មិនធ្លាក់ចុះកាន់ជ្រោះគឺមរណៈផង មិនធ្លាក់ចុះកាន់ជ្រោះគឺសោក បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសៈផង ។ សមណៈឬព្រាហ្មណ៍ទាំងនោះ រមែងផុតស្រឡះចាកជាតិ ជរា មរណៈ សោក បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសៈ តថាគតពោលថា ផុតស្រឡះចាកទុក្ខបាន ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរធ្វើសេចក្តីព្យាយាមថា នេះជាទុក្ខ ។បេ។ គួរធ្វើសេចក្តីព្យាយាមថា នេះជាទុក្ខនិរោធគាមិនីបដិបទា ។

[៤៣៦] ម្នាលភិក្ខុទាំងឡាយ នរកមានសេចក្តីក្រហល់ក្រហាយធំ សត្វរមែងឃើញនូវរូបណាមួយ ដោយចក្ខុក្នុងនរកនោះ រមែងឃើញរូបមិនជាទីប្រាថ្នា មិនឃើញរូបជាទីប្រាថ្នា ឃើញរូបមិនជាទីគាប់ចិត្ត មិនឃើញរូបជាទីគាប់ចិត្ត ឃើញរូបមិនជាទីពេញចិត្ត មិនឃើញរូបជាទីពេញចិត្ត ស្តាប់សំឡេងណាមួយដោយត្រចៀក ។បេ។

យង្កិញ្ចិ កាយេន ផោដ្ឋព្វំ ផុសតិ ។ យង្កិញ្ចិ មនសា ធម្មំ វិជានាតិ អនិដ្ឋរូបញ្ញេវ វិជានាតិ នោ ឥដ្ឋរូបំ អកន្តរូបញ្ញេវ វិជានាតិ នោ កន្តរូបំ អមនាបរូបញ្ញេវ វិជានាតិ នោ មនាបរូបន្តិ ។

(៤៣៣) ឯវំ វុត្តេ អញ្ញតរោ ភិក្ខុ ភគវន្តំ ឯតទវោច មហា វត សោ ភន្តេ បរិឡាហោ សុមហា វត សោ ភន្តេ បរិឡាហោ អត្ថិ នុ ខោ ភន្តេ ឯតម្ហា បរិឡាហា អញ្ញោ បរិឡាហោ មហន្តតរោ ច ភយានកតរោ ចាតិ ។ អត្ថិ ខោ ភិក្ខុ ឯតម្ហា បរិឡាហា អញ្ញោ បរិឡាហោ មហន្តតរោ ច ភយានកតរោ ចាតិ ។ កតមោ បន ភន្តេ ឯតម្ហា បរិឡាហា អញ្ញោ បរិឡាហោ មហន្តតរោ ច ភយានកតរោ ចាតិ ។

(៤៣៤) យេ ហិ កេចិ ភិក្ខវេ[១] សមណា វា ព្រាហ្មណា វា ឥទំ ទុក្ខន្តិ យថាភូតំ នប្បជានន្តិ ។ បេ ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យថាភូតំ នប្បជានន្តិ ។ តេ ជាតិសំវត្តនិកេសុ សង្ខារេសុ អភិរមន្តិ ។

១ ភិក្ខុ ឥតិ ភវិតព្វំ ។

ពាល់ត្រូវនូវផ្សព្វណាមួយ ដោយកាយ ។ ដឹងច្បាស់ធម្មារម្មណ៍ណាមួយ ដោយចិត្ត ដឹងច្បាស់រូបមិនជាទីប្រាថ្នា មិនដឹងច្បាស់រូបជាទីប្រាថ្នា ដឹងច្បាស់រូបមិនជាទីគាប់ចិត្ត មិនដឹងច្បាស់រូបជាទីគាប់ចិត្ត ដឹងច្បាស់រូបមិនជាទីពេញចិត្ត មិនដឹងច្បាស់រូបជាទីពេញចិត្ត ។

[ ៤៣៣ ] កាលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ភិក្ខុមួយរូប បានក្រាបទូលសួរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន សេចក្តីក្រហល់ក្រហាយនោះធំណាស់តើ បពិត្រព្រះអង្គដ៏ចំរើន សេចក្តីក្រហល់ក្រហាយនោះធំណាស់តើ បពិត្រព្រះអង្គដ៏ចំរើន សេចក្តីក្រហល់ក្រហាយដទៃដែលធំជាងផង គួរខ្លាចផង ជាងសេចក្តីក្រហល់ក្រហាយនេះ មានដែរឬ ។ ម្នាលភិក្ខុ សេចក្តីក្រហល់ក្រហាយដទៃដែលធំជាងផង គួរខ្លាចផង ជាងសេចក្តីក្រហល់ក្រហាយនេះ មានដែរ ។ បពិត្រព្រះអង្គដ៏ចំរើន សេចក្តីក្រហល់ក្រហាយដែលធំជាងផង គួរខ្លាចផង ជាងសេចក្តីក្រហល់ក្រហាយនេះ តើដូចម្តេច ។

[ ៤៣៤ ] ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ឯណានីមួយ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខ ។បេ។ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទា ។ សមណៈឬព្រាហ្មណ៍ទាំងនោះ ត្រេកអរក្នុងពួកសង្ខារ ដែលប្រព្រឹត្តទៅដើម្បីជាតិ ។ បេ ។

បេ ។ អភិរតា អភិសង្ខរោន្តិ ។ អភិសង្ខរិត្វា ជាតិបរិឡាហេនបិ បរិឌយ្ហន្តិ ជរាបរិឡាហេនបិ បរិឌយ្ហន្តិ មរណបរិឡាហេនបិ បរិឌយ្ហន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសបរិឡាហេនបិ បរិឌយ្ហន្តិ ។ តេ ន បរិមុច្ចន្តិ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ ន បរិមុច្ចន្តិ ទុក្ខស្មាតិ វទាមិ ។

[៤៣៥] យេ ច ខោ កេចិ ភិក្ខវេ(១) សមណា វា ព្រាហ្មណា វា ឥទំ ទុក្ខន្តិ យថាភូតំ បជានន្តិ ។បេ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យថាភូតំ បជានន្តិ ។ តេ ជាតិសំវត្តនិកេសុ សង្ខារេសុ នាភិរមន្តិ ។បេ។ អនភិរតា ន អភិសង្ខរោន្តិ ។ អនភិសង្ខរិត្វា ជាតិបរិឡាហេនបិ ន បរិឌយ្ហន្តិ ជរាបរិឡាហេនបិ ន បរិឌយ្ហន្តិ មរណបរិឡាហេនបិ ន បរិឌយ្ហន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសបរិឡាហេនបិ ន បរិឌយ្ហន្តិ ។

---

១ ឱ. ភិក្ខុ ។

កាលបើត្រេកអរហើយ រមែងតាក់តែង ៗ លុះតាក់តែងហើយ រមែងក្តៅដោយសេចក្តីក្រហល់ក្រហាយគឺជាតិផង ក្តៅដោយសេចក្តីក្រហល់ក្រហាយគឺជរាផង ក្តៅដោយសេចក្តីក្រហល់ក្រហាយគឺមរណៈផង ក្តៅដោយសេចក្តីក្រហល់ក្រហាយគឺ សោក បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសៈផង ៗ សមណៈឬព្រាហ្មណ៍ទាំងនោះ រមែងមិនផុតស្រឡះចាកជាតិជរា មរណៈ សោក បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសៈ តថាគតពោលថា មិនផុតស្រឡះចាកទុក្ខឡើយ ៗ សមណៈឬព្រាហ្មណ៍ទាំងនោះ រមែងមិនផុតស្រឡះចាកជាតិ ជរា មរណៈ សោក បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសៈ តថាគតពោលថា នឹងមិនផុតស្រឡះចាកទុក្ខឡើយ ៗ

[៤៣៥] ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ឯណានីមួយ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខ ៗ បេ ៗ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទា ៗ សមណៈឬព្រាហ្មណ៍ទាំងនោះ រមែងមិនត្រេកអរក្នុងសង្ខារទាំងឡាយ ដែលប្រព្រឹត្តទៅដើម្បីជាតិ ៗ បេ ៗ កាលបើមិនត្រេកអរហើយរមែងមិនបានតាក់តែង ៗ លុះមិនបានតាក់តែងហើយ រមែងមិនក្តៅដោយសេចក្តីក្រហល់ក្រហាយគឺជាតិផង មិនក្តៅដោយសេចក្តីក្រហល់ក្រហាយគឺមរណៈផង មិនក្តៅដោយសេចក្តីក្រហល់ក្រហាយគឺសោក បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសៈផង ៗ

តេ បរិមុច្ចន្តិ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ បរិមុច្ចន្តិ ទុក្ខស្មាតិ វទាមិ ។ តស្មាតិហ ភិក្ខវេ ឥទំ ទុក្ខន្តិ យោគោ ករណីយោ ។បេ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យោគោ ករណីយោតិ ។

(៤៣៦) យោ ច ខោ ភិក្ខវេ(១) ឯវំ វទេយ្យ អហំ ទុក្ខំ អរិយសច្ចំ យថាភូតំ អនភិសមេច្ច ។បេ។ ទុក្ខនិរោធគាមិនីបដិបទំ អរិយសច្ចំ យថាភូតំ អនភិសមេច្ច សម្មា ទុក្ខស្សន្តំ ករិស្សាមីតិ នេតំ ឋានំ វិជ្ជតិ ។ សេយ្យថាបិ ភិក្ខវេ យោ ឯវំ វទេយ្យ អហំ កូដាគារស្ស ហេដ្ឋិមំ ឃរំ អករិត្វា ឧបរិមំ ឃរំ អារោបេស្សាមីតិ នេតំ ឋានំ វិជ្ជតិ ។ ឯវមេវ ខោ ភិក្ខវេ យោ ឯវំ វទេយ្យ អហំ ទុក្ខំ អរិយសច្ចំ យថាភូតំ អនភិសមេច្ច ។បេ។ ទុក្ខនិរោធគាមិនីបដិបទំ អរិយសច្ចំ យថាភូតំ អនភិសមេច្ច សម្មា ទុក្ខស្សន្តំ ករិស្សាមីតិ នេតំ ឋានំ វិជ្ជតិ ។

---

១ ឱ. យោ ហិ ភិក្ខវេ ។

## បបាតវគ្គ ទី ៥

សមណៈឬព្រាហ្មណ៍ទាំងនោះ រមែងផុតស្រឡះចាកជាតិ ជរា មរណៈ សោក បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសៈ តថាគតពោលថា ផុតស្រឡះចាកទុក្ខបាន ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរធ្វើសេចក្តីព្យាយាមថា នេះជាទុក្ខ ។បេ។ គួរធ្វើសេចក្តីព្យាយាមថា នេះជាទុក្ខនិរោធគាមិនីបដិបទា ។

[៤៣៦] ម្នាលភិក្ខុទាំងឡាយ បុគ្គលណា ពោលយ៉ាងនេះថា អាត្មាអញមិនបាច់ត្រាស់ដឹងនូវទុក្ខអរិយសច្ចតាមសេចក្តីពិត ។បេ។ មិនបាច់ត្រាស់ដឹងនូវទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចតាមសេចក្តីពិត ក៏គង់នឹងធ្វើនូវទីបំផុតនៃទុក្ខដោយប្រពៃបាន ហេតុនេះមិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលណា ពោលយ៉ាងនេះថា អាត្មាអញមិនបាច់ធ្វើផ្ទះខាងក្រោមនៃផ្ទះមានកំពូល នឹងលើកផ្ទះខាងលើតែម្តង (គឺមិនបាច់ធ្វើគ្រឿងក្រោមធ្វើតែគ្រឿងលើ) ហេតុនេះមិនមានទេយ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលណា ពោលយ៉ាងនេះថា អាត្មាអញមិនបាច់ត្រាស់ដឹងនូវទុក្ខអរិយសច្ចតាមសេចក្តីពិត ។បេ។ មិនបាច់ត្រាស់ដឹងនូវទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចតាមសេចក្តីពិត នឹងធ្វើនូវទីបំផុតនៃទុក្ខដោយប្រពៃតែម្តង ហេតុនេះមិនមានឡើយ ក៏យ៉ាងនោះដែរ ។

(៤៣៧) យោ ច ខោ ភិក្ខវេ ឯវំ វទេយ្យ អហំ ទុក្ខំ អរិយសច្ចំ យថាភូតំ អភិសមេច្ច ។បេ។ ទុក្ខនិរោធគាមិនីបដិបទំ អរិយសច្ចំ យថាភូតំ អភិសមេច្ច សម្មា ទុក្ខស្សន្តំ ករិស្សាមីតិ ឋានមេតំ វិជ្ជតិ ។ សេយ្យថាបិ ភិក្ខវេ យោ ឯវំ វទេយ្យ អហំ កូដាគារស្ស ហេដ្ឋិមំ ឃរំ ករិត្វា ឧបរិមំ ឃរំ អារោបេស្សាមីតិ ឋានមេតំ វិជ្ជតិ ។ ឯវមេវ ខោ ភិក្ខវេ យោ ឯវំ វទេយ្យ អហំ ទុក្ខំ អរិយសច្ចំ យថាភូតំ អភិសមេច្ច ។បេ។ ទុក្ខនិរោធគាមិនីបដិបទំ អរិយសច្ចំ យថាភូតំ អភិសមេច្ច សម្មា ទុក្ខស្សន្តំ ករិស្សាមីតិ ឋានមេតំ វិជ្ជតិ ។ តស្មាតិហ ភិក្ខវេ ឥទំ ទុក្ខន្តិ យោគោ ករណីយោ ។បេ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យោគោ ករណីយោតិ ។

(៤៣៨) ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ អថខោ អាយស្មា អានន្ទោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ វេសាលិយំ(១) បិណ្ឌាយ បាវិសិ ។

១ ឱ.ម. វេសាលី ។

[ ៤៣៧ ] ម្នាលភិក្ខុទាំងឡាយ បើបុគ្គលណាពោលយ៉ាងនេះវិញថា អាត្មាអញបានត្រាស់ដឹងនូវទុក្ខអរិយសច្ចតាមសេចក្តីពិត ។ បេ ។ បានត្រាស់ដឹងនូវទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចតាមសេចក្តីពិត ហើយនឹងធ្វើនូវទីបំផុតនៃសេចក្តីទុក្ខបាន ហេតុនេះទើបមាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលណាពោលយ៉ាងនេះថា អាត្មាអញធ្វើផ្ទះខាងក្រោមនៃផ្ទះមានកំពូលហើយសឹមលើកផ្ទះខាងលើ ហេតុនេះទើបមាន យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលណាពោលយ៉ាងនេះថា អាត្មាអញត្រាស់ដឹងនូវទុក្ខអរិយសច្ច តាមសេចក្តីពិត ។ បេ ។ ត្រាស់ដឹងនូវទុក្ខ-និរោធគាមិនីបដិបទាអរិយសច្ចតាមសេចក្តីពិតហើយនឹងធ្វើនូវទីបំផុតនៃទុក្ខដោយប្រពៃបាន ហេតុនេះទើបមានយ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរធ្វើសេចក្តីព្យាយាមថា នេះជាទុក្ខ ។ បេ ។ គួរធ្វើសេចក្តីព្យាយាមថា នេះជាទុក្ខនិរោធគាមិនីបដិបទា ។

[ ៤៣៨ ] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងកូដាគារសាលា នាមហាវន ជិតក្រុងវេសាលី ។ គ្រានោះឯង ព្រះអានន្ទដ៏មានអាយុ ស្លៀកស្បង់ប្រដាប់បាត្រនឹងចីវរ ក្នុងបុព្វណ្ហ-សម័យ ហើយចូលទៅកាន់ក្រុងវេសាលី ដើម្បីបិណ្ឌបាត ។

## បបាតវគ្គោ បញ្ចមោ

អទ្ទសា ខោ អាយស្មា អានន្ទោ សម្ពហុលេ លិច្ឆវិកុមារកេ សណ្ឋាគារេ ឧបាសនំ ករោន្តេ ទូរតោ វ សុខុមេន តាឡច្ឆិគ្គឡេន អសនំ អតិបាតេន្តេ ពោខានុពោខំ(១) អវិរាធិតំ ។ ទិស្វានស្ស ឯតទហោសិ សិក្ខិតា វតិមេ លិច្ឆវិកុមារកា សុសិក្ខិតា វតិមេ លិច្ឆវិកុមារកា យត្រ ហិ នាម ទូរតោ វ សុខុមេន តាឡច្ឆិគ្គឡេន អសនំ អតិបាតេស្សន្តិ ពោខានុពោខំ អវិរាធិតន្តិ ។

(៤៣៩) អថខោ អាយស្មា អានន្ទោ វេសាលិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច ឥធាហំ ភន្តេ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ វេសាលិយំ បិណ្ឌាយ បាវិសឹ ។ អទ្ទសំ ខ្វាហំ ភន្តេ សម្ពហុលេ លិច្ឆវិកុមារកេ សណ្ឋាគារេ ឧបាសនំ ករោន្តេ ទូរតោ វ សុខុមេន តាឡច្ឆិគ្គឡេន អសនំ អតិបាតេន្តេ ពោខានុពោខំ អវិរាធិតំ ។

---

១ ពោង្ខានុពោង្ខំ ។

ព្រះអានន្ទដ៏មានអាយុ ក៏បានឃើញពួកលិច្ឆវិកុមារច្រើននាក់ កំពុងធ្វើគ្រឿងក្រោះក្នុងផ្ទះ ជាទីរៀនទូវសិល្បៈ កំពុងបាញ់សរតាមរន្ធបន្ទោងដ៏តូចអំពីចម្ងាយឲ្យចេញទៅតៗគ្នា មិនឲ្យដាច់ឡើយ ។ លុះព្រះអានន្ទនោះ បានឃើញហើយ ក៏មានសេចក្តីត្រិះរិះ ដូច្នេះថា ពួកលិច្ឆវិកុមារនេះ ចេះសិក្សាណាស់តើ ពួកលិច្ឆវិកុមារនេះ ចេះសិក្សាល្អណាស់តើ ព្រោះពួកលិច្ឆវិកុមារនេះ ចេះបាញ់សរតាមរន្ធបន្ទោងដ៏តូចអំពីចម្ងាយ ឲ្យចេញទៅតៗគ្នា មិនឲ្យដាច់ឡើយ ។

[៤៣៩] លំដាប់នោះ ព្រះអានន្ទមានអាយុ ត្រាច់ទៅក្នុងក្រុងវេសាលីដើម្បីបិណ្ឌបាត កាលត្រឡប់មកពីបិណ្ឌបាតក្នុងបច្ឆាភត្ត ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទមានអាយុអង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ក្នុងទីឯណោះ ខ្ញុំព្រះអង្គស្លៀកស្បង់ប្រដាប់បាត្រនឹងចីវរក្នុងបុព្វណ្ហសម័យ ហើយចូលទៅក្នុងក្រុងវេសាលី ដើម្បីបិណ្ឌបាត ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានឃើញពួកលិច្ឆវិកុមារច្រើននាក់ កំពុងធ្វើនូវគ្រឿងក្រោះក្នុងផ្ទះជាទីរៀនទូវសិល្បៈ បាញ់សរតាមរន្ធបន្ទោងដ៏តូចអំពីចម្ងាយ ឲ្យចេញទៅតៗគ្នា មិនឲ្យដាច់ឡើយ ។

ទិស្វាន មេ ឯតទហោសិ សិក្ខិតា វតិមេ លិច្ឆវិ-
កុមារកា សុសិក្ខិតា វតិមេ លិច្ឆវិកុមារកា
យត្រ ហិ នាម ទូរតោវ សុខុមេន តាឡច្ឆិគ្គឡេន
អសនំ អតិបាតេស្សន្តិ ភោខានុបោខំ អវិរាធិតន្តិ ។
តំ កឹ មញ្ញសិ អានន្ទ កតមំ នុ ខោ ទុក្ករតរំ
វា ទុរភិសម្ភវតរំ វា ។ យោ ទូរតោវ សុខុមេន
តាឡច្ឆិគ្គឡេន អសនំ អតិបាតេយ្យ បោខានុបោខំ
អវិរាធិតំ យោ វា សត្តធា ភិន្នស្ស វាលស្ស កោដិយា
កោដឹ បដិវិជ្ឈេយ្យាតិ ។ ឯតទេវ ភន្តេ ទុក្ករតរញ្ចេវ
ទុរភិសម្ភវតរញ្ច យោ វា សត្តធា ភិន្នស្ស វាលស្ស
កោដិយា កោដឹ បដិវិជ្ឈេយ្យាតិ ។ អថខោ តេ
អានន្ទ ទុប្បដិវិជ្ឈតរំ បដិវិជ្ឈន្តិ យេ ឥទំ ទុក្ខន្តិ
យថាភូតំ បដិវិជ្ឈន្តិ ។ បេ ។ អយំ ទុក្ខនិរោធគាមិនី-
បដិបទាតិ យថាភូតំ បដិវិជ្ឈន្តិ ។ តស្មាតិហានន្ទ
ឥទំ ទុក្ខន្តិ យោគោ ករណីយោ ។ បេ ។ អយំ
ទុក្ខនិរោធគាមិនីបដិបទាតិ យោគោ ករណីយោតិ ។

លុះខ្ញុំព្រះអង្គបានឃើញហើយមានសេចក្តីត្រិះរិះដូច្នេះថា ពួកលិច្ឆវីកុមារនេះ ចេះសិក្សាណាស់តើ ពួកលិច្ឆវីកុមារនេះ ចេះសិក្សាល្អណាស់តើ ព្រោះពួកលិច្ឆវីកុមារនេះ ចេះបាញ់សរតាមរន្ធបន្ទោងដ៏តូច ឲ្យចេញទៅត ៗ គ្នា មិនឲ្យផាច់ ៗ ម្នាលអានន្ទ អ្នកសំគាល់ហេតុនោះដូចម្តេច អំពើដូចម្តេចហ្ន៎ ដែលបុគ្គលធ្វើបានដោយកម្រក្រៃលែងផង ហេតុកើតឡើងព្រមដោយកម្រផង ។ ជនណាបាញ់សរតាមរន្ធបន្ទោងដ៏តូចអំពីចម្ងាយឲ្យចេញទៅត ៗ គ្នា មិនឲ្យផាច់ ឬក៏ជនណាបាញ់ទំលុះនូវចុងនៃចុងរោមកន្ទុយដែលប្រៀកជា ៧ ចំរៀក ៗ បពិត្រព្រះអង្គដ៏ចំរើន បុគ្គលណាបាញ់ទំលុះនូវចុងនៃចុងរោមកន្ទុយ ដែលប្រៀកជា ៧ ចម្រៀក ហេតុនុ៎ះដែលបុគ្គលធ្វើបានដោយកម្រឬជាហេតុកើតឡើងព្រមដោយកម្រ ។ ម្នាលអានន្ទ ពួកជនណាចាក់ធ្លុះតាមសេចក្តីពិតថា នេះជាទុក្ខ ៗ ពេ ៗ ចាក់ធ្លុះតាមសេចក្តីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទា ពួកជនទាំងនោះទើបឈ្មោះថាចាក់ធ្លុះនូវហេតុដែលបុគ្គលចាក់ធ្លុះបានដោយកម្រ ៗ ម្នាលអានន្ទ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរធ្វើសេចក្តីព្យាយាមថា នេះជាទុក្ខ ៗ ពេ ៗ គួរធ្វើសេចក្តីព្យាយាមថា នេះជាទុក្ខនិរោធគាមិនីបដិបទា ៗ

(៤៤០) អត្ថិ ភិក្ខវេ លោកន្តរិកា អឃា អសំវុតា អន្ធការា អន្ធការតិមិសា យត្ថបិមេសំ ចន្ទិមសុរិយានំ ឯវំមហិទ្ធិកានំ ឯវំមហានុភាវានំ អាភាយ នានុភោន្តីតិ ។

(៤៤១) ឯវំ វុត្តេ អញ្ញតរោ ភិក្ខុ ភគវន្តំ ឯតទវោច មហា វត សោ ភន្តេ អន្ធការោ សុមហា វត សោ ភន្តេ អន្ធការោ អត្ថិ នុ ខោ ភន្តេ ឯតម្ហា អន្ធការា អញ្ញោ អន្ធការោ មហន្តតរោ ច ភយានកតរោ ចាតិ ។ អត្ថិ ខោ ភិក្ខុ ឯតម្ហា អន្ធការា អញ្ញោ អន្ធការោ មហន្តតរោ ច ភយានកតរោ ចាតិ ។ កតមោ បន ភន្តេ ឯតម្ហា អន្ធការា អញ្ញោ អន្ធការោ មហន្តតរោ ច ភយានកតរោ ចាតិ ។

(៤៤២) យេ ហិ កេចិ ភិក្ខុ សមណា វា ព្រាហ្មណា វា ឥទំ ទុក្ខន្តិ យថាភូតំ នប្បជានន្តិ ។ បេ ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យថាភូតំ នប្បជានន្តិ ។ តេ ជាតិសំវត្តនិកេសុ សង្ខារេសុ អភិរមន្តិ ។

បបាតវគ្គ ទី ៥

[៤៤០] ម្នាលភិក្ខុទាំងឡាយ ពួកសត្វក្នុងលោកន្តរនរក មានតែសេចក្តីទុក្ខឥតល្ហែ ជានរកងងឹត ជានរកងងឹតសូន្យឈឹង ក្នុងនរកនោះ មិនដែលបានទទួលពន្លឺនៃព្រះចន្ទនិងព្រះអាទិត្យទាំងឡាយនេះ ដែលមានឫទ្ធិធំយ៉ាងនេះ មានអានុភាពធំ យ៉ាងនេះឡើយ ។

[៤៤១] កាលព្រះមានព្រះភាគ ទ្រង់សំដែងយ៉ាងនេះហើយ ភិក្ខុមួយរូប បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ងងឹតនោះ ជាងងឹតធំណាស់ បពិត្រព្រះអង្គដ៏ចំរើន ងងឹតនោះ ជាងងឹតធំមហិមា បពិត្រព្រះអង្គដ៏ចំរើន ងងឹតដទៃដែលធំជាងផង គួរខ្លាចផង ជាងងងឹតនេះមានដែរឬ ។ ម្នាលភិក្ខុ ងងឹតដទៃដែលធំជាងផង គួរខ្លាចផង ជាងងងឹតនេះ មានដែរ ។ បពិត្រព្រះអង្គដ៏ចំរើន ចុះងងឹតដទៃធំជាងផង គួរខ្លាចផង ជាងងងឹតនេះ តើដូចម្តេច ។

[៤៤២] ម្នាលភិក្ខុ ពួកសមណៈឬព្រាហ្មណ៍ឯណានីមួយ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខ ។ បេ ។ មិនដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទា ។ សមណៈឬព្រាហ្មណ៍ទាំងនោះ រមែងត្រេកអរក្នុងសង្ខារទាំងឡាយ ដែលប្រព្រឹត្តទៅដើម្បីជាតិ ។ បេ ។

បេ ។ អភិរតា អភិសង្ខរោន្តិ ។ អភិសង្ខរិត្វា ជាតន្ធការម្បិ បបតន្តិ ជរន្ធការម្បិ បបតន្តិ មរណន្ធការម្បិ បបតន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសន្ធការម្បិ បបតន្តិ ។ តេ ន បរិមុច្ចន្តិ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ ន បរិមុច្ចន្តិ ទុក្ខស្មាតិ វទាមិ ។

(៤៤៣) យេ ច ខោ កេចិ ភិក្ខុ សមណា វា ព្រាហ្មណា វា ឥទំ ទុក្ខន្តិ យថាភូតំ បជានន្តិ ។បេ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យថាភូតំ បជានន្តិ។ តេ ជាតិសំវត្តនិកេសុ សង្ខារេសុ ជាភិរមន្តិ ។បេ។ អនភិរតា ន អភិសង្ខរោន្តិ ។ អនភិសង្ខរិត្វា ជាតន្ធការម្បិ ន បបតន្តិ ជរន្ធការម្បិ ន បបតន្តិ មរណន្ធការម្បិ ន បបតន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសន្ធការម្បិ ន បបតន្តិ ។ តេ បរិមុច្ចន្តិ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ បរិមុច្ចន្តិ ទុក្ខស្មាតិ វទាមិ ។

កាលបើត្រេកអរហើយ រមែងតាក់តែង ។ លុះតាក់តែងហើយក៏ធ្លាក់ចុះកាន់ទីងងឹតគឺជាតិផង ធ្លាក់ចុះកាន់ទីងងឹតគឺជរាផង ធ្លាក់ចុះកាន់ទីងងឹតគឺមរណៈផង ធ្លាក់ចុះកាន់ទីងងឹតគឺសោក បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសៈផង ។ សមណៈឬព្រាហ្មណ៍ទាំងនោះ មិនផុតស្រឡះចាកជាតិ ជរា មរណៈ សោក បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសៈ តថាគតពោលថា មិនផុតស្រឡះចាកទុក្ខឡើយ ។

[៤៤៣] ម្នាលភិក្ខុ ពួកសមណៈឬព្រាហ្មណ៍ ឯណានីមួយ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខ ។ បេ ។ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទា ។ សមណៈឬព្រាហ្មណ៍ទាំងនោះ មិនត្រេកអរក្នុងសង្ខារទាំងឡាយ ដែលប្រព្រឹត្តទៅ ដើម្បីជាតិ ។ បេ ។ កាលបើមិនត្រេកអរហើយ ក៏រមែងមិនតាក់តែង ។ លុះមិនបានតាក់តែងហើយ ក៏មិនធ្លាក់ចុះកាន់ទីងងឹតគឺជាតិផង មិនធ្លាក់ចុះកាន់ទីងងឹតគឺជរាផង មិនធ្លាក់ចុះកាន់ទីងងឹតគឺមរណៈផង មិនធ្លាក់ចុះកាន់ទីងងឹតគឺសោក បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសៈផង ។ សមណៈឬព្រាហ្មណ៍ទាំងនោះរមែងផុតស្រឡះចាកជាតិ ជរា មរណៈ សោក បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសៈ តថាគតពោលថា ផុតស្រឡះចាកទុក្ខបាន ។

តស្មាតិហ ភិក្ខុ ឥទំ ទុក្ខន្តិ យោគោ ករណីយោ ។ បេ ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យោគោ ករណីយោតិ ។

(៤៤៤) សេយ្យថាបិ ភិក្ខវេ បុរិសោ មហាសមុទ្ទេ ឯកច្ឆិគ្គឡំ យុគំ បក្ខិបេយ្យ តត្រាបិស្ស កាណោ កច្ឆបោ សោ វស្សសតស្ស វស្សសតស្ស អច្ចយេន សកឹ សកឹ ឧម្មុជ្ជេយ្យ ។ តំ កឹ មញ្ញថ ភិក្ខវេ អបិ នុ សោ កាណោ កច្ឆបោ វស្សសតស្ស វស្សសតស្ស អច្ចយេន សកឹ សកឹ ឧម្មុជ្ជន្តោ អមុស្មឹ ឯកច្ឆិគ្គឡេ យុគេ គីវំ បវេសេយ្យាតិ ។ យទិ នូន ភន្តេ កទាចិ ករហចិ ទីឃស្ស អទ្ធុនោ អច្ចយេនាតិ ។ ខិប្បតរំ ខោ សោ ភិក្ខវេ កាណោ កច្ឆបោ វស្សសតស្ស វស្សសតស្ស អច្ចយេន សកឹ សកឹ ឧម្មុជ្ជន្តោ អមុស្មឹ ឯកច្ឆិគ្គឡេ យុគេ គីវំ បវេសេយ្យ ។ ន ត្វេវាហំ ភិក្ខវេ សកឹ វិនិបាតគតេន ពាលេន(១) មនុស្សត្តំ វទាមិ ។

---

១ ម វិនិតកតេន ពហុលេន ។

បបាតវគ្គ ទី ៥

ម្នាលភិក្ខុ ព្រោះហេតុនោះ ក្នុងសាសនានេះ គួរធ្វើសេចក្ដីព្យាយាមថា នេះជាទុក្ខ ។ បេ ។ គួរធ្វើសេចក្ដីព្យាយាមថា នេះជាទុក្ខនិរោធគាមិនី-បដិបទា ។

[ ៤៤៤ ] ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសបោះនឹមមានប្រហោះតែមួយក្នុងមហាសមុទ្រ ក៏ក្នុងមហាសមុទ្រនោះមានអណ្ដើកខ្វាក់ (មួយ) លុះកន្លងមួយរយឆ្នាំ ៗ ទៅ ទើបអណ្ដើកខ្វាក់នោះងើបម្ដង ៗ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សំគាល់នូវហេតុនោះដូចម្ដេច កាលបើកន្លងមួយរយឆ្នាំ ៗ ទៅ ទើបអណ្ដើកខ្វាក់នោះងើបម្ដង ៗ តើគួរនឹងស៊កក្នុងនឹមមានប្រហោះតែមួយឯណោះបានដែរឬ ។ បពិត្រព្រះអង្គដ៏ចំរើន ក្រែងតែកាលកន្លងយូរអង្វែងទៅ ទើបមានម្ដងៗខ្លះ ។ ម្នាលភិក្ខុទាំងឡាយ លុះកន្លងមួយរយឆ្នាំ ៗ ទៅ ទើបអណ្ដើកខ្វាក់នោះងើបម្ដង ៗ ក៏ស៊កទៅក្នុងនឹមមានប្រហោះតែមួយឯណោះទុកជាឆាប់ពេកណាស់ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ជនពាលដែលធ្លាក់ទៅក្នុងវិនិបាតហើយ បានមកជាមនុស្សអស់វារៈម្ដង តថាគតពោលថា មិនបានឆាប់ឡើយគឺយូរពេកណាស់ ។

តំ កិស្ស ហេតុ ។ ន ហេត្ថ ភិក្ខវេ អត្ថិ ធម្មចរិយា សមចរិយា កុសលកិរិយា បុញ្ញកិរិយា អញ្ញមញ្ញខាទិកា ។ ឯត្ថ ភិក្ខវេ វត្តតិ ទុព្វលខាទិកា ។ តំ កិស្ស ហេតុ ។ អទិដ្ឋត្តា ភិក្ខវេ ចតុន្នំ អរិយសច្ចានំ ។ កតមេសំ ចតុន្នំ ។ ទុក្ខស្ស អរិយសច្ចស្ស ។បេ។ ទុក្ខនិរោធគាមិនីបដិបទាយ អរិយសច្ចស្ស ។ តស្មាតិហ ភិក្ខវេ ឥទំ ទុក្ខន្តិ យោគោ ករណីយោ ។បេ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យោគោ ករណីយោតិ ។

(៤៤៨) សេយ្យថាបិ ភិក្ខវេ អយំ មហាបឋវី ឯកោទិកា(១) អស្ស តត្រ បុរិសោ ឯកច្ឆិគ្គឡំ យុគំ បក្ខិបេយ្យ តមេនំ បុរត្ថិមោ វាតោ បច្ឆិមេន សំហរេយ្យ បច្ឆិមោ វាតោ បុរត្ថិមេន សំហរេយ្យ ឧត្តរោ វាតោ ទក្ខិណេន សំហរេយ្យ ទក្ខិណោ វាតោ ឧត្តរេន សំហរេយ្យ តត្រស្ស កាណោ កច្ឆបោ សោ វស្សសតស្ស វស្សសតស្ស អច្ចយេន សកិំ សកិំ ឧម្មុជ្ជេយ្យ ។

---

១ ឱ. ម. ឯកោទកា ។

ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះបុគ្គលពាលក្នុងលោកនេះគ្មានប្រព្រឹត្តនូវធម៌ គ្មានប្រព្រឹត្តស្មើ គ្មានធ្វើកុសល គ្មានធ្វើបុណ្យទេ មានតែទំពាស៊ីនូវគ្នានឹងគ្នា ។ ម្នាលភិក្ខុទាំងឡាយ ការទំពាស៊ីនូវសត្វដែលមានកំឡាំងថយ រមែងប្រព្រឹត្តទៅក្នុងបុគ្គលពាលនុ៎ះ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះបុគ្គលពាលមិនឃើញនូវអរិយសច្ច ៤ ។ អរិយសច្ច ៤ គឺអ្វីខ្លះ ។ គឺទុក្ខអរិយសច្ច ១ ។បេ។ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ១ ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរធ្វើសេចក្តីព្យាយាមថា នេះជាទុក្ខ ។បេ។ គួរធ្វើសេចក្តីព្យាយាមថា នេះជាទុក្ខនិរោធគាមិនីបដិបទា ។

(៤៤៥) ម្នាលភិក្ខុទាំងឡាយ ដូចជាផែនដីធំនេះ មានទឹកពុំតែជាមួយគ្នា មានបុរសបោះនឹមមានរន្ធតែមួយទៅលើផែនដីនោះ ខ្យល់ពីទិសខាងកើត បក់នឹមនោះទៅទិសខាងលិច ខ្យល់ពីទិសខាងលិច បក់ (នឹមនោះ) ទៅទិសខាងកើត ខ្យល់ពីទិសខាងជើង បក់ (នឹមនោះ) ទៅទិសខាងត្បូង ខ្យល់ពីទិសខាងត្បូង បក់(នឹមនោះ)ទៅទិសខាងជើង លុះកន្លងមួយរយឆ្នាំ ៗ ទៅ ទើបមានអណ្តើកខ្វាក់មួយក្នុងទីនោះងើបម្តង ៗ ។

តំ កឹ មញ្ញថ ភិក្ខវេ អបិ នុ ខោ កាណោ កច្ឆបោ វស្សសតស្ស វស្សសតស្ស អច្ចយេន សកឹ សកឹ ឧម្មុជ្ជន្តោ អមុស្មឹ ឯកច្ឆិគ្គឡេ យុគេ គីវំ បវេសេយ្យាតិ ។ អធិច្ចមិទំ ភន្តេ យំ សោ កាណោ កច្ឆបោ វស្សសតស្ស វស្សសតស្ស អច្ចយេន សកឹ សកឹ ឧម្មុជ្ជន្តោ អមុស្មឹ ឯកច្ឆិគ្គឡេ យុគេ គីវំ បវេសេយ្យាតិ ។ ឯវំ អធិច្ចមិទំ ភិក្ខវេ យំ មនុស្សត្តំ លភតិ ។ ឯវំ អធិច្ចមិទំ ភិក្ខវេ យំ តថាគតោ លោកេ ឧប្បជ្ជតិ អរហំ សម្មាសម្ពុទ្ធោ ។ ឯវំ អធិច្ចមិទំ ភិក្ខវេ យំ តថាគតប្បវេទិតោ ធម្មវិនយោ លោកេ ទិប្បតិ(១) ។ តស្សិទំ ភិក្ខវេ មនុស្សត្តំ លទ្ធំ តថាគតោ ច លោកេ ឧប្បន្នោ អរហំ សម្មាសម្ពុទ្ធោ តថាគតប្បវេទិតោ ច ធម្មវិនយោ លោកេ ទិប្បតិ ។ តស្មាតិហ ភិក្ខវេ ឥទំ ទុក្ខន្តិ យោគោ ករណីយោ ។ បេ ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យោគោ ករណីយោតិ ។

---

១ ម. ទិព្វតិ ។

## បបាតវគ្គ ទី ៥

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់នូវហេតុនោះដូចម្ដេច លុះកន្លង មួយរយឆ្នាំ ៗ ទៅ ទើបអណ្ដើកខ្វាក់នោះងើបម្ដង ៗ តើគួរនឹងស៊កកក្នុង នឹមមានប្យោះតែមួយឯណោះបានដែរឬ ។ បពិត្រព្រះអង្គដ៏ចំរើន លុះកន្លង មួយរយឆ្នាំៗទៅ ទើបអណ្ដើកខ្វាក់នោះងើបម្ដងៗ គួរនឹងស៊កកទៅក្នុងនឹម មានប្យោះតែមួយឯណោះ ដោយហេតុឯណា ហេតុនោះ កម្រក្រៃពេក យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលបាននូវភាពជាមនុស្ស កម្រក្រៃពេកយ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគត ជា អរហន្តសម្មាសម្ពុទ្ធ កើតក្នុងលោកកម្រក្រៃពេកយ៉ាងនោះដែរ ។ ម្នាល ភិក្ខុទាំងឡាយ ធម្មវិន័យដែលតថាគតសំដែងហើយ រមែងភ្លឺច្បាស់ក្នុង លោក កម្រក្រៃពេកយ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ការបាននូវអត្ត-ភាពជាមនុស្សនេះ ១ ព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធកើតក្នុងលោក១ ធម្មវិន័យដែលតថាគតសំដែងហើយ រមែងភ្លឺច្បាស់ក្នុងលោក១ ( ទាំង៣ នេះក្រដួបគ្នា)ៗ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនា នេះ គួរធ្វើសេចក្ដីព្យាយាមថា នេះជាទុក្ខ ។ បេ ។ គួរធ្វើសេចក្ដីព្យាយាម ថា នេះជាទុក្ខនិរោធគាមិនីបដិបទា ។

(៤៤៦) សេយ្យថាបិ ភិក្ខវេ បុរិសោ សិនេរុស្ស បព្វតរាជស្ស សត្ត មុគ្គមត្តិយោ បាសាណសក្ខរា ឧបនិក្ខិបេយ្យ ។ តំ កឹ មញ្ញថ ភិក្ខវេ កតមំ នុ ខោ ពហុតរំ យា វា សត្ត មុគ្គមត្តិយោ បាសាណសក្ខរា ឧបនិក្ខិត្តា យោ ច សិនេរុ បព្វតរាជាតិ ។ ឯតទេវ ភន្តេ ពហុតរំ យទិទំ សិនេរុ បព្វតរាជា អប្បមត្តិកា សត្ត មុគ្គមត្តិយោ បាសាណសក្ខរា ឧបនិក្ខិត្តា សង្ខម្បិ ន ឧបេន្តិ ឧបនិធម្បិ ន ឧបេន្តិ កលភាគម្បិ ន ឧបេន្តិ សិនេរុំ បព្វតរាជានំ ឧបនិធាយ សត្ត មុគ្គមត្តិយោ បាសាណសក្ខរា ឧបនិក្ខិត្តាតិ ។ ឯវមេវ ខោ ភិក្ខវេ អរិយសាវកស្ស ទិដ្ឋិសម្បន្នស្ស បុគ្គលស្ស អភិសមេតាវិនោ ឯតទេវ ពហុតរំ ទុក្ខំ យទិទំ បរិក្ខីណំ បរិយាទិន្នំ អប្បមត្តកំ អវសិដ្ឋំ សង្ខម្បិ ន ឧបេតិ ឧបនិធម្បិ ន ឧបេតិ កលភាគម្បិ ន ឧបេតិ បុរិមំ ទុក្ខក្ខន្ធំ បរិក្ខីណំ បរិយាទិន្នំ ឧបនិធាយ យទិទំ សត្តក្ខត្តុំបរមតា ។

(៤៤៦) ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសយកដុំក្រួស៧ដុំ ប៉ុនគ្រាប់សណ្ដែកបាយ ទៅប្រៀបផ្ទឹមនឹងស្ដេចភ្នំឈ្មោះសិនេរុ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់នូវហេតុនោះដូចម្ដេច ដុំក្រួស៧ដុំ ប៉ុនគ្រាប់សណ្ដែកបាយ ដែលបុគ្គលយកទៅប្រៀបផ្ទឹមក្ដី ស្ដេចភ្នំឈ្មោះសិនេរុក្ដី របស់ទាំងពីរនោះ តើរបស់ណាច្រើនជាង ។ បពិត្រព្រះអង្គដ៏ចំរើន ស្ដេចភ្នំឈ្មោះសិនេរុនេះមានចំនួនច្រើនជាង ដុំក្រួស៧ដុំ ប៉ុនគ្រាប់សណ្ដែកបាយ ដែលបុគ្គលប្រៀបធៀបហើយមានចំនួនតិចជាងដុំក្រួស ៧ ដុំ ប៉ុនគ្រាប់សណ្ដែកបាយ ដែលបុគ្គលយកទៅប្រៀបធៀបនឹងស្ដេចភ្នំសិនេរុ មិនដល់នូវការរាប់ផង មិនដល់នូវការប្រៀបធៀបផង មិនដល់នូវចំណែកនៃចំណិតផង យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអរិយសាវកដែលបរិបូណ៌ដោយទិដ្ឋិ ជាអ្នកត្រាស់ដឹង (នូវមគ្គនឹងផល) សេចក្ដីទុក្ខ (របស់អរិយសាវកនោះ) ដែលអស់ទៅរលីងទៅច្រើនជាង សេចក្ដីទុក្ខដែលសល់នៅតិចជាង មិនដល់នូវការរាប់ផង មិនដល់នូវការប្រៀបធៀបផង មិនដល់នូវចំណែកនៃចំណិតផង ដើម្បីប្រៀបធៀបនូវគំនរទុក្ខពីមុនដែលអស់ទៅរលីងទៅ ចំនួន៧អត្តភាពជាយ៉ាងយូរ ក៏យ៉ាងនោះឯង ។

យោ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ ។បេ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យថាភូតំ បជានាតិ ។ តស្មាតិហ ភិក្ខវេ ឥទំ ទុក្ខន្តិ យោគោ ករណីយោ ។បេ។ អយំ ទុក្ខនិរោធគាមិនី-បដិបទាតិ យោគោ ករណីយោតិ ។

(៤៤៧) សេយ្យថាបិ ភិក្ខវេ សិនេរុ បព្ពតរាជា បរិក្ខយំ បរិយាទានំ គច្ឆេយ្យ ឋបេត្វា សត្ត មុគ្គមត្តិយោ បាសាណសក្ខរា ។ តំ កឹ មញ្ញថ ភិក្ខវេ កតមំ នុ ខោ ពហុតរំ យំ វា សិនេរុស្ស បព្ពតរាជស្ស បរិក្ខីណំ បរិយាទិន្នំ យា ច សត្ត មុគ្គមត្តិយោ បាសាណសក្ខរា អវសិដ្ឋាតិ ។ ឯតទេវ ភន្តេ ពហុតរំ សិនេរុស្ស បព្ពតរាជស្ស យទិទំ បរិក្ខីណំ បរិយាទិន្នំ អប្បមត្តិកា សត្ត មុគ្គមត្តិយោ បាសាណសក្ខរា អវសិដ្ឋា សង្ខម្បិ ន ឧបេន្តិ ឧបនិធម្បិ ន ឧបេន្តិ កលភាគម្បិ ន ឧបេន្តិ សិនេរុស្ស បព្ពតរាជស្ស បរិក្ខីណំ បរិយាទិន្នំ ឧបនិធាយ សត្ត មុគ្គមត្តិយោ បាសាណសក្ខរា អវសិដ្ឋាតិ ។

បុគ្គលណា ដឹងច្បាស់តាមសេចក្ដីពិតថា នេះជាទុក្ខ ។ បេ ។ ដឹងច្បាស់តាមសេចក្ដីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទា ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរធ្វើសេចក្ដីព្យាយាមថា នេះជាទុក្ខ ។ បេ ។ គួរធ្វើសេចក្ដីព្យាយាមថា នេះជាទុក្ខនិរោធគាមិនីបដិបទា ។

(៤៤៧) ម្នាលភិក្ខុទាំងឡាយ ស្ដេចកំណោះសិនេរុ ក៏ដល់នូវការអស់ទៅរលីងទៅ លើកលែងតែកុំបាច់និយាយដល់ដុំក្រួស ៧ ដុំ ប៉ុនគ្រាប់សណ្ដែកបាយឡើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់នូវហេតុនោះដូចម្ដេច ការអស់ទៅរលីងទៅនៃស្ដេចភ្នំឈ្មោះសិនេរុក្ដី ដុំក្រួស ៧ ដុំ ប៉ុនគ្រាប់សណ្ដែកបាយដែលសល់នៅក្ដី របស់ទាំងពីរនោះ តើរបស់ណាច្រើនជាង ។ បពិត្រព្រះអង្គដ៏ចំរើន ការអស់ទៅរលីងទៅនៃស្ដេចភ្នំឈ្មោះសិនេរុមានចំនួនច្រើនជាង ដុំក្រួស ៧ ដុំ ប៉ុនគ្រាប់សណ្ដែកបាយដែលសល់នៅមានចំនួនតិចជាង ដុំក្រួស ៧ ដុំ ប៉ុនគ្រាប់សណ្ដែកបាយដែលសល់នៅ ក៏មិនដល់នូវការរាប់ផង មិនដល់នូវការប្រៀបធៀបផង មិនដល់នូវចំណែកនៃចំណិតផង ដោយការប្រៀបធៀបនូវការអស់ទៅរលីងទៅនៃស្ដេចភ្នំឈ្មោះសិនេរុឡើយ យ៉ាងណាមិញ ។

ឯវមេវ ខោ ភិក្ខវេ អរិយសាវកស្ស ទិដ្ឋិសម្បន្នស្ស បុគ្គលស្ស អភិសមេតាវិនោ ឯតទេវ ពហុតរំ ទុក្ខំ យទិទំ បរិក្ខីណំ បរិយាទិន្នំ អប្បមត្តកំ អវសិដ្ឋំ សង្ខម្បិ ន ឧបេតិ ឧបនិធម្បិ ន ឧបេតិ កលភាគម្បិ ន ឧបេតិ បុរិមំ ទុក្ខក្ខន្ធំ បរិក្ខីណំ បរិយាទិន្នំ ឧបនិធាយ យទិទំ សត្តក្ខត្តុំបរមតា ។ យោ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ ។បេ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យថាភូតំ បជានាតិ ។ តស្មាតិហ ភិក្ខវេ ឥទំ ទុក្ខន្តិ យោគោ ករណីយោ ។បេ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យោគោ ករណីយោតិ ។

បបាតវគ្គោ បញ្ចមោ

តស្សុទ្ទានំ

ចិន្តា បបាតោ បរិឡាហោ
កូដំ វាលន្ធការិតំ(១)
ឆិគ្គឡេន ច ទ្វេ វុត្តា
សិនេរុ អបរេ ទុវេតិ ។

១ ឱ. ម. កូដាគារន្ធការកំ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអរិយសាវកដែលបរិបូណ៌ដោយទិដ្ឋិ ជាអ្នកត្រាស់ដឹង (នូវមគ្គនិងផល) សេចក្ដីទុក្ខដែលអស់ទៅវិនាសទៅ (នៃអរិយសាវកនោះ) មានចំនួនច្រើន សេចក្ដីទុក្ខដែលសល់នៅមានចំនួនតិច មិនដល់នូវការពច់ មិនដល់នូវការប្រៀបធៀប មិនដល់នូវចំណែកនៃចំណិតនឹងគំនរទុក្ខពីមុនដែលអស់ទៅរលីងទៅចំនួន៧អត្តភាពជាយ៉ាងយូរ យ៉ាងនោះឯង ។ បុគ្គលណាដឹងច្បាស់តាមសេចក្ដីពិតថា នេះជាទុក្ខ ។បេ។ ដឹងច្បាស់តាមសេចក្ដីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទា ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរធ្វើសេចក្ដីព្យាយាមថា នេះជាទុក្ខ ។បេ។ គួរធ្វើសេចក្ដីព្យាយាមថា នេះជាទុក្ខនិរោធគាមិនីបដិបទា ។

ចប់ បបាតវគ្គ ទី ៥ ។

## ឧទ្ទាននៃបបាតវគ្គនោះគឺ

និយាយអំពីការគិត ១ អំពីជ្រោះ១ អំពីសេចក្ដីក្រហល់ក្រហាយ ១ អំពីសាលាមានកំពូល ១ អំពីទំលុះចុងសរសៃរោម ១ អំពីលោកន្តរនរកងងឹតសូន្យឈឹង ១ អំពីច្បោះនឹម ២ លើក អំពីស្ដេចភ្នំឈ្មោះសិនេរុដទៃពីរលើក ។

# អភិសមយវគ្គោ ឆដ្ឋោ

(៤៤៨) អថខោ ភគវា បរិត្តំ នខសិខាយំ បំសុំ អារោបេត្វា ភិក្ខូ អាមន្តេសិ តំ កឹ មញ្ញថ ភិក្ខវេ កតមំ នុ ខោ ពហុតរំ យោ ចាយំ មយា បរិត្តោ នខសិខាយំ បំសុ អារោបិតោ អយំ ច មហាបថវីតិ ។ ឯតទេវ ភន្តេ ពហុតរំ យទិទំ មហាបថវី អប្បមត្តកាយំ ភគវតា បរិត្តោ នខសិខាយំ បំសុ អារោបិតោ សង្ខម្បិ ន ឧបេតិ ឧបនិធម្បិ ន ឧបេតិ កលភាគម្បិ ន ឧបេតិ មហាបថវឹ ឧបនិធាយ ភគវតា បរិត្តោ នខសិខាយំ បំសុ អារោបិតោតិ ។ ឯវមេវ ខោ ភិក្ខវេ អរិយសាវកស្ស ទិដ្ឋិសម្បន្នស្ស បុគ្គលស្ស អភិសមេតាវិនោ ឯតទេវ ពហុតរំ ទុក្ខំ យទិទំ បរិក្ខីណំ បរិយាទិន្នំ អប្បមត្តកំ អវសិដ្ឋំ សង្ខម្បិ ន ឧបេតិ ឧបនិធម្បិ ន ឧបេតិ កលភាគម្បិ ន ឧបេតិ បុរិមំ ទុក្ខក្ខន្ធំ បរិក្ខីណំ បរិយាទិន្នំ ឧបនិធាយ យទិទំ សត្តក្ខត្តុំ-បរមតា ។ យោ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ ។

# អភិសមយវគ្គ ទី ៦

[៤៤៨] គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់លើកនូវអាចម៍ដីមានប្រមាណតិច ដាក់លើខ្នងព្រះនខា ហើយត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់នូវហេតុនោះដូចម្តេច អាចម៍ដីមានប្រមាណតិច ដែលតថាគតលើកដាក់លើចុងក្រចកក្តី មហាប្រឹថពីនេះក្តី របស់ទាំងពីរនោះ តើរបស់ណាច្រើនជាង ។ បពិត្រព្រះអង្គចំរើន មហាប្រឹថពីនេះច្រើនជាង អាចម៍ដីមានប្រមាណតិច ដែលព្រះមានព្រះភាគទ្រង់លើកដាក់លើខ្នងព្រះនខា មានប្រមាណតិចទេ អាចម៍ដីមានប្រមាណតិច ដែលព្រះមានព្រះភាគលើកដាក់លើចុងព្រះនខា មិនបានដល់នូវការរាប់ផង មិនបានដល់នូវការប្រៀបធៀបផង មិនបានដល់នូវចំណែកនៃចំណិតផង ដោយការប្រៀបធៀបនឹងមហាប្រឹថពីបានឡើយ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអរិយសាវកដែលបរិបូណ៌ ដោយទិដ្ឋិ ជាអ្នកត្រាស់ដឹង (នូវមគ្គនឹងផល) សេចក្តីទុក្ខរបស់អរិយសាវកនោះដែលអស់ទៅ រលីងទៅច្រើនជាង សេចក្តីទុក្ខដែលសល់នៅមានប្រមាណតិច មិនបានដល់នូវការរាប់ផង មិនបានដល់នូវការប្រៀបធៀបផង មិនបានដល់នូវចំណែកនៃចំណិតផង ដោយការប្រៀបធៀបនឹងគំនរទុក្ខពីមុនដែលអស់ទៅរលីងទៅចំនួន ៧ អត្តភាពជាយ៉ាងយូរ ក៏យ៉ាងនោះឯង ។ បុគ្គលណាដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខ ។ បេ ។

បេ ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យថាភូតំ បជានាតិ ។ តស្មាតិហ ភិក្ខវេ ឥទំ ទុក្ខន្តិ យោគោ ករណីយោ ។បេ។ អយំ ទុក្ខនិរោធគាមិនី-បដិបទាតិ យោគោ ករណីយោតិ ។

(៤៤៩) សេយ្យថាបិ ភិក្ខវេ បោក្ខរណី បញ្ញាស យោជនានិ អាយាមេន បញ្ញាស យោជនានិ វិត្ថារេន បញ្ញាស យោជនានិ ឧព្វេធេន បុណ្ណា ឧទកស្ស សមតិត្តិកា កាកបេយ្យា តតោ បុរិសោ កុសគ្គេន ឧទកំ ឧទ្ធរេយ្យ ។ តំ កឹ មញ្ញថ ភិក្ខវេ កតមំ នុ ខោ ពហុតរំ យំ វា កុសគ្គេន(១) ឧព្ភតំ យំ វា បោក្ខរណិយា ឧទកន្តិ ។ ឯតទេវ ភន្តេ ពហុតរំ យទិទំ បោក្ខរណិយា ឧទកំ អប្ប-មត្តកំ កុសគ្គេន ឧទកំ ឧព្ភតំ សង្ខម្បិ ន ឧបេតិ ឧបនិធម្បិ ន ឧបេតិ កលភាគម្បិ ន ឧបេតិ បោក្ខរណិយា ឧទកំ ឧបនិធាយ កុសគ្គេន ឧទកំ ឧព្ភតន្តិ ។ ឯវមេវ ខោ ភិក្ខវេ អរិយសាវកស្ស ។បេ។ យោគោ ករណីយោតិ ។

---

១ ឱ. យំ វា កុសគ្គេន ឧទកំ ។

ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទា ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរធ្វើសេចក្តីព្យាយាមថា នេះជាទុក្ខ ។ បេ ។ គួរធ្វើសេចក្តីព្យាយាមថា នេះជាទុក្ខនិរោធ-គាមិនីបដិបទា ។

[៤៤៩] ម្នាលភិក្ខុទាំងឡាយ ដូចស្រះបោក្ខរណី បណ្តោយ ៥០ យោជន៍ ទទឹង ៥០ យោជន៍ ជំរៅ ៥០ យោជន៍ មានទឹកពេញស្មើល្មម ក្អែកទុំផឹកបាន បុរសគប្បីជ្រលក់ទឹកដោយចុងនៃស្បូវអំពីស្រះនោះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់នូវហេតុនោះដូចម្តេច ទឹកដែលបុរសជ្រលក់ ដោយចុងនៃស្បូវ ហើយលើកឡើងនឹងទឹកក្នុងស្រះបោក្ខរណី ទឹកទាំងពីរនោះ តើទឹកណាច្រើនជាង ។ បពិត្រព្រះអង្គដ៏ចំរើន ទឹកក្នុងស្រះបោក្ខរណីនុ៎ះច្រើនជាង ទឹកដែលបុរសជ្រលក់ដោយចុងនៃស្បូវហើយលើកឡើង មានប្រមាណតិច ទឹកដែលបុរសជ្រលក់ដោយចុងនៃស្បូវហើយលើកឡើង មិនបានដល់នូវការរាប់ផង មិនបានដល់នូវការប្រៀបធៀបផង មិនដល់នូវចំណែកនៃចំណិតផង ដោយការប្រៀបផ្ទឹមនឹងទឹកក្នុងស្រះបោក្ខរណីបានឡើយ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអរិយសាវក ។ បេ ។ ភិក្ខុគួរធ្វើសេចក្តីព្យាយាម ។

[៤៩០] សេយ្យថាបិ ភិក្ខវេ យត្ថិមា មហានទិយោ សំសន្ទន្តិ សមេន្តិ ។ សេយ្យថីទំ ។ គង្គា យមុនា អចិរវតី សរភូ មហី ។ តតោ បុរិសោ ទ្វេ វា តីណិ វា ឧទកផុសិតានិ ឧទ្ធរេយ្យ ។ តំ កឹ មញ្ញថ ភិក្ខវេ កតមំ នុ ខោ ពហុតរំ យានិ វា ទ្វេ វា តីណិ វា ឧទកផុសិតានិ ឧព្ភតានិ យំ វា សម្ភេជ្ជំ ឧទកន្តិ ។ ឯតទេវ ភន្តេ ពហុតរំ យទិទំ សម្ភេជ្ជំ ឧទកំ អប្បមត្តកានិ ទ្វេ វា តីណិ វា ឧទកផុសិតានិ ឧព្ភតានិ សង្ខម្បិ ន ឧបេន្តិ ឧបនិធម្បិ ន ឧបេន្តិ កលភាគម្បិ ន ឧបេន្តិ សម្ភេជ្ជំ ឧទកំ ឧបនិធាយ ទ្វេ វា តីណិ វា ឧទកផុសិតានិ ឧព្ភតានីតិ ។ ឯវមេវ ខោ ភិក្ខវេ អរិយសាវកស្ស (សោឡស បេយ្យាលោ) យោគោ ករណីយោតិ ។

[៤៩១] សេយ្យថាបិ ភិក្ខវេ យត្ថិមា មហានទិយោ សំសន្ទន្តិ សមេន្តិ ។ សេយ្យថីទំ ។ គង្គា យមុនា អចិរវតី សរភូ មហី ។ តំ ឧទកំ បរិក្ខយំ

## អភិសមយវគ្គ ទី ៦

[៤៩០] ម្នាលភិក្ខុទាំងឡាយ ដូចស្ទឹងធំទាំងឡាយនេះ រមែងហូរជោរជន់ ៗ ស្ទឹងធំទាំងនោះគឺស្ទឹងណាខ្លះ ៗ គឺស្ទឹងគង្គា យមុនា អចិ-រវតី សរភូ មហី ៗ បុរសគប្បីលើកឡើងនូវដំណក់នៃទឹកពីរឬបីដំណក់ អំពីស្ទឹងទាំងនោះ ៗ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់នូវហេតុនោះដូចម្តេច ដំណក់នៃទឹកពីរឬបីដំណក់ដែលបុរសលើកឡើងនឹងទឹកដែលលាយច្រឡំអំពីទឹកដទៃហូរជោរជន់មក ទឹកទាំងពីរនោះតើ ទឹកណាច្រើនជាង ៗ បពិត្រព្រះអង្គដ៏ចំរើន ទឹកដែលលាយច្រឡំអំពីស្ទឹងដទៃហូរជោរជន់មកនុ៎ះច្រើនជាង ដំណក់នៃទឹកពីរឬបីដំណក់ដែលបុរសលើកឡើង មានប្រមាណតិចទេ ដំណក់នៃទឹកពីរឬបីដំណក់ដែលបុរសលើកឡើង មិនបានដល់នូវការរាប់ផង មិនបានដល់នូវការប្រៀបធៀបផង មិនបានដល់នូវចំណែកនៃចំណិតផង ដោយការប្រៀបធៀបនឹងទឹកដែលលាយច្រឡំអំពីស្ទឹងដទៃហូរជោរជន់មកបានឡើយ យ៉ាងណាមិញ ៗ ម្នាលភិក្ខុទាំងឡាយ អរិយសាវក (នោះឯងជាបេយ្យាលៈ) ភិក្ខុគប្បីធ្វើសេចក្តីព្យាយាម ៗ

[៤៩១] ម្នាលភិក្ខុទាំងឡាយ ដូចស្ទឹងធំទាំងឡាយនេះ រមែងហូរជោរជន់មក ៗ ស្ទឹងធំទាំងនោះគឺស្ទឹងណាខ្លះ ៗ គឺស្ទឹងគង្គា យមុនា អចិរវតី សរភូ មហី ៗ ទឹកនោះក៏គង់ដល់នូវការអស់ទៅរលីងទៅ

បរិយាទានំ គច្ឆេយ្យ ឋបេត្វា ទ្វេ វា តីណិ វា ឧទកផុសិតានិ ។ តំ កឹ មញ្ញថ ភិក្ខវេ កតមំ នុ ខោ ពហុតរំ ។ យំ វា សមុទ្ទេ ឧទកំ បរិក្ខីណំ បរិយាទិន្នំ ឧបនិធាយ ទ្វេ វា តីណិ វា ឧទកផុសិតានិ អវសិដ្ឋានីតិ ។ ឯតទេវ ភន្តេ ពហុតរំ សមុទ្ទេ ឧទកំ យទិទំ បរិក្ខីណំ បរិយាទិន្នំ អប្បមត្តកានិ ទ្វេ វា តីណិ វា ឧទកផុសិតានិ អវសិដ្ឋានិ សង្ខម្បិ ន ឧបេន្តិ ឧបនិធម្បិ ន ឧបេន្តិ កលភាគម្បិ ន ឧបេន្តិ សមុទ្ទេ ឧទកំ បរិក្ខីណំ បរិយាទិន្នំ ឧបនិធាយ ទ្វេ វា តីណិ វា ឧទកផុសិតានិ អវសិដ្ឋានីតិ ។ ឯវមេវ ខោ ភិក្ខវេ អរិយសាវកស្ស ។បេ។ យោគោ ករណីយោតិ ។

[៦៥៦] សេយ្យថាបិ ភិក្ខវេ បុរិសោ មហាបឋវិយា សត្ត កោលដ្ឋិមត្តិយោ គុឡិកា ឧបនិក្ខិបេយ្យ ។ តំ កឹ មញ្ញថ ភិក្ខវេ កតមំ នុ ខោ ពហុតរំ យា វា សត្ត កោលដ្ឋិមត្តិយោ គុឡិកា ឧបនិក្ខិត្តា អយំ វា មហាបឋវីតិ ។

លើកលែងតែដំណក់ទឹកពីរឬបីចេញ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំង-ឡាយសំគាល់នូវហេតុនោះដូចម្តេច ទឹកដែលលាយច្រឡំគ្នានឹង ដំណក់នៃទឹកពីរ ឬ បីដំណក់ ដោយការប្រៀបធៀបនឹងទឹក ដែលអស់ទៅរលីងទៅ ទឹកទាំងពីរនោះ តើទឹកណាច្រើនជាង ។ បពិត្រព្រះអង្គដ៏ចំរើន ទឹកដែលលាយច្រឡំគ្នា ដែលអស់ទៅរលីងទៅនុ៎ះច្រើនជាង ដំណក់ទឹកពីរឬបីដំណក់ ដែលសល់នៅមានប្រមាណតិច ដំណក់ទឹកពីរឬបីដំណក់ដែលសល់នៅ មិនបានដល់នូវការរាប់ផង មិនបានដល់នូវការប្រៀបធៀបផង មិនដល់នូវចំណែកនៃចំណិតផង ដោយការប្រៀបធៀបនឹងទឹកដែលលាយច្រឡំគ្នាដែលអស់ទៅរលីងទៅបានឡើយ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវក ។ បេ ។ ភិក្ខុគួរធ្វើសេចក្តីព្យាយាម ។

[៤៩២] ម្នាលភិក្ខុទាំងឡាយ ដូចបុរសដំកល់ទុកនូវដីស្អិត ៧ ដុំ មានចំនួនប៉ុនផ្លែពុទ្រា ដើម្បីប្រៀបផ្ទឹមនឹងមហា-ប្រឹថពី ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់នូវហេតុនោះដូចម្តេច ដីស្អិត ៧ ដុំ មានចំនួនប៉ុនផ្លែពុទ្រាដែលបុរសដំកល់ទុកនឹងមហាប្រឹថពីនេះ របស់ទាំងពីរនោះ តើរបស់ណាច្រើនជាង ។

ឯតទេវ ភន្តេ ពហុតរំ យទិទំ មហាបថវី អប្បមត្តិកា សត្ត កោលដ្ឋិមត្តិយោ គុឡិកា ឧបនិក្ខិត្តា សង្ខម្បិ ន ឧបេន្តិ ឧបនិធម្បិ ន ឧបេន្តិ កលភាគម្បិ ន ឧបេន្តិ មហាបថវឹ ឧបនិធាយ សត្ត កោលដ្ឋិមត្តិយោ គុឡិកា ឧបនិក្ខិត្តាតិ ។ ឯវមេវ ខោ ភិក្ខវេ អរិយសាវកស្ស (សោយេវ បេយ្យាលោ) យោគោ ករណីយោតិ ។

(៤៥៣) សេយ្យថាបិ ភិក្ខវេ មហាបថវី បរិក្ខយំ បរិយាទានំ គច្ឆេយ្យ ឋបេត្វា សត្ត កោលដ្ឋិមត្តិយោ គុឡិកា ។ តំ កឹ មញ្ញថ ភិក្ខវេ កតមំ នុ ខោ ពហុតរំ យំ វា មហាបថវិយា បរិក្ខីណំ បរិយាទិន្នំ យា វា សត្ត កោលដ្ឋិមត្តិយោ គុឡិកា អវសិដ្ឋាតិ ។ ឯតទេវ ភន្តេ ពហុតរំ មហាបថវិយា យទិទំ បរិក្ខីណំ បរិយាទិន្នំ អប្បមត្តិកា សត្ត កោលដ្ឋិមត្តិយោ គុឡិកា អវសិដ្ឋា សង្ខម្បិ ន ឧបេន្តិ ឧបនិធម្បិ ន ឧបេន្តិ កលភាគម្បិ ន ឧបេន្តិ មហាបថវិយា បរិក្ខីណំ

បពិត្រព្រះអង្គដ៏ចំរើន មហាប្រឹថពីនុ៎ះច្រើនជាង ដីស្អិត ៧ដុំ មានចំនួនប៉ុនផ្លែពុទ្រាដែលបុរសដំកល់ទុកមានប្រមាណតិច ដីស្អិត ៧ដុំ មានចំនួនប៉ុនផ្លែពុទ្រាដែលបុរសដំកល់ទុក មិនបានដល់នូវការរាប់ផង មិនបានដល់នូវការប្រៀបធៀបផង មិនបានដល់នូវចំណែកនៃចំណិតផង ដោយការប្រៀបធៀបនឹងមហាប្រឹថពីបានឡើយ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវក (នោះឯងជាបេយ្យាល:) ភិក្ខុគួរធ្វើសេចក្ដីព្យាយាម ។

(៤៩៣) ម្នាលភិក្ខុទាំងឡាយ ដូចមហាប្រឹថពីដល់នូវការអស់ទៅរលីងទៅ លើកលែងតែដីស្អិត៧ដុំមានចំនួនប៉ុនផ្លែពុទ្រាចេញ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សំគាល់នូវហេតុនោះដូចម្ដេច ការអស់ទៅរលីងទៅនៃមហាប្រឹថពីនឹងដីស្អិត៧ដុំមានចំនួនប៉ុនផ្លែពុទ្រាដែលសល់នៅតើរបស់ណាច្រើនជាង ។ បពិត្រព្រះអង្គដ៏ចំរើន ការអស់ទៅរលីងទៅ នៃមហាប្រឹថពីនុ៎ះ មានប្រមាណច្រើនជាង ដីស្អិត៧ដុំ មានចំនួនប៉ុនផ្លែពុទ្រាដែលសល់នៅមានប្រមាណតិច ដីស្អិត៧ដុំ មានចំនួនប៉ុនផ្លែពុទ្រា ដែលសល់នៅ មិនបានដល់នូវការរាប់ផង មិនបានដល់នូវការប្រៀបធៀបផង មិនបានដល់នូវចំណែកនៃចំណិតផង ដោយការប្រៀបធៀប នឹងការអស់

បរិយាទិន្នំ ឧបនិធាយ សត្ត កោលដ្ឋិមត្តិយោ គុឡិកា អវសិដ្ឋាតិ ។ ឯវមេវ ខោ ភិក្ខវេ អរិយសាវកស្ស (សោយេវ បេយ្យាលោ) យោគោ ករណីយោតិ ។

[៤៨] សេយ្យថាបិ ភិក្ខវេ បុរិសោ មហាសមុទ្ទេ ទ្វេ វា តីណិ វា ឧទកផុសិតានិ ឧទ្ធរេយ្យ ។ តំ កឹ មញ្ញថ ភិក្ខវេ កតមំ នុ ខោ ពហុតរំ យានិ វា ទ្វេ វា តីណិ វា ឧទកផុសិតានិ ឧព្ភតានិ យំ វា មហាសមុទ្ទេ ឧទកន្តិ ។ ឯតទេវ ភន្តេ ពហុតរំ យទិទំ មហាសមុទ្ទេ ឧទកំ អប្បមត្តកានិ ទ្វេ វា តីណិ វា ឧទកផុសិតានិ ឧព្ភតានិ សង្ខម្បិ ន ឧបេន្តិ ឧបនិធម្បិ ន ឧបេន្តិ កលភាគម្បិ ន ឧបេន្តិ មហាសមុទ្ទេ ឧទកំ ឧបនិធាយ ទ្វេ វា តីណិ វា ឧទកផុសិតានិ ឧព្ភតានីតិ ។ ឯវមេវ ខោ ភិក្ខវេ អរិយសាវកស្ស (សោយេវ បេយ្យាលោ) យោគោ ករណីយោតិ ។

[៤៩] សេយ្យថាបិ ភិក្ខវេ មហាសមុទ្ទោ(១) បរិក្ខយំ បរិយាទានំ គច្ឆេយ្យ ឋបេត្វា ទ្វេ វា តីណិ វា ឧទកផុសិតានិ ។ តំ កឹ មញ្ញថ ភិក្ខវេ

---

១ ឱ.ម. មហាសមុទ្ទេ ឧទកំ ។

ទៅ រលីងទៅ នៃមហាប្រឹថពីបានឡើយ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវក (នោះឯងជាបេយ្យាលៈ) ភិក្ខុគួរធ្វើសេចក្ដីព្យាយាម ។

(៤៩៤) ម្នាលភិក្ខុទាំងឡាយ ដូចបុរសលើកឡើងនូវដំណក់ទឹកពីរឬបីដំណក់ក្នុងមហាសមុទ្រ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់នូវហេតុនោះដូចម្តេច ដំណក់ទឹកពីរឬបីដំណក់ដែលបុគ្គលលើកឡើងនឹង ទឹកក្នុងមហាសមុទ្រ ទឹកទាំងពីរនោះ តើទឹកណាច្រើនជាង ។ បពិត្រព្រះអង្គដ៏ចំរើន ទឹកក្នុងមហាសមុទ្រនុ៎ះមានប្រមាណច្រើនជាង ដំណក់ទឹកពីរឬបីដំណក់ ដែលបុរសលើកឡើងមានប្រមាណតិច ដំណក់ទឹកពីរឬបីដំណក់ដែលបុរសលើកឡើងមិនបានដល់នូវការរាប់ផង មិនបានដល់នូវការប្រៀបធៀបផង មិនបានដល់នូវចំណែកនៃចំណិតផង ដោយការប្រៀបធៀបនឹងទឹកក្នុងមហាសមុទ្របានឡើយ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវក (នោះឯងជាបេយ្យាលៈ) ភិក្ខុគួរធ្វើសេចក្ដីព្យាយាម ។

(៤៩៥) ម្នាលភិក្ខុទាំងឡាយ ដូចទឹកក្នុងមហាសមុទ្រ ដល់នូវការអស់ទៅ រលីងទៅ លើកលែងតែដំណក់ទឹកពីរឬបីដំណក់ចេញ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សំគាល់នូវហេតុនុ៎ះ ដូចម្តេច

កតមំ នុ ខោ ពហុតរំ យំ វា មហាសមុទ្ទេ ឧទកំ បរិក្ខីណំ បរិយាទិន្នំ យានិ វា ទ្វេ វា តីណិ វា ឧទកផុសិតានិ អវសិដ្ឋានីតិ ។ ឯតទេវ ភន្តេ ពហុតរំ មហាសមុទ្ទេ ឧទកំ(១) បរិក្ខីណំ បរិយាទិន្នំ អប្បមត្តកានិ ទ្វេ វា តីណិ វា ឧទកផុសិតានិ អវសិដ្ឋានិ សង្ខម្បិ ន ឧបេន្តិ ឧបនិធម្បិ ន ឧបេន្តិ កលភាគម្បិ ន ឧបេន្តិ មហាសមុទ្ទេ ឧទកំ បរិក្ខីណំ បរិយាទិន្នំ ឧបនិធាយ ទ្វេ វា តីណិ វា ឧទកផុសិតានិ អវសិដ្ឋានីតិ ។ ឯវមេវ ខោ ភិក្ខវេ អរិយសាវកស្ស (សោយេវ បេយ្យាលោ) យោគោ ករណីយោតិ ។

(៤៨៦) សេយ្យថាបិ ភិក្ខវេ បុរិសោ ហិមវតោ បព្វតរាជស្ស សត្ត សាសបមត្តិយោ បាសាណសក្ខរា ឧបនិក្ខិបេយ្យ ។ តំ កឹ មញ្ញថ ភិក្ខវេ កតមំ នុ ខោ ពហុតរំ យា វា សត្ត សាសបមត្តិយោ បាសាណសក្ខរា ឧបនិក្ខិត្តា អយំ វា ហិមវា បព្វតរាជាតិ ។

---

១ ឱ.ម. ឧទកំ យទិទំ ។

ទឹកក្នុងមហាសមុទ្រដែលអស់ទៅ រលីងទៅនឹងដំណក់ទឹកពីរឬបីដំណក់ដែលសល់នៅ ទឹកទាំងពីរនោះ តើទឹកណាច្រើនជាង ។ បពិត្រព្រះអង្គដ៏ចំរើន ទឹកក្នុងមហាសមុទ្រដែលអស់ទៅ រលីងទៅនុ៎ះមានប្រមាណច្រើនជាង ដំណក់ទឹកពីរឬបីដំណក់ដែលសល់នៅ មានប្រមាណតិច ដំណក់ទឹកពីរឬបីដំណក់ដែលសល់នៅ មិនបានដល់នូវការរាប់ផង មិនបានដល់នូវការប្រៀបធៀបផង ទាំងមិនបានដល់នូវចំណែកនៃចំណិតផង ដោយការប្រៀបធៀបនឹងទឹកក្នុងមហាសមុទ្រ ដែលអស់ទៅ រលីងទៅបានឡើយ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវក (នោះឯងជាបេយ្យាលៈ) ភិក្ខុគួរធ្វើសេចក្តីព្យាយាម ។

[៤៩៦] ម្នាលភិក្ខុទាំងឡាយ ដូចបុរសដាក់ទុកនូវដុំក្រួស ៧ ដុំ មានប្រមាណប៉ុនគ្រាប់ស្ពៃ (ដើម្បីប្រៀបធៀប) នឹងស្តេចភ្នំឈ្មោះហិមវន្ត ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សំគាល់នូវហេតុនោះដូចម្តេច ដុំក្រួស ៧ ដុំ មានប្រមាណប៉ុនគ្រាប់ស្ពៃ ដែលបុរសដាក់ទុកនឹងស្តេចភ្នំឈ្មោះហិមវន្ត របស់ទាំងពីរនោះ តើរបស់ណាច្រើនជាង ។

ឯតទេវ ភន្តេ ពហុតរំ យទិទំ ហិមវា បព្វតរាជា អប្បមត្តិកា សត្ត សាសបមត្តិយោ បាសាណសក្ខរា ឧបនិក្ខិត្តា សង្ខ្យម្បិ ន ឧបេន្តិ ឧបនិធម្បិ ន ឧបេន្តិ កលភាគម្បិ ន ឧបេន្តិ ហិមវន្តំ បព្វតរា-ជានំ ឧបនិធាយ សត្ត សាសបមត្តិយោ បាសាណ-សក្ខរា ឧបនិក្ខិត្តាតិ ។ ឯវមេវ ខោ ភិក្ខវេ អរិយ-សាវកស្ស ។ បេ ។ យោគោ ករណីយោតិ ។

(៤៩៧) សេយ្យថាបិ ភិក្ខវេ ហិមវា បព្វតរាជា បរិក្ខយំ បរិយាទានំ គច្ឆេយ្យ ឋបេត្វា សត្ត សាសបមត្តិយោ បាសាណសក្ខរា ។ តំ កឹ មញ្ញថ ភិក្ខវេ កតមំ នុ ខោ ពហុតរំ យំ វា ហិមវតោ បព្វតរាជស្ស បរិក្ខីណំ បរិយាទិន្នំ យា វា សត្ត សាសបមត្តិយោ បាសាណសក្ខរា អវសិដ្ឋាតិ ។ ឯតទេវ ភន្តេ ពហុតរំ ហិមវតោ បព្វតរាជស្ស យទិទំ បរិក្ខីណំ បរិយាទិន្នំ អប្បមត្តិកា សត្ត សាសប-មត្តិយោ បាសាណសក្ខរា អវសិដ្ឋា សង្ខ្យម្បិ ន ឧបេន្តិ

បពិត្រព្រះអង្គដ៏ចំរើន ស្ដេចភ្នំឈ្មោះហិមវន្តនុ៎ះ មានប្រមាណច្រើនជាងដុំក្រួស៧ដុំ មានប្រមាណប៉ុនគ្រាប់ស្ពៃដែលបុរសដំកល់ទុកមានប្រមាណតិច ដុំក្រួស៧ដុំ មានប្រមាណប៉ុនគ្រាប់ស្ពៃដែលបុរសដំកល់ទុក មិនបានដល់ការរាប់ផង មិនបានដល់នូវការប្រៀបធៀបផង មិនបានដល់នូវចំណែកនៃចំណិតផង ដោយការប្រៀបធៀបនឹងស្ដេចភ្នំឈ្មោះហិមវន្តបានឡើយយ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវក ។ បេ ។ ភិក្ខុគួរធ្វើសេចក្ដីព្យាយាម ។

(៤៩៧) ម្នាលភិក្ខុទាំងឡាយ ដូចជាស្ដេចភ្នំឈ្មោះហិមវន្ត ដល់នូវការអស់ទៅ រលីងទៅ លើកលែងតែក្រួស៧ដុំ មានប្រមាណប៉ុនគ្រាប់ស្ពៃចេញ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សំគាល់នូវហេតុនោះដូចម្ដេច ការអស់ទៅរលីងទៅនៃស្ដេចភ្នំឈ្មោះហិមវន្តនឹងដុំក្រួស ៧ ដុំ មានប្រមាណប៉ុនគ្រាប់ស្ពៃដែលសល់នៅ របស់ទាំងពីរនោះ តើរបស់ណាច្រើនជាង ។ បពិត្រព្រះអង្គដ៏ចំរើន ការអស់ទៅ រលីងទៅនៃស្ដេចភ្នំឈ្មោះហិមវន្តនុ៎ះឯង មានប្រមាណច្រើនជាង ដុំក្រួស ៧ ដុំ មានប្រមាណប៉ុនគ្រាប់ស្ពៃដែលសល់នៅ មិនបានដល់នូវការរាប់ផង

ឧបនិធម្បិ ន ឧបេន្តិ កលភាគម្បិ ន ឧបេន្តិ ហិមវតោ បព្វតរាជស្ស បរិក្ខីណំ បរិយាទិន្នំ ឧបនិធាយ សត្ត សាសបមត្តិយោ បាសាណសក្ខរា អវសិដ្ឋាតិ ។ ឯវមេវ ខោ ភិក្ខវេ អរិយសាវកស្ស ទិដ្ឋិសម្បន្នស្ស បុគ្គលស្ស អភិសមេតាវិនោ ឯតទេវ ពហុតរំ ទុក្ខំ យទិទំ បរិក្ខីណំ បរិយាទិន្នំ អប្បមត្តកំ អវសិដ្ឋំ សង្ខម្បិ ន ឧបេតិ ឧបនិធម្បិ ន ឧបេតិ កលភាគម្បិ ន ឧបេតិ បុរិមំ ទុក្ខក្ខន្ធំ បរិក្ខីណំ បរិយាទិន្នំ ឧបនិធាយ យទិទំ សត្តក្ខត្តុំបរមតា ។ យោ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ ។ បេ ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យថាភូតំ បជានាតិ ។ តស្មាតិហ ភិក្ខវេ ឥទំ ទុក្ខន្តិ យោគោ ករណីយោ ។ បេ ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យោគោ ករណីយោតិ ។

អភិសមយវគ្គោ ឆដ្ឋោ

